# ម៉ាក្រូសេដ្ឋកិច្ច



បណ្ឌិត ហង់ ជួន ណារ៉ុន

២០០៩

បោះពុម្ព ដោយមានការឧបត្ថម្ភគាំទ្រពីសំណាក់

**ធនាគារអភិវឌ្ឍន៍អាស៊ី**

រូបនៅលើទំព័រទី១ គឺ រូបចម្លាក់ «**ព្រះវរុណ**» ឬ «**ព្រះតិរុណ**» ដែលជាព្រះអាទិទេពម្ចាស់ទឹក និង ម្ចាស់សមុទ្រ ។ (ថតដោយ **ហង់ ជួន ណារ៉ុន**) ។

# ម៉ាក្រូសេដ្ឋកិច្ច

បណ្ឌិត ហង់ ជួន ណារ៉ុន

ភ្នំពេញ

២០០៩

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនទៅដល់បុព្វការីជន **កម្ពុជា** ទាំងអស់

ដែលខិតខំបូជាញើសឈាម ដោយមិនខ្លាចនឿយហត់

ដើម្បីកិច្ចអភិវឌ្ឍន៍ និង វិបុលភាព

នៃមាតុភូមិ **កម្ពុជា** យើង

ជាពិសេស

ដល់

វៀមច្បងនៃ

**កងកម្លាំងប្រដាប់អាវុធ**

ដែលបានពលីជីវិតដើម្បីការពារជាតិមាតុភូមិ

ក្នុងគោលដៅថែរក្សាវប្បធម៌ និង អារ្យធម៌ខ្មែរអោយបានគង់វង់

ទុកដល់កូនចៅ **កម្ពុជា** ជំនាន់ក្រោយ

**បោះពុម្ពលើកទី ១**

**ឆ្នាំ ២០០៩**

# មាតិកា

## ផ្នែកទី១

## ទស្សនទានស្តីពីម៉ាក្រូសេដ្ឋកិច្ច

**ជំពូកទី១ - បុព្វកថាស្តីពីម៉ាក្រូសេដ្ឋកិច្ច** **១**

១- ប្រព័ន្ធគណនីជាតិ ១

២- ផលិតផលសរុបក្នុងស្រុក ៤

៣- ផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារ និង តាមថ្លៃថេរ ៧

៤- សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ៩

៥- ទំនាក់ទំនងរវាងតុល្យភាពក្រៅស្រុក និង គម្លាតធនធានក្នុងស្រុក ១០

## ផ្នែកទី២

## ឧបករណ៍វិភាគម៉ាក្រូសេដ្ឋកិច្ច

**ជំពូកទី២ - កំណើនសេដ្ឋកិច្ច** **១៣**

១- អនុគមន៍ផលិតកម្មក្នុងគំរូបូរាណនិយម ១៣

២- ប្រភពនៃកំណើនសេដ្ឋកិច្ច ១៤

៣- អនុគមន៍ផលិតកម្ម **ខប់ - ដូក្លាស** ១៥

៤- គំរូកំណើន **សូឡូ** ១៦

**ជំពូកទី៣ - រូបិយវត្ថុ និង អតិផរណា** ១៩

១- ទ្រឹស្តីរូបិយវត្ថុបែបបូរាណនិយម ១៩

២- វិធីសាស្ត្រ **ខេមប្រ៊ីជ** ស្តីពីបរិមាណរូបិយវត្ថុ ២១

៣- អត្រាការប្រាក់ ២៣

៤- ទ្រឹស្តីកេនស៍និយម ២៦

៥- គំរូរូបិយវត្ថុនិយម ៣០

៦- អតិផរណា និង វិធានការគោលនយោបាយឆ្លើយតប ៣៦

**ជំពូកទី៤ - ការវិភាគរូបិយវត្ថុ** ៤៥

១- តួនាទីរបស់ធនាគារកណ្តាល ៤៥

២- ធនាគារពាណិជ្ជ ៤៨

៣- ការអង្កេតរូបិយវត្ថុ និង ការវិភាគរូបិយវត្ថុ ៤៩

## ផ្នែកទី៣

## គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

**ជំពូកទី៥ - កេនស៍ និង ការវិភាគម៉ាក្រូសេដ្ឋកិច្ច** ៥២

១- សេចក្តីផ្តើម ៥២

២- លក្ខខណ្ឌនៃធាតុចេញសមតា ៥៣

**ជំពូកទី៦ - ទីផ្សាររូបិយវត្ថុ: ខ្សែកោង LM** ៧០

១- ប្រព័ន្ធកេនស៍និយមៈ រូបិយវត្ថុ ការប្រាក់ និង ប្រាក់ចំណូល ៧០

២- ផលប៉ះពាល់នៃការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ ៧៦

៣- សមតានៃទីផ្សាររូបិយវត្ថុៈ ខ្សែកោង **LM** ៧៨

**ជំពូកទី៧ - ទីផ្សារផលិតផល: ខ្សែកោង IS** ៨៦

១- សមតានៃទីផ្សារផលិតផលៈ ខ្សែកោង **IS** ៨៦

២- ចំណុចសមតាៈ បង្គំនៃខ្សែបន្ទាត់ **IS** និង **LM** ៩២

**ជំពូកទី៨ - ការផ្គត់ផ្គង់សរុប និង តម្រូវការសរុប** ៩៤

១- ប្រព័ន្ធទ្រឹស្តីកេនស៍ ៩៤

២- ខ្សែកោងផ្គត់ផ្គង់សរុបតាមទ្រឹស្តីកេនស៍ ៩៩

៣- កេនស៍និយម និង បូរាណនិយម ១១០

**ជំពូកទី៩ - គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចតាមបែបបុរាណនិយម** ១១៣

១- គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ១១៣

២- គោលនយោបាយរូបិយវត្ថុ ១១៧

**ជំពូកទី១០ - គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរូបិយវត្ថុនិយម** **១២០**

១- ទ្រឹស្តីរូបិយវត្ថុនិយម និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ១២០

២- ទ្រឹស្តីរូបិយវត្ថុនិយម និង គោលនយោបាយរូបិយវត្ថុ ១២១

**ជំពូកទី១១ - ការរំពឹងទុក** **១២៣**

១- ការពិនិត្យឡើងវិញនូវទ្រឹស្តីកេនស៍ ១២៣

២- ទស្សនទាននៃការរំពឹងទុកដោយវិចារណញ្ញាណ ១២៤

៣- ផលវិបាកខាងផ្នែកគោលនយោបាយនៃការរំពឹងទុកប្រកបដោយវិចារណញ្ញាណ ១២៧

៤- ឧបករណ៍វិភាគការរំពឹងទុក ១៣២

៥. ការអនុវត្តទ្រឹស្តីនៃការរំពឹងទុកចំពោះទីផ្សារហិរញ្ញវត្ថុ ១៣៤

**ជំពូកទី១២ - ជញ្ជីងទូទាត់** **១៣៧**

១- ទស្សនទានទូទៅ ១៣៧

២- សមាសធាតុនៃជញ្ជីងទូទាត់ ១៣៨

៣- ទំនាក់ទំនងជាមូលដ្ឋានរវាងតុល្យភាពសញ្ជ័យ-វិនិយោគ និង គណនីចរន្តខាងក្រៅ ១៤៣

**ជំពូកទី១៣ - អត្រាប្តូរប្រាក់** **១៤៧**

១- អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ និង អត្រាប្តូរប្រាក់ពិត ១៤៧

២- អត្រាប្តូរប្រាក់ពិត និង តុល្យភាពពាណិជ្ជកម្ម ១៤៨

៣- កត្តាកំណត់អត្រាប្តូរប្រាក់ពិត ១៤៩

៤- គោលនយោបាយសេដ្ឋកិច្ច និង អត្រាប្តូរប្រាក់ពិត ១៤៩

៥- ឥទ្ធិពលនៃគោលនយោបាយពាណិជ្ជកម្ម ១៥២

៦- ការកំណត់អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ ១៥៣

៧. សមមូលនៃអនុភាពទិញ

**ជំពូកទី១៤ - វិបត្តិសេដ្ឋកិច្ច ១៥៥**

២- មូលហេតុនៃវិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ១៥៥

៣-វិបត្តិបំណុលនៅម៉ិកស៊ិក ១៥៩

៤-វិបត្តិហិរញ្ញវត្ថុនៅអាស៊ី ឆ្នាំ ១៩៩៧-១៩៩៨ ១៦១

៥-វិបត្តិហិរញ្ញវត្ថុពិភពលោក ឆ្នាំ ២០០៨ ១៦៣

## ផ្នែកទី៤

## ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា

**ជំពូកទី១៥ - ដុល្លារូបនីយកម្ម និង គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ១៦៦**

១- ដុល្លារូបនីយកម្មនៅកម្ពុជា ១៦៦

២- ដុល្លារូបនីយកម្ម និង គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ១៦៨

**ជំពូកទី១៦ - ការគ្រប់គ្រងរូបិយវត្ថុ ១៧៣**

១- គោលដៅនៃគោលនយោបាយរូបិយវត្ថុ ១៧៣

២- ការកំណត់គោលដៅ ១៧៤

៣- ឧបករណ៍គោលនយោបាយរូបិយវត្ថុ ១៨០

៤- គោលនយោបាយរូបិយវត្ថុនៅក្នុងប្រទេសកម្ពុជា ១៨៨

៥- កំណែទម្រង់ស្ថាប័នដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ២០០

៦- អតិផរណា: បុព្វហេតុ និង ជំរើសម្រាប់ការគ្រប់គ្រងអតិផរណានៅកម្ពុជា ២០១

**ជំពូកទី១៧ - ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** **២៣៨**

១- សេចក្តីផ្តើម ២៣៨

២- គោលនយោបាយហិរញ្ញវត្ថុសាធារណៈ: ក្របខ័ណ្ឌទស្សនទាន ២៣៩

៣- គោលដៅនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ២៤១

៤- ផលប៉ះពាល់សេដ្ឋកិច្ចនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ២៤១

៥- ឧបករណ៍គោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ២៥២

៦- ផលប៉ះពាល់ម៉ាក្រូសេដ្ឋកិច្ចនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម និង វិនិយោគ ២៦៤

៧- ការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ២៧១

**ឯកសារស្រាវជ្រាវ**

**អ្នកនិពន្ធ**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ការពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានក្លាយជាប្រធានបទមួយយ៉ាងសំខាន់ នៅពេលដែលពិភពលោកយើងទាំងមូលកំពុងប្រឈមមុខនឹងវិបត្តិហិរញ្ញវត្ថុ ដែលពុំធ្លាប់មានតាំងតែពីទសវត្សរ៍ឆ្នាំ ១៩៣០ មកម្ល៉េះ ។ បញ្ហានេះមានលក្ខណៈកាន់តែស្រួចស្រាលថែមទៀត ចំពោះប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍដូច **កម្ពុជា** ដែលកំពុងខិតខំពង្រឹងនូវមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចទីផ្សារ និង រៀបចំនូវឧបករណ៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដើម្បីអនុវត្តអោយមានប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ ។

**រាជរដ្ឋាភិបាលកម្ពុជា** មានការប្តេជ្ញាចិត្តយ៉ាងខ្លាំង ដើម្បីអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងគោលដៅធានាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និង ការសម្រេចបាននូវគោលដៅសហស្សវត្សរ៍កម្ពុជា ។ ការសម្រេចបានដោយ **រាជរដ្ឋាភិបាលកម្ពុជា** នៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ នូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមជាង ៩% ក្នុងមួយឆ្នាំ ក្នុងបរិការណ៍នៃអតិផរណាទាប ស្ថិរភាពអត្រាប្តូរប្រាក់ និង វិន័យថវិកាបានធ្វើអោយសាធារណៈជន អ្នកស្រាវជ្រាវ និង អ្នកវិភាគគោលនយោបាយមានចំណាប់អារម្មណ៍ចំពោះបច្ចេកទេសនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ។

ក្នុងន័យនេះ ខ្ញុំសូមអបអរសាទរចំពោះ បណ្ឌិត **ហង់ ជួន ណារ៉ុន** ដែលបានខិតខំប្រឹងប្រែងស្រាវជ្រាវប្រមូលផ្តុំនូវបទពិសោធន៍ល្អៗ ក្នុងកម្រិតជាតិ និង អន្តរជាតិ ដើម្បីចងក្រងជាសៀវភៅ «**ម៉ាក្រូសេដ្ឋកិច្ច**» នេះឡើង ដោយបកស្រាយ និង ពន្យល់អំពីវិធីសាស្ត្រ និងបច្ចេកទេសទាំងឡាយពាក់ព័ន្ធនឹងការរៀបចំ និង ការអនុវត្តគោលនយោបាយរូបិយវត្ថុ និង ហិរញ្ញវត្ថុសាធារណៈដែល **រាជរដ្ឋាភិបាលកម្ពុជា** បាន និង កំពុងអនុវត្តនៅក្នុងបរិបទនៃសេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មកម្រិតខ្ពស់ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងផ្តល់ព័ត៌មានដែលមានសារៈប្រយោជន៍ដល់អ្នកស្រាវជ្រាវ និងសាធារណជនអំពីប្រព័ន្ធនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា និងបង្កើតឱ្យមានកិច្ចពិភាក្សាបែបស្ថាបនា ដើម្បីកែលម្អថែមទៀតក្នុងគោលដៅជួយជាគំនិតយោបល់ដល់ **រាជរដ្ឋាភិបាលកម្ពុជា** ក្នុងការអនុវត្តអោយបានជោគជ័យនូវ «**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទីពីរ ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា** ដែលដើរតួជាឧបករណ៍ដ៏សំខាន់សម្រាប់ទ្រទ្រង់ការអនុវត្ត «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា**» ។

**ហ៊ុន សែន**

# ម៉ាក្រូសេដ្ឋកិច្ច

## ផ្នែកទី១

## ទស្សនទានស្តីពីម៉ាក្រូសេដ្ឋកិច្ច

### ជំពូកទី១ - បុព្វកថាស្តីពីម៉ាក្រូសេដ្ឋកិច្ច

ពាក្យ *«វិទ្យាសាស្ត្រម៉ាក្រូសេដ្ឋកិច្ច»* បានកើតឡើងនៅអំឡុងទសវត្សទី ៣០ នៃសតវត្សទី ២០ ។ បន្ទាប់ពីចម្ងល់មីក្រូសេដ្ឋកិច្ចបានគ្របដណ្តប់ក្នុងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលដ៏យូរ មានចំណាប់អារម្មណ៍យ៉ាងច្រើនបានផ្តោតទៅលើការសិក្សាអំពីចំណូល អនិកម្មភាព និងថ្លៃ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកដែលចាប់ផ្តើមឡើងនៅឆ្នាំ ១៩២៩ គឺជាហេតុផលដ៏សមរម្យសម្រាប់ការសិក្សាបញ្ហាម៉ាក្រូសេដ្ឋកិច្ច ។ ចំណាប់អារម្មណ៍សំខាន់បានផ្តោតទៅលើទ្រឹស្តី *«វដ្តធុរកិច្ច»* និង អនុសាសន៍នយោបាយ សម្រាប់ការធ្វើឱ្យមានស្ថិរភាពសកម្មភាពសេដ្ឋកិច្ច ។

វិទ្យាសាស្ត្រម៉ាក្រូសេដ្ឋកិច្ចផ្តោតលើគោលនយោបាយរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងធាតុចេញ (Output) អនិកម្មភាព អតិផរណា និង គោលនយោបាយដ៏សមស្របដើម្បីម្រេចបាននូវគោលដៅសេដ្ឋកិច្ចរួម ដូចជាកម្រិតអនិកម្មភាព អត្រាអតិផរណា ឬ គោលដៅសម្រាប់អត្រាប្តូរប្រាក់ ។ សរុបសេចក្តីទៅ ម៉ាក្រូសេដ្ឋកិច្ចសិក្សាពីចរិតលក្ខណៈនៃសេដ្ឋកិច្ចជាតិទាំងមូល ។ អថេរសំខាន់ៗរួមមាន ផលិតផលសរុបក្នុងសេដ្ឋកិច្ច ថ្លៃសរុប អនិកម្មភាព និងនិកម្មភាព អត្រាការប្រាក់ អត្រាបៀវត្ស និង អត្រាប្តូរប្រាក់ ។

សរុបមក ប្រធានបទសំខាន់នៃម៉ាក្រូសេដ្ឋកិច្ច គឺការវិភាគនៃអញ្ញត្តិម៉ាក្រូសេដ្ឋកិច្ច ដូចជាផលិតផលសរុប អតិផរណា និកម្មភាព ជញ្ជីងទូទាត់ និង អត្រាប្តូរប្រាក់ជាដើម ។ ដូច្នេះ ម៉ាក្រូសេដ្ឋកិច្ចសិក្សាអំពីរចនាសម្ព័ន្ធប្រសិទ្ធកម្មនៃសេដ្ឋកិច្ចជាតិ និង គោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីសម្រេចអោយបាននូវគោលដៅម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ច អនិកម្មភាព ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការដោះស្រាយវិបត្តិសេដ្ឋកិច្ច និងការធានាអោយបាននូវការកើនឡើងនៃសុខុមាលភាពរបស់ប្រជាជន ។

### ១ - ប្រព័ន្ធគណនីជាតិ

ប្រព័ន្ធគណនីជាតិ គឺជាក្របខ័ណ្ឌគណនេយ្យសម្រាប់ប្រមូលទិន្ន័យម៉ាក្រូសេដ្ឋកិច្ច និង វិភាគសេដ្ឋកិច្ចទៅតាមស្តង់ដារអន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការប្រៀបធៀប និង វិភាគកម្រិតនៃកំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចរវាងប្រទេសផ្សេងៗគ្នា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រព័ន្ធគណនីជាតិបែងចែកជា ប្រព័ន្ធគណនេយ្យសំខាន់ៗពីរ និង តារាងតុល្យការ គឺ៖

ទីមួយ- *គណនីចរន្ត* - ដែលមានគណនីផលិតកម្ម និង គណនីប្រាក់ចំណូល ។ គណនីផលិតកម្មកត់ត្រានូវការផលិតទំនិញ និង សេវា ។ គណនីចំណូលកត់ត្រានូវការបែងចែកប្រាក់ចំណូលនៅក្នុងដំណាក់កាលផលិតកម្ម និង ការប្រើប្រាស់ប្រាក់ចំណូលសម្រាប់ការប្រើប្រាស់ និង សញ្ច័យ ។

ទីពីរ- *គណនីប្រមូលផ្តុំ* - ដែលកត់ត្រានូវការទិញ និង ការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុ ។ គណនីទាំងនេះផ្សារភ្ជាប់នឹងគ្នាតាមរយៈសញ្ច័យ ដែលត្រូវបានប្រើប្រាស់សម្រាប់ការទិញទ្រព្យសកម្មហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុ ។ គណនីប្រមូលផ្តុំរួមមាន គណនីមូលធន គណនីហិរញ្ញវត្ថុ និង គណនីបម្រែបម្រួលនៃគណនីទ្រព្យសកម្ម ។

ទីបី- *តារាងតុល្យការ* កត់ត្រានូវតម្លៃនៃសន្និធិទ្រព្យសកម្ម និង ទ្រព្យអកម្ម ដើមគ្រា និង ចុងគ្រា ។

គណនីខាងលើនេះត្រូវបានរៀបចំឡើងសម្រាប់តួអង្គសំខាន់ៗនៃសេដ្ឋកិច្ចជាតិ ដូចជា ÷ (១) សាជីវកម្មមិនមែនហិរញ្ញវត្ថុ (២) សាជីវកម្មហិរញ្ញវត្ថុ (៣) ស្ថាប័នរដ្ឋ (៤) ស្ថាប័នមិនយកកម្រៃបម្រើការអោយគេហជន និង (៥) គេហជន ។

## ១.១- វិស័យសេដ្ឋកិច្ចសំខាន់ៗ

វិស័យសេដ្ឋកិច្ចសំខាន់ៗរួមមាន ÷ (១) សាជីវកម្មមិនមែនហិរញ្ញវត្ថុ (២) សាជីវកម្មហិរញ្ញវត្ថុ (៣) ស្ថាប័នរដ្ឋ (៤) ស្ថាប័នមិនយកកម្រៃបម្រើការអោយគេហជន និង (៥) គេហជន ។

***គេហជន*** - ផ្គត់ផ្គង់ដី ពលកម្ម និង មូលធនសម្រាប់ទីផ្សារកត្តាផលិតកម្មផ្សេងៗ និង ត្រូវការទំនិញ និង សេវាលើទីផ្សារទំនិញ ក៏ប៉ុន្តែគេក៏អាចធ្វើការជាផលិតករផងដែរដោយបង្កើតឡើងជាសហគ្រាសផ្ទាល់ខ្លួន ។ ពួកគេសម្រេចចិត្តថាតើត្រូវចំណាយប៉ុន្មានលើការប្រើប្រាស់ ទុកសញ្ច័យប៉ុន្មាន និង វិនិយោគប៉ុន្មានលើទីផ្សារហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃទស្សនៈវិស័យរបស់ពួកគេស្តីពីបរិស្ថានសេដ្ឋកិច្ច និង ការរំពឹងទុកពីអនាគត ។

***សហគ្រាស*** - ប្រើប្រាស់នូវកត្តាផលិតកម្មដូចជាដី ពលកម្ម និង មូលធន ដើម្បីផលិតទំនិញ និង សេវាសម្រាប់ទីផ្សារ។ ពួកគេសម្រេចចិត្តពាក់ព័ន្ធនឹងផលិតកម្ម និង ការវិនិយោគ ដើម្បីបង្កើនជាអតិបរិមានូវប្រាក់ចំណេញ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***វិស័យហិរញ្ញវត្ថុ*** - ផ្តល់នូវសេវាអន្តរការីយកម្មហិរញ្ញវត្ថុសម្រាប់សេដ្ឋកិច្ចជាតិ ។ វិស័យនេះរួមមាន ស្ថាប័នអន្តរការីយកម្មហិរញ្ញវត្ថុ ដូចជា ធនាគារ និង ស្ថាប័នហិរញ្ញវត្ថុ ដូចជា **មូលនិធិសន្ធហធន** (Mutual funds) សហភាពឥណទាន មូលនិធិបេឡាសោធននិវត្តិន៍ និង ក្រុមហ៊ុនធានារ៉ាប់រង ។

***រដ្ឋាភិបាល*** - មានតួនាទីបង្កើតឡើងនូវក្របខ័ណ្ឌគតិយុត្តិ ផ្តល់សេវាសាធារណៈដូចជា អប់រំ សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ មូលនិធិសន្តិសុខសង្គម គ្រប់គ្រងប្រព័ន្ធសារពើពន្ធ និង ប្រព័ន្ធចំណាយសាធារណៈ ។

***វិស័យអន្តរជាតិ*** - ផ្សារភ្ជាប់សេដ្ឋកិច្ចជាតិទៅនឹងបរទេស និង ប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិ ។

### *១.២- សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ*

សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗរួមមាន ÷

***ផលិតផលសរុប*** - គឺជាតម្លៃនៃទំនិញ និង សេវាទាំងអស់ដែលផលិតដោយសេដ្ឋកិច្ចទាំងមូល ។ ទស្សនទាននេះអាច នាំអោយមានការរាប់លើសពីរដង ។

***តម្លៃបន្ថែម*** - គឺជាតម្លៃនៃផលិតផលសរុប ដកចេញនូវតម្លៃនៃការប្រើប្រាស់អន្តរកាល ។ សេដ្ឋវិទូប្រើប្រាស់នូវទស្សនទាននៃតម្លៃបន្ថែម ដើម្បីវាស់វែងនូវផលិតផលរបស់ប្រទេសមួយ ។ ផលិតផលដែលមិនអាចលក់បាន ត្រូវញែកចេញពីផលិតផល ដែលអាចលក់លើទីផ្សារ ។ ផលិតផលដែលមិនអាចលក់បានរួមមាន ការផលិតសម្រាប់ការប្រើប្រាស់ខ្លួនឯង ដូចជាការធ្វើស្រែ សម្រាប់តែបរិភោគខ្លួនឯង និង ផ្ទះសម្រាប់នៅខ្លួនឯង ។

***ការប្រើប្រាស់*** - ត្រូវបានចែកចេញជាពីរផ្នែកផ្សេងគ្នា ÷ ការប្រើប្រាស់អន្តរកាល និង ការប្រើប្រាស់ចុងក្រោយ ។ ការប្រើប្រាស់អន្តរកាល គឺ ការផ្តល់នូវធាតុចូលសម្រាប់ផលិតកម្ម ចំណែកឯការប្រើប្រាស់ចុងក្រោយ គឺជាការប្រើប្រាស់នូវទំនិញ និង សេវា ទាំងនៅក្នុងប្រទេស ទាំងនាំចូល ដោយគ្រួសារ និង ស្ថាប័នរដ្ឋ ។

***ផលិតផលសរុបក្នុងស្រុក*** - គឺជាការបូកចូលគ្នានៃតម្លៃបន្ថែមក្នុងគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចជាតិ។ ផលិតផលសរុបក្នុងស្រុក គឺជារង្វាស់នៃតម្លៃនៃទំនិញ និង សេវានៅក្នុងសេដ្ឋកិច្ចជាតិ ។

***ការវិនិយោគ*** - (ការបង្កើតមូលនិធិសរុប) គឺជាការបូកចូលគ្នានូវស្តុករូបិយនៃមូលធននៅក្នុងសេដ្ឋកិច្ច ។ យើងអាចអោយនិយមន័យម៉្យាងទៀតថា គឺជាផលិតផលដែលផលិតនៅក្នុងឆ្នាំបច្ចុប្បន្ន តែមិនមែនសម្រាប់ការប្រើប្រាស់នៅក្នុងឆ្នាំនេះទេ ។ ក្នុងន័យម៉ាក្រូសេដ្ឋកិច្ច ការវិនិយោគរួមមាន ការផលិតគ្រឿងចក្រ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រោងចក្រ ផ្ទះសម្បែង និង ការប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌ ។ ដូចនេះ ការទិញសញ្ញាប័ណ្ណ ឬ ការទិញមូលបត្រ ដែលធម្មតាហៅថាការវិនិយោគ មិនមែនជាការវិនិយោគក្នុងន័យម៉ាក្រូសេដ្ឋកិច្ចឡើយ ដោយសារការទិញលក់មូលបត្រនេះមិនបានឆ្លុះបញ្ចាំងពីការផ្ទេរនូវទ្រព្យសកម្មហិរញ្ញវត្ថុរវាងតួអង្គសេដ្ឋកិច្ចឡើយ ។

***ការរំលស់*** - ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីភាពខុសគ្នារវាង ការវិនិយោគសុទ្ធ និង ការវិនិយោគដុល ដែលអាចហៅ បានថាជា ***ការប្រើប្រាស់នូវមូលធនអចលនវត្ថុ*** ។ ដោយសន្និធិមូលធនត្រូវរិចរិលពីមួយឆ្នាំទៅមួយឆ្នាំ ការរំលស់គឺជាតម្លៃដើម្បីយកទៅទិញមូលធនមកជំនួយមូលធនចាស់នៅក្នុងរយៈពេលណាមួយ ហើយត្រូវដកចេញពីការវិនិយោគដុល ដើម្បីទទួលបាននូវការវិនិយោគសុទ្ធ ។ ទំនាក់ទំនងនេះអាចសរសេរជារូបមន្តដូចតទៅ៖

*ការវិនិយោគសុទ្ធ = ការវិនិយោគដុល - ការរំលស់*

***ការវិនិយោគសុទ្ធ*** - គឺជាការវិនិយោគដុល ដកចេញនូវការរំលស់ ហើយត្រូវបានប្រើប្រាស់ដើម្បីវាស់វែងនូវការកើនឡើងនូវសមត្ថភាពផលិត អោយបានត្រឹមត្រូវល្អជាងការវិនិយោគដុល ។

***ការនាំចេញសុទ្ធ*** - ការជាតម្លៃនៃការនាំចេញទំនិញ និង សេវា ដកចេញនូវតម្លៃនៃការនាំចូលទំនិញ និង សេវា ហើយត្រូវបានប្រើប្រាស់ដើម្បីវាស់វែងនូវផលប៉ះពាល់នៃពាណិជ្ជកម្មក្រៅប្រទេសមកលើតម្រូវការសរុប ។ ការនាំចេញសុទ្ធ គឺជាធាតុមួយនៃតម្រូវការសរុបនូវទំនិញ និង សេវាក្នុងស្រុក ហើយអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ផលិតផលសរុបក្នុងស្រុក។

***សមត្ថភាពស្រូប*** - ដែលអាចហៅបានថាជា ***តម្រូវការសរុបក្នុងស្រុក*** គឺជា ផលបូកនៃការប្រើប្រាស់ចុងក្រោយទាំងអស់ (C) និង ការវិនិយោគដុល (I): A = C+I ។

## ២- ផលិតផលសរុបក្នុងស្រុក

ផលិតផលសរុបក្នុងស្រុក (ផសស) អាចគណនាបានដោយប្រើវិធីសាស្រ្តជាមូលដ្ឋានបីយ៉ាង ដោយផ្តល់នូវលទ្ធផលដូចៗគ្នា÷វិធីសាស្រ្តផលិតកម្ម វិធីសាស្រ្តប្រាក់ចំណូល និង វិធីសាស្រ្តចំណាយ ។

### *២.១- វិធីសាស្រ្តផលិតកម្ម*

គណនាតាមវិធីសាស្រ្តផលិតកម្ម ***ផលិតផលសរុបក្នុងស្រុក*** គឺជាផលបូកនៃតម្លៃបន្ថែមដុលផលិតដោយសេដ្ឋកិច្ច ទាំងមូល ឬ ជា ផលដកនៃតម្លៃផលិតកម្ម ឬ ធាតុចេញ (Output) និង តម្លៃនៃទំនិញ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| តារាងទី ១.១ - ផលិតផលសរុបក្នុងស្រុកតាមវិធីសាស្ត្រផលិតកម្ម *(ពាន់លានរៀល)* | | | |
|---|---|---|---|
| | **2005** | **2006** | **2007** |
| **កសិកម្ម** | **7,909** | **8,972** | **10,406** |
| - ធញ្ញជាតិ | 4,034 | 4,518 | 5,436 |
| - ការចិញ្ចឹមសត្វ | 1,198 | 1,379 | 1,528 |
| - ជលផល | 1,892 | 2,160 | 2,435 |
| - ព្រៃឈើ | 784 | 915 | 1,008 |
| **ឧស្សាហកម្ម** | **6,436** | **7,816** | **8,738** |
| - រ៉ែ | 97 | 115 | 133 |
| - កមន្តសាល | 4,585 | 5,541 | 6,073 |
| - អគ្គិសនី | 124 | 164 | 195 |
| - សំណង់ | 1,631 | 1,995 | 2,338 |
| **សេវា** | **10,064** | **11,557** | **13,493** |
| - ពាណិជ្ជកម្ម | 2,364 | 2,662 | 3,126 |
| - សណ្ឋាគារ | 1,117 | 1,306 | 1,519 |
| - គមនាគមន៍ | 1,904 | 2,115 | 2,423 |
| - ហិរញ្ញវត្ថុ | 294 | 378 | 491 |
| - រដ្ឋបាលសាធារណៈ | 464 | 515 | 668 |
| - អចលនទ្រព | 1,701 | 1,947 | 2,198 |
| - ផ្សេងៗ | 2,221 | 2,634 | 3,069 |
| **ពន្ធលើផលិតផលដកការឧត្ថម្ភធន** | 1,598 | 1,795 | 2,788 |
| **ផលិតផលសរុបក្នុងស្រុក** | **25,754** | **29,849** | **35,039** |

និង សេវាទាំងអស់ដែលត្រូវបានប្រើប្រាស់ នៅក្នុងដំណើរការផលិតកម្ម (ការប្រើប្រាស់អន្តរកាល) ។ ដូច្នេះ ÷

$$\mathbf{GDP = \Sigma VA} \qquad \mathbf{(1.1.)}$$

ដែល **ΣVA** គឺជាផលបូកនៃតម្លៃបន្ថែមនៃគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចជាតិ ។

ផសស គឺជាទស្សនទានដុល ដែលមានបញ្ចូលនូវការរំលស់ផងដែរ (ការប្រើប្រាស់នូវមូលធនអចលនវត្ថុ) ។ ដូចនេះ ផលិតផល សរុបសុទ្ធ ស្មើនឹង ÷

$$\mathbf{NDP = GDP — D} \qquad \mathbf{(1.2.)}$$



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែល **D** គឺជា ការរំលស់ ឬ ការប្រើប្រាស់នូវមូលធនអចលនវត្ថុ ។

### ២.២- វិធីសាស្ត្រប្រាក់ចំណូល

ផលិតផលសរុបក្នុងស្រុក គឺជាផលបូកនៃប្រាក់ចំណូលនៃផលិតករក្នុងស្រុកទាំងអស់ ។ ដូច្នេះ ÷

$$GDP = W + OS + TSP \qquad (1.3.)$$

ដែល

**W =** គឺជាប្រាក់បៀវត្សរ៍របស់បុគ្គលិក និង ចំណាយលើពលកម្មផ្សេងទៀត ដូចជាវិភាគទានសន្តិសុខសង្គមរបស់និយោជក និង វិភាគទានសន្តិសុខសង្គមរបស់និយោជិក ។

**OS =** គឺជាប្រាក់ចំណេញប្រតិបត្តិការដុលរបស់សហគ្រាស (រួមមាន ប្រាក់ចំណេញ ថ្លៃឈ្នួល ការប្រាក់ និង រំលស់) ។

**TSP =** គឺជាពន្ធដកការឧបត្ថម្ភធនលើផលិតផល ។

### ២.៣- វិធីសាស្ត្រចំណាយ

ផលិតផលសរុបក្នុងស្រុក គឺជាផលបូកនៃការប្រើប្រាស់ចុងក្រោយ ។ ដូច្នេះ ÷

$$GDP = C + I + (X-M) \qquad (1.4.)$$

ដែល

**C =** គឺជាការប្រើប្រាស់ចុងក្រោយនៃវិស័យរដ្ឋាភិបាល និង ក្រៅរដ្ឋាភិបាល ។

**I =** គឺជាវិនិយោគដុល (ការបង្កើតមូលធនអចលវត្ថុ និង ការផ្លាស់ប្តូរនៃបញ្ជីសារពើភ័ណ្ឌ) ។

**X =** គឺជាការនាំចេញទំនិញ និង សេវា ។

**M =** គឺជាការនាំចូលទំនិញ និង សេវា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| តារាងទី ១.២- ផលិតផលសរុបក្នុងស្រុកតាមវិធីសាស្ត្រចំណាយ *(ពាន់លានរៀល)* | | | |
|---|---|---|---|
| | **2005** | **2006** | **2007** |
| ការប្រើប្រាស់ចុងក្រោយ | 23,203 | 25,268 | 28,829 |
| ការបង្កើតមូលធនអចលនវត្ថុដុល | 4,864 | 6,001 | 6,796 |
| បម្រែបម្រួលនៃបញ្ជីសារពើភ័ណ្ឌ | (109) | (110) | (111) |
| ការនាំចេញ | 16,505 | 19,461 | 21,691 |
| ការនាំចូល | 18,736 | 21,721 | 24,506 |
| កំហុសស្ថិតិ | 26 | 841 | 2,229 |
| **ផលិតផលសរុបក្នុងស្រុក** | **25,754** | **29,849** | **35,039** |

សរុបមក យើងឃើញថា ÷

**Y = GDP** = ផលិតផលសរុប (ធាតុចេញ)

= ប្រាក់ចំណូលសរុប

= ចំណាយសរុប

## ៣- ផលិតផលសរុបក្នុងស្រុក តាមថ្លៃទីផ្សារ និង តាមថ្លៃថេរ

ផលិតផលសរុបក្នុងស្រុក គឺជាសូចនាករដែលវាស់វែងតម្លៃធាតុចេញ នៅក្នុងឆ្នាំណាមួយ តាមថ្លៃនៃឆ្នាំនោះ ។ ដូច្នេះ ការឡើងចុះនៃតម្លៃផលិតផលសរុបក្នុងស្រុក ឆ្លុះបញ្ចាំងអោយឃើញនូវបម្រែបម្រួល ទាំងថ្លៃ ទាំងបរិមាណ ។ ដើម្បីរំលេចអោយឃើញនូវបម្រែបម្រួលបរិមាណធាតុចូល គេត្រូវយកផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារទៅចែកនឹងសន្ទស្សន៍ថ្លៃ ។ ដូច្នេះ យើងបាន ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ***ផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារ*** ដែលវាស់វែងនូវតម្លៃធាតុចេញនៃសេដ្ឋកិច្ច តាមថ្លៃជាក់ស្តែង ។

- ***ផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ*** ដែលវាស់វែងនូវតម្លៃធាតុចេញនៃសេដ្ឋកិច្ច តាមថ្លៃថេរនៃឆ្នាំគ្រាគោល ឬ ឆ្នាំមូលដ្ឋាន ។ ផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរត្រូវបានប្រើប្រាស់ដើម្បីវាស់វែងកំណើនធាតុចេញពិត ដែលជាសូចនាករមួយយ៉ាងសំខាន់ ដើម្បីវាស់វែងកំណើនសេដ្ឋកិច្ច ។




- ***បរិត្តផរណា*** (GDP deflator) គឺជាសន្ទស្សន៍ថ្លៃដែលវាស់នូវកម្រិតថ្លៃជាមធ្យមនៅក្នុងសេដ្ឋកិច្ចជាតិ សម្រាប់ធាតុចេញ ដោយប្រៀបធៀបទៅនឹងថ្លៃគ្រាគោល ។ សន្ទស្សន៍នេះស្មើនឹង ១០០ នៅក្នុងឆ្នាំគ្រាគោល ។ ដូច្នេះ កំណើនភាគរយនៃបរិតផរណាឆ្លុះបញ្ចាំងអោយឃើញនូវការឡើងថ្លៃទំនិញ និង សេវានៅក្នុងសេដ្ឋកិច្ច ទាំងមូលតែម្តង ។

ទំនាក់ទំនងរវាងផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារ និង ផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ អាចសរសេរបាន ដូចតទៅ៖

***ផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារ*** = [ផលិតផលសរុបក្នុងតាមថ្លៃថេរ × បរិត្តផរណា ]/១០០ **(1.5.)**


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ*** = [ផលិតផលសរុបក្នុងតាមថ្លៃទីផ្សារ / បរិតផរណា ]×១០០ **(1.6.)**

***បរិត្តផរណា*** = [ផលិតផលសរុបក្នុងតាមថ្លៃទីផ្សារ / ផលិតផលសរុបក្នុងតាមថ្លៃថេរ ]×១០០ **(1.7.)**

ដូច្នេះកំណើនសេដ្ឋកិច្ចអាចសរសេរបានថា ÷

$$(I + v) = (I + g) \times (I + p) \quad (1.8.)$$

ដែល

**v =** គឺជា អត្រាកំណើននៃផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារ គិតជាភាគរយ ។

**g =** គឺជា អត្រាកំណើននៃផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ គិតជាភាគរយ ។

**p =** គឺជា អត្រាកំណើនអតិផរណា វាស់ដោយបរិត្តផរណា គិតជាភាគរយ ។

## ៤- សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ

### *៤.១- ប្រាក់ចំណូលជាតិដុល*

ផលិផលសរុបក្នុងស្រុកជាសូចនាករដែលវាស់វែងនូវធាតុចេញផលិតដោយនិវាសនជន តែវាមិនអាចវាស់វែងនូវប្រាក់ចំណូលដែលទទួល ឬ ផ្ទេរអោយអនិវាសនជនឡើយ ។ ប្រាក់ចំណូលជាតិដុល (GNI) គឺជាសូចនាករដែលវាស់នូវ ***ប្រាក់ចំណូលសុទ្ធពីកត្តាផលិតកម្មពីបរទេស*** ($Y_f$) ដែលជា៖ (១) ប្រាក់ចំណូលមូលធនដោយរួមមានចំណូលពីវិនិយោគ ក្រោមរូបភាពជាភាគលាភបានមកពីវិនិយោគផ្ទាល់ និង ការប្រាក់លើកម្ចីក្រៅប្រទេស ឬ ឥណទានក្រៅប្រទេស (២) ប្រាក់ចំណូលពីពលកម្មរបស់អន្តោប្រវេសន៍ ឬ ចំណាកស្រុក និង (៣) ចំណូលសេវាពីដីធ្លី ផ្ទះសំបែង និង សួយសារ ។ ដូច្នេះ ÷

$$GNI = GDP + Y_f \quad (1.9.)$$

ក៏ប៉ុន្តែ **GNI** ជាសូចនាករដែលឈរលើមូលដ្ឋាននៃប្រាក់ចំណូលតែប៉ុណ្ណោះ ដោយឥតមានពាក់ព័ន្ធនឹងផលិតកម្មឡើយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ៤.២- ប្រាក់ចំណូលជាតិដុលដែលអាចប្រើប្រាស់បាន

ប្រាក់ចំណូលជាតិដុលដែលអាចប្រើប្រាស់បាន (GNDI) គឺជាប្រាក់ចំណូលសរុប ដែលនិវាសនជនអាចប្រើប្រាស់ សម្រាប់ការប្រើប្រាស់ចុងក្រោយ ឬ សម្រាប់សញ្ចយ ។ សូចនាករ GNI នេះ គឺជាផលបូក GNI ទៅនឹងការផ្ទេរចរន្តសុទ្ធពីបរទេស ($TR_f$) ។ យើងទទួលបាននូវរូបមន្ត ÷

$$GNDI = GNI + TR_f$$

### ៤.៣- សញ្ចយជាតិដុល

ប្រាក់សញ្ចយជាតិដុល (S) អាចចាត់ទុកថាជាផលដករវាង GDNI និង ការប្រើប្រាស់ចុងក្រោយ ។ ដូច្នេះ យើងបានសមីការ ÷

$$S = GNDI + C$$

## ៥- ទំនាក់ទំនងរវាងអតុល្យភាពក្រៅស្រុក និង គម្លាតធនធានក្នុងស្រុក

បទពិសោធន៍ជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍បានបង្ហាញអោយឃើញថា ជាញឹកញយអតុល្យភាពនៃជញ្ជីងទូទាត់ជាមួយប្រទេសក្រៅនាំអោយមាននូវឱនភាពធនធានផ្ទៃក្នុងប្រទេស ដូចជាអតុល្យភាពរវាងចំណាយក្នុងស្រុក និង ធនធានដែលមាន (ឬរវាងសញ្ចយជាតិ និង វិនិយោគ) ។ ប្រការនេះ គេអាចដោះស្រាយបានតាមរយៈការផ្លាស់ប្តូរនូវគោលនយោបាយក្នុងស្រុក ។ ការវិភាគលើបញ្ហានេះ គឺការកំណត់នូវទំនាក់ទំនងរវាងប្រាក់ចំណូលជាតិ និង ធនធានដែលមានសម្រាប់ការប្រើប្រាស់ និង វិនិយោគ ។ ដូច្នេះ ***ផលិតផលសរុបក្នុងស្រុក*** អាចអោយនិយមន័យថា គឺជា ផលបូកនៃការប្រើប្រាស់ វិនិយោគ និង ការនាំចេញសុទ្ធ (ការនាំចេញ- ការនាំចូល)÷

$$GDP = C + I + (X\text{-}M)$$

ប្រសិនបើយើងបន្ថែមទៅសមីការទាំងសងខាងនូវចំនួន $Y_f$ ដែលជាប្រាក់ចំណូលពីកត្តាផលិតកម្មសុទ្ធពីបរទេស - ការសងការប្រាក់សុទ្ធ ការផ្ទេរប្រាក់ចំណេញ ។ល។ មក យើងបាននូវសូចនាករថ្មីមួយ គឺ ***ប្រាក់ចំណូលសរុបក្នុងស្រុក***÷

$$GDI = C + I + (X\text{-}M) + Y_f$$


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ទាប់មក ប្រសិនបើយើងបន្ថែមទៅសមីការទាំងសងខាងនូវចំនួន $TR_f$ ដែលជាការផ្ទេរសុទ្ធពីបរទេស -

**តារាងទី ១.៣ សូចនាករចំណូល និង ចំណាយសំខាន់ៗ**

| | | |
|---|---|---|
| GDP = | $C + I + (X\text{-}M) = A + (X\text{-}M)$ | (1) |
| GNI = | $GDP + Y_f = C + I + (X\text{-}M) + Y_f$ | (2) |
| | $A + (X\text{-}M) + Y_f$ | (3) |
| GNDI = | $GNI + TR_f$ | (4) |
| | $C + I + (X\text{-}M)) + Y_f + TR_f$ | (5) |
| | $A + (X\text{-}M + Y_f + TR_f)$ | (6) |
| GNDI - A= | $(X\text{-}M + Y_f + TR_f)$ | (7) |
| | CAB | |
| GNDI - C= | S | |
| GNDI - C= | $I + X—M + Y_f + TR_f = S$ | (8) |
| S - I= | | |

ដូចជា ការផ្ទេរឯកជន (ប្រាក់ចំណូលរបស់ពលករពីបរទេស និង អំណោយឯកជន) និង ការផ្ទេរសាធារណៈ (ជំនួយសាធារណៈ) មក យើងបាននូវសូចនាករថ្មីមួយ គឺ ***ប្រាក់ចំណូលសរុបជាតិដែលអាចប្រើប្រាស់បាន÷***

$$\mathbf{GNDI = C + I + (X\text{-}M) + Y_f + Tr_f} \qquad (1.10)$$

ប្រសិនបើយើងដកពីសមីការ **(1.10)** នូវការប្រើប្រាស់ និង វិនិយោគ ដែលជាចំណាយសរុបនៃសេដ្ឋកិច្ច ឬ ហៅម្យ៉ាងទៀតថាជា សមត្ថភាពស្រូប (A) នៃធនធាន នោះយើងនឹងបាន÷

$$\mathbf{GNDI - A = (X\text{-}M) + Y_f + Tr_f = CAB} \qquad (1.11)$$

សមីការខាងស្តាំដៃ ដែលមានសមាសធាតុជា ការនាំចេញ ដកការនាំចូល បូក ប្រាក់ចំណូលពី


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កត្តាផលិតកម្មសុទ្ធពីបរទេស និង បូក ការផ្ទេរសុទ្ធពីបរទេស គឺជា ***តុល្យភាពនៃគណនីចរន្ត***នៃជញ្ជីងទូទាត់ CAP ។ ក្នុងករណីដែលមានអតុល្យភាពរវាង ***ប្រាក់ចំណូលសរុបជាតិដែលអាចប្រើប្រាស់បាន*** (GNDI) ដែលជាធនធានរបស់ប្រទេសជាតិដែលអាចប្រើប្រាស់បាន និងសមត្ថភាពស្រូប (A) ដែលជាចំណាយសរុបនៃសេដ្ឋកិច្ចជាតិ លទ្ធផលនៃអតុល្យភាពនេះនឹងមានផលប៉ះពាល់ភ្លាមទៅលើ***តុល្យភាពគណនីចរន្ត***នៃជញ្ជីងទូទាត់ ។ សមីការ **(1.11)** បង្ហាញអោយឃើញថា ឱនភាព***គណនីចរន្ត***នៃជញ្ជីងទូទាត់តែងតែឆ្លុះបញ្ចាំងអោយឃើញនូវចំណាយសរុបរបស់សេដ្ឋកិច្ចជាតិ ឬ សមត្ថភាពស្រូប (A=C+I) មានទំហំច្រើនលើសលុបបហួសពីធនធានដែលមាន GNDI។

ដូច្នេះ អតុល្យភាពខាងក្រៅ ដូចជា ឱនភាពនៃគណនីចរន្តនៃជញ្ជីងទូទាត់អាចនឹងដោះស្រាយបានតាមរយៈ វិធានការគោលនយោបាយផ្ទៃក្នុង ដូចជាគោលនយោបាយរូបិយវត្ថុ គោលនយោបាយថវិកា ឬ គោល-នយោបាយអត្រាប្តូរប្រាក់ជាដើម ដើម្បីកាត់បន្ថយចំណាយសរុប ឬ សមត្ថភាពស្រូបអោយសមស្របទៅនឹងធនធានដែលមាន (GNDI) ។

**GNDI –C = I + (X-M)+** $Y_f + Tr_f$ ឬ

**S = I + (X-M)+** $Y_f + Tr_f$

ប្រសិនបើយើងដកនូវវិនិយោគ (I) ពីសមីការខាងលើ យើងនឹងទទួលបាននូវសមីការថ្មីមួយទៀត គឺ៖

$$S - I = (X-M) + Y_f + Tr_f = CAB \quad (1.12)$$

ផ្នែកខាងស្តាំដៃនៃសមីការ **(1.12)** នេះ គឺជា ***តុល្យភាពគណនីចរន្ត***នៃជញ្ជីងទូទាត់ ។ ដូច្នេះ គម្លាតរវាងសញ្ចយជាតិ និង វិនិយោគនៅក្នុងសេដ្ឋកិច្ចជាតិ ស្មើនឹង ***តុល្យភាពគណនីចរន្តនៃជញ្ជីងទូទាត់*** ។ ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់នឹងកើតមានឡើង នៅពេលដែលចំណាយវិនិយោគមានទំហំលើសពីសញ្ចយ ដែលទាមទារអោយរដ្ឋាភិបាលទាក់ទាញនូវធនធានពីបរទេស ដើម្បីយកទៅធ្វើហិរញ្ញប្បទាននៃគង្វះធនធាននេះ ។ ប្រសិនបើរដ្ឋមិនបានយកធនធាននេះទៅវិនិយោគក្នុងវិស័យផលិតកម្ម ដែលជួយបង្កើតសមត្ថភាពផលិតរបស់សេដ្ឋកិច្ចជាតិទេនោះ ឱនភាពគណនីចរន្តនឹងកើនឡើងខ្លាំងថែមទៀត ជាហេតុបង្កអោយមានវិបត្តិសេដ្ឋកិច្ច ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី២

# ឧបករណ៍វិភាគម៉ាក្រូសេដ្ឋកិច្ច

# ជំពូកទី២

# កំណើនសេដ្ឋកិច្ច

## ១. អនុគមន៍ផលិតកម្មក្នុងគំរូបុរាណនិយម

ទំនាក់ទំនងដ៏សំខាន់នៅក្នុងគំរូបុរាណនិយម គឺអនុគមន៍ផលិតកម្មសរុប ដែលជាទំនាក់ទំនងរវាងបរិមាណធាតុចេញ និង បរិមាណកត្តាផលិតកម្មជាធាតុចូល ហើយអាចសរសេរបានដូចខាងក្រោម៖

សមីការ ២.១ $Y = f(K^*, N)$

Y : ជាផលិតផលពិត

K*: បរិមាណមូលធន (ដីចំការ និង ឧបករណ៍)

N : ចំនួនកម្មករប្រើក្នុងផលិតកម្ម

សម្រាប់រយៈពេលខ្លីចំនួនមូលធនត្រូវបានសន្មតថាថេរ ហើយបច្ចេកវិជ្ជា និង ប្រជាជនក៏សន្មតថាមិនប្រែប្រួលដែរ (ជាចំនួនថេរ) ។

ក្នុងរយៈពេលខ្លីចំនួនមូលធនសន្មតថាថេរ (បញ្ជាក់ដោយសញ្ញា * លើអក្សរ K) និង ចំនួនកម្មករប្រែប្រួល ប៉ុន្តែសន្មតថាចំនួនប្រជាជនថេរ (បើមិនដូច្នេះទេអាចនឹងមានចំនួនកម្មករបន្ថែមតាមរយៈកំណើនប្រជាជន) ។

នៅក្នុងរយៈពេលខ្លី រាល់ការប្រែប្រួល Y អាស្រ័យលើការប្រែប្រួល N ។ ទំនាក់ទំនងនេះ មានបង្ហាញក្នុងរូប ៣.១ ដែលជាអនុគមន៍ផលិតកម្មបែបបុរាណនិយម ដែលបង្ហាញនូវលក្ខណៈសំខាន់មួយចំនួនដូចជា៖

ក- នៅពេលដែល N មានបរិមាណតិច អនុគមន៍ស្ទើរតែជាបន្ទាត់ត្រង់ ដែលចំណោតរបស់វាវាស់ពី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការកើនផលិតផល សម្រាប់ការកើនឡើងនៃ N ហើយកំណាត់ខ្សែកោងនេះឆ្លុះបញ្ចាំងពី *«ផលថេរមាត្រសាស្ត្រ»* ។

**ខ-** ប៉ុន្តែនៅពេល N កើនឡើង ចំណោតខ្សែកោងបែរទៅជាទ្រេតមិនចោតខ្លាំងដែលបញ្ជាក់ពី *«ផលនៃឯកតាបន្ថែមមានតិចតួច»* ពោលគឺធាតុចេញកើនឡើងដោយសមាមាត្រតិចជាងការកើន N ។

**គ-** តាមអនុគមន៍ផលិតកម្ម គេអាចគណនាខ្សែកោងដែលពាក់ព័ន្ធ គឺផលិតភាពនៃមួយឯកតាពលកម្មបន្ថែម (Marginal Productivity of Labour-MPN) ។ MPN គឺជាការបន្ថែមលើផលិតផលសរុប ដោយសារការបន្ថែមពលកម្មមួយឯកតា (បរិមាណធាតុចូលផ្សេងទៀតនៅថេរ) ។ ផលបន្ថែមមួយឯកតានៃពលកម្ម គឺជាជំរាលនៃអនុគមន៍ផលិតកម្ម ($\Delta Y/\Delta N$) ។

សេដ្ឋវិទូបែបបូរាណនិយមធ្វើការសន្មតថា***ទីផ្សារមានដំណើរការល្អ***។ ក្រុមហ៊ុន និង កម្មករមានការគិតគូរប្រកបដោយវិចារណៈញ្ញាណ ដោយ***ពួកគេមានព័ត៌មានយ៉ាងច្បាស់លាស់អំពីថ្លៃ និង គ្មានការរាំងស្ទះដល់ការកែតម្រូវបៀវត្ស និង ការជាត់ទាត់ទីផ្សារ***។ សេដ្ឋវិទូបូរាណនិយមយល់ឃើញថា ÷

១. ថ្លៃ និង បៀវត្សមានលក្ខណៈទន់ភ្លន់ឥតខ្ចោះ ។

២. ព័ត៌មានឥតខ្ចោះអំពីថ្លៃទីផ្សារសម្រាប់គ្រប់អ្នកចូលរួមក្នុងទីផ្សារ ។

សម្មតិកម្មពីរនេះមាន គឺជាមូលដ្ឋាននៃទ្រឹស្តីសមតាតាមបែបបូរាណនិយម រវាងនិកម្មភាព និង ធាតុចេញ និង ជាសមាសធាតុនៃទ្រឹស្តីបូរាណនិយម ដែល **គេនស៍** បានជំទាស់ ។

## ២. ប្រភពនៃកំណើនសេដ្ឋកិច្ច

អនុគមន៍ផលិតកម្មបង្ហាញពីទំនាក់ទំនងរវាង **ធាតុចូល** និង **ធាតុចេញ** ។ ដើម្បីសម្រួលដល់ការគិតគូរ យើងសន្មតថា ពលកម្ម (N) និង មូលធន (K) គឺជាធាតុចូលដ៏សំខាន់ ។ សមីការ ២.២ បង្ហាញថា **ធាតុចេញ** (Y) អាស្រ័យទៅលើកម្រិតនៃធាតុចូល និង បច្ចេកវិទ្យា (A) ។ ប្រសិនបើបច្ចេកវិទ្យា (A) កាន់តែខ្ពស់ នោះគេអាចផលិតធាតុចេញបានកាន់តែច្រើន ដោយប្រើប្រាស់នូវធាតុចូលដដែល ។

សមីការ ២.២ $Y = AF(K, N)$

ដោយឈរលើមូលដ្ឋាននៃសមីការ ២.២. យើងអាចរកនូវកំណើនសេដ្ឋកិច្ច ដែលតាងដោយសមីការខាងក្រោម ÷

សមីការ ២. ៣ $\Delta Y/Y = [(1-\theta) \times \Delta N/N] + (\theta \times \Delta K/K) + \Delta A/A$


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែល (1-θ) និង θ គឺជាមេគុណ ដែលជាចំណែកនៃពលកម្មនៅក្នុងប្រាក់ចំណូល និង ជាចំណែកនៃមូលធននៅក្នុងប្រាក់ចំណូល ។

សមីការ ២.៣ បង្ហាញនូវការចូលរួមវិភាគទាននៃធាតុចូល តាមរយៈការបង្កើនផលិតភាព ដើម្បីបង្កើនធាតុចេញ ។ ពលកម្ម និង មូលធនចូលរួមចំណែកក្នុងកំណើនធាតុចេញ តាមរយៈកំណើននៃធាតុចូលទាំងពីរគុណនឹងចំណែករបស់កត្តាទាំងពីរ នៅក្នុងប្រាក់ចំណូល ។ ការកែលំអរបច្ចេកវិទ្យា ឬ វឌ្ឍនភាពនៃបច្ចេកវិទ្យា ដែលជាកំណើនផលិតភាពនៃកត្តាផលិតកម្ម ។

## ៣. អនុគមន៍ផលិតកម្ម ខប់-ដូក្លាស

អនុគមន៍ផលិតកម្មសាមញ្ញអាចសរសេរបានថា $Y = AF(K, N)$ ។ សេដ្ឋវិទូតែងតែប្រើនូវអនុគមន៍ផលិតកម្ម ដែលរកឃើញដោយលោក **វិកសែល** (Wicksell, 1851-1926) តែត្រូវបានយកទៅសាកល្បងផ្ទៀងផ្ទាត់នូវទិន្នន័យស្ថិតិ ដោយលោក **ឆាល ខប់** (Charles Cobb) និង លោក **ប៉ូល ដូក្លាស** (Paul Douglas) នៅឆ្នាំ ១៩២៨ ។ អនុគមន៍ នេះអាចសរសេរបានដូចតទៅ៖

$$Y = AL^{\alpha}K^{\beta},$$

ដែល៖

- $Y$ គឺជាផលិតកម្ម (តម្លៃរូបិយវត្ថុនៃបរិមាណផលិតកម្មទំនិញក្នុងមួយឆ្នាំ) ។
- $L$ គឺជាធាតុចូល ជាពលកម្ម
- $K$ គឺជាធាតុចូល ជាមូលធន
- $A$ គឺជាកត្តាផលិតភាពទូទៅ
- $\alpha$ និង $\beta$ គឺជាភាពយឺតនៃពលកម្ម និង មូលធន ចំពោះធាតុចេញ ។ ទាំងពីរនេះ គឺជាចំនួនថេរ ដែលកំណត់ដោយបច្ចេកវិទ្យា ។ ភាពយឺតនៃធាតុចេញ ជារង្វាស់រង្វាល់នៃការឆ្លើយតបនៃធាតុចេញ ចំពោះបន្លាស់ប្តូរនៃកម្រិតពលកម្ម និង មូលធននៅក្នុងផលិតកម្ម ។ ប្រសិនបើ $\alpha = 0.15$ នោះកំណើនពលកម្មចំនួន ១% នឹងនាំអោយធាតុចេញកើនឡើង ០,១៥% ។ ប្រសិនបើ ÷

$$\alpha + \beta = 1$$

នោះអនុគមន៍នៃផលិតកម្មមានកំណើនថេរ ។ ពោលគឺ ប្រសិនបើ កត្តា និង កើនឡើងចំនួន ២០% នោះធាតុចេញនឹងកើនឡើងចំនួន ២០% ដែរ ។ ប្រសិនបើ៖

$$\alpha + \beta < 1$$


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- នោះប្រាក់ចំណេញពីវិនិយោគ នឹងកាន់តែធ្លាក់ចុះទៅ ។ ប្រសិនបើ÷

$\alpha + \beta > 1$

នោះប្រាក់ចំណេញពីវិនិយោគកាន់តែកើនឡើង ។ ដោយសន្មតថាមានការប្រណាំងប្រជែងគ្នាយ៉ាងល្អ ដោយសារមានការប្រណាំងប្រជែងដ៏ល្អឥតខ្ចោះ $\alpha$ និង $\beta$ គឺជាចំណែកនៃពលកម្ម និង មូលធន នៅក្នុងផលិតផលធាតុចេញ។

## ៤. គំរូកំណើន សូឡូ

គំរូកំណើនសេដ្ឋកិច្ចនេះត្រូវបានបង្កើតដោយលោក **រ៉ូប៊ែ សូឡូ** (Robert Solow) នៅចុងទសវត្សទី ៥០ ដើម្បីសិក្សាអំពីកំណើនសេដ្ឋកិច្ច ។ គំរូ **សូឡូ** បង្ហាញអោយឃើញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាង÷

- កំណើននូវកម្រិតជីវភាពរបស់ប្រទេសមួយ និង កត្តាសំខាន់ៗ ដូចជា អត្រាសញ្ចយ កំណើនប្រជាជន និង អត្រាវឌ្ឍនភាពនៃបច្ចេកវិទ្យា ។

- ការវិវត្តនៃកំណើនសេដ្ឋកិច្ច និង សន្ទុះរបស់វា ។

- កម្លាំងសេដ្ឋកិច្ច ដែលជម្រុញអោយប្រទេសដែលមានការអភិវឌ្ឍយឺត អាចឈានទៅទាន់ប្រទេសដែលចម្រើនលឿនលឿន ។

គំរូ **សូឡូ** សិក្សាពីកំណើនសេដ្ឋកិច្ចក្នុងរយៈពេលណាមួយ ដោយវិភាគទៅលើកំណើនពលកម្ម មូលធនទៅលើកំណើនសេដ្ឋកិច្ច ។ យើងចាប់ផ្តើមពីសមីការផលិតកម្មបូរាណនិយមបែបថ្មី $Y/L = F(K/L)$ ដោយយើងរៀបចំអោយក្លាយទៅជា $y = f(k)$ ។ អនុគមន៍នេះសន្មតថា កម្រៃដែលបានមកពីមូលធននឹងកាន់តែធ្លាក់ចុះ ។ យើងមានអញ្ញត្តិដូចតទៅ÷

$n$ = កំណើនប្រជាជន

$d$ = រំលស់

$k$ = សន្និធិមូលធនក្នុងពលករម្នាក់

$y$ = ធាតុចេញ ឬ ចំណូលរបស់ពលករម្នាក់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

L = កម្លាំងពលកម្ម

s = សញ្ជ័យ

យើងមានទំនាក់ទំនងដូចតទៅ៖

$y_t = Y_t/N_t$ ផលិតផលចេញរបស់ពលករម្នាក់នៅក្នុងឆ្នាំ t ។

$c_t = C_t/N_t$ ការប្រើប្រាស់របស់ពលករម្នាក់នៅក្នុងឆ្នាំ t ។

$k_t = K_t/N_t$ មូលធនរបស់ពលករម្នាក់នៅក្នុងឆ្នាំ t ។

យើងមានអនុគមន៍៖

$y_t = f(k_t)$

**រូបទី ២.១ ដ្យាក្រាមគំរូកំណើនរបស់សូឡូ**




អនុគមន៍ផលិតកម្មសម្រាប់ពលករម្នាក់ $y_t = f(k_t)$ គឺជាផលិតផលចេញរបស់ពលករម្នាក់ នៅក្នុងឆ្នាំ t ដែលអាស្រ័យលើបរិមាណនៃមូលធនសម្រាប់ពលករម្នាក់ ។ អនុបាតមូលធន-ពលកម្ម (បរិមាណមូលធនសម្រាប់ពលករម្នាក់) តាងដោយ $k_t$ ដែលវាស់នៅលើអ័ក្ស x ។

ប្រសិនបើគ្មានកំណើនផលិតភាពទេ នោះសេដ្ឋកិច្ចនឹងឈានទៅដល់ **ចំណុចនឹងថ្កល់** នៅត្រង់ **A** ពោល គឺស្ថានភាព ដែលធាតុចេញសម្រាប់ពលករម្នាក់ៗ ការប្រើប្រាស់សម្រាប់ពលករម្នាក់ៗ និង សន្និធិមូលធនសម្រាប់ពលករម្នាក់ៗនៅថេរ ពោលគឺនៅនឹងថ្កល់ ដែល $y_t$, $c_t$ និង $k_t$ នឹងមិនផ្លាស់ប្តូរទេ ។ គំរូសូឡូ គឺជាទំនាក់ទំនងប្រតិសកម្ម រវាងកម្លាំងសេដ្ឋកិច្ចចំនួនប្រាំ គឺ អនុគមន៍ផលិតកម្មម៉ាក្រូសេដ្ឋកិច្ចសមីការផលិតផលសរុបក្នុងស្រុក សមីការសញ្ចយ បន្លាស់ប្តូរមូលធន និង បន្លាស់ប្តូរកម្លាំងពលកម្ម ។

- អនុគមន៍ផលិតកម្មម៉ាក្រូ $Y = AK^a L^{1-a}$

$$Y = AK^a L^{1-a} \leftrightarrow y = Ak^a$$

- សមីការផលិតផលសរុបក្នុងស្រុក $Y = C + G + I + NX$

- សមីការសញ្ចយ $I = sY$

- បន្លាស់ប្តូរមូលធន

$\Delta K = sY - \delta K$ ដែល $\delta$ គឺជាអត្រារំលស់

- បន្លាស់ប្តូរកម្លាំងពលកម្ម

$L_{t+1} = L_t(1 + gL)$ ដែល **gL** គឺជាអនុគមន៍កំណើនរបស់ L។

តាមគំរូ សូឡូ បង្ហាញអោយឃើញថា កត្តាបីសំខាន់ៗដែលកំណត់នូវកំណើនសុខុមាលភាពរបស់ប្រទេសនៅក្នុងរយៈពេលវែង ÷ (១) **អត្រាសញ្ចយ**: កំណើនអត្រាសញ្ចយនឹងជម្រុញដល់ការវិនិយោគ និង ការបង្កើតសន្និធិមូលធនកាន់តែច្រើនទៅៗ ។ (២) **អត្រាកំណើនប្រជាជន**: ការកើនឡើងនៃកំណើនប្រជាជននឹងធ្វើអោយធាតុចេញ ការប្រើប្រាស់ និង មូលធនសម្រាប់ពលករម្នាក់នឹងធ្លាក់ចុះនៅក្នុងរយៈពេលវែង ដោយសារ នៅពេលដែលប្រជាជនកាន់តែកើនឡើង ធាតុចេញកាន់តែកើនឡើងនឹងត្រូវយកទៅប្រើប្រាស់ ដើម្បីបំពាក់អោយពលករ ។ ដូច្នេះ នៅសល់ធាតុចេញកាន់តែតិចទៅៗសម្រាប់ការប្រើប្រាស់ និង សម្រាប់បង្កើនមូលធនសម្រាប់ពលករម្នាក់ៗ ។ និង (៣) **ផលិតភាព**: កំណើនផលិតភាពនឹងនាំអោយធាតុចេញកើនឡើង ។ នៅពេលដែលចំណូលកើនឡើង សញ្ចយក៏កើនឡើង ហើយមូលធនក៏ចេះតែកើនឡើងដែរ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី៣

# រូបិយវត្ថុ និង អតិផរណា

## ១. ទ្រឹស្តីរូបិយវត្ថុបែបបរិមាណ

ក្នុងទ្រឹស្តីបូរាណនិយម បរិមាណរូបិយវត្ថុកំណត់តម្រូវការសរុប និង បន្តទៅទៀត តម្រូវការសរុបនេះកំណត់ថ្លៃ ។ ទ្រឹស្តីបូរាណនិយមអះអាងថា «ថ្លៃសមាមាត្រទៅនឹងបរិមាណរូបិយវត្ថុ» ។

ចំណុចចាប់ផ្តើមគឺ «សមីការពាណិជ្ជកម្ម» (The Equation of Exchange)។ ក្នុងរយៈពេលណាមួយមានចំនួនប្រតិបត្តិការដ៏ជាក់លាក់ (ពោល គឺ T = ចំនួន ទិញ/លក់) នៅក្នុងសេដ្ឋកិច្ច ។ បរិមាណរូបិយវត្ថុជាក់ស្តែងដែលត្រូវការចាំបាច់សម្រាប់គ្រប់ប្រតិបត្តិការក្នុងសេដ្ឋកិច្ច គឺគ្រាន់តែជាភាគរយនៃថ្លៃផលិតផល និង ការទិញសរុប ។ ខ្លឹមសារនេះ ឆ្លុះបញ្ចាំងជាសរុបនៅក្នុងសមីការពាណិជ្ជកម្ម (EE) ខាងក្រោម ÷

សមីការ ៣.១ $MV \equiv P_T T$

M ជាបរិមាណរូបិយវត្ថុ V ល្បឿនបង្វិលរូបិយវត្ថុក្នុងប្រតិបត្តិការ P សន្ទស្សន៍ថ្លៃទំនិញក្នុងប្រតិបត្តិការ និង T ចំនួនប្រតិបត្តិការ ។ ទំនាក់ទំនងនេះ គឺជារូបមន្តសម្គាល់តាមនិយមន័យនៃល្បឿនបង្វិល ។ ដូចនេះ បរិមាណរូបិយវត្ថុគុណនឹងល្បឿនបង្វិលរបស់វា ស្មើនឹង ថ្លៃ គុណនឹងទំហំប្រតិបត្តិការ ។

ការបង្ហាញសមីការនេះ (សមីការ ៣.១) គឺជាលក្ខណៈសម្គាល់ដែលក្នុងនោះ V ត្រូវបានយកជាសំណល់ ពោលគឺ ÷

សមីការ ៣.២ $V_T \equiv \frac{P_T T}{M}$

សំខាន់ជាងនេះទៀតក្នុងប្រតិបត្តិការនេះមានបញ្ចូលមិនត្រឹមតែទំនិញ និង សេវាផលិតថ្មីទេប៉ុន្តែថែមទាំងទំនិញប្រើរួចហើយ ។ ពាក់ព័ន្ធចំពោះតែទំនិញ និង សេវាផលិតថ្មីដែលមានទំនាក់ទំនងទៅនឹងចំណូលនៃកត្តាផលិតកម្ម នោះសមីការប្តូរ (EE) គឺ :

សមីការ ៣.៣ $MV \equiv PY$ ដែល Y ជាផលិតផលទំនិញ និង សេវាបច្ចុប្បន្ន

P ជាសន្ទស្សន៍ថ្លៃរបស់ទំនិញ និង សេវាទាំងនោះ ។

បញ្ជាក់ម្តងទៀតថា EE គឺជារូបមន្តសម្គាល់ (តំណាង) ប្រសិនបើ V ត្រូវបានគណនាជាសំណល់ ពោលគឺ ÷


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សមីការ ៣.៤ $V \equiv \frac{PY}{M}$

សេដ្ឋវិទូមួយចំនួនរួមទាំង **អេវីង ហ្វីស្ស័រ** (Irving Fisher) បានប្រឹងប្រែងពន្យល់ពីតម្លៃនៃអថេរនីមួយៗរបស់វា ដោយផ្ដែកលើកត្តាឯករាជ្យលើកលែងតម្លៃអថេរ P ។ ដំបូងដូចយើងបានឃើញថានៅក្នុងគំរូបូរាណនិយម ធាតុចេញពិត Y ត្រូវបានកំណត់ដោយកត្តាផ្គត់ផ្គង់ (ឧទាហរណ៍ K, MPN, N, W/P បច្ចេកវិទ្យា និង ប្រជាជន) ។ ជាងនេះទៀត រូបិយវត្ថុត្រូវបានចាត់ទុកថា ជាមធ្យោបាយដោះដូរ ហើយបរិមាណរបស់វាត្រូវបានកំណត់ដោយឯករាជ្យពីអាជ្ញាធររូបិយវត្ថុ ពោលគឺធនាគារកណ្ដាល ។

V ក៏ត្រូវបានចាត់ទុកថាកំណត់ដោយឯករាជ្យពីទំលាប់ទូទាត់ (ប្រចាំសប្ដាហ៍ ពីរសប្ដាហ៍ ប្រចាំខែ) និងបច្ចេកវិជ្ជាទូទាត់ ឧទាហរណ៍ មូលប្បទានប័ត្រកំណត់លក់ (point of sale) ប័ណ្ណឥណទាន ឬ ប័ណ្ណឥណពន្ធ ។ ដូចនេះរយៈពេលទូទាត់កាន់តែឆាប់ នោះសាច់ប្រាក់នៅនឹងបុគ្គលម្នាក់ៗកាន់តែតិច ដែលធ្វើឱ្យកើនល្បឿនវង្វិលរូបិយវត្ថុ ។ ដូចគ្នានេះដែរ ការទិញដោយមូលប្បទានប័ត្រ និង ឥណទាន មាននិន្នាការទៅរកការកើនឡើងល្បឿនបង្វិល ពោលគឺ ចំនួនសាច់ប្រាក់កាន់តែតិច ដែលធ្វើហិរញ្ញប្បទានប្រតិបត្តិការ ។ ជារួមល្បឿនវង្វិលកំណត់ដោយកត្តាស្ថាប័នដែលអាចចាត់ទុកមិនប្រែប្រួល ក្នុងរយៈពេលខ្លី ។ ប្រសិនបើ V កំណត់ដោយឯករាជ្យ មិនមែនជាសំណល់នោះ EE លែងជាសមីការសម្គាល់ហើយ ។ ក្នុង រយៈពេលខ្លីបើ Y នៅថេរដោយសារកត្តាផ្គត់ផ្គង់ និង V នៅថេរដោយសារកត្តាស្ថាប័ននោះ EE ក្លាយជា ÷

សមីការ ៣.៥ $M\overline{V} = P\overline{Y}$

ឬ សមីការ ៣.៦ $P = \frac{\overline{V}}{\overline{Y}}M$

ដូចនេះ **ហ្វីស្ស័រ** បានលើកឡើងថាតាមលក្ខណៈដែលបានសន្មតយើងពិនិត្យឃើញកម្រិតថ្លៃប្រែប្រួល (១) ដោយត្រង់ដូចនឹងបរិមាណរូបិយវត្ថុចរាចរ (M) (២) ដោយត្រង់ដូចនឹងល្បឿនបង្វិលរូបិយវត្ថុក្នុងចរាចរ (V) ៣) បញ្ច្រាសនឹងបរិមាណពាណិជ្ជកម្មដែលបានធ្វើ ។ ទំនាក់ទំនងទី១ក្នុងចំណោមទំនាក់ទំនងទាំងបីខាងលើមានសារៈសំខាន់ជាងគេ វាបង្កើតនូវ *«ទ្រឹស្ដីបរិមាណរូបិយវត្ថុ»* ។ ប្រការនេះបញ្ជាក់ថាកម្រិតថ្លៃអាស្រ័យលើការផ្គត់ផ្គង់រូបិយវត្ថុ ។ ការបង្កើន M ពីរដងធ្វើឱ្យ P កើនពីរដង ។ នេះជាលទ្ធផលមូលដ្ឋាន នៃ *«ទ្រឹស្ដីបរិមាណរូបិយវត្ថុ»* ÷ *បរិមាណរូបិយវត្ថុកំណត់ថ្លៃ* ។

ធាតុចេញ (ឬប្រតិបត្តិការ) គឺជារង្វាស់នៃសកម្មភាពសេដ្ឋកិច្ចពិត ។ តាម **ហ្វីស្ស័រ**កម្រិតសមតាត្រូវបានកំណត់ ដោយកត្តាស្ថាប័នបែបនេះ និង អាចចាត់ទុកថានៅថេរក្នុងរយៈពេលខ្លី ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ២. វិធីសាស្ត្រខេមប្រ៊ីជស្តីពីបរិមាណរូបិយវត្ថុ

ការបកស្រាយផ្សេងទៀតត្រូវបានផ្តល់ដោយសាលា**ខេមប្រ៊ីជ** ដែលត្រូវបានគេសម្គាល់ថា ជាវិធីសាស្ត្រ **ខេមប្រ៊ីជ** ឬ វិធីសាស្ត្រសមតុល្យសាច់ប្រាក់**ខេមប្រ៊ីជ** ។ វិធីសាស្ត្រនេះឱ្យដឹងថា ប្រជាជនរក្សាទុកប្រាក់ (សមតុល្យសាច់ប្រាក់) ងាយស្រួលជាងរក្សាទុកវត្ថុមានតម្លៃផ្សេងទៀតសម្រាប់ធ្វើប្រតិបត្តិការដោះដូរ ។ ប៉ុន្តែរក្សាទុកសាច់ប្រាក់មានន័យថា នឹងមិនទទួលបានប្រយោជន៍ពីការវិនិយោគ ក្នុងសកម្មភាពដែលមានផលចំណេញទេ ។

**អាល់ហ្វ្រេត ម៉ារស្សាល់** និង **ពីហ្គូ** ក៏បានលើកបង្ហាញពីទំនាក់ទំនងសមាមាត្រ រវាងបរិមាណរូបិយវត្ថុ និងថ្លៃសរុប ។ **ម៉ារស្សាល**បានសិក្សាដោយផ្តោតលើការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗអំពីបរិមាណរូបិយវត្ថុដ៏សមស្របត្រូវរក្សាទុកៈ (១)ភាពងាយស្រួលក្នុងប្រតិបត្តិការ បើប្រៀបធៀបនឹងវត្ថុមានតម្លៃផ្សេងទៀត និង (២) សុវត្ថិភាពតាមរយៈការកាត់បន្ថយលទ្ធភាពជួបការលំបាក ឬ ធនក្ស័យដោយសារគ្មានលទ្ធភាពសងដោយចៃដន្យ ។ ប៉ុន្តែដូច **ពីហ្គូ** បានកត់សម្គាល់ថា *«រូបិយវត្ថុទុកក្នុងដៃមិនផ្តល់ចំណូលទេ»* ដូចនេះ រូបិយវត្ថុត្រូវបានរក្សាទុកក្នុងដៃក្នុងកម្រិតដែលប្រយោជន៍នៃភាពងាយស្រួល និង សុវត្ថិភាពមានច្រើនជាងចំណូល ដែលបាត់បង់ពីការមិនវិនិយោគក្នុងសកម្មភាពមានផលចំណេញ ។

**ម៉ារស្សាល** និង សេដ្ឋវិទូ **ខេមប្រ៊ីជ** ដទៃទៀត បានសន្មតថា តម្រូវការរូបិយវត្ថុអាចជាចំណែកមួយនៃប្រាក់ចំណូល ។ សមីការ **ខេមប្រ៊ីជ**ត្រូវបានសរសេរដូចខាងក្រោម ÷

សមីការ ៣.៧ $M^d = kPY$

$M^d$ = តម្រូវការរូបិយវត្ថុ

$k$ = ភាគចំណែកនៃចំណូលតាមថ្លៃទីផ្សារ

$P$ = កម្រិតថ្លៃ

$Y$ = ចំណូលពិត

តម្រូវការរូបិយវត្ថុ (M) សន្មតថាជាភាគចំណែកមួយ (k) នៃចំណូលតាមថ្លៃទីផ្សារ និង ថ្លៃ (P) គុណនឹងបរិមាណចំណូលពិត (Y) ។ ចំណែកនៃចំណូលដែលសមរម្យត្រូវរក្សាទុកក្នុងទម្រង់ជារូបិយវត្ថុ (K) ត្រូវបានសន្មតថា មិនប្រែប្រួលក្នុងរយៈពេលខ្លីដោយអាស្រ័យលើទម្លាប់ទូទាត់នៃសង្គម ។ គេចង់បានសាច់ប្រាក់ដោយសារវាមានប្រយោជន៍ ក្នុងប្រតិបត្តិការ និង បរិមាណប្រតិបត្តិការជាអនុគមន៍នៃចំណូល ដូចនេះ តម្រូវការរូបិយវត្ថុប្រែប្រួល ដោយស្របនឹងកម្រិតចំណូល ។ សំខាន់គឺតម្រូវការរូបិយវត្ថុ ជាអនុគមន៍នៃចំណូលរបស់វា ។

ជាសមតា ការផ្គត់ផ្គង់រូបិយវត្ថុ (ដែលកំណត់ដោយអាជ្ញាធររូបិយវត្ថុដោយឯករាជ្យ) ស្មើនឹងតម្រូវការរូបិយវត្ថុ ឬ÷


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សមីការ ៣.៨ $Ms = Md = kP\bar{Y}$

k សន្មតថាថេរក្នុងរយៈពេលខ្លី និងគេស្គាល់ថាជា **អញ្ញត្តិថេរខេមប្រ៊ីជ** ។

Y ដូចបានបញ្ជាក់រួចហើយកំណត់ដោយកត្តាផ្គត់ផ្គង់ ។

វិធីរបស់ **ហ្វីស្ស៊ែរ** (សមីការ ៣.៥) និងវិធី **ខេមប្រ៊ីជ** (សមីការ ៣.៧) មានលក្ខណៈ ដូចគ្នាទាំងស្រុងបើ V = 1/k ដូចនេះប្រសិនបើប្រជាជនរក្សាទុក ¼ នៃចំណូលតាមថ្លៃទីផ្សាររបស់ពួកគេជាសាច់ប្រាក់ នោះចំនួនដងនៃប្រាក់មធ្យមត្រូវប្រើស្មើ ៤ ។

ដូចក្នុងវិធីសាស្ត្រ **ហ្វីស្ស៊ែរ** បរិមាណរូបិយវត្ថុកំណត់កម្រិតថ្លៃ ។ សមីការប្តូរតាមរបៀប **ហ្វីស្ស៊ែរ** អាចមានទម្រង់ដូចខាងក្រោម ÷

$Md\ 1/k = P\bar{Y}$

ការប្រែប្រួលដ៏ធំនៃវិធីសាស្ត្រ**ខេមប្រ៊ីជ** គឺការចាប់ផ្តើមជាផ្លូវការអំពីតម្រូវការរូបិយវត្ថុ ។ វាក៏មានការវាយតម្លៃផលប៉ះពាល់បរិមាណរូបិយវត្ថុលើថ្លៃ (រូប ៣.១) ។ ប្រសិនបើបរិមាណរូបិយវត្ថុកើនឡើង ប៉ុន្តែផាតុចេញនៅថេរ នោះប្រជាជននឹងយកសាច់ប្រាក់ដែលលើសទៅប្រើប្រាស់ ឬ វិនិយោគ ។ តម្រូវការទំនិញកើនឡើង ធ្វើឱ្យទំនិញឡើងថ្លៃ ***រូបិយវត្ថុយ៉ាងច្រើនស្វែងរកទំនិញទំនិញដែលមានតិចតួច*** ។ ប្រសិនបើ Y ថេរ (រូប ៣.២) ដូចបានសន្មតក្នុងគំរូបុរាណនិយម និង K ជាចំនួនថេរ នោះសមតាថ្មីកើតមាននៅត្រង់កន្លែងដែលកំណើនរូបិយវត្ថុ នាំឱ្យថ្លៃកើនជាសមាមាត្រ មានន័យថា ***ផាតុចេញនៅដដែលថ្លៃកើនឡើង*** ពោលគឺ **អតិផរណា** ។

**រូប ៣.១ ខ្សែកោងតម្រូវការសរុបបុរាណនិយម**






fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិធី **ខេមប្រ៊ីជ** ជាជំហានឈានទៅរកទ្រឹស្ដីរូបិយវត្ថុកាន់តែទំនើប ។ **កេនស៍** បានប្រឆាំងជំទាស់នឹងទ្រឹស្ដីបរិមាណដោយផ្ដល់នូវទ្រឹស្ដីតម្រូវការរូបិយវត្ថុបែបថ្មី ។ អ្នករូបិយវត្ថុនិយមក៏យកទ្រឹស្ដីបរិមាណរបស់ **ខេមប្រ៊ីជ** ជាចំណុចចាប់ផ្ដើមសម្រាប់ទ្រឹស្ដីតម្រូវការរូបិយវត្ថុរបស់ពួកគេដែរ ។

ទ្រឹស្ដីបរិមាណជាទ្រឹស្ដីនៃតម្រូវការសរុបដ៏សាំញ៉ាំសម្រាប់ផាតុចេញ នៅក្នុងប្រព័ន្ធបុរាណនិយម (រូប៣.២)។

ឧបមាថា រូប ៣.១ ផ្គត់ផ្គង់នៅថេរ ដូចនេះចំពោះគ្រប់បរិមាណរូបិយវត្ថុ (M1) នឹងមានតម្រូវការរបស់វានីមួយៗដែលខុសពីកម្រិតថ្លៃដោយបញ្រ្ចាស ពោលគឺ ខ្សែកោងតម្រូវការជ្រាលចុះ ហើយនឹងមានសមតា កម្រិតថ្លៃដែល *«ជាត់ទាត់ទីផ្សារ»* ពោលគឺតម្រូវការស្មើផ្គត់ផ្គង់ ។ ប្រសិនបើបរិមាណរូបិយវត្ថុ (M2) កើនឡើង ខ្សែកោងតម្រូវការនឹងរំកិលទៅស្ដាំពោលគឺ ក្នុងកម្រិតថ្លៃដូចគ្នា តម្រូវការនឹងកើន ប៉ុន្តែបញ្ជាក់ម្ដងទៀតថាផ្គត់ផ្គង់នៅថេរ ។ សមតាថ្មីនឹងមាននៅត្រង់បរិមាណផាតុចេញ ដូចគ្នា ប៉ុន្តែថ្លៃខ្ពស់ជាង ។

ការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង ធ្វើឱ្យរំកិលខ្សែកោងតម្រូវការសរុបទៅខាងស្ដាំ ។ ការប្រែប្រួលបរិមាណរូបិយវត្ថុគឺ ជាកត្តាតែមួយគត់ដែលរំកិលខ្សែកោងតម្រូវការសរុប ព្រោះសមតាតម្លៃ k (ឬ V) ត្រូវបានចាត់ទុកថានៅថេរក្នុងរយៈកាលខ្លីហើយតម្រូវការសរុបគ្រាន់តែខុសពីផ្គត់ផ្គង់រូបិយវត្ថុ ។

**រូប ៣.២ ការផ្គត់ផ្គង់ និង តម្រូវការសរុបនៅក្នុងប្រព័ន្ធបុរាណនិយម**




## ៣. អត្រាការប្រាក់

នៅក្នុងប្រព័ន្ធបុរាណនិយម សមាសធាតុនៃតម្រូវការទំនិញមានការប្រើប្រាស់វិនិយោគ និង ចំណាយរដ្ឋាភិបាល ដែលដើរតួនាទីយ៉ាងច្បាស់លាស់ក្នុងការកំណត់អត្រាការប្រាក់ ។ អត្រាការប្រាក់នេះធានាថា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការប្រែប្រួលដោយឯករាជ្យនៅក្នុងសមាសធាតុជាក់លាក់ណាមួយនៃតម្រូវការ មិនប៉ះពាល់ដល់បរិមាណតម្រូវការទំនិញសរុបទេ ។

**រូប ៣.៣ ការកំណត់អត្រាការប្រាក់នៅក្នុងប្រព័ន្ធបុរាណនិយម**




នៅក្នុងទ្រឹស្តីបុរាណនិយម ដោយប្រើវិធី **ខេមប្រ៊ីដ** អត្រាការប្រាក់ (ថ្លៃរូបិយវត្ថុ) វាស់ចំណាយ នៃការរក្សាទុកសាច់ប្រាក់ ។ ចំពោះគ្រប់កម្រិតនីមួយៗនៃ k បុគ្គលនីមួយៗមានអ្វីដែលហៅថា *«មូលនិធិអាចឱ្យខ្ចីបាន»* ដែលលើសពីតម្រូវការរូបិយវត្ថុរបស់គេសម្រាប់ប្រើក្នុងគោលដៅប្រតិបត្តិការសាច់ប្រាក់ គេអាចរក្សាទុកមូលនិធិដូចជាវត្ថុមានតម្លៃ ប៉ុន្តែវាមិនកើនប្រាក់ចំណេញទេ ។ ដូចនេះបុគ្គលម្នាក់ៗមានបំណងរក្សាទុករូបិយវត្ថុលើសរបស់គេជាមូលបត្រដែលមានការប្រាក់ ។ គំរូបុរាណនិយមចាត់ទុកថាបុគ្គលដែលមានវិចារណៈញ្ញាណ មិនរក្សាទុករូបិយវត្ថុសល់របស់ខ្លួន ក្នុងទម្រង់ជាសាច់ប្រាក់ទេ ។

ក្រុមហ៊ុនខ្ចីទុនពីបុគ្គលម្នាក់ៗដើម្បីសង់រោងចក្រ និង ឧបករណ៍ថ្មី ដែលនៅចុងក្រោយបំផុតនឹងកើន Y ។ ប៉ុន្តែរាល់ការវិនិយោគ មានពាក់ព័ន្ធនឹងអត្រាផលចំណេញដ៏សមស្រប ។ ក្រុមហ៊ុនអាចរកចំណេញលើការវិនិយោគ ប្រសិនបើអត្រានៃផលចំណេញ ពីវិនិយោគនោះច្រើនជាង **ថ្លៃឱកាស** (Opportunity Cost) រូបិយវត្ថុ ពោលគឺអត្រាការប្រាក់ ។ គម្រោងដែលមានអត្រាចំណេញខ្ពស់ជាងអត្រាការប្រាក់គួរត្រូវបានអនុវត្ត និង ទន្ទឹមនឹងនេះ គម្រោងដែលមានអត្រាចំណេញទាបជាងអត្រាការប្រាក់ បច្ចុប្បន្នមិនគួរត្រូវបានគេអនុវត្តទេ (រូប ៣.៣) ។

តម្រូវការទុនដែលអាចឱ្យខ្ចីមានលក្ខណៈខុសគ្នា និង បញ្ច្រាស់ពីអត្រាការប្រាក់ ។ ដូចគ្នានេះដែរ គឺមានផ្គត់ផ្គង់មូលនិធិអាចឱ្យខ្ចីដែលផ្សេងៗពីគ្នា និង ស្របជាមួយនឹងអត្រាការប្រាក់ ពោលគឺខ្សែកោងផ្គត់ផ្គង់ទេរឡើងលើ ។ សមតាសម្រេចបាននៅត្រង់ខ្សែកោងពីរកាត់គ្នា ហើយការប្រែប្រួលដោយឯករាជ្យ ក្នុងលក្ខខណ្ឌ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តម្រូវការ មានបង្ហាញនៅក្នុងរូប ៣.៤ ។ ប្រសិនបើតម្រូវការរំកិលទៅឆ្វេង ដំបូងការផ្គត់ផ្គង់មូលនិធិអាចឱ្យខ្ចីមានទំហំធំជាងតម្រូវការ ដែលធ្វើឱ្យអត្រាការប្រាក់ធ្លាក់ចុះរហូតដល់មានសមតាថ្មី ។

អត្រាការប្រាក់ដើរតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងគំរូបុរាណនិយម ក្នុងការបញ្ជាក់អនិកម្មភាពពេញលេញ ។ ធាតុចេញនៅថេរ និង ផ្នែកលើកត្តាផ្គត់ផ្គង់ ជាពិសេស ទីផ្សារពលកម្ម ដែលកែតម្រូវដោយខ្លួនឯង ។ ការធ្លាក់ចុះអត្រាការប្រាក់ក្នុងរូប ៣.៤ ធ្វើឱ្យការប្រើប្រាស់កើន ដោយធ្វើឱ្យផាត់ទាត់ជាមួយការធ្លាក់ចុះវិនិយោគ និង រក្សាតម្រូវការឯករាជ្យសរុប ( C + I) នៅដដែល ។

**រូប ៣.៤ ការធ្លាក់ចុះជាស្វ័យប្រវត្តិនៃតម្រូវការវិនិយោគ**




សមតាអត្រាការប្រាក់ក្នុងទ្រឹស្តីបុរាណនិយម គឺនៅត្រង់កម្រិតចំនួនមូលនិធិដែលបុគ្គលម្នាក់ៗចង់ឱ្យខ្ចីស្មើនឹងចំនួនមូលនិធិដែលអ្នកដទៃចង់ខ្ចី ។

ចំណាយវិនិយោគផ្សេងៗគ្នាដោយបញ្រ្ចាស់ជាមួយអត្រាការប្រាក់ ។ សេដ្ឋវិទូបុរាណនិយម បានពន្យល់ទំនាក់ទំនងនេះ ដូចតទៅ៖

ក្រុមហ៊ុនមួយអាចមានគម្រោងវិនិយោគមួយចំនួន ដែលផ្តល់នូវប្រាក់ចំណេញរំពឹងទុកផ្សេងៗគ្នា ហើយគេអាចដាក់ចំណាត់ថ្នាក់គម្រោងទាំងនេះ តាមលំដាប់នៃប្រាក់ចំណេញរំពឹងទុក រីឯអត្រាការប្រាក់តំណាងឱ្យថ្លៃនៃការខ្ចីបុលមូលនិធិដើម្បីហិរញ្ញប្បទានគម្រោងវិនិយោគទាំងនេះ ។ នៅពេលដែលចំណាយខ្ចីបុលទាប គម្រោងជាច្រើនបន្ទាប់ពីដកចំណាយការប្រាក់នឹងមានចំណេញ ហើយវិនិយោគនឹងកើនឡើង ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាក់មួយដុល្លារដែលសន្សំទុកពេលនេះ នឹងចំណេញបានការប្រាក់ខ្ពស់ជាង និង អ្នកសន្សំមានលទ្ធភាពកាន់តែធំក្នុងការប្រើប្រាស់ទំនិញនៅពេលអនាគត ។ សេដ្ឋវិទូបុរាណនិយមចាត់ទុកថា រូបវន្តបុគ្គលអាចមានប្រៀបក្នុងការជ្រើសយកជម្រើសដ៏ពេញចិត្ត ហើយគេអាចសន្សំបានច្រើនដោយមានអត្រាការប្រាក់ខ្ពស់ជាង ។

ប៉ុន្តែការសន្សំមិនចាំបាច់ដាក់ក្នុងសញ្ញាប័ណ្ណទេ រូបិយវត្ថុក៏រក្សាជាសម្បត្តិដ៏មានសក្តានុពល ព្រោះរូបិយវត្ថុមិនមានបង់ការប្រាក់ទេ អ្នកសេដ្ឋវិទូបុរាណនិយមចាត់ទុកថាសញ្ញាប័ណ្ណអាចត្រូវបានគេនិយមរក្សាទុកជាទ្រព្យសម្បត្តិ ។

សេដ្ឋវិទូបុរាណនិយមជឿជាក់ថា នៅក្នុងស្ថានភាពមិនអំណោយផលជារួមប្រជាជនអាចផ្ទេរទ្រព្យសម្បត្តិទៅជាទម្រង់រូបិយវត្ថុ ។ ក្នុងរយៈកាលបែបនេះមានការរំជើបរំជួល និង ក្ស័យធននៅក្នុងវិស័យធនាគារ ហើយប្រជាជនអាចព្រួយបារម្ភអំពីការខកខានមិនអាចទូទាត់សញ្ញាប័ណ្ណ និង *«ការប្រមូលទុក»* រូបិយវត្ថុ ប៉ុន្តែនៅពេលធម្មតា អ្នកបុរាណនិយមបានចាត់ទុកថា ***ការសន្សំជាតម្រូវការសម្រាប់សញ្ញាប័ណ្ណ*** ។

សមតាអត្រាការប្រាក់ដំបូងនៅត្រង់ $r_0$ បន្ទាប់ពីការធ្លាក់ចុះវិនិយោគ ការផ្គត់ផ្គង់មូលនិធិអាចខ្ចីលើសពីតម្រូវការ ដែលនាំឱ្យដាក់សំពាធលើអត្រាការប្រាក់ ។ នៅខណៈដែលអត្រាការប្រាក់ធ្លាក់ចុះ មានការកែតម្រូវពីរយ៉ាងគឺៈ ទីមួយសញ្ជ័យថយចុះ ធ្វើឱ្យការប្រើប្រាស់កើនឡើង ហើយបរិមាណនៃការធ្លាក់ចុះសញ្ជ័យនេះ និង ការកើនឡើងដោយស្មើគ្នានៃតម្រូវការប្រើប្រាស់បច្ចុប្បន្នត្រូវបានបង្ហាញ ដោយប្រវែងដែលតាងដោយអក្សរ A នៅក្នុងរូប ។ ទីពីរ វិនិយោគមានសកម្មភាពរីកដុះដាល ដោយសារការធ្លាក់ចុះអត្រាការប្រាក់ និង ការកើនវិនិយោគ ដោយសារអត្រាការប្រាក់នេះត្រូវបានវាស់ដោយចំងាយ B ក្នុងរូប ។ សមតាមាននៅត្រង់អត្រាការប្រាក់ $r_1$ ដែលសញ្ជ័យ (ការផ្គត់ផ្គង់មូលនិធិអាចឱ្យខ្ចី) ស្មើនឹងវិនិយោគ (តម្រូវការមូលនិធិអាចឱ្យខ្ចី) ម្តងទៀត ។

*តួនាទីស្និទ្ធភាពរបស់បន្ទីយកម្មរបស់អត្រាប្តូរប្រាក់មានសារៈសំខាន់ណាស់ ចំពោះប្រព័ន្ធបុរាណនិយម ។ ការកែតម្រូវអត្រាការប្រាក់ គឺ ជាខ្សែត្រៀមជួរមុខដើម្បីការពារអនិកម្មភាពពេញលេញ* ។ វិបត្តិដែលប៉ះពាល់ដល់តម្រូវការប្រើប្រាស់តម្រូវការវិនិយោគ ឬ តម្រូវការរដ្ឋាភិបាល នឹងមិនប៉ះពាល់ដល់តម្រូវការផលិតផលទាំងស្រុងទេ។ វិបត្តិទាំងនេះនឹងមិនរំកិលខ្សែកោងតម្រូវការសរុបក្នុងរូប ៣.៣ ទោះបីជាមាន ក៏មិនជះឥទ្ធិពលលើធាតុចេញ ឬ និកម្មភាពដែរ ពីព្រោះដោយសារមានលក្ខណៈកែតម្រូវដោយខ្លួនឯងនៃទីផ្សារពលកម្មបុរាណនិយម ដូចមានតាងនៅខ្សែកោងផ្គត់ផ្គង់សរុប ដែលមានរាងបញ្ឈរ ពោលគឺខ្សែត្រៀមជួរទីពីរដើម្បីការពារអនិកម្មភាពពេញលេញ ។

## ៤. ទ្រឹស្តីកេនស៍និយម

តម្រូវការរូបិយវត្ថុសរុបនៅក្នុងគំរូ **កេនស៍និយម** ឬ MD = TD + PD + SD ដែល TD និង PD ប្រែប្រួលជាវិជ្ជមានជាមួយប្រាក់ចំណូល និងជាអវិជ្ជមានជាមួយនឹងអត្រាការប្រាក់ ខណៈដែល SD មិនប្រែប្រួលទៅតាមប្រាក់ចំណូលទេ ប៉ុន្តែវាប្រែប្រួលជាអវិជ្ជមានជាមួយនឹងអត្រាការប្រាក់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**រូប ៣.៥ ឧស្សនកេនស៍និយមស្ដីពីផលប៉ះពាល់នៃកំណើនចំណាយរដ្ឋាភិបាល**




ដោយបូកកត្តាទាំងអស់នេះបញ្ចូលគ្នា យើងបាន ÷

សមីការ ៣.៩ $Md = L(Y, r)$

ហើយប្រសិនបើយើងសន្មតថាអនុគមន៍នេះជាខ្សែបន្ទាត់ នោះយើងបាន÷

សមីការ ៣.១០ $Md = co + c1Y – c2r$ ដែល $c1 > 0, c2 > 0$ ក្នុងនោះ÷

c0 ជាបរិមាណរូបិយវត្ថុអប្បបរមាដែលត្រូវរក្សាទុក

c1 ជាកំណើនរូបិយវត្ថុ ក្នុងមួយឯកតានៃកំណើនប្រាក់ចំណូល និង

c2 ជាការធ្លាក់ចុះនៃរូបិយវត្ថុ ក្នុងមួយឯកតានៃកំណើនអត្រាការប្រាក់ ។

ក្រុមហ៊ុនខ្ចីរូបិយវត្ថុពីគេហជន ដើម្បីធ្វើហិរញ្ញប្បទានគម្រោងវិនិយោគ ដោយបោះផ្សាយសញ្ញាប័ណ្ណ (ដែលជំនួសទ្រព្យសកម្មទាំងអស់ដែលផ្ដល់ការប្រាក់) ។ ថ្លៃដែលត្រូវបង់សម្រាប់រូបិយវត្ថុនេះ គឺ អត្រាការប្រាក់។ **កេនស៍**បានសន្មតថា ក្រុមហ៊ុនមានតារាងកម្មវិធីវិនិយោគ ដែលអាចវាស់វែងពីអត្រានៃប្រាក់ចំណេញសង្ឃឹមទុក ដែលនឹងទទួលបានពីគម្រោងផ្សេងៗ ដោយផ្ទៀងផ្ទាត់នឹងអត្រាការប្រាក់ ។ ប្រសិនបើប្រាក់ចំណេញសង្ឃឹមទុក


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដកថ្លៃដើមនៃរូបិយវត្ថុជាចំនួនវិជ្ជមាន នោះ ប្រសិនបើកត្តាផ្សេងទៀតនៅថេរ ក្រុមហ៊ុននឹងអនុវត្តគម្រោងនេះ។ ផ្ទុយទៅវិញ ប្រសិនបើលទ្ធផលអវិជ្ជមាន នោះគម្រោងនេះនឹងមិនត្រូវបានអនុវត្តឡើយ ។ ប្រការនេះហៅថា «**អត្រាពិតនៃផលចំណេញ**» ។

**រូប ៣.៦ ទស្សនៈគេនស៍និយមស្តីពីការគ្មានប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុ**




ប្រសិនបើអត្រាការប្រាក់កើនឡើង នោះឥណទានសម្រាប់អាជីវកម្មនឹងថយចុះ ។ ប្រសិនបើអត្រាការប្រាក់ថយចុះ នោះឥណទាននឹងកើនឡើង (រូបភាព ៣.៦) ។ ប្រសិនបើការវិនិយោគកើនឡើង នោះចំណាយសរុបនឹងរំកិលឡើងលើ ដោយសារកំណើនដោយស្វ័យប្រវត្តិនៃ I ។ កំណើនតាមរយៈមេគុណចំណាយសរុបនេះ នឹងនាំឱ្យមានកំណើនយ៉ាងខ្លាំងជាងនេះនៃប្រាក់ចំណូល ។ ដូច្នេះហើយ វេយិតភាពនៃតម្រូវការសរុបចំពោះអត្រាការប្រាក់មានសារសំខាន់ ក្នុងការកំណត់គោលនយោបាយរូបិយវត្ថុដ៏សមស្រប ។

ជាក់ស្តែង អត្រាការប្រាក់ត្រូវបានកំណត់ដោយកត្តាទីផ្សារពីរប្រភេទផ្សេងគ្នា។ ទីមួយគឺទីផ្សារសញ្ញាប័ណ្ណ។ ទីពីរ គឺទីផ្សាររូបិយវត្ថុខ្លួនឯង ។ ដូច្នេះ ការរក្សាទុកទ្រព្យសម្បត្តិ (Wh = ទ្រព្យសកម្ម) ជារូបិយវត្ថុ ឬ ជាសញ្ញាប័ណ្ណ (ទ្រព្យសកម្មដែលបានការប្រាក់) នោះយើងបាន ÷

សមីការ ៣.១១ $Wh = M + B$


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រការនេះមានន័យថា មានទីផ្សាររូបិយវត្ថុពីរផ្សេងគ្នាៈ ទីផ្សារមួយ- ជាទីផ្សាររូបិយវត្ថុខ្លួនឯង និងមួយទៀតជាទីផ្សារហិរញ្ញប្បទានវិនិយោគ ។ តាមគំរូ**កេនស៍** ចំណុចសមតារួមនឹងត្រូវបង្កើតឡើងដោយទំនាក់ទំនងប្រតិសកម្មរវាងទីផ្សាររូបិយវត្ថុទាំងពីរនេះ ។

## *៤.១. - ខ្សែកោង LM*

ខ្សែកោងទីមួយ ត្រូវបានកំណត់ដោយខ្សែកោង LM (តម្រូវការសាច់ប្រាក់) ។ រូបភាព ៣.៦ បង្ហាញនូវចំណុចសមតានៅក្នុងទីផ្សាររូបិយវត្ថុ ដោយមាន $M^s_0$ និងចំណូលផ្សេងៗ Y (0, ១, ២) ។ ចំណុចសមតា $Y_0$ កើតឡើង នៅពេលដែល $r_0$ ។ ប្រសិនបើ Y កើនឡើងដល់ $Y_1$ នោះតម្រូវការប្រតិបត្តិការនឹងកើនឡើង ប៉ុន្តែដោយសារការផ្គត់ផ្គង់សាច់ប្រាក់នៅថេរ កំណើនតម្រូវការនេះនឹងបង្កើនតម្លៃសាច់ប្រាក់ ពោលគឺ អត្រាការប្រាក់នឹងកើនឡើងពី $r_0$ ទៅ $r_1$ ។ កំណើននៃការប្រាក់នេះនឹងកាត់បន្ថយតម្រូវការសាច់ប្រាក់ដើម្បីកេងយកចំណេញ និងកាត់បន្ថយតម្រូវការប្រតិបត្តិការ នៅគ្រប់កម្រិតនៃ Y (ថ្លៃឱកាស (Opportunity costs) កើនឡើង នាំឱ្យការគ្រប់គ្រងសាច់ប្រាក់ត្រូវបានកែលម្អ និង កាត់បន្ថយតម្រូវការសម្រាប់ប្រតិបត្តិការ) ។ ចំណុចសមតាត្រូវបានបង្កើតឡើងវិញ នៅពេលដែលកំណើនតម្រូវការប្រតិបត្តិការ ដោយសារកំណើននៃ Y ត្រូវបានផាត់ទាត់ដោយសារការធ្លាក់ចុះនៃតម្រូវការប្រតិបត្តិការ និងតម្រូវការដើម្បីកេងយកចំណេញ ដែលបណ្តាលមកពីកំណើននៃអត្រាការប្រាក់ ។ ដោយទុកអោយ Y ប្រែប្រួល យើងអាចគណនាចំណុចមួយចំនួនបាន ( A, B, C) ដោយសារការផ្គត់ផ្គង់រូបិយវត្ថុនៅថេរ និង កំណើន Y អត្រាការប្រាក់សមតាថ្មីមួយត្រូវបានបង្កើតឡើង ( $r_0$, $r_1$, $r_2$) ។ យើងអាចភ្ជាប់ចំណុចទាំងនេះ ( Y, r) ដើម្បីគូសខ្សែកោង LM (រូបភាព ៣.៦) ដែលកំណត់លក្ខខណ្ឌសមតានៅលើទីផ្សាររូបិយវត្ថុ ។

## ៤.២.- ខ្សែកោង IS

ដោយសន្មតនៅពេលនេះថា គ្មានផ្នែករដ្ឋចូលពាក់ព័ន្ធទេ នោះយើងអាចធ្វើអោយលក្ខខណ្ឌសមតានេះមានលក្ខណៈកាន់តែសាមញ្ញថែមទៀត ÷

សមីការ ៣.១២ $I(r) = S(Y)$

ពោលគឺ ការវិនិយោគគឺជាអនុគមន៍នៃអត្រាការប្រាក់ (មានមេគុណប្រាប់ទិសអវិជ្ជមាន) ស្មើនឹងសញ្ចយ (មានមេគុណប្រាប់ទិសវិជ្ជមាន) ដែលជាអនុគមន៍នៃប្រាក់ចំណូល (សមីការ ៣.១២) ។ នៅត្រង់ ចំណុចណាមួយក៏ដោយនៃ r យើងទទួលបាននូវកម្រិតផ្សៀងផ្ទាត់នៃការវិនិយោគ ដែលសមស្របទៅនឹងកម្រិតនៃសញ្ចយ នៅតាមកម្រិតដ៏ជាក់លាក់មួយនៃ Y ។ បើយើងយក r ពីសមីការ ៣.១២ (a) និង Y ពីសមីការ ៣.១២ (b) មកជំនួស យើងអាចគូសខ្សែកោង IS ដែលបង្ហាញពីកម្រិតនៃ r និង Y ដែល I(r) = S(Y) ដូចក្នុងរូបភាព ៣.១២ (c) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ៤.៣. ចំណុចសមតា

បន្ទាប់ពីបានគូសខ្សែកោង LM ដើម្បីវាស់វែងនូវចំណុចសមតានៃចំណង់ចំណូលចិត្តដើម្បីរក្សាសាច់ប្រាក់ ដោយមាន r និង Y ដែលប្រែប្រួល និងគូសខ្សែកោង IS ដើម្បីវាស់វែងចំណង់ចំណូលចិត្តសញ្ជ័យ-វិនិយោគ ដោយមាន r និង Y ដែលប្រែប្រួល យើងអាចកំណត់ចំណុចសមតា ដែលកើតឡើងនៅពេលដំណាលគ្នានៅលើទីផ្សាររូបិយវត្ថុ និង លើទីផ្សារផលិតផល (រូបភាព ៦.១៧) ។ នៅត្រង់ចំណុចនេះ វាជាចំណុចសមតាដែលខ្សែកោងទាំងពីរកាន់តែខិតចូលជិតយ៉ាងស្រួល ដូចត្រូវបានបកស្រាយនៅក្នុងរូបភាព ៦.១៨ (ដោយសន្មតថាកត្តាខាងក្រៅ ឬស្វ័យភាព វាមិនប្រែប្រួល) ។

## ៥. គំរូរូបិយវត្ថុនិយម

### ៥.១. តម្រូវការរូបិយវត្ថុ

ទ្រឹស្តី «រូបិយវត្ថុនិយម» ចាប់ផ្តើមពីវិធីសាស្រ្ត ***ខេមប្រ៊ីជ*** នៃ «សមីការពាណិជ្ជកម្ម» ។

សមីការ $M^d = kPY$ ដែលតម្រូវការរូបិយវត្ថុ គឺជាអនុគមន៍នៃ «ប្រាក់ចំណូលថ្លៃទីផ្សារ (Nominal income)» ពោលគឺស្មើនឹង P x Y ដោយ k ត្រូវបានសន្មតថានៅថេរ ឬ សមាសធាតុថេរនៃ «ចំណូលតាមថ្លៃទីផ្សារ» ដែលរក្សាទុកជាសាច់ប្រាក់ ។

ដោយ k ត្រូវបានសន្មតថានៅថេរ ហើយការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានកំណត់ពីខាងក្រៅដោយធនាគារកណ្តាល សមីការ **ខេមប្រ៊ីជ** អាចសរសេរបានជា ទ្រឹស្តីនៃ«**ចំណូលតាមថ្លៃទីផ្សារ**» ÷

សមីការ ៣.១៤ $M(1/k) = PY$, ឬ អាចសរសេរម្យ៉ាងទៀតបានជា៖

សមីការ ៣.១៥ $MV = PY$ ដែល V ក៏ត្រូវបានគេសន្មតថាថេរដែរ ។

***កេនស៍*** សន្មតថាទ្រព្យសកម្ម ឬ ទ្រព្យសម្បត្តិអាចរក្សាទុកបាន ក្នុងរូបភាពជា រូបិយវត្ថុសាច់ប្រាក់ ឬជាទ្រព្យសកម្មឯទៀត ដែលគេដាក់ឈ្មោះអោយថាជា ***សញ្ញាប័ណ្ណ*** ដែលជាទ្រព្យសកម្មដែលផ្តល់នូវការប្រាក់ ។ ចំណុចគន្លឹះសម្រាប់ ***កេនស៍*** ដើម្បីកំណត់ថា តើទ្រព្យសកម្មទំហំប៉ុន្មានដែលត្រូវរក្សាទុកជាសាច់ប្រាក់ ហើយទំហំប៉ុន្មានដែលត្រូវរក្សាទុកជាសញ្ញាប័ណ្ណ គឺអត្រាការប្រាក់ ។ ពោលគឺ k នឹងប្រែប្រួលទៅតាមអត្រាការប្រាក់ (r) ។ ប្រសិនបើ r កើនឡើង ធ្វើឱ្យតម្រូវការរូបិយវត្ថុដើម្បីកេងយកចំណេញនឹងធ្លាក់ចុះ ហើយតម្រូវការរូបិយវត្ថុសម្រាប់ប្រតិបត្តិការក៏ធ្លាក់ចុះដែរ ។ ប្រសិនបើ r ធ្លាក់ចុះ តម្រូវការសាច់ប្រាក់នឹងកើនឡើង ។ ដោយ ***កេនស៍*** ចាត់ទុក k ជាអញ្ញាតិមួយ ហើយមិនមែនជាចំនួនថេរនោះ យើងមិនអាចប្រើនូវសមីការពាណិជ្ជកម្មដើម្បីបង្កើតទ្រឹស្តី «**ចំណូល**


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**តាមថ្លៃនីផ្សារ**» បានឡើយ ។ គឺត្រង់នេះហើយ ដែលពួករូបិយវត្ថុនិយមបដិសេធនូវទ្រឹស្តីរបស់ **កេនស៍** ។

*អ្នករូបិយវត្ថុនិយម (ជាពិសេស **ហ្វ្រីដមែន** និងសាវ័ករបស់គាត់ ) បានចាប់ផ្តើមទទួលយកការសន្មត របស់ **កេនស៍** ដែលលើកថា ទ្រព្យសម្បត្តិអាចត្រូវបានរក្សាទុកជាសាច់ប្រាក់ ឬ ទ្រព្យសកម្មដែលអាចទទួលបាន ការប្រាក់ ។ ក៏ប៉ុន្តែ ពួកគេមិនទទួលយកទ្រឹស្តីថាវាទ្រព្យសកម្មទាំងនោះមានប្រភេទដូចៗគ្នា ដែលហៅថា* «**សញ្ញាប័ណ្ណ**» *នោះឡើយ* ។ ពួកគេមានជំនឿថា ÷

សមីការ ៣.១៦ $M^d = L(P, Y, r_B, r_E, r_D)$ ដែល r ជាអត្រាចំណេញ÷

- ពីសញ្ញាប័ណ្ណ (B) ត្រូវបានគេហៅថាជាអត្រាការប្រាក់ ។

- ពីភាគហ៊ុនរបស់ក្រុមហ៊ុន (E) ដែលហៅថាជាភាគលាភ បូកចំណេញពីមូលធន និង

- ពីទំនិញប្រើប្រាស់បានយូរ ដូចជា អចលនទ្រព្យ ស្នាដៃសិល្បៈ និងទ្រព្យសកម្មជារូបវ័ន្តផ្សេងទៀត (D) ដែលហៅថាតម្លៃ ។

តាមអ្នករូបិយវត្ថុនិយម កំណើនណាមួយនៃ r ទាំងបី នឹងធ្វើឱ្យមានការធ្លាក់ចុះនូវតម្រូវការប្រាក់ ក៏ប៉ុន្តែ វានឹងទូទាត់វិញដោយការធ្លាក់ចុះនៃអត្រាចំណេញមួយ ឬពីរផ្សេងទៀត ដែលជាមូលហេតុធ្វើឱ្យ k មិនប្រែប្រួល ។ ឧទាហរណ៍ នៅពេលដែលថ្លៃភាគហ៊ុនកើនឡើង នោះថ្លៃនៃសញ្ញាប័ណ្ណនឹងមានទំនោរធ្លាក់ចុះ ។

នៅត្រង់ចំណុចនេះ យើងអាចរំលេចអោយឃើញនូវភាពខុសគ្នាបីយ៉ាងរវាង **កេនស៍** និង អ្នករូបិយវត្ថុ-និយម ÷

**ទីមួយ**- ចំពោះ **កេនស៍** តម្រូវការរូបិយវត្ថុគ្មានស្ថិរភាពទេ ដោយសារការផ្លាស់ប្តូរជំនឿទុកចិត្តរបស់វិនិយោគិន ។ ក៏ប៉ុន្តែ ចំពោះអ្នករូបិយវត្ថុនិយមវិញ តម្រូវការរូបិយវត្ថុមានស្ថិរភាព ពីព្រោះដោយមានអត្រាការប្រាក់ច្រើន កំណើននៃអត្រា r ប្រភេទមួយនឹងត្រូវផាត់ទាត់ដោយការធ្លាក់ចុះនៃ r មួយផ្សេងទៀត ។

**ទីពីរ**- ចំពោះ **កេនស៍** តម្រូវការរូបិយវត្ថុមានច្រើនប្រភេទ÷ តម្រូវការសម្រាប់ប្រតិបត្តិការ តម្រូវការសម្រាប់ការប្រុងប្រយ័ត្ន និង តម្រូវការកេងយកចំណេញ ។ ចំពោះអ្នករូបិយវត្ថុនិយមវិញ តម្រូវការរូបិយវត្ថុ គឺជាតម្រូវការរូបិយវត្ថុ ជាទ្រព្យសកម្មដែលមានប្រយោជន៍ ហើយភាពខុសគ្នានៃប្រភេទតម្រូវការ នេះមិនមានសារៈសំខាន់ប៉ុន្មានទេ ។ និង

**ទីបី**- ចំពោះ **កេនស៍** ទ្រព្យសម្បត្តិ Wh មានសមាសភាពដូចតទៅ÷សាច់ប្រាក់ និង ទ្រព្យសកម្មទទួលបានការប្រាក់ដូចគ្នា ដែលហៅថា ***សញ្ញាប័ណ្ណ*** ។ ចំពោះអ្នករូបិយវត្ថុនិយម មានអត្រាចំណេញផ្សេងៗគ្នា


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុប្រភេទផ្សេងៗគ្នា ។ ឧទាហរណ៍ដូចជា សញ្ញាប័ណ្ណ ភាគហ៊ុន និងទំនិញប្រើប្រាស់បានយូរ ។

ដោយប្រើឡើងវិញនូវសមីការ**ខេមប្រ៊ីដ** ***ទ្រឹស្តីតម្រូវការរូបិយវត្ថុ*** របស់អ្នករូបិយវត្ថុនិយមអាចសរសេរបានទៅជាសមីការដូចខាងក្រោម៖

សមីការ ៣.១៧ $Md = k\ (r_B, r_E, r_D)\ PY$

ដោយ *k* មិនមែនជាចំនួនថេរដូចនៅក្នុងគំរូបុរាណនិយមឡើយ តែជាអញ្ញត្តិអាស្រ័យលើអត្រាចំណេញខុសៗគ្នា ។ កំណើននៃអញ្ញត្តិណាមួយ នឹងនាំឱ្យ *k* ធ្លាក់ចុះ ក៏ប៉ុន្តែសរុបមក អត្រាចំណេញទាំងនេះ នឹងទូទាត់បង្គ្រប់ឱ្យគ្នាទៅវិញទៅមក ហើយ *k* នឹងមានស្ថិរភាព ។

ចំពោះអ្នករូបិយវត្ថុនិយម ចំណុចសមតានៃទីផ្សាររូបិយវត្ថុកើតមាននៅពេលដែល÷

សមីការ ៣.១៨ $M = M^d\ k\ (r_B, r_E, r_D)\ PY$

តាមសមតិកម្មរបស់អ្នករូបិយវត្ថុនិយម តម្រូវការរូបិយវត្ថុមានស្ថិរភាព កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុនឹងទាមទារឱ្យ PY កើនឡើង ឬអោយ $r_B$, $r_E$, $r_D$ ធ្លាក់ចុះ ដែលនឹងបណ្តាលឱ្យ *k* កើនឡើង ។ ដោយសារតែការផ្លាស់ប្តូរនៃការផ្គត់ផ្គង់រូបិយវត្ថុនឹងនាំអោយ PY មានការប្រែប្រួល បរិមាណរូបិយវត្ថុមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកំណត់ «**ចំណូលតាមថ្លៃទីផ្សារ**» (Nominal income)។

## ៥.២. ទ្រឹស្តីចំណូលតាមថ្លៃទីផ្សារ

ដូចយើងបានឃើញសមីការ **ខេមប្រ៊ីដ** រួចហើយ *k* ជាចំនួនថេរ និង $M^s$ កំណត់ដោយធនាគារកណ្តាលនោះ «**ចំណូលតាមថ្លៃទីផ្សារ**» គឺជា៖

សមីការ ៣.១៩ $PY = (1/k)\ M$ ពោលគឺ «**ចំណូលតាមថ្លៃទីផ្សារ**» PY ត្រូវស្មើនឹង 1/k គុណនឹង បរិមាណផ្គត់ផ្គង់រូបិយវត្ថុ ។

សម្រាប់អ្នករូបិយវត្ថុនិយម កត្តាផ្សេងទៀតនៅក្នុងសមីការ ៩.៥ ($r_B$, $r_E$, $r_D$) ត្រូវបានសន្មតថាឥទ្ធិពលដ៏តិចតួចទៅលើតម្រូវការរូបិយវត្ថុ ហើយសឹងតែក្លាយជាចំនួនថេរទៅហើយ ពោលការរក្សាទុករូបិយវត្ថុ ឬសាច់ប្រាក់ (k) ស្មើរតែនៅថេរ ។ ទស្សនាទានរបស់អ្នករូបិយវត្ថុនិយមត្រូវបានបង្ហាញនៅក្នុងរូបភាព (៣.៧) ដែលខ្សែកោង LM មិនមានភាពយឺត ដោយឆ្លុះបញ្ចាំងនូវការសន្មតថា k គឺជាចំនួនមួយដែលស្មើរតែនៅថេរ ពោលតម្រូវការរូបិយវត្ថុមិនមានភាពយឺត ដោយផ្ទៀងផ្ទាត់ទៅនឹងការផ្លាស់ប្តូរជាក្រុមនៃ $r_B$, $r_E$, $r_D$ ។ ផ្ទុយទៅវិញ ខ្សែកោង IS


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គឺមានភាពយឺតខ្លាំងជាមួយអត្រាការប្រាក់ (មេគុណមានលក្ខណៈជម្រាល) ដែលឆ្លុះបញ្ចាំងនូវការសន្មតរបស់អ្នករូបិយវត្ថុនិយម ដែលថា តម្រូវការសរុបមានវេទយិតភាពខ្លាំងទៅនឹងបន្លាស់ប្តូរអត្រាការប្រាក់ ។

**រូប ៣.៧ ឧស្សនរូបិយវត្ថុនិយមស្តីពី IS-LM**




ចំណុចនេះ មានលក្ខណៈផ្ទុយនឹងគំរូ **កេនស៍** ដែលខ្សែកោង LM មានភាពយឺតល្អជាមួយនឹងអត្រាការប្រាក់ តែខ្សែកោង LM គ្មានភាពយឺតល្អជាមួយនឹងអត្រាការប្រាក់ទេ (រូបភាព ៣.៦) ។ ជាការពិត ខ្សែកោង LM និង IS ត្រូវបានគេសន្មតថា កម្រិតថ្លៃនៅថេរ ។ ក៏ប៉ុន្តែ អ្នករូបិយវត្ថុនិយមជឿថាថ្លៃនឹងប្រែប្រួល ។

ឥទ្ធិពលនៃការសន្មតរបស់អ្នករូបិយវត្ថុនិយមដូចជា- តម្រូវការរូបិយវត្ថុមានស្ថិរភាព តម្រូវការរូបិយវត្ថុមិនយឺតតាមអត្រាការប្រាក់ ការវិនិយោគ និងសញ្ជ័យយឺតតាមអត្រាការប្រាក់ ប្តូកនឹងភាពប្រែប្រួលនៃកម្រិតថ្លៃ- ទៅលើតម្រូវការសរុប ត្រូវបានបង្ហាញនៅក្នុងរូបភាព ៣.៨ ដែលក្នុងនោះ កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុនាំអោយមានកំណើននៃ Y និង P ។ ចំណុចសំខាន់ គឺ ជំហររបស់អ្នករូបិយវត្ថុនិយមគឺយ៉ាងច្រើននៃ «**ចំណូលតាមថ្លៃទីផ្សារ**» ទាមទារឱ្យមានការផ្លាស់ប្តូរនៃការផ្គត់ផ្គង់រូបិយវត្ថុ ។

ក៏ប៉ុន្តែ អ្វីដែលគេមិនបានឆ្លើយ គឺសារធាតុនៃបន្ទាត់ខ្សែកោងការផ្គត់ផ្គង់សរុប និង ភាពស័ក្តិសិទ្ធិនៃការផ្លាស់ប្តូរនៃការផ្គត់ផ្គង់រូបិយវត្ថុ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**រូប ៣.៨ ទស្សនរូបិយវត្ថុនិយមស្តីពីការផ្គត់ផ្គង់ និង តម្រូវការសរុប**




## *៥.៣. មីលតុន ហ្វ្រីដមែន និង សាលារូបិយវត្ថុ*

វាក្យស័ព្ទ «**រូបិយវត្ថុនិយម**» ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៦៨ ដោយលោក **កាល ប្រ៊ុនន័រ** (Karl Brunner) ដោយសំដៅទៅរកទ្រឹស្តី និងលទ្ធិម៉ាក្រូសេដ្ឋកិច្ច ដែលបានបង្កើតឡើងដោយសេដ្ឋវិទូ **មីលតុន ហ្វ្រីដមែន** (Milton Friedman) ដែលមានសម្ព័ន្ធភាពយ៉ាងជិតស្និទ្ធជាមួយសាកលវិទ្យាល័យ **ឈីកាហ្គោ** ។ ក៏ប៉ុន្តែ ទាល់តែនៅចុងទសវត្សរ៍ទី ៦០ និងទសវត្សរ៍ទី ៧០ ទើប «**រូបិយវត្ថុនិយម**» បានក្លាយទៅជាកម្លាំងបញ្ញាញាណដ៏មានឥទ្ធិពល ហើយគេត្រូវរង់ចាំរហូតដល់ចុងទសវត្សរ៍ទី ៧០ និងដើមទសវត្សរ៍ទី ៨០ ទើបវាត្រូវបានប្រើក្នុងគោលនយោបាយសេដ្ឋកិច្ច ។ **មីលតុន ហ្វ្រីដមែន** បង្ហាញយ៉ាងខ្លីនូវទស្សនៈរបស់គាត់ ដែលពឹងផ្អែកទាំងស្រុងទៅលើយន្តការទីផ្សារ ÷ «គោលដៅជាមូលដ្ឋានរយៈពេលវែង ដែលសេដ្ឋវិទូភាគច្រើនមានការឯកភាពគ្នា គឺសេរីភាពខាងផ្នែកនយោបាយ ប្រសិទ្ធភាពសេដ្ឋកិច្ច និង សមភាពដ៏ធំធេងនៃអំណាចសេដ្ឋកិច្ច....។ ខ្ញុំជឿ ជាក់ថាតែមកដល់ពេលនេះមិនទាន់មានការឯកភាពគ្នាអោយបានទូលំទូលាយនៅឡើយទេ យើងអាចសម្រេចបាននូវគោលដៅទាំងបីនេះ ដោយពឹងផ្អែកអោយបានច្រើនបំផុតលើយន្តការនៃទីផ្សារ ក្នុងក្របខណ្ឌនៃ «**សណ្ដាប់ធ្នាប់ប្រកួតប្រជែង**» ដើម្បីរៀបចំការប្រើប្រាស់ធនធានសេដ្ឋកិច្ច» ។ **(មីលតុន ហ្វ្រីដមែន ១៩៤៨)**

**ហ្វ្រីដមែន** បានបង្កើតចក្ខុវិស័យជាមូលដ្ឋានរបស់គាត់ស្តីពីទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងតួនាទីនៃគោល-នយោបាយរបស់រដ្ឋាភិបាល ដែលជាចក្ខុវិស័យមួយដ៏ល្បីល្បាញនៅពេលក្រោយមក តាមរយៈស្នាដៃដ៏មាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រជាប្រិយភាពរបស់គាត់ដូចជា «*មូលធននិយម និងសេរីភាព (១៩៦២)*» និង «*សេរីភាពក្នុងការជ្រើសរើស (១៩៨០ និពន្ធរួមគ្នាជាមួយ* ***រូស ហ្រ្វីដម៉ែន*** *១៩៤៨ )*» ។ ទោះបីជាយ៉ាងណា **ហ្រ្វីដម៉ែន** មានជំនឿទៅលើប្រព័ន្ធទីផ្សារដែលជាអ្នកបែងចែកដ៏មានប្រសិទ្ធភាពនៃធនធាន ។ គាត់មានភាពជឿជាក់ថា ការធ្វើផែនការ និងការធ្វើអន្តរាគមន៍នឹងបង្កឱ្យមានបញ្ហាធ្ងន់ធ្ងរជាជាងការព្យាបាលនៃផលលំបាកផ្នែកសេដ្ឋកិច្ច ដែលវាមិនមែនជាគោលការណ៍ជាមូលដ្ឋាននៃ «រូបិយវត្ថុនិយម» ។

យើងអាចសង្ខេបបាននូវលក្ខណៈសំខាន់ៗនៃ«**រូបិយវត្ថុនិយម**»របស់លោក **ហ្រ្វីដម៉ែន**ដូចខាងក្រោម៖

(១)-*<u>យន្តការបញ្ជូនចែកចាយរូបិយវត្ថុ</u>* : ជំរុញអោយភ្នាក់ងារសេដ្ឋកិច្ចកាត់បន្ថយការផ្គត់ផ្គង់សាច់ប្រាក់អតិរេក ដោយទិញទំនិញ ជាជាងទិញសញ្ញាប័ណ្ណ ។

(២)-*<u>ស្ថិរភាពនៃតម្រូវការសាច់ប្រាក់</u>* : នៅក្នុងការអនុវត្ត គេមានជំនឿថាតម្រូវការសាច់ប្រាក់ ជាអនុគមន៍មិនប្រែប្រួលមួយនៃទ្រព្យសម្បត្តិ ថ្លៃ ការផ្លាស់ប្តូរថ្លៃ និងការប្រាក់ ។

(៣)-*<u>ទំនាក់ទំនងហេតុ- ផលនៃរូបិយវត្ថុ-និង-ប្រាក់ចំណូល</u>* : ចលនានោះនៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុជាមូលហេតុចម្បងនៃការឡើងចុះនៃអាជីវកម្ម ហើយចលនានៅក្នុងតម្រូវការសរុបពាក់ព័ន្ធនឹងទំនិញ មានផលប៉ះពាល់តិចតួចតែប៉ុណ្ណោះ ។

(៤)-*<u>សម្មតិកម្មនៃអត្រាធម្មជាតិនៃនិកម្មភាព</u>* : គេមានជំនឿថា វាមានអត្រានិកម្មភាពខុសប្លែកពីគេមួយដែលវាមិនពាក់ព័ន្ធជាមួយកំណើនអតិផរណា ហើយនៅក្នុងរយៈពេលវែង កម្លាំងសេដ្ឋកិច្ចនោះអាចផាត់ទាត់នៅក្នុងកម្រិតអត្រានិកម្មភាពនោះ ។

(៥)-*<u>វិធាននៃឧត្តមភាពនៃគោលនយោបាយរូបិយវត្ថុ</u>* : គេមានជំនឿថា គោលនយោបាយរូបិយវត្ថុ មានប្រសិទ្ធភាពខ្ពស់ជាងគោលនយោបាយសារពើពន្ធយ៉ាងខ្លាំង ដោយផ្តល់អនុសាសន៍ថា ធនាគារកណ្តាលត្រូវផ្តោតលើគោលដៅបរិមាណរូបិយវត្ថុសរុប ជាជាងគិតគូពីអត្រាការប្រាក់ ហើយយ៉ាងហោចណាស់ក៏នៅក្នុងរយៈពេលវែង ការអនុវត្តនូវគោលនយោបាយផ្គត់ផ្គង់រូបិយវត្ថុមានស្ថិរភាព វាប្រសើរជាងការអនុវត្តនូវគោលនយោបាយរូបិយវត្ថុបដិខួប (Counter-cyclical) ឆន្ទានុសិទ្ធិដែរ ។

ការវិវត្តនៃ«**រូបិយវត្ថុនិយម**»ឆ្លងកាត់នូវពីរដំណាក់កាល៖

-**ដំណាក់កាលទី១**: ការពិភាក្សាគ្នាជុំវិញ ***ហេតុផលនៃរូបិយវត្ថុ-ប្រាក់ចំណូល*** ដែលមានលក្ខណៈក្តៅគគុក នៅក្នុងទសវត្សរ៍ទី ៦០ ។ និង

-**ដំណាក់កាលទី២**: ការពិភាក្សាគ្នាជុំវិញសម្មតិកម្ម**ខ្សែកោងហ្វីលីព** និង សម្មតិកម្មនៃការពន្លឿន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(Acceleration hypothesis) ដែលបានគ្របដណ្តប់នៅក្នុងទសវត្សរ៍ទី ៧០ ។ គឺលោក **ហ្វ្រីដមែន** ដែលជាដើមចមនៃការពិភាក្សានេះ ។

នៅក្នុងកម្រិតគោលនយោបាយ «**រូបិយវត្ថុនិយម**» បានស្គាល់នូវភាពល្បីល្បាញនៅចុងទសវត្សរ៍ទី ៧០ និងដើមទសវត្សរ៍ ទី ៨០ ហើយបានក្លាយជាមូលដ្ឋាននៃគោលនយោបាយរូបិយវត្ថុ គឺ៖ ធនាគារកណ្តាលជាច្រើននៅចុងទសវត្សរ៍ទី ៧០ បានបោះបង់ចោលនូវ***គោលដៅអត្រាការប្រាក់*** និងបានអនុម័តយក ***គោលដៅនៃការផ្គត់ផ្គង់រូបិយវត្ថុ*** និង ការប្រើប្រាស់គោលនយោបាយរូបិយវត្ថុ ដើម្បីកាត់បន្ថយអត្រាអតិផរណា នៅសហរដ្ឋអាមេរិក និងនៅប្រទេសអង់គ្លេស ។ មហន្តរាយដ៏ធំធេងនៃការពិសោធន៍គោលនយោបាយរូបិយវត្ថុទាំងនេះបានធ្វើឱ្យអាប់ឱនដល់លទ្ធិ«**រូបិយវត្ថុនិយម**» ដ៏រឹងត្អឹងនៅក្នុងចំណោមអ្នកធ្វើគោលនយោបាយសេដ្ឋកិច្ច ។

## ៦. អតិផរណា និង វិធានការគោលនយោបាយឆ្លើយតប

### *៦.១. មូលហេតុនៃអតិផរណា*

អតិផរណាចែកចេញជា ៣ ប្រភេទធំៗ គឺ៖ អតិផរណាដែលបណ្តាលមកពីកំណើននៃតម្រូវការ អតិផរណាដែលបណ្តាមកពីការកើនឡើងនៃថ្លៃដើម និង អតិផរណាវដ្តសង្សារ ដែលបណ្តាលមកពីអន្តរប្រតិសកម្មរវាងថ្លៃដើម និង ការឡើងថ្លៃទំនិញជារួម ។

**តារាង ៣.៩- រូបិយវត្ថុ ឥណទាន និង អតិផរណា**




រូបទី ៣.៩ បង្ហាញអោយឃើញថា កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ និងអតិផរណាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ។ ប្រការនេះ ដូចលោក **មីលតុន ហ្វ្រីដមែន** បានមានប្រសាសន៍ថា *«ជានិច្ចកាល និងគ្រប់ទីកន្លែងទាំងអស់ អតិផរណាជាបាតុភូតរូបិយវត្ថុ»* ហើយដែលយើងហៅថា អតិផរណាទាញដោយតម្រូវការ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៦.១.១. អតិផរណាបណ្ដាលមកពីកំណើនតម្រូវការ

**អតិផរណាបណ្ដាលមកពីកំណើនតម្រូវការ** : ជាអតិផរណាដែលបណ្ដាលមកពីការកើនឡើងនៃតម្រូវការសរុប ដោយសារការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង ហើយផ្នែកឯកជន និងរដ្ឋបង្កើនចំណាយរបស់ខ្លួន ។ ការកើនឡើងនៃតម្រូវការទំនិញ និងសេវាកម្មទាំងអស់ (ឬហៅថាតម្រូវការសរុប) គឺជាកត្តាដែល «ទាញ» តម្លៃទំនិញ និងសេវាកម្មសព្វសារពើអោយឡើងថ្លៃ ជាពិសេសនៅពេលដែលចំនួនផ្គត់ផ្គង់សរុប មិនអាចកើនឡើងបានដោយសារសមត្ថភាពផ្គត់ផ្គង់នៅមានកម្រិត ។ ចំណុចសំខាន់នៃទ្រឹស្ដីអតិផរណា ដែលបណ្ដាលមកពីកំណើនតម្រូវការ គឺផ្ដោតទៅលើការផ្គត់ផ្គង់រូបិយវត្ថុ ពោលគឺ អតិផរណាបណ្ដាលមកពីចំនួនរូបិយវត្ថុធ្វើចរាចរលើទីផ្សារកើនឡើង ធៀបនឹងសមត្ថភាពផ្គត់ផ្គង់សរុបរបស់សេដ្ឋកិច្ច ។

លំហូរចូលមូលធនពីក្រៅប្រទេស គឺជាប្រភពមួយដ៏សំខាន់នៃការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ ។ លំហូរមូលធននេះ គឺដើម្បីយកមកធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្ត ។ ចាប់តាំងពីឆ្នាំ ២០០៥ មក គណនីមូលធន និង ហិរញ្ញវត្ថុបានកើនឡើងយ៉ាងខ្លាំង ។ គណនីហិរញ្ញវត្ថុកើនឡើងចំនួន ៣៩ ភាគរយ ពី ៣២៤ លានដុល្លារ នៅក្នុងឆ្នាំ ២០០៦ ដល់ ៤៥១ លានដុល្លារ នៅក្នុងឆ្នាំ ២០០៧ ។ ការផ្ទេរជាមូលធន ក្រោមរូបភាពជាកម្ចីរយៈពេល



រូបទី ៣-១០ ការផ្គត់ផ្គង់រូបិយវត្ថុ

មធ្យម និងវែងបានកើនឡើង ៤១ ភាគរយ ពី ១២៣ លានដុល្លារ នៅក្នុងឆ្នាំ ២០០៦ ដល់ ១៧៣ លានដុល្លារ នៅក្នុងឆ្នាំ ២០០៧ ។

លំហូរចូលមូលធនពីក្រៅប្រទេស ក្រោមរូបភាពជាវិនិយោគផ្ទាល់ក្រៅប្រទេសបានកើនឡើង ចំនួន ៥៥ ភាគរយ ពី ៤៧៥ លានដុល្លារ នៅក្នុងឆ្នាំ ២០០៦ ដល់ ៨៦៧ លានដុល្លារក្នុងឆ្នាំ ២០០៧ ។ ការកើនឡើងនៃ

វិនិយោគផ្ទាល់ពីបរទេសឆ្លុះបញ្ចាំងពីកំណើននៃជំនឿទុកចិត្តរបស់វិនិយោគិន មកលើស្ថិរភាពនយោបាយ និង ម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា ។ វិនិយោគផ្ទាល់ពីបរទេសត្រូវបានគេចាត់ទុកថា ជាលំហូរមូលធនដែលមិនបង្កើតបំណុល ដោយសារលំហូរវិនិយោគមិនបង្កើនបំណុលក្រៅប្រទេសរបស់ប្រទេសឡើយ ដោយសារវិនិយោគិនទិញយកភាគហ៊ុននៅក្នុងក្រុមហ៊ុន ឬ ពង្រីកនូវសាខាក្រុមហ៊ុនរបស់ខ្លួនតែប៉ុណ្ណោះ ។ លក្ខណៈសម្បត្តិនៃលំហូរនៃ




វិនិយោគផ្ទាល់ពីបរទេស គឺស្ថិតត្រង់ថា វិនិយោគប្រភេទនេះមិនមែនត្រឹមតែផ្ទេរធនធានពីក្រៅប្រទេសប៉ុណ្ណោះទេ ថែមទាំងធានាអោយបាននូវការផ្ទេរនូវបច្ចេកវិទ្យា និង បទពិសោធន៍គ្រប់គ្រងពីបរទេសទៀតផង ដែលមានសារៈសំខាន់ខ្លាំងជាងការផ្ទេរធនធានហិរញ្ញវត្ថុទៅទៀត ។

ជារួម លំហូរចូលមូលធនបានដើរតួនាទី ដើម្បីធ្វើហិរញ្ញប្បទាននូវឱនភាពគណនីចរន្ត ដែលចេះតែកើនឡើង ដោយសារកំណើននៃការនាំចូល និង កំណើនសេដ្ឋកិច្ចខ្ពស់ ។ លំហូរមូលធនកាន់តែមានកម្រិតធំធេង ដែលមិនត្រឹមតែបំពេញបង្គ្រប់នូវឱនភាពគណនីចរន្តប៉ុណ្ណោះទេ ថែមទាំងមានអតិរេកចំនួន ២៩០ លានដុល្លារ ឬ ៣,៤ ភាគរយនៃផសស នៅក្នុងឆ្នាំ ២០០៧ កន្លងទៅនេះ ដោយសារតែកំណើននៃចំណូលពីវិស័យទេសចរណ៍ ដែលមានចំនួន ១,១ ពាន់លានដុល្លារ ការផ្ទេរក្នុងវិស័យឯកជន និង សាធារណៈ ចំនួន ៧៤៨ លានដុល្លារ កំណើនកម្ចីដែលមានលក្ខណៈសម្បទាន និង វិនិយោគផ្ទាល់ពីបរទេស ។ លំហូរមូលធនដ៏ច្រើនសន្ធឹកសន្ធាប់ជួយដល់រដ្ឋាភិបាលក្នុងការបង្កើនទុនបម្រុងអន្តរជាតិ ។ ក៏ប៉ុន្តែ លំហូរនេះក៏បានបង្កើតនូវបញ្ហាមួយចំនួន ក្នុងការគ្រប់គ្រងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចផងដែរ ÷

- លំហូរមូលធនមានលក្ខណៈបណ្តោះអាសន្ន ហើយនឹងត្រូវហូរចេញវិញនៅពេលណាមួយនៅអនាគត ។
- លំហូរមូលធននាំអោយការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង និង ធ្វើអោយអតិផរណាកើនឡើង ប្រសិនបើធនាគារជាតិនៃកម្ពុជាធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីទិញយករូបិយប័ណ្ណជាប្រាក់ដុល្លារ ដើម្បីធានានូវស្ថិរភាព


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃអត្រាប្តូរប្រាក់ ។ ប្រការនេះនឹងធ្វើអោយទុនបម្រុងអន្តរជាតិកើនឡើង ។ ជាក់ស្តែង ក្នុងរយៈពេលតែពីរឆ្នាំប៉ុណ្ណោះ ទុនបម្រុងរបស់កម្ពុជាបានកើនឡើងចំនួន ១ ពាន់លានដុល្លារ ចាប់ពីពាក់កណ្តាលឆ្នាំ ២០០៦ ដល់ពាក់កណ្តាលឆ្នាំ ២០០៧ បើប្រៀបធៀបនឹងរយៈពេលមុន ដែលទាមទារនូវរយៈពេល ១២ ឆ្នាំ ដើម្បីបង្កើនទុនបម្រុងចំនួន ១ ពាន់លានដុល្លារ គឺចាប់ពី ១០០ លានដុល្លារ នៅក្នុងឆ្នាំ ១៩៩៤ ដល់ ១ ពាន់លានដុល្លារ នៅពាក់កណ្តាលឆ្នាំ ២០០៦ ។

- ដោយសារអន្តរាគមន៍ដោយធនាគារជាតិនៃកម្ពុជា ក្នុងការទិញរូបិយប័ណ្ណដុល្លារ និង បញ្ចេញប្រាក់រៀលទៅក្នុងទីផ្សារប្តូរប្រាក់ ធ្វើឡើងដោយរដ្ឋាភិបាលមិនបានបោះផ្សាយសញ្ញាប័ណ្ណ ឬ ប័ណ្ណរតនាគារ ដើម្បីស្រូបយកប្រាក់រៀលចូលមកក្នុងប្រព័ន្ធធនាគារវិញ នោះមូលដ្ឋានរូបិយវត្ថុត្រូវបានកើនឡើងច្រើនជាងមុន ជាមូលហេតុធ្វើអោយមានអតិផរណា ។

- ប្រសិនបើធនាគារជាតិនៃកម្ពុជាមិនធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ទេ នោះតម្លៃប្រាក់រៀលនឹងកើនឡើងប្រៀបធៀបនឹងប្រាក់ដុល្លារ ដែលជាមូលហេតុមួយ ធ្វើអោយកម្ពុជាអាចនឹងបាត់បង់នូវសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ជាពិសេសសម្រាប់ទំនិញដែលអាចនាំចេញបាន ។

- លំហូរចូលនៃមូលធនត្រូវបានប្រើប្រាស់ដើម្បីធ្វើហិរញ្ញប្បទានបណ្តោះអាសន្ន នូវការប្រើប្រាស់ ជាពិសេសវិស័យអចលនវត្ថុ ។ ក៏ប៉ុន្តែ ការប្រើប្រាស់នេះនឹងត្រូវកាត់បន្ថយវិញ នៅពេលដែលមូលធននេះនឹងត្រូវហូរចេញពីកម្ពុជាវិញ នៅក្នុងពេលអនាគត ។

## ៦.១.២. អតិផរណាបណ្តាលមកពីកំណើនថ្លៃដើម

**អតិផរណាបណ្តាលមកពីកំណើនថ្លៃដើម** : ជាអតិផរណាដែលគឺបណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងនៃបរិមាណផ្គត់ផ្គង់សរុប ដោយសារតម្លៃធាតុចូលសំរាប់ផលិតកម្មកើនឡើង ។ កត្តាជំរុញថ្លៃដើមមួយចំនួន ដូចជា

**តារាង ៣.១២ - អតិផរណាប្រចាំឆ្នាំ (%)**






fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រេង ស្បៀង ឬ ថ្លៃឈ្នួលអាចបង្កើនកំរិតតម្លៃទំនិញទូទៅ ។ ផលិតករដែលត្រូវបង់ថ្លៃដើមនៃធាតុចូលខ្ពស់ នឹងបញ្ជូនបន្ទុកនេះបន្តទៅអោយអតិថិជន ដោយវិធីបង្កើនតម្លៃធាតុចេញ ឬទំនិញលើទីផ្សារ ។

យើងបានឃើញថា អត្រាអតិផរណានៅកម្ពុជាចាប់ផ្តើមកើនឡើង ទៅតាមការឡើងនៃតម្លៃប្រេងឥន្ធនៈ ។ អតិផរណានៅឆ្នាំ ២០០២ គឺ សូន្យ ហើយឡើង ១,១៥% នៅក្នុងឆ្នាំ ២០០៣ និង ៣,៩% នៅក្នុងឆ្នាំ ២០០៤ ។ ទន្ទឹមនឹងនេះដែរ តម្លៃប្រេងនៅលើទីផ្សារអន្តរជាតិបានចាប់ឡើងថ្លៃតាំងតែពីឆ្នាំ ២០០៣ មកម្ល៉េះ ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា អត្រាអតិផរណានៅកម្ពុជា កើនឡើងតាមថ្លៃប្រេងឥន្ធនៈ ។

នៅពេលដែលថ្លៃប្រេងឡើងខ្ពស់ក្នុងពាក់កណ្តាលឆមាសទី ២ នៃឆ្នាំ ២០០៧ អត្រា អតិផរណាឡើងដល់ ១០,៨% ក្នុងខែ ធ្នូ ឆ្នាំ ២០០៧ ។ ថ្លៃស្បៀងដែលបានកើនឡើងយ៉ាងខ្លាំងដែរនៅដើមឆ្នាំ ២០០៨ នោះ បានរុញអតិផរណាអោយឡើងកាន់តែខ្ពស់ថែមទៀត ។

ការកើនឡើងនៃអត្រាអតិផរណា ជាសំខាន់គឺបានបង្ហាញអោយឃើញពីឥទ្ធិពលរបស់ថ្លៃថាមពល ប្រេងឥន្ធនៈ ដែលបានឡើងយ៉ាងខ្ពស់ ។ យើងត្រូវតែយកចិត្តទុកដាក់ដល់អតិផរណាដែលបានកើនឡើង និង ជាពិសេសការកើនឡើងនៃថ្លៃស្បៀង ដោយសារកត្តានេះអាចបណ្តាលអោយរង្គោះរង្គើដល់ស្ថិរភាពសេដ្ឋកិច្ចសង្គម និងអាចប៉ះពាល់ដល់លទ្ធភាពនៃការធានាអោយមានកំណើនសេដ្ឋកិច្ច តាមអត្រាមួយយ៉ាងខ្ពស់ ក្នុងបរិការណ៍ អតិផរណាទាប ដែលប្រទេសកម្ពុជាធ្លាប់សម្រេចបានក្នុងឆ្នាំកន្លងមកនេះ ។

### ៦.១.៣. វដ្តអតិផរណា

**វដ្តអតិផរណា** : គឺបណ្តាលមកពីការរំពឹងគិតទៅពេលអនាគត ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ន ដោយភាគច្រើនគឺផ្សារភ្ជាប់នឹង «វដ្តសង្សារនៃដំណើរប្រតិសកម្ម ទៅវិញទៅមក រវាងថ្លៃទំនិញ និង ប្រាក់បៀវត្ស» ។ ដោយសារអតិផរណាកើនឡើងជាប្រចាំ និយោជិកទាមទារតម្លើងប្រាក់បៀវត្សរបស់ខ្លួន ដើម្បីទប់ទល់នឹងថ្លៃទំនិញ ដែលចេះតែកើនឡើងឥតឈប់ឈរ (ដោយប្រាក់បៀវត្សដុល ត្រូវតែកើនលើសសន្ទស្សន៍ថ្លៃទំនិញ ដើម្បីធ្វើអោយ ប្រាក់បៀវត្សសុទ្ធមានកម្រិតសមស្រប ជាមួយនឹងសន្ទស្សន៍ថ្លៃទំនិញបន្ទាប់ពីដកពន្ធចេញ) ហើយនិយោជកបញ្ចូល ការឡើងថ្លៃនេះ ទៅក្នុងថ្លៃដើមទំនិញ ពោលគឺបញ្ជូនការឡើងថ្លៃប្រាក់បៀវត្សទៅអោយអតិថិជន តាមរយៈវិធីតម្លើង ថ្លៃទំនិញ ដែលជាផ្នែកមួយនៃវដ្តសង្សារនៃដំណើរការប្រតិសកម្មបន្ថែមគ្នាទៅវិញទៅមក រវាងអតិផរណា និង ប្រាក់បៀវត្ស ។ អតិផរណាវដ្តសង្សារបង្ហាញពីព្រឹត្តិការណ៍ក្នុងអតីតកាល ដូចនេះគេអាចចាត់ទុកវាជាអតិផរណា ដែលវិលចុះវិលឡើង ។

## ៦.២. វិធានការគោលនយោបាយឆ្លើយតបទៅនឹងអតិផរណា

ដើម្បីដាក់ចេញនូវវិធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាព អាជ្ញាធររូបិយវត្ថុត្រូវកំណត់អោយបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ច្បាស់ថា តើនៅក្នុងកម្រិតណា ដែលអតិផរណាបង្កើតឡើងដោយកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ ហើយនៅក្នុងកម្រិតណា ដែលអតិផរណាត្រូវបានបង្កើតឡើងដោយកំណើនថ្លៃដើម ឧទាហរណ៍ ការឡើងថ្លៃនៃប្រេងឥន្ធនៈ និង និងទំនិញជាស្បៀង និង ជាឧបភោគបរិភោគ ។

### ៦.២.១. វិធានការទប់ទល់អតិផរណាដែលបណ្តាលមកពីកំណើននៃតម្រូវការ

ដើម្បីឆ្លើយតបទៅនឹងបញ្ហា អតិផរណាដែលបណ្តាលមកពីកំណើននៃតម្រូវការ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការរូបិយវត្ថុមួយចំនួន ដូចខាងក្រោម ÷

- អនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយត្ន័ និងតឹងរឹងដើម្បីទប់អតិផរណាកុំអោយឡើងខ្ពស់ពេក ។

- បន្តអនុវត្តគោលនយោបាយអត្រាប្តូរប្រាក់ *«អណ្តែតដោយគ្រប់គ្រង»* សំដៅរក្សាស្ថិរភាពអត្រាប្តូរប្រាក់ បង្កើនទំនុកចិត្តរបស់សាធារណជន និងរក្សាអានុភាពទិញរបស់ប្រាក់រៀល ។ ដើម្បីទប់ស្កាត់កុំអោយអត្រាប្តូរប្រាក់ឡើងចុះខ្លាំងពេក និងកុំអោយទីផ្សារមានការរង្គោះរង្គើ ធនាគារជាតិនៃកម្ពុជានឹងខិតខំរក្សាបរិមាណរូបិយវត្ថុដែលធ្វើចរាចរក្នុងស្រុកអោយស្ថិតនៅក្នុងកម្រិតសមស្រប និងបន្តលក់លុយដុល្លារអាមេរិចទៅអោយអគ្គិសនីកម្ពុជាបន្ថែមទៀត ។

- បង្កើនទុនបំរុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជ ពី ៨% ឡើងទៅ ១៦% ដើម្បីស្រូបយកសាច់ប្រាក់បន្ថែមទៀតពីសេដ្ឋកិច្ច ជាពិសេសរឹតបន្តឹងការផ្តល់កម្ចីធនាគារទៅអោយវិស័យឯកជន បន្ទាប់ពីកម្ចីក្នុងវិស័យនេះ បានកើនឡើងយ៉ាងខ្លាំងរួចមក ។

- អនុញ្ញាតអោយធនាគារខ្លះដែលមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ ដែលមានសាច់ប្រាក់ងាយស្រួលលើសពីសេចក្តីត្រូវការអាចធ្វើការវិនិយោគទ្រព្យសកម្មរបស់ខ្លួនមួយចំនួនទៅបរទេសបាន ។

- កម្រិតការផ្តល់ឥណទានរបស់ធនាគារពាណិជ្ជ ទៅអោយវិស័យដែលមានហានិភ័យខ្ពស់មួយចំនួន ជាពិសេសវិស័យអចលនវត្ថុ ដោយតម្រូវអោយធនាគារពាណិជ្ជអាចផ្តល់កម្ចីត្រឹមតែ ១៥% ប៉ុណ្ណោះ ទៅអោយវិស័យនេះ ដើម្បីបង្ការកុំអោយវិបត្តិអចលនវត្ថុរាលដាលមកលើវិស័យធនាគារ ។

- (តាមសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ) បង្កើនទុនអប្បបរមារបស់ធនាគារពាណិជ្ជពី ៥០ ពាន់លានរៀល (១៣ លានដុល្លារ) ទៅ ១៥០ ពាន់ លានរៀល (៣៦,៥ លានដុល្លារ) លើកលែងតែធនាគារណាដែលមានម្ចាស់ហ៊ុនអាចជឿទុកចិត្តបាន ដែលជាធនាគារ ឬស្ថាប័នហិរញ្ញវត្ថុ ដែលមានចំណាត់ថ្នាក់វិនិយោគ ផ្តល់ដោយក្រុមហ៊ុនចាត់ថ្នាក់ដែលគួរអោយទុកចិត្តបាន និងបង្កើនទុនអប្បបរមាដល់ ៣០ ពាន់លានរៀល (៧,៣ លានដុល្លារ) សំរាប់ធនាគារឯកទេស ។

- អនុវត្តគោលនយោបាយប្រយ័ត្នប្រយែង ឈានបន្តិចម្តងៗ សំដៅធ្វើបដិដុល្លារូបនីយកម្ម ។

### ៦.២.២. វិធានការទប់ទល់អតិផរណាបណ្តាលមកពីកំណើនថ្លៃដើម

ដើម្បីឆ្លើយតបទៅនឹងបញ្ហាអតិផរណាដែលបណ្តាលមកពីកំណើនថ្លៃដើម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈមួយចំនួន ដែលមានលក្ខណៈជាវិធានការដើម្បីទប់ទល់នឹងការធ្លាក់ចុះនៃសមត្ថភាពចំណាយរបស់ប្រជាជនកម្ពុជា ជាពិសេសមន្ត្រីរាជការ ។ ដូច្នេះ វិធានការទាំងនេះមានលក្ខណៈធ្វើអោយចំណាយសាធារណៈកាន់តែកើនឡើង និង ធ្វើអោយបរិមាណរូបិយវត្ថុដែលចរាចរលើទីផ្សារកាន់តែកើនច្រើនឡើង រួមមាន៖

- ផ្តល់ឧបត្ថម្ភធនលើការនាំចូលប្រេងឥន្ធនៈ ដោយអនុវត្តនូវថ្លៃរដ្ឋបាល (ថ្លៃគោលនៅឆ្នាំ ២០០១) ដើម្បីគណនាពន្ធដែលក្រុមហ៊ុនប្រេងត្រូវបង់ពន្ធជូនរដ្ឋ ។ វិធានការនេះមានគោលដៅកម្រិតកុំអោយការឡើងថ្លៃប្រេងឥន្ធនៈជះឥទ្ធិពលទាំងស្រុងមកលើថ្លៃទំនិញក្នុងស្រុក (រាជរដ្ឋាភិបាល តាមរយៈយន្តការឧបត្ថមធនដោយស្ងៀមស្ងាត់ ចំនួន ១៧០ លាន ដុល្លារក្នុងឆ្នាំ ២០០៧ និង ២៥០ លានដុល្លារ ក្នុងឆ្នាំ ២០០៨) ។

- ផ្តល់ការឧបត្ថម្ភធនបណ្តោះអាសន្ន និងរយៈពេលខ្លី ទៅអោយក្រុមហ៊ុនអគ្គិសនីកម្ពុជា ដើម្បីរក្សាថ្លៃលក់អគ្គិសនី អោយនៅដដែល (បានផ្តល់ប្រមាណ ៣០លានដុល្លារសំរាប់ឆ្នាំ ២០០៧ និង ២០០៨) ។

- អនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ទៅតាមឥណទាន ដែលបានអនុម័ត ។

- ដំឡើងជារៀងរាល់ឆ្នាំ នូវប្រាក់បៀវត្សមូលដ្ឋានសំរាប់មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងនិវត្តជន ចំនួន ២០% ក្នុងមួយឆ្នាំ ។

- តម្លើងប្រាក់ឧបត្ថម្ភសំរាប់ប្រពន្ធ ប្តី និងកូនរបស់មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ និង កងនគរបាលជាតិ មន្ត្រីបាត់បង់សមត្ថភាព និង យុទ្ធជនពិការ ចំនួន ១០០% ចាប់ពីខែ មេសា ឆ្នាំ ២០០៨ តទៅ ។

- បង្កើនប្រាក់ឧបត្ថម្ភសំរាប់ការរស់នៅចំនួន ២០.០០០ រៀលក្នុងមួយខែ ចាប់ពីខែមេសា ទៅដល់ខែ ធ្នូ ឆ្នាំ ២០០៨ ដល់មន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធ ។

- អនុវត្តនូវវិធានការសន្សំសំចៃការប្រើប្រាស់ប្រេងឥន្ធនៈ និងថាមពលអគ្គិសនី នៅតាមក្រសួងមន្ទីររបស់រាជរដ្ឋាភិបាល ។ ការប្រើប្រាស់ប្រេងឥន្ធនៈនៅក្នុងក្រសួងមន្ទីរទាំងអស់នឹងត្រូវអនុវត្ត ក្នុងក្របខ័ណ្ឌនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ។

- តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលបានផ្តល់ឥណទានតាមអត្រាការប្រាក់ទាប ទៅអោយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សមាគមម៉ាស៊ីនកិនស្រូវ ដើម្បីទិញស្រូវសំរាប់យកមកកិន និង ស្តុកទុកសម្រាប់ជាស្តុកយុទ្ធសាស្ត្រសម្រាប់ការប្រើប្រាស់ក្នុងស្រុក ។ កម្មវិធីនេះចាប់ផ្តើមផ្តល់ជូនតាំងពីឆ្នាំ ២០០៥ មក ត្រូវបានកើនឡើងដល់ ១០ លានដុល្លារ ក្នុងឆ្នាំ ២០០៨ នេះ ។

- រាជរដ្ឋាភិបាលបានផ្តល់ការអនុញ្ញាតអោយនាំចូលនូវគ្រឿងឧបភោគបរិភោគ ឡើងវិញពីប្រទេសជិតខាងជាពិសេស ការនាំចូលសាច់ជ្រូក ដែលពីមុនត្រូវបានហាមឃាត់ដោយសារបញ្ហាសុខភាព ។

- ផ្អាកជាបណ្តោះអាសន្ននូវការប្រមូលពន្ធអប្បបរមា ចំនួន ១% ពីបណ្តារោងចក្រ សហគ្រាសកាត់ដេរ ដើម្បីជួយសម្រួលលំហូរសាច់ប្រាក់ ដើម្បីអោយរោងចក្រទាំងនោះមានលទ្ធភាពបង្កើនប្រាក់បៀវត្សអប្បបរមាចំនួន ៦ ដុល្លារបន្ថែមទៀតក្នុងមួយខែ ទៅអោយកម្មករ និង កម្មការិនី ដែលពីមុនមានចំនួនត្រឹម ៥០ ដុល្លារក្នុងមួយខែតែប៉ុណ្ណោះ ។

- ពិនិត្យលទ្ធភាពបន្ថយពន្ធនាំចូលលើធាតុចូលកសិកម្ម ។ វិធានការនេះត្រូវផ្សារភ្ជាប់ទៅនឹងការបង្កើនពន្ធនាំចូលលើទំនិញប្រណិត ដូចជារថយន្ត គ្រឿងទូរស័ព្ទ ទូរទស្សន៍ ឧបករណ៍បំពងសម្លេងទំនើប ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនវីដេអូចាក់កាសែត គ្រឿងស្រវឹង គ្រឿងសំអាង និងទំនិញដែលមិនចាំបាច់មួយចំនួនទៀត ។

- លើកលែងពន្ធលើតម្លៃបន្ថែមសំរាប់ផលិតផលកសិកម្មជាបណ្តោះអាសន្ន ដើម្បីបង្កើនសន្តិសុខស្បៀង និង លើកទឹកចិត្តអោយមានការកែច្នៃផលិតផលកសិកម្មដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ។

- ហាមឃាត់នូវការនាំចេញស្រូវ និងអង្ករបណ្តោះអាសន្ន ក្នុងរយៈពេល ២ ខែ តែបន្ទាប់មក ត្រូវបានលើកលែងវិញ ។

- បង្គាប់អោយក្រុមហ៊ុន **ហ្គ្រីន ត្រេដ** និង សមាគមម៉ាស៊ីនកិនស្រូវកម្ពុជា លក់អង្ករចេញពីស្តុករបស់ខ្លួនតាមថ្លៃថោក ដើម្បីជួយសម្រាលជីវភាពរបស់ប្រជាជនក្រីក្រ ដែលរស់នៅទីក្រុង ។

ទោះបីជាវិធានការខាងលើភាគច្រើន ពាក់ព័ន្ធទៅនឹងការបង្កើនចំណាយរបស់រដ្ឋ ឬ បន្ថយពន្ធក៏ដោយ ក៏វិធានការខាងលើនេះ ត្រូវបានដាក់ចេញដោយផ្អែកលើការកាត់បន្ថយចំណាយរបស់រដ្ឋផងដែរ ដើម្បីកាត់បន្ថយអត្រាអតិផរណា ។ វិធានការទាំងនេះរួមមាន ÷

- បន្តដាក់ចេញនូវវិធានការបង្កើនចំណូល និង កម្រិតចំណាយថវិកា ដើម្បីបង្កើនអតិរេកថវិកាចរន្ត និងកាត់បន្ថយឱនភាពថវិកាសរុប ។

- បង្កើនប្រាក់បញ្ញើរដ្ឋាភិបាលក្នុងប្រព័ន្ធធនាគារ ។

គោលបំណងនៃវិធានការគោលនយោបាយដែលដាក់ចេញដោយរាជរដ្ឋាភិបាលនេះ គឺធ្វើអោយសេដ្ឋកិច្ចកម្ពុជាងាកត្រឡប់ទៅលើវិថីនៃកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ដោយមានអតិផរណាទាបឡើងវិញ ។

ដើម្បីសំរេចបាននូវគោលបំណងនេះដែលបានដាក់ចេញនេះ ទាមទារអោយរាជរដ្ឋាភិបាលអនុវត្តនូវវិធានការគោលនយោបាយប្រទាក់ក្រឡាគ្នានៅតាមទិសដៅសំខាន់ៗ ដែលរួមមានវិធានការចម្រុះ បង្កើនប្រសិទ្ធភាពទីផ្សារ ក៏ដូចជាការកែសម្រួលគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈផងដែរ ។ *រាជរដ្ឋាភិបាលត្រូវធ្វើការកែសម្រួលគោលនយោបាយរបស់ខ្លួនជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងថ្លៃទំនិញជាប្រចាំ* ។ វិធានការដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដើម្បីរក្សាកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពរួមមាន៖

១. អនុវត្តគោលនយោបាយជំរុញការវិនិយោគក្នុងវិស័យប្រេង ជារួមគឺវិស័យប្រភពថាមពល និង ធានាថារបបវិនិយោគមានស្ថិរភាព និងអាចរំពឹងទុកបាន លើកទឹកចិត្តអោយមានកិច្ចសហការកាន់តែខ្លាំងថែមទៀតរវាងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិតាមរយៈភាពជាដៃគូដ៏រឹងមាំ ។

២. រៀបចំធ្វើការផ្សព្វផ្សាយដល់សាធារណជន អោយបានយល់ច្បាស់ពីគោលនយោបាយដើម្បីជំរុញអោយមានការសន្សំសំចៃ និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល ដែលអាចជួយសម្រាលដល់កំណើនតម្រូវការអគ្គិសនីនៅក្នុងប្រទេសកម្ពុជា ។

៣. បន្តផ្តោតការយកចិត្តទុកដាក់ លើការកែលម្អគោលនយោបាយកសិកម្ម សំដៅពង្រឹងហេដ្ឋារចនា-សម្ព័ន្ធ ប្រព័ន្ធចែកចាយ និងប្រព័ន្ធស្តុកទឹក ពង្រីកប្រព័ន្ធធារាសាស្ត្រ និងពិនិត្យមើលលទ្ធភាពផ្តល់ឧបត្ថម្ភធនទៅអោយផ្នែកដែលមានផលិតផលទិន្នផលខ្ពស់ និងធាតុចូលសំខាន់ៗនៃកសិកម្ម ដូចជាជីជាដើម ។

៤. វិធានការសារពើពន្ធថ្មីនឹងផ្តោតទៅលើការតាមដាន ត្រួតពិនិត្យ និងក្នុងករណីចាំបាច់ផ្តោតទៅលើការធ្វើអោយមានស្ថិរភាពវិស័យសេដ្ឋកិច្ចសំខាន់ៗ ដែលចាំបាច់ក្នុងការកាត់បន្ថយហានិភ័យ ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច ដូចជាវិស័យអចលនទ្រព្យ និងប្រព័ន្ធហិរញ្ញវត្ថុជាដើម ។

៥. រឹតបន្តឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដើម្បីឆ្លើយតបទៅនឹងសំពាធអតិផរណាជាទូទៅ ។

ជារួម ការកើនឡើងនៃអតិផរណាគឺជាការគំរាមកំហែងដល់វិបុលភាព និងដំណើររីកចំរើនរបស់សេដ្ឋកិច្ចជាតិ ហើយផលប៉ះពាល់នេះអាចមានទំហំធំធេង ។ ដូចនេះ គោលនយោបាយឆ្លើយតបរបស់រាជរដ្ឋាភិបាលត្រូវមានភាពសមស្រប ប្រទាក់ក្រឡាគ្នា និងមានសង្គតិភាព ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការឡើងថ្លៃប្រេង និងស្បៀងទៅលើអតិផរណា និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចទូទៅ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៤

## ការវិភាគរូបិយវត្ថុ

ប្រព័ន្ធហិរញ្ញវត្ថុ បង្កើតឡើងដោយប្រព័ន្ធធនាគារ និង ស្ថាប័នហិរញ្ញវត្ថុមិនមែនជាធនាគារ ដូចជា ក្រុមហ៊ុនធានារ៉ាប់រង មូលនិធិទៅវិញទៅមក មូលនិធិបេឡាសោធននិវត្ត និងមូលនិធិទីផ្សាររូបិយវត្ថុ ។ ទន្ទឹមនឹងនេះ នៅមានផ្នែកហិរញ្ញវត្ថុក្រៅប្រព័ន្ធថែមទៀត ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ប្រព័ន្ធធនាគារមានសមាសធាតុដូចតទៅៈ

- ធនាគារកណ្តាល ដែលជានិយ័តករនៃប្រព័ន្ធធនាគារ និង

- ធនាគារពាណិជ្ជ ឬ ធនាគារទទួលប្រាក់បញ្ញើ ដែលបង្កើតឡើងនូវប្រព័ន្ធទូទាត់នៅក្នុងសេដ្ឋកិច្ចជាតិ រួមទាំង រូបិយវត្ថុ និង ប្រាក់បញ្ញើផងដែរ ។

ស្ថាប័នហិរញ្ញវត្ថុមានតួនាទីជាអ្នកបង្វែរប្រាក់សញ្ច័យហិរញ្ញវត្ថុ ទៅអោយក្រុមហ៊ុនអាជីវកម្ម ដើម្បីធ្វើការវិនិយោគនៅក្នុងសេដ្ឋកិច្ចពិត ។ ដំណើរការនេះហៅថាជា **«អន្តរការីកម្មហិរញ្ញវត្ថុ»** ។ អ្នកត្រូវការធនធានហិរញ្ញវត្ថុអាចខ្ចីពីធនាគារ តាមរយៈនូវឧបករណ៍ហិរញ្ញវត្ថុជាច្រើន ដូចជា ភាគហ៊ុន សញ្ញាប័ណ្ណ លិខិតពាណិជ្ជកម្ម ឥណទានសាងសង់ និង មូលនិធិទៅវិញទៅមក ។

### ១- តួនាទីរបស់ធនាគារកណ្តាល

ធនាគារកណ្តាល គឺជាស្ថាប័នដែលមានភារកិច្ចបោះផ្សាយក្រដាសប្រាក់ គ្រប់គ្រងនូវទុនបម្រុងអន្តរជាតិ ទទួលឥណទានដើម្បីគ្រប់គ្រងតុល្យភាពជញ្ជីងទូទាត់ ដើរតួនាទីជាធនាគារិករបស់រដ្ឋាភិបាល ត្រួតពិនិត្យប្រព័ន្ធរូបិយវត្ថុ និង បម្រើការជាឥណទាយិកចុងក្រោយដល់ប្រព័ន្ធធនាគារ ។

តួនាទីសំខាន់បំផុតរបស់ធនាគារកណ្តាល គឺការបម្រើការងារជាឥណទាយិកចុងក្រោយរបស់ប្រព័ន្ធធនាគារ នៅពេលដែលមានវិបត្តិធនាគារ ។ នៅពេលមានការជ្រួលច្របល់ខាងផ្នែកហិរញ្ញវត្ថុ ដែលគំរាមកំហែងដល់ប្រព័ន្ធធនាគារ ធនាគារកណ្តាលត្រូវដាក់ចេញនូវវិធានការជាបន្ទាន់ ដើម្បីធានាអោយបាននូវសេចក្តីទុកចិត្តរបស់អ្នកផ្ញើប្រាក់ ក្នុងគោលដៅបញ្ចៀសអោយខាងតែបាននូវការមកដកយកប្រាក់បញ្ញើពីធនាគារ ដែលអាចអោយប្រព័ន្ធធនាគារទាំងមូលដួលរលំ ឬ ក្ស័យធនបាន នៅពេលដែលអ្នកផ្ញើប្រាក់ភាគច្រើនមានការស្លន់ស្លោរមកដកប្រាក់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចេញពីធនាគារ ។ ម្យ៉ាងវិញទៀត ប្រសិនបើមានធនាគារណាមួយជួបប្រទះនឹងកង្វះខាតសាច់ប្រាក់ ប្រព័ន្ធធនាគារទាំងមូលនឹងជួបប្រទះនឹងវិបត្តិសាច់ប្រាក់ ធនាគារនឹងមានការមិនទុកចិត្តគ្នា ហើយមិនអោយឥណទានគ្នាខ្ចី ក្នុងក្របខ័ណ្ឌនៃកម្ចីអន្តរធនាគារ ។ ប្រការនេះនឹងបង្កើតអោយមាននូវវិបត្តិមិនទុកចិត្តគ្នា ហើយលទ្ធផលនឹងមានការ «បង្កកឥណទាន» និង «វិបត្តិខ្វះឥណទាន» ។ ក្នុងករណីនេះ ធនាគារកណ្តាលមានតួនាទីបញ្ចៀសនូវការដួលរលំនូវប្រព័ន្ធធនាគារទាំងមូលតែម្តង ដោយចេញនូវការធានាចំពោះអ្នកផ្ញើប្រាក់ ដើម្បីចេញសងប្រាក់បញ្ញើទាំងអស់ក្នុងគោលដៅរារាំងមិនអោយវិបត្តិនេះ រាលដាលដល់ធនាគារផ្សេងទៀតនៅក្នុងប្រព័ន្ធធនាគារ ។

**តារាង៤.១- តារាងតុល្យការធនាគារជាតិនៃកម្ពុជា** (ថ្ងៃទី ៣១ ធ្នូ ២០០៧) ឯកតាលានរៀល

| **ទ្រព្យសកម្ម** | | **ទ្រព្យអកម្ម** | |
|---|---|---|---|
| ***ទ្រព្យសកម្មបរទេស*** | | ***រូបិយវត្ថុបម្រុង*** | |
| - ប្រាក់បញ្ញើរជារូបិយប័ណ្ណនៅបរទេស | ៥.៧៩១.២២១ | - រូបិយវត្ថុបោះផ្សាយ | ២.២១១.៨៨៤ |
| - ប្រាក់ SDR នៅ IMF | ៨៩៣ | - ប្រាក់បញ្ញើររបស់ធនាគារពាណិជ្ជ | ៣.១១៨.៩០៨ |
| - ប្រាក់រៀលបង់ចូលជាសមាជិក IMF | ៥៤២.២៦៦ | ***ទ្រព្យអកម្មបរទេស*** | |
| -វិនិយោគលើមូលប័ត្របរទេស | ១.៣២០.៩៩០ | - បំណុលចំពោះ IMF | ៦៤៦.៤៨៣ |
| - លោហធាតុមានតម្លៃនៅបរទេស | ១.៣៤៨.៨៨២ | ***ប្រាក់បញ្ញើររបស់រដ្ឋាភិបាល*** | ១.៩២៧.៧៨៦ |
| ***សាច់ប្រាក់ជារៀល និង ជារូបិយប័ណ្ណ*** | ២៩៤.៦៦៦ | ***ដើមទុន*** | ១០០.០០០ |
| ***អោយខ្ចីនិង បុរេប្រទាន*** | | ***ទុនបម្រុង*** | ១.៧២៣.៩២៦ |
| - ចំពោះធនាគារពាណិជ្ជ | ៧១.៨០០ | ***រំលស់បង្គរទុក*** | ៩៦.១៨៨ |
| - ចំពោះរដ្ឋាភិបាល | ២៩៦.៥៨៧ | ***សវិធានធន*** | ២០៩.៦៧៩ |
| ***អចលនទ្រព្យ*** | ៤៩១.១៣៦ | ***ផ្សេងៗ*** | ៣.១៧៨.៦៣៤ |
| ***ផ្សេងៗ*** | ៣.០៤៩.០៤៧ | | |
| **សរុប** | **១៣.២០៧.៤៨៨** | **សរុប** | **១៣.២០៧.៤៨៨** |

ដូច្នេះ ការវិភាគម៉ាក្រូសេដ្ឋកិច្ចត្រូវផ្តោតទៅលើតារាងតុល្យការរបស់ធនាគារកណ្តាលតែម្តង ជាពិសេសចលនានៃការបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ តាមរយៈការបោះផ្សាយក្រដាស់ប្រាក់ថ្មី និង លំហូរចូលនៃមូលធនពីក្រៅប្រទេស ។ មានតែធនាគារកណ្តាលប៉ុណ្ណោះទេ ដែលអាចបង្កើតនូវមូលដ្ឋានរូបិយវត្ថុបាន តាមរយៈប្រតិបត្តិការហិរញ្ញវត្ថុ ដូចជាការផ្តល់កម្ចីអោយរដ្ឋាភិបាល និង ធនាគារពាណិជ្ជ អន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីទិញ ឬលក់រូបិយប័ណ្ណ ដើម្បីកែសម្រួលអត្រាប្តូរប្រាក់ ។ ធនាគារកណ្តាល គឺជាស្ថាប័នដែលរៀបចំ និង អនុវត្តនូវគោល-នយោបាយរូបិយវត្ថុ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តារាងតុល្យការរបស់ធនាគារកណ្ដាល គឺជាឯកសារមួយដ៏សំខាន់សម្រាប់ការវិភាគម៉ាក្រូសេដ្ឋកិច្ច ។ ផ្នែកសំខាន់ៗនៃតារាងតុល្យការនេះមាន៖

***- ទ្រព្យសកម្មបរទេសសុទ្ធ:*** ដោយមានសមាសធាតុដូចតទៅ៖ (១) ទុនបម្រុងអន្តរជាតិ (ខាងផ្នែកទ្រព្យសកម្មមាន មាស រូបិយប័ណ្ណ ទុននៅក្នុងមូលនិធិរូបិយវត្ថុអន្តរជាតិ អេសដេអ៊ែរ ។ ខាងផ្នែកទ្រព្យអកម្ម មានបំណុលរយៈពេលខ្លីដែលជំពាក់ធនាគារកណ្ដាលបរទេស ពោលគឺ ប្រាក់បញ្ញើរបស់ធនាគារកណ្ដាលបរទេស ឧបករណ៍ស្វប់ Overdraft បំណុលរយៈពេលមធ្យម និង រយៈពេលវែង ដូចជាការប្រើប្រាស់កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ) (២) ទ្រព្យសកម្ម និង ទ្រព្យអកម្មដទៃទៀតរបស់ធនាគារកណ្ដាល ដែលមិនអាចរាប់ចូលជាទុនបម្រុង ។

***- ឥណទេយ្យសុទ្ធរដ្ឋាភិបាល:*** គឺជាឥណទានដោយផ្ទាល់ និង មូលប័ត្ររបស់រដ្ឋាភិបាល ដែលធនាគារកណ្ដាលរក្សាទុក ។ ចំនួននេះត្រូវបានកត់ត្រា ដោយដកចេញនូវប្រាក់បញ្ញើរបស់រដ្ឋាភិបាល ដោយសារមានតែឥណទេយ្យសុទ្ធរដ្ឋាភិបាលតែប៉ុណ្ណោះ ដែលមានឥទ្ធិពលទៅលើការបង្កើតមូលដ្ឋានរូបិយវត្ថុ ។

***- ឥណទានផ្ដល់អោយធនាគារ:*** រាប់បញ្ចូលនូវឥណទានដោយផ្ទាល់ទាំងអស់ ដល់ធនាគារពាណិជ្ជ និង បំណុលរយៈពេលខ្លីរបស់ធនាគារពាណិជ្ជ (Bill of exchange)។ ឥណទាននេះផ្ដល់តាមរយៈយន្តការឥណទានដែលធនាគារជាតិអោយធនាគារពាណិជ្ជខ្ចី ដោយយកអត្រាអប្បហារ (Discount rate)។

***- ឥណទានផ្នែកឯកជន:*** ធនគារកណ្ដាលអាចអោយឥណទាន ទៅសហគ្រាសខ្លះខ្ចី ។

***- សមាសធាតុផ្សេងៗ:*** ដូចជាអចលទ្រព្យ នៅក្នុងទ្រព្យសកម្ម និង ដើមទុន និង ទុនបម្រុងនៅក្នុងទ្រព្យអកម្ម ។

***- រូបិយវត្ថុបម្រុង:*** រូបិយវត្ថុបម្រុងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការវិភាគ និង ការកំណត់គោល-នយោបាយរូបិយវត្ថុ ។ រូបិយវត្ថុបម្រុង គឺជារូបិយវត្ថុបោះផ្សាយ ដែលទុកនៅក្នុងធនាគារ និង កំពុងដាក់អោយចរាចរ និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ។ ប្រាក់បញ្ញើជារូបិយប័ណ្ណរបស់សាធារណៈជនក៏អាចរាប់បញ្ចូលក្នុងរូបិយវត្ថុបម្រុងបានដែរ ។

យើងឃើញថា កត្តាមួយចំនួន ដែលមានឥទ្ធិពលលើរូបិយវត្ថុបម្រុង (RM)÷

- ***ទ្រព្យសកម្មបរទេសសុទ្ធ*** (NFA)


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ***ឥណទេយ្យរដ្ឋាភិបាលសុទ្ធ*** (NCG)
- ***ឥណទានផ្តល់អោយធនាគារពាណិជ្ជ*** (CDMB)
- ***ឥណទានផ្តល់អោយផ្នែកឯកជន*** (CPS)
- ***ផ្សេងៗ*** (OIN)

ដូច្នេះ យើងអាចសរសេរសមីការដូចតទៅ ÷

$$RM \equiv NFA + NCG + CDMB + CPS + OIN \quad (4.1)$$

តែបើគិតជាលំហូរវិញ សមីការនេះអាចសរសេរបានដូចតទៅ÷

$$\Delta RM \equiv \Delta NFA + \Delta NCG + \Delta CDMB + \Delta CPS + \Delta OIN \quad (4.2)$$

## ២. ធនាគារពាណិជ្ជ

ធនាគារពាណិជ្ជដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ÷

ទីមួយ- ធនាគារពាណិជ្ជផ្តល់នូវសេវាអន្តរការីកម្មហិរញ្ញវត្ថុរវាងអ្នកសញ្ជ័យ និង វិនិយោគិន ដែលជាដំណើរការមួយ ដែលប្រែក្លាយទ្រព្យសកម្មហិរញ្ញវត្ថុ អោយមានការីបរិច្ឆេទច្បាស់លាស់ ។ គុណសម្បត្តិរបស់ធនាគារពាណិជ្ជ គឺ ប្រែក្លាយប្រាក់បញ្ញើ ដែលមានរយៈកាលខ្លី អោយក្លាយទៅជាឥណទាន ដែលមានរយៈកាលវែង ។

ទីពីរ- ធនាគារពាណិជ្ជដើរតួនាទី ជាអ្នកបង្កើតរូបិយវត្ថុបញ្ញើនៅក្នុងសេដ្ឋកិច្ចជាតិ ដោយផ្តល់ឥណទានដលវិនិយោគិន ដែលត្រូវការធនធានហិរញ្ញវត្ថុ ដើម្បីយកទៅដាក់ទុនវិនិយោគ ។ ដូច្នេះ ធនាគារពាណិជ្ជមានតួនាទីបង្កើតនូវរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ចជាតិ ។

ទីបី- សកម្មភាពរបស់ធនាគារពាណិជ្ជ ជាពិសេសគោលនយោបាយរបស់ធនាគារពាណិជ្ជក្នុងការទទួលប្រាក់បញ្ញើ និង ផ្តល់នូវឥណទាន ជះឥទ្ធិពលទៅលើការផ្គត់ផ្គង់រូបិយវត្ថុ និង សាច់ប្រាក់នៅក្នុងសេដ្ឋកិច្ចជាតិ ។

ទីបួន- ធនគារពាណិជ្ជជួយធនាគារកណ្តាល ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៣. ការអង្កេតរូបិយវត្ថុ និង ការវិភាគរូបិយវត្ថុ

### ៣.១. ការអង្កេតរូបិយវត្ថុ

ការអង្កេតរូបិយវត្ថុ គឺជាតារាងតុល្យការនៃប្រព័ន្ធធនាគារទាំងមូល ដោយប្រមូលផ្ដុំនូវតារាងតុល្យការរបស់ធនាគារកណ្ដាល និង តារាងតុល្យការរបស់ធនាគារពាណិជ្ជទាំងអស់ ។ ទ្រព្យសកម្ម និង ទ្រព្យអកម្មនៃការអង្កេតរូបិយវត្ថុ គឺជាទ្រព្យសកម្ម និង ទ្រព្យអកម្មនៃប្រព័ន្ធធនាគារទាំងមូលតែម្ដង ។ ដូច្នេះ ការអង្កេតរូបិយវត្ថុមានសារៈសំខាន់ណាស់ ហើយមានគោលដៅផ្ដល់អ្នកសម្រេចគោលនយោបាយ នូវទិន្នន័យស្ដីពីសម្រាប់យល់ពីការវិវត្តនៃស្ថានភាពរូបិយវត្ថុ និង ឥណទាននៃប្រព័ន្ធធនាគារទាំងមូលតែម្ដង ក្នុងគោលដៅចាត់វិធានការអោយបានទាន់ពេលវេលា ។

**តារាងលេខ ៤.២- ការអង្កេតរូបិយវត្ថុ**

| ទ្រព្យសកម្ម | ទ្រព្យអកម្ម |
|---|---|
| ***ទ្រព្យសកម្មបរទេសសុទ្ធ*** (NFA) | ***រូបិយវត្ថុទូទៅ*** (M2) |
| - ទ្រព្យសកម្មបរទេស | ***រូបិយវត្ថុ*** (M1) |
| - ទ្រព្យអកម្មបរទេស | - រូបិយវត្ថុក្រៅធនាគារ (CY) |
| ***ទ្រព្យសកម្មក្នុងស្រុកសុទ្ធ*** (NDA) | - ប្រាក់បញ្ញើចរន្ត (DD) |
| - ឥណទានក្នុងស្រុក (NDC) | ***រូបិយវត្ថុផ្សេងៗ*** (QM) |
| - *ឥណទេយ្យសុទ្ធរដ្ឋាភិបាល* (NCG) | - ប្រាក់បញ្ញើមានកាលកំណត់ និង សន្សំ (TD) |
| @ ឥណទេយ្យរដ្ឋាភិបាល | - ប្រាក់បញ្ញើជារូបិយវត្ថុ (FC) |
| @ ប្រាក់បញ្ញើរដ្ឋាភិបាល | |
| - ឥណទានផ្នែកមិនមែនរដ្ឋាភិបាល | |
| - *សហគ្រាសរដ្ឋ* | |
| - *ឥណទានវិស័យឯកជន* (CPS) | |
| - ខ្ទង់ផ្សេងៗសុទ្ធ (OIN) | |
| - *ប្រាក់បញ្ញើហាមឃាត់* | |
| - *មូលធន និង ធនបម្រុង* | |
| - *ផ្សេងៗ* | |

តារាង ៤.២ បង្ហាញអោយឃើញថា ទ្រព្យអកម្មនៃប្រព័ន្ធធនាគារនៅក្នុងការអង្កេតរូបិយវត្ថុ រូបិយវត្ថុទូទៅ (M2) គឺជាទ្រព្យអកម្មនៃប្រព័ន្ធធនាគារ ឬ អាចហៅម៉្យាងទៀតថា ជាស្តុករូបិយវត្ថុ ។ រូបិយវត្ថុទូទៅ (M2) គឺជាផលបូករវាងរូបិយវត្ថុ (M1) និង រូបិយវត្ថុផ្សេងៗ (QM) ។

រូបិយវត្ថុ (M1) = រូបិយវត្ថុក្រៅធនាគារ (CY) + ប្រាក់បញ្ញើចរន្ត (DD)

រូបិយវត្ថុទូទៅ (M2) = រូបិយវត្ថុ (M1) + រូបិយវត្ថុផ្សេងៗ (QM)

ដូច្នេះ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

$$M2 = CY + DD + TD \quad (4.3)$$

សមីការទំនាក់ទំនងរវាងទ្រព្យសកម្ម និង ទ្រព្យអកម្មនៃប្រព័ន្ធធនាគារបញ្ជាក់អោយឃើញថាស្តុករូបិយវត្ថុគឺជាផលបូកនៃសមភាគីរបស់ខ្លួន ពោលគឺទ្រព្យសកម្មបរទេសសុទ្ធ (NFA) និង ទ្រព្យសកម្មក្នុងស្រុកសុទ្ធ (NDA)។ ដូច្នេះ យើងបាន៖

$$M2 = NFA + NDA \quad (4.4)$$

ដោយ $NDA = NDC + OIN$

នោះយើងបាន៖

$$M2 = NFA + NDC + OIN \quad (4.5)$$

ដូច្នេះ គិតជាកំណើន៖

$$\Delta M2 = \Delta NFA + \Delta NDC + \Delta OIN \quad (4.6)$$

## ៣.២. ការវិភាគរូបិយវត្ថុ

ការអង្កេតរូបិយវត្ថុបានបង្ហាញនូវទំនាក់ទំនងពីរសំខាន់ៗ៖

- ទំនាក់ទនងរវាងស្ថានភាពអន្តរជាតិរបស់ប្រទេស និង ទ្រព្យសកម្មបរទេសសុទ្ធ ។ និង
- ទំនាក់ទំនងដោយផ្ទាល់គណនីរដ្ឋាភិបាល និង ហិរញ្ញប្បទានរបស់រដ្ឋតាមរយៈប្រព័ន្ធធនាគារ ។

ប្រព័ន្ធធនាគារក៏មានទំនាក់ទំនងជាមួយវិស័យសេដ្ឋកិច្ចពិត និង គណនីជាតិ តាមរយៈតម្រូវការរូបិយវត្ថុ និង ឥណទាន ដែលផ្តល់ទៅអោយផ្នែកឯកជន ។

***– ទំនាក់ទំនងរវាងវិស័យធនាគារជាមួយនឹងជញ្ជីងទូទាត់:*** ប្រតិបត្តិការជញ្ជីងទូទាត់ត្រូវបានកត់ត្រាទុកក្រោមគណនីចរន្ត ហើយតុល្យភាពរួមនៃជញ្ជីងទូទាត់ត្រូវបានផ្តល់ហិរញ្ញប្បទាន តាមរយៈបម្រែបម្រួលទុនបម្រុងអន្តរជាតិសុទ្ធនៃប្រព័ន្ធធនាគារ ។ ជារួម ទ្រព្យសកម្មបរទេសសុទ្ធប្រែប្រួលមានលក្ខណៈដូចគ្នា ទោះបីមានមូលហេតុខុសគ្នាក៏ដោយ៖ ពោលទោះបីជាការប្រែប្រួលនេះបណ្តាលមកពីការអង្កេតរូបិយវត្ថុ ឬ សមីការជញ្ជីងទូទាត់ក៏ដោយ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឧទាហរណ៍ នៅក្នុងការអង្កេតរូបិយវត្ថុ៖

$$\Delta NFA = \Delta M2 - \Delta NDA$$

ហើយនៅក្នុងជញ្ជីងទូទាត់៖

$CAB + \Delta FI + = 0$

ដោយសារ $\Delta NFA = - \Delta RES$ នោះយើងបាន៖

$$\Delta NFA = \Delta M2 - \Delta NDA = CAB + FE = - \Delta RES \quad (4.7)$$

សមីការនៃការអង្កេតរូបិយវត្ថុបង្ហាញអោយឃើញថា អតិរេកនៃការពង្រីកឥណទានក្នុងស្រុក លើសកំណើននៃស្តុករូបិយវត្ថុ (ដែល នៅក្នុងលក្ខខណ្ឌតុល្យភាព ស្មើនឹងតម្រូវការរូបិយវត្ថុ) ត្រូវបានឆ្លុះបញ្ចាំងអោយឃើញនូវការធ្លាក់ចុះនៃទ្រព្យសកម្មបរទេសសុទ្ធនៃប្រព័ន្ធធនាគារ ($\Delta$NFA មានសញ្ញាអវិជ្ជមាន) ។ ទំនាក់ទំនងនេះ គឺជាមូលដ្ឋាននៃជំហររូបិយវត្ថុ សម្រាប់ការរៀបចំនូវតុល្យភាពអត្រាប្តូរប្រាក់ ។

ជាការពិតណាស់ ភាពខុសគ្នារវាងរូបិយវត្ថុមានប្រភពផ្ទៃក្នុង (ឥណទានក្នុងស្រុក) និង រូបិយវត្ថុ ដែលមានប្រភពពីខាងក្រៅ (ទ្រព្យសកម្មបរទេសសុទ្ធ) ក៏ដូចជាទំនាក់ទំនងរវាងអញ្ញត្តិទាំងពីរ គឺជាប្រភពស្នូលនៃក្របខ័ណ្ឌកម្មវិធីនីយកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី៣

# គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

## ជំពូកទី៥

## កេនស៍ និង ការវិភាគម៉ាក្រូសេដ្ឋកិច្ច

### ១. សេចក្តីផ្តើម

តាមគំរូនៃទ្រឹស្តីបូរាណនិយមបានសន្មតថា ការផ្គត់ផ្គង់សរុប ជានិច្ចកាលតែងតែស្មើនឹងតម្រូវការសរុប ពីព្រោះច្បាប់របស់លោក **សេយ៍** បានពោលអះអាងថា *«ការផ្គត់ផ្គង់បង្កើតតម្រូវការផ្ទាល់ខ្លួនរបស់វា»* ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ការធ្លាក់ចុះជាទូទៅនៃសេដ្ឋកិច្ចពិភពលោកនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ពោលគឺពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៣៩ គឺជាការធ្លាក់ចុះដែលមានទំហំធំធេង និង មានរយៈពេលវែង ។ សមត្ថភាពផលិតកម្មរបស់ប្រទេសអភិវឌ្ឍន៍មានកម្រិតខ្ពស់ជាងយ៉ាងខ្លាំង ធៀបទៅនឹងតម្រូវការធាតុចេញជាក់ស្តែងដែលប្រទេសទាំងនោះត្រូវផលិត ។ ស្រដៀងគ្នានេះដែរផលិកម្មកសិកម្មភាគច្រើននិង ផលិតកម្មឧស្សាហកម្មសំខាន់ៗមួយចំនួនផ្សេងទៀតនៅជុំវិញពិភពលោកបានផ្តល់ទិន្នផលលើសលប់ ក្រៃលែងធៀបទៅនឹងតម្រូវការជាក់ស្តែង ។ ចំណែកអត្រានៃភាពគ្មានការងារធ្វើបានកើនឡើងពី ៣% នៅឆ្នាំ ១៩២៩ ដល់ ២៥% នៅឆ្នាំ ១៩៣៣ ហើយជាមួយគ្នានោះ ផលិផលជាតិសរុបបានធ្លាក់ចុះប្រមាណ ៣០% ។ ស្ថិតនៅក្នុងបរិបទនេះហើយ ដែលទ្រឹស្តីសេដ្ឋកិច្ចបែប **កេនស៍**និយម ត្រូវបានបង្កើតឡើង ។

នៅឆ្នាំ ១៩៣៦ សេដ្ឋវិទូជនជាតិអង់គ្លេសឈ្មោះ **ចន ម៉ៃណាដ កេនស៍** (John Maynard Keynes) បានសរសេរសៀវភៅមួយដែលមានចំណងជើងថា «**ទ្រឹស្តីទូទៅស្តីអំពីអនិកម្មភាព ការប្រាក់ និង រូបិយវត្ថុ**» ដែលបានក្លាយជាមូលដ្ឋាននៃប្រព័ន្ធទ្រឹស្តីបែបកេនស៍និយម ។ និកម្មភាពកម្រិតខ្ពស់នៅប្រទេសអង់គ្លេសបានក្លាយជាប្រធានបទនៃការជជែកពិភាក្សានៅក្នុងចំណោមសេដ្ឋវិទូជាច្រើន និង អ្នករៀបចំគោលនយោបាយស្តីអំពីហេតុបច្ច័យ និង គោលនយោបាយត្រឹមត្រូវ ដើម្បីដោះស្រាយនិកម្មភាព ដែលបានកើនឡើងនៅពេលនោះ ។

តាមទ្រឹស្តីរបស់កេនស៍និកម្មភាពកម្រិតខ្ពស់បានកើតឡើង ពីភាពទន់ខ្សោយនៃតម្រូវការសរុប ។ តម្រូវការសរុបមានកម្រិតទាបពេក ដោយសារតម្រូវការនៃការវិនិយោគមិនគ្រប់គ្រាន់ ។ ទ្រឹស្តីកេនស៍បានផ្តល់មូលដ្ឋានសម្រាប់គោលនយោបាយសេដ្ឋកិច្ច ដើម្បីដោះស្រាយបញ្ហានិកម្មភាព ដោយធ្វើឡើងតាមរយៈការជំរុញតម្រូវការសរុប ។ នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ លោក **កេនស៍** បានស្នើអោយប្រកាន់យកវិធានការនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ធ្វើជាឧបករណ៍សម្រាប់ដោះស្រាយបញ្ហា ។ ក្នុងនោះ ចំណាយរបស់រដ្ឋាភិបាលត្រូវផ្តោតជាសំខាន់ទៅលើគម្រោងសាធារណៈ ក្នុងក្របខ័ណ្ឌសកម្មភាពនៃគោលនយោបាយសារពើពន្ធដ៏ទូលំទូលាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មួយ ដើម្បីជំរុញលើកទឹកចិត្តឱ្យតម្រូវការមានការកើនឡើង ។ ចំណាយខាងលើនោះត្រូវអនុត្តដោយផ្ទាល់ និង ដោយប្រយោល ដោយហេតុថាវានឹងធ្វើឱ្យប្រាក់ចំណូលកើនឡើង ហើយចំណាយរបស់អ្នកប្រើប្រាស់ ជាពិសេសអ្នកដែលត្រូវបានជួលឱ្យបម្រើការងារនៅក្នុងគម្រោងសាធារណៈក៏ត្រូវកើនឡើង ។ ហើយតាមរយៈនេះ អនិកម្មភាពនឹងត្រូវបានបង្កើតឡើង ។ ជាងនេះទៅទៀត ទ្រឹស្តីកេនស៍គាំទ្រផងដែរ ដល់ការប្រើប្រាស់នូវគោលនយោបាយរូបិយវត្ថុ និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើនិយ័តកម្មលើតម្រូវការសរុប ។

យោងតាមការវិភាគតាមបែបបុរាណនិយម អ្នកដែលជំទាស់នឹងគំនិតរបស់ **កេនស៍** ជឿថា ការបង្កើនចំណាយរបស់រដ្ឋាភិបាល ទោះជាធ្វើឡើងតាមរយៈហិរញ្ញប្បទានដោយការបង្កើនរូបិយវត្ថុបន្ថែម និង ផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុក៏ដោយ ក៏វានឹងមិនមានឥទ្ធិពលដល់អនិកម្មភាព ឬ កម្រិតថ្លៃឡើយ ។ ប្រសិនបើគម្រោងការងារសាធារណៈត្រូវបានទទួលហិរញ្ញប្បទាន ដោយការបោះរូបិយវត្ថុបន្ថែម កម្រិតថ្លៃនឹងមានការប្រែប្រួល ប៉ុន្តែកម្រិតធាតុចេញ ឬ កម្រិតឈានិកម្មភាពនឹងមិនមានការប្រែប្រួលឡើយ ។ នៅក្នុងប្រព័ន្ធទ្រឹស្តីបែបបុរាណនិយម គោលនយោបាយរូបិយវត្ថុមិនមានឥទ្ធិពលលើចំណូលទេ ។ ហេតុនេះ *ការគ្រប់គ្រងថវិកាដោយប្រយ័ត្នប្រយែងបានក្លាយជាមធ្យោបាយ សម្រាប់ធ្វើអោយមានតុល្យភាពរវាងចំណាយ និងចំណូលថវិកា* ។ តាមទ្រឹស្តីនេះ គេទទួលស្គាល់ថា ការបង្កើនពន្ធ ឬ កាត់បន្ថយចំណាយរបស់រដ្ឋាភិបាល នឹងមិនបន្ថយតម្រូវការសរុប ធាតុចេញសរុប និង អនិកម្មភាពនោះទេ ពីព្រោះគេយល់ថា ធាតុចេញ និង អនិកម្មភាពត្រូវបានកំណត់ដោយការផ្គត់ផ្គង់ ។ ហេតុដូច្នេះ តាមទ្រឹស្តីបុរាណនិយម គោលនយោបាយសារពើពន្ធមិនមានឥទ្ធិពលលើតម្រូវការសរុបនោះឡើយ ។

## ២. លក្ខខណ្ឌធាតុចេញសមតា

ការវិភាគនៃគំរូរបស់ **កេនស៍** ផ្អែកទៅលើសម្មតិកម្មសាមញ្ញមួយចំនួនដូចខាងក្រោម ÷

- កត្តាផលិតកម្មទាំងអស់ (K, L, E, N ដែល N តំណាងឱ្យធនធានធម្មជាតិ) ជាកម្មសិទ្ធិរបស់ «គេហជន» (មិនមែនជារបស់កម្មករដូចនៅក្នុងគំរូបុរាណនិយមឡើយ) ។

- ធាតុចេញទាំងអស់ត្រូវបានផលិតដោយសហគ្រាសឯកជន ហើយរដ្ឋាភិបាលទិញផលិតផលទាំងនោះពីសហគ្រាសឯកជនមិនមែនផលិតដោយខ្លួនឯងនោះឡើយ ។

- សេដ្ឋកិច្ចទាំងមូលបិទជិតមិនមានការនាំចេញ ឬ នាំចូលនោះឡើយ ។ ចំណូលជាតិ (ចំណូលដែលរកបានដោយកត្តាផលិតកម្មទាំងអស់) ស្មើនឹងផលិតផលក្នុងស្រុកសរុប ។

- កម្រិតថ្លៃសរុបមានលក្ខណៈមិនប្រែប្រួល ហើយអថេរទាំងអស់ជាអថេរពិត និង ការផ្លាស់ប្តូរទាំងអស់គឺជាការផ្លាស់ប្តូរពិត ។

- សញ្ញាណសម្គាល់មួយ នៃគំរូរបស់កេនស៍បានកំណត់ថា កម្រិតសមតានៃធាតុចេញសរុបដែលទាមទារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យធាតុចេញសរុប (Y) នេះ ត្រូវស្មើនឹងតម្រូវការសរុប (E) ។

$$(5.1) \quad Y = E$$

ជាទូទៅតម្រូវការមានបីប្រភេទ គឺតម្រូវការប្រើប្រាស់ (C) តម្រូវការវិនិយោគ (I) និង តម្រូវការរបស់រដ្ឋាភិបាល (G) ។ ដូច្នេះ ផ្អែកតាមទំនាក់ទំនងខាងលើនេះ គេអាចកំណត់រូបមន្តដូចខាងក្រោម ÷

$$(5.2) \quad Y = E = C + I + G$$

ដែលក្នុងនោះ (C) ត្រូវបង្កើតឡើងដោយការផ្តល់នូវកត្តាផលិតកម្មដោយគេហជន ចំពោះសហគ្រាស ហើយ (I) បានមកពីការខ្ចីបន្តពីគេហជន និង ការបង់ការប្រាក់ ចំណែកឯចំណាយរបស់រដ្ឋាភិបាល (G) បានទទួលហិរញ្ញប្បទានពីចំណូលពន្ធ (T) ដែលសន្មតថាមានសមតុល្យស្មើនឹង (G)។ ផ្អែកតាមការសន្មតទាំងនេះ និងឈរលើសម្មតិកម្ម ដែលថាផលិតផលជាតិសរុប (Y) ស្មើនឹងចំណូលជាតិ យើងអាចនិយាយថាសមីការដែលមានទំនាក់ទំនងរវាងធាតុចេញ និង ចំណាយទាំងអស់ អាចតាងដូចខាងក្រោម ÷

$$(5.3) \quad Y \equiv C + S + T$$

ទស្សនាទានគន្លឹះមួយនៃគំរូរបស់កេនស៍ គឺ «**ការរំពឹងទុក**» មានន័យថា ការធ្វើសេចក្តីសម្រេចចិត្តនៅថ្ងៃនេះ គឺ ជាការប៉ាន់ស្មាន ដែលផ្អែកលើលក្ខខណ្ឌដែលនឹងកើតមាននៅថ្ងៃស្អែក ។ ចំណុចនេះបង្ហាញថា នៅមានភាពផ្សេងគ្នា ដែលអាចកើតមានឡើងរវាងលទ្ធផលនៃការប៉ាន់ស្មាន និងលទ្ធផលជាក់ស្តែង ។ ក្នុងខណៈដែលភាពផ្សេងគ្នានេះ មានឥទ្ធិពលទៅលើចំណាយគ្រប់ប្រភេទ (C, I, និង G) លោក **កេនស៍** បានផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើភាពផ្សេងគ្នា រវាងការវិនិយោគនៅក្នុងផែនការ (I) និង ការវិនិយោគជាក់ស្តែង ($I_r$) ដែលត្រូវធ្វើឡើង ដោយសហគ្រាសឯកជន ។ ផ្អែកតាមទស្សនាទាននេះ យើងអាចទាញបាននូវសមីការដូចខាងក្រោម ÷

$$(5.4) \quad Y = C + I_r + G$$

ផ្អែកតាមការសមីការនេះរួមជាមួយនឹងសមីការ (5.3) និង (5.4) ខាងលើយើងអាចពិនិត្យ និង កែសម្រួលសមីការនេះទៅជា ÷

$$(5.5) \quad S + T = I + G$$

ដូចគ្នានេះដែរ ដោយប្រើប្រាស់សមីការ (5.2) និង (5.4) យើងអាចធ្វើសេចក្តីសន្និដ្ឋានលើចំណុចសមតា បានដូចខាងក្រោម ÷

$$(5.6) \quad I_r = I$$

ដូច្នេះ យន្តការដែលទទួលស្គាល់ថា ការវិនិយោគនៅក្នុងផែនការ ជានិច្ចកាលតែងតែស្មើនឹងការវិនិយោគ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាក់ស្តែងនោះ តាមគំរូរបស់កេនស៍ គឺការវិនិយោគទៅលើសន្និធិរបស់អាជីវកម្ម ហើយចំណុចយើងនឹងបានឃើញនៅផ្នែកខាងក្រោយនេះដែរ ។

ហេតុដូច្នេះ តាមគំរូរបស់កេនស៍ មានជម្រើសចំនួនបីដូចខាងក្រោម ដើម្បីដោះស្រាយរកចំណុចសមតា ÷

(5.2) $Y = C + I + G$

(5.5) $S + T = I + G$

(5.6) $I_r = I$

ចំណងទាក់ទងនៃលក្ខខណ្ឌចំណុចសមតារបស់ទំនាក់ទំនងទាំងបីខាងលើនេះ នឹងមានបង្ហាញដូចតទៅ ÷

***ទីមួយ-*** ចរន្តលំហូរជារង្វង់នៃចំណូល និង ធាតុចេញនៅក្នុងរូបភាព (៥.១) ជាតំណាងឱ្យគណនីចំណូលជាតិ ។ លំហូរនៃចំណូលជាតិ (Y) ពីក្រុមហ៊ុនអាជីវកម្មទៅគេហជន គឺជាការទូទាត់ចំពោះកត្តាសេវា ។ ចំណូលជាតិត្រូវបានបែងចែកជាបីដោយគេហជន (*ដែលជាអ្នកផ្គត់ផ្គង់កត្តាសេវាកម្មផង និង ជាអ្នកត្រូវការនូវធាតុចេញផង*)÷ *(១)* ***លំហូរចំណាយប្រើប្រាស់*** ដែលវិលត្រឡប់ទៅកាន់សហគ្រាសវិញ (*ដែលជាអ្នកផ្គត់ផ្គង់នូវធាតុចេញផង និង ជាអ្នកត្រូវការកត្តាសេវាកម្មផង*) ក្រោមរូបភាព ជាតម្រូវការនៃធាតុចេញ *(២)* ***លំហូរសញ្ច័យទៅក្នុងទីផ្សារហិរញ្ញវត្ថុ*** (មួយចំណែកនៃប្រាក់ចំណូលដែលបានសន្សំ ត្រូវបានគេរក្សាទុកក្រោមទម្រង់ជាទ្រព្យសកម្មហិរញ្ញវត្ថុ ឧទាហរណ៍ដូចជា រូបិយប័ណ្ណ ការផ្ញើប្រាក់នៅធនាគារ សញ្ញាប័ណ្ណ និង មូលប័ត្រជាដើម) និង *(៣)* ***លំហូរនៃការបង់ពន្ធ*** (ចំណាយបង់ពន្ធសុទ្ធ គឺស្មើនឹងចំណាយបង់ពន្ធសរុប ដកចំនួនទឹកប្រាក់ដែលបង្វិលត្រឡប់ជាការឧបត្ថម្ភដល់គ្រួសារវិញ ។

***ទីពីរ-*** សមីការ (5.5) សន្មតថា ការលេចធ្លាយទាំងឡាយចេញពីការប្រើប្រាស់ដោយផ្ទាល់ S+T ពិតជាត្រូវផាត់ទាត់ ដោយការបញ្ចូលមកវិញនូវធាតុជំនួសដែលតាងដោយកន្សោម I+G ។

***ទីបី-*** សមីការ (5.6) សន្មតថា វិនិយោគនៅក្នុងផែនការ និង វិនិយោគជាក់ស្តែងត្រូវតែស្មើគ្នានៅត្រង់ចំណុចសមតា តាមរយៈយន្តការកែតម្រូវនៃសន្និធិរបស់សហគ្រាសអាជីវកម្ម ។ ក្នុងន័យនេះ ប្រសិនបើ C+G ទាបជាងការរំពឹងទុកនោះ សន្និធិរបស់សហគ្រាសអាជីវកម្ម នឹងកើនឡើង ។ ផ្ទុយទៅវិញប្រសិនបើ C+G ខ្ពស់ជាងការរំពឹងទុកនោះ សន្និធិរបស់សហគ្រាសអាជីវកម្មនឹងធ្លាក់ចុះដែលឆ្លុះបញ្ចាំងតាមរយៈទំនាក់ទំនងខាងក្រោម ÷

(5.7) $Y > E$

$C + I_r + G > C + I + G$

$I_r > I$

ក្នុងករណីសន្និធិជាក់ស្តែង មានទំហំធំជាងសន្និធិដែលបានគ្រោងទុក យើងអាចទាញបាននូវទំនាក់ទំនង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចខាងក្រោម ។

(5.8) $E > Y$

$C + I + G > C + I_r + G$

$I > I_r$

នៅក្នុងទំនាក់ទំនង (5.7) និង (5.8) ខាងលើ សហគ្រាសនឹងផ្លាស់ប្តូរការសម្រេចចិត្តអំពីធាតុចេញរបស់ខ្លួន ចំពោះការធ្វើផែនការសម្រាប់កំឡុងពេលខាងក្រោយ ។ ប្រសិនបើបរិមាណសន្និធិលើសពីកម្រិតតម្រូវការ នោះធាតុចេញនឹងត្រូវកាត់បន្ថយ ហើយផ្ទុយទៅវិញ ប្រសិនបើបរិមាណសន្និធិទាបជាងតម្រូវការ នោះធាតុចេញនឹងត្រូវបង្កើនឡើង ។

## ២.១. សមាសធាតុនៃតម្រូវការសរុប

តម្រូវការសរុបតាមគំរូរបស់ **កេនស៍** កំណត់ដោយសមាសធាតុសំខាន់បី ÷

(ក) ការប្រើប្រាស់ (C)

(ខ) ការវិនិយោគ (I)

(គ) ចំណាយរបស់រដ្ឋាភិបាល (G)

**រូប ៥.១ លំហូរជារង្វង់នៃប្រាក់ចំណូល និង ធាតុចេញ**





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.១.១.ការប្រើប្រាស់

គណនីការប្រើប្រាស់ ជាទូទៅមានទំហំពី ៦០ ទៅ ៧០% នៃតម្រូវការសរុប ។ **កេនស៍** ជឿជាក់ថា ការប្រើប្រាស់ជាអនុគមន៍ថេរទៅនឹងប្រាក់ចំណូលក្រោយពេលគិតពន្ធ ពោលគឺប្រាក់ចំណូលដែលគេបានប្រើប្រាស់ ត្រូវកំណត់ដោយ ($Y_D$=Y-T) ដែលក្នុងនោះ (T) តំណាងឱ្យការបង់ពន្ធសុទ្ធ ដែលបានពីចំណាយបង់ពន្ធសរុប ដកការផ្ទេរសងពីរដ្ឋាភិបាលទៅឱ្យសហគ្រាស ។ កត្តាដទៃទៀត ដែលមានឥទ្ធិពលដល់ការប្រើប្រាស់ មានដូចជា កំណើនប្រាក់ចំណូលដែលគេរំពឹងទុក ទ្រព្យសម្បត្តិពេលអនាគត និង ការរំពឹងទុកអំពីការប្រែប្រួលថ្លៃ ។ ទោះបីជា យ៉ាងណាក៏ដោយ ជាទូទៅ កត្តាទាំងអស់នោះមិនត្រូវបានគេកត់សម្គាល់ជាដុំកំភួននោះទេ ។ រួមសេចក្តីទៅ ការប្រើប្រាស់ត្រូវបានគេរាប់បញ្ចូល ទាំងការប្រែប្រួលកម្រិតប្រាក់ចំណូលផងដែរ ។ ពោលគឺប្រសិនបើប្រាក់ចំណូល កើនឡើង នោះការប្រើប្រាស់ (C) នឹងកើនឡើង ។

នៅក្នុងគំរូរបស់កេនស៍ អនុគមន៍ការប្រើប្រាស់អាចត្រូវបានគេបង្ហាញដូចខាងក្រោម÷

(5.9) $C = a + bY_D$ ដែល $a > 0$ និង $0 < b < 1$

ក្នុងនោះ (a) តំណាងឱ្យការប្រើប្រាស់ដែលមិនបានគិតទុកជាមុន ឬ ចំណាយដើម្បីរក្សាអត្ថិភាពរបស់អាជីវកម្ម ពោលគឺ ទោះបីមិនមានចំណូលក៏យើងត្រូវតែមានម្ហូបអាហារ សម្លៀកបំពាក់ និង ទីជម្រក ដែលអាចដោះស្រាយបាន តាមរយៈការលក់ទ្រព្យសម្បត្តិខ្លះ ឬ ត្រូវខ្ចីគេក៏ដោយដើម្បីការរស់នៅ ។ ការប្រើប្រាស់ដែលមិនបានគិតទុកមុន គឺជាចំណុច ប្រសព្វរវាងអនុគមន៍នៃការប្រើប្រាស់ និង អ័ក្សអាកស៊ីស (x) ហើយ (b) តំណាង ឱ្យ ***ឧបនិស្ស័យបន្ថែមដើម្បីប្រើប្រាស់*** (Marginal Propensity to Consume-MPC) ឬ មេគុណនៃអនុគមន៍ការប្រើប្រាស់ធៀបទៅនឹងប្រាក់ចំណូល ក្រោយពេលគិតពន្ធ ។ MPC នឹងកើនឡើង នៅពេលដែលការប្រើប្រាស់ក្នុងមួយឯកតានៃប្រាក់ចំណូលដែលកើន ឡើង ។

(5.10) $b = \Delta C/\Delta Y_D$

មេគុណនេះវាស់វែងនូវការកើនឡើងនៃការប្រើប្រាស់ ដោយសារការកើនឡើងមួយឯកតានៃប្រាក់ចំណូល ក្រោយពេលបង់ពន្ធ ។ លោកកេនស៍សន្មតថា ការកើនឡើងនៃប្រាក់ចំណូលក្រោយពេលបង់ពន្ធ ($Y_D$) នឹងត្រូវបែង ចែកជាការប្រើប្រាស់ និង សញ្ចយ ។ ពោលគឺការកើនឡើងនៃការប្រើប្រាស់ តិចជាងការកើនឡើងនៃប្រាក់ចំណូល ក្រោយពេលបង់ពន្ធ ($Y_D$) ។ គួរកត់សម្គាល់ថា ចំពោះគ្រួសារដោយឡែកនីមួយៗ MPC របស់គេប្រែប្រួល ទៅតាម កម្រិតប្រាក់ចំណូលរបស់ខ្លួន ។ ដូច្នេះ អ្នកមានមាន ***ឧបនិស្ស័យបន្ថែមដើម្បីប្រើប្រាស់*** (MPC) ទាបជាងអ្នកក្រ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សម្រាប់សេដ្ឋកិច្ចទាំងមូល MPC ជាទូទៅនៅតែអាចគណនាបាន ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**រូប ៥.២ អនុគមន៍ការប្រើប្រាស់កេនស៍និយម**




រួមសេចក្តីមក ប្រាក់ចំណូលក្រោយពេលបង់ពន្ធបង្កើតនូវសមីការគណនេយ្យ តាមទំនាក់ទំនងរវាងការប្រើប្រាស់ និង សញ្ជ័យ ដូចខាងក្រោម÷

តាមរយៈរូបមន្ត (5.3) $Y \equiv C + S + T$

យើងអាចទាញបាន (5.11) $Y_D \equiv Y - T \equiv C + S$

**រូប ៥.៣ អនុគមន៍សញ្ជ័យកេនស៍និយម**






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូច្នេះ តាមសមីការ ៥.៤ អនុគមន៍នៃការសន្សំ អាចត្រូវបានកំណត់ដូចខាងក្រោម÷

(5.12) $S = -a + (1-b)Y_D$

ហើយ ***ឧបនិស្ស័យបន្ថែមដើម្បីសញ្ច័យ*** (Marginal Propensity to Save - MPS) ពោលគឺការកើនឡើងនៃសញ្ច័យកើតមាននៅពេលដែល ចំណាយក្រោយពេលបង់ពន្ធកើនឡើងមួយឯកតា អាចត្រូវបានកំណត់ដូចខាងក្រោម÷

(5.13) $\Delta S/\Delta Y_D = 1 - b$

## ២.១.២. ការវិនិយោគ

ការវិនិយោគ គឺជាអថេរសំខាន់មួយផងដែរ នៅក្នុងប្រព័ន្ធទ្រឹស្តីរបស់កេនស៍ ។ ក្នុងនោះ ការប្រែប្រួលកម្រិតនៃការវិនិយោគ (I) ដែលធ្វើឡើងដោយសហគ្រាស គឺជាអថេរដ៏សំខាន់មួយសម្រាប់ធានាថា Y = E ។ គាត់បានចាត់ទុកថា (I) ជាអថេរស្វយ័ត ដែលប្រែប្រួលមិនអាស្រ័យទៅនឹងបម្រែបម្រួលនៃ (ΔY) ប៉ុន្តែអាចបណ្តាលមកពីហេតុផលផ្សេងទៀត ក្នុងខណៈដែលការប្រើប្រាស់ (C) ត្រូវបានគាត់ចាត់ទុកថា ជាអថេរប្រែប្រួល (Induced variable) ពោលគឺ ប្រែប្រួលទៅតាម (Y) ។

ដើម្បីពន្យល់អំពីមូលហេតុនៃបម្រែបម្រួលនៃតម្រូវការសរុប និង ប្រាក់ចំណូល **កេនស៍** បានពិនិត្យមើលជាសំខាន់លើសមាសធាតុស្វយ័តនៃតម្រូវការ ឬ ចំណាយស្វយ័ត (*ចំណាយស្វយ័ត ឬ តម្រូវការស្វយ័ត គឺសំដៅជាពិសេស លើការចំណាយតម្រូវការដែលមិនពឹងផ្អែកលើចំណូល មានន័យថា ទោះជាចំណូលតិច ឬ ច្រើនក៏គេចាំបាច់ត្រូវតែចំណាយ*) ពោលគឺចំណាយដែលត្រូវបានកំណត់ដោយមិនគិតពីកម្រិតចំណូលបច្ចុប្បន្ន ។ នៅពេលដែលសមាសធាតុនៃចំណាយទាំងនេះប្រែប្រួល នឹងបណ្តាលឱ្យប្រាក់ចំណូលប្រែប្រួល ។ កេនស៍ជឿថា *វិនិយោគ គឺជាសមាសធាតុស្វយ័ត ដែលប្រែប្រួលខ្លាំងបំផុតនៃតម្រូវការសរុប* ។ គាត់មានជំនឿយ៉ាងមុតមាំថា ចំណាយវិនិយោគដែលប្រែប្រួលនោះ គឺជាមូលហេតុចម្បងនៃអស្ថិរភាពរបស់ប្រាក់ចំណូល ។

**កេនស៍**បានលើកឡើងនូវអថេរសំខាន់ពីរ ជាកត្តាកំណត់ នៅក្នុងការសម្រេចអំពីកម្រិតនៃការវិនិយោគនៅក្នុងរយៈពេលខ្លីដែលសំដៅលើអត្រាការប្រាក់ (r) និង លក្ខខណ្ឌអាជីវកម្មដែលគេរំពឹងទុក ពោលគឺការរំពឹងទុកអំពីប្រាក់ចំណេញដែលគេរកបាន (π) ។ អត្រាការប្រាក់វាស់វែងនូវថ្លៃដើមផ្ទាល់ ឬ ថ្លៃដើមប្រយោល ដែលត្រូវបានប្រើប្រាស់សម្រាប់ការធ្វើហិរញ្ញប្បទានចំពោះគម្រោងមួយជាក់លាក់ ពោលឱ្យចំ គឺការវិនិយោគ ។ កម្រិតនៃការវិនិយោគត្រូវបានគេសន្មតថា មានទំនាក់ទំនងផ្ទុយគ្នាទៅនឹងកម្រិតនៃអត្រាការប្រាក់ ។ អត្រាការប្រាក់កាន់តែខ្ពស់នឹងធ្វើឱ្យមានគម្រោងវិនិយោគកាន់តែតិចដែលមានអត្រាចំណូលរំពឹងទុកខ្ពស់គ្រប់គ្រាន់ ដើម្បីអាចទូទាត់សងនូវចំណាយការប្រាក់បាន ។

ការរំពឹងទុករបស់អ្នកគ្រប់គ្រងអាជីវកម្មស្តីអំពីលទ្ធភាពប្រាក់ចំណេញអនាគតរបស់គម្រោងវិនិយោគ គឺជា


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សមាសធាតុសំខាន់មួយនៃការវិភាគរបស់កេនស៍ ។ ភាពមិនប្រាកដប្រជាមួយចំនួន គឺជាមូលហេតុដែលនាំឱ្យមានការគណនាមិនត្រឹមត្រូវមួយរយភាគរយ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏មានភាពមិនប្រាកដប្រជាខ្លះត្រូវបានលោកកេនស៍ ចាត់ទុកថា ជាភាពមិនប្រាកដប្រជាពិត ពោលគឺវាមានហានិភ័យនៅជាប់ជាមួយនោះ ។

### ២.១.៣. ពន្ធ និង ចំណាយរបស់រដ្ឋាភិបាល

ចំណាយរបស់រដ្ឋាភិបាល គឺជាសមាសធាតុសំខាន់ទីពីរ *ចំណាយស្វយ័ត* ។ **កេនស៍** បានសន្មតដូចគ្នាជាមួយនឹងការវិនិយោគ (I) ដែរថា ចំណាយរបស់រដ្ឋាភិបាល និង ការយកពន្ធ មិនមែនជាអនុគមន៍ផ្ទាល់នៃប្រាក់ចំណូលនោះទេ ។ ពោលគឺវាមិនអាស្រ័យទៅនឹងអថេរប្រាក់ចំណូល (Y) ។ ចំណាយរបស់រដ្ឋាភិបាលត្រូវបានសន្មតថា ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អ្នកធ្វើគោលនយោបាយ ។ ចំណាយរបស់រដ្ឋាភិបាល និង ការយកពន្ធទាំងអស់នេះ គឺជាអថេរដែលមានលក្ខណៈនយោបាយ ដូច្នេះវាមិនមានទំនាក់ទំនងជាចាំបាច់ ដើម្បីធានានូវសមភាព (Y = E) នោះទេ ។

### ២.២. ចំណូលសមតា

ទម្រង់ដំបូងនៃលក្ខខណ្ឌសម្រាប់គណនារកចំណុចសមតានៃប្រាក់ចំណូល ត្រូវបានគេកំណត់តាមរូបមន្តខាងក្រោម៖

$$(5.2) \quad Y = E = C + I + G$$

ចំណូលសមតា (Y) គឺជាអថេរផ្ទៃក្នុង (Endogenous variable) ដែលនឹងត្រូវបានកំណត់ ។ អថេរខាងក្រៅ (Exogenous variable) ដូចជា I, G និង T ដែលទទួលបានពីខាងក្រៅគំរូនេះ ។ ការប្រើប្រាស់ប្រែប្រួលទៅតាម ការផ្លាស់ប្តូរនៃប្រាក់ចំណូលក្រោយពេលគិតពន្ធពោលគឺ៖

$$(5.9) \quad C = a + bY_D \text{ ឬ}$$

$$C = a + bY - bT$$

ប្រសិនបើយើងយកអញ្ញត្តិសមីការ (5.9) មកជំនួសក្នុង (5.2) យើងបាន ÷

$$Y = C + I + G$$

$$Y = a + bY - bT + I + G$$

$$Y - bY = a - bT + I + G$$

$$Y(1 - b) = a - bT + I + G$$


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

$$\overline{Y} = \frac{1}{1-b}(a - bT + I + G)$$ (5.14)

រូបភាព (5.4) អធិប្បាយនូវការកំណត់នៃប្រាក់ចំណូលសមតា ។ នៅលើអ័ក្ស (x) យើងកំណត់ការវាស់វែងដោយ (Y) ។ ហើយនៅលើអ័ក្ស (Y) យើងកំណត់ការវាស់វែងដោយ (C, I, G) ដែលជាសមាសធាតុនៃតម្រូវការសរុប ។ នៅពេលដែល គូសសង់សមីការនៃការប្រើប្រាស់ យើងនឹងទទួលបានខ្សែកោងមួយ ដែលមានមេគុណប្រាប់ទិសវិជ្ជមាន ប្រសព្វនឹងអ័ក្ស (Y) ត្រង់ចំណុច (a-bT) ដែលគេត្រូវបោះបង់ ។ មេគុណប្រាប់ទិសរបស់ខ្សែកោងនេះគឺជាមេគុណនៃការប្រើប្រាស់ (MPC=b) ដែលនឹងឆ្លុះបញ្ចាំងនូវចំនួនប្រាក់ចំណូល ដែលនឹងត្រូវគេចំណាយលើការប្រើប្រាស់ ចំនួនប្រាក់ចំណូលដែលគេត្រូវសន្សំ និង ចំនួនប្រាក់ចំណូលសម្រាប់គោលបំណងនៃការវិនិយោគ ។

**រូប ៥.៤ ការកំណត់ប្រាក់ចំណូលសមតា**




ប្រសិនបើយើងបន្ថែមអថេរស្វយ័តនៃតម្រូវការសរុប (I, G) វានឹងធ្វើឱ្យសមីការនៃការប្រើប្រាស់រំកិលឡើង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លើតាមទិសស្រប ដោយអនុលោមទៅតាមតម្លៃរបស់អថេរ I និង G ។ នៅពេលនេះ មេគុណប្រាប់ទិសរបស់ខ្សែកោងចំណាយសរុប (AEC) នៅតែដូចគ្នានឹងមេគុណប្រាប់ទិសរបស់ខ្សែកោងចំណាយប្រើប្រាស់ ។ ក្នុងករណីនេះ យើងពិនិត្យឃើញថា I និង G មិនប្រែប្រួល ទៅតាមបំលាស់ប្តូរ Y ឡើយ ។

បន្ទាត់ ៤៥ អង្សារ ដែលកាត់តាមគល់ទាំងពីរ (XOY) បញ្ជាក់ថា គ្រប់ចំណុចទាំងអស់ ដែលស្ថិតនៅលើបន្ទាត់នេះ តំណាងឱ្យភាពស្មើគ្នារវាងចំណាយ និង ផាតុចេញដែលទទួលបាន ។ ចំណុចប្រសព្វរវាងខ្សែកោង (AEC) និង បន្ទាត់ ៤៥ អង្សារ ចង្អុលបង្ហាញនូវចំណុចសមតាដែលគេនឹងទទួលបាន *(ចំណុច A ក្នុងរូប ៥.៤)* ។ គ្រប់ចំណុចដែលស្ថិតនៅពីខាងលើចំណុច (A) នេះ និង ខ្សែកោង (AEC) បង្ហាញថា តម្រូវការលើសពីផាតុចេញ ហើយសន្និធិរបស់ក្រុមហ៊ុននឹងធ្លាក់ចុះ ដែលនឹងរុញឱ្យប្រព័ន្ធតម្រូវការ និង ការផ្គត់ផ្គង់រត់ទៅរកចំណុចសមតាវិញ ។ ចំណុចទាំងឡាយ នៅពីខាងក្រោមចំណុច (A) និង ខ្សែកោង (AEC) បង្ហាញថា តម្រូវការសរុបតិចជាងផាតុចេញដែលគេផលិតបាន ហើយសន្និធិរបស់ក្រុមហ៊ុននឹងកើនឡើង និង វិលទៅរកចំណុចសមតាវិញ ។

ផ្តើមចេញពីសមីការ (5.2) យើងដឹងថា Y = E = C + I + G ពោលគឺ E = C + I + G ។ ជំនួស (C) ទៅក្នុងសមីការ (5.9) យើងបាន E = a + bY – bT + I + G ។ ម្យ៉ាងទៀត E = a – bT + I + G + bY ដែល (a-Bt + I+ G) គឺជា***សមាសផាតុស្វយ័តនៃចំណាយ*** ហើយជាចំណុចប្រសព្វរបស់ខ្សែកោង នៅខណៈពេលដែល b គឺជាបន្ទាត់ប៉ះខ្សែកោង ។ មេគុណរបស់ (Y) នឹងស្មើ (MPC) ។ នៅពេលដែលចំណាយស្វយ័តប្រែប្រួល ចំណាយសរុបនឹងរំកិល តាមទិសស្របបញ្ឈរ នៅក្នុងចំនួនមួយដែលឆ្លុះគ្នានឹងចំណុចប្រសព្វខាងលើ ។

តម្រូវការសរុបសមតានឹងប្រែប្រួលច្រើនជាង ការប្រែប្រួលនៃចំណាយស្វយ័ត ។ យើងអាចមើលឃើញច្បាស់ថា តាមរយៈការប្រៀបធៀបបម្រែបម្រួលតាមទិសឈរនៃចំណាយសរុប (ដោយសារបម្រែបម្រួលចំណាយស្វយ័ត) ទៅនឹងការប្រែប្រួលតាមទិសដេកនៃផាតុចេញសមតា ។ ផ្អែកតាមបន្ទាត់ប៉ះខ្សែកោងនៃចំណាយសរុប បម្រែបម្រួលតាមទិសដេក នឹងមានទំហំធំជាបម្រែបម្រួលតាមទិសឈរ ។ ចំណុចសំខាន់នៅត្រង់ថាភាពខុសគ្នានេះមានទំហំប៉ុណ្ណា ?

នេះជាចំណុចដែលផ្តល់ឱកាសឱ្យ ***កេនស៍***ផ្សព្វផ្សាយចេញនូវគំនិតសំខាន់បំផុតមួយរបស់គាត់បន្ថែមទៅលើការគិតពិចារណាអំពីសេដ្ឋកិច្ច ពោលគឺគំនិតស្តីពីមេគុណ (Multiplier) ។ មេគុណចំណាយស្វយ័ត ធ្វើឱ្យផាតុចេញសមតាប្រែប្រួល ក្នុងមួយឯកតានៃចំណាយស្វយ័ត (ចំណាយរបស់រដ្ឋាភិបាលជាដើម) ។ ដោយប្រើប្រាស់រូបមន្តដូចខាងក្រោម ÷

$$\bar{Y} = \frac{1}{1-b}(a - bT + I + G) \quad (5.14)$$

យើងអាចផ្តាច់កន្សោម (1/1-b) ចេញពីការផ្លាស់ប្តូរចំណាយស្វយ័ត (a-bT+I+G) ។ តាមពិត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គឺជាមេគុណនៃការចំណាយសរុប ដែល b = MPC ។ ប្រសិនបើតម្លៃ b តូចជា ១ នោះតម្លៃភាគបែងនឹងតូចជាង ១ ហើយនៅពេល គេចែកវានឹង ១ វានឹងបង្កើតបាននូវចំនួនមួយ ជាមេគុណដែលមានតម្លៃធំជាង ១ ។ ប្រការនេះ ប្រសិនបើមានការផ្លាស់ប្ដូរការចំណាយស្វយ័ត ជាពិសេស ប្រសិនបើមានការវិនិយោគមិនស្ថិតថេរ នឹងនាំឱ្យធាតុចេញសមតាមានការប្រែប្រួលយ៉ាងខ្លាំង ។ ពោលគឺ ប្រសិនបើ៖

b = 0.5; នោះមេគុណ = 2;

b = 0.8; នោះមេគុណ = 5;

b = 0.9; នោះមេគុណ = 10

គួរកត់សម្គាល់ថា ចំណុចសមតាកើតមានជាមួយនឹងការសន្មតថា I + G = S + T ។ ប្រសិនបើគ្មានចំណាយរដ្ឋាភិបាលទេនោះ ការវិនិយោគ I នឹងត្រូវតែស្មើជាមួយនឹងសញ្ចយ S នៅចំណុចសមតា ។ ការទិតៀនមួយរបស់លោក **កេនស៍** ចំពោះគំរូបុរាណនិយម គឺថា « ***ទ្រឹស្ដីស្ដីពីមូលនិធិដែលអាចឱ្យខ្ចីបាន*** » មិនប្រាកដជាពិតនោះទេ ។ ម្យ៉ាងទៀត ដោយការភ័យខ្លាច និង អសន្តិសុខ បុគ្គលម្នាក់ៗអាចសន្សំប្រាក់ តែមិនមែនសម្រាប់វិនិយោគទេ ។ ទន្ទឹមនឹងនេះ សហគ្រាសអាចមិនមានឆន្ទៈក្នុងការធ្វើវិនិយោគ ក្នុងកម្រិតមួយដែលអ្នកប្រើប្រាស់ចង់សន្សំ ។ ភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការវិនិយោគ គឺជាមូលហេតុដ៏សំខាន់ដែល **កេនស៍** ទាមទារឱ្យមានអន្តរាគមន៍ពីរដ្ឋាភិបាល ។

សរុបសេចក្ដីមក ទ្រឹស្ដីដ៏សាមញ្ញបំផុតរបស់ **កេនស៍** អាចសង្ខេបបានដូចខាងក្រោម ។ *«ការប្រើប្រាស់ជាអនុគមន៍ថេរនៃប្រាក់ចំណូល ពោលគឺ* ***ឧបនិស្ស័យបន្ថែមដើម្បីប្រើប្រាស់*** *(MPC) មានលក្ខណៈថេរ ។ បម្រែបម្រួលប្រាក់ចំណូលបណ្ដាលមកពីការផ្លាស់ប្ដូរសមាសធាតុស្វយ័តនៃតម្រូវការសរុប ជាពិសេសគឺការប្រែប្រួលនៃសមាសធាតុវិនិយោគដែលពុំមានស្ថិរភាព ។ បន្លាស់ប្ដូរសមាសធាតុស្វយ័តនៃតម្រូវការសរុបនឹងបណ្ដាលឱ្យមានការប្រែប្រួលយ៉ាងធំធេងនូវប្រាក់ចំណូលសមតា ដែលបណ្ដាលមកពីមេគុណ ។ ក្នុងករណី ដែលគ្មានគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាព នោះប្រាក់ចំណូលក៏នឹងមិនមានស្ថិរភាពដែរ ដោយសារតែអស្ថិរភាពនៃការវិនិយោគ ។ ហេតុនេះ តាមរយៈការប្រែប្រួលដ៏សមរម្យនៃចំណាយរដ្ឋាភិបាល និង ការយកពន្ធរដ្ឋាភិបាលផ្លាស់ប្ដូរទិសនៃចលនាវិលចុះឡើងនៃការវិនិយោគបាន ។ ការប្រែប្រួលដ៏សមរម្យនៃ G និង T នឹងរក្សាចំណាយស្វយ័តឱ្យនៅថេរបាន ទោះបីជាត្រូវប្រឈមនឹងការប្រែប្រួលដោយមិនចាំបាច់នៃការវិនិយោគក៏ដោយ »*។

## ២.៣. បម្រែបម្រួលនៃចំណូលសមតា

ការកើនឡើងនៃការវិនិយោគ (I) ធ្វើឱ្យខ្សែកោង (AEC) រំកិលឡើងលើក្នុងកម្រិត ($\Delta$I) ប៉ុន្តែធាតុចេញសមតាកើនឡើងច្រើនជា ($\Delta$I) ។ ចំណូលកើនឡើងក្នុងកម្រិត ($\Delta$I) នឹងធ្វើឱ្យចំណាយប្រើប្រាស់កើនឡើង ($\Delta$C)


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីព្រោះ ចំណែកនៃចំណូលសរុបដែលកើនឡើង (Y) នឹងត្រូវចំណាយទៅវិញដែរ ។ ដូច្នេះ គេអាចទាញយកបាននូវ៖

$$\Delta Y = \Delta I + \Delta C \text{ ឬ}$$

$\Delta Y - \Delta C = \Delta I$, និង ដោយសន្មតថា ការប្រមូលពន្ធមានបរិមាណថេរ ។ ឆ្លងតាមសមីការនេះ ចំណុចសមតាអាចឆ្លុះបញ្ចាំងតាមសមីការខាងក្រោម ÷

$$\Delta S = \Delta I \quad (5.19)$$

**រូប ៥.៥. ផលប៉ះពាល់នៃកំណើនវិនិយោគដោយស្វយ័តទៅលើទ្រាក់ចំណូលសមតា**




ដូច្នេះ ដោយរក្សា T និង G ឱ្យនៅថេរ នោះចំណុចសមតាត្រូវតែកើនឡើងក្នុងទំហំមួយដែលគ្រប់គ្រាន់ដើម្បីឆ្លើយតបចំពោះសមតុល្យ (ΔI) ។ ដោយ $(\Delta S) = (1\text{-}b)(\Delta Y)$ និង ដោយប្រើប្រាស់សមីការ (5.19) យើងបាន៖


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(5.20) $\Delta Y/\Delta I = 1/MPS$ ឬ

$= 1/(1-b)$

ករណីដូចគ្នានេះដែរចំពោះការកើតឡើងនៃ ($\Delta G$) ។ ដូច្នេះយើងបាន៖

$\Delta Y = (1/1\text{-}b)\,\Delta G$, និង

(5.21) $\Delta Y/\Delta G = 1/1\text{-}b$

ទោះបីជាយ៉ាងណា យើងនឹងទទួលបានលទ្ធផលខុសគ្នា ដោយសារបម្រែបម្រួលនៃពន្ធ ពោលគឺ ($\Delta I$)

**រូប ៥.៦ ផលប៉ះពាល់នៃកំណើនពន្ធទៅលើប្រាក់ចំណូលសមតា**




$\Delta Y = (1/1\text{-}b)(\text{-}b)\Delta T$ ឬ

(5.22) $\Delta Y/\Delta T = \text{-}b/1\text{-}b$



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដូច្នេះការកើនឡើងនៃពន្ធនឹងធ្វើឱ្យថយចុះនូវចំណូលក្រោយពេលបង់ពន្ធ ដែលធ្វើចំណាយប្រើប្រាស់ (C) ធ្លាក់ចុះទៅតាមគ្រប់កម្រិតនៃបម្រែបម្រួលថយចុះរបស់ (ΔI) (រូបទី 5.7)។ ទោះបីជាយ៉ាងណាក៏ដោយ ការកើនឡើង ១ ដុល្លារនៃពន្ធបណ្ដាលឱ្យចំណាយប្រើប្រាស់ធ្លាក់ចុះ (b) ជាមួយនឹងសំណល់ (1-b) ដែលកើតឡើងតាមរយៈសញ្ច័យ ។ ដូច្នេះ មិនដូចការប្រែប្រួលនៃចំណាយស្វយ័តនោះទេ ព្រោះវាមានមេគុណ ដែលមានឥទ្ធិពលទៅលើ (Y) ចំណែកការប្រែប្រួលនៃពន្ធមានឥទ្ធិពលតិចជាង ។ ទោះជាយ៉ាងណាក៏ដោយ យើងសន្មតថា «***ការប្រែប្រួល (T) គឺជាការប្រែប្រួលថេរ ពោលគឺ ជាចំនួនថេរ***» ។ ក៏ប៉ុន្តែ យើងអាចទទួលបាននូវលទ្ធផលផ្សេង ប្រសិនបើយើងផ្លាស់ប្ដូរអត្រាពន្ធវិញនោះ ។ ដូច្នេះ នៅក្នុងប្រព័ន្ធពន្ធកើនឡើង (Progressive) អ្នកដែលមានចំណូលច្រើននឹងបង់ពន្ធតាមអត្រាខ្ពស់ជាង ដូច្នេះ ការប្រែប្រួលក្នុងរចនាសម្ព័ន្ធអត្រាពន្ធនឹងមានលទ្ធផលផ្សេងៗគ្នា ។ ឧទាហរណ៍ ការកាត់បន្ថយអត្រាពន្ធចំពោះអ្នកដែលមានចំណូលទាប នឹងមានផលប៉ះពាល់ធំជាងចំពោះចំណាយប្រើប្រាស់ (ដោយសារអ្នកមានចំណូលទាបមាន ឧបនិស្ស័យបន្ថែមដើម្បីប្រើប្រាស់ខ្ពស់ជាង - MPC) ។ ការផ្លាស់ប្ដូរអត្រាពន្ធដែលផ្ដោតលើអ្នកមានចំណូលខ្ពស់ នឹងមានផលប៉ះពាល់ច្រើនជាងទៅលើសញ្ច័យ ពីព្រោះអ្នកមានចំណូលខ្ពស់មានឧបនិស្ស័យបន្ថែមដើម្បីសញ្ច័យ (MPS) ខ្ពស់ជាង (លើកលែងតែក្នុងករណីដែលគេចំណាយលើទំនិញប្រណិតប៉ុណ្ណោះ ទើបការវិភាគខាងលើនេះ អាចមានកំហុសឆ្គង) ។

ដោយសារការប្រែប្រួលនៃ (G) ឬ (T) នឹងមានឥទ្ធិពលលើចំណូលសមតា យើងអាចប្រើ (G) និង (T) ជាឧបករណ៍គួរឱ្យជឿទុកចិត្តបាននៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដើម្បីសងបង្គ្រប់ការផ្លាស់ប្ដូរនៃការវិនិយោគ ។ ជាទូទៅ ការធ្លាក់ចុះនៃការវិនិយោគ (I) នឹងត្រូវសងបង្គ្រប់ដោយការកើនឡើងនៃចំណាយរដ្ឋាភិបាល (G) ។

## ៣. គោលនយោបាយស្ថិរភាពឧបនីយកម្មសារពើពន្ធ

ដោយសារតែចំណូលសមតាទទួលរងឥទ្ធិពលនៃបម្រែបម្រួលចំណាយរដ្ឋាភិបាល និង ការយកពន្ធ ហេតុដូច្នេះ យើងអាចផ្លាស់ប្ដូរឧបករណ៍គោលនយោបាយសារពើពន្ធនេះ ដើម្បីរក្សាស្ថិរភាពនៃចំណាយស្វយ័តសរុប និង ចំណូលសមតា ទោះបីជាសមាសភាពនៃការវិនិយោគមិនមានស្ថិរភាពក៏ដោយ ។

ឧទាហរណ៍ នៅពេលដែលការវិនិយោគធ្លាក់ចុះ ក្នុងករណីអវត្តមានអន្តរាគមន៍គោលនយោបាយ តម្រូវការសរុបនឹងធ្លាក់ចុះទៅដល់កម្រិតមួយទាបជាងធាតុចេញជាសក្ដានុពល ។ ដូច្នេះ គោលនយោបាយសារពើពន្ធដ៏សមស្របនឹងអាចបង្កើននូវចំណាយរបស់រដ្ឋាភិបាល ក្នុងកម្រិតគ្រប់គ្រាន់មួយ ដែលនឹងជួយឱ្យមានចំណុចសមតាឡើងវិញ ។ ផ្ទុយទៅវិញ យើងអាចប្រើប្រាស់ការកាត់បន្ថយពន្ធ ដើម្បីរក្សាកម្រិតដើមនៃតម្រូវការសរុប ។ ដោយសារមេគុណពន្ធតូច ការកាត់បន្ថយពន្ធដ៏សមរម្យ អាចមានមានលទ្ធផលធំធេងជាងការបង្កើនចំណាយទៅទៀត ។

## ៣.១. ការនាំចេញ-នាំចូល

កន្លងមក យើងបានសន្មតថា ការវិភាគទាំងអស់ស្ថិតនៅក្នុងលក្ខខណ្ឌសេដ្ឋកិច្ចបិទជិត ដែលមិនមានវត្តមាន នៃការនាំចេញ-នាំចូល ។ សន្មតថា (X) តំណាងឱ្យការនាំចេញ ហើយ (Z) តាងឱ្យការនាំចូល ដូច្នេះយើងអាច គូសសមីការចំណូល និង ចំណាយរបស់ជាតិដូចខាងក្រោម ÷

(5.23) $Y = E = C + I + G + X - Z$

**រូប ៥.៧ ការអនុវត្តគោលនយោបាយស្ថិរភាវូបនីយកម្មថវិកា**




ការនាំចេញតំណាងឱ្យការលក់ផលិតផលនៃផលិតកម្មក្នុងស្រុកទៅឱ្យបរទេស ។ ក្នុងន័យនេះ វាជាចំណែកមួយនៃតម្រូវការសរុប ។ ការនាំចេញជាការទិញផលិតផលពីបរទេស មិនមែនផលិតផលរបស់ផលិតកម្មក្នុងស្រុកឡើយ ។ វាតំណាងឱ្យការថយចុះនៃតម្រូវការចំពោះទំនិញ និង សេវាកម្មក្នុងស្រុក ហើយត្រូវដកចេញពីតម្រូវការសរុប។ តើអ្វីទៅជាចំណុចសមតានៅក្នុងសេដ្ឋកិច្ចចំហ? ចំណាយលើការប្រើប្រាស់ (C) អាស្រ័យទៅនឹងការប្រែប្រួលរបស់ (Y) ពោលគឺ ÷

(5.24) $C = a + bY$

ក្នុងករណីនៃការនាំចេញ តម្រូវការមានលក្ខណៈស្វយ័ត ពោលគឺវាត្រូវបានកំណត់ដោយចំណូលបរទេស

មិនមែនដោយចំណូលក្នុងស្រុកទេ ដោយអត្រាប្តូរប្រាក់ និង ថ្លៃអន្តរជាតិ មិនមែនក្នុងស្រុកទេ ។ ក្នុងករណីនៃការនាំចូលវាអាស្រ័យទៅនឹង (Y) ដែលសំដៅទៅលើ (ΔY) ដូច (C) ដែរ៖

(5.25) $Z = u + vY$ ដែល

u តំណាងឱ្យកម្រិតស្វយ័តនៃការនាំចូល v តំណាងឱ្យឧបនិស្ស័យបន្ថែមនៃការនាំចូល (Marginal Propensity to Import) សំដៅទៅលើភាគរយនៃប្រាក់ចំណូលបន្ថែម ដែលចំណាយទៅលើការនាំចូល ។

ប្រសិនបើ (Z) អាស្រ័យទៅនឹង (ΔY) ហើយ (C) ក៏អាស្រ័យនឹង (ΔY) នោះមានន័យថា អថេរទាំងពីរនេះមានទំនាក់ទំនងនឹងគ្នា ។ រាល់ការកើនឡើងនៃ (Y) នឹងបែងចែកគ្នារវាងការចំណាយប្រើប្រាស់ចំពោះទំនិញ ឬសេវាដែលផលិតនៅក្នុងស្រុក ឬ នាំចូល ។

(5.23) $Y = E = C + I + G + X - Z$

ដោយជំនួស $C = a + bY$ និង $Z = u + vY$ យើងបាន :

(5.26) $Y = (1/1\text{-}b+v)(a + I + G + X + u)$

ដោយមិនគិតពី (T) ប្រៀបធៀបជាមួយសមីការសេដ្ឋកិច្ចដូចគ្នានេះនៅក្នុងសេដ្ឋកិច្ចបិទ យើងបាន :

(5.27) $Y = (1/1\text{-}b)(a+I+G)$

ប្រការនេះបញ្ជាក់យ៉ាងច្បាស់នូវទំនាក់ទំនងទៅនឹងមេគុណនៃចំណាយ ពោលគឺ ប្រសិនបើឧបនិស្ស័យនៃការនាំចូលកាន់តែខ្ពស់ (v) នោះមេគុណចំណាយកាន់តែទាបដែរ ។ ច្បាស់ណាស់ថា ប្រការនេះបានបន្ថយឥទ្ធិពលរបស់ការប្រែប្រួលនៃចំណាយស្វយ័ត (G) ។ ការនាំចូលចាត់ទុកដូចជាការលេចធ្លាយចេញពីប្រព័ន្ធ ។ ការលេចធ្លាយកាន់តែច្រើន នាំឱ្យរដ្ឋាភិបាល ធនាគារកណ្តាល និង ស្ថាប័នជាតិមានអានុភាពកាន់តែតិចក្នុងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព ។

ជាសង្ខេប ការកើនឡើងនៃតម្រូវការចំពោះការនាំចេញ មានឥទ្ធិពលពង្រីក (Expansionary) លើចំណូលសមតា ក៏ប៉ុន្តែការកើនឡើងនៃការនាំចូលបែរជាមានឥទ្ធិពលបង្រួម (Contractionary) ទៅវិញចំពោះចំណូលសមតា ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ផ្អែកលើទស្សនវិស័យគោលនយោបាយ ប្រទេសជាតិទាំងឡាយនាំចូលនូវទំនិញដែលបានផលិតប្រកបដោយប្រសិទ្ធភាពជាងពីបរទេស និង ការធ្វើពាណិជ្ជកម្មធ្វើឱ្យកើនឡើងនូវប្រសិទ្ធភាពជាទូទៅនៃការប្រើប្រាស់ធនធាននៅលើពិភពលោក ។ ឥទ្ធិពលពង្រីកនៃការកើនឡើងការនាំចេញ និង ឥទ្ធិពលបង្រួមនៃការកើនឡើងការនាំចូល គឺជាមូលហេតុច្បាស់លាស់មួយដែល ប្រទេសជាតិមួយព្យាយាមជំរុញសេដ្ឋកិច្ចក្នុងស្រុក តាមរយៈការបង្កើនការនាំចេញ និង ទប់ស្កាត់ការនាំចូល ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចំណុចគន្លឹះនៃគំរូរបស់**កេនស៍**ទាំងអស់ គឺនៅត្រង់ថា តម្រូវការដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់ចំណូល ។ តាមទស្សនៈរបស់ **កេនស៍** ការប្រែប្រួលសមាសធាតុស្វយ័តនៃតម្រូវការសរុប ជាពិសេស តម្រូវការនៃការវិនិយោគ គឺកត្តាគន្លឹះដែលបណ្តាលឱ្យមានការផ្លាស់ប្តូរកម្រិតចំណូលសមតា ។ ដោយសារមធ្យោបាយនៃដំណើរការមេគុណ ការផ្លាស់ប្តូរការចំណាយស្វយ័ត រាប់បញ្ចូលផងដែរនូវការផ្លាស់ប្តូរនៃការចំណាយប្រើប្រាស់ ។ ការវិនិយោគមិនគ្រប់គ្រាន់ និង កម្រិតទាបទៅៗនៃតម្រូវការសរុប គឺជាបុព្វហេតុនៃបំណកស្រាយរបស់**កេនស៍** ចំពោះនិកម្មភាពដ៏សម្បើមក្នុងអំឡុងកាលវិបត្តិដ៏ធ្ងន់ធ្ងរនៃសេដ្ឋកិច្ចពិភពលោក នៅទសវត្សរ៍ឆ្នាំ ១៩៣០ ។ ដូច្នេះ គោលនយោបាយស្ថិរភាវូបណីយកម្មសារពើពន្ធ ដើរតួនាទីយ៉ាងសំខាន់ក្នុងការចាត់ចែងតម្រូវការសរុប ឱ្យរុលទៅរកធាតុចេញសមតា ដោយរំកិលចេញពីតម្រូវការនៃការវិនិយោគមិនមានស្ថិរភាព ។

# ជំពូកទី ៦

## ទីផ្សាររូបិយវត្ថុ: ខ្សែកោង LM

### ១. ប្រព័ន្ធកេនស៍និយម : រូបិយវត្ថុ ការប្រាក់ និង ចំណូល

#### *១.១. រូបិយវត្ថុតាមប្រព័ន្ធទ្រឹស្តីកេនស៍និយម*

ទ្រឹស្តីជាមូលដ្ឋានរបស់ **កេនស៍**ស្តីអំពីរូបិយវត្ថុគឺជាទស្សនៈដែលយល់ឃើញថា រូបិយវត្ថុមានឥទ្ធិពលទៅលើចំណូល ដោយសារអត្រាការប្រាក់ ។ ការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុធ្វើឱ្យធ្លាក់ចុះអត្រាការប្រាក់ ហើយបន្តពីនោះការធ្លាក់ចុះនៃអត្រាការប្រាក់ធ្វើឱ្យកើនឡើងនូវតម្រូវការសរុប និង ចំណូល ។ ដូច្នេះ មានទំនាក់ទំនងពីរយ៉ាង៖ (១) ទំនាក់ទំនងរវាងរូបិយវត្ថុ និង អត្រាការប្រាក់ និង (២) ឥទ្ធិពលនៃអត្រាការប្រាក់ទៅលើតម្រូវការសរុប ។

#### អត្រាការប្រាក់ និង តម្រូវការសរុប

គម្រោងវិនិយោគមួយនឹងត្រូវអនុវត្ត ប្រសិនបើការរំពឹងទុកនៃប្រាក់ចំណេញរបស់វា លើសការចំណាយលើការប្រាក់ដែលនឹងត្រូវដើម្បីធ្វើហិរញ្ញប្បទានគម្រោងនោះ បូកនឹងបរិមាណដែលសមល្មមនឹងហានិភ័យនៃគម្រោងនោះ ។ ដូច្នេះ បើសិនជាការប្រាក់មានកម្រិតខ្ពស់ជាងនេះ នោះនឹងមានគម្រោងវិនិយោគតែមួយចំនួនតូចប៉ុណ្ណោះដែលនឹងអាចអនុវត្តទៅបាន ។

អត្រាការប្រាក់ក៏មានឥទ្ធិពលផងដែរទៅលើសមាសធាតុដទៃទៀតនៃតម្រូវការសរុប ក្រៅពីបរិយាកាសធុរកិច្ច ដូចជាការវិនិយោគទៅលើការសាងសង់លំនៅដ្ឋាន ចំណាយប្រើប្រាស់ទៅលើទំនិញប្រើប្រាស់បានយូរ ដូចជារថយន្ត និង សម្ភារៈប្រើប្រាស់តាមផ្ទះជាដើម ។

កត្តាដ៏សំខាន់មួយដែលកំណត់ការផ្លាស់ប្តូរនៃចំណូលសមតា គឺទំហំនៃការរំកិលតម្រូវការសរុប ដែលបណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់ ។ ប្រសិនបើការប្រែប្រួលអត្រាការប្រាក់មានវេទយិតភាពកាន់តែខ្លាំងទៅលើសមាសធាតុនៃតម្រូវការសរុប នោះចលនារំកិលឡើងនៃខ្សែកោងរបស់សមីការតម្រូវការសរុបនឹងកាន់តែធំ ។ ដូច្នេះ វេទយិតភាពអត្រាការប្រាក់នៃតម្រូវការសរុប មានសារសំខាន់ណាស់ក្នុងការកំណត់ថាតើ គោលនយោបាយរូបិយវត្ថុនឹងមានប្រសិទ្ធភាពបែបណាលើចំណូលសមតា ។

#### *១.២. ទ្រឹស្តីកេនស៍និយមអំពីអត្រាការប្រាក់*

លោក**កេនស៍**មានជំនឿថា បរិមាណរូបិយវត្ថុដើរតួនាទីសំខាន់ក្នុងការកំណត់អត្រាការប្រាក់ ។ ការវិភាគ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

របស់ **កេនស៍** ចាប់ផ្ដើមពីសម្មតិកម្មដ៏សាមញ្ញមួយចំនួន ។ ទីមួយ **កេនស៍**សន្មតថា ទ្រព្យសកម្មហិរញ្ញវត្ថុអាចចែកចេញជាពីរក្រុមគឺ៖ (១) ទ្រព្យសកម្មជារូបិយវត្ថុ និង (២) ទ្រព្យសកម្មមិនមែនជារូបិយវត្ថុ ដែលកំណត់ថាជាសញ្ញាប័ណ្ណ ។ រូបិយវត្ថុជារូបិយវត្ថុត្រូវបានតាងដោយ (M1) ដែលរួមមានក្រដាសប្រាក់ និង គណនីនៅធនាគារដែលគេអាចប្រើប្រាស់មូលប្បទានប័ត្របាន ។ សញ្ញាប័ណ្ណរាប់បញ្ចូលនូវសញ្ញាប័ណ្ណជាក់ស្ដែង និង ទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែងដទៃទៀត ដែលភាគច្រើនជាភាគហ៊ុនរបស់សាជីវកម្ម ។ ការបែងចែកដាច់ពីគ្នារវាងរយៈពេលវែង (សញ្ញាប័ណ្ណ) និង រយៈពេលខ្លី (រូបិយវត្ថុ) គឺជាចំណុចសំខាន់មួយ ។ សញ្ញាប័ណ្ណរយៈពេលវែងគឺជាប្រភេទទ្រព្យសកម្មដែលផ្ដល់ការប្រាក់ រីឯរូបិយវត្ថុមិនផ្ដល់ការប្រាក់ទេ ។ សញ្ញាប័ណ្ណត្រូវបានគេសន្មតថាជាប្រភេទមូលប័ត្រអមតៈ ដែលផ្ដល់ការប្រាក់ថេរសម្រាប់ពេលជាក់លាក់មួយនាពេលអនាគត ដោយមិនទូទាត់ប្រាក់ដើម (តម្លៃចារឹក) ឡើយ ។

ជាមួយនឹងក្របខ័ណ្ឌដ៏សាមញ្ញនេះ លោក**កេនស៍** យកចិត្តទុកដាក់ទៅលើវិធីដែលបុគ្គលម្នាក់សម្រេចចិត្តអំពីរបៀបបែងចែកធនធានហិរញ្ញវត្ថុរបស់គេ ពោលគឺការបែងចែករវាងទ្រព្យសកម្ម ជារូបិយវត្ថុ (M) និង ជាសញ្ញាប័ណ្ណ (B) ។ ក្នុងន័យនេះ យើងបាន៖

$$Wh \equiv B + M \quad (6.1)$$

អត្រាការប្រាក់សមតាចំពោះសញ្ញាប័ណ្ណ គឺជាអត្រាកាប្រាក់ដែលធ្វើឱ្យតម្រូវការចំពោះសញ្ញាប័ណ្ណស្មើនឹងចំនួនសញ្ញាប័ណ្ណដែលមាន ។ យើងអាចពន្យល់បានពីរយ៉ាងអំពី អត្រាការប្រាក់សមតា៖ គឺអត្រាដែលធ្វើឱ្យការផ្គត់ផ្គង់ និង តម្រូវការសញ្ញាប័ណ្ណស្មើគ្នា ឬ អត្រាដែលធ្វើឱ្យការផ្គត់ផ្គង់ និងតម្រូវការរូបិយវត្ថុស្មើគ្នា ។ ចំណុចសមតានៅក្នុងទីផ្សារសញ្ញាប័ណ្ណ ក៏មានន័យថាចំណុចសមតានៅលើទីផ្សាររូបិយវត្ថុផងដែរ ។ លោក **កេនស៍** បានជ្រើសយកវិធីសាស្ត្រទីពីរដើម្បីឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរវាងរូបិយវត្ថុ និង អត្រាការប្រាក់ ។

ការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានសន្មតថាមានលក្ខណៈថេរ ដែលកំណត់ពីក្រៅដោយដោយធនាគារកណ្ដាលត្រង់ចំណុច ($M_0$) ។ អត្រាការប្រាក់សមតា គឺ ($r_0$) ជាអត្រាដែលតម្រូវការរូបិយវត្ថុស្មើនឹងការផ្គត់ផ្គង់រូបិយវត្ថុដែលថេរ ។ ជាងនេះទៅទៀត អត្រាការប្រាក់សមតា ត្រូវបានកំណត់ដោយកត្តាទាំងឡាយដែលមានឥទ្ធិពលទៅលើការផ្គត់ផ្គង់ និង តម្រូវការរូបិយវត្ថុ ។

## ១.៣. ទ្រឹស្ដីកេនស៍អំពីតម្រូវការរូបិយវត្ថុ

គេបានសន្មតដូចនៅក្នុងគំរូបុរាណនិយមថា ការផ្គត់ផ្គង់រូបិយវត្ថុ (M1) ត្រូវធ្វើឡើងដោយធនាគារកណ្ដាល និង មានចំនួនថេរ ។ ដោយសន្មតថា ប្រាក់ចំណូលអាចរក្សាបានជារូបិយវត្ថុ ដែលត្រូវបានចាយ ឬ ប្រែក្លាយទៅជាទ្រព្យសកម្មដែលផ្ដល់ការប្រាក់ (សញ្ញាប័ណ្ណ) ។ ក្នុងន័យនេះ ចំពោះលោក **កេនស៍** មានមូលហេតុសំខាន់ៗបីដើម្បីរក្សារូបិយវត្ថុ ក្រោមរូបភាពជាសាច់ប្រាក់៖


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- តម្រូវការសម្រាប់ប្រតិបត្តិការ
- តម្រូវការប្រុងប្រយ័ត្ន
- តម្រូវការសម្រាប់កេងយកចំណេញ
- តម្រូវការសរុប

### ១.៣.១. តម្រូវការប្រតិបត្តិការ

**រូប ៦.១ ការកំណត់អត្រាការប្រាក់សមតា**




លោក**កេនស៍** យល់ឃើញថា មូលហេតុទីមួយ គឺតម្រូវការសម្រាប់កិច្ចប្រតិបត្តិការ ។ គេរក្សាទុកទ្រព្យបិយវត្ថុសម្រាប់ទុកជា មធ្យោបាយនៃការដោះដូរដើម្បីប្រើប្រាស់នៅក្នុងប្រតិបត្តិការនានា ។ តម្រូវការប្រតិបត្តិការប្រែប្រួលជាវិជ្ជមានជាមួយនឹងបរិមាណប្រតិបត្តិការ ($T_D$) ហើយចំណូលត្រូវបានគេសន្មតថាជារង្វាស់ដ៏ល្អមួយសម្រាប់ ($T_D$)។ រូបិយវត្ថុដែលទទួលបានពីប្រតិបត្តិការមួយ ត្រូវប្រើប្រាស់ដើម្បីទិញសញ្ញាប័ណ្ណ ដែលនឹងអាចលក់ដើម្បីទទួលយករូបិយវត្ថុមកវិញបាន នៅពេលដែលចាំបាច់ ។ ប្រាក់ចំណេញដែលទទួលបានពីទង្វើបែបនេះ គឺជាការប្រាក់ដែលទទួលបានពីការកាន់កាប់រក្សាសញ្ញាប័ណ្ណ ។ ដោយសារតែចំណូលដែលនឹងទទួលបាន គឺជាការប្រាក់ពីសញ្ញាប័ណ្ណ យើងយល់ឃើញថា ការលើកទឹកចិត្តដើម្បីកាត់បន្ថយសមតុល្យនៃប្រតិបត្តិការនឹងកើនឡើង នៅពេលដែលអត្រាការប្រាក់កើនឡើង ។ ដូច្នេះ បុគ្គល និង គ្រួសារនឹងខិតខំកាត់បន្ថយតម្រូវការប្រតិបត្តិការនៃរូបិយវត្ថុនៅពេលដែលអត្រាការប្រាក់កើនឡើង ។ ជាសន្និដ្ឋាន តម្រូវការប្រតិបត្តិការ ($T_D$) ប្រែប្រួលស្របគ្នាជាមួយនឹង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាក់ចំណូល និង ផ្ទុយគ្នានឹងអត្រាការប្រាក់ ។

ក្នុងខណៈដែល **កេនស៍** មិនបានសង្កត់ធ្ងន់លើផលប៉ះពាល់នៃ (r) ទៅលើ ($T_D$) សហគ្រាសទាំងឡាយបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះប្រការនេះ ដែលស្តែងឡើងតាមរយៈការអនុវត្តក្នុងការគ្រប់គ្រងសាច់ប្រាក់របស់គេ ។ សហគ្រាសដែលមានប្រតិបត្តិការក្នុងទ្រង់ទ្រាយធំ នឹងកាត់បន្ថយតម្រូវការប្រតិបត្តិការ ($T_D$) នៅពេលដែលអត្រាការប្រាក់ (r) កើនឡើង ។

## ១.៣.២. តម្រូវការប្រុងប្រយ័ត្ន

បុគ្គលម្នាក់ៗតែងតែមានតម្រូវការសាច់ប្រាក់ទុកនៅក្នុងដៃ សម្រាប់កិច្ចការបន្ទាន់នានា ដូចជាចំណាយលើសេវាសុខភាព និង ការជួសជុលនានា ។ ស្របគ្នានេះដែរ សាច់ប្រាក់មួយចំនួនតែងតែត្រូវបានគេរក្សាទុកនៅក្នុងដៃ ហើយក្នុងន័យនេះ **កេនស៍** បានសន្មតថា ចំនួនសាច់ប្រាក់ទុកសម្រាប់តម្រូវការបន្ទាន់ ($P_D$) នេះ នឹងប្រែប្រួលស្របគ្នាជាមួយនឹងកម្រិតចំណូលរបស់បុគ្គលម្នាក់ៗ ។ ដើម្បីងាយស្រួលក្នុងការវិភាគ យើងនឹងសន្មតថា ($P_D$) អាចចាត់ទុកជាផ្នែកមួយរបស់ ($T_D$) ជាតម្រូវការ «មិនបានគ្រោងទុក» នូវរូបិយវត្ថុសម្រាប់ប្រតិបត្តិការ ។

## ១.៣.៣. តម្រូវការសម្រាប់កេងយកចំណេញ

តម្រូវការរូបិយវត្ថុសម្រាប់កេងយកចំណេញ ($S_D$) គឺជាវិភាគទានពិតនៃទ្រឹស្តីរូបិយវត្ថុរបស់ **កេនស៍** ។ គាត់បានអះអាងថា ភាពមិនប្រាកដប្រជាអំពីអត្រាការប្រាក់នៅពេលអនាគត និង ទំនាក់ទំនងរវាងអត្រាការប្រាក់ជាមួយនឹងថ្លៃរបស់សញ្ញាប័ណ្ណ (ជាពិសេស ការធ្លាក់ចុះ និង ការកើនឡើងនៃតម្លៃរបស់វា) មានន័យថា មានពេលមួយនោះ បុគ្គលម្នាក់ៗត្រូវតែរក្សានូវរូបិយវត្ថុជាសាច់ប្រាក់ ។ ប្រសិនបើអ្នកទិញសញ្ញាប័ណ្ណនៅថ្ងៃនេះ នោះអ្នកយកចំណូលរបស់អ្នក ទៅទិញសម្បត្តិម្យ៉ាង ដែលផ្តល់ការប្រាក់ទៅតាមអត្រាកំណត់មួយ ឧបមាថា ($r_1$) ។ ថ្លៃសញ្ញាប័ណ្ណ ជួនកាលគេហៅថាជាទិន្នផល ដែលវាស់វែងដោយថ្លៃទិញ ឧទាហរណ៍ថា ១.០០០ ដុល្លារ និង គូប៉ុង ឬអត្រាការប្រាក់លើសញ្ញាប័ណ្ណនោះ ឧបមាថា ៥% ។ ប្រសិនបើថ្ងៃ ស្អែកអត្រាការប្រាក់កើនឡើងទៅដល់ ($r_2$ = 10%) នោះអ្នកនឹងខាតបង់ ($r_2 - r_1$) ។ លើសពីនេះទៀត ប្រសិនបើអ្នក ព្យាយាមលក់សញ្ញាប័ណ្ណចាស់របស់អ្នក នោះថ្លៃរបស់វានឹងធ្លាក់ចុះទៅដល់ទិន្នផលមួយតាមអត្រា ($r_2$) ។ ភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលអ្នកបានចំណាយលើសញ្ញាប័ណ្ណ នឹង ចំនួនទឹកប្រាក់ដែលទទួលដោយឥទ្ធិពលថ្លៃនៅពេលលក់ គេឱ្យឈ្មោះថា «ការខាតបង់ទុន» ។ ជាឧទាហរណ៍ បើសញ្ញាប័ណ្ណត្រូវបានទិញក្នុងតម្លៃ ១.០០០ ដុល្លារ ជាមួយនឹងអត្រាគូប៉ុង ៥% នោះសញ្ញាប័ណ្ណនេះនឹងអាចលក់បានតម្លៃ ៥០០ ដុល្លារ នៅថ្ងៃស្អែក ជាមួយនឹងអត្រា ១០% ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**រូប ៦.២ ខ្សែកោងតម្រូវការរូបិយវត្ថុដើម្បីកេងយកចំណេញ ជាលក្ខណៈបុគ្គល និង សរុប**







**កេនស៍**បានអះអាងថា ភាពមិនច្បាស់លាស់នឹងនាំឱ្យបុគ្គលមួយចំនួនរក្សាទុកសាច់ប្រាក់ ដើម្បីរកចំណូលឱ្យបានច្រើនសម្រាប់ថ្ងៃស្អែក និង ចៀសវាងការខាតបង់មូលធនរបស់ខ្លួន ។ ផ្ទុយទៅវិញ ប្រសិនបើអត្រាការប្រាក់ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះ នោះតម្រូវការសម្រាប់កេងយកចំណេញនៃរូបិយវត្ថុ នឹងធ្លាក់ចុះក្នុងកម្រិតខ្ពស់ជាងទិន្នផលពីសញ្ញាប័ណ្ណ ដែលបានទិញនៅក្នុងថ្ងៃនេះ ដោយរំពឹងថាអត្រាការប្រាក់ថ្ងៃស្អែកនឹងទាបជាងនេះ ហើយនឹងមានឱកាសដើម្បី «ចំណេញដើមទុន» ផងដែរ ។ ដូច្នេះ សញ្ញាប័ណ្ណមានតម្លៃ ១.០០០ ដុល្លារ ជាមួយនឹងទិន្នផល ១០% នឹងត្រូវលក់ក្នុងតម្លៃ ២.០០០ ដុល្លារ ប្រសិនបើអត្រាការប្រាក់ធ្លាក់មកនៅត្រឹម ៥% នៅថ្ងៃស្អែក ។

**កេនស៍** បានសន្និដ្ឋានថា បុគ្គលផ្សេងគ្នាមានទស្សនៈផ្សេងៗគ្នា អំពីការផ្លាស់ប្តូរនៃអត្រាការប្រាក់នៅពេលអនាគត ។ បុគ្គលម្នាក់ៗមានការយល់ឃើញរៀងៗខ្លួន អំពីអ្វីដែលជាអត្រាការប្រាក់ធម្មតា ។ ចំពោះអ្នកទាំងឡាយណាដែលយល់ថា អត្រាធម្មតាមានកម្រិតខ្ពស់ជាងអត្រានៅថ្ងៃនេះ នឹងមានទំនោរថាតម្រូវការកេងយកចំណេញ ($S_D$) មានកម្រិតខ្ពស់ជាង ។ ចំណែកអ្នកដែលបានគិតថា អត្រាការប្រាក់ធម្មតាទាបជាងអត្រានៅថ្ងៃនេះ នោះគេនឹងមានតម្រូវការកេងយកចំណេញ ($S_D$) ទាបជាងដែរ ។

នៅពេលដែលអត្រាការប្រាក់មានកម្រិតទាប បុគ្គលជាច្រើននឹងត្រូវមានតម្រូវការកេងយកចំណេញ ($S_D$)


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្ពស់ ដោយគេរំពឹងទុកថា អត្រាការប្រាក់នៅថ្ងៃស្អែកនឹងកើនឡើង និង ដើម្បីចៀសវាងការខាតបង់ដើមទុន ។ ប្រសិនបើបុគ្គលភាគច្រើនសមល្មមរក្សាទុកសាច់ប្រាក់ នោះនឹងមាន **អន្ទាក់រូបិយវត្ថុងាយ** (Liquidity trap) ។ នេះគឺជាស្ថានភាពនៃអត្រាការប្រាក់យ៉ាងទាប ដែលតម្រូវការកេងយកចំណេញនៃរូបិយវត្ថុមានរាងស្ទើរតែជាបន្ទាត់ដេក ហើយតម្រូវការរូបិយវត្ថុ (Liquidity) មានភាពរួញយឺតពេញលេញ ស្របទៅតាមអត្រាការប្រាក់ ។ ប្រការនេះបានឆ្លុះបញ្ចាំងនៅក្នុងរូបភាព (6.4b) ដែលខ្សែកោងមានទំនោរទៅរកភាពសណ្ឋកជាមួយនឹងអ័ក្សអាកស៊ីស ។ ក្នុងលក្ខខណ្ឌនៃ **អន្ទាក់រូបិយវត្ថុងាយ** កំណើនណាក៏ដោយនៃការផ្គត់ផ្គង់រូបិយវត្ថុ មិនធ្វើឱ្យអត្រាការប្រាក់មានការប្រែប្រួលឡើយ ។ ស្ថានភាពបែបនេះកើតមានឡើងនៅពេលដែលទិន្នផលរបស់ទ្រព្យសកម្មដែលផ្តល់ចំណូលមានកម្រិតទាបខ្លាំង ដែលធ្វើឱ្យហានិភ័យក្នុងការរក្សាទ្រព្យសកម្មនោះមានកម្រិតខ្ពស់ខ្លាំង (ការខាតបង់មូលធនប្រសិនបើអត្រាការប្រាក់កើនឡើង) ។ ប្រការនេះ ធ្វើឱ្យវិនិយោគិនចង់រក្សាវាទុកទ្រព្យសកម្មជាសាច់ប្រាក់ងាយស្រួលចំពោះរាល់កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ ។

### ១.៣.៤. តម្រូវការសរុប

តម្រូវការប្រតិបត្តិការ និង តម្រូវការប្រុងប្រយ័ត្នសម្រាប់តម្រូវការបន្ទាន់ប្រែប្រួលជាវិជ្ជមាន ស្របជាមួយនឹងចំណូល ប៉ុន្តែប្រែប្រួលជាអវិជ្ជមានជាមួយនឹងអត្រាការប្រាក់ ។ តម្រូវការរូបិយវត្ថុដើម្បីកេងយកចំណេញមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងអត្រាការប្រាក់ ។ តម្រូវការរូបិយវត្ថុសរុប តាមគំរូរបស់ **កេនស៍** គឺ÷

$M_D = T_D + P_D + S_D$ ដែល ($T_D$) និង ($P_D$) ប្រែប្រួលជាវិជ្ជមានស្របនឹងចំណូល ហើយប្រែប្រួលផ្ទុយទៅនឹងអត្រាការប្រាក់ ក្នុងខណៈដែល ($S_D$) មិនប្រែប្រួលស្របជាមួយចំណូល ប៉ុន្តែ ប្រែប្រួលអវិជ្ជមានជាមួយអត្រាការប្រាក់ ។ ជារួម យើងអាចទទួលបានរូបមន្តខាងក្រោម÷

(6.2) $M_d = L(Y, r)$

ហើយប្រសិនបើយើងសន្មតថា អនុគមន៍នេះជាអនុគមន៍បន្ទាត់ នោះ÷

(6.3) $M_d = c_o + c_1Y - c_2r$ ដែល $c_1 > 0, c_2 > 0$ និង

$c_0$ គឺជាចំនួនអប្បរមានៃសាច់ប្រាក់ដែលត្រូវតែរក្សាទុក ($c_1$) គឺជាការកើនឡើងនៃរូបិយវត្ថុដែលត្រូវការក្នុងមួយឯកតានៃការកើនឡើងរបស់ចំណូល ហើយ ($c_2$) គឺជាការថយចុះនៃរូបិយវត្ថុដែលត្រូវការ ក្នុងមួយឯកតានៃការកើនឡើងរបស់អត្រាការប្រាក់ ។ ឧបមាថាអនុគមន៍បន្ទាត់នេះ ជាបន្ទាត់ត្រង់ នោះតម្រូវការសរុបនៃរូបិយវត្ថុមានមេគុណថយចុះ ធៀបទៅនឹងអត្រាការប្រាក់ (រូបទី 6.2) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២. ផលប៉ះពាល់នៃការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ

តម្រូវការរូបិយវត្ថុសរុប ($M^d$) មានមេគុណធ្លាក់ចុះ៖ ការធ្លាក់ចុះនៃអត្រាការប្រាក់ និង ការកើនឡើងនៃតម្រូវការរូបិយវត្ថុ ។ ការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានគេសន្មតថា ត្រូវបានកំណត់ពីក្រៅដោយគោលនយោបាយ ដែលតាងដោយអថេរ ($M^s{}_0$) នៅត្រង់ចំណុចតល់អ័ក្ស ។

នៅចំណុចសមតាដំបូង អត្រាការប្រាក់ ($r_0$) បន្ទាប់ពីការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង នោះការផ្គត់ផ្គង់រូបិយវត្ថុនឹងលើសពីសេចក្តីត្រូវការ ។ នៅត្រង់ចំណុច ($r_0$) ប្រជាពលរដ្ឋមិនចង់រក្សាប្រាក់បន្ថែមទេ ។ គេមានបំណងចង់កាត់បន្ថយរូបិយវត្ថុ ដែលគេបានរក្សាទុក ដោយទិញសញ្ញាប័ណ្ណជាជំនួសវិញ ។ ការកើនឡើងតម្រូវការនៃសញ្ញាប័ណ្ណនឹងធ្វើអោយអត្រាការប្រាក់ធ្លាក់ចុះ ធ្វើឱ្យអ្នកលក់សញ្ញាប័ណ្ណ (អ្នកខ្ចីប្រាក់) ប្រឹងប្រែងលក់សញ្ញាប័ណ្ណរបស់គេ ។ ការធ្លាក់ចុះនៃអត្រាការប្រាក់បណ្តាលឱ្យតម្រូវការរូបិយវត្ថុកើនឡើង ហើយចំណុចសមតាថ្មីនឹងសម្រេចបាន ជាមួយនឹងអត្រាការប្រាក់ ($r_1$) ។

### ២.១ ការវិនិយោគ

សហគ្រាសខ្ចីប្រាក់ពីគ្រួសារដើម្បីធ្វើហិរញ្ញប្បទានគម្រោងវិនិយោគ តាមរយៈការចេញលក់ហ៊ុន និង សញ្ញាប័ណ្ណ ឬ ខ្ចីពីស្ថាប័នហិរញ្ញវត្ថុ ។ ថ្លៃដែលគេត្រូវបង់ទូទាត់ចំពោះប្រាក់កម្ចីនេះគឺអត្រាការប្រាក់ ។ ដូចគ្នានឹងការកត់សម្គាល់ពីមុនដែរ **កេនស៍**បានសន្មតថា សហគ្រាសមានតារាងវិភាគការវិនិយោគ ដែលផ្ទៀងផ្ទាត់អត្រាប្រាក់ចំណេញរំពឹងទុកពីគម្រោងផ្សេងៗ ទៅតាមការប្រែប្រួលនៃអត្រាការប្រាក់ ។ ប្រសិនបើប្រាក់ចំណេញរំពឹងទុក ដកចំណាយថ្លៃដើម ហើយគេទទួលបានចំនួនវិជ្ជមាន (ចំណេញ) នោះសហគ្រាសនឹងអនុវត្តគម្រោងនោះ ។ តែផ្ទុយទៅវិញ ប្រសិនបើ លទ្ធផលនេះជាចំនួនអវិជ្ជមាន គេនឹងមិនអនុវត្តគម្រោងនោះទេ ។

ប្រសិនបើអត្រាការប្រាក់កើនឡើង នោះការខ្ចីប្រាក់របស់សហគ្រាសនឹងថយចុះ ប្រសិនបើអត្រាការប្រាក់ធ្លាក់ចុះ នោះការខ្ចីនឹងកើនឡើង (រូបទី 6.1) ។ ប្រសិនបើការវិនិយោគកើនឡើង នោះការចំណាយសរុបនឹងរំកិល ឡើងលើក្នុងកម្រិតកើនឡើងស្វយ័តស្មើនឹង (I) ។ ការកើនឡើងនេះ យោងតាមមេគុណចំណាយសរុប នឹងធ្វើឱ្យចំណូលកើនឡើងកាន់តែខ្លាំង ។ ស្របពេលជាមួយគ្នានេះ វេទយិតភាពអត្រាការប្រាក់នៃតម្រូវការសរុប គឺជាប្រការសំខាន់ណាស់ក្នុងការកំណត់គោលនយោបាយរូបិវត្ថុឱ្យបានត្រឹមត្រូវ ។

### ២.២. ទ្រឹស្តីនៃអត្រាការប្រាក់

ជាការពិត អត្រាការប្រាក់ត្រូវបានកំណត់នៅក្នុងទីផ្សារពីរផ្សេងគ្នា ។ ទីមួយគឺជាទីផ្សារសម្រាប់សញ្ញាប័ណ្ណ ។ ទីពីរគឺទីផ្សារសម្រាប់រូបិយវត្ថុផ្ទាល់តែម្តង ។ មនុស្សម្នាក់ៗអាចរក្សាទ្រព្យសម្បត្តិរបស់ខ្លួនក្រោមទម្រង់ជារូបិយវត្ថុ ឬ សញ្ញាប័ណ្ណ ពោលគឺ ÷


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(6.1) $W_h = B + M$

**រូប ៦.៣ ផលប៉ះពាល់នៃការកាត់បន្ថយអត្រាការប្រាក់ទៅលើវិនិយោគ ចំណាយសរុប និង ប្រាក់ចំណូលសមតា**




ក្នុងកម្រិតអត្រាការប្រាក់ណាមួយ នឹងមានតម្រូវការចំពោះរូបិយវត្ថុកម្រិតណាមួយដែរ (សមីការ (6.2 & 6.3) និង ការផ្គត់ផ្គង់រូបិយវត្ថុ ដែលផ្តល់ដោយធនាគារកណ្តាល (រូបទី 6.2) ហើយមានតម្លៃសមតា (R) ដែលផ្ទឹមផ្គង តម្រូវការជាមួយនឹងការផ្គត់ផ្គង់រូបិយវត្ថុ ។ ផ្សេងពីនេះ នៅមានតម្រូវការ និង ការផ្គត់ផ្គង់សញ្ញាប័ណ្ណ ហើយតម្លៃសមតា គឺ (r) ដែលចូលរួមថ្លឹងថ្លែងនូវតម្រូការ និង ការផ្គត់ផ្គង់ ។ ចំណុចសមតាជារួម អត្រាការប្រាក់ដែលទទួលបានមានចំនួនដូចគ្នា ។

## ២.៣. ចំណុចសមតា

រូបភាព ៦.៤ បង្ហាញអំពីចំណុចសមតាដំបូងនៅក្នុងទីផ្សាររូបិយវត្ថុ បន្ទាប់ពីការផ្គត់ផ្គង់រូបិយវត្ថុបានកើន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឡើង ។ ដោយខុសពីគំរូបុរាណនិយម ការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុមិនត្រឹមតែធ្វើឱ្យ (r) ថយចុះប៉ុណ្ណោះទេ តែថែមទាំងនាំឱ្យមានការកើនឡើងនៃ (I) ផងដែរ ដែលប្រការនេះនឹងនាំឱ្យមានកំណើនចំណូលជារួម ដូចមាននៅក្នុង (រូបភាព ៦.១) ។

**រូប ៦.៤ សមតាលើទីផ្សាររូបិយវត្ថុ**




## ៤. សមតានៃទីផ្សាររូបិយវត្ថុ: ខ្សែកោង LM

តម្រូវការរូបិយវត្ថុតាមទ្រឹស្តីរបស់ **កេនស៍** រាប់បញ្ចូលសមាសធាតុទាំងអស់នៃតម្រូវការប្រតិបត្តិការ តម្រូវការប្រុងប្រយ័ត្នសម្រាប់ពេលបន្ទាន់ តម្រូវការកេងយកចំណេញ និង តម្រូវការសរុប ។ តម្រូវការរូបិយវត្ថុត្រូវបានសន្មតថា នឹងប្រែប្រួលជាវិជ្ជមានជាមួយនឹងចំណូល ដោយសារតម្រូវការប្រតិបត្តិការ ។ តម្រូវការរូបិយវត្ថុមានបម្រែបម្រួលអវិជ្ជមានជាមួយនឹងអត្រាការប្រាក់ ដោយសារតែតម្រូវការរូបិយវត្ថុដើម្បីកេងយកចំណេញ និង ដោយសារបរិមាណនៃសមតុល្យប្រតិបត្តិការនៅគ្រប់កម្រិតចំណូលមានការធ្លាក់ចុះ នៅពេលដែលអត្រាការប្រាក់ធ្លាក់ចុះ ។ ក្នុងន័យនេះ ជាទូទៅ តម្រូវការរូបិយវត្ថុអាចសរសេរបាន ដូចខាងក្រោម ÷

(6.2) $M^d = L(Y, r)$

ម្យ៉ាងទៀត តាមទម្រង់បន្ទាត់ត្រង់ យើងបាន ÷

$M^d = c_o + c_1Y - c_2r$ ដែល $c_o > 0, c_1 > 0$ និង $c_2 > 0$


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឥឡូវនេះ យើងចង់រកគ្រប់បន្សំទាំងអស់នៃអត្រាការប្រាក់ (r) និង ចំណូល (Y) ដែលធ្វើឱ្យមានសមតានូវតម្រូវការរូបិយវត្ថុ និង ការផ្គត់ផ្គង់រូបិយវត្ថុ ក្នុងចំនួនថេរមួយ ដែលតំណាងដោយ ($M^s_0$)។ ការតភ្ជាប់គ្រប់ចំណុចទាំងអស់នេះ ត្រូវបានគេហៅថា **បន្ទាត់ LM** ពីព្រោះនៅតាមបណ្តោយបន្ទាត់នេះ តម្រូវការរូបិយវត្ថុស្មើនឹងការផ្គត់ផ្គង់រូបិយវត្ថុ (M)។ សមីការ **បន្ទាត់ LM** អាចត្រូវបានគេសរសេរដូចខាងក្រោម ÷

(6.4) $M^s_0 = M^d = c_0 + c_1Y - c_2r$

នៅក្នុងរូបភាព ៦.៥ បន្ទាត់តម្រូវការរូបិយវត្ថុចំនួនបីផ្សេងគ្នាត្រូវគេគូស អោយស្របទៅនឹងកម្រិតចំណូលកាន់តែខ្ពស់ទៅៗ គឺ $Y_0$, $Y_1$, $Y_2$ ។ នៅត្រង់ ($Y_0$) ចំណុចសមតាត្រូវសម្រេចបាន នៅត្រង់អត្រាការប្រាក់ ($r_0$) ។ នៅពេលចំណូលកើនឡើងពី ($Y_0$) ទៅ ($Y_1$) ហើយពី ($Y_1$) ទៅ ($Y_2$) នោះ បន្ទាត់តម្រូវការរូបិយវត្ថុរំកិលទៅខាងស្តាំ នៅពេលគេដៅវានៅលើអ័ក្ស ដោយធៀបទៅនឹងអត្រាការប្រាក់ ។ ចំណុចទាំងឡាយ ដែលកើតឡើងដោយសារការប្រសព្វគ្នា រវាងបន្ទាត់តម្រូវការរូបិយវត្ថុទាំងនេះ ជាមួយនឹងបន្ទាត់ឈរ ដោយសារការផ្គត់ផ្គង់រូបិយវត្ថុជាចំនួនថេរ គឺជាចំណុចសមតាសម្រាប់ទីផ្សាររូបិយវត្ថុ ។

**រូប ៦.៥ សមតាលើទីផ្សាររូបិយវត្ថុ និង ខ្សែបន្ទាត់ LM**




ដោយសារការប្រែប្រួលនៃចំណូល (Y) យើងអាចគូសបាននូវចំណុចជាស៊េរី (A, B, C) ដែលបង្ហាញថា ដោយសារការផ្គត់ផ្គង់រូបិយវត្ថុជាចំនួនថេរ និង កំណើននៃ (Y) អត្រាការប្រាក់សមតាថ្មីនឹងត្រូវបង្កើតឡើង គឺ ($r_0$, $r_1$, $r_2$) ។ ចំណុចទាំងនេះ (Y, r) អាចត្រូវបានគេដៅដើម្បីបង្ហាញរូបភាពនៅលើបន្ទាត់ (LM) ដូច នៅក្នុងរូបភាព (6.5b) ដែលចង្អុលបង្ហាញនូវគន្លងលក្ខខណ្ឌសមតា នៅលើទីផ្សាររូបិយវត្ថុ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៤.១. កត្តាកំណត់ជម្រាលបន្ទាត់ (LM)

ជម្រាលរបស់បន្ទាត់ (LM) ឆ្លុះបញ្ចាំងការប្រែប្រួលនៃអត្រាការប្រាក់ ដែលបណ្ដាលមកពីការកើនឡើងនៃ (Y) ពោលគឺ ($\Delta r/\Delta Y$) ។ មានកត្តាពីរដែលមានឥទ្ធិពលលើជម្រាលនេះ តម្លៃ ($c_1$) និង ភាពរួញយឺតនៃតម្រូវការរូបិយវត្ថុ ជាពិសេសតម្លៃ ($c_2$) ។

***ទីមួយ-*** ពីសមីការ (7.4) យើងដឹងថា $Md = co + c1Y – c2r$ ។ ដោយគិតតែពីការកើនឡើងនៃ (Y) ($M^d$) នឹងកើនឡើង ប្រសិនបើ (Y) កើនឡើងក្នុងកម្រិត $c_1 \times \Delta Y$ ដែល ($c_1$) ជាអញ្ញតិនៃកំណើនតម្រូវការរូបិយវត្ថុ ក្នុងមួយឯកតានៃការកើនឡើងរបស់ចំណូល ។ ដោយសារការផ្គត់ផ្គង់រូបិយវត្ថុជាចំនួនថេរ អត្រាការប្រាក់ត្រូវកើនឡើងឱ្យខ្ពស់គ្រប់គ្រាន់ ដើម្បីបង្រួបទូទាត់នូវកំណើនតម្រូវការរូបិយវត្ថុ ដែលបណ្ដាលមកពីចំណូល ។ ប្រសិនបើ ($c_1$) កើនកាន់តែខ្ពស់ អត្រាការប្រាក់ត្រូវតែកើនឡើងកាន់តែច្រើន ។ ផ្ទុយទៅវិញ បើ ($c_1$) កាន់តែតូច នោះនឹងមានការកើនឡើងយ៉ាងតិចតួចនៃអត្រាការប្រាក់ ។ ម៉្យាងវិញទៀត តម្លៃ ($c_1$) កាន់តែខ្ពស់ នោះជម្រាលនៃបន្ទាត់ (LM) កាន់តែត្រង់ឡើងលើ ។ ក៏ប៉ុន្តែ តម្លៃ ($c_1$) ជាចំនួនមានស្ថិរភាព ដែលកំណត់ដោយកត្តាស្ថាប័ន ឧទាហរណ៍ ដូចជាបច្ចេកវិជ្ជា និង រយៈពេលទូទាត់ជាដើម ។

**រូប ៦.៦ ភាពយឺតនៃតម្រូវការរូបិយវត្ថុចំពោះអត្រាការប្រាក់ និង ជម្រាលនៃខ្សែបន្ទាត់ LM**









fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

***ទីពីរ-*** ដោយគិតតែអំពី ការឆ្លើយតបនៃតម្រូវការរូបិយវត្ថុ $M^d$ ចំពោះការប្រែប្រួល r (វេទយិតភាពអត្រាការប្រាក់នៃតម្រូវការរូបិយវត្ថុ) យើងដឹងថា ការកើនឡើងនៃអត្រាការប្រាក់ r ធ្វើឱ្យកើនឡើងថ្លៃរក្សាទុកនូវរូបិយវត្ថុ ដែលបណ្តាលឱ្យ តម្រូវការកេងយកចំណេញ និង តម្រូវការប្រតិបត្តិការមានការថយចុះ ។ នៅក្នុងសមីការ ៧.៤ យើងដឹងថា $M^d = c_o + c_1Y - c_2r$ ដែល ($c_2$) វាស់វែងនូវការប្រែប្រួលនៅក្នុងតម្រូវការ $M^d$ ចំពោះការប្រែប្រួលនៃអត្រាការប្រាក់ ($-c_2 = \Delta M^d/\Delta r$) ។ រូបភាព 6.6a បង្ហាញថា $M^d$ មានភាពរួញយឺតយ៉ាងតិចតួច (បន្ទាត់ត្រង់) (ដែលវាស់ដោយតម្លៃដាច់ខាត ពោលគឺមិនគិតពីសញ្ញាអវិជ្ជមាន ដែលជាប់ពាក់ព័ន្ធជាមួយ ($c_2$) ។ ប្រការនេះមានន័យថា ($c_2$) មានតម្លៃទាប ពោលគឺ កំណើនយ៉ាងតិចតួចនៃ (Y) តម្រូវឱ្យអត្រាការប្រាក់ (r) កើនយ៉ាងខ្លាំង ដើម្បីកាត់បន្ថយនូវតម្រូវការកេងយកចំណេញ និង តម្រូវការប្រតិបត្តិការ ដើម្បីបំពេញបង្គ្រប់នូវកំណើន ($M^d$) ដែលបណ្តាលមកពីកំណើនចំណូល ។ ម្យ៉ាងវិញទៀត ប្រសិនបើ $M^d$ មានភាពរួញយឺតឆ្លើយតបនឹងអត្រាការប្រាក់ខ្លាំង ដូចនៅក្នុងរូបភាព 6.6b នោះ ($c_2$) នឹងមានទំហំធំ ដែលតម្រូវអោយ (r) ប្រែប្រួលតែបន្តិចបន្តួចប៉ុណ្ណោះ ។

**រូប ៦.៧ ខ្សែបន្ទាត់ LM នៅក្នុងគំរូបុរាណនិយម**




មានករណីពិសេសពីរ ពោលគឺ តម្រូវការរូបិយវត្ថុ ដែលមិនរួញយឺតពេញលេញ ទៅតាមអត្រាការប្រាក់ និង ដែលរួញយឺតពេញលេញទៅតាមអត្រាការប្រាក់ ។ ទីមួយ ប្រសិនបើតម្រូវការរូបិយវត្ថុមានលក្ខណៈមិនរួញយឺតពេញលេញ ទៅតាមអត្រាការប្រាក់ នោះ $c_2=0$ ។ ប្រការនេះមានន័យថា សមីការ 6.4 ក្លាយទៅជា $M^d= c_0 + c_1Y$ ពោលគឺតម្រូវការរូបិយវត្ថុ គឺជាអនុគមន៍នៃ Y ។ នេះគឺជាស្ថានភាពនៅក្នុងគំរូបុរាណនិយម ។ ស្របជាមួយនេះដែរ តម្រូវការរូបិយវត្ថុ នឹងមិនប្រែប្រួលដោយសារការផ្លាស់ប្តូរអត្រាការប្រាក់នោះទេ ហើយខ្សែបន្ទាត់ (LM) នឹងមានសណ្ឋានតាមទិសឈរ (Figure 6.7) ឬ $M^d = M^s{}_0 = c_0 + c_1Y$ ហើយគេអាចទាញបាន ÷

(6.5) $Y = (M^s{}_0 - c_0)/c_1$

***ទីពីរ*** - ប្រសិនបើតម្រូវការរូបិយវត្ថុមានលក្ខណៈរួញយឺតពេញលេញ (ខិតទៅជិតអនន្ត) ដោយសារការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រែប្រួលអត្រាការប្រាក់ ។ ដូចដែលបានកត់សម្គាល់នៅក្នុងការពិភាក្សាអំពីតម្រូវការកេងយកចំណេញ **កេនស៍** ជឿជាក់ថា នៅចំណុចដែលអត្រាការប្រាក់ទាប តម្រូវការកេងយកចំណេញនឹងមានកម្រិតខ្ពស់ ដោយសារតម្លៃនៃការរក្សាទុករសាច់ប្រាក់នឹងមានកម្រិតទាប ហើយមានហានិភ័យចំពោះការខាតបង់ទុននៅពេលអនាគតក៏កាន់តែខ្ពស់ ពោលគឺប្រសិនបើអ្នកណាម្នាក់ទិញសញ្ញាប័ណ្ណ នៅពេលដែលអត្រាការប្រាក់ទាបខ្លាំង ហើយបន្ទាប់ពីអត្រាការប្រាក់កើនឡើង នោះថ្លៃនៃសញ្ញាប័ណ្ណត្រូវតែកាត់បន្ថយ ដើម្បីឱ្យទិន្នផលរបស់វាស្មើអត្រាការប្រាក់ដែលមានកម្រិតខ្ពស់ជាងនៅពេលនេះ ។ ស្ថានភាពនេះបង្កើតឡើងនូវអ្វីដែល **កេនស៍**ហៅថា ***អន្ទាក់រូបិយវត្ថុទៅ*** (Liquidity Trap) *នៅពេលដែលការប្រែប្រួលនៃអត្រាការប្រាក់ មានផលប៉ះពាល់យ៉ាងតិចតួច ឬ មិនមានផលប៉ះពាល់អ្វីទាំងអស់នៅលើតម្រូវការ* ($M^d$) ។ ក៏ប៉ុន្តែ ស្ថានភាពបែបនេះអាចកើតមានតែនៅក្នុងករណី ដែលអត្រាការប្រាក់មានកម្រិតយ៉ាងទាប ។ ដូច្នេះ យើងត្រូវតែផ្លាស់ប្តូរពីបន្ទាត់ត្រង់ទៅបន្ទាត់កោង សម្រាប់ ($M^d$) និង (LM) រូបភាព (6.8)។ ប្រការនេះមានន័យថា ជម្រាលខ្សែកោងទាំងពីរនេះមិនមែនជាចំនួនថេរទេ ប៉ុន្តែវាត្រូវប្រែប្រួលទៅតាមអត្រាការប្រាក់ ។

**រូប ៦.៨ អន្ទាក់រូបិយវត្ថុរបស់កេនស៍**





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.២. កត្តាដែលធ្វើអោយខ្សែបន្ទាត់ (LM) រំកិល

ការធ្វើចលនាតាមជម្រាលនៃចំណុចសមតា ឆ្លុះបញ្ចាំងនូវការប្រែប្រួលរបស់អថេរផ្ទៃក្នុង ដែលត្រូវបានកំណត់នៅលើអ័ក្ស (X) និង (Y) ។ ការរំកិលនៃខ្សែកោងឆ្លុះបញ្ចាំងអំពីការប្រែប្រួលនៃកត្តាខាងក្នុង ឬ កត្តាថេរ ។ ដូច្នេះ ប្រការខាងលើនេះ ធ្វើឱ្យយើងមើលឃើញនូវការកែតម្រូវទៅវិញទៅមក នៃ (Y) និង (r) ទៅតាមការផ្លាស់ប្តូររបស់គ្នាទៅវិញទៅមក ដោយរាប់បញ្ចូលទាំងជម្រាល និង ភាពរួញយឺតផងដែរ ។ បន្ទាប់ពីនេះ យើងនឹងពិចារណាអំពីកត្តាខាងក្រៅពីរ ពោលគឺការផ្គត់ផ្គង់រូបិយវត្ថុថេរ និង ការផ្លាស់ប្តូរនៅក្នុង «**ចំណង់ចំណូលចិត្តរក្សារូបិយវត្ថុងាយស្រួល**» ពោលគឺ ការផ្លាស់ប្តូរលក្ខខណ្ឌស្ថាប័ន ដែលបង្ហាញពី កំឡុងពេល និង បច្ចេកវិជ្ជានៃការទូទាត់ រួមនឹងបរិយាកាសផងដែរ ។

**រូប ៦.៩ ការរំកិលនៃខ្សែបន្ទាត់ LM ដោយសារកំណើនបរិមាណរូបិយវត្ថុ**




**ការផ្លាស់ប្តូរការផ្គត់ផ្គង់រូបិយវត្ថុ** : ទីមួយ ពិចារណាអំពីការផ្លាស់ប្តូរនៃការផ្គត់ផ្គង់រូបិយវត្ថុ ($M^s$) ។ គេបានសន្និដ្ឋានថា $M^s$ ត្រូវបានកំណត់ឱ្យនៅថេរ ដោយធនាគារកណ្តាល ។ ធនាគារកណ្តាលផ្លាស់ប្តូរការផ្គត់ផ្គង់រូបិយវត្ថុ (Figure 6.9) ។ យើងដឹងថា ÷

(6.4) $M^s_0 = M^d = c_0 + c_1Y - c_2r$ ដូច្នេះអាចរក (r)÷

(6.4a) $$r = \frac{c_0}{c_2} - \frac{1}{c_3}(M_0^s) + \frac{c_1Y}{c_2}$$



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលខ្សែបន្ទាត់ (LM) មានចំណុចប្រសព្វត្រង់ $c_0/c_2 - 1/c_3(M^s_0)$ និង ជម្រាល $c_1Y/c_2$ ។

ដោយសារការផ្គត់ផ្គង់រូបិយវត្ថុ ($M^s_0$) គឺជាសមាសធាតុមួយនៃចំណុចប្រសព្វ ដូច្នេះការកើនឡើង ឬ ថយចុះនៅនៃ $M^s$ នឹងបណ្តាលអោយចំណុចប្រសព្វរំកិលលើងលើ ឬ ចុះក្រោម ។ ម្យ៉ាងវិញទៀត ដោយសារសញ្ញាអវិជ្ជមានចំណុចប្រសព្វនឹងរំកិលតាមទិសផ្ទុយ ពោលគឺការកើនឡើងនៃ $M^s$ បណ្តាលឱ្យចំណុចប្រសព្វធ្លាក់ចុះ (Figure 6.1) ។ ប្រសិនបើ (Y) ថេរ នោះការកើនឡើងនៃ $M^s$ មានន័យថា រូបិយវត្ថុច្រើនថែមទៀតនឹងត្រូវរក្សាទុកជាសាច់ប្រាក់ចំពោះគ្រប់កម្រិតនៃអត្រាការប្រាក់ ។ ប្រសិនបើ (Y) អាចប្រែប្រួលបាន នោះអត្រាការប្រាក់ដែលមានស្រាប់ $r_0$ អាចរក្សាបានតែក្នុងករណី (Y) កើនឡើងពី $Y_0$ ទៅ $Y_1$ តែប៉ុណ្ណោះ ។

**រូប ៦.១០ ការរំកិលនៃខ្សែបន្ទាត់ LM ដោយសារការរំកិលនៃអនុគមន៍តម្រូវការរូបិយវត្ថុ**




**ការប្រែប្រួលនៃអនុគមន៍តម្រូវការរូបិយវត្ថុ:** ទីពីរ យើងពិចារណាអំពីការប្រែប្រួលនៃអនុគមន៍តម្រូវការរូបិយវត្ថុ ÷ $M^d = c_0 + c_1Y - c_2r$ ។ យើងបានឃើញហើយថា មេគុណ ($c_0$, $c_1$ & $c_2$) ត្រូវបានបង្កើតឡើងតាមរបៀបស្ថាប័ន ពោលគឺ ធ្វើឱ្យទៅជាទម្លាប់នៃឥរិយាបថគ្រួ ។ ប្រសិនបើមនុស្សម្នាក់ៗជឿជាក់ថា ថ្ងៃនេះនឹងបន្តទៅរហូតដល់ថ្ងៃស្អែក នោះមេគុណខាងលើនេះនឹងប្រហែលជានៅថេរ ។ ប៉ុន្តែ ប្រសិនបើគេលែងមានជំនឿទុកចិត្តហើយនោះតម្លៃរបស់វានឹងត្រូវផ្លាស់ប្តូរ ។ ប្រសិនបើមានការព្រួយបារម្ភអំពីការកើនឡើងយ៉ាងខ្លាំងនៃអត្រាការប្រាក់ (ហើយនិងមានការខាតបង់ទុនផងនោះ) នឹងនាំឱ្យមាននិន្នាការរក្សាទុករូបិយវត្ថុបន្ថែមទៀត ពោលគឺនៅរាល់ចំណុចនៃអត្រាការប្រាក់ដដែលនេះ គេនឹងរក្សាទុករូបិយវត្ថុកាន់តែច្រើន ដែលធ្វើអោយបន្ទាត់តម្រូវការរូបិយវត្ថុ ($M^d$) រំកិលទៅខាងស្តាំ (Fig. 6.11) ។ ឆ្លើយតបនឹងចលនានេះ នៅរាល់គ្រប់កម្រិតអត្រាការប្រាក់ ខ្សែបន្ទាត់ (LM) នឹងរំកិលទៅខាងឆ្វេង ដែលឆ្លុះបញ្ចាំងអំពីតម្រូវការកាន់តែច្រើនឡើងចំពោះសាច់ប្រាក់ងាយស្រួល នៅកម្រិតអត្រាការប្រាក់នីមួយ ៗ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រដៀងគ្នានេះដែរ ប្រសិនបើមានការប្រែប្រួលនៃរបៀបទូទាត់ និង បច្ចេកវិទ្យា នឹងមានការផ្លាស់ប្តូរនូវចំនួនរូបិយវត្ថុដែលត្រូវរក្សា នៅតាមកម្រិតការប្រាក់នីមួយៗ ។ ឧទាហរណ៍ ការដាក់អោយប្រើប្រាស់នូវប័ណ្ណឥណពន្ធ បានកាត់បន្ថយនូវបរិមាណរូបិយវត្ថុដែលគេរក្សាទុក នៅគ្រប់កម្រិតនៃអត្រាការប្រាក់ ដែលឆ្លុះបញ្ចាំងពីការកែលម្អការគ្រប់គ្រងសាច់ប្រាក់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៧

## ទីផ្សារផលិតផល: ខ្សែកោង IS

### ១. សមតានៃទីផ្សារផលិតផល : ខ្សែកោង IS

មនុស្សយើងម្នាក់ៗតែងតែមានផែនការគ្រោងទុកសម្រាប់ថ្ងៃស្អែក ។ ប៉ុន្តែ នៅពេលដែលថ្ងៃអនាគតនេះបានមកដល់ វាមិនដែលដូចអ្វីដែលយើងចង់បាននោះទេ ។ យើងត្រូវរៀបចំផែនការនេះម្តងហើយម្តងទៀត រហូតដល់ពេលមួយដែលយើងសន្មតថា ចំណុចសមតានៃទីផ្សារផលិតផលកើតឡើង នៅពេលដែល÷

(7.1) $Y = C + I + G$, ឬ

(7.2) $I + G = S + T$

**រូប ៧.១ ការគូសខ្សែបន្ទាត់ IS** (T=G =0 )






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យើងបានរៀបចំនូវតារាងសមតាទីផ្សារផលិតផល ដែលយើងហៅថាខ្សែបន្ទាត់ IS ដែលទាញចេញពីសមីការ (7.2) ។ យើងនឹងរកបន្សំនៃអត្រាការប្រាក់ និង ចំណូល ដែលបង្កើតឡើងនូវចំណុចសមតា សម្រាប់ទីផ្សារផលិតផល ។ យើងអាចបង្កើតលក្ខខណ្ឌសមតាដ៏សាមញ្ញដូចខាងក្រោម :

(7.3) $I(r) = S(Y)$

នោះមានន័យថា ការវិនិយោគគឺជាអនុគមន៍នៃអត្រាការប្រាក់ ដែលមានមេគុណអវិជ្ជមាន ហើយស្មើនឹងសញ្ច័យ ដែលមានមេគុណវិជ្ជមាន ជាអនុគមន៍នៃចំណូល (Fig. 7.1)។ នៅគ្រប់កម្រិតនៃអត្រាការប្រាក់ (r) យើងទទួលបាននូវកម្រិតដូចគ្នាដែរនៃការវិនិយោគ ហើយចំពោះគ្រប់កម្រិតនៃការវិនិយោគ វាទាមទារនូវសញ្ច័យដែលមានកម្រិតឆ្លើយតបគ្នា និង ស្របទៅនឹងកម្រិតជាក់ស្តែងនៃចំណូល (Y) ។ ដោយយកអត្រាការប្រាក់ (r) ពីរូបភាព 7.1a និង (Y) ពីរូបភាព 7.1b យើងអាចគូសខ្សែបន្ទាត់ (IS) ដែលបង្ហាញនូវកម្រិតអត្រាការប្រាក់ (r) និង ចំណូល (Y) ទៅតាមទំនាក់ទំនង $I(r) = S(Y)$ ដូចដែលបង្ហាញនៅក្នុងរូបភាព 7.1.c ។

## ១.១. *កត្តាកំណត់មេគុណនៃខ្សែបន្ទាត់ (IS)*

**រូប ៧.២ ការឆ្លើយតបនៃវិនិយោគចំពោះអត្រាការប្រាក់ និង ជម្រាលនៃខ្សែបន្ទាត់ IS**






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានកត្តាពីរដែលកំណត់មេគុណនៃខ្សែបន្ទាត់ (IS) ÷ តម្រូវការវិនិយោគឆ្លើយតបខ្លាំងចំពោះអត្រាការប្រាក់ និង ឧបនិស្ស័យបន្ថែមដើម្បីសញ្ជ័យ ។ ប្រសិនបើការវិនិយោគឆ្លើយតបយ៉ាងលឿនទៅនឹងបម្រែបម្រួលនៃអត្រាការប្រាក់ នោះមេគុណនៃអនុគមន៍វិនិយោគនឹងមានលក្ខណៈផ្តេក ដូចដែលមានបង្ហាញនៅក្នុងរូបភាព 7.2a ។

ការឆ្លើយតបនៃការវិនិយោគចំពោះអត្រាការប្រាក់មានកម្រិតខ្ពស់ខ្លាំង បើធៀបទៅនឹង (I) ។ ដូច្នេះ មេគុណនៃខ្សែបន្ទាត់ (IS) នឹងមានចំណោតខ្លាំងជាងការឆ្លើយតបនៃតម្រូវការវិនិយោគចំពោះអត្រាការប្រាក់ និង មានលក្ខណៈកាន់តែផ្តេក នៅពេលដែលកាឆ្លើយតបនៃការវិនិយោគចំពោះអត្រាការប្រាក់កាន់តែខ្ពស់ ។

ឧបនិស្ស័យបន្ថែមដើម្បីសញ្ជ័យ (MPS) (ដែលមានទិសផ្ទុយនឹង MPS) កំណត់នូវមេគុណនៃខ្សែបន្ទាត់អនុគមន៍សញ្ជ័យ ។ ប្រសិនបើ MPS កាន់តែខ្ពស់ ខ្សែបន្ទាត់អនុគមន៍សញ្ជ័យមានចំណោតកាន់តែខ្លាំង (Figure 7.2b) ។ បើប្រៀបធៀបទៅ MPS គឺជាអញ្ញត្តិថេរស្ថាប័ន ដែលមិនប្រែប្រួលនៅក្នុងវិធីសាស្ត្រដ៏សាមញ្ញនេះទេ ។

## ១.២. កត្តាដែលរំកិលខ្សែបន្ទាត់ (IS)

**ការប្រែប្រួលនៃអនុគមន៍វិនិយោគៈ** កត្តាទីមួយដែលធ្វើឱ្យខ្សែបន្ទាត់ (IS) រំកិលបាន គឺការប្រែប្រួលនៃអនុគមន៍វិនិយោគ ។ នៅខណៈមួយ សហគ្រាសមានតារាងប្រសិទ្ធភាពបន្ថែមនៃការវិនិយោគ ដែលបង្ហាញពីចំណុចត្រូវបោះបង់នៃគម្រោងវិនិយោគ ចំពោះកម្រិតនីមួយៗនៃអត្រាការប្រាក់ (r) ។ ប្រសិនបើប្រសិទ្ធភាពបន្ថែមនៃការវិនិយោគនេះប្រែប្រួល ឧទាហរណ៍ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីធ្វើឱ្យអត្រាចំណេញដែលរំពឹងទុកពីគម្រោងវិនិយោគកើនឡើង ដូច្នេះត្រូវគណនាឡើងវិញនូវកម្មវិធីវិនិយោគ ដែលនឹងនាំឱ្យមានការរំកិលនូវខ្សែកោង (IS) ទៅខាងស្តាំឆ្លុះបញ្ចាំង ពីកម្រិតកើនឡើងនៃការវិនិយោគ នៅគ្រប់ចំណុចនីមួយៗនៃការប្រាក់ ។

កត្តាទីពីរដែលអាចរំកិលខ្សែបន្ទាត់ (IS) គឺចំណាយរដ្ឋាភិបាល និង ការបង់ពន្ធ ។ ប្រសិនបើយើងបញ្ចូលផ្នែករដ្ឋាភិបាលទៅក្នុងសមីការ នោះលក្ខខណ្ឌសមតាប្តូរទៅជា÷

(7.4) $$I(r) + G = S(Y-T) + T$$

ដូច្នេះ សញ្ជ័យលែងជាអនុគមន៍ដ៏សាមញ្ញនៃចំណូលទៀតឡើយ ប៉ុន្តែគឺជាអនុគមន៍នៃ«ចំណូលក្រោយពេលបង់ពន្ធ» ពោលគឺសញ្ជ័យឯកជន (អនុគមន៍នៃចំណូលក្រោយពេលបង់ពន្ធ) បំពេញបង្គ្រប់នូវសញ្ជ័យ «ចាប់បង្ខំ» ក្នុងទម្រង់ជាពន្ធ ។ ដូចគ្នានេះដែរ ការវិនិយោគឯកជនត្រូវបំពេញដោយចំណាយរដ្ឋាភិបាល ដែលធ្វើហិរញ្ញប្បទានដោយពន្ធ ដែលជាសញ្ជ័យចាប់បង្ខំ ។

ដើម្បីគូសខ្សែបន្ទាត់ (IS) ដោយមានផ្នែករដ្ឋាភិបាលចូលរួម យើងត្រូវចាប់ផ្តើមគូសអនុគមន៍វិនិយោគដែលមានមេគុណប្រាប់ទិសចុះក្រោម ដែលធៀងផ្ទាត់នឹងអត្រាការប្រាក់ ដែលបំពេញដោយចំណាយរដ្ឋាភិបាល និងត្រូវបានកំណត់ជាលក្ខណៈស្វ័យប្រវត្តិ (រូបទី 7.3a) ។ ដូចគ្នានេះដែរ អនុគមន៍សញ្ជ័យរំកិលទៅខាងស្តាំ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងបរិមាណនៃពន្ធដែលដកចេញពីចំណូលដុល ។ ក្នុងករណីទាំងពីរ G និង T ត្រូវបានគេសន្មតថា ជាចំនួនស្វយ័តដែលថេរ ហើយ ក្នុងករណីទី១ (G) ផ្ទៀងផ្ទាត់ជាមួយអត្រាការប្រាក់ ហើយក្នុងករណីទី២ (T) ផ្ទៀងផ្ទាត់ជាមួយចំណូល ។ ដោយប្រើប្រាស់ខ្សែបន្ទាត់កែសម្រួលពីរ (I + G) និង s(Y-T) យើងអាចគណនាកម្រិតការប្រាក់ដែលធ្វើឱ្យការវិនិយោគស្មើនឹងសញ្ជ័យ ដែលផ្ទៀងផ្ទាត់ទៅនឹងកម្រិតចំណូលដែលត្រូវកំណត់នៅលើខ្សែបន្ទាត់ (IS) (រូបភាព 7.3) ។

**រូប ៧.៣ ខ្សែបន្ទាត់ IS ដែលមានវិស័យរដ្ឋាភិបាល**




បន្ទាប់ពីសម្រេចបាននូវចំណុចសមតា រដ្ឋាភិបាលដែលជាតួអង្គស្វយ័ត អាចសម្រេចផ្លាស់ប្តូរ (G) ឬ (T) ។

**បម្រែបម្រួលចំណាយរដ្ឋាភិបាល:** ទីមួយ- ប្រសិនបើ (G) កើនឡើង នោះខ្សែកោងបង្គំនៃការវិនិយោគ និង ចំណាយរដ្ឋាភិបាល (I+G) រំកិលទៅខាងស្តាំ (រូបទី 7.4b) ។ ចំណុចសមតានឹងទាមទារឱ្យមានកម្រិតកើនឡើងស្មើគ្នានៅក្នុង (S+T) ដែលអាចកើតបាន ប្រសិនបើ (Y) កើនឡើងពី $Y_0$ ទៅ $Y_1$ (រូបទី 7.4b) ។ ឧបមាថា (G) មិនរុញច្រានចេញ (I) (មានន័យថា រដ្ឋាភិបាលខ្ចីប្រាក់លើទីផ្សារសញ្ញាប័ណ្ណ) នោះអត្រាការប្រាក់បច្ចុប្បន្ន ($r_0$) នឹងអាចនៅដដែល ប្រសិនបើ (Y) កើនឡើង ។ នេះមានន័យថា នៅគ្រប់កម្រិតអត្រាការប្រាក់ ខ្សែបន្ទាត់ IS រំកិលពី


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

$IS_0$ ទៅ $IS_1$ ហើយនៅពេលកម្រិតអត្រាការប្រាក់ប្រែប្រួលពី $r_0$ ទៅ $r_1$ នោះចំណូល រំកិលពី $Y_0$ ទៅ $Y_1$ ។

ចុះទំនាក់ទំនងរវាង ($\Delta G$) និង ($\Delta Y$) តើវានឹងយ៉ាងណា?

(7.5) $\Delta Yr_0 = \Delta G(1/1\text{-}b)$ ដែល 1-b = MPS ឬ 1-MPC និង (1/1-b) គឺជាមេគុណចំណាយស្វយ័ត (សមីការ 5.21) ។

### រូប ៧.៤ ការរំកិលនៃខ្សែបន្ទាត់ IS ដោយសារកំណើនចំណាយរដ្ឋាភិបាល




**បម្រែបម្រួលនៃពន្ធ:** ទីពីរ- តើមានអ្វីកើតឡើង ប្រសិនបើ (T) ប្រែប្រួល ។ កំណើនពន្ធនឹងមិនប៉ះពាល់ដោយផ្ទាល់ទៅលើអនុគមន៍វិនិយោគទេ (រូប 7.5a) ។ ផ្ទុយទៅវិញ វានឹងកាត់បន្ថយសញ្ច័យ ដែលធ្វើឱ្យខ្សែបន្ទាត់សញ្ច័យរំកិលទៅខាងឆ្វេង (រូប 7.5b) ។ ដើម្បីរក្សាកម្រិតអត្រាការប្រាក់ឱ្យស្ថិតនៅ ($r_0$) (Y) ត្រូវតែថយចុះពី $Y_0$ ទៅ $Y_1$ ។ ប្រការនេះធ្វើឱ្យខ្សែបន្ទាត់ IS រំកិលទៅខាងឆ្វេង (រូបទី 7.5c)


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទៅតាមកម្រិតនៃមេគុណពន្ធ $\Delta Yr_0 = \Delta T\ (-b/1-b)$ ។

នៅទីបញ្ចប់ យើងដឹងថា ជំនឿទុកចិត្ត និង ការរំពឹងទុកអំពីការវិនិយោគអាចប្រែប្រួលបាន (ប្រែប្រួលជាស្វ័យប្រវត្តិនៅក្នុងអនុគមន៍សញ្ញ័យ) ។ តើអ្វីជាលទ្ធផលនៃកំណើននូវជំនឿទុកចិត្ត? ប្រសិនបើយើងពិនិត្យមើលរូបភាព ៧.៤ ហើយជំនួស ($\Delta G$) ដោយ I យើងទទួលបានលទ្ធផលដូចគ្នា ពោលគឺអនុគមន៍ I+G រំកិលទៅខាងស្តាំ ហើយចំណូលត្រូវតែកើនឡើង ប្រសិនបើចង់រក្សាអត្រាការប្រាក់ ($r_0$) ឱ្យស្ថិតនៅដដែល ហើយខ្សែបន្ទាត់ IS នឹងរំកិលទៅខាងស្តាំ ស្មើនឹងកម្រិតមេគុណនៃចំណាយស្វយ័ត ($\Delta Yr_0 = \Delta I(1/1-b)$)។

**រូប ៧.៥ ការរំកិលនៃខ្សែបន្ទាត់ IS ដោយសារកំណើនពន្ធ**





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២. ចំណុចសមតា : បន្សំនៃខ្សែបន្ទាត់ IS និង LM

ខ្សែបន្ទាត់ LM ត្រូវបានបង្កើតឡើង ដើម្បីវាស់វែងចំណុចសមតានៃចំណង់ចំណូលសាច់ប្រាក់ងាយស្រួលជាមួយនឹងការផ្លាស់ប្តូរនៃអត្រាការប្រាក់ r និង ចំណូល Y ហើយខ្សែបន្ទាត់ IS វាស់វែងនូវចំណង់ចំណូលសញ្ចយ-ការវិនិយោគ ទៅតាមការផ្លាស់ប្តូរ r និង Y ។ ដូច្នេះឥឡូវនេះ យើងអាចកំណត់ក្នុងពេលជាមួយគ្នានូវចំណុចសមតានៅលើទីផ្សាររូបិយវត្ថុ និង ផលិតផល (រូបភាព ៧.៦) ។ ចំណុចប្រសព្វនៃខ្សែបន្ទាត់ទាំងពីរ ពោលគឺ ចំណុច E នៅក្នុងរូប គឺជាចំណុចសមតានៃផ្សារទាំងពីរ ។ ដូចដែលបានបង្ហាញពីមុនមកហើយ ប្រសិនបើទីផ្សាររូបិយវត្ថុស្ថិតនៅចំណុចសមតា នោះទីផ្សារសញ្ញាប័ណ្ណក៏ត្រូវតែស្ថិតក្នុងចំណុចសមតាដូចគ្នា ។ ដូច្នេះ អត្រាការប្រាក់ និង កម្រិតចំណូល នៅត្រង់ចំណុចប្រសព្វនៃខ្សែបន្ទាត់ទាំងពីរ IS និង LM ដូចដែលមានបង្ហាញនៅក្នុងរូបភាព ៧.៦ កំណត់ដោយ $r_0$ និង $Y_0$ គឺជាតម្លៃដែលបង្កើតឡើងនូវចំណុចសមតា នៅលើទីផ្សាររូបិយវត្ថុផង ទីផ្សារផលិតផលផង និងទីផ្សារសញ្ញាប័ណ្ណផង ។

**រូប ៧.៦ បន្សំនៃខ្សែបន្ទាត់ IS និង LM**






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណុចនេះ គឺជាចំណុចសមតា ដែលជាចំណុចប្រមូលផ្តុំនៃគំរូ (ដោយសន្មតថា កត្តាស្វយ័ត ឬ កត្តាផ្ទៃក្នុងជាចំនួនថេរ) ដូចបានបង្ហាញនៅក្នុងរូបភាព ៧.៧។

**រូប ៧.៧ ការសម្របសម្រួលទៅនឹងសមតានៅក្នុងគំរូ IS និង LM**



## ជំពូកទី ៨

## ការផ្គត់ផ្គង់សរុប និង តម្រូវការសរុប

### ១. ប្រព័ន្ធទ្រឹស្តីកេនស៍

ការវិភាគអំពីចំណាយសរុបរបស់ **កេនស៍** និង ខ្សែបន្ទាត់ IS/LM ត្រូវឈរលើមូលដ្ឋាននៃការសន្មតថា ថ្លៃ និង ប្រាក់ឈ្នួល ជាចំនួនថេរ ។ ជាលទ្ធផល ខ្សែបន្ទាត់នៃការផ្គត់ផ្គង់សរុប តាមលក្ខខណ្ឌទាំងនេះ គួរតែមានលក្ខណៈរាបស្មើ (រូបទី 8.1) ។ លក្ខខណ្ឌដូច្នេះឆ្លើយតបបានទៅនឹងស្ថានភាពដែលផាតុចេញជាក់ស្តែងស្ថិតនៅក្រោមសមត្ថភាពផលិតកម្មជាក់ស្តែងរបស់នៃសេដ្ឋកិច្ច ។ ហេតុដូច្នេះ រាល់កំណើននៃផាតុចេញនឹងមិនមានផលប៉ះពាល់ទៅលើប្រាក់បៀវត្ស ឬ ថ្លៃឡើយ ពោលគឺ កំណើនផាតុចេញនឹងមិនបង្កើតឱ្យមានសម្ពាធអតិផរណាឡើយ ឧទាហរណ៍ដូចក្នុងករណីនៃវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរនៃសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ ១៩២៩ ដែល **កេនស៍**បានសរសេរនៅក្នុងសៀវភៅគាត់មួយ ដែលមានចំណងជើងថា **ទ្រឹស្តីទូទៅស្តីពីអនិកម្មភាព ការប្រាក់ និង រូបិយវត្ថុ** ។

**រូប ៨.១ ខ្សែបន្ទាត់នៃការផ្គត់ផ្គង់សរុបនៅក្នុងគំរូកេនស៍និយមដែលមានថ្លៃថេរ**




តែទោះបីជាយ៉ាងណាក៏ដោយ តាមលក្ខខណ្ឌធម្មតា កំណើនផាតុចេញនឹងនាំឱ្យប្រាក់បៀវត្ស និង ថ្លៃកើនឡើង ដែលនាំឱ្យខ្សែបន្ទាត់ផ្គត់ផ្គង់រំកិលឡើងលើ ដោយមានកំណើនផាតុចេញដោយសារថ្លៃ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.១. ខ្សែកោងតម្រូវការសរុបរបស់កេនស៍

តាមទ្រឹស្តីរបស់កេនស៍ តើការប្រែប្រួលថ្លៃមានឥទ្ធិពលយ៉ាងណាខ្លះទៅលើតម្រូវការសរុប ? ចំណុចទី១ យើងអាចមើលឃើញ ហើយថាតើតម្រូវការសរុបរបស់រដ្ឋ ត្រូវបានកំណត់យ៉ាងប្រទាក់ក្រឡាគ្នា ជាមួយខ្សែបន្ទាត់ IS/LM (រូបទី 8.2)។ ប៉ុន្តែសំណួរបន្ទាប់មកទៀតនោះ គឺនៅត្រង់ថា តើបម្រែបម្រួលថ្លៃ (ΔP) មានឥទ្ធិពលប៉ះពាល់លើខ្សែកោងទាំងនេះ ឬយ៉ាងណា?

**រូប ៨.២ ការគូសខ្សែបន្ទាត់នៃតម្រូវការសរុប**




### ១.១.១. ខ្សែបន្ទាត់ *IS*

លក្ខខណ្ឌសមតាសម្រាប់ខ្សែបន្ទាត់ (IS) កើតឡើងនៅពេលដែល

(8.1) $$I(r) + G = S(Y) + T$$



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យើងដឹងថា G និង T ត្រូវបានកំណត់ជាស្វ័យប្រវត្តិដោយរដ្ឋាភិបាល ហើយសន្មតថាជាចំនួនថេរ ពោលគឺកម្រិតពិតប្រាកដរបស់វា មិនទទួលរងឥទ្ធិពលនៃបម្រែបម្រួលថ្លៃ (ΔP) នោះទេ ។ ម៉្យាងវិញទៀត គេសន្មត ថាការវិនិយោគ (I) ត្រូវកំណត់ដោយអត្រាការប្រាក់ពិត ។ ក្នុងខណៈដែល (ΔP) អាចមានឥទ្ធិពលដោយប្រយោលទៅលើ (r) វាគ្មានឥទ្ធិពលដោយផ្ទាល់ទៅលើការវិនិយោគពិតឡើយ ។ ដូចគ្នានេះដែរ ការសន្សំពិត (S) ត្រូវបានសន្មតថាអាស្រ័យទៅនឹងចំណូលពិត Y ហើយមិនទទួលឥទ្ធិពលដោយផ្ទាល់ដោយ (ΔP) ឡើយ ។ ដូច្នេះ បម្រែបម្រួលថ្លៃ (ΔP) នឹងមិនមានឥទ្ធិពលអ្វីឡើយទៅលើខ្សែបន្ទាត់ IS (រូបទី 8.2)។

### ១.១.២. ខ្សែបន្ទាត់ *LM*

**រូប ៨.៣ ផលប៉ះពាល់នៃការផ្គត់ផ្គង់រូបិយវត្ថុលើតម្រូវការសរុប**





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លក្ខខណ្ឌសមតានៃខ្សែបន្ទាត់ (LM) កើតឡើងនៅពេលដែល ÷

(8.2) M/P = L(Y, r)

ដូច្នេះការផ្គត់ផ្គង់រូបិយវត្ថុពិតស្មើនឹងតម្រូវការរូបិយវត្ថុ ពោលគឺ ***តម្រូវការសមតុល្យរូបិយវត្ថុពិត*** ។ ក៏ប៉ុន្តែ (M) តំណាងឱ្យបរិមាណថេរនៃរូបិយវត្ថុ ដែលបានកំណត់ឡើងជាស្វ័យប្រវត្តិដោយធនាគារកណ្តាល ។ បើឧបមាថា គេហកិច្ចចង់រក្សានូវសមតុល្យរូបិយវត្ថុពិតក្នុងចំនួនដ៏សមស្រប នោះ (ΔP) នឹងមានឥទ្ធិពលលើការផ្គត់ផ្គង់រូបិយវត្ថុពិត និង ចំណុចសមតានៃទីផ្សាររូបិយវត្ថុ (រូបទី 8.2a) ។ ឧបមាថា ការផ្គត់ផ្គង់រូបិយវត្ថុមានតាមថ្លៃទីផ្សារត្រូវបាន កំណត់នៅត្រង់ ($M_0$) ហើយ $P_2 > P_1 > P_0$ នោះ នៅពេលដែលកម្រិតថ្លៃកើនឡើង ខ្សែបន្ទាត់ (LM) នឹងរំកិលទៅខាងឆ្វេង ។ តាមរយៈរូបភាព 8.2a យើងអាចគណនាកម្រិតប្រែប្រួលនៃ (Y) ដោយមាន (ΔP) ហើយតាមរយៈព័ត៌មាននេះ យើងអាចគណនារកខ្សែបន្ទាត់តម្រូវការសរុប (ADC-រូបទី 8.2b) ដែលកំណត់នូវកម្រិតធាតុចេញនៅគ្រប់កម្រិតនៃថ្លៃ ។ គួរកត់សម្គាល់ថា P គឺជា «***កម្រិតថ្លៃសរុប***» ហើយមិនមែនជាថ្លៃទំនិញ ឬ សេវាទីមួយៗឡើយ។ ដូច្នេះ ខ្សែបន្ទាត់តម្រូវការសរុប (ADC) ទទួលរងឥទ្ធិពលនៃកត្តារូបិយវត្ថុ តាមរយៈខ្សែបន្ទាត់ (LM) ក៏ដូចជាបម្រែបម្រួលនៃកត្តាពិត តាមរយៈខ្សែបន្ទាត់ (IS) ពោលគឺ ចំណាយរដ្ឋាភិបាលពិត (G) ពន្ធពិត (T) ការវិនិយោគពិត (I) និង សញ្ចយពិត (S) ។ កត្តាទាំងឡាយដែលនាំឱ្យកម្រិតសមតានៃ (Y) កើនឡើង នៅក្នុងគំរូ IS/LM នឹងបណ្តាលឱ្យខ្សែកោងតម្រូវការសរុប (ADC) រំកិលទៅខាងស្តាំ ។ ហើយផ្ទុយទៅវិញ កត្តាទាំងឡាយដែលធ្វើអោយសមតានៃចំណូល (Y) ធ្លាក់ចុះ នឹងរំកិលខ្សែបន្ទាត់តម្រូវការសរុប (ADC) ទៅខាងឆ្វេង ។

ប្រសិនបើយើងពិនិត្យមើលកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុពី ($M_0$) ទៅ ($M_1$) (រូប 8.3a) ។ កំណើននេះធ្វើឱ្យខ្សែបន្ទាត់ LM រំកិលទៅខាងស្តាំ ពោលគឺចេញពីចំណុចសមតា A ទៅកាន់ B ។ អត្រាការប្រាក់ធ្លាក់ចុះ ហើយ ចំណូល (Y) កើនឡើងពី ($Y_0$) ទៅ ($Y_1$) ។ ឧបមាថា កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ (M) និង ចំណូល (Y) មានតុល្យភាព និងមិនមានការប្រែប្រួលថ្លៃ (P) ទេ ។ ជាលទ្ធផល នឹងមានការរំកិលខ្សែបន្ទាត់តម្រូវការសរុប (ADC) (រូប 8.3b) ហើយចំណូល (Y) កើនឡើងពី ($Y_0$) ទៅ ($Y_1$) ដោយមិនមានការប្រែប្រួលថ្លៃ (P) ។ គួរកត់សម្គាល់ថា ជាមួយនឹងសម្មតិកម្មទាំងនេះ ចលនារបស់ខ្សែបន្ទាត់ (ADC) នៅតាមចំណុចដែលមានកម្រិតថ្លៃដូចគ្នា នឹងនាំឱ្យមានកំណើននៃចំណូល ដែលត្រូវគ្នាទៅនឹងចលនានៃចំណុចសមតារបស់ខ្សែបន្ទាត់ (IS/LM) ពោលគឺ វាមិនទទួលផលប៉ះពាល់ពីមេគុណនោះទេ ។

### ១.២. បន្តំខ្សែបន្ទាត់ (ADC) របស់កេនស៍ជាមួយនឹងខ្សែបន្ទាត់ផ្គត់ផ្គង់សរុបតាមទ្រឹស្តីបុរាណនិយម

ប្រសិនបើថ្លៃ និងប្រាក់បៀវត្សមិនមែនជាចំនួនថេរទេនោះ ផលប៉ះពាល់នៃបន្លាស់ប្តូរគោលនយោបាយនឹងអាស្រ័យទៅនឹងសម្មតិកម្មអំពីការផ្គត់ផ្គង់សរុប ។ យើងពិនិត្យមើលករណីនៃកំណើន (G) នៅក្នុងរូបភាព ៨.៤ ។ ខ្សែបន្ទាត់ (ADC) នឹងរំកិលទៅខាងស្តាំ ពី ($Y^d_0$) ទៅ ($Y^d_1$) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រសិនបើខ្សែបន្ទាត់នៃការផ្គត់ផ្គង់សរុប (ASC) ផ្ទៀងផ្ទាត់ទៅនឹងគំរូបុរាណនិយម នោះវានឹងមានភាពមិនរួញយឺតពេញលេញចំពោះ $\Delta P(Y^s_0)$ ។ ផលប៉ះពាល់នៃ $\Delta G$ នាំឱ្យមានកំណើនថ្លៃ ដោយមិនមានឥទ្ធិពលអ្វីទៅលើ (Y) ទេ ។ ប្រសិនបើខ្សែបន្ទាត់ផ្គត់ផ្គង់សរុប (ASC) មានមេគុណប្រាប់ទិសកើនឡើង ($Y^s_1$ ក្នុងលក្ខខណ្ឌសេដ្ឋកិច្ចធម្មតា) នោះបម្រែបម្រួលចំណាយរដ្ឋាភិបាល ($\Delta G$) នឹងនាំឱ្យមានកំណើន (Y) ប៉ុន្តែមានទំហំតូចជាង $\Delta G$ ($Y_0$ ទៅ $Y_2$) ដែលឥទ្ធិពលខ្លះត្រូវបានស្រូបដោយកំណើនថ្លៃ ។ ប្រសិនបើថ្លៃ និង ប្រាក់បៀវត្សជាចំនួនថេរ នោះខ្សែបន្ទាត់ (ASC) នឹងមានរាងផ្តេកស្របទៅនឹងអ័ក្សអាស៊ីស ($Y^s_2$ ក្នុងលក្ខខណ្ឌសេដ្ឋកិច្ចដែលមានការធ្លាក់ចុះធ្ងន់ធ្ងរ) ហើយ $\Delta G$ នឹងនាំឱ្យមានការកើនឡើងជាសមមូលនៃចំណូល (Y) ពី $Y_0$ ទៅ $Y_2$។ ដូច្នេះ មិនមានការផ្លាស់ប្តូរថ្លៃទេ ។

**រូប ៨.៤ តួនាទីរបស់ការផ្គត់ផ្គង់សរុបក្នុងការកំណត់ធាតុចេញដើម្បីឆ្លើយតបទៅនឹងបន្លាស់ប្តូរគោលនយោបាយ**





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២. ខ្សែកោងផ្គត់ផ្គង់សរុបតាមទ្រឹស្តីកេនស៍

ខ្សែកោងផ្គត់ផ្គង់សរុប តាមគំរូរបស់ **កេនស៍** គឺផ្អែកលើសម្មតិកម្ម ដែលមូលធន និង បច្ចេកវិទ្យាជាចំនួនថេរ ហើយកម្លាំងពលកម្មប្រែប្រួល ដែលឆ្លុះបញ្ចាំងនៅក្នុងអនុគមន៍ផលិតកម្ម (រូបទី 8.5b) ដូចនៅក្នុងគំរូបូរាណនិយមដែរ ។

**រូប ៨.៥ ខ្សែកោងសរុបកេនស៍និយម នៅពេលដែលបៀវត្សថេរ**




### ២.១. ខ្សែបន្ទាត់តម្រូវការពលកម្ម

តាមអនុគមន៍ផលិតកម្ម សហគ្រាសជួលកម្លាំងពលកម្មរហូតដល់ចំណុចមួយ ដែលថ្លៃបៀវត្សពិតស្មើនឹងផលិតផលបន្ថែមនៃកម្លាំងពលកម្ម (Marginal product of labor)(W/P = MPN) ឬ

(8.1) W = MPN x P ពោលគឺប្រាក់បៀវត្សស្មើនឹងតម្លៃជារូបិយវត្ថុនៃ MPN ។

តាមរយៈការបន្ថែមខ្សែកោងតម្រូវការកម្លាំងពលកម្មតាមទិសដេក សម្រាប់សហគ្រាសនីមួយៗ នៅគ្រប់កម្រិតប្រាក់បៀវត្សពិត នោះខ្សែកោងតម្រូវការកម្លាំងពលកម្ម សម្រាប់សេដ្ឋកិច្ចទាំងមូលមួយ ត្រូវបានបង្កើតឡើង ។

## ២.២. ការផ្គត់ផ្គង់កម្លាំងពលកម្ម

ខ្សែកោងនៃការផ្គត់ផ្គង់កម្លាំងពលកម្មនៅក្នុងគំរូរបស់**កេនស៍** មិនមែនឈរលើមូលដ្ឋាននៃសម្មតិកម្ម ដែលថាកម្លាំងពលកម្មត្រូវប្រឈមនឹងការផាត់ទាត់ រវាងការនៅទំនេរ និង ប្រាក់បៀវត្សពិត ដូចក្នុងគំរូបុរាណនិយមឡើយ។ ផ្ទុយទៅវិញ ការផ្គត់ផ្គង់កម្លាំងពលកម្មឈរលើមូលដ្ឋាននៃប្រាក់បៀវត្សជារូបិយវត្ថុ ដោយមានព័ត៌មានមិនពេញលេញ អំពីកម្រិតថ្លៃ ។

## ២.៣. ចំណុចសមតានៃតម្រូវការ និង ការផ្គត់ផ្គង់កម្លាំងពលកម្ម

នៅក្នុងគំរូបុរាណនិយម ចំណុចសមតានៃការផ្គត់ផ្គង់ និង តម្រូវការកម្លាំងពលកម្ម ត្រូវបានធានាដោយសម្មតិកម្មដែលថា ប្រាក់បៀវត្សជារូបិយវត្ថុ និង ថ្លៃមានភាពទន់ភ្លន់ពេញលេញ ។ ក៏ប៉ុន្តែ **កេនស៍** យល់ឃើញថាប្រាក់បៀវត្សជារូបិយវត្ថុ មិនមានភាពទន់ភ្លន់ពេញលេញនោះទេ ហើយតាមពិត វាមានលក្ខណៈរឹងកំព្រឹស ក្នុងរូបភាពបីយ៉ាង ដែលបណ្តាលមកពីប្រាក់បៀវត្ស គឺជាលទ្ធផលនៃការចរចាររវាងសហជីព និង ក្រុមហ៊ុន ។

**រូប ៨.៦ និកម្មភាព ដែលមានបៀវត្សថេរ**





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ទីមួយ–** ការចរចារប្រាក់បៀវត្សផ្តោតមិនត្រឹមតែទៅលើអត្រាប្រាក់បៀវត្សប៉ុណ្ណោះទេ ប៉ុន្តែថែមកម្រិតផ្សេងគ្នានៃប្រាក់បៀវត្សរបស់កម្មករប្រភេទផ្សេងៗគ្នាផងដែរ ពោលគឺ មិនមែនកម្មកររួមដូចៗគ្នាទេ តែជាកម្មករច្រើនបែប និងច្រើនប្រភេទ ។ កម្មករមួយក្រុមប្រឆាំងនឹងការកាត់បន្ថយប្រាក់បៀវត្ស ដែលមិនត្រឹមតែជាបញ្ហាហិរញ្ញវត្ថុប៉ុណ្ណោះទេ ក៏ប៉ុន្តែ គឺដោយសារឋានៈរបស់ពួកគេ ដោយប្រៀបធៀបទៅនឹងកម្មករដទៃទៀត ។ ដូចគ្នានេះដែរ យើងក៏ឃើញមានប្រាក់បៀវត្សខុសគ្នារវាងមន្ត្រីនគរបាល និង មន្ត្រីពន្លត់អគ្គីភ័យ ។ គម្លាតប្រាក់បៀវត្សឆ្លុះបញ្ចាំងពីតម្លៃប្រៀបធៀបរបស់ក្រុមកម្មករនីមួយៗ ។ ដូច្នេះ កិច្ចប្រឹងប្រែងទាំងឡាយដែលធ្វើឱ្យមានការផ្លាស់ប្តូរតុល្យភាពនេះ តែងតែត្រូវបានគេប្រឆាំងជានិច្ច ។

**ទីពីរ–** សហជីពកម្មករចរចារកិច្ចសន្យាសម្រាប់រយៈពេលវេលាជាក់លាក់ណាមួយ ឧទាហរណ៍ ២ ឬ ៣ ឆ្នាំ ។ ក្នុងកំឡុងពេលនេះ ប្រាក់បៀវត្សជារូបិយវត្ថុ មិនអាចផ្លាស់ប្តូរដោយសហគ្រាសបានឡើយ ។

**ទីបី–** ទោះបីជាគ្មានកិច្ចសន្យាផ្លូវការរវាងសហជីពកម្មករជាមួយសហគ្រាសក៏ដោយ ក៏មាននិន្នាការដើម្បីកំណត់ប្រាក់បៀវត្សជារូបិយវត្ថុនៅក្នុងរយៈពេលជាក់លាក់មួយ ។

ដូច្នេះ បើយើងពិចារណារួមគ្នាមក កត្តាទាំងបីធ្វើឱ្យប្រាក់បៀវត្សរូបិយវត្ថុ មានលក្ខណៈ «រឹងកំព្រឹស» ដោយមិនមានភាពទន់ភ្លន់ពេញលេញ ដូចដែលគេសន្មតិនៅក្នុងគំរូបូរាណនិយមនោះទេ ។ នៅក្នុងករណីជ្រុលបំផុត ភាព «រឹងកំព្រឹស» នេះ បានក្លាយទៅជាប្រាក់បៀវត្សរូបិវត្ថុថេរ ហើយចំណុចសមតាមិនអាចកើតមានបានឡើយ (រូប 8.6) ។ ដោយសារប្រាក់បៀវត្សថេរនេះ កម្រិតពិតប្រាកដនៃនិកម្មភាពត្រូវកំណត់ឡើងដោយសារតែតម្រូវការកម្លាំងពលកម្មតែប៉ុណ្ណោះ ។ ប្រការនេះមានន័យថា ប្រាក់បៀវត្សរូបិយវត្ថុមិនបានកែតម្រូវ ដើម្បីធានាបាននូវនិកម្មភាពពេលលេញ។ ផ្ទុយទៅវិញ អាចមានចំណុចអសមតា ដែលធ្វើអោយចំនួនកម្លាំងពលកម្មដែលត្រូវការ នៅក្នុងលក្ខខណ្ឌនៃប្រាក់បៀវត្សរូបិយវត្ថុថេរ ដែលតិចជាងអ្វីដែលពលករចង់ផ្គត់ផ្គង់កម្លាំងពលកម្ម ។

## ២.៤. ខ្សែកោងផ្គត់ផ្គង់សរុប

ប្រសិនបើអត្រាប្រាក់បៀវត្សថេរ (ឬ «រឹងកំព្រឹស») ប៉ុន្តែថ្លៃមានលក្ខណៈទន់ភ្លន់ នោះសហគ្រាសនឹងផ្លាស់ប្តូរចំនួនកម្លាំងពលកម្ម ដែលគេជួលអោយមកធ្វើការ ដោយឈរលើមូលដ្ឋាននៃថ្លៃដែលគេទទួលបានចំពោះផាតុចេញរបស់គេ ដោយជានិច្ចកាលតែងតែធានាថា W/P = MPN ។ ដូច្នេះ ប្រសិនបើថ្លៃកើនឡើង (និងប្រាក់បៀវត្សជារូបិយវត្ថុនៅដដែល) ក្រុមហ៊ុននឹងជួលកម្មករបន្ថែមទៀតជាមិនខាន (រូប 8.5a) ។

ដូច្នេះនៅរាល់ចំណុចផ្សេងៗគ្នានៃថ្លៃ (P) ផាតុចេញនឹងប្រែប្រួល ហើយខ្សែកោងផ្គត់ផ្គង់របស់សហគ្រាសអាចគណនាបាន ។ ដោយផ្អែកលើព័ត៌មានអំពីថ្លៃដែលមាននៅក្នុងរូបភាព (រូប 8.5a) និងព័ត៌មានផាតុចេញដែលមាននៅក្នុងរូបភាព (រូប 8.5b) នោះខ្សែកោងផ្គត់ផ្គង់របស់សហគ្រាសអាចត្រូវបានគណនា ដូចដែលបង្ហាញនៅក្នុងរូបភាព (រូប 8.5c) ។ ផលបូកតាមទិសដេកនៃខ្សែកោងផ្គត់ផ្គង់សម្រាប់សហគ្រាសនីមួយៗ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅគ្រប់កម្រិតថ្លៃ បង្កើតបានជាខ្សែកោងផ្គត់ផ្គង់សរុបសម្រាប់សេដ្ឋកិច្ចទាំងមូល ។ ដោយខុសពីខ្សែកោងផ្គត់ផ្គង់សរុបតាមទិសឈរនៃគំរូបុរាណនិយម នោះទេលទ្ធផលនៅពេលនេះ គឺជាខ្សែកោងដែលមានមេគុណប្រាប់ទិសកើនឡើង ដែលបង្ហាញថា ប្រសិនបើថ្លៃកើនឡើង ផលិតផលចេញនឹងកើនឡើង ។

## ២.៤.១. ផលប៉ះពាល់នៃបម្រែបម្រួលការផ្គត់ផ្គង់រូបិយវត្ថុ និង ចំណាយរដ្ឋាភិបាល

**រូប ៨.៧ ផលប៉ះពាល់នៃកំណើនការផ្គត់ផ្គង់រូបិយវត្ថុ នៅពេលដែលថ្លៃអថេរ**




ដូចដែលយើងបានឃើញហើយថា កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុនឹងរំកិលខ្សែកោង (LM) ពីចំណុចសមតាត្រង់ A តាមទិសចុះ ទៅខាងស្តាំរហូតដល់ចំណុចសមតាថ្មី B (រូបទី 8.7)។ ប្រសិនបើថ្លៃថេរ លទ្ធផលគឺជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណើននៃធាតុចេញពី $Y_0$ ទៅ $Y'_1$ ។ ប៉ុន្តែ បើធាតុចេញកើនឡើង (ចលនាស្របទៅនឹងខ្សែកោងផ្គត់ផ្គង់សរុប) កម្រិតថ្លៃនឹងកើនឡើង ។ ផលប៉ះពាល់នៃកំណើនថ្លៃ គឺការកាត់បន្ថយការផ្គត់ផ្គង់រូបិយវត្ថុពិត ដែលរំកិលខ្សែកោង (LM) ថយក្រោយពីចំណុចសមតា B ឡើងលើទៅ C ហើយធាតុចេញនឹងធ្លាក់ចុះពី $Y'_1$ ទៅ $Y_1$ ។

**រូប ៨.៨ ផលប៉ះពាល់នៃកំណើនចំណាយរដ្ឋាភិបាល នៅពេលដែលថ្លៃអថេរ**




កំណើនចំណាយរដ្ឋាភិបាល មានផលប៉ះពាល់ស្រដៀងគ្នាទៅនឹងករណីមុនៗដែរ (រូប 8.8) ។ កំណើនចំណាយរដ្ឋាភិបាល (G) នឹងធ្វើឱ្យខ្សែកោង IS រំកិលឡើងលើ និង ទៅទិសខាងស្តាំ ដោយចេញពីចំណុចសមតា A ទៅ B ។ ប្រសិនបើថ្លៃថេរ នោះធាតុចេញនឹងកើនពី $Y_0$ ទៅ $Y'_1$ ។ ក៏ប៉ុន្តែ ប្រសិនបើថ្លៃប្រែប្រួល នោះកំណើននៃធាតុចេញនឹងនាំអោយថ្លៃកើនឡើងដែរ ដែលនឹងកាត់បន្ថយការផ្គត់ផ្គង់រូបិយវត្ថុពិត ដែលរំកិលខ្សែកោង (LM) ឡើងទៅខាងឆ្វេង ពីចំណុចសមតា B ឆ្ពោះទៅចំណុចសមតាថ្មី C ។ ទន្ទឹមនឹងនេះ ធាតុចេញនឹងធ្លាក់ចុះត្រឡប់ពី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

$Y'_1$ ទៅ $Y_1$ វិញ ។

### ២.៤.២. ទ្រឹស្តីបុរាណនិយម និង កេនស៍និយមអំពីការផ្គត់ផ្គង់កម្លាំងពលកម្ម

គំរូបុរាណនិយមសន្និដ្ឋានថា ការផាត់ទាត់រវាងពលកម្ម និង ការលំហែកម្សាន្ត កម្លាំងពលកម្មធ្វើការសម្រេចចិត្តដោយផ្អែកទៅលើប្រាក់បៀវត្សពិត ។ ដូច្នេះ កំណើននៃប្រាក់បៀវត្សពិតបាននាំឱ្យមានកំណើននៃការផ្គត់ផ្គង់កម្លាំងពលកម្ម ។ ម្យ៉ាងវិញទៀត គំរូរបស់កេនស៍បានសន្មតថា កម្លាំងពលកម្មធ្វើសេចក្តីសម្រេចចិត្តរវាងការងារ និង ការលំហែកម្សាន្ត ដោយឈរលើមូលដ្ឋាននៃប្រាក់បៀវត្សជារូបិយវត្ថុ ។ គឺនៅត្រង់ចំណុចនេះហើយដែល **កេនស៍** បានលើកឡើងនូវគំនិតផ្ទាល់ខ្លួនរបស់គាត់ស្តីពី *ចំណេះដឹងមិនសុក្រឹត* ។ ដូច្នេះ នៅពេលដែលពលករអាចដឹងច្បាស់តាមរយៈការចរចារ នូវប្រាក់បៀវត្សរ៍ជារូបិយវត្ថុ គេមិនអាចដឹងពីកម្រិតថ្លៃសរុបបានឡើយ ។ ម៉្យាងវិញទៀត កម្លាំងពលកម្មត្រូវពឹងផ្អែកលើការរំពឹងទុកស្តីពីកម្រិតថ្លៃសរុប ដោយឈរលើបទពិសោធន៍កន្លងមក ។

អនុគមន៍ផ្គត់ផ្គង់កម្លាំងពលកម្មរបស់ **កេនស៍** មានដូចខាងក្រោម ÷

(8.4) $$N^s = t(W/P^e)$$

ដែល W គឺប្រាក់ជាបៀវត្សរូបិយវត្ថុ និង $P^e$ គឺជាកម្រិតថ្លៃដែលគេរំពឹងទុក ។

ជាការពិត ប្រការនេះមានន័យថា ការផ្គត់ផ្គង់កម្លាំងពលកម្មអាស្រ័យនឹងប្រាក់បៀវត្សពិត ។ ក៏ប៉ុន្តែប្រាក់បៀវត្ស គឺជាប្រាក់បៀវត្សជារូបិយវត្ថុចែកនឹងកម្រិតថ្លៃដែលគេរំពឹងទុក ។ ដូចដែលបានលើកឡើងខាងលើ ជាទូទៅកម្លាំងពលកម្មធ្វើការរំពឹងទុកនៃកម្រិតថ្លៃរបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃបទពិសោធន៍ពីអតីតកាល ដែលអាចបង្ហាញតាមរូបមន្តដូចខាងក្រោម ÷

(8.5) $$P^e = a_1P_{-1} + a_2P_{-2} + a_3P_{-3}\ldots\ a_nP_{-n}$$

ដែល $P_{-i}$ តំណាងឱ្យរយៈពេលពីអតីតកាល ហើយ $a_i$ គឺជាទម្ងន់ភ្ជាប់ជាមួយរយៈពេលនីមួយៗ ។

ប្រការនេះសន្មតថា ព័ត៌មានជាក់លាក់អំពីកម្រិតថ្លៃពីអតីកាល អាចទទួលបានតាមតម្លៃសមរម្យ ហើយតាមរយៈនេះ វាអាចបង្ហាញបានដោយងាយតាមសមីការ ៨.៥ ។ យើងក៏សន្មតផងដែរ នូវឥរិយាបទសម្លឹងថយដើម្បីព្យាករណ៍អនាគត។ ម៉្យាងវិញទៀត **កេនស៍** បានសន្មតថា ការកែតម្រូវនៅក្នុងការរំពឹងទុកអាចផ្លាស់ប្តូរដោយយឺតៗ ទៅតាមឥរិយាបទថ្លៃនៅក្នុងពេលអតីតកាល ។ ដូច្នេះ ការរំពឹងទុកមិនផ្លាស់ប្តូរភ្លាមៗនោះទេ ទៅតាមលក្ខខណ្ឌសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ក៏ប៉ុន្តែវាអាចកើតមានឡើងសន្សឹមៗនៅពេលដែលបច្ចុប្បន្នចាប់ផ្តើមរំកិលទៅរកអតីតកាល ។

### ២.៤.៣. ខ្សែកោងនៃការផ្គត់ផ្គង់សរុបរបស់កេនស៍ ដោយប្រើប្រាក់បៀវត្សរូបិយវត្ថុអថេរ

ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មប្រែប្រួលជាមួយនឹងប្រាក់បៀវត្សជារូបិយវត្ថុ ដោយសន្មតិអំពីការរំពឹងទុកមានលក្ខណៈថេរនៃកម្រិតថ្លៃសរុប (រូប 8.9a) ។

**រូប ៨.៩ ខ្សែកោងការផ្គត់ផ្គង់សរុបកេនស៍និយម នៅពេលដែលប្រាក់បៀវត្សអថេរ**




ទោះបីជាយ៉ាងណាក៏ដោយ សហគ្រាសទាំងឡាយត្រូវការកម្លាំងពលកម្ម ដោយឈរលើមូលដ្ឋាននៃប្រាក់បៀវត្សពិត ដែលជាអនុគមន៍នៃ***ផលិតភាពបន្ថែមរបស់កម្លាំងពលកម្ម*** (MPN) ប្រាក់បៀវត្សជារូបិយវត្ថុ និងកម្រិតថ្លៃ ។ ឧបមាថា សហគ្រាសដឹងយ៉ាងច្បាស់ពីកម្រិតថ្លៃ ដែលគេអាចលក់ធាតុចេញរបស់គេ ។ ក្នុងន័យនេះ ខ្សែកោងតម្រូវការកម្លាំងពលកម្មនឹងរំកិលទៅខាងស្តាំ នៅពេលដែលថ្លៃកើនឡើង ។ ក៏ប៉ុន្តែខ្សែកោងនៃការផ្គត់ផ្គង់កម្លាំងពលកម្មពឹងផ្អែកទៅលើកម្រិតថ្លៃដែលគេរំពឹងទុកថាមានលក្ខណៈថេរ (ក្នុងរយៈពេលខ្លី) ។ នៅពេលដែលកម្រិតថ្លៃកើនឡើង សហគ្រាសនឹងបង្កើនធាតុចេញរបស់គេ ដោយត្រូវជួលកម្លាំងពលកម្មបន្ថែមទៀត ។ ក៏ប៉ុន្តែ

គេអាចធ្វើដូច្នេះទៅបាន ទាល់តែគេបង្កើនប្រាក់បៀវត្សជារូបិយវត្ថុ ។ នៅពេលដែលអនិកម្មភាពកើនឡើង នោះផាតុចេញនឹងកើនឡើងដែរ (រូប 8.9b)។ ដោយផ្អែកលើព័ត៌មាននៅក្នុងរូបភាព 8.9a និង 8.9b នោះគេអាចគណនាខ្សែកោងផ្គត់ផ្គង់សរុបដោយត្រូវបាន (រូប 8.9c)។ ជាមួយនឹងសម្មតិកម្មដូចខាងលើ ទោះបីជាប្រាក់បៀវត្សរូបិយវត្ថុនឹងមានលក្ខណៈទន់ភ្លន់ក៏ដោយ ក៏ខ្សែកោងផ្គត់ផ្គង់សរុបមានមេគុណប្រាប់ទិសកើនឡើង តែមិនមែនឈរត្រង់ដូចនៅក្នុងគំរូបូរាណនិយមនោះទេ ។

## ២.៤.៤. ផលប៉ះពាល់គោលនយោបាយនៃប្រាក់បៀវត្សរូបិយវត្ថុអថេរ

ដោយខ្សែកោងផ្គត់ផ្គង់សរុបមានមេគុណប្រាប់ទិសកើនឡើង ការប្រែប្រួលនៃខ្សែកោងតម្រូវការសរុបនឹងមានឥទ្ធិពលទៅលើផាតុចេញ (ដោយខុសពីខ្សែកោងផ្គត់ផ្គង់សរុប (ASC) ដែលមានរាងឈរត្រង់ នៅក្នុងគំរូបូរាណនិយម) ដែលបម្រែបម្រួលនៃតម្រូវការនឹងនាំឱ្យថ្លៃកើនឡើង ។ ក៏ប៉ុន្តែប្រសិនបើយើងប្រៀបធៀបស្ថានភាពដែលថ្លៃរូបិយវត្ថុនៅថេរ ជាមួយនឹងថ្លៃអថេរ ASC មិនរួញយឺតខ្លាំងក្នុងករណីអថេរ (រូបភាព 8.10)។

**រូប ៨.១០ ខ្សែកោងការផ្គត់ផ្គង់សរុបកេនស៍និយម នៅពេលដែលប្រាក់បៀវត្សថេរ និង អថេរ**






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រសិនបើប្រាក់បៀវត្សជារូបិយវត្ថុមានលក្ខណៈថេរ នោះនៅពេលថ្លៃកើនឡើង នឹងធ្វើផាតុចេញកើនឡើង ពី $Y_0$ ទៅ $Y_1$ (រូបភាព 8.10c)។ ប្រាក់បៀវត្សជារូបិយវត្ថុថេរឆ្លើយតបទៅនឹងអតិរេកនៃកម្លាំងពលកម្ម ពោលគឺនៅពេលដែលមានវិបត្តិសេដ្ឋកិច្ច ដូចជាវិបត្តិសេដ្ឋកិច្ចនៅក្នុងអំឡុងឆ្នាំ ១៩៣០ ជាដើម ។ កត្តាតែមួយគត់ដែលមានឥទ្ធិពលទៅលើកំណើននៃផាតុចេញ គឺការធ្លាក់ចុះនៃ MPN ដោយសារការថយចុះប្រាក់ចំណូលបន្ថែម ដែលដាក់កំហិតលើកំណើននៃអនិកម្មភាព ។

ប្រសិនបើប្រាក់បៀវត្សប្រែប្រួល (ដោយផ្ទៀងផ្ទាត់ជាមួយនិកម្មភាពពេញលេញ និងកម្រិតប្រាក់បៀវត្សបច្ចុប្បន្ន) នោះកំណើនថ្លៃធ្វើឱ្យមានកំណើនផាតុចេញ ដែលនឹងត្រូវទាមទារនូវកម្លាំងពលកម្មបន្ថែម ដែលចាំបាច់ត្រូវមានប្រាក់បៀវត្សកាន់តែខ្ពស់ ។ ប្រការនេះមានន័យថា ថ្លៃដើមរបស់សហគ្រាសសម្រាប់ទូទាត់កម្លាំងពលកម្មកើនឡើងនៅពេលដែលផាតុចេញកើនឡើង ។ ប្រាក់បៀវត្សជារូបិយវត្ថុកាន់តែខ្ពស់ជាកំហិតក្នុងការប្រើប្រាស់កម្លាំងពលកម្មបន្ថែមសម្រាប់ការឡើងថ្លៃ ។ ជាការពិត ខ្សែកោងផ្គត់ផ្គង់សរុប ASC ក្នុងករណីប្រាក់បៀវត្សប្រែប្រួលមានចំណោតខ្លាំងជាង និងមានភាពមិនរួញយឺតខ្លាំងជាង បើប្រៀបធៀបជាមួយប្រាក់បៀវត្សថេរ ហើយកំណើនផាតុចេញ $Y'_1$ មានកម្រិតទាបជាង $Y_1$ (រូបភាព 8.10c)។

នៅក្នុងគំរូបុរាណនិយម ខ្សែកោង ASC ត្រង់ឈរ ឆ្លុះបញ្ចាំងនូវសម្មតិកម្មដែលថា ផាតុចេញកំណត់ដោយការផ្គត់ផ្គង់តែមួយគត់ ។ បម្រែបម្រួលនៃខ្សែកោង ADC មិនបានធ្វើអោយផាតុចេញកើនឡើងទេ ប៉ុន្តែធ្វើអោយថ្លៃកើនឡើង ដែលនឹងនាំអោយមានកំណើននៃប្រាក់បៀវត្ស ។ ទន្ទឹមនឹងនេះ បម្រែបម្រួលគោលនយោបាយដូចជាកំណើនចំណាយរដ្ឋាភិបាល ឬ ការផ្គត់ផ្គង់រូបិយវត្ថុគ្មានឥទ្ធិពលអ្វីទៅលើផាតុចេញ ឬ អនិកម្មភាពឡើយ ។

ផ្ទុយទៅវិញ នៅក្នុងគំរូរបស់ **កេនស៍** ដែលមានប្រាក់បៀវត្សថេរ និង បម្រែបម្រួលថ្លៃ បន្លាស់ប្តូរគោល-នយោបាយធ្វើឱ្យខ្សែកោង ADC រំកិល (ឬមួយតាមរយៈសារខ្សែកោង IS ដោយសារចំណាយរដ្ឋាភិបាល ឬមួយតាមរយៈខ្សែកោង LM ដោយសារបម្រែបម្រួលការផ្គត់ផ្គង់រូបិយវត្ថុ) ។ ផលប៉ះពាល់នៃបន្លាស់ប្តូរគោលនយោបាយប្រព្រឹត្តទៅដោយពេញលេញតាមរយៈឥទ្ធិពលនៃមេគុណគោលនយោបាយ ពោលគឺកំណើនថ្លៃនឹងមិនមានឥទ្ធិពលអ្វីឡើយ ដោយឈរលើមូលដ្ឋាននៃសម្មតិកម្មថា ខ្សែកោង ASC ផ្តេក ហើយមិនបង្កើតជាឧបស័គ្គដល់បន្លាស់ប្តូរគោលនយោបាយឡើយ ។ ស្ថានភាពនេះឆ្លើយតបទៅនឹងការធ្លាក់ចុះធ្ងន់ធ្ងរនៃសេដ្ឋកិច្ច ដែលមានធនធានមិនប្រើប្រាស់យ៉ាងច្រើន ។ ទោះបីជាផាតុចេញកើនឡើង ក៏មិនធ្វើអោយថ្លៃ ឬ ប្រាក់បៀវត្ស រូបិយវត្ថុកើនឡើងដែរ ។

នៅក្នុងគំរូរបស់**កេនស៍** ដែលមានប្រាក់បៀវត្សថេរ តែថ្លៃប្រែប្រួល ដែលប្រហាក់ប្រហែលនឹងលក្ខខណ្ឌសេដ្ឋកិច្ចធម្មតា នោះកំណើនផាតុចេញត្រូវបានកំហិតដោយការថយចុះនៃផលិតផលបន្ថែមរបស់កម្លាំងពលកម្ម ពោលគឺ ដោយមូលធន និង បច្ចេកវិទ្យានៅថេរ ការបន្ថែមនូវកម្លាំងពលកម្មក្នុងឯកតាច្រើនទៀតនឹងនាំឱ្យផាតុចេញកើនឡើងកាន់តែតិចទៅៗ សម្រាប់រាល់ឯកតាបន្ថែមនៃកម្លាំងពលកម្ម ។ ដូច្នេះសហគ្រាសជួលកម្លាំងពលកម្មដល់ត្រឹមតែចំណុចដែលប្រាក់បៀវត្សពិតស្មើនឹង MPN នឹងបង្កើនអនិកម្មភាព ប្រសិនបើថ្លៃកើនឡើងប៉ុណ្ណោះ ពោលគឺ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅពេលដែលប្រាក់ចំណេញកើនឡើង ។ ដូច្នេះលទ្ធផល គឺខ្សែកោង ASC មានមេគុណប្រាប់ទិសកើនឡើង ដោយសារសហគ្រាសនឹងបង្កើនកម្លាំងពលកម្ម និងផាគុចេញនៅក្នុងករណីដែលថ្លៃកើនឡើងប៉ុណ្ណោះ ។

នៅក្នុងគំរូរបស់**កេនស៍** ដែលមានថ្លៃ និង ប្រាក់បៀវត្សប្រែប្រួល សហគ្រាសនឹងបង្កើនផាគុចេញ ប្រសិនបើថ្លៃកើនឡើង ។ ក៏ប៉ុន្តែការឆ្លើយតបរបស់សហគ្រាសចំពោះការកើនឡើងថ្លៃអាចមានកំហិតដោយសារតែការថយចុះនៃមេគុណផលិតកម្ម និង តម្រូវការកំណើនប្រាក់បៀវត្ស ដើម្បីទាក់ទាញកម្លាំងពលកម្មបន្ថែម ។ ដូច្នេះ ខ្សែកោង ASC មានមេគុណប្រាប់ទិសកើនឡើងដូចករណីមុនៗដែរ ប៉ុន្តែមានចំណោតខ្លាំងជាង ដោយសារតែនៅពេលដែលថ្លៃកើនឡើង វានឹងមានឥទ្ធិពលកាន់តែតិចទៅទៅលើផាគុចេញ ហើយតិចជាងករណីដែលប្រាក់បៀវត្សរូបិយវត្ថុនៅថេរថែមទៀត ។

### ២.៥. ឥទ្ធិពលនៃការរំកិលនៃខ្សែកោងផ្គត់ផ្គង់សរុប

**រូប ៨.១១ បម្រែបម្រួលថ្លៃ និង ផាគុចេញនៅពេលមានរំកិលនៃខ្សែកោងតម្រូវការ និង ការផ្គត់ផ្គង់**





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កន្លងមកយើងបានពិចារណាអំពីចលនារំកិលនៃខ្សែកោងតម្រូវការសរុប ដែលបណ្តាលមកពី ***អញ្ញត្តិគោលនយោបាយ*** ដូចជាកំណើនចំណាយរដ្ឋាភិបាល (G) ពន្ធ (T) ឬ ការផ្គត់ផ្គង់រូបិយវត្ថុ (M) ។ ឥទ្ធិពលនៃបន្លាស់ប្តូរនៃខ្សែកោងតម្រូវការសរុប (ADC) គឺច្បាស់ណាស់៖ កំណើន (G) ឬ (M) នឹងរំកិលខ្សែកោង ADC ទៅខាងស្តាំ និងដោយសារខ្សែកោង ASC មានមេគុណប្រាប់ទិសកើនឡើង ថ្លៃ និងធាតុចេញនឹងកើនឡើងផងដែរ ។ ការថយចុះនៃ (G) ឬ (M) នឹងមានឥទ្ធិពលផ្ទុយ ដែលរំកិលខ្សែកោង (ADC) ទៅខាងឆ្វេង ។ ក្នុងករណីមានការប្រែប្រួលក្នុងការយកពន្ធ (ΔT) ចលនារំកិលរបស់ខ្សែកោងនេះនឹងមានទិសផ្ទុយទៅវិញ (Figure 8.11a) ។ តើអ្វីទៅជាកត្តាដែលធ្វើឱ្យខ្សែកោង ASC រំកិល (Figure 8.11b)?

**រូប ៨.១២ ការរំកិលនៃខ្សែកោងការផ្គត់ផ្គង់ ដោយសារការរំពឹងថាថ្លៃនឹងកើនឡើង**




ជាការពិត យើងមានសម្មតិកម្មថា កត្តាទាំងអស់នៃតម្រូវការមានលក្ខណៈអថេរ (C, I, G, T, X, Z) ក្នុងខណៈដែលកត្តាទាំងអស់នៃការផ្គត់ផ្គង់មានលក្ខណៈថេរ (មូលធន វត្ថុធាតុដើម និង បច្ចេកវិទ្យា) លើកលែងតែកម្លាំងពលកម្មប៉ុណ្ណោះ ។ ទោះជាកម្លាំងពលកម្មត្រូវបានទទួលរងកំហិតនៃការផ្លាស់ប្តូរ នៅក្នុងករណីប្រាក់បៀវត្សហិរញ្ញវត្ថុ ក្នុងខណៈដែលថ្លៃ ($P^e$) ត្រូវបានគេចាត់ទុកថាមានលក្ខណៈថេរក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើយើងផ្លាស់ប្តូរថ្លៃ ($P^e$) នោះ ខ្សែកោងតម្រូវការសរុបនឹងរំកិល (រូបទី 8.12)។ ជាការពិតណាស់


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តាមបទពិសោធន៍ដែលមានកន្លងមកបង្ហាញថា ការរំពឹងទុកនៃកម្លាំងពលកម្មដែលពាក់ព័ន្ធនឹងថ្លៃ នឹងមានការប្រែប្រួល ហើយរំកិលខ្សែកោង (ASC) ពីទីតាំងដើម ។

*ដូចគ្នានេះដែរ បម្រែបម្រួលនៃមូលធន វត្ថុធាតុដើម ឬ បច្ចេកវិទ្យា*នឹងរំកិលខ្សែកោង (ASC) ។ ប្រសិនបើបរិមាណមូលធនកើនឡើង អនុគមន៍ផលិតកម្មនឹងរំកិល ។ ប្រសិនបើថ្លៃវត្ថុធាតុដើមដូចជា ប្រេង កើនឡើង នោះអនុគមន៍ផលិតកម្មនឹងរំកិល ។ ហើយ ជាការពិតណាស់ ប្រសិនបើបច្ចេកវិទ្យាប្រែប្រួល អនុគមន៍ផលិតកម្មនឹងប្រែប្រួល ។ បម្រែបម្រួលនៃកត្តាផ្គត់ផ្គង់នឹងបណ្តាលឱ្យខ្សែកោង ASC រំកិល ។ ផលប៉ះពាល់នៃការរំកិលនេះនឹងអាស្រ័យទៅលើរូបរាងរបស់ខ្សែកោង ASC ។ ដូច្នេះ ប្រសិនបើខ្សែកោង ASC មានភាពរួញយឺតខ្លាំង ការរំកិលនៃខ្សែកោង ASC នឹងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើថ្លៃ និងធាតុចេញ ។ ប្រសិនបើខ្សែកោង ASC មានភាពមិនរួញយឺត នោះការរំកិលនៃខ្សែកោង ASC នឹងមានឥទ្ធិពលតិចតួចជាង ។

## ៣. កេនស៍និយម និង បុរាណនិយម

**រូប ៨.១៣ ខ្សែកោងតម្រូវការ និង ការផ្គត់ផ្គង់សរុប បុរាណនិយម និងកេនស៍និយម**






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាំងនៅក្នុងគំរូបូរាណនិយម និង កេនស៍និយម ទំនាក់ទំនងអន្តរសកម្មរវាងខ្សែកោង ASC និង ខ្សែកោង ADC ដែលកំណត់នូវថ្លៃ និង ធាតុចេញនៃសេដ្ឋកិច្ចជាតិ ។ ក្នុងករណីតម្រូវការ យើងបានឃើញថា គំរូបូរាណនិយម មិនមានបង្ហាញនូវទ្រឹស្តីអ្វីច្បាស់លាស់អំពីតម្រូវការឡើយ ។ ក៏ប៉ុន្តែ ក៏ទ្រឹស្តីដោយប្រយោលមួយត្រូវបានបង្កើតឡើង ដោយប្រើប្រាស់នូវ **ទ្រឹស្តីអំពីបរិមាណរូបិយវត្ថុ** ។

(8.6) MV = PY

ដែល M ការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានកំណត់ដោយធនាគារកណ្តាល V គឺជាល្បឿន ឬ រង្វិលនៃរូបិយវត្ថុ (Velocity) ដែលត្រូវបាន គេសន្មតថាជាចំនួនថេរ ដែលត្រូវបានបង្កើតឡើងដោយស្ថាប័ន ហើយ P គឺជាថ្លៃ និង Y គឺជាធាតុចេញរបស់សេដ្ឋកិច្ច ។ ចំណែករូបមន្ត **ខេមប្រ៊ីជ** បានកំណត់ដូចខាងក្រោមនេះទៅវិញ ÷

(8.7) M = Md = kPY

ដែល K គឺជាចំនួនថេរ ដែលតំណាងឱ្យចំនួនសាច់ប្រាក់នៅក្នុងដៃរបស់គេហជន ។ នៅក្នុងគំរូបូរាណនិយម កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុនឹងនាំឱ្យតម្រូវការកើនឡើង ប៉ុន្តែនាំឱ្យថ្លៃកើនឡើងដែរ ពីព្រោះខ្សែកោង ASC ត្រូវបានសន្មតថា កំណត់ឡើងដោយសារតែកត្តាផ្គត់ផ្គង់សុទ្ធសាធ (រូបទី 8.13a) ។ កំណែតម្រូវបឋម ឬ យន្តការស្ថិរភាពរូបនីយកម្ម គឺ សំដៅទៅលើការប្រើប្រាស់អត្រាការប្រាក់ ឬ ថ្លៃដើមនៃរូបិយវត្ថុ ។ ដូច្នេះ ប្រសិនបើ G កើនឡើង ហើយត្រូវបានធ្វើហិរញ្ញប្បទានដោយកម្ចី នោះអត្រាការប្រាក់នឹងកើនឡើង ដែលធ្វើឱ្យ I ធ្លាក់ចុះ ដើម្បីសម្របសម្រួលទៅនឹងកម្ចីរដ្ឋាភិបាល ។ ជាការពិត មានតែកត្តារូបិយវត្ថុ ឬ តាមតម្លៃទីផ្សារទេ ដែលនឹងធ្វើអោយ ADC រំកិល ។ រំកិលនេះនឹងត្រូវបានស្រូបយក តាមរយៈបម្រែបម្រួលថ្លៃ ដោយគ្មានការប្តូរធាតុចេញ ឬ អនិកម្មភាព។

ផ្ទុយទៅវិញ ខ្សែកោង ADC របស់**កេនស៍** នឹងរំកិលឆ្លើយតបទៅនឹងបម្រែបម្រួលនៃកត្តាទាំងឡាយនៃតម្រូវការ ដូចជា (C, I, G, X, ឬ Z) ។ ម៉្យាងវិញទៀត **កេនស៍**ជឿថា អស្ថិរភាពនៃ I ឆ្លើយតបទៅនឹងបន្លាស់ប្តូរនៃការរំពឹងទុករបស់អាជីវកម្ម នឹងធ្វើឱ្យខ្សែកោង ADC រំកិល និង រួមចំណែកដល់អស្ថិរភាពនៃថ្លៃ និង ធាតុចេញ ។

គំរូបូរាណនិយមសន្មតថា ខ្សែកោង ASC មានភាពមិនរួញយឺតពេញលេញ ហើយកំណត់ដ៏តឹងរឹងដោយកត្តានៃការផ្គត់ផ្គង់ ។ កម្លាំងពលកម្មឆ្លើយតបទៅនឹងបន្លាស់ប្តូរនៃប្រាក់បៀវត្សពិត ហើយការឡើងថ្លៃនឹងនាំអោយប្រាក់បៀវត្សរូបិយវត្ថុកើនឡើង ដើម្បីរក្សាប្រាក់បៀវត្សពិតអោយនៅដដែល ។ ថ្លៃ និងប្រាក់បៀវត្សជារូបិយវត្ថុត្រូវបានគេសន្មតថា មានលក្ខណៈទន់ភ្លន់ពេញលេញ ។ នៅក្នុងគំរូ **កេនស៍** គេសន្មតថា កម្លាំងពលកម្មឆ្លើយតបទៅនឹងប្រាក់បៀវត្សជារូបិយវត្ថុ ដោយរំពឹងទុកថា ថ្លៃ ($P^e$) នឹងមានលក្ខណៈថេរ ។ ម៉្យាងវិញទៀត **កេនស៍**សន្មតថា ប្រាក់បៀវត្សរូបិយវត្ថុនឹងមានលក្ខណៈ «រឹងត្អឹង» ដោយពុំមែនទន់ភ្លន់ឡើយ ។ ប្រការនេះមានន័យថា ប្រសិនបើថ្លៃកើនឡើង ប្រាក់បៀវត្សរូបិយវត្ថុមិនប្រែប្រួលឡើយ ។ ប្រការនេះមានន័យថា ការឡើងថ្លៃនឹងនាំឱ្យសហគ្រាសទទួលបានចំណេញច្រើនជាង ហើយធាតុចេញកាន់តែខ្ពស់នឹងនាំឱ្យមានខ្សែកោង ASC មានមេគុណកើនឡើង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងរយៈពេលខ្លី (រូបទី 8.13b)។ ភាព «រឹងត្អឹង» នៃប្រាក់បៀវត្សរូបិយវត្ថុមានន័យថា នឹងគ្មានការកែតម្រូវជាស្វ័យប្រវត្តិ ដើម្បីអោយសេដ្ឋកិច្ចត្រលប់ទៅកាន់និកម្មភាពពេញលេញវិញឡើយ ។ ***កេនស៍***មិនបដិសេធថា ការកែតម្រូវនឹងកើតមានឡើង ក្នុងរយៈពេលវែងនោះទេ ប៉ុន្តែលោកនិយាយថា៖ « ***នៅក្នុងរយៈពេលវែងយើងទាំងអស់គ្នាប្រាកដជានឹងស្លាប់អស់ជាមិនខាន*** » ។ ដោយសារមតិខុសគ្នាទាំងអស់នេះ អំពីខ្សែកោង ASC និង ខ្សែកោង ASC ធ្វើអោយលទ្ធផលនៃគោលនយោបាយរបស់ទ្រឹស្តីនៃសាលាទាំងពីរ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំង ។

**រូប ៨.១៤ ផលប៉ះពាល់រយៈពេលខ្លីនៃកំណើនតម្រូវការសរុបនៅក្នុងគំរូកេនស៍**




នៅក្នុងគំរូរបស់***កេនស៍***ស្តីពី *គោលនយោបាយពង្រីកសកម្មភាព* កំណើននូវការផ្គត់ផ្គង់រូបិយវត្ថុនឹងនាំឱ្យតម្រូវការសរុបកើនឡើង ។ កម្រិតថ្លៃ និង កម្រិតផាតុចេញនឹងកើនឡើង ហើយនិកម្មភាពនឹងកើនឡើងដែរ នៅពេលដែលតម្រូវការកម្លាំងពលកម្មកើនឡើង ។ បញ្ហាសំខាន់នៃលទ្ធផលទាំងនេះគឺថា ស្ថានភាពនៃខ្សែកោងការផ្គត់ផ្គង់សរុប និង ការផ្គត់ផ្គង់កម្លាំងពលកម្មនៅថេរនៅក្នុងរយៈពេលខ្លី ។

នៅក្នុងរយៈពេលវែង កម្រិតថ្លៃរំពឹងទុកមានទំនោរទៅរកកម្រិតថ្លៃជាក់ស្តែង ។ អនិកម្មភាព និង ផាតុចេញបានត្រលប់មករកកម្រិតដើមវិញ លើកលែងតែកម្រិតថ្លៃ និង ប្រាក់បៀវត្សដែលស្ថិតនៅខ្ពស់ជាងជាអចិន្ត្រៃយ៍ ដោយសារកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ ។ ផាតុចេញ និង អនិកម្មភាពស្ថិតនៅលើកម្រិតសមតាក្នុងរយៈពេលវែង រហូតដល់ពេលដែលអ្នកផ្គត់ផ្គង់កម្លាំងពលកម្មអាចដឹងបានច្បាស់នូវការផ្លាស់ប្តូរនៃកម្រិតថ្លៃដែលបណ្តាលមកពី *គោលនយោបាយពង្រីកសកម្មភាព* ។ អ្នករូបិយវត្ថុនិយម អាចយល់ស្របជាមួយនឹងការវិភាគអំពីកំណើននៃតម្រូវការសរុប ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ៩

## គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចតាមបែបបុរាណនិយម

ឥទ្ធិពលនៃការផ្លាស់ប្ដូរគោលនយោបាយផ្សេងៗលើធាតុចេញ អនិកម្មភាព កម្រិតថ្លៃ និង អត្រាការប្រាក់មានដូចខាងក្រោម៖

### ១. គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

គោលនយោបាយសារពើពន្ធ គឺជាការចាត់ចែងថវិកា ដូចនេះរួមមានការសម្រេចចិត្តលើចំណាយរដ្ឋាភិបាល និងការបង់ពន្ធ ។

#### ១.១. ចំណាយរដ្ឋាភិបាល

ដូចក្រុមហ៊ុន និង ក្រុមគ្រួសារដែរ រដ្ឋាភិបាលមានបញ្ហាថវិកា និង លក្ខខណ្ឌដែលរាល់ចំណាយទាំងអស់ត្រូវធ្វើហិរញ្ញប្បទានពីប្រភពមួយចំនួន ។ រដ្ឋាភិបាលមានប្រភពមូលនិធិបីគឺ ÷ *ការយកពន្ធ លក់សញ្ញាប័ណ្ណជាសាធារណៈ (ខ្ចីមូលនិធិពីមហាជន) ឬ បោះពុម្ពរូបិយវត្ថុថ្មី* ។ យើងចាត់ទុកថាការផ្គត់ផ្គង់រូបិយវត្ថុនៅថេរ និងការប្រមូលពន្ធនៅដដែល ។ បន្ទាប់មកការកើនឡើងចំណាយរបស់រដ្ឋាភិបាលចាត់ទុកថាត្រូវបានធ្វើហិរញ្ញប្បទានដោយលក់សញ្ញាប័ណ្ណឱ្យមហាជន ។

ការកើនឡើងចំណាយរដ្ឋាភិបាលដែលហិរញ្ញប្បទានដោយសញ្ញាប័ណ្ណ នឹងមិនមានឥទ្ធិពលលើតម្លៃសមតានៃធាតុចេញ ឬ កម្រិតថ្លៃទេ ។ ធាតុចេញមិនទទួលរងផលប៉ះពាល់ពីការប្រែប្រួលចំណាយរដ្ឋាភិបាលទេ ដូចនេះក៏មិនមានផលប៉ះពាល់លើអនិកម្មភាពដែរ ។

ការកើនឡើងចំណាយរដ្ឋាភិបាល ដែលហិរញ្ញប្បទានពីការលក់សញ្ញាប័ណ្ណឱ្យមហាជន ប៉ះពាល់ដល់មូលនិធិអាចឱ្យខ្ចី ។ ប្រសិនបើចំណាយរដ្ឋាភិបាលធំជាងចំណូលពន្ធ នាំឱ្យ (G – T) វិជ្ជមាន ដែល G ជាចំណាយរដ្ឋាភិបាលសរុប T ជាចំណូលពន្ធ និង (G – T) ជាឱនភាពរដ្ឋាភិបាល ។ យើងសន្មតថា មុនពេលកើនចំណាយរដ្ឋាភិបាល ថវិកាមានតុល្យភាព ពោលគឺ G = T ។

ការកើនឡើងចំណាយរដ្ឋាភិបាលបង្កើតឱ្យមានតម្រូវការកើនឡើង សម្រាប់មូលនិធិអាចឱ្យខ្ចីដោយសាររដ្ឋាភិបាលលក់សញ្ញាប័ណ្ណចំពោះមហាជនដើម្បីហិរញ្ញប្បទានចំណាយថ្មី ។ នេះធ្វើឱ្យមានអ្នកខ្ចីច្រើនជាងអ្នកឱ្យខ្ចីនៅត្រង់អត្រាការប្រាក់ដំបូង $r_0$ និង បណ្ដាលឱ្យអត្រាការប្រាក់ ត្រូវបានរុញឡើងដល់ $r_1$ ។ ការកើនអត្រាការប្រាក់មានឥទ្ធិពលពីរគឺ៖ ទីមួយ ការសន្សំកើនពី $S_0$ ទៅ $S_1$ នេះគឺប្រវែង A ក្នុងរូប ៩.១ ។ ការកើនការសន្សំឆ្លុះបញ្ចាំងនូវការធ្លាក់ចុះការប្រើប្រាស់ដោយស្មើគ្នា ។ ទីពីរបរិមាណវិនិយោគថយចុះ ទន្ទឹមនឹងអត្រាការប្រាក់កើនឡើង ។ នៅត្រង់ $r_1$ កម្រិតថ្មីនៃវិនិយោគនៅចំ $I_1$ ។ ការធ្លាក់ចុះវិនិយោគគឺ ប្រវែង B ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### រូប ៩.១ ផលប៉ះពាល់នៃកំណើនចំណាយរដ្ឋាភិបាលនៅក្នុងគំរូបុរាណនិយម




បរិមាណថយចុះការប្រើប្រាស់ដែលស្មើនឹងចំនួនកើនឡើងការសន្សំ (ប្រវែង A) បូកចំនួនធ្លាក់ចុះនៃការវិនិយោគ (ប្រវែង B) គឺស្មើបរិមាណកើនឡើងនៃចំណាយរដ្ឋាភិបាល (G – T) ។ ការកើនចំណាយរដ្ឋាភិបាលដែលហិរញ្ញប្បទានដោយការលក់សញ្ញាប័ណ្ណ ចំពោះមហាជនធ្វើឱ្យអត្រាការប្រាក់កើនឡើងក្នុងកម្រិតមួយសមល្មមនឹងធ្វើអោយចំណាយរបស់ផ្នែកឯកជន ក៏ត្រូវបានកាត់បន្ថយ *(Crowd out-ច្រានចេញ)* ក្នុងបរិមាណនេះដែរ (ការប្រើប្រាស់បូកវិនិយោគ) ។ ចំណាយឯកជនមិនត្រូវបានលើកទឹកចិត្តទេ ព្រោះអត្រាការប្រាក់ខ្ពស់ធ្វើឱ្យគេហជនផ្ទេរពីការប្រើប្រាស់បច្ចុប្បន្ន ទុកសម្រាប់ប្រើប្រាស់នៅពេលអនាគតជាជំនួសវិញ ពោលគឺគេសន្សំច្រើនជាង ។ ការវិនិយោគធ្លាក់ចុះ ពីព្រោះចំនួនគម្រោងដែលអាចរកចំណេញបានមានកាន់តែតិច ក្នុងលក្ខខណ្ឌចំណាយខ្ចីបុលខ្ពស់ ។ ការកាត់បន្ថយចំណាយឯកជននេះទប់តម្រូវការសរុបមិនឱ្យកើនឡើងនៅខណៈដែលតម្រូវការរបស់រដ្ឋាភិបាលកើនឡើង ។ ការកើនចំណាយរដ្ឋាភិបាល ដែលហិរញ្ញប្បទានដោយសញ្ញាប័ណ្ណមិនជះឥទ្ធិពលលើថ្លៃទេ ពីព្រោះតម្រូវការសរុបមិនបានប្រែប្រួល ។

តើអ្វីជាផលប៉ះពាល់នៃការកើនឡើងចំណាយរដ្ឋាភិបាល ប្រសិនបើរដ្ឋាភិបាលបោះពុម្ពរូបិយវត្ថុ ដើម្បីធ្វើហិរញ្ញប្បទានចំណាយថ្មី ? ដោយសារបរិមាណរូបិយវត្ថុប្រែប្រួល នោះកម្រិតថ្លៃនឹងប្រែប្រួលជាសមាមាត្រគ្នានេះដែរ ។ ការកើនរូបិយវត្ថុរំកិលខ្សែកោងតម្រូវការសរុបឡើងលើតាមខ្សែកោងផ្គត់ផ្គង់សរុប ដែលស្ថិតនៅបញ្ឈរ ប្រការនេះនាំឱ្យកម្រិតថ្លៃកើនឡើង ។ ចំណុចសំខាន់បំផុតគឺ ថាការកើនចំណាយរដ្ឋាភិបាលគ្មានឥទ្ធិពលដោយឯករាជ្យទៅលើតម្រូវការសរុបទេ ។

ប៉ុន្តែប្រសិនបើចំណាយធំជាងពន្ធ (G – T > 0) រដ្ឋាភិបាលមានឱនភាព និង ត្រូវស្វែងរកមូលនិធិតាមវិធីមួយក្នុងចំណោមវិធីពីរផ្សេងទៀត នោះគឺការខ្ចី ឬ ការបោះពុម្ពរូបិយវត្ថុ ។ ប្រសិនបើពន្ធពិតជាបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កើនឡើងសម្រាប់ធ្វើការទូទាត់ចំណាយរដ្ឋាភិបាលដែលមានកម្រិតខ្ពស់ នោះផលប៉ះពាល់មានផ្សេងពីនេះ វាអាស្រ័យលើឥទ្ធិពលខាងផ្នែកតម្រូវការ ដែលផ្ទុយនឹងផលប៉ះពាល់ផ្នែកផ្គត់ផ្គង់ ។

## ១.២. ការខ្ចីបុល

ប្រសិនបើរដ្ឋាភិបាលខ្ចីពីផ្នែកផ្គត់ផ្គង់ *«មូលនិធិអាចខ្ចី»* ពីកម្មករ នោះវាធ្វើឱ្យកើនតម្រូវការសម្រាប់មូលនិធិបែបនេះ និង រុញអត្រាការប្រាក់ឡើង (រូប ៩.៥៖ វិកិលពី I ទៅ I + [G – T > 0]) ។ នៅអត្រាការប្រាក់ខ្ពស់ជាងនេះ ($r_0$ ទៅ $r_1$) ការប្រើប្រាស់ធ្លាក់ចុះព្រោះផលពីការសន្សំកើន នោះគឺការផ្គត់ផ្គង់មូលនិធិអាចខ្ចីកើនឡើង ។ ប៉ុន្តែការធ្លាក់ចុះការប្រើប្រាស់ត្រូវបំពេញមកវិញ ដោយការកើន G ដូចនេះ សមតាបូរាណនិយមនៅរក្សាដដែល ។

អត្រាការប្រាក់ខ្ពស់នាំឱ្យក្រុមហ៊ុនកាត់បន្ថយការខ្ចី សម្រាប់គោលដៅវិនិយោគពោលគឺ នៅត្រង់អត្រាការប្រាក់ $r_1$ ការវិនិយោគឯកជនថយចុះពី $I_0$ ទៅ $I_1$ ក្នុងខណៈដែលការខ្ចីរបស់រដ្ឋាភិបាលជាកត្តា*«កាត់បន្ថយ»* កម្ចីរបស់ឯកជន (រូប ៩.១) ។ សមតាបូរាណនិយមរក្សានៅត្រង់ចំណុច ដែលចំណាយរដ្ឋាភិបាលកើន ទៅប្រសព្វជាមួយការប្រើប្រាស់ឯកជន និង ការវិនិយោគដែលថយចុះ ។

ប៉ុន្តែកំណើនសេដ្ឋកិច្ចអាចទទួលរងនូវផលប៉ះពាល់ ។ ការវិនិយោគឯកជនធ្វើឱ្យកើនចំនួនទុនដែលនាំទៅរកធាតុចេញកម្រិតខ្ពស់ជាងមុន នៅរយៈកាលបន្ទាប់ ។ ប្រសិនបើចំណាយរបស់រដ្ឋាភិបាលដែលកើននោះត្រូវបានយកទៅប្រើប្រកបដោយប្រសិទ្ធភាព និង បង្កើនមូលដ្ឋានធនធានសាធារណៈ ឧទាហរណ៍ ការអប់រំ និង ផ្លូវថ្នល់ត្រូវបានធ្វើឱ្យប្រសើរឡើង វាក៏អាចនាំឱ្យមានកំណើនសេដ្ឋកិច្ចតាមរយៈការកាត់បន្ថយថ្លៃផលិតប្រកបដោយប្រសិទ្ធភាព និង ក្នុងករណីនេះអនុគមន៍ផលិតកម្មរំកិលឡើងលើ ។ ប៉ុន្តែប្រសិនបើការកើនចំណាយរដ្ឋាភិបាលមិនបង្កើនមូលដ្ឋានធនធានសាធារណៈ និង មិនបន្ថយចំណាយផលិតកម្ម នោះកំណើនសេដ្ឋកិច្ចនឹងថយចុះ ។

## ១.៣. ការបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ

ប្រសិនបើរដ្ឋាភិបាលធ្វើហិរញ្ញប្បទាន G ដោយបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ ជំនួសការបង្កើនពន្ធ ឬ ខ្ចីនោះថ្លៃនឹងកើនឡើង ប៉ុន្តែធាតុចេញសរុបនៅដដែល ។ តាមពិតថ្លៃខ្ពស់ហាក់បីដូចជាពន្ធ ដែលបន្ថយការប្រើប្រាស់ឯកជន និង វិនិយោគ តែបំពេញការធ្លាក់ចុះបែបនេះដោយការកើន G ។

## ១.៤. គោលនយោបាយសារពើពន្ធ

ដើម្បីវាយតម្លៃផលប៉ះពាល់ផ្សេងៗនៃយោបាយពន្ធ យើងងាកពីការបង្កើនពន្ធទៅការបន្ថយពន្ធ ។ យើងនឹងពិចារណាទាំងផលប៉ះពាល់ខាងផ្នែកតម្រូវការ និង ខាងផ្នែកផ្គត់ផ្គង់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### រូប ៩.២ ផលប៉ះពាល់ខាងផ្នែកផ្គត់ផ្គង់នៃការកាត់បន្ថយពន្ធលើប្រាក់ចំណូល






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ផលប៉ះពាល់ខាងតម្រូវការ:*** ការវិភាគការប្រែប្រួលពន្ធផ្តល់លទ្ធផលប្រហាក់ប្រហែលគ្នា នឹងការវិភាគពាក់ព័ន្ធនឹងចំណាយរដ្ឋាភិបាល ។ តាមរយៈការកើនចំណូលរបស់គេហជន ការបន្ថយពន្ធអាចជំរុញការប្រើប្រាស់ ។ ប្រសិនបើរដ្ឋាភិបាលលក់សញ្ញាប័ណ្ណឱ្យមហាជន ដើម្បីជំនួសការបាត់បង់ចំណូលពីការកាត់បន្ថយពន្ធ នោះនឹងមាន *ការច្រានចេញ*ដូចគ្នា ដោយសារករណីបង្កើនហិរញ្ញប្បទានតាមរយៈសញ្ញាប័ណ្ណ នឹងបង្កើនចំណាយរដ្ឋាភិបាល ។ សមតាអត្រាការប្រាក់នឹងកើន វិនិយោគថយចុះ និង អាចកើតមានក្នុងករណីដែលអត្រាការប្រាក់ទាក់ទាញការសន្សំឱ្យកើនឡើង មានន័យថា ការប្រើប្រាស់អាចថយចុះទៅរកកម្រិតមុនពេលបន្ថយពន្ធ ។ ក្នុងករណីកាត់បន្ថយពន្ធ តម្រូវការសរុបមិនទទួលរងផលប៉ះពាល់ដូចករណីបង្កើនចំណាយដែរ ។ ប្រសិនបើចំណូលដែលបានបាត់បង់ដោយសារការកាត់បន្ថយពន្ធត្រូវបានបំពេញមកវិញដោយការបោះពុម្ពរូបិយវត្ថុថ្មី នោះដូចក្នុងករណីកើនចំណាយរដ្ឋាភិបាលដែរគឺ ការបង្កើតរូបិយវត្ថុធ្វើឱ្យកើនតម្រូវការសរុប និង ការបន្ថយពន្ធនឹងធ្វើឱ្យកម្រិតថ្លៃកើនឡើង ។ ការកាត់បន្ថយពន្ធមិនមានផលប៉ះពាល់ប្រកបដោយឯករាជ្យលើតម្រូវការសរុបទេ ។

***ផលប៉ះពាល់ខាងផ្នែកផ្គត់ផ្គង់:*** ប្រសិនបើការកាត់បន្ថយពន្ធត្រូវបានធ្វើឡើងដោយការកាត់ជាសរុប មានន័យថា រាល់គេហជនទទួលបានការបន្ថយពន្ធ ១០០ដុល្លារ នោះប៉ះពាល់ខាងផ្នែកតម្រូវការទាំងអស់ដែលយើងត្រូវពិចារណា ។

ការវិភាគខាងផ្នែកតម្រូវការ បានចាត់ទុកយ៉ាងពិសេសថា ការបន្ថយពន្ធគឺការកាត់បន្ថយ *«ជាសរុប»* ឧទាហរណ៍ បុគ្គលជាប់ពន្ធគ្រប់រូបទទួលបានការកាត់បន្ថយពន្ធចំនួន ៥០០ ដុល្លារ ។ ប៉ុន្តែការបន្ថយពន្ធអាចធ្វើតាមការបន្ថយ *«អត្រាលើប្រាក់ចំណូលបន្ថែម»* ។ ក្នុងករណីគេរកចំណេញបានកាន់តែច្រើន គេអាចរក្សាទុកជាចំណូលក្រោយពីកាត់ពន្ធកាន់តែច្រើនដែរ ។ តាមការអនុវត្តជាក់ស្តែងនេះអាចមានចំនួនស្មើនឹង បរិមាណកើនឡើងនៃបៀវត្ស*«ពិត»* ។ ការកើនបៀវត្សពិត (ការកើនដែលក្រុមហ៊ុនមិនបានបង់) អាចជំរុញឆន្ទៈកម្មករ ដើម្បីធ្វើការដែលធ្វើឱ្យរំកិលការផ្គត់ផ្គង់ការងារ (រូប ៩.២a) ជាក់ស្តែង នេះគឺបន្ថយបៀវត្សពិត ដែលបង់ដោយក្រុមហ៊ុន ប្រការនេះនាំឱ្យក្រុមហ៊ុនកើនផាតុចេញ (រូប ៩.២b) និង សមតានិកម្មភាពរំកិលពី $N_0$ ទៅ $N_1$ ហើយសមតាផាតុចេញ (រូប ៩.២c) ផ្លាស់ពី $Y_0$ ទៅ $Y_1$ ។

សរុបសេចក្តីមកការប្រែប្រួលចំណាយរដ្ឋាភិបាល ឬ ពន្ធ គ្មានឥទ្ធិពលដោយឯករាជ្យទៅលើតម្រូវការសរុបទេ ដោយសារការកែតម្រូវអត្រាការប្រាក់ និងមានឥទ្ធិពល*ច្រានចេញ* ចំពោះសមាសធាតុតម្រូវការវិស័យឯកជន។ ការប្រែប្រួលអត្រាពន្ធលើចំណូលបន្ថែម មានផលប៉ះពាល់ខាងផ្នែកផ្គត់ផ្គង់ជាបន្ថែមទៀត ។ ការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណូលបន្ថែមវាជំរុញការផ្គត់ផ្គង់ពលកម្ម និងនាំទៅរកការកើនឡើងនិកម្មភាព និង ផាតុចេញ ។

## ២. គោលនយោបាយរូបិយវត្ថុ

ក្នុងប្រព័ន្ធបូរាណនិយម បរិមាណរូបិយវត្ថុកំណត់កម្រិតថ្លៃ និង សម្រាប់ចំណូលពិតមានជាសម្មតិកម្ម



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នោះបរិមាណរូបិយវត្ថុកំណត់ចំណូលតាមថ្លៃទីផ្សារ ។ ក្នុងន័យនេះ គោលនយោបាយរូបិយវត្ថុមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋវិទ្យាបុរាណនិយម ។ ស្ថិរភាពរូបិយវត្ថុ ជាការកែតម្រូវសម្រាប់ស្ថិរភាពថ្លៃ ។

ដូចយើងបានឃើញ នៅក្នុងគំរូបុរាណនិយម នយោបាយរូបិយវត្ថុគ្មានឥទ្ធិពល *«ពិត»* ទេ ។ សារៈសំខាន់របស់វាស្ថិតនៅលើការរក្សាថ្លៃឱ្យមានស្ថិរភាព និង ការជៀសវាងឥទ្ធិពលអាក្រក់នៃអតិផរណា ។ ក្នុងន័យម៉្យាងទៀតគឺថា រូបិយវត្ថុមិនមានសារៈសំខាន់ទេ ។ បរិមាណរូបិយវត្ថុមិនមានឥទ្ធិពលអ្វីទៅលើតម្លៃសមតានៃអថេរពិតក្នុងប្រព័ន្ធដូចជា ផលិតផល និកម្មភាព និងអត្រាការប្រាក់ ។

សម្រាប់សេដ្ឋវិទ្យាបុរាណនិយម រូបិយវត្ថុជា «របាំង» ដែលកំណត់តម្លៃទីផ្សារ ក្នុងនោះយើងវាស់អថេរបែបនេះ តាមរយៈកម្រិតសកម្មភាពសេដ្ឋកិច្ច ប៉ុន្តែគ្មានឥទ្ធិពលទៅលើបរិមាណពិតទេ ។

សេដ្ឋវិទ្យាបុរាណនិយមបានផ្តោតទៅលើនិន្នាការសេដ្ឋកិច្ច ដែលកែតម្រូវដោយខ្លួនឯង ។ ពួកគេយល់ឃើញថាប្រសិនបើមិនមានសកម្មភាពដែលបង្កើតអោយមានអស្ថិរភាពរបស់រដ្ឋាភិបាលទេនោះ វិស័យឯកជននឹងមានស្ថិរភាព ហើយអនិកម្មភាពពេញលេញនឹងអាចសម្រេចបាន ។ យន្តការទីមួយដែលធ្វើឱ្យមានស្ថិរភាពដោយខ្លួនឯងនោះ គឺអត្រាការប្រាក់ ដែលកែតម្រូវ ដើម្បីទប់ទល់នឹងវិបត្តិនៃតម្រូវការតាមវិស័យ កុំឱ្យជះឥទ្ធិពលទៅលើតម្រូវការសរុប ។ កត្តាអោយមានស្ថិរភាពទីពីរ គឺថ្លៃទន់ភ្លន់ដោយសេរី និងបៀវត្សជារូបិយវត្ថុ ដែលទប់ការប្រែប្រួលតម្រូវការសរុបមិនឱ្យជះឥទ្ធិពលទៅលើផលិតផល ។ ភាពទន់ភ្លន់នៃថ្លៃ និង បៀវត្សគឺសំខាន់បំផុត សម្រាប់លក្ខណៈសម្បត្តិនៃប្រព័ន្ធបុរាណនិយមដែលមានអនិកម្មភាពពេញលេញ ។ ប្រការដែលធ្វើអោយវិស័យឯកជនមានស្ថេរភាពនាំឱ្យសេដ្ឋវិទ្យាបុរាណនិយមឈានទៅរកសេចក្តីសន្និដ្ឋានបែបនយោបាយគ្មានអន្តរាគមន៍ ។ ក្នុងវិទ្យាសាស្ត្រសេដ្ឋកិច្ចគំរូបុរាណនិយមគឺ ÷

- ចំណេះដឹងឥតខ្ចោះ ដូចនេះគ្រប់តួអង្គបានដឹងអ្វីដែលតួអង្គដទៃៗទៀតបានធ្វើ និងដឹងរាល់វិធី និងមធ្យោបាយនៃការសម្រេចបានគោលដៅរបស់គេ ដែលជាកត្តាធ្វើអោយប្រយោជន៍ និង ប្រាក់ចំណេញកើនឡើងជាអតិបរមា ។

- ការប្រកួតប្រជែងឥតខ្ចោះ ដូចនេះគ្មានអ្នកណាម្នាក់មានអំណាចលើទីផ្សារទេ និង ម្នាក់ៗជា *«អ្នកសម្របតាមថ្លៃ»* មិនមែនជា *«អ្នកបង្កើតថ្លៃ»* ទេ ។

- ភាពទន់ភ្លន់ឥតខ្ចោះនៃថ្លៃ និង បៀវត្ស ដូចនេះ អនិកម្មភាពពេញលេញត្រូវបានធានា ។

- យ៉ាងហោចណាស់ ក្នុងរយៈពេលខ្លី ចំនួនដើមទុនជារោងចក្រ និង គ្រឿងឧបករណ៍នៅថេរដូចបច្ចេកវិទ្យា និង ប្រជាជនដែរ ។ ការផ្លាស់ប្តូរប្រព្រឹត្តទៅដោយរលូន និង គ្មានលំអៀងហើយគ្មាន *«ភាពរឹងត្អឹង»* ណាដែលរារាំងមិនឱ្យរក្សាបាន *«សមតា»* ឥតខ្ចោះទេ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអនុវត្តជាក់ស្តែងតាមគំរូបុរាណនិយម អាចសម្រេចបានយ៉ាងប្រាកដក្នុងមីក្រូសេដ្ឋកិច្ចក្នុងគំរូដែលហៅថា *«គំរូសមតា»* ទូទៅ ។ សមតាទូទៅកើតមាន នៅពេលដែលមានសមតាដំណាលគ្នានៅក្នុងគ្រប់ទីផ្សារដោយសន្មតថា មានការប្រកួតប្រជែងឥតខ្ចោះ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១០

# គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរូបិយវត្ថុនិយម

ដោយប្រើនូវគំរូរូបិយវត្ថុនិយម គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុ មានលទ្ធផលខុសពីគំរូ **កេនស៍និយម** ។

## ១. ទ្រឹស្តីរូបិយវត្ថុនិយម និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ដោយសន្មតិថា រដ្ឋាភិបាលបង្កើនចំណាយ (G) ដោយមិនបង្កើនពន្ធ (T) ដូច្នេះចាំបាច់ត្រូវធ្វើហិរញ្ញប្បទាននៃឱនភាពនេះ តាមរយៈការបោះពុម្ពរូបិយវត្ថុបន្ថែម ឬ ខ្ចីពីទីផ្សារហិរញ្ញវត្ថុ (រូប 10.1) ។ កំណើននៃចំណាយរដ្ឋាភិបាល (G) ធ្វើឱ្យខ្សែកោង IS រំកិលទៅខាងស្តាំ ។ ដោយទទួលយកនូវជំហររបស់ពួករូបិយវត្ថុនិយមទាក់ទងទៅនឹងមេគុណនៃខ្សែកោង IS និង LM នោះការរំកិលនៃខ្សែកោង IS ដែលជាលទ្ធផលនៃការកើនឡើងជាដុំកំភួននៃអត្រាការប្រាក់ពី $r_0$ ទៅ $r_1$ ជាមួយនឹងការកើនឡើងយ៉ាងតិចតួចនៃធាតុចេញ Y ($Y_0$ ទៅ $Y_1$)។

**រូប ១០.១ ទស្សនៈរូបិយវត្ថុនិយមស្តីពីផលប៉ះពាល់នៃចំណាយរដ្ឋាភិបាល**






fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាការពិត កំណើននៃការខ្ចីប្រាក់របស់រដ្ឋាភិបាលធ្វើឱ្យអត្រាការប្រាក់កើនឡើង ដែលធ្វើឱ្យការវិនិយោគឯកជនធ្លាក់ចុះ (ការច្រានចេញ) ដែលធ្វើឱ្យផលប៉ះពាល់នៃកំណើន (G) ទៅលើផាតុចេញ Y មានកម្រិតអប្បបរិមា ។ យើងអាចប្រៀបធៀបលទ្ធផលនេះទៅនឹងគំរូរបស់ **កេនស៍** ។

## ២. ទ្រឹស្តីរូបិយវត្ថុនិយម និង គោលនយោបាយរូបិយវត្ថុ

ចំពោះក្រុមរូបិយវត្ថុនិយម អស្ថិរភាពនៃ Y មានលទ្ធផលមិនដូចគំរូ**កេនស៍** ដែលបណ្តាលមកពីអស្ថិរភាពនៃការវិនិយោគឯកជនឡើយ ក៏ប៉ុន្តែវាមានសណ្ឋានដូចគ្នាទៅអស្ថិរភាពនៅក្នុងកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ ។ ដូច្នេះ ប្រការដ៏ប្រសើរបំផុតដែលធនាគារកណ្តាលអាចធ្វើបាននោះ គឺត្រូវបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ ប្រកបដោយល្បឿនស្មើៗគ្នា ពោលគឺត្រូវអនុវត្តទៅតាមវិធានជាក់លាក់ ជាជាងការធ្វើឡើងទៅតាមឆន្ទានុសិទ្ធិរបស់អ្នកធ្វើគោលនយោបាយ ។ ដោយទទួលយកនូវសម្មតិកម្មរបស់ពួករូបិយវត្ថុនិយមអំពី LM និង IS បន្លាស់ប្តូរខ្សែកោង IS ពោលគឺកំណើននៃ G ឬ X នឹងមានឥទ្ធិពលតិចតួចទៅ Y ប៉ុន្តែវាមានឥទ្ធិពលជាដុំកំភួនទៅលើអត្រាការប្រាក់ r និង ថ្លៃ P ។ កំណើនប្រកបដោយស្ថិរភាពនៃការផ្គត់ផ្គង់រូបិយវត្ថុនឹងកាត់បន្ថយសម្ពាធអតិផរណា ដោយមិននាំឱ្យមានអស្ថិរភាពបន្ថែមទៀត (រូបទី 10.2) ។

**រូប ១០.២ ទស្សនៈរូបិយវត្ថុនិយមស្តីពីការកំណត់ប្រាក់ចំណូល ដោយមានអត្រាកំណើនរូបិយវត្ថុថេរ**




កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុក៏ត្រូវមានលក្ខណៈស្ថិរភាពដែរ ដោយសារចំណេះដឹងមិនអស់អំពីការផ្លាស់ប្តូររួមនៅក្នុងសេដ្ឋកិច្ចជាតិ ។ ដូច្នេះ ដោយយោលទៅតាមទ្រឹស្តី និងព័ត៌មានដែលមាននាពេលបច្ចុប្បន្ន

នេះ យើងមិនអាចព្យាករណ៍ឱ្យបានត្រឹមត្រូវជាក់លាក់នូវស្ថានភាពអនាគតនៃសេដ្ឋកិច្ចជាតិបានឡើយ ហើយការប្រើប្រាស់នូវគោលនយោបាយរូបិយវត្ថុប្រកបដោយឆន្ទានុសិទ្ធិ ដើម្បីឱ្យមានឥទ្ធិពលជាដុំកំភួនទៅលើតម្រូវការសរុប នឹងនាំឱ្យមានអស្ថិរភាពបន្ថែមទៀតដល់ប្រព័ន្ធទាំងមូល ។ ដូច្នេះ ជំហររបស់អ្នករូបិយវត្ថុនិយម គឺត្រូវខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យមានស្ថិរភាពសេដ្ឋកិច្ច ជាជាងការកំណត់គោលដៅដាក់ឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ច ។

ជារួម ទ្រឹស្តី«**រូបិយវត្ថុនិយម**» ស្នើសុំឱ្យមានការផ្លាស់ប្តូរតិចតួចនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ពីព្រោះវានាំឱ្យមានការ «**រុញច្រានចេញ**» ការវិនិយោគឯកជន និង ត្រូវបង្កើនអត្រាកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុអោយបានថេរ ដើម្បីធ្វើឱ្យមានស្ថិរភាព ជាជាងការខិតខំជម្រុញកំណើនសេដ្ឋកិច្ច ។ ភាពខុសគ្នារវាងជំហររបស់ ពួក«**រូបិយវត្ថុនិយម**» និង ពួក«**កេនស៍និយម**» អាចមើលឃើញយ៉ាងច្បាស់ក្រឡែត នៅក្នុងរូបភាព ៩.៧ (រូប 9.7) ។ម្យ៉ាងវិញទៀត ដូចនៅក្នុងគំរូបុរាណនិយមដែរ គំរូបែប «**រូបិយវត្ថុនិយម**» ទាមទារឱ្យមានអន្តរាគមន៍ដ៏តិចបំផុតរបស់រដ្ឋាភិបាលនៅក្នុងសេដ្ឋកិច្ច ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១១

# ការរំពឹងទុក

ទ្រឹស្តីសេដ្ឋកិច្ចបូរាណនិយមបែបថ្មី ចាប់បដិសន្ធិឡើងដើម្បីដោះស្រាយបញ្ហាអតិផរណាខ្ពស់ និង និកម្មភាពនៅទសវត្សរ៍ឆ្នាំ ១៩៧០ និង ការមិនពេញចិត្តចំពោះទ្រឹស្តីសេដ្ឋកិច្ចតាមបែបកេនស៍និយម ។ ទាំងទ្រឹស្តីរូបិយវត្ថុនិយម ទាំងទ្រឹស្តីសេដ្ឋកិច្ចបូរាណនិយមបែបថ្មី សុទ្ធតែមានប្រភពចេញមកពីទ្រឹស្តីសេដ្ឋកិច្ចបូរាណនិយម ។ មគ្គុទ្ទេសក៍ឈានមុខគេនៅក្នុងទ្រឹស្តីសេដ្ឋកិច្ចបូរាណនិយមបែបថ្មី គឺលោក **រ៉ូប៊ើត លូកាស** (Robert E. Lucas) ដែលជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ **ស៊ីកាហ្គោ** យល់ឃើញថា រដ្ឋមិនត្រូវអនុវត្តនូវគោលនយោបាយធ្វើអន្តរាគមន៍សេដ្ឋកិច្ចឡើយ ។

គោលការណ៍ជាមូលដ្ឋាននៃគោលនយោបាយសេដ្ឋកិច្ចបូរាណនិយមបែបថ្មី គឺការធ្វើស្ថិរភាពរូបនីយកម្មនៃអថេរពិត ដូចជាធាតុចេញ និង អនិកម្មភាព ដែលមិនអាចសម្រេចបានតាមរយៈការគ្រប់គ្រងសរុបនោះទេ ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុ ជាប្រព័ន្ធដែលធ្វើឱ្យតម្រូវការសរុបផ្លាស់ប្តូរនឹងមិនមានឥទ្ធិពលអ្វីលើធាតុចេញ និង អនិកម្មភាពឡើយ ទោះជានៅក្នុងរយៈពេលខ្លីក៏ដោយ ។

## ១. ការពិនិត្យឡើងវិញនូវទ្រឹស្តីកេនស៍

នៅក្នុងគំរូ**កេនស៍** ត្រូវបានគេសន្មតថា ថ្លៃរំពឹងទុកនៃកម្លាំងពលកម្ម ពោលគឺថ្លៃអនាគត មានប្រតិកម្មឆ្លើយតបយឺតៗ បើផ្អែកលើបទពិសោធន៍កន្លងមក ។ ជាក់ស្តែង ប្រការនេះមានន័យថា ការរំពឹងទុកសម្លឹងថយក្រោយ ឬ ការព្យាករណ៍អំពីអនាគត ដោយផ្អែកលើបទពិសោធន៍នៃអតីតកាល និង ត្រូវស្រូបយកបទពិសោធន៍ ដែលគេបានពើបប្រទះក្នុងពេលថ្មីៗ ។ ដោយសារគម្លាតនៅពីក្រោយនៃកម្លាំងពលកម្ម ខ្សែកោងផ្គត់ផ្គង់សរុបត្រូវបានគេសន្មតថានឹងមានមេគុណប្រាប់ទិសកើនឡើងនៅក្នុងរយៈពេលខ្លី ។ ក្នុងន័យនេះ ចំណងទាក់ទងខាងផ្នែកគោលនយោបាយ ពោលគឺកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ ។

ការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ M នឹងនាំឱ្យខ្សែកោងតម្រូវការសរុប ADC រំកិលទៅខាងស្តាំ (ចម្ងល់នៅត្រង់ថា ហេតុអ្វីបានជាការកើនឡើងនៃរូបិយវត្ថុបណ្តាលឱ្យអត្រាការប្រាក់ (r) ធ្លាក់ចុះ ដែលនាំឱ្យការវិនិយោគកើនឡើង?)។ នៅពេលដែលខ្សែកោងតម្រូវការសរុបរំកិល ទាំងធាតុចេញ (Y) និង ថ្លៃ (P) កើនឡើង ។ ដោយសារមានគម្លាតនៅក្នុងការរំពឹងទុកនៃថ្លៃរបស់កម្លាំងពលកម្ម ក្នុងខណៈដែលថ្លៃកើនឡើង នោះនិយោជកទទួលបាននូវផលចំណេញច្រើនជាងមុន (ដោយសន្មតថាប្រាក់ឈ្នួលជារូបិយវត្ថុ $W^m$ នៅថេរក្នុងរយៈពេលខ្លី) ហើយអនិកម្មភាពកើនឡើង ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២. ទស្សនាទាននៃការរំពឹងទុកប្រកបដោយវិចារណញ្ញាណ

គំរូបុរាណនិយមថ្មី (ឬសាលារំពឹងទុកប្រកបដោយវិចារណញ្ញាណ) មិនទទួលយកសម្មតិកម្មរបស់**កេនស៍** និង របស់អ្នករូបិយវត្ថុនិយម ស្តីពីការរំពឹងទុកដោយសម្លឹងថយក្រោយនោះឡើយ ។ ផ្ទុយទៅវិញ គេសន្មតយកការរំពឹងទុក *ដោយសម្លឹងឆ្ពោះទៅមុខ* ឬ *ប្រកបដោយវិចារណញ្ញាណ* ពោលគឺ គ្មានកំហុសជាប្រព័ន្ធឡើយនៅក្នុងការរំពឹងទុក ។

គេមិនទទួលយកនូវភាពផ្សេងគ្នា រវាងលទ្ធផលក្នុងរយៈពេលខ្លី និង ក្នុងរយៈពេលវែង នៅក្នុងការវិភាគរបស់អ្នករូបិយវត្ថុនិយម និង របស់កេនស៍ ស្តីពីឥទ្ធិពលនៃតម្រូវការសរុបទៅលើផាតុចេញ និង និកម្មភាពឡើយ ។ ចំណុចប្រមូលផ្តុំនៅក្នុងការទិតៀនរបស់គេ គឺថា សម្មតិកម្មរបស់កេនស៍ ក៏ដូចជារបស់អ្នករូបិយវត្ថុនិយម ពាក់ព័ន្ធនឹងការរំពឹងទុកអំពីថ្លៃ ដោយសន្មតថា អ្នកផ្គត់ផ្គង់កម្លាំងពលកម្មបង្កើតឡើងនូវការរំពឹងទុកស្តីពីកម្រិតថ្លៃសរុបក្នុងពេលបច្ចុប្បន្ន (ឬ អត្រាអតិផរណា) ដោយឈរមូលដ្ឋាននៃឥរិយាបថថ្លៃពីអតីតកាល ។

សេដ្ឋវិទូបុរាណនិយមបែបថ្មីបានលើកសំណួរថា ហេតុអ្វីបានជាភ្នាក់ងារប្រកបដោយវិចារណញ្ញាណធ្វើការរំពឹងទុកអំពីកម្រិតថ្លៃ ដោយពឹងផ្អែកតែទៅលើតម្លៃអតីតកាលនៃកម្រិតថ្លៃប៉ុណ្ណោះទៅវិញ ។ គេលើកឡើងថាភ្នាក់ងារសេដ្ឋកិច្ចនឹងបង្កើតឡើងនូវការរំពឹងទុកប្រកបដោយវិចារណញ្ញាណជំនួសវិញ ។ ការរំពឹងទុកត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានសមស្របទាំងអស់ដែលមាន ទាក់ទងនឹងអញ្ញត្តិដែលត្រូវព្យាករណ៍ ។ ភ្នាក់ងារសេដ្ឋកិច្ចត្រូវបានគេសន្មតថា បានប្រើប្រាស់រាល់ព័ត៌មានសមស្របទាំងអស់ និង វាយតម្លៃប្រកបដោយវិចារណ-ញ្ញាណនូវផលវិបាកនៃព័ត៌មាននោះ ចំពោះឥរិយាបថនាពេលអនាគតរបស់អញ្ញត្តិណាមួយ ។ គេយល់នូវទំនាក់ទំនងរវាងអញ្ញត្តិដែលគេសង្កេត និងអញ្ញត្តិ ដែលគេកំពុងព្យាយាមព្យាករណ៍ ។ ដូច្នេះ ផ្អែកតាមសម្មតិកម្មនៃការរំពឹងទុកប្រកបដោយវិចារណញ្ញាណ ការរំពឹងទុក ***«មានលក្ខណៈដូចគ្នានឹងការព្យាករណ៍អំពីទ្រឹស្តីសេដ្ឋកិច្ចដែរ»*** ។

***សម្មតិកម្មនៃការរំពឹងទុកប្រកបដោយវិចារណញ្ញាណ***អះអាងថា ភ្នាក់ងារសេដ្ឋកិច្ច ឬមួយបន្ទាប់ពីបានយល់យ៉ាងច្បាស់ពីសមាសធាតុជាប្រព័ន្ធនៃគ្រោះរាំងស្ងួត និង មានការរំពឹងទុកជាវិជ្ជមានថានឹងមានអតិផរណា (ដោយប្រើប្រាស់អស់លទ្ធភាពនៃព័ត៌មានដែលខ្លួនមាន) ឬមួយគេយល់ថាគ្រោះរាំងស្ងួតនឹងមិនកើតមាននៅឆ្នាំក្រោយឡើយ ។ ដូច្នេះ គេមិនជឿថានឹងមានគ្រោះរាំងស្ងួតនៅឆ្នាំក្រោយឡើយ ហើយអតិផរណានៅឆ្នាំក្រោយច្បាស់ជាទាបជាងឆ្នាំនេះមិនខាន (គ្មានកំហុសមានលក្ខណៈជាប្រព័ន្ធឡើយ)។

សេដ្ឋវិទូបុរាណនិយមបែបថ្មីបានទិតៀនទ្រឹស្តី ***«ការរំពឹងទុកបន្សាំ»*** របស់ **ហ្វ្រីដមែន** ដែលសន្មតថាភ្នាក់ងារសេដ្ឋកិច្ចទាំងឡាយតែងតែមាន *កំហុសជាលក្ខណៈប្រព័ន្ធ* ។ គេអះអាងថា ទំនងជាគ្មានហេតុផលអ្វីដើម្បីអោយភ្នាក់ងារទាំងនោះរំពឹងគិតថា អតិផរណានៅឆ្នាំក្រោយដូចគ្នានឹងឆ្នាំនេះទេ ។ ឧបមាថា យើងព្យាករណ៍ថាអតិផរណានឹងស្មើនឹងសូន្យ ។ បន្ទាប់មកស្រាប់តែមានគ្រោះរាំងស្ងួតដោយចៃដន្យ ដែលនាំអោយមានអតិផរណា។ ដោយឈរលើមូលដ្ឋាននៃទ្រឹស្តី ***«ការរំពឹងទុកបន្សាំ»*** របស់ **ហ្វ្រីដមែន** ភ្នាក់ងារត្រូវតែរំពឹងជាមុនថា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អតិផរណានៅឆ្នាំក្រោយនឹងនៅដដែល ។ ហេតុអ្វីទៅ? តើភ្នាក់ងារទាំងនេះនឹងរំពឹងគិតថានឹងមានគ្រោះរាំងស្ងួតទៀតឬយ៉ាងណា? ប្រសិនបើដូច្នោះមែន នោះគ្រោះរាំងស្ងួតពិតជាលែងចៃដន្យ ហើយវាបានក្លាយទៅជារឿងធម្មតាវិញហើយ ឬ យ៉ាងហោចណាស់ វាមានទំនាក់ទំនងជាប្រព័ន្ធទៅនឹងភាពរាំងស្ងួតដែលកើតឡើងពីពេលកន្លងមក ។ ប៉ុន្តែ ប្រសិនបើគ្រោះរាំងស្ងួតមានលក្ខណៈជាប្រព័ន្ធបែបនេះ នោះភ្នាក់ងារទាំងឡាយគួរតែមានការរំពឹងទុកខ្លះអំពីគ្រោះរាំងស្ងួតដែលកើតមានពីលើកទីមួយ ហើយដូច្នេះ ការរំពឹងទុកលើកដំបូង មិនគួរថានឹងមានអតិផរណាសូន្យនោះឡើយ ។

ដូច្នេះ តាមអំណះអំណាងរបស់សេដ្ឋវិទូបូរាណនិយមបែបថ្មី នៅពេលដំបូង នៅពេលដែលភ្នាក់ងាររំពឹងគិតថាអតិផរណាស្មើនឹងសូន្យ ឬមួយភ្នាក់ងារមិនបានប្រើប្រាស់អស់នូវព័ត៌មានដែលគាត់មាន (ពោលគឺភាពរាំងស្ងួតនោះកើតឡើងជាធម្មតា ឬ មានលក្ខណៈជាប្រព័ន្ធ) ឬមួយក៏ការព្យាករណ៍របស់គេដែលថា ភាពរាំងស្ងួតឆ្នាំនេះនឹងនាំអោយមានអតិផរណានៅឆ្នាំក្រោយ ពិតជាមិនសមហេតុផលទាំងស្រុង ។ ករណីទាំងពីរនេះវាផ្ទុយទាំងស្រុងនឹងការរំពឹងទុកប្រកបដោយវិចារណញ្ញាណ ។

**រូប ១១.១ ធាតុចេញ និង អនិកម្មភាពនៅក្នុងគំរូបូរាណនិយមបែបថ្មី**




ប្រសិនបើការរំពឹងទុកប្រកបដោយវិចារណញ្ញាណ នៅក្នុងការព្យាករណ៍តម្លៃនៃកម្រិតថ្លៃសរុបសម្រាប់ពេលបច្ចុប្បន្ន អ្នកផ្គត់ផ្គង់កម្លាំងពលកម្មនឹងប្រើប្រាស់នូវព័ត៌មានដែលទាក់ទងទាំងអស់ពីអតីតកាល មិនត្រឹមតែព័ត៌មានអំពីឥរិយាបថនៃថ្លៃកាលពីអតីតកាលនោះទេ ។ ម្យ៉ាងវិញទៀត គេនឹងប្រើប្រាស់ព័ត៌មានដែលគេមានអំពីថ្ងៃបច្ចុប្បន្ននៃអញ្ញត្តិដែលដើរតួនាទីនៅក្នុងការកំណត់ថ្លៃ ។ បើគិតពីចំណុចសំខាន់បំផុតនៅក្នុងគោលនយោបាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រប់គ្រងតម្រូវការសរុប អ្នកផ្គត់ផ្គង់កម្លាំងពលកម្មនឹងគិតអំពីសកម្មភាពទាំងអស់នៃគោលនយោបាយ ដែលគេបានប៉ាន់ស្មានទុក ឬ រំពឹងទុក ។ ម្យ៉ាងវិញទៀត គេបានសន្មតថា គេយល់ច្បាស់ពីទំនាក់ទំនងរវាងគោលនយោបាយ និងកម្រិតថ្លៃនេះ ។

ដោយឈរលើមូលដ្ឋាននៃករណីកម្លាំងពលកម្ម នៅក្នុងគំរូបូរាណនិយមបែបថ្មី យើងឃើញថា សមីការនៃការផ្គត់ផ្គង់កម្លាំងពលកម្ម អាចសរសេរបានដូចខាងក្រោម៖

$N^s = t(W/P^e)$ ដែល t តំណាងរយៈពេល W គឺជាប្រាក់បៀវត្សជារូបិយវត្ថុ ហើយ $P^e$ គឺជាការរំពឹងទុកអំពីថ្លៃ ។

ផលវិបាករបស់វាមានដូចតទៅ៖ ខ្សែកោងផ្គត់ផ្គង់សរុប (ASC) ដោយឈរលើមូលដ្ឋាននៃអន្តរសកម្មនៃតម្រូវការ និង ការផ្គត់ផ្គង់កម្លាំងពលកម្ម (ដោយសន្មតថា កត្តាដទៃទៀតនៃផលិតកម្ម និង ថ្លៃរបស់វាត្រូវបានរក្សាទុកឱ្យនៅថេរ) នឹងអាស្រ័យលើថ្លៃដែលគេបានរំពឹងទុក ជាជាងថ្លៃប្រវត្តិសាស្ត្រ ។ នៅក្នុងគំរូបូរាណនិយមបែបថ្មី តាមការពិត $P^e$ ពឹងផ្អែកទៅលើកម្រិតដែលគេរំពឹងទុកនៃសមាសធាតុទាំងអស់របស់គំរូនោះ ពោលគឺ $M^e$, $G^e$, $T^e$, $I^e$ ជាដើម ។ ខ្លឹមសារនេះមានបង្ហាញនៅក្នុងរូបភាព 11.1 ។

**រូប ១១.២ ឧស្សាហ៍:បុរាណនិយមបែបថ្មីស្តីពីផលប៉ះពាល់នៃកំណើនការផ្គត់ផ្គង់រូបិយវត្ថុ**




នៅក្នុងគំរូនេះ គេសន្មតថាការផ្គត់ផ្គង់រូបិយវត្ថុមានការកើនឡើង ។ ប្រសិនបើគេរំពឹងគិតថានឹងមានកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ នោះការរំកិលនៃខ្សែកោងតម្រូវការសរុបពី $Y_1$ ទៅ $Y_{-0}$ នឹងត្រូវប៉ះប៉ូវបង្គ្រប់


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីព្រោះពលករនឹងមិនព្រមទទួលយកនូវប្រាក់បៀវត្សរូបិយវត្ថុនាពេលនេះ ហើយនឹងទាមទារប្រាក់បៀវត្សខ្ពស់ជាងនេះ ដែលធ្វើឱ្យខ្សែកោងការផ្គត់ផ្គង់កម្លាំងពលកម្មរំកិលពី ($N-1$ ទៅ $N_0$) ដើម្បីប៉ះប៉ូវនឹងការឡើងថ្លៃដែលគេបានរំពឹងទុក ។ ជាការឆ្លើយតប ខ្សែកោង ADC នឹងរំកិលត្រឡប់មកវិញពី $Y_0$ ទៅ $Y_1$ ហើយអ្វីដែលមានការប្រែប្រួលនោះ មានតែប្រាក់បៀវត្ស និង ថ្លៃ ដែលខ្ពស់ជាងមុន (ដោយប្រាក់បៀវត្សពិតនៅដដែល) ប៉ុន្តែមិនមានកំណើននៃធាតុចេញ Y នោះទេ ។

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើគេមិនបានរំពឹងទុកថានឹងមានកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុទេនោះ (ការភ្ញាក់ផ្អើលខាងផ្នែករូបិយវត្ថុ) នោះខ្សែកោង ADC នឹងរំកិលឡើងទៅខាងស្តាំ ពី $Y_1$ ទៅ $Y_2$ (រូបទី 11.2) ។ ប្រសិនគេមិនបានរំពឹងទុកទេនោះ នោះដំបូងពលករនឹងទទួលយកនូវប្រាក់បៀវត្សរូបិយវត្ថុ ហើយខ្សែកោងតម្រូវការកម្លាំងពលកម្មនឹងរំកិលពី $N^dP_0$ ទៅ $N^dP_1$ ក្នុងខណៈដែលថ្លៃកើនឡើង ។ ដូច្នេះក្នុងរយៈពេលខ្លី កំណើនការផ្គត់ផ្គង់រូបិយវត្ថុដែលមិនបានរំពឹងទុកនឹងមានឥទ្ធិពលទៅលើធាតុចេញ ។ ក៏ប៉ុន្តែនៅក្នុងរយៈពេលវែង នៅពេលដែលថ្លៃកើនឡើង ពលករចាប់ផ្តើមទាមទារប្រាក់បៀវត្សកាន់តែខ្ពស់ ហើយខ្សែកោងផ្គត់ផ្គង់នឹងរំកិលឡើងលើទៅខាងឆ្វេង ហើយនឹងមិនមានកំណើនធាតុចេញ នៅក្នុងរយៈពេលវែងទេ ប៉ុន្តែប្រាក់បៀវត្ស និង ថ្លៃនឹងកើនឡើង ។

ដូច្នេះ គំរូបូរាណនិយមបែបថ្មីខុសពីគំរូរបស់**កេនស៍** ចំពោះបន្លាស់ប្តូរដែលបានរំពឹងទុក ឬព្យាករណ៍ទុក ក៏ប៉ុន្តែ គ្មានបន្លាស់ប្តូរដែលមិនបានរំពឹងទុកឡើយ ។ គំរូបូរាណនិយមបែបថ្មីមិនខុសពីគំរូបូរាណនិយមនោះទេ ចំពោះបន្លាស់ប្តូរដែលបានរំពឹងទុក ប៉ុន្តែចំពោះបញ្ហាផ្សេងទៀត គំរូទាំងពីរនេះខុសគ្នា ដោយគ្មានការសន្មតអំពី «ចំណេះដឹងឥតខ្ចោះ» នោះទេ ពោលគឺ អ្វីដែលមិនបានរំពឹងទុកអាចបណ្តាលឱ្យធាតុចេញផ្លាស់ប្តូរបាន ។

## ៣. ផលវិបាកខាងផ្នែកគោលនយោបាយនៃការរំពឹងទុកប្រកបដោយវិចារណញ្ញាណ

ត្រង់ចំណុចនេះ នៅក្នុងគំរូបូរាណនិយមបែបថ្មី គេហាក់ដូចជាផ្តល់អនុសាសន៍ថា *«ប្រសិនបើរដ្ឋាភិបាលចង់កាច់ចង្កូតក្បាលម៉ាស៊ីនសេដ្ឋកិច្ច ត្រូវធ្វើដោយគ្មានការគ្រោងទុកមុន»* ។ ជាការពិតណាស់ គេមិនអាចធ្វើដូច្នេះបានក្នុងរយៈពេលវែងបានទេ ។ យើងលើកករណីនៃកំណើនដោយគ្មានការរំពឹងគិតជាមុននៃចំណាយរដ្ឋាភិបាលដើម្បីឆ្លើយតបទៅនឹងការធ្លាក់ចុះនៃវិនិយោគឯកជន (រូប 11.3a)។

ការផ្លាស់ប្តូរគោលនយោបាយដែលគ្រោងទុកជាមុន និង ដែលមិនបានគ្រោងទុកជាមុន នឹងមានផលប៉ះពាល់ខុសគ្នាឆ្ងាយណាស់ នៅពេលដែលការរំពឹងទុកទាំងអស់ត្រូវបានសន្មតថាប្រកបដោយវិចារណញ្ញាណ ។ ទីមួយ- យើងសន្មតថា ការផ្លាស់ប្តូរគោលនយោបាយត្រូវបានគេរំពឹងទុកមុន ពីព្រោះអ្នកធ្វើគោលនយោបាយបានប្រកាសថា នឹងមានការផ្លាស់ប្តូរនូវគោលនយោបាយ ។សាធារណជនអាចរំពឹងទុកជាមុនថា នឹងមានការផ្លាស់ប្តូរគោលនយោបាយ ពីព្រោះអ្នកនយោបាយតែងតែមានសកម្មភាពដែលគេអាចប៉ាន់ស្មានបាន ។ ឧទាហរណ៍ ប្រសិនបើអ្នកនយោបាយធ្លាប់ដែលបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ ដើម្បីដោះស្រាយបញ្ហានិកម្មភាព


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នោះសាធារណៈជនអាចរំពឹងគិតឃើញជាមុនថា នៅពេលដែលគេសង្កេតឃើញមាននិកម្មភាពច្រើន នោះរដ្ឋាភិបាលច្បាស់ជានឹងបង្កើនការផ្គត់ផ្គង់រូបិយវត្ថុជាមិនខាន ។

**រូប ១១.៣ ឧស្សន: បុរាណនិយមបែបថ្មីស្តីពីផលប៉ះពាល់នៃការធ្លាក់ចុះស្វយ័តនៃវិនិយោគ**




ការធ្លាក់ចុះដំបូងនៃការវិនិយោគ I បណ្តាលឱ្យខ្សែកោងតម្រូវការសរុប (ADC) រំកិលចុះទៅខាងឆ្វេង ។ បន្ទាប់មក ធាតុចេញ (Y) ក៏ធ្លាក់ចុះពី $Y_0$ ទៅ $Y_1$ ។ ថ្លៃ (P) ក៏ធ្លាក់ចុះពី $P_0$ ទៅ $P_1$ ។ នៅកម្រិតថ្លៃមួយដែលកាន់តែទាប តម្រូវការកម្លាំងពលកម្មក៏ធ្លាក់ចុះដែរ (រូប 11.3b)។ ឥទ្ធិពលបន្ថែមទៀត អាស្រ័យទៅលើថាតើការធ្លាក់ចុះនៃ I អាចត្រូវបានគេប៉ាន់ស្មានជាមុនបានឬទេ ។

## ៣.១. ការរំពឹងទុកជាមុន

ប្រសិនបើរំពឹងទុកជាមុន នោះពលករនឹងយល់ឃើញថាថ្លៃនឹងធ្លាក់ចុះ ដោយដឹងថាប្រាក់បៀវត្សរ៍បូបិយវត្ថុនៅក្នុងកម្រិតបច្ចុប្បន្ននឹងកើនឡើង ហើយការផ្គត់ផ្គង់កម្លាំងពលកម្មនឹងរំកិលចុះក្រោម ។ ប្រការនេះនឹងធ្វើឱ្យខ្សែកោងផ្គត់ផ្គង់សរុបរំកិលចុះ (រូបទី 11.3a) ហើយដែលនឹងធ្វើឱ្យថ្លៃធ្លាក់ចុះបន្ថែមទៀត រហូតដល់ចំណុចសមតាត្រូវបានកើតឡើងវិញនៅត្រង់ចំណុច $Y_0$ និង $N_0$ ។ ប្រសិនបើករណីបែបកើតមានឡើង នោះមិនចាំបាច់មានអន្តរាគមន៍ពីរដ្ឋាភិបាលឡើយ ។

## ៣.២. ការមិនបានរំពឹងទុកជាមុន

ប្រសិនបើការធ្លាក់ចុះនៃ I មិនត្រូវបានគេរំពឹងទុកជាមុនទេនោះ កម្លាំងពលកម្មមិនអាចរំពឹងទុកនូវការ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ធ្លាក់ចុះនៃថ្លៃ (P) បានឡើយ ហើយដូច្នេះនឹងមិនមានការកើនឡើងនៃការផ្គត់ផ្គង់កម្លាំងពលកម្ម ហើយខ្សែកោងផ្គត់ផ្គង់កម្លាំងពលកម្មនឹងមិនរំកិលទេ ពោលគឺខ្សែកោង $N^s$ នឹងស្ថិតនៅចំណុច $N^s$ ($I^e{}_0$) ដដែល ។ ចំណែកផលិតផលនឹងធ្លាក់ចុះទៅកាន់ចំណុច $Y_1$ ហើយអនិកម្មភាពនឹងធ្លាក់ទៅដល់ $N_1$។ នៅត្រង់ចំណុចនេះ រដ្ឋាភិបាលអាចធ្វើអន្តរាគមន៍ ។ ក៏ប៉ុន្តែ ប្រសិនបើគេបានរំពឹងទុកជាមុននូវសកម្មភាពរបស់រដ្ឋាភិបាល នោះវានឹងមានការយឺតយ៉ាវក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាល ពោលគឺ ការទទួលស្គាល់ ការរៀបចំ ការអនុវត្ត និង ផលប៉ះពាល់ ។ ក៏ប៉ុន្តែ ប្រសិនបើភ្នាក់ងារសេដ្ឋកិច្ចទាំងអស់រំពឹងគិតថា វិនិយោគនឹងសម្រេចបានក្នុងកម្រិតទាប នោះថ្លៃនឹងសម្រេចបានក្នុងកម្រិតមួយទាបដែរ ហើយការផ្គត់ផ្គង់កម្លាំងពលកម្មនឹងកើនឡើង (ដើម្បីឆ្លើយតបទៅនឹងប្រាក់បៀវត្សពិត ក្នុងកម្រិតមួយដែលខ្ពស់ជាង) ។ ខ្សែកោង ASC នឹងរំកិល ហើយការកែសម្រួលនឹងកើតឡើង ដោយមិនចាំបាច់មានអន្តរាគមន៍ពីរដ្ឋាភិបាល ។ ដូច្នេះ នៅក្នុងករណីនៃគំរូបុរាណនិយមបែបថ្មី រដ្ឋាភិបាលមិនត្រូវធ្វើអន្តរាគមន៍ខាងផ្នែករូបិយវត្ថុទេ ប៉ុន្តែរដ្ឋាភិបាលត្រូវអនុវត្តនូវគោលនយោបាយស្ថិរភាពរូប-នីយកម្មវិញ ពោលគឺត្រូវកំណត់នូវការរំពឹងទុកដ៏ច្បាស់លាស់នៃសកម្មភាពរបស់ខ្លួន ដើម្បីតួអង្គដទៃទៀតអាចមានប្រតិកម្មបាន ។

ក្នុងបរិបទនៃខ្សែកោង***ហ្វីលីព*** (Phillips Curve) យើងអាចជំនួសពាក្យ «***រាំងស្ទះ***» ដោយពាក្យ «***គោលនយោបាយរូបិយវត្ថុដោយពន្លឿន***» ។ ដោយសារគោលនយោបាយរូបិយវត្ថុដោយពន្លឿនមានលក្ខណៈជាប្រព័ន្ធ ដូច្នេះកម្មកររំពឹងទុកថា នឹងមានកើតឡើងនូវអតិផរណាយ៉ាងលឿនតាំងពីគ្រាដំបូងម្ល៉េះ ដែលធ្វើឱ្យគេមិនព្រមផ្គត់ផ្គង់កម្លាំងពលកម្មបន្ថែម ដើម្បីឆ្លើយតបទៅនឹងប្រាក់បៀវត្សរូបិយវត្ថុកម្រិតខ្ពស់មួយ ។ ពោលគឺ កម្លាំងពលកម្មនឹងមិនរំកិលឡើងលើតាមខ្សែកោង***ហ្វីលីព***រយៈពេលខ្លី ពីចំណុចដើម ($U = U^*$, $p = 0$) ឡើងទៅដល់ចំណុច a($U = U_1$, $\pi = \pi_1$)។ ក៏ប៉ុន្តែ វានឹងលោតផ្លោះឆ្ពោះទៅកាន់ចំណុច b($U = U^*$, $\pi = \pi_1$) តែម្តងនៅខ្សែកោង***ហ្វីលីព*** រយៈពេលវែង។ គេអាចនិយាយបានម្យ៉ាងទៀតថា រដ្ឋាភិបាលមិនអាចបញ្ចុះ អត្រានិកម្មភាពឱ្យទៅដល់ចំណុច $U_1$ ទេ ទោះបីជាក្នុងរយៈពេលបណ្តោះអាសន្នក៏ដោយ ។

ប្រការនេះពុំមានន័យថា និកម្មភាពមិនអាចធ្លាក់ចុះទាបជាង $U^*$ ដោយសារការពន្លឿនរូបិយវត្ថុនោះទេ ។ ក៏ប៉ុន្តែ ការពន្លឿននេះអាចកើតមានឡើង ដោយគ្មានលក្ខណៈជាប្រព័ន្ធ ឬ ដោយសារកត្តាចៃដន្យ ដែលធ្វើឱ្យភ្នាក់ងារមិនអាចធ្វើការរំពឹងទុកបាន ។ ក្នុងករណីនេះ ពួកគេមិនអាចមានការរំពឹងទុកអំពីអតិផរណាឱ្យបានត្រឹមត្រូវឡើយ ហើយភ្នាក់ងារពិតជាចង់ឱ្យនិកម្មភាពនេះរំកិលទៅចំណុច a($U = U_1$, $\pi = \pi_1$) ។ ក៏ប៉ុន្តែ ករណីនេះគ្រាន់តែជាសភាពការណ៍បណ្តោះអាសន្នប៉ុណ្ណោះ ។ នៅពេលដែលគេបានយល់យ៉ាងច្បាស់ថា មានអ្វីបានកើតឡើង នោះពួកគេនឹងចាកចេញពីទីផ្សារពលកម្មជាយថាហេតុ ហើយធ្វើឱ្យនិកម្មភាពវិលត្រឡប់ទៅកាន់ចំណុច $U^*$ វិញជាក់ជាមិនខានឡើយ ។ ដូច្នេះចំណុចសំខាន់នៃរឿងនេះ គឺថា មានតែការពន្លឿនរូបិយវត្ថុដែលកើតឡើយដោយចៃដន្យ និងមិនបានរំពឹងទុកទេ ដែលអាចធ្វើឱ្យនិកម្មភាពធ្លាក់ចុះនៅក្នុងរយៈពេលបណ្តោះអាសន្នបាន ។ ដូច្នេះ គោលនយោបាយរូបិយវត្ថុពន្លឿន ដែលមានលក្ខណៈជាប្រព័ន្ធ នឹងមិនអាចធ្វើឱ្យនិកម្មភាពធ្លាក់ចុះទាបបានឡើយ ។ ពោលគឺ គ្មានគោលនយោបាយអ្វី ដែលមានប្រសិទ្ធភាពអាចជំនួសខ្សែកោង***ហ្វីលីព*** រយៈពេលខ្លីបានឡើយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីធ្វើឱ្យសេចក្ដីសន្និដ្ឋានបែបនេះមានខ្លឹមសារ យើងចាំបាច់ត្រូវមានសម្មតិកម្មជាច្រើន ។ សម្មតិកម្មដ៏សំខាន់មួយ គឺ *ព័ត៌មានជាទូទៅត្រូវបានគេដឹង* ។ ប្រសិនបើរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយរូបិយវត្ថុពន្លឿនដោយអាចិកំបាំងទាំងស្រុង ភ្នាក់ងារអាចមិនដឹងថាគោលនយោបាយនេះមានលក្ខណៈជាប្រព័ន្ធ ហើយគេនឹងផ្គត់ផ្គង់កម្លាំងពលកម្មបន្ថែម ។ ក៏ប៉ុន្តែ ក្រុមបូរាណនិយមបែបថ្មីបានអះអាងថា អាចិកំបាំងមិនអាចរក្សាបានទាំងស្រុងនោះទេ ហើយកម្មករច្បាស់ជានឹងអាចយល់ដឹងថា ការពន្លឿនរូបិយវត្ថុនេះកើតឡើងដោយមានលក្ខណៈជាប្រព័ន្ធ។ ពោលគឺ តាមរយៈការតាមដានអំពីដំណើរនៃអតិផរណា គេអាចនឹងដឹងជាបណ្ដើរៗថា រដ្ឋាភិបាលកំពុងអនុវត្តនូវគោលនយោបាយពន្លឿនរូបិយវត្ថុជាប្រព័ន្ធ ។ ដូច្នេះ ពួកគេនឹងបញ្ចូលព័ត៌មាននេះទៅក្នុងការសម្រេចចិត្តរបស់ពួកគេ ហើយគេនឹងផ្លាស់ប្ដូរការរំពឹងទុករបស់គេទៅតាមនេះដែរ ។ ប្រការនេះនឹងធ្វើឱ្យគោលនយោបាយរបស់រដ្ឋាភិបាលមិនអាចសម្រេចបានដដែល ។

សម្មតិកម្មចាំបាច់ផ្សេងទៀតនោះគឺ *មិនមានកំហុសជាប្រព័ន្ធ* ឡើយ ។ មូលហេតុអ្វីបានជាភ្នាក់ងារមានភាពល្ងង់ខ្លៅ និង ខ្វះការពិចារណាដោយសមហេតុផល ហើយសន្មតថា គ្រោះរាំងស្ងួតដ៏ចៃដន្យនៅឆ្នាំនេះនឹងនាំឱ្យមានភាពរាំងស្ងួតនៅឆ្នាំក្រោយ? ជាការពិត ក្រុមបូរាណនិយមបែបថ្មីបានទទួលស្គាល់ថា មនុស្សអាចភ័ន្តច្រឡំ និង ខ្វះការពិចារណាគ្រប់ជ្រុងជ្រោយៈ ភ្នាក់ងារណាក៏ដោយក៏អាចធ្វើការសន្និដ្ឋានដ៏ចម្លែក យ៉ាងងាយស្រួល និង អាចមានកំហុសជាប្រព័ន្ធបាន ។ ក៏ប៉ុន្តែ ពួកគេអះអាងថា គ្រប់មនុស្សទាំងអស់មិនអាចមានកំហុសជាប្រព័ន្ធបានឡើយ ។ ដោយសារសេចក្ដីសន្និដ្ឋានត្រូវឈរលើមូលដ្ឋាននៃ ***«ចំនួនសរុប»*** កម្មករម្នាក់ៗអាចមានកំហុសជាប្រព័ន្ធ និង មានការភ័ន្តច្រឡំដែលជាលក្ខណៈបុគ្គល ។ ក៏ប៉ុន្តែ ដោយផ្អែកតាមការវិនិច្ឆ័យនៃច្បាប់ចំនួនច្រើន (The law of large numbers) នោះ ការភ័ន្តច្រឡំជាលក្ខណៈបុគ្គលទាំងនេះ នឹងត្រូវសាបរលាបទៅតាម ចំនួនភាគច្រើន។

ដូចដែល **លូកាស** (Lucas) **(១៩៧២-១៩៧៣)** **សារ៉ែន** (Sargent) **(១៩៧៣)** និង **សារ៉ែន** និង **វ៉ាឡេស** (Wallace) **(១៩៧៥-១៩៧៦)** បានបញ្ជាក់យ៉ាងច្បាស់ហើយថា ផលវិបាកខាងផ្នែកគោលនយោបាយនៃទ្រឹស្ដីរបស់ពួកបូរាណនិយមបែបថ្មី គឺ *គោលនយោបាយរូបិយវត្ថុដែលមានលក្ខណៈជាប្រព័ន្ធ មិនមានឥទ្ធិពលទៅលើផាតុចេញទេ* ។ មានតែគោលនយោបាយដែលធ្វើឱ្យមានភាពភ្ញាក់ផ្អើល ឬ ដោយមិនបានគ្រោងទុកទេ ទើបអាចមានឥទ្ធិពលទៅលើផាតុចេញ ។ ដោយចាប់ផ្ដើមចេញពីគំនិតរបស់ **ហ្វ្រីដម៉ែន** ដែលថា *«មានតែរូបិយវត្ថុដែលសំខាន់»* យើងបានឃើញនូវទស្សនរបស់ពួកបូរាណនិយមបែបថ្មី ដែលយល់ឃើញថា *«រូបិយវត្ថុមិនសំខាន់ទេ»* (ឬ ថា *«មានតែរូបិយវត្ថុភ្ញាក់ផ្អើលទេដែលសំខាន់»*) អីឡូវនេះ ការពិភាក្សាកាន់តែតម្រង់ទិសដៅទៅរកការជ្រុលនិយមកាន់តែខ្លាំង ។

ចំណុចសំខាន់នៃដំណើរការនេះ គឺការបកស្រាយឡើងវិញនៃខ្សែកោង**ហ្វីលីព** ថាជា «ខ្សែកោងផ្គត់ផ្គង់សរុប» ។ សូមរំលឹកឡើងវិញ នូវសមីការរូបិយវត្ថុសាមញ្ញ (ដែល $\beta = 1$:)÷


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

$\pi = h(U - U^*) + \pi^e$

យើងបានធ្វើការកែប្រែមួយចំនួន ដោយឆ្លុះបញ្ចាំងនូវទំនាក់ទំនងរវាងអតិផរណា និង និកម្មភាព និង អត្រាធម្មជាតិនៃនិកម្មភាព ($h'<0$)។ ច្បាប់**អូគុន** (Okun, 1962) អះអាងថា នៅពេលដែលធាតុចេញធ្លាក់ចុះ ៣% និកម្មភាពកើនឡើង ១% ។ ដូច្នេះ យើងអាចអះអាងថា និកម្មភាព និង ធាតុចេញមានទំនាក់ទំនងនឹងគ្នា។ ដូច្នេះ ធាតុចេញកាន់តែខ្ពស់ អនិកម្មភាពកើនឡើង ។ ក្នុងន័យនេះ យើងអាចរៀបចំរូបមន្តដែលឆ្លុះបញ្ចាំងនូវទំនាក់ទំនង **អូគុន** ដូចតទៅ÷

$U - U^* = g(Y - Y_F)$ ដែល $g' < 0$, និង ដែល $Y_F$ គឺជាធាតុចេញនៅក្នុងខណៈ ដែលអនិកម្មភាពពេញលេញបានកើតមានឡើង ។ ដូច្នេះ នៅពេលដែលធាតុចេញជាក់ស្តែង (Y) ស្ថិតនៅខ្ពស់ជាងធាតុចេញនៃអនិកម្មភាពពេញលេញ ($Y_F$) និកម្មភាពពិតប្រាកដ (U) ស្ថិតនៅលើអត្រានិកម្មភាពជាធម្មជាតិ ($U^*$)។ យើងអាចតាងគម្លាតនៃធាតុចេញ និង ធាតុចេញនៅខណៈមានអនិកម្មភាពពេញលេញ ដោយ $y = Y - Y_F$ ។ ជាលទ្ធផល ខ្សែកោង **ហ្វីលីព**អាចត្រូវបានគេសរសេរឡើងវិញដូចខាងក្រោម÷

$$(\pi - \pi^e) = h(g(y))$$

ដូច្នេះ ដោយយក $(h^\circ g)(y) = h(g(y))$, នោះយើងបាន

$$y = (h^\circ g)^{-1}(\pi - \pi^e)$$

ឬ យក $f = (h^\circ g)^{-1}$: យើងបាន $y = f\,(\pi - \pi^e)$

ដែល $f\,' > 0$ ។ យក $\pi = p - p_{-1}$ និង $\pi^e = p^e - p_{-1}$ ដូច្នេះ អនុគមន៍ខាងលើអាចសរសេរដូចខាងក្រោម÷

$$y = f\,(p - p^e)$$

ដើម្បីឱ្យធាតុចេញមានទំនាក់ទំនងជាវិជ្ជមានទៅនឹងភាពខុសគ្នារវាងថ្លៃ និង ថ្លៃរំពឹងទុក (ឬច្បាស់ជាងនេះទៀត គម្លាតនៃធាតុចេញជាក់ស្តែង Y ពីកម្រិតភាពធាតុចេញ នៅពេលមានអនិកម្មភាពពេញលេញ ($Y_F$) មានទំនាក់ទំនងជាវិជ្ជមានទៅនឹងគម្លាតនៃភាពខុសគ្នារវាងថ្លៃជាក់ស្តែង និងថ្លៃរំពឹងទុក) ។ អនុគមន៍ *«ការផ្គត់ផ្គង់សរុប»* នេះ (ជួនកាលត្រូវបានគេហៅថា *«អនុគមន៍ផ្គត់ផ្គង់របស់* ***លូកាស***) គឺជា ស្ពាបត្យកម្មចម្រុះរវាងទ្រឹស្តីរូបិយវត្ថុនិយម និង ទ្រឹស្តីបុរាណបែបថ្មី ដែលក្នុងនោះ សម្មតិកម្មនៃអត្រារួមជាធម្មជាតិ មានសារៈសំខាន់ខ្លាំងណាស់ ។ គួរកត់សម្គាល់ថា អត្រាធម្មជាតិលេចចេញ ជារូបរាងឡើងនៅពេលដែល $p = p^e$ (ក្នុងរយៈពេលវែង) ដូច្នេះ $y = 0$ មានន័យថា $Y = Y_F$ ។ សម្មតិកម្មស្តីពីការរំពឹងទុកប្រកបដោយវិចារណញ្ញាណ មានន័យថា÷


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

$p^e = p$ នៅគ្រប់ពេល ពោលគឺ $Y = Y_F$ នៅក្នុងរយៈពេលខ្លី និង រយៈពេលវែង ។

## ៤. ឧបករណ៍វិភាគការរំពឹងទុក

### ៤.១. អត្រាការប្រាក់ទីផ្សារ និង អត្រាការប្រាក់ពិត

ដើម្បីវិភាគហិរញ្ញវត្ថុ យើងត្រូវពិចារណាលើទស្សនទានពីរ គឺ ចំនួនតាមថ្លៃទីផ្សារ ដែលភាសាអង់គ្លេសថា Nominal និង ចំនួនពិត (Real) ។ ចំនួនតាមថ្លៃទីផ្សារ គឺជាចំនួន ដែលគណនាជារូបិយវត្ថុ តាមថ្លៃចរន្ត ពោលគឺជាថ្លៃនាពេលបច្ចុប្បន្ន ។ ចំណែកឯចំនួនពិត គឺជាចំនួន ដែលស្តែងចេញជាបរិមាណរូបសាស្ត្រ ដោយមិនគិតជារូបិយវត្ថុឡើយ ។ ឧទាហរណ៍ ធាតុចេញពិត គឺជាបរិមាណផលិតផល និង សេវាដែលផលិតបានក្នុងមួយឆ្នាំ ។ ធាតុចេញតាមថ្លៃទីផ្សារ គឺស្មើនឹងធាតុចេញពិត គុណនឹងថ្លៃទីផ្សារនៃទំនិញ និង សេវាទាំងនោះ ។ ជួនកាលយើងថាផលិតផលសរុបតាមថ្លៃទីផ្សារ គឺជាបរិមាណនៃផលិតផល និង សេវាផលិតនៅក្នុងប្រទេសក្នុងមួយឆ្នាំ គុណនឹងថ្លៃរបស់ទំនិញ និង សេវានៅក្នុងឆ្នាំនោះ ។ ចំណែកឯ ផលិតផលសរុបពិតមានន័យថា យើងត្រូវប្រើថ្លៃគ្រាគោល ពោលគឺថ្លៃទំនិញ និង សេវាក្នុងឆ្នាំមូលដ្ឋានណាមួយ ដើម្បីធ្វើអោយថ្លៃនៅថេរ ងាយស្រួលយើងវិភាគពីកំណើនបរិមាណនៃផលិតផល និង សេវា ពោលគឺ យើងដកចេញនូវអត្រាអតិផរណាពីការគិតគូរនេះ ។

**អត្រាការប្រាក់ទីផ្សារ** គឺជាអត្រាការប្រាក់ដែលយើងប្រើជាក់ស្តែង និង ដែលបោះផ្សាយនៅតាមទំព័រសារព័ត៌មាននានា ។ អត្រាការប្រាក់ត្រូវបានគណនាសម្រាប់រយៈពេលមួយឆ្នាំ ។ ឧទាហរណ៍ អត្រាការប្រាក់សម្រាប់ឆ្នាំ t គឺ $i_t$ ។ ប្រសិនបើយើងខ្ចីប្រាក់ពីធនាគារនៅឆ្នាំនេះ 1 ដុល្លារ ។ ឆ្នាំក្រោយយើងត្រូវសងធនាគារវិញ ទាំងដើម ទាំងការប្រាក់ ពោលគឺ $1 + i_t$ ។ ដោយប្រើប្រាស់នូវទស្សនទានការប្រាក់ និង ពេលវេលា 1 ដុល្លារ ឆ្នាំនេះត្រូវស្មើនឹង $1 + i_t$ នៅឆ្នាំក្រោយ ។

**អត្រាការប្រាក់ពិត** គឺជាអត្រាការប្រាក់ដែលស្តែងចេញតាមរយៈតម្លៃទំនិញមួយចំនួន ។ យើងតាងអត្រាការប្រាក់ពិតសម្រាប់ឆ្នាំ t គឺ $r_t$ ។ ប្រសិនបើយើងខ្ចីប្រាក់ពីធនាគារនៅឆ្នាំនេះ ដើម្បីទិញទំនិញមួយចំនួន ។ យើងត្រូវសងធនាគារវិញ ទាំងដើម ទាំងការប្រាក់ ពោលគឺ $1 + r_t$ គុណនឹងទំនិញមួយចំនួននៅឆ្នាំក្រោយ ។ ដូច្នេះ អត្រាការប្រាក់ពិតចង់សង្កត់ធ្ងន់លើថ្លៃទំនិញនៅឆ្នាំក្រោយ ។ ដូច្នេះយើងបាន៖

សមីការ (11.1) $$1 + r_t = (1 + i_t)(P_t/P^e_{t+1})$$ ដែល៖

$P^e_{t+1}$ គឺជាថ្លៃទំនិញដែលយើងរំពឹងនៅឆ្នាំក្រោយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រសិនបើយើងតាង $\pi^e_t$ គឺជាអត្រាអតិផរណានៅឆ្នាំក្រោយ ដែលជាកំណើនថ្លៃទំនិញនៅឆ្នាំក្រោយដោយប្រៀបធៀបនឹងថ្លៃនៅឆ្នាំនេះ យើងបាន÷

សមីការ (11.2) $\pi^e_t = (P^e_{t+1} - P_t)/P_t$ ដែលជាភាគរយនៃការឡើងថ្លៃទំនិញនៅឆ្នាំក្រោយ ។

ដោយយកសមីការ (11.2) ទៅជំនួសក្នុងសមីការ (11.1) យើងទទួលបាន÷

សមីការ (11.3) $1 + r_t = (1 + i_t)/(1 + \pi^e_t)$

### ៤.២. តម្លៃបច្ចុប្បន្នរំពឹងទុក

**តម្លៃបច្ចុប្បន្នរំពឹងទុក** នៃសេរីការទូទាត់អនាគត គឺជាតម្លៃនៅថ្ងៃនេះនៃសេរីការទូទាត់ដែលរំពឹងថានឹងទទួល ។ ទស្សនទាននេះត្រូវបានប្រើប្រាស់នៅក្នុងការគណនារកប្រាក់ចំណេញរបស់គម្រោងវិនិយោគ ។ ប្រសិនបើយើងគណនាឃើញថា ចំណូលដែលយើងរំពឹងទុកថានឹងបានទទួលពីគម្រោងក្នុងរយៈពេលខាងមុខ ដោយគិតតាមតម្លៃបច្ចុប្បន្ន មានចំនួនលើសពីចំណាយនាពេលបច្ចុប្បន្ននេះ នោះវិនិយោគិនអាចអនុវត្តគម្រោងនេះបាន ។

ដើម្បីរកតម្លៃបច្ចុប្បន្ននៃចំនួនមួយ **A** ដែលនឹងទទួលបាននៅឆ្នាំក្រោយ គឺយើងត្រូវយកចំនួន **A** ទៅគុណនឹងមេគុណ $1/(1 + i_t)$។

ដើម្បីរកតម្លៃបច្ចុប្បន្ននៃចំនួនមួយ **A** ដែលនឹងទទួលបាននៅពីឆ្នាំក្រោយ គឺយើងត្រូវយកចំនួន **A** ទៅគុណនឹងមេគុណ $1/(1 + i_t)(1 + i_{t+1})$។ ដូច្នេះ ប្រសិនបើយើងចង់រកសេរីនៃចំណូលដែលនឹងទទួលបាននោះ ÷

$$\$A_t = \$F_t + [1/(1+ i_t)]\ \$F_{t+1} + [1/(1+ i_t)(1+ i_{t+1})\$F_{t+2} + \ldots$$

ប្រសិនបើអត្រាការប្រាក់នៅថេររហូត នោះយើងនឹងទទួលបានរូបមន្តរួមដូចតទៅ÷

$$\$A_t = \$F_t\ [1 + 1/(1 + i_t)+\ldots +1/(1+ i_t)^{n-1}]$$

$$\$A_t = \$F_t\ [\{1-[1/(1+ i_t)^n ]\}/ \{1-[1/(1 + i_t)]\}]$$

ក៏ប៉ុន្តែ យើងឃើញថា អត្រាប្តូប្រាក់នឹងមិនថេរទេ ដោយសារវានឹងប្រែប្រួលនៅឆ្នាំមុខ ។ ដូច្នេះ អត្រាប្តូរ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាក់នេះ គឺជាអត្រាប្ដូរប្រាក់រំពឹងទុក ហើយដោយជំនួសសមីការនេះ យើងទទួលបាន៖

$$\$A_t = \$F_t + [1/(1+i_t)]\ \$F^e_{t+1} + [1/(1+i_t)(1+i^e_{t+1})\$F^e_{t+2} + \ldots$$

## ៥. ការអនុវត្តទ្រឹស្ដីនៃការរំពឹងទុកចំពោះទីផ្សារហិរញ្ញវត្ថុ

### ៥.១. សញ្ញាប័ណ្ណ

សញ្ញាប័ណ្ណគឺជាឧបករណ៍ហិរញ្ញវត្ថុ ដែលមានលក្ខណៈពិសេសដូចតទៅ៖

- **ហានិភ័យក្ស័យធន**៖ គឺជាហានិភ័យដែលអ្នកបោះផ្សាយសញ្ញាប័ណ្ណមិនមានលទ្ធភាពក្នុងការសងទាំងស្រុងនូវទឹកប្រាក់នៃសញ្ញាប័ណ្ណ ។

- **កាលកំណត់**៖ រយៈពេលដែលត្រូវសងដល់អ្នកទិញសញ្ញាប័ណ្ណ ដូចជារយៈពេល ៦ ខែ ១ ឆ្នាំ ៥ ឆ្នាំ ១០ ឆ្នាំ ឬ ៣០ ឆ្នាំ ជាដើម ។

សញ្ញាប័ណ្ណនីមួយៗមានថ្លៃ និង ការប្រាក់របស់វា ដែលហៅថា **ទិន្នផលតាមកាលកំណត់** ឬ ទិន្នផល ។ ដោយសារមានទំនាក់ទំនងរវាងទិន្នផល និង កាលកំណត់ផ្សេងៗនៃសញ្ញាប័ណ្ណ យើងអាចគូសខ្សែកោងមួយ ដែលឆ្លុះបញ្ចាំងនូវទំនាក់ទំនងរវាងទិន្នផល និង កាលកំណត់នេះ ដែលមានឈ្មោះថា **ខ្សែកោងទិន្នផល** ។

#### ៥.១.១. ថ្លៃនៃសញ្ញាប័ណ្ណ

ការគណនាថ្លៃសញ្ញាប័ណ្ណមានការពាក់ព័ន្ធជាមួយនឹងតម្លៃបច្ចុប្បន្ន ។ ថ្លៃនៃសញ្ញាប័ណ្ណមានទំនាក់ទំនងជាមួយនឹងប្រាក់ដើមដែលត្រូវសង គឺចំនួន \$100 និង ការប្រាក់ដែលត្រូវទទួល $i_t$÷

ថ្លៃនៃសញ្ញាប័ណ្ណ ដែលមានកាលកំណត់ ១ ឆ្នាំ គឺ÷ $\$P_{1t} = \$100/(1+i_{1t})$ (11.1)

ថ្លៃនៃសញ្ញាប័ណ្ណ ដែលមានកាលកំណត់ ២ ឆ្នាំ គឺ÷ $\$P_{2t} = \$100/(1+i_{1t})\ (1+i^e_{t+1})$ (11.2)

#### ៥.១.២. មជ្ឈត្តការរវាងសញ្ញាប័ណ្ណផ្សេងគ្នា និង ថ្លៃនៃសញ្ញាប័ណ្ណ

យើងអាចធ្វើមជ្ឈត្តការ (Arbitrage) ថា តើគួរវិនិយោគលើសញ្ញាប័ណ្ណ ១ ឆ្នាំ ឬ ២ ឆ្នាំ។ ប្រសិនបើយើងវិនិយោគ 1\$ នៅក្នុងសញ្ញាប័ណ្ណមួយឆ្នាំ នោះយើងនឹងទទួលបាន $(1+i_{1t})$ ។ ដោយថ្លៃនៃសញ្ញាប័ណ្ណពីរឆ្នាំ គឺ $\$P_{2t}$ នោះ ប្រាក់ 1\$ ដែលយើងវិនិយោគនៅក្នុងសញ្ញាប័ណ្ណពីរឆ្នាំ យើងនឹងទទួល $\$1/\$P_{2t}$

នៅថ្ងៃនេះ។ លុះដល់ឆ្នាំក្រោយ សញ្ញាប័ណ្ណនៅសល់តែមួយឆ្នាំទៀត តែប៉ុណ្ណោះ ហើយវានឹងក្លាយជាសញ្ញាប័ណ្ណមួយឆ្នាំ ។ ដូច្នេះ យើងអាចលក់សញ្ញាប័ណ្ណនេះឆ្នាំក្រោយតាមថ្លៃ÷ $\$P^e_{1t+1}$ ដែលជាថ្លៃរំពឹងទុកសម្រាប់សញ្ញាប័ណ្ណមួយឆ្នាំ ។ ដូច្នេះ ប្រសិនបើយើងវិនិយោគ 1$ ក្នុងសញ្ញាប័ណ្ណពីរឆ្នាំ នៅឆ្នាំក្រោយយើងនឹងទទួលបាន $(\$P^e_{1t+1} / \$P_{2t})$ ។

ប្រសិនបើសញ្ញាប័ណ្ណទាំងពីរផ្តល់នូវចំណូលដូចគ្នាក្នុងមួយឆ្នាំ នោះយើងនឹងបាន ÷

$$(1+ i_{1t}) = \$P^e_{1t+1} / \$P_{2t} \qquad (11.3)$$

សមីការខាងឆ្វេង គឺចំណូលពីប្រាក់ 1$ ក្នុងការវិនិយោគលើសញ្ញាប័ណ្ណមួយឆ្នាំ ហើយសមីការខាងស្តាំ គឺចំណូលរំពឹងទុកពីការវិនិយោគលើសញ្ញាប័ណ្ណពីរឆ្នាំ ក្នុងរយៈពេលមួយឆ្នាំ ។

យើងអាចសរសេរឡើងវិញនូវសមីការ (11.3) ខាងលើ ÷

$$\$P_{2t} = \$P^e_{1t+1} / (1+ i_{1t}) \qquad (11.4)$$

ប្រសិនសរសេរឡើងវិញនូវសមីការ (11.1) ឡើងវិញសម្រាប់ឆ្នាំក្រោយ ដោយរំលេចអោយឃើញនូវការរំពឹងទុក នោះយើងបាន÷

$$\$P^e_{1t+1} = \$100/ (1+ i^e_{1t+1})$$

ប្រសិនបើយើងជំនួស $\$P^e_{1t+1}$ នៅក្នុងសមីការ (11.4) យើងបាន÷

$$\$P_{2t} = \$100/ (1+ i_{1t})(1+ i^e_{1t+1}) \qquad (11.5)$$

### ៥.១.៣. ទិន្នផលនៃសញ្ញាប័ណ្ណ

**ទិន្នផលតាមកាលកំណត់** ឬ **ទិន្នផល**នៃសញ្ញាប័ណ្ណរយៈពេល n ឆ្នាំ ឬ អាចហៅថាជា **អត្រាការប្រាក់ចំនួន** n **ឆ្នាំ** គឺជា អត្រាការប្រាក់ថេរប្រចាំឆ្នាំ ដែលធ្វើអោយថ្លៃសញ្ញាប័ណ្ណថ្ងៃនេះស្មើនឹងការទូទាត់នាពេលអនាគតនៃសញ្ញាប័ណ្ណ ។ ដូច្នេះយើងបាន÷

$$\$P_{2t} = \$100/ (1+ i_{2t})^2 \qquad (11.6)$$

ឧទាហរណ៍សញ្ញាប័ណ្ណនេះលក់ថ្លៃ នៅថ្ងៃនេះ ដូច្នេះយើងបាន÷


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

$\$90 = \$100/ (1+ i_{2t})^2 =>$

$(1+ i_{2t})^2 = \$100/\$90 =>$

$(1+ i_{2t}) = \sqrt{\$100/\$90} =>$

$i_{2t} = 5.4\%$

យើងអាចរកទំនាក់ទំនងរវាងអត្រាការប្រាក់ពីរឆ្នាំ និង អត្រាការប្រាក់មួយឆ្នាំ ដោយប្រៀបធៀបសមីការ (11.6) ជាមួយសមីការ (11.5) តាមរយៈការលប់ចោលនូវអញ្ញត្តិ $\$P_{2t}$ ដូចខាងក្រោម÷

$$\$100/ (1+ i_{2t})^2 = \$100/ (1+ i_{1t}) (1+ i^e_{1t+1})$$

$$(1+ i_{2t})^2 = (1+ i_{1t}) (1+ i^e_{1t+1})$$

យើងបាន÷

$$i_{2t} = 1/2 (i_{1t} + i^e_{1t+1}) \quad (11.7)$$

សមីការ (11.7) មានន័យថា អត្រាការប្រាក់ពីឆ្នាំ គឺជាចំនួនមធ្យមភាគនៃអត្រាការប្រាក់មួយឆ្នាំបច្ចុប្បន្ន និង អត្រាការប្រាក់មួយឆ្នាំ នៅឆ្នាំក្រោយ ។ ប្រសិនបើយើងប្រើសមីការនេះដើម្បីរកអត្រាការប្រាក់របស់សញ្ញាប័ណ្ណច្រើនឆ្នាំ នោះយើងនឹងបាននូវសមីការ ដែលបង្ហាញអោយឃើញថា អត្រាការប្រាក់ n ឆ្នាំស្មើនឹងមធ្យមភាគនៃអត្រាការប្រាក់មួយឆ្នាំនាពេលបច្ចុប្បន្ន និង មួយឆ្នាំរំពឹងទុក នៅក្នុងរយៈពេលឆ្នាំនេះ និង ឆ្នាំ (n+1) ខាងមុខ÷

$$i_{nt} = 1/n (i_{1t} + i^e_{1t+1} + \ldots + i^e_{1t+n-1})$$

យើងអាចសន្និដ្ឋានបានថា ខ្សែកោងទិន្នផលដែលមានមេគុណឡើងលើ មានន័យថា ទីផ្សារហិរញ្ញវត្ថុនឹងរំពឹងថា អត្រាការប្រាក់រយៈពេលខ្លីនឹងកើនឡើងនាពេលអនាគត ។ ដូចគ្នានេះដែរ ខ្សែកោងទិន្នផលដែលមានមេគុណចុះក្រោម មានន័យថា ទីផ្សារហិរញ្ញវត្ថុនឹងរំពឹងថា អត្រាការប្រាក់រយៈពេលខ្លីនឹងធ្លាក់ចុះនាពេលខាងមុខ ។ ប្រសិនបើយើងគុណសមីការ (11.7) នឹងចំនួន 2 យើងបាន÷

$$i^e_{1t+1} = 2i_{2t} - i_{1t} \quad (11.8)$$


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ១២

# ជញ្ជីងទូទាត់

## ១- ទស្សនទានទូទៅ

ការវាស់វែង និង ការវាយតម្លៃស្ថានភាពខាងក្រៅរបស់ប្រទេស គឺជាផ្នែកមួយយ៉ាងសំខាន់នៃការវិភាគម៉ាក្រូសេដ្ឋកិច្ច ។ ជញ្ជីងទូទាត់កត់ត្រានូវសកម្មភាពនៃការទូទាត់ និង ការទទួលធនធានពីអនិវាសនជន ។ យើងអាចអោយនិយមន័យ ***ជញ្ជីងទូទាត់*** ថាជា «***តារាងតុល្យការនៃការទូទាត់របស់សេដ្ឋកិច្ចជាតិជាមួយនឹងបរទេស***» ។ ជញ្ជីងទូទាត់ត្រូវបានកត់ត្រាដោយឈរលើមូលដ្ឋាននៃប្រព័ន្ធគណនេយ្យទ្វេរភាគ ។ ទស្សនទានសំខាន់ៗនៃជញ្ជីងទូទាត់ គឺ៖

- ***ការទូទាត់ក្នុងវិស័យពិត និង ក្នុងវិស័យហិរញ្ញវត្ថុ*** – ការទូទាត់ក្នុងវិស័យពិត គឺ ការទូទាត់ពាក់ព័ន្ធនឹងទំនិញ និង សេវា (ប្រតិបត្តិការនាំចេញ និង នាំចូល ការធ្វើដំណើរ និង ការដឹកជញ្ជូនជើងទឹក) ។ ការទូទាត់ក្នុងវិស័យហិរញ្ញវត្ថុ ធ្វើអោយមានបម្រែបម្រួលនៃទ្រព្យសកម្ម និង ទ្រព្យអកម្ម (ការសងដើមកម្ចីធ្វើអោយទ្រព្យអកម្មថយចុះ) ។ ការទូទាត់ក្នុងវិស័យពិតត្រូវបានកត់ត្រានៅក្នុងគណនីចរន្ត ហើយការទូទាត់ក្នុងវិស័យហិរញ្ញវត្ថុត្រូវបានកត់ត្រាទុកក្នុងគណនីមូលធន និង ហិរញ្ញវត្ថុ ។

- ***ការផ្ទេរ*** – គឺជាប្រតិបត្តិការជាឯកតោភាគីឆ្លងកាត់ព្រំដែន ។ ធនធានសម្រាប់ហិរញ្ញប្បទានទ្វេរភាគី ឬ ពហុភាគីត្រូវបានកត់ត្រាទុកក្នុងការផ្ទេរ ។ អំណោយជាសម្ភារៈ ដែលគ្មានការទូទាត់សងជាសាច់ប្រាក់ គឺជាការផ្ទេរ ។ ប្រតិបត្តិការនេះត្រូវកត់ត្រាជាការនាំចូលទំនិញ និង កត់ត្រាម្ខាងទៀតនៅក្នុងការផ្ទេរ ដើម្បីអោយសមស្របតាមគោលការណ៍នៃគណនេយ្យទ្វេរភាគ ។ ការផ្ទេរត្រូវបានចែកជាការផ្ទេរចរន្ត ដូចជាការផ្ទេរសាច់ប្រាក់ អំណោយជាសម្ភារៈ (ដូចជាថ្នាំពេទ្យ ឬ ម្ហូបអាហារ) វិភាគទានសម្រាប់អង្គការអន្តរជាតិ និង ប្រាក់ចំណូលដែលពលករផ្ទេរពីបរទេស ។ ការផ្ទេរជាមូលធន មានរូបភាព ជាសាច់ប្រាក់ (ជំនួយឥតសំណងសម្រាប់វិនិយោគ) ឬ ជាសម្ភារៈ (ការលប់បំណុលចោល) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២- សមាសធាតុនៃជញ្ជីងទូទាត់

ជញ្ជីងទូទាត់ត្រូវបានចែកចេញជាជញ្ជីងទូទាត់ចរន្ត និង ជញ្ជីងទូទាត់មូលធន ។

### ២.១- គណនីចរន្ត

#### ២.១.១. សមាសភាពនៃគណនីចរន្ត

គណនីចរន្តមានសមាសភាពដូចតទៅ÷

***ក- គណនីទំនិញ និង សេវា*** (ប្រតិបត្តិការនាំចេញ និង នាំចូល) និង សេវា (ដឹកជញ្ជូន ការធ្វើដំណើរ សេវារដ្ឋ ការធានារ៉ាប់រង សេវាហិរញ្ញវត្ថុ កុងស៊ុងតង់ និង សេវាដទៃទៀត) ។

***ខ- គណនីប្រាក់ចំណូល*** ដែលចែកចេញជា ប្រាក់បំណាច់បុគ្គលិក (ប្រាក់បៀវត្សដែលត្រូវផ្ទេរអោយបុគ្គលិកដែលរស់នៅបរទេស) និង ចំណូលវិនិយោគ (ការសងការប្រាក់លើបំណុលបរទេស) ។

***គ- គណនីការផ្ទេរចរន្ត*** ដែលចែកចេញជា ការផ្ទេរឯកជន (ប្រាក់ចំណូលរបស់ពលករពីបរទេស និង អំណោយឯកជន) និង ការផ្ទេរសាធារណៈ (ជំនួយសាធារណៈ) ។

#### ២.១.២. ការវិភាគគណនីចរន្ត

យើងបានពិភាក្សានៅក្នុងជំពូកទី ១ ពីរូបមន្ត និង ទំនាក់ទំនងរវាងជញ្ជីងទូទាត់ ចំណូលសរុប និង ចំណាយសរុបនៃសេដ្ឋកិច្ចជាតិ ឬ សមត្ថភាពស្រូប ដូចមានសមីការខាងក្រោម÷

$$S - I = (X\text{-}M) + Y_f + Tr_f = CAB \qquad (12.1)$$

សមីការ **(3)** នេះ បង្ហាញអោយឃើញថា គម្លាតរវាងសញ្ច័យជាតិ និង វិនិយោគនៅក្នុងសេដ្ឋកិច្ចជាតិ ស្មើនឹង ***តុល្យភាពគណនីចរន្តនៃជញ្ជីងទូទាត់*** ។ ការប្រែប្រួលនៃស្ថានភាពគណនីចរន្ត ដូចជាការកើនឡើងនៃអតិរេក ឬ ការថយចុះនៃឱនភាព តម្រូវអោយសញ្ច័យជាតិកើនឡើង បើប្រៀបធៀបជាមួយនឹងវិនិយោគ ។

គណនីចរន្តនៃជញ្ជីងទូទាត់ក៏ឆ្លុះបញ្ចាំងផងដែរនូវគម្លាតរវាងប្រាក់ចំណូល និង សមត្ថភាពស្រូបនៃសេដ្ឋកិច្ចជាតិ ។

**GNDI—A = CAB** **(12.2)**

សមីការ **(2.2)** បង្ហាញអោយឃើញថា ដើម្បីកែលម្អតុល្យភាពនៃគណនីចរន្ត គេត្រូវបញ្ចេញធនធាន ឬ មួយតាមរយៈការកាត់បន្ថយសមត្ថភាពស្រូបក្នុងស្រុក ដោយប្រៀបធៀបនឹងប្រាក់ចំណូល ឬមួយតាមរយៈការកើនឡើងនូវប្រាក់ចំណូលជាតិ ។

ម៉្យាងវិញទៀត តុល្យភាពគណនីចរន្តតែងតែស្មើនឹង ការផ្លាស់ប្តូរទ្រព្យសកម្មសុទ្ធនៃស្ថាប័នពុំមែនធនាគារ ឬ លំហូរហិរញ្ញវត្ថុដែលមិនមែនជារូបិយវត្ថុ ($\Delta FI$) និង ការផ្លាស់ប្តូរទ្រព្យសកម្មបរទេសសុទ្ធនៃប្រព័ន្ធធនាគារ ឬ លំហូរហិរញ្ញវត្ថុជារូបិយវត្ថុ ($\Delta RES$) ។ ក្នុងន័យនេះ យើងអាចសរសេរសមីការដូចខាងក្រោម ÷

$$CAB = \Delta FI + \Delta RES$$

ឬ

$$CAB + \Delta FI + \Delta RES = 0 \qquad \textbf{(12.3)}$$

## ២.២- គណនីមូលធន និង ហិរញ្ញវត្ថុ

### ២.២.១. សមាសភាពនៃគណនីមូលធន និង ហិរញ្ញវត្ថុ

គណនីមូលធន និង ហិរញ្ញវត្ថុ រួមមាន ÷

***ក- គណនីមូលធន*** ការផ្ទេរជាមូលធន និង ការទិញ និង ការលក់នូវទ្រព្យសកម្មពុំមែនផលិតកម្ម និង មិនមែនហិរញ្ញវត្ថុ ។

***ខ- គណនីហិរញ្ញវត្ថុ*** ដែលចែកចេញជា ÷

- ***វិនិយោគដោយផ្ទាល់***: ដែលចែកចេញជា មូលធនជាភាគហ៊ុន ការយកភាគលាភទៅវិនិយោគថែមទៀត និង មូលធនឯទៀត ។ វិនិយោគដោយផ្ទាល់ គឺការវិនិយោគនៅក្នុងសេដ្ឋកិច្ចជាតិ ដោយនិវាសនជននៅឯបរទេស និង ដោយអនិវាសនជន ។

- ***វិនិយោគក្នុងភាគហ៊ុន***: ដែលចែកចេញជា បំណុលរយៈពេលវែង ភាគហ៊ុន មូលប័ត្រ ឧបករណ៍បំណុលនៃទីផ្សាររូបិយវត្ថុ ដេរីវាទីវហិរញ្ញវត្ថុដែលអាចជួញដូរបាន រួមទាំង ឧបករណ៍ ស្វប់រូបិយវត្ថុ និង អត្រាប្តូរប្រាក់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ***វិនិយោគផ្សេងទៀត***: ដែលចែកចេញជា ឥណទានពាណិជ្ជកម្ម និង កម្ចី រួមទាំងកម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

- ***ទ្រព្យសកម្មបម្រុង***: ដែលទុកសម្រាប់បំពេញសេចក្តីត្រូវការចាំបាច់ភ្លាមៗ ។ សម្រាប់គណនាជញ្ជីងទូទាត់ទ្រព្យសកម្មបម្រុងត្រូវបានដាក់បញ្ចូលក្នុងគណនីជញ្ជីងទូទាត់ ក្នុងរូបភាពជាលំហូរនៃការផ្លាស់ប្តូរនៃទុនបម្រុងអន្តរជាតិដុល ។ ទ្រព្យសកម្មទាំងនេះរួមបញ្ចូលទាំងរូបិយប័ណ្ណ (រូបិយវត្ថុ ប្រាក់បញ្ញើ និង មូលបត្រ) មាសដ៏អេសដេអ៊ែ និង ទុនបម្រុងរបស់ប្រទេសនៅក្នុងមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ទុនបម្រុងដែលធនាគារកណ្តាលគ្រប់គ្រងអាចយកទៅប្រើប្រាស់ដោយផ្ទាល់ (ដើម្បីធ្វើហិរញ្ញប្បទានអតុល្យភាព) ឬ ដោយប្រយោល (ដើម្បីធ្វើនិយ័តកម្មពាក់ព័ន្ធនឹងអតុល្យភាព តាមរយៈប្រតិបត្តិការទិញ- លក់រូបិយប័ណ្ណនៅលើទីផ្សារប្តូរប្រាក់ ដើម្បីទ្រទ្រង់អត្រាប្តូរប្រាក់) ។

## ២.២.២. គណនីមូលធន និង ហិរញ្ញវត្ថុ និង បំណុលក្រៅប្រទេស

ឱនភាពគណនីចរន្តត្រូវធ្វើហិរញ្ញប្បទាន ដោយកំណើននៃទ្រព្យអកម្មបរទេស ឬ ការថយចុះនៃទ្រព្យសកម្មបរទេស ។ លំហូរហិរញ្ញវត្ថុនេះ គឺជាគណនីមូលធន និង គណនីហិរញ្ញវត្ថុនៃជញ្ជីងទូទាត់ ។

គណនីមូលធន និង គណនីហិរញ្ញវត្ថុកត់ត្រានូវកម្ចីពីបរទេសសុទ្ធ និង ការផ្ទេរមូលធនរបស់ប្រទេស ។ ***លំហូរហិរញ្ញវត្ថុមិនមែនជារូបិយវត្ថុ*** នៅក្នុងគណនី ($\Delta FI$) គឺជាផលបូកនៃវិនិយោគទុនពីបរទេសដោយផ្ទាល់ ($FDI$) និង កម្ចីពីបរទេសសុទ្ធ ($NFB$) ហើយ ដោយបូកជាមួយ ហិរញ្ញប្បទានជារូបិយវត្ថុ ($\Delta RES$) ស្មើនឹងតុល្យភាពគណនីចរន្ត ។ ដូច្នេះ ប្រភពនៃហិរញ្ញប្បទានសម្រាប់គណនីចរន្ត អាចសរសេរបានថាជា៖

$$\text{CAB} + FDI + NFD + \Delta RES = \mathbf{0}$$

លំហូរហិរញ្ញវត្ថុដើម្បីធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្ត នឹងនាំអោយមានការធ្លាក់ចុះនៃទ្រព្យសកម្មបរទេសសុទ្ធនៃសេដ្ឋកិច្ចជាតិ ។ ដូច្នេះ បញ្ហាសំខាន់ពាក់ព័ន្ធនឹងដំណោះស្រាយឱនភាពគណនីចរន្ត គឺស្ថិតនៅត្រង់ចំណុចដែលថា តើរដ្ឋាភិបាលអាចដោះស្រាយនូវបញ្ហាដែលពាក់ព័ន្ធនឹងបម្រែបម្រួលនៃវិនិយោគបរទេសសុទ្ធ ដោយមិនចាំបាច់អោយមានការផ្លាស់ប្តូរគោលនយោបាយ ពោលគឺដោយមិនចាំបាច់កាត់បន្ថយចំណាយសរុបនៃសេដ្ឋកិច្ច ឬ សមត្ថភាពស្រូប (A=C+I) ឬ ដោយផ្លាស់ប្តូរអត្រាការប្រាក់ ឬ អត្រាប្តូរប្រាក់ ។ ជារួម ប្រសិនបើលំហូរមូលធនត្រូវបានយកទៅប្រើប្រាស់សម្រាប់បង្កើនសមត្ថភាពផលិតរបស់សេដ្ឋកិច្ច នោះការធ្វើសេវាបំណុលក៏មានសភាពងាយស្រួលដែរ ។ ប្រសិនបើគ្មានលំហូរមូលធនពីបរទេសទេ រដ្ឋាភិបាលត្រូវតែកែសម្រួលគោល-


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នយោបាយ ដើម្បីទាក់ទាញវិនិយោគឯកជន ឬ ត្រូវរកកម្ចីពីបរទេស ។ ពុំនោះសោត ទុនបម្រុងបរទេសនឹងត្រូវធ្លាក់ចុះជាមិនខាន ឬ មួយសេដ្ឋកិច្ចនឹងត្រូវបង្ខំចិត្តកាត់បន្ថយនូវសមត្ថភាពស្រូបជាមិនខាន ។

នៅក្នុងគណនីមូលធន និង ហិរញ្ញវត្ថុ លំហូរភាគច្រើន គឺជាការបង្កើតអោយមានបំណុល ។ ដូច្នេះលំហូរដែលកត់ត្រានៅក្នុងគណនីមូលធន និង ហិរញ្ញវត្ថុមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបំណុល ដូចសមីការនេះ÷

$$D_t = D_{t-1} + B_t - A_t \qquad \textbf{(12.4)}$$

ដែល

$D_t$ = ស្តុកនៃបំណុលចាស់ និង កម្ចីបើកផ្តល់ថ្មីនៅចុងឆ្នាំ

$B_t$ = ការបើកផ្តល់កម្ចីថ្មីនៅក្នុងរយៈពេល $t$

$A_t$ = ការសងប្រាក់ដើម នៅក្នុងរយៈពេល $t$

សមីការ **(12.4)** នេះមានន័យថា បំណុលនៅចុងឆ្នាំនេះ ស្មើនឹងបំណុលនៅចុងឆ្នាំមុន បូកនឹងលំហូរសុទ្ធដែលបង្កើតអោយមានបំណុល ពោលគឺការបើកផ្តល់កម្ចីថ្មី ដកចេញនូវការសងប្រាក់ដើម ។

នៅពេលដែលវិនិយោគិនទិញភាគហ៊ុននៅក្នុងសហគ្រាសក្នុងស្រុក ឬ បង្កើតសហគ្រាសថ្មី សកម្មភាពនេះមិនបណ្តាលអោយមានកាតព្វកិច្ចជាកិច្ចសន្យាទេ ។ វិនិយោគផ្ទាល់ពីបរទេស គឺជាលំហូរមូលធនដែលមិនបង្កើតបំណុល ដោយសារវិនិយោគផ្ទាល់ពីបរទេសមិនបានបង្កើនបំណុលទេ ។ ទន្ទឹមនឹងនេះ វិនិយោគផ្ទាល់ពីបរទេសនាំមកនូវបច្ចេកវិទ្យា និង បទពិសោធន៍គ្រប់គ្រងថែមទៀត ។

ផ្ទុយទៅវិញ វិនិយោគជា *Portfolio* បង្កើតអោយមានបំណុល ដូចជា សញ្ញាប័ណ្ណ ភាគហ៊ុន ឬ មូលប័ត្រផ្សេងៗ ។ ប្រការនេះ ក៏ឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់វិនិយោគិន មកលើទីផ្សារហិរញ្ញវត្ថុរបស់ប្រទេសផងដែរ ដែលបង្កលក្ខណៈងាយស្រួល អោយរដ្ឋាភិបាល ឬ ផ្នែកឯកជនក្នុងស្រុកអាចរកមូលធននៅលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិបាន។

### ២.២.៣. តួនាទីរបស់ទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិមានតួនាទីសំខាន់ ជាប្រភពហិរញ្ញប្បទាននៃឱនភាពជញ្ជីងទូទាត់ និង គាំទ្រដល់អត្រាប្តូរប្រាក់ ។ ក្នុងបរិបទនៃអត្រាប្តូរប្រាក់អណ្តែត (floating) អាជ្ញាធររូបិយវត្ថុអាចប្រើប្រាស់គោលនយោបាយដទៃទៀត ដើម្បី


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ធ្វើហិរញ្ញប្បទានឱនភាព ដូចជា កម្ចីពីបរទេស ឬ ការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ និង ហិរញ្ញវត្ថុសាធារណៈ។ ដូច្នេះ ទុនបម្រុងអន្តរជាតិមិនមែនមានតួនាទីត្រឹមតែធ្វើហិរញ្ញប្បទានឱនភាពជញ្ជីងទូទាត់ប៉ុណ្ណោះទេ ។ ការបង្កើនទុនបម្រុងអន្តរជាតិ គឺ សម្រាប់ធ្វើអោយមានទំនុកចិត្តលើរូបិយវត្ថុជាតិ និង លើសេដ្ឋកិច្ចជាតិ បំពេញនូវតម្រូវការខាងផ្នែកគតិយុត្តិ ឬ សម្រាប់ជាមូលដ្ឋានដើម្បីស្វែងរកកម្ចីសម្រាប់យកមកអភិវឌ្ឍ ។ ជារួម ការប្រើប្រាស់ទុនបម្រុងអន្តរជាតិ ដើម្បីយកទៅធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្ត ជាជាងការផ្លាស់ប្តូរគោលនយោបាយ អាចធ្វើទៅបានប្រសិនបើឱនភាពនេះ មានចរិតបណ្តោះអាសន្ន ឬ អាចកែតម្រូវបានឡើងវិញ ឬ មួយក៏ក្នុងករណី ដែលប្រទេសជាតិជួបប្រទះនឹងបញ្ហាបណ្តោះអាសន្ន ដូចជាការប្រមូលផលស្រូវមិនបានច្រើន ជាដើម ។

ទន្ទឹមនឹងនេះ លំហូរមូលធនពីក្រៅប្រទេស គឺជាមធ្យោបាយយ៉ាងស័ក្តិសិទ្ធមួយ ដើម្បីធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្ត ដែលបណ្តាលមកពីការកើនឡើងនៃការនាំចូល ឬ កំណើនសេដ្ឋកិច្ចខ្ពស់ជាដើម ។ លំហូរមូលធនអនុញ្ញាតអោយធនាគារកណ្តាលបង្កើននូវទុនបម្រុងអន្តរជាតិផងដែរ ។ ទន្ទឹមនឹងគុណប្រយោជន៍ លំហូរមូលធនដ៏ច្រើនសន្ធឹកសន្ធាប់ ក៏អាចបង្កើតផងដែរនូវគុណវិបត្តិមួយចំនួន ដែលទាមទារអោយមានការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្នផងដែរ ដូចជា÷

- លំហូរចូលមូលធន គឺជាបាតុភូតបណ្តោះអាសន្ន ហើយលំហូរចេញក៏អាចឆាប់រហ័សផងដែរ ។
- លំហូរចូលមូលធននឹងធ្វើអោយការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង និង ធ្វើអោយអតិផរណាកើនឡើង ប្រសិនបើធនាគារកណ្តាលធ្វើអន្តរាគមន៍ទិញយករូបិយប័ណ្ណពីទីផ្សារ ដើម្បីបង្កើនទុនបម្រុងអន្តរជាតិ ។ តែប្រសិនបើធនាគារកណ្តាលលក់សញ្ញាប័ណ្ណ (bonds or bill) ដើម្បីស្រូបយករូបិយវត្ថុអោយចូលក្នុងប្រព័ន្ធធនាគារវិញ (Sterilize) នោះនឹងមិនមានអតិផរណាទេ ។
- ប្រសិនបើធនាគារកណ្តាលមិនធ្វើអន្តរាគមន៍ទិញរូបិយប័ណ្ណពីទីផ្សារទេនោះ លំហូរចូលមូលធនដ៏គំហុកនឹងធ្វើអោយអត្រាប្តូរប្រាក់កាន់តែកើនឡើង ពោលគឺរូបិយវត្ថុជាតិកាន់តែមានតម្លៃខ្ពស់ឡើង ។
- លំហូរចូលមូលធនអាចជួយធ្វើហិរញ្ញប្បទានជាបណ្តោះអាសន្ននូវកំណើននៃការប្រើប្រាស់ ក៏ប៉ុន្តែបន្ទាប់ពីបំណុលកាន់តែកើនឡើងច្រើនឡើង ចំណាយសរុបនៃសេដ្ឋកិច្ចជាតិ (C+I) នឹងត្រូវធ្លាក់ចុះទៅពេលអនាគត ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣- ទំនាក់ទំនងជាមូលដ្ឋានរវាងតុល្យភាពសញ្ជ័យ- វិនិយោគ និង គណនីចរន្តខាងក្រៅ

### ៣.១. ទំនាក់ទំនងរវាងគណនីចរន្តជាមួយនឹងសូចនាករសេដ្ឋកិច្ចសំខាន់ៗ

ដោយផ្អែកលើទំនាក់ទំនងរវាងប្រាក់ចំណូលរួម តម្រូវការរួម និង តុល្យភាពគណនីចរន្តខាងក្រៅ ដែលត្រូវបានពិភាក្សា នៅក្នុងផ្នែកទី១ យើងបានសមីការ ÷

$$S\text{-}I = X\text{-}M + Y_1 + TR_1 = CAB \qquad (12.5)$$

ដែល

**S =** គឺជា សញ្ជ័យជុលជាតិ ។

**I =** គឺជា វិនិយោគជុល (ដោយរួមទាំង ការផ្លាស់ប្តូរនៃបញ្ញើសារពើភ័ណ្ឌ) ។

**X =** គឺជា ការនាំចេញទំនិញ និង សេវា ។

**M =** គឺជា ការនាំចូលទំនិញ និង សេវា ។

**$Y_1$ =** ចំណូលសុទ្ធពីកត្តាផលិតកម្មពីបរទេស ។

**$TR_1$ =** ការផ្ទេរសុទ្ធពីបរទេស ។

***គម្លាតរវាងសញ្ជ័យ និង វិនិយោគ*** (S-I) ***=តុល្យភាពគណនីចរន្ត*** (CAB) ***= ការប្រើប្រាស់សញ្ជ័យបរទេស*** **(12.6)**

សមីការ (12.6) បង្ហាញអោយឃើញថា តុល្យភាពគណនីចរន្តនៃជញ្ជីងទូទាត់ អាចអោយនិយមន័យបានច្រើន÷(១) ជាផលប្ញូកនៃសមាសធាតុទាំងអស់នៃជញ្ជីងទូទាត់ (២) ជាផលប្ញូកនៃប្រភពហិរញ្ញប្បទានសម្រាប់សមាសធាតុទាំងអស់នៅក្នុងជញ្ជីងទូទាត់ (៣) តាមទិសដៅម៉ាក្រូសេដ្ឋកិច្ច វាឆ្លុះបញ្ចាំងនូវគម្លាតរវាងប្រាក់ចំណូលដែលប្រើប្រាស់បាន និង លទ្ធភាពស្រូប និង គម្លាតរវាងសញ្ជ័យ និង វិនិយោគ ។ ដូច្នេះ តុល្យភាពគណនីចរន្តនៃជញ្ជីងទូទាត់ គឺជាទស្សនទានមួយដ៏សំខាន់ ដែលផ្សារភ្ជាប់សេដ្ឋកិច្ចជាតិ ទៅនឹងសេដ្ឋកិច្ចពិភពលោក ។ ប្រការនេះ តុល្យភាពគណនីចរន្តនៃជញ្ជីងទូទាត់ គឺជាប្រភពមួយក្នុងចំណោមប្រភពទាំងឡាយ ដែលនាំអោយមានវិបត្តិសេដ្ឋកិច្ច ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សមីការ (12.6) អាចសរសេរឡើងវិញបានដូចតទៅ ÷

$$(S_p + S_g) - (I_p+I_g) = CAB \qquad (12.7)$$

ដែល p និង g ជាផ្នែកឯកជន និង ផ្នែកសាធារណៈ ។ ទំនាក់ទំនងនេះអាចសរសេរឡើងវិញបានដូចតទៅ ÷

$$(S_p - I_p) + (S_g - I_g) = CAB$$

សមីការនេះបង្ហាញអោយឃើញថា ÷

***គម្លាតសញ្ចយ-វិនិយោគនៃផ្នែកឯកជន + គម្លាតសញ្ចយ-វិនិយោគនៃផ្នែករដ្ឋ = តុល្យភាពគណនីចរន្ត*** (12.8)

សមីការ (12.8) បង្ហាញអោយឃើញពីសារសំខាន់នៃទំនាក់ទំនងរវាង សមាសធាតុបីសំខាន់ៗ គឺ ÷ (១) គម្លាតសញ្ចយ-វិនិយោគនៃផ្នែកឯកជន (២) តុល្យភាពថវិការដ្ឋ (ឱនភាព ឬ អតិរេក) និង (៣) តុល្យភាពគណនីចរន្ត ។ ប្រការនេះឆ្លុះបញ្ចាំងពីអន្តរប្រតិសកម្មរវាងរដ្ឋាភិបាល និង ផ្នែកឯកជន ក្នុងការសម្រេចបាននូវ

| **ប្រអប់ទី ១២.១ - ទំនាក់ទំនងរវាងតុល្យភាពតាមផ្នែក និង គណនីចរន្ត** | | |
|---|---|---|
| **តុល្យភាពតាមផ្នែក** | | **តុល្យភាពគណនីចរន្ត** |
| **ឯកជន** | **រដ្ឋ** | |
| (1) $(S_p - I_p) > 0$<br>(2) $(S_p - I_p) < 0$<br>(3) $(S_p - I_p) < 0$ | $(S_g - I_g) < 0$<br>$(S_g - I_g) < 0$<br>$(S_g - I_g) > 0$ | $CAB < 0$; ប្រសិនបើ $\|(S_g - I_g)\| > \|(S_p - I_p)\|$<br>$CAB < 0$<br>$CAB < 0$; ប្រសិនបើ $\|(S_p - I_p)\| > \|(S_g - I_g)\|$ |

តុល្យភាព ឬ អតុល្យភាពនៃគណនីចរន្ត ។

ប្រអប់ទី១២.១ បង្ហាញអោយឃើញពីទំនាក់ទំនងរវាងតុល្យភាពនៃផ្នែកឯកជន និង រដ្ឋ និង លទ្ធផលនៃតុល្យភាពគណនីចរន្ត ។ ***ស្ថានភាពទី១*** គឺជាស្ថានភាពមួយដែលប្រទេសជាច្រើនធ្លាប់ជួបប្រទះ គឺឱនភាពនៃគណនីចរន្តបណ្តាលមកពីឱនភាពថវិកា និង ដែលនាំអោយមាន «***ឱនភាពទ្វេដង***» គឺ ឱនភាពថវិកាផង និង ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ក្នុងពេលតែមួយ ។ ក្នុងន័យនេះ ដើម្បីកាត់បន្ថយឱនភាពគណនីចរន្ត ត្រូវកាត់បន្ថយឱនភាពថវិកាជាមុនសិន ។ ក្នុងករណីខ្លះ អតិរេកនៃសញ្ចយឯកជនលើសវិនិយោគឯកជនជួយសម្រាលបន្ទុកនៃឱនភាពថវិកា ដែលធ្វើអោយមានឱនភាពគណនីចរន្តតែបន្តិចបន្តួចតែប៉ុណ្ណោះ ។

***ស្ថានភាពទី២*** គឺជាស្ថានភាពមួយដែលមានឱនភាពថវិកាផង និង ឱនភាពសញ្ចយឯកជន-


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិនិយោគឯកជន ដែលជាកត្តានាំអោយមានឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ ។

***ស្ថានភាពទី៣*** គឺបង្ហាញអោយឃើញថា ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់បណ្តាលមកពីឱនភាពថវិកាផង និង ឱនភាពសញ្ច័យឯកជន-វិនិយោគឯកជនផង ។ ក៏ប៉ុន្តែ ប្រសិនបើឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ឆ្លុះបញ្ចាំងនូវការកើនឡើងយ៉ាងគំហុកនៃវិនិយោគឯកជន ដែលធ្វើហិរញ្ញប្បទានដោយលំហូរមូលធនពីក្រៅប្រទេស នឹងមានផលលំបាកខាងផ្នែកគោលនយោបាយផ្សេងពីស្ថានភាពដែល ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ឆ្លុះបញ្ចាំងនូវការកើនឡើងយ៉ាងគំហុកនៃការប្រើប្រាស់ឯកជន និង កង្វះនៃសញ្ច័យឯកជន ។

## ៣.២- អតុល្យភាព

### ៣.២.១- អតុល្យភាពក្រៅប្រទេស

សមីការ (12.8) បង្ហាញអោយឃើញថា តុល្យភាពចរន្តនៃជញ្ជីងទូទាត់ គឺជាផលដករវាងសញ្ច័យ និង វិនិយោគនៅក្នុងវិស័យសាធារណៈ និង ឯកជន ។

$$S\text{-}I = X\text{-}M + Y_1 + TR_1 = CAB \qquad (12.9)$$

ទំនាក់ទំនងនេះបង្ហាញអោយឃើញពីមូលហេតុដ៏សំខាន់នៃបញ្ហាជញ្ជីងទូទាត់ ។ កំណើននៃឱនភាពគណនីចរន្ត គឺបណ្តាលមកពីកំណើននៃឱនភាព (ឬការថយចុះនៃអតិរេក) សញ្ច័យ-វិនិយោគនៃវិស័យសាធារណៈ ឬ ឯកជន ។ ដូច្នេះ ដំណោះស្រាយបញ្ហានេះអាស្រ័យថា តើវិស័យណាមួយ ដែលនាំអោយមានអតុល្យភាពនេះ ហើយថា តើកំណើននៃឱនភាព (ឬការថយចុះនៃអតិរេក) បណ្តាលមកពីការធ្លាក់ចុះនៃសញ្ច័យ ការកើនឡើងនៃវិនិយោគ ឬ ដោយសារកត្តាទាំងពីរ ។ ជារួម អតុល្យភាពក្រៅប្រទេសនឹងនាំអោយកើនឡើងនូវបំណុលក្រៅប្រទេស ដែលជាប្រភពមួយយ៉ាងសំខាន់នៃវិបត្តិសេដ្ឋកិច្ច ។

### ៣.២.២- អតុល្យភាពថវិកា

កំណើនចំណាយថវិកាត្រូវតែធ្វើហិរញ្ញប្បទាន ដោយកំណើនចំណូលពន្ធ និង ពុំមែនសារពើពន្ធ ។ ពុំនោះសោតនឹងមានឱនភាពថវិកា ។ ដូច្នេះ ក្នុងបរិការណ៍នៃកំណើនចំណាយថវិកា ចំណូលពន្ធត្រូវតែកើនឡើង ដើម្បីយកទៅធ្វើហិរញ្ញប្បទានចំណាយ ។ ក្នុងករណីនេះ តុល្យភាពពុំមែនហិរញ្ញវត្ថុរបស់រដ្ឋាភិបាលនឹងនៅដដែល ។ ចំណែកឯផ្នែកឯកជនវិញ ក៏ត្រូវកាត់បន្ថយសញ្ច័យ ឬ កាត់បន្ថយចំណាយផងដែរ ។ ប្រសិនបើផ្នែកឯកជនកាត់បន្ថយចំណាយ នោះតុល្យភាពហិរញ្ញវត្ថុរបស់ផ្នែកឯកជននឹងនៅដដែល ដោយសារតែតុល្យភាពពុំមែនហិរញ្ញវត្ថុនឹង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មិនត្រូវប៉ះពាល់ឡើយ ។ ក៏ប៉ុន្តែ ប្រសិនបើផ្នែកឯកជនកាត់បន្ថយសញ្ជ័យ តុល្យភាពពុំមែនហិរញ្ញវត្ថុនឹងកាន់តែលំបាក ដែលទាមទារអោយផ្នែកឯកជនត្រូវខ្ចីធនធានពីធនាគារ កាត់បន្ថយតុល្យភាពសាច់ប្រាក់ ឬ ខ្ចីឥណទានពីបរទេស ។ ប្រសិនបើផ្នែកឯកជនរក្សាចំណាយអោយនៅដដែល នៅក្នុងបរិការណ៍នៃប្រាក់ចំណូលក្រោយពន្ធត្រូវធ្លាក់ចុះ នោះឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់នឹងកាត់តែដុនដាបខ្លាំងឡើង ។

# ជំពូកទី ១៣

# អត្រាប្តូរប្រាក់

## ១. អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ និង អត្រាប្តូរប្រាក់ពិត

អត្រាប្តូរប្រាក់រវាងរូបិយវត្ថុនៃប្រទេសពីរ គឺជាថ្លៃនៃរូបិយវត្ថុ ដែលនិវាសនជននៃប្រទេសទាំងពីរដោះដូរគ្នាទៅវិញទៅមក ។ អត្រាប្តូរប្រាក់មានពីរប្រភេទ គឺៈ អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ និង អត្រាប្តូប្រាក់ពិត ។

### ១.១. អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ

អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ គឺជាថ្លៃប្រៀបធៀបនៃរូបិយវត្ថុរបស់ប្រទេសពីរ ។ ឧទាហរណ៍ ប្រសិនបើអត្រាប្តូរប្រាក់រៀល- ដុល្លារ ស្មើនឹង ៤.០០០ រៀល ក្នុងមួយដុល្លារ មានន័យថាប្រសិនបើយើងយកប្រាក់ចំនួន ៤.០០០ រៀល ទៅដូរនៅលើទីផ្សារប្តូរប្រាក់ នោះយើងបានប្រាក់ដុល្លារមួយដុល្លារ ។ ដូច្នេះ នៅពេលដែលគេនិយាយថា អត្រាប្តូរប្រាក់រវាងប្រទេសពីរ គឺ ជា ***អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ*** ។

### ១.២. អត្រាប្តូរប្រាក់ពិត

អត្រាប្តូរប្រាក់ពិត គឺជា ***ថ្លៃប្រៀបធៀបនៃទំនិញនៅក្នុងប្រទេសពីរ*** ។ អត្រាប្តូរប្រាក់ពិតបង្ហាញអោយឃើញនូវអត្រាដែលយើងអាចដោះដូរទំនិញរបស់ប្រទេសមួយ ជាមួយទំនិញនៃប្រទេសមួយទៀត ។ អត្រាប្តូរប្រាក់ពិតនេះ យើងអាចហៅម៉្យាងទៀតថាជា « ***លក្ខខណ្ឌពាណិជ្ជកម្ម*** » ។

ដើម្បីកំណត់នូវទំនាក់ទំនងរវាងអត្រាប្តូរប្រាក់ពិត និង អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ យើងត្រូវពិនិត្យមើលនូវមុខទំនិញមួយមុខ ដែលផលិតដោយប្រទេសជាច្រើន ឧទាហរណ៍ ខោកាត់ស្រាប់ ។ នៅប្រទេសកម្ពុជា ខោកាត់ស្រាប់មួយថ្លៃ ៨០.០០០ រៀល ។ ចំណែកនៅសហរដ្ឋអាមេរិក ខោកាត់ស្រាប់មួយថ្លៃ ៤០ ដុល្លារ ។ ដើម្បីប្រៀបធៀបនូវថ្លៃនៃខោទាំងពីរ យើងត្រូវដូរថ្លៃអោយទៅជារូបិយវត្ថុតែមួយ ។ ប្រសិនបើយើងដូរ ៨០.០០០ រៀល ដោយចែកនឹង ៤០០០ រៀល យើងបាន ២០ ដុល្លារ ។ ដូច្នេះ ខោនៅកម្ពុជាថ្លៃ ២០ ដុល្លារ ហើយខោដូចគ្នានេះដែរថ្លៃ ៤០ ដុល្លារនៅសហរដ្ឋអាមេរិក ពោលគឺនៅសហរដ្ឋអាមេរិក ខោដូចគ្នានេះថ្លៃជាងនៅកម្ពុជាពីរដង ។ ដូច្នេះយើងបានៈ

***អត្រាប្តូរប្រាក់ពិត*** = [(៤.០០០ រៀល/ ដុល្លារ) × (៨០.០០០ រៀល ខោកម្ពុជា)] / (៤០ ដុល្លារ ខោអាមេរិក)=

= ២ ខោកម្ពុជា/ខោអាមេរិក

ដូច្នេះ តាមថ្លៃ និង អត្រាប្តូរប្រាក់នេះ ខោកម្ពុជាពីរ អាចទិញបានខោអាមេរិកមួយ ។ យើងអាចសរសេរៈ

***អត្រាប្តូរប្រាក់ពិត*** = [អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ × ថ្លៃទំនិញក្នុងស្រុក] / ទំនិញបរទេស

យើងអាចសរសេរបានម៉្យាងទៀតថាៈ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***អត្រាប្តូរប្រាក់ពិត*** = អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ × អនុបាតថ្លៃទំនិញ

**E = e X (P/P*)**

ដូច្នេះ ប្រសិនបើអត្រាប្តូរប្រាក់ពិតខ្ពស់ នោះទំនិញបរទេសនឹងថោក ហើយទំនិញក្នុងស្រុកនឹងថ្លៃជាង ។ ប្រសិនបើអត្រាប្តូរប្រាក់ពិតទាបទំនិញបរទេសនឹងថ្លៃ ហើយទំនិញក្នុងស្រុកនឹងថោក ។

## ២. អត្រាប្តូរប្រាក់ពិត និង តុល្យការពាណិជ្ជកម្ម

ប្រសិនបើអត្រាប្តូរប្រាក់ពិតទាប នោះទំនិញក្នុងស្រុកនឹងថោក ។ និវាសនជននឹងទិញទំនិញនាំចូលកាន់តែតិចទៅៗ ហើយជនបរទេសក៏ចេះតែទិញទំនិញក្នុងស្រុកកាន់តែច្រើន ។ ដោយសារតែកត្តា ទាំងពីរនេះបរិមាណនៃការនាំចេញសុទ្ធនឹងកើនឡើង ។

ផ្ទុយទៅវិញ ប្រសិនបើអត្រាប្តូរប្រាក់ពិតខ្ពស់ ទំនិញផលិតក្នុងស្រុកមានថ្លៃខ្ពស់ ។ និវាសនជនកម្ពុជានឹងទិញទំនិញក្នុងស្រុកកាន់តែតិចទៅៗ ដោយពួកគេទិញទំនិញនាំចូលកាន់តែច្រើន ហើយជនបរទេសក៏ទិញទំនិញក្នុងស្រុកកាន់តែតិចទៅៗ ។ ប្រការនេះនឹងធ្វើអោយការនាំចេញសុទ្ធនឹងធ្លាក់ចុះ។

យើងអាចសរសេរជាសមីការរវាងអត្រាប្តូរប្រាក់ពិត និង ការនាំចេញសុទ្ធ÷

**NX = NX (E)**

**តារាងទី ១៣.១- អត្រាប្តូរប្រាក់ពិត និង ការនាំចេញសុទ្ធ**






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣. កត្តាកំណត់អត្រាប្តូរប្រាក់ពិត

ដោយឈរមូលដ្ឋាននៃការវិភាគខាងលើ យើងអាចសន្និដ្ឋានបានថាៈ

ទីមួយ- អត្រាប្តូរប្រាក់ពិតពាក់ព័ន្ធនឹងការនាំចេញសុទ្ធ ។ នៅពេលដែលអត្រាប្តូរប្រាក់ពិតទាប ទំនិញក្នុងស្រុកថោកជាងទំនិញនាំចូល ដែលធ្វើអោយការនាំចេញសុទ្ធនឹងកើនឡើង ។

ទីពីរ- តុល្យភាពជញ្ជីងពាណិជ្ជកម្ម (ការនាំចេញសុទ្ធ) ត្រូវស្មើនឹងលំហូរចេញនូវមូលធន ដែលស្មើនឹងសញ្ជ័យដកការវិនិយោគ ។ សញ្ជ័យកំណត់ដោយអនុគមន៍ការប្រើប្រាស់ និង អត្រាការប្រាក់លើទីផ្សារអន្តរជាតិ ។

រូប ទី១៣.២ ខាងក្រោមឆ្លុះបញ្ចាំងនូវលក្ខខណ្ឌខាងលើនេះ ។ ខ្សែកោងបង្ហាញពីទំនាក់ទំនង រវាងការនាំចេញសុទ្ធ និង អត្រាប្តូរប្រាក់ពិត ដែលមានមេគុណប្រាប់ទិសធ្លាក់ចុះ ដោយសារតែអត្រាប្តូរប្រាក់ពិតទាបធ្វើអោយទំនិញក្នុងស្រុកថោក ។ ខ្សែកោងនៃអតិរេកសញ្ជ័យលើសវិនិយោគ (S-I) ត្រង់ឡើងលើ ដោយសារអញ្ញត្តិទាំងពីរនេះ ពោលគឺសញ្ជ័យ និងវិនិយោគមិនអាស្រ័យនឹងអត្រាប្តូរប្រាក់ទេ ។

**តារាងទី ១៣.២- អត្រាប្តូរប្រាក់ពិត និង ការនាំចេញសុទ្ធ**




## ៤. គោលនយោបាយសេដ្ឋកិច្ច និង អត្រាប្តូរប្រាក់ពិត

### *៤.១. គោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅក្នុងស្រុក*

ប្រសិនបើរដ្ឋាភិបាលកាត់បន្ថយសញ្ជ័យជាតិ ដោយបង្កើនចំណាយរដ្ឋាភិបាល និង កាត់បន្ថយពន្ធនឹងធ្វើអោយផលដក (S-I) ធ្លាក់ចុះ និង ធ្វើអោយការនាំចេញសុទ្ធ (NX) នឹងធ្លាក់ចុះ ហើយនឹងបង្កើតអោយមានឱនភាពពាណិជ្ជកម្ម ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### តារាងទី ១៣.៣- ឥទ្ធិពលនៃគោលនយោបាយពង្រីកហិរញ្ញវត្ថុសាធារណៈក្នុងស្រុក




រូបភាពលេខ ១៣.៣ បង្ហាញអោយឃើញថា អត្រាប្តូរប្រាក់សមតានឹងសម្របសម្រួល ដែលនឹងធ្វើអោយធ្លាក់ចុះ ។ ការផ្លាស់ប្តូរគោលនយោបាយនឹងធ្វើអោយខ្សែត្រង់រំកិលទៅខាងឆ្វេង ។

### ៤.២. គោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅបរទេស

ប្រសិនបើរដ្ឋាភិបាលបរទេសបង្កើនចំណាយរដ្ឋាភិបាល និង កាត់បន្ថយពន្ធ នោះសញ្ច័យពិភពលោកនឹងធ្លាក់ចុះ ហើយអត្រាការប្រាក់ពិភពលោកនឹងឡើង ។ ការកើនឡើងនៃអត្រាការប្រាក់ពិភពលោក នឹងធ្វើអោយចំណាយវិនិយោគធ្លាក់ចុះ (S-I) ដែលនឹងធ្វើអោយផលសង និង ការនាំចេញសុទ្ធកើនឡើង ។ ដូច្នេះ ការកើនឡើងអត្រាប្តូរប្រាក់ពិភពលោកនឹងបង្កើតអោយមានអតិរេកពាណិជ្ជកម្ម ។

រូបភាពទី ១៣.៤ បង្ហាញអោយឃើញថា ការផ្លាស់ប្តូរគោលនយោបាយនឹងរំកិលខ្សែបន្ទាត់ត្រង់ (S-I) ទៅខាងស្តាំ និង បង្កើនទឹកប្រាក់ ដែលត្រូវយកទៅវិនិយោគពីបរទេស ។ អត្រាប្តូរប្រាក់ពិតសមតានឹងធ្លាក់ចុះ ហើយទំនិញទីផ្សារនឹងថោកជាង ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### តារាងទី ១៣.៤ - ឥទ្ធិពលនៃគោលនយោបាយពង្រីកហិរញ្ញវត្ថុសាធារណៈនៅបរទេស




## ៤.៣. ការកើនឡើងនូវការវិនិយោគ

ប្រសិនបើការវិនិយោគនៅក្នុងស្រុកកើនឡើង ដោយមានអត្រាប្តូរប្រាក់នៅថេរ នោះផលដក (S-I) នឹងធ្លាក់ចុះ ដូច្នេះ ការនាំចេញសុទ្ធ (NX) នឹងធ្លាក់ចុះ ។ ដូច្នេះ កំណើនការវិនិយោគក្នុងស្រុកនឹងបង្កើតអោយមានឱនភាពពាណិជ្ជកម្ម ។ រូបទី ១៣.៥ បង្ហាញអោយឃើញថា កំណើនវិនិយោគរំកិលខ្សែបន្ទាត់ត្រង់ (S-I) ទៅខាងឆ្វេង ដោយកាត់បន្ថយការនាំចេញសុទ្ធ និង បង្កើននូវអត្រាប្តូរប្រាក់ ។

### តារាងទី ១៣.៥ - ឥទ្ធិពលនៃកំណើនការវិនិយោគមកលើអត្រាប្តូរប្រាក់ពិត





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៥. ឥទ្ធិពលនៃគោលនយោបាយពាណិជ្ជកម្ម

គោលនយោបាយពាណិជ្ជកម្ម គឺជាគោលនយោបាយដែលមានទិសដៅធ្វើអោយមានឥទ្ធិពលដោយផ្ទាល់ទៅលើបរិមាណផលិតផល និង សេវា ដែលត្រូវនាំចេញ និង នាំចូល ។ គោលនយោបាយពាណិជ្ជកម្មមានទិសដៅបង្កើនការនាំចេញ ឬ ការពារឧស្សាហកម្មក្នុងស្រុកពីការប្រណាំងប្រជែងពីបរទេស ដោយយកពន្ធលើការនាំចូល ឬ កំណត់បរិមាណទំនិញ ឬ សេវាដែលត្រូវនាំចូល ដោយប្រើប្រាស់នូវកូតា ។ គោលនយោបាយការពារឧស្សាហកម្មក្នុងស្រុក ហៅថាគោលនយោបាយ **ការពារនិយម** ។ រូបលេខ ១៣.៦ បង្ហាញអោយឃើញថា បន្ទាប់ពីអនុវត្តនូវគោលនយោបាយការពារនិយម ការនាំចូលនឹងធ្លាក់ចុះ ការនាំចេញសុទ្ធនឹងកើនឡើង ដោយសារខ្សែកោង (NX) នឹងរំកិលចេញក្រៅ និង សម្រេចបាននូវចំណុចសមតាថ្មី ដែលជាចំណុចមួយដែលមានអត្រាប្តូរប្រាក់ពិតខ្ពស់ជាងមុន ។

**តារាងទី ១៣.៦ - ឥទ្ធិពលនៃគោលនយោបាយការពារនិយមមកលើអត្រាប្តូរប្រាក់ពិត**




ដោយសារតែអត្រាប្តូរប្រាក់ពិតកើនឡើង ទំនិញ និង សេវាផលិតក្នុងស្រុកថ្លៃជាងទំនិញ និង សេវាដែលនាំចូល ។ ដូច្នេះ នៅចំណុចសមតាថ្មី ការនាំចេញនឹងត្រូវកាត់បន្ថយ ។ ជាលទ្ធផល ការអនុវត្តនូវគោលនយោបាយការពារនិយម ធ្វើអោយទាំងការនាំចេញ និង ការនាំចូលត្រូវធ្លាក់ចុះ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៦. ការកំណត់អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ

យើងមានទំនាក់ទំនងរវាងអត្រាប្តូរប្រាក់ពិត និង អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារដូចតទៅ៖

***អត្រាប្តូរប្រាក់ពិត*** = អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ × អនុបាតថ្លៃទំនិញ

**E = e X (P/P*)**

ដូច្នេះយើងអាចសរសេរបានថា៖

**e = E/(P/P*)**

យើងឃើញថាអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារអាស្រ័យលើអត្រាប្តូរប្រាក់ពិត និង កម្រិតថ្លៃនៅក្នុងប្រទេសទាំងពីរ ។ ប្រសិនបើអត្រាប្តូរប្រាក់ពិតនៅដដែល នៅពេលដែលថ្លៃឡើង នោះអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារនឹងធ្លាក់ចុះ។ យើងអាចសរសេរបានថា៖

%ប្រែប្រួលនៃ **e** = %ប្រែប្រួលនៃ **E** + %ប្រែប្រួលនៃ **P*** — %ប្រែប្រួលនៃ **P**

ប្រសិនបើយើងតាង $\pi$ ជាអត្រាអតិផរណាក្នុងប្រទេស ហើយ $\pi^*$ ជាអត្រាអតិផរណានៅបរទេស យើងបាន៖

%ប្រែប្រួលនៃ **e** = %ប្រែប្រួលនៃ **E** + ($\pi^*$ —$\pi$) ឬ

***ការប្រែប្រួលអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ = ការប្រែប្រួលអត្រាប្តូរប្រាក់ពិត + ផលដកនៃអតិផរណា***

ដូច្នេះ ប្រសិនបើកម្ពុជាមានអតិផរណាខ្ពស់ជាងសហរដ្ឋអាមេរិក ប្រាក់ដុល្លារអាចទិញនូវប្រាក់រៀលបានកាន់តែច្រើន ។ ប្រសិនបើកម្ពុជាមានអតិផរណាទាបជាងអាមេរិក ដុល្លារអាចទិញប្រាក់រៀលបានកាន់តែតិចទៅៗ ។

## ៧. សមមូលនៃអនុភាពទិញ

នៅក្នុងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងសម្គាល់កម្មដ៏ល្បីល្បាញមួយគឺ **ច្បាប់ស្តីពីថ្លៃមួយ** (The Law of One Price)៖ «ទំនិញតែមួយមិនអាចលក់តាមថ្លៃផ្សេងគ្នា នៅកន្លែងខុសគ្នានៅពេលជាមួយគ្នាទេ»។ ប្រសិនបើអង្ករមួយបាវនៅភ្នំពេញថ្លៃជាងនៅកំពង់ចាម នោះឈ្មួញនឹងទិញអង្ករពីកំពង់ចាម ដើម្បីយកមកលក់នៅភ្នំពេញ ដើម្បីយកចំណេញហើយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រសិនបើយើងប្រើ **ច្បាប់ស្តីពីថ្លៃមួយ** នៅលើទីផ្សារអន្តរជាតិ នោះយើងបាននូវ **សមមូលនៃអនុភាពទិញ** (Purchasing Power Parity) ។ តាមសម្មតិកម្មនេះ ប្រាក់ដុល្លារត្រូវតែមានអនុភាពទិញ ដូចៗគ្នា ទោះជានៅប្រទេសណាក៏ដោយ ។ ទ្រឹស្តី **សមមូលនៃអនុភាពទិញ**មានផលប៉ះពាល់ពីរយ៉ាង គឺ ÷ (១) ដោយសារខ្សែបន្ទាត់ការនាំចេញសុទ្ធនៅរាបស្មើ នោះការប្រែប្រួលនៃសញ្ជ័យ និង វិនិយោគមិនប៉ះពាល់ដល់ អត្រាប្តូរប្រាក់ពិត ឬ អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារឡើយ ។ (២) ដោយសារអត្រាប្តូរប្រាក់ពិតមានលក្ខណៈថេរ ការប្រែប្រួលនៃអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារនឹងនាំអោយទំនិញឡើងថ្លៃ ។

**តារាងទី ១៣.៧ - សមមូលនៃអានុភាពថ្លៃទិញ**





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី១៤

# វិបត្តិសេដ្ឋកិច្ច

## ១- មូលហេតុនៃវិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍

វិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ភាគច្រើនកើតចេញពីអតុល្យភាពថវិកា និង អតុល្យភាពនៃជញ្ជីងទូទាត់ ។ ការកើនឡើងនៃវិនិយោគកាន់តែច្រើនដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច លើសពីសញ្ច័យក្នុងស្រុក ដែលមាននឹងធ្វើអោយឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់កាន់តែរីកធំឡើង ដូចពិពណ៌នាក្នុងសមីការ (2.4)។ ដើម្បីធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្ត លំហូរហិរញ្ញវត្ថុនឹងកើនឡើង ដែលនឹងនាំអោយមានការធ្លាក់ចុះនៃទ្រព្យសកម្មបរទេសសុទ្ធនៃសេដ្ឋកិច្ចជាតិ និង កើនឡើងនូវបំណុលបរទេស ។ ប្រសិនបើលំហូរមូលធនត្រូវបានយកទៅប្រើប្រាស់សម្រាប់បង្កើនសមត្ថភាពផលិតរបស់សេដ្ឋកិច្ច នោះការធ្វើសេវាបំណុលក៏មានសភាពងាយស្រួលដែរ ។ ក៏ប៉ុន្តែ ប្រសិនបើលំហូរមូលធនត្រូវបានយកទៅធ្វើហិរញ្ញប្បទានវិស័យសំណង់ និង អចលនវត្ថុ ដែលតែងតែកើនឡើងខ្លាំង នៅពេលដែលកំណើនសេដ្ឋកិច្ចសម្រេចបានខ្ពស់ នោះនឹងមានការលំបាកក្នុងការរកធនធានហិរញ្ញវត្ថុដើម្បីយកមកសងបំណុលវិញ ។ នៅក្នុងគណនីមូលធន និង ហិរញ្ញវត្ថុ លំហូរភាគច្រើន គឺជាការបង្កើតអោយមានបំណុល ។

ទោះបីជាមូលហេតុនៃវិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍បណ្តាលមកពីឱនភាពគណនីចរន្ត ដែលមានលក្ខណៈគ្មានចីរភាពក៏ដោយ ការស្តែងចេញនូវវិបត្តសេដ្ឋកិច្ចអាចមានរូបភាពផ្សេងៗគ្នា ។ ដូច្នេះហើយ វិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានចែកចេញជាពីរផ្សេងគ្នាគឺ ÷

ទីមួយ- **វិបត្តិគណនីចរន្ត** នៃជញ្ជីងទូទាត់ ។ ***វិបត្តិគណនីចរន្ត គឺជាដំណើរការកែតម្រូវនៃគណនីចរន្តក្រោយពីមានលំហូរចេញមូលធនយ៉ាងច្រើនសន្ធឹកសន្ធាប់ ។*** ប្រទេសដែលមានវិបត្តិគណនីចរន្ត គឺជាប្រទេសដែលទំហំនៃវិនិយោគមានទំហំធំធេងជាងសញ្ច័យក្នុងស្រុក ដែលបណ្តាលអោយមានឱនភាពគណនីចរន្ត ។ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ច ការនាំចូលចេះតែកើនឡើង ជាហេតុធ្វើអោយឱនភាពគណនីចរន្តកាន់តែរីកធំធេងឡើង ។ ដោយប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ជាប្រទេសនាំចេញវត្ថុធាតុដើម ការធ្លាក់ចុះនៃតម្លៃវត្ថុធាតុដើម និង ការកើនឡើងនៃថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ធ្វើអោយឱនភាពគណនីចរន្តកាន់តែកើនឡើង ហើយបំណុលក្រៅប្រទេសក៏រីកប៉ោងយ៉ាងខ្លាំង ។ វិបត្តិគណនីចរន្តផ្ទុះឡើងនៅពេលមួយដែលការនាំចេញត្រូវធ្លាក់ចុះខ្លាំង ហើយការនាំចូលកាន់តែកើនឡើង ធ្វើអោយគណនីចរន្តមានឱនភាពកាន់តែខ្លាំងឡើង ។ សមិទ្ធកម្មម៉ាក្រូសេដ្ឋកិច្ច


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងប្រទេស ដូចជាអតិផរណា ឱនភាពថវិកាកាន់តែមានសភាពធ្ងន់ធ្ងរឡើង ហើយសញ្ញ៉យធ្លាក់ ចុះដល់កម្រិតមួយយ៉ាងទាប ។ នៅពេលមួយ ដែលវិនិយោគិនលែងមានការទុកចិត្តលើសេដ្ឋកិច្ចជាតិ ហើយចាប់ផ្តើមផ្ទេរមូលធនចេញពីប្រទេស ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនឹងកាន់តែធ្លាក់ដុនដាបខ្លាំងឡើង ។ ការនាំចូលនឹងបន្តកើនឡើង ហើយការនាំចេញបន្តធ្លាក់ចុះ ។ តម្លៃរូបិយវត្ថុជាតិនឹងបាត់បង់តម្លៃយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាហេតុធ្វើអោយមានវិបត្តិរូបិយវត្ថុ ។ អតិផរណានឹងកើនឡើងយ៉ាងខ្លាំង ដែលនឹងជះឥទ្ធិពលជាអវិជ្ជមានលើសេដ្ឋកិច្ចពិតរបស់ជាតិ ។ ជាហេតុធ្វើអោយ ឱនភាពគណនីចរន្តត្រូវបានធ្វើហិរញ្ញប្បទាន ដោយលំហូរចូលនៃមូលធនពីក្រៅប្រទេស ។

វិបត្តិប្រភេទនេះតម្រូវអោយអនុវត្តនូវគោលនយោបាយរូបិយវត្ថុរឹតបន្តឹង ដើម្បីកាត់បន្ថយអតិផរណា កាត់បន្ថយចំណាយ និង បង្កើនចំណូល ដើម្បីអោយកាត់បន្ថយឱនភាពថវិកា និង ធ្វើអោយថវិកាមានតុល្យភាពឡើងវិញ អនុវត្តនូវកំណែទម្រង់រចនាសម្ព័ន្ធ និង គោលនយោបាយអត្រាប្តូរប្រាក់សមស្រប ។ វិធានការទាំងអស់នេះមានទិសដៅបង្កើនការនាំចេញ និង កាត់បន្ថយការនាំចូល ដែលឈានទៅកាត់បន្ថយឱនភាពគណនីចរន្ត និង ដោះស្រាយបញ្ហាវិបត្តិសេដ្ឋកិច្ច ។ គណនីចរន្តនេះអាចត្រូវបានកែតម្រូវតាមរយៈការកើនឡើងនៃការនាំចេញ ឬ ការកាត់បន្ថយការនាំចូល ។ កម្រិតនៃភាពបើកចំហរនៃសេដ្ឋកិច្ចជាតិ និង កម្រិតនៃដុល្លារភាវូបនីយកម្មនៃប្រព័ន្ធធនាគារអាចដើរតួនាទីកំណត់ក្នុងដំណើរការកែតម្រូវនេះ ។

ទីពីរ-**វិបត្តិគណនីមូលធន** នៃជញ្ជីងទូទាត់ ។ វិបត្តិគណនីមូលធន បណ្តាលមកពីការហូរចូលយ៉ាងគំហុកនៃមូលធន លើសពីសេចក្តីត្រូវការសម្រាប់ធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ទៅទៀត ហើយសមាសធាតុនៃលំហូរនេះ ភាគច្រើន គឺជាបំណុលរយៈពេលខ្លី និង ជារូបិយប័ណ្ណ ។ ដូច្នេះ ***វិសមិតភាពរវាងរយៈពេលសងប្រាក់ និង រូបិយប័ណ្ណ*** (ការខ្ចីឥណទានរយៈពេលខ្លី និង ជារូបិយប័ណ្ណបរទេស ដូចជាប្រាក់ដុល្លារ ឬ អឺរ៉ូ ឬ យ៉េន ដើម្បីយកមកអោយអតិថិជនធនាគារខ្ចីសម្រាប់រយៈពេលវែង និង ជារូបិយវត្ថុជាតិ) នៅក្នុងតារាងតុល្យការនៃស្ថាប័នហិរញ្ញវត្ថុ ដែលជាដើមចមនាំអោយមានវិបត្តិហិរញ្ញវត្ថុពីរយ៉ាងក្នុងពេលតែមួយ ÷ (១) **វិបត្តិរូបិយវត្ថុ** (វិបត្តិក្រៅប្រទេស) ដែលបណ្តាលមកពីលំហូរចេញយ៉ាងលឿន នូវរូបិយប័ណ្ណបរទេសពីប្រទេសដែលជួបវិបត្តិ កង្វះខាតសាច់ប្រាក់ ទាំងនៅក្នុងប្រទេស ទាំងនៅក្នុងបរិការណ៍អន្តរជាតិ ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមានការភ័យខ្លាចមិនអោយខ្ចី និង (២) **វិបត្តិធនាគារ** (វិបត្តិក្នុងប្រទេស) ដែលនាំអោយឥណទានផ្ទៃក្នុងមានការកាត់បន្ថយយ៉ាងខ្លាំងក្លា ។ ជារួម វិបត្តិគណនីមូលធនមានលក្ខណៈខុសពីវិបត្តិគណនីចរន្ត ដែលនៅត្រង់ថា លំហូរចូលខ្លាំងពេកនៃមូលធនពីបរទេសនឹងធ្វើអោយថ្លៃរូបិយវត្ថុជាតិមានតម្លៃខ្ពស់ពីតម្លៃពិតរបស់ខ្លួន ដោយសាររដ្ឋាភិបាលប្រកាន់យកនូវគោលនយោបាយអត្រាប្តូរប្រាក់ថេរ ។ ម្យ៉ាងវិញទៀត ការសំបូរធនធានហិរញ្ញវត្ថុតម្រូវអោយធនាគារវិនិយោគក្នុងវិស័យ ដែលមិនមែនជាវិស័យនាំចេញ ដូចជាវិស័យអចលនវត្ថុ និង សំណង់ជាដើម ។ ប្រការនេះ ធ្វើអោយការនាំចេញមិនបានកើនឡើងខ្លាំងឡើយ ដែលបង្កនូវការលំបាកក្នុងការសង



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បំណុល។ ដូច្នេះ សមិទ្ធកម្មម៉ាក្រូសេដ្ឋកិច្ចជាមូលដ្ឋាននៅរឹងមាំល្អ ។

នៅពេលដែលបំណុលក្រៅប្រទេសកើនឡើងលើសពីសមត្ថភាពទ្រទ្រង់របស់សេដ្ឋកិច្ចជាតិ នោះតម្រូវការក្នុងការសងបំណុលក៏មានទំហំធំធេងផងដែរ ។ ដោយបំណុលក្រៅប្រទេសត្រូវសងវិញជារូបិយប័ណ្ណអន្តរជាតិ ការកើនឡើងនៃតម្រូវការក្នុងការសងបំណុលនឹងដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរ ទៅលើអត្រាប្តូរប្រាក់ ដោយសារសេចក្តីត្រូវការរូបិយប័ណ្ណនឹងមានទំហំធំលើសលុបពីការផ្គត់ផ្គង់រូបិយប័ណ្ណនៅលើទីផ្សារ ។ នៅពេលនេះ **ច្បាប់ស្តីពីទ្រិសមិតភាពបីយ៉ាង** (Impossible Trinity) នឹងត្រូវតែយកមកអនុវត្ត ។ ពោលគឺ គេមិនអាចអនុវត្តនូវគោលនយោបាយខាងក្រោម ក្នុងពេលតែមួយ អោយលើសពីលក្ខខណ្ឌចំនួនពីរបានឡើយ÷

**១. *គោលនយោបាយអត្រាប្តូរប្រាក់ថេរ*** (Fixed exchange rate) **។**

***២. លំហូរមូលធនចេញ- ចូលដោយសេរី ក្នុងបរិការណ៍នៃសេរីភាវូបនីយកម្មនៃគណនីមូលធន ។***

***៣. គោលនយោបាយរូបិយវត្ថុឯករាជ ។***

ដូច្នេះ នៅក្នុងបរិការណ៍នៃសេរីភាវូបនីយកម្មនៃគណនីមូលធន ដែលអនុញ្ញាតអោយមូលធនហូរចេញ-ចូលដោយសេរី ដូចនៅក្នុងប្រទេសកម្ពុជា ការដោះស្រាយបញ្ហាឱនភាពគណនីចរន្ត គឺស្ថិតត្រង់ការផ្លាស់ប្តូរគោល-នយោបាយរូបិយវត្ថុ ឬ គោលនយោបាយអត្រាប្តូរប្រាក់ ។ ដោយសារតែនៅប្រទេសកម្ពុជា ការប្រើប្រាស់ដុល្លារមានទំហំយ៉ាងធំធេង ហើយប្រតិបត្តិការធនាគារប្រមាណជា ៩៧ ភាគរយ ត្រូវប្រើប្រាស់ដុល្លារ នោះ គោលនយោបាយរូបិយវត្ថុគ្មានប្រសិទ្ធភាពឡើយ ។ ដូច្នេះ មានតែគោលនយោបាយអត្រាប្តូប្រាក់ទេ ដែលអាចជួយបន្ថយសម្ពាធបាន។

នៅក្នុងបរិការណ៍នៃលំហូរមូលធនសេរី ការកំណត់យកអត្រាប្តូរប្រាក់អណ្តែត (Floated exchange rate) នឹងជួយអោយអត្រាប្តូរប្រាក់កែតម្រូវបន្តិចម្តងៗ ដោយចៀសវាងការបាត់បង់តម្លៃរូបិយវត្ថុយ៉ាងគំហុក នៅក្នុងខណៈ ដែលរដ្ឋាភិបាលត្រូវបង្ខំចិត្តប្តូរគោលនយោបាយអត្រាប្តូរប្រាក់ ពីថេរ ទៅអណ្តែត ឬ នៅពេលដែលរូបិយវត្ថុជាតិនឹងត្រូវបាត់បង់តម្លៃយ៉ាងគំហុកនៅពេលណាមួយ ។ ក្នុងករណីនេះ វិបត្តិអាចនឹងស្តែងចេញពីវិបត្តិរូបិយវត្ថុ ដែលនឹងអាចរាលដាលដល់វិស័យធនាគារ ហើយក្លាយជាវិបត្តិហិរញ្ញវត្ថុ ដោយវិនិយោគិនត្រូវផ្ទេរមូលធនយ៉ាងច្រើនទៅបរទេសវិញ ដោយសារការខាតបង់ដោយសារតែការតម្លៃរូបិយវត្ថុជាតិនឹងធ្លាក់ចុះយ៉ាងគំហុក ហើយមូលធននឹងហូរយ៉ាងគំហុកចេញពីប្រទេស ។ ប្រការនេះនឹងធ្វើអោយប៉ះពាល់ដល់សេដ្ឋកិច្ចពិត ដែលនឹងធ្វើអោយវិបត្តិហិរញ្ញវត្ថុនឹងក្លាយទៅជាវិបត្តិសេដ្ឋកិច្ចផងដែរ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការពង្រឹងយន្តការត្រួតពិនិត្យដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការបង្ការកុំអោយមានវិបត្តិសេដ្ឋកិច្ច ទាំងវិបត្តិគណនីចរន្ត ទាំងវិបត្តិគណនីមូលធន ។ ការវិភាគសេដ្ឋកិច្ចដើម្បីចាប់យកសញ្ញានៃវិបត្តិសេដ្ឋកិច្ចត្រូវផ្តោតលើសូចនាករមួយចំនួនដូចតទៅៈ

***១- សូចនាករវិស័យក្រៅប្រទេស***

- ទំហំទុនបម្រុងអន្តរជាតិ ដើម្បីយកមកធានាការសងបំណុលរយៈពេលខ្លី និង រយៈពេលវែង និង សម្រាប់ប្រៀបធៀបទៅនឹងឱនភាពគណនីចរន្ត
- តុល្យភាពគណនីចរន្ត គិតជាភាគរយនៃផសស
- បំណុលក្រៅប្រទេស គិតជាភាគរយនៃផសស
- តម្លៃអត្រាប្តូរប្រាក់កើនលើសពីតម្លៃពិត (Overvaluation)
- របបអត្រាប្តូរប្រាក់

***២- សូចនាករថវិកា***

- តុល្យភាពថវិកាសរុប
- តុល្យភាពថវិការចរន្ត
- បំណុលសាធារណៈគិតជាភាគរយនៃ ផសស
- បំណុលរយៈពេលខ្លី ជាគាគរយនៃបំណុលសរុប
- បំណុលជារូបិយប័ណ្ណ ជាភាគរយនៃបំណុលសរុប

***៣- សូចនាករហិរញ្ញវត្ថុ***

- អនុបាតសាធនភាព (ទ្រព្យសកម្មសុទ្ធ/ទ្រព្យសកម្មសរុប)


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- អនុបាទប្រាក់ចំណេញរបស់ធនាគារ

- ឥណទានមិនដំណើរការ

- កំណើនឥណទានផ្តល់អោយផ្នែកឯកជន

- ភាគរយនៃឥណទានជារូបិយប័ណ្ណអន្តរជាតិ

ការត្រួតពិនិត្យ និង វិភាគសេដ្ឋកិច្ចជាប្រចាំ មានសារៈសំខាន់ណាស់ ដើម្បីផ្តល់សញ្ញាអោយបានទាន់ពេលវេលា ក្នុងគោលដៅបញ្ចៀសវិបត្តិសេដ្ឋកិច្ចកុំអោយរាលដាល ដល់វិស័យផ្សេងៗនៃសេដ្ឋកិច្ចជាតិ ។ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងឱនភាពគណនីចរន្ត រដ្ឋាភិបាលអាចចាត់វិធានការដូចតទៅៈ

- យកទុនបម្រុងជារូបិយប័ណ្ណអន្តរជាតិទៅធ្វើអន្តរាគមន៍នៅលើទីផ្សារ ដើម្បីអោយអត្រាប្តូរប្រាក់មានស្ថិរភាព ។ តែវិធានការនេះមានគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារតែទុនបម្រុងជារូបិយប័ណ្ណអាចមានកម្រិត ហើយរដ្ឋាភិបាលប្រហែលជាមិនអាចនឹងសម្រេចបាននូវគោលដៅនេះបាន ដោយសារបំណុលមានទំហំធំពេក ហើយ ទុនបម្រុងអន្តរជាតិមានចំនួនមិនគ្រប់គ្រាន់ ដើម្បីអោយសម្រេចបាននូវស្ថិរភាពអត្រាប្តូរប្រាក់ ។ ក្នុងករណីនេះ រដ្ឋាភិបាលគួរតែទុកអោយអត្រាប្តូរប្រាក់អណ្តែតដោយសេរី ទៅតាមទីផ្សារ ដោយសុខចិត្តទុកទុនបម្រុងសម្រាប់ប្រើប្រាស់ថ្ងៃក្រោយ ។

- ការអនុវត្តគោលនយោបាយអត្រាប្តូរប្រាក់អណ្តែត នឹងជួយអោយសេដ្ឋកិច្ចកែសម្រួលបន្តិចម្តងៗ តាមដំណាក់កាល ក្នុងគោលដៅកាត់បន្ថយសម្ពាធនៃបំណុលបរទេស ។

- កាត់បន្ថយនូវសមត្ថភាពស្រូប ពោលគឺ កាត់បន្ថយនូវការប្រើប្រាស់ និង វិនិយោគ ដើម្បីអោយថវិកាមានតុល្យភាពឡើងវិញ និង កាត់បន្ថយឱនភាពគណនីចរន្ត ។

## ២. វិបត្តិបំណុលនៅម៉ិកស៊ិក

នៅអំឡុងទស្សវត្សទី ៨០ ប្រទេសអាមេរិកឡាទីនមួយចំនួន ដូចជាប្រទេសម៉ិកស៊ិក ឈីលី អ៊ុរ៉ាក្វាយ និង អាហ្សង់ទីនបានឆ្លងកាត់នូវវិបត្តិសេដ្ឋកិច្ចយ៉ាងជ្រាលជ្រៅ ។ ប្រទេសទាំងនេះបានអនុវត្តនូវគោលនយោបាយរូបិយវត្ថុនិយម ដោយធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មក្រៅប្រទេស តាមរយៈការកាត់បន្ថយពន្ធគយ និង កូតានាំចូល ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ការធ្វើសេរីភាវូបនីយកម្មទីផ្សារហិរញ្ញវត្ថុ ការកាត់បន្ថយការធ្វើនិយ័តកម្ម


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេដ្ឋកិច្ច ការបន្ថយតម្លៃអត្រាប្តូរប្រាក់ ។ គេបានលុបបំបាត់នូវការត្រួតពិនិត្យលំហូរមូលធន ការត្រួតពិនិត្យរូបិយប័ណ្ណ និង ការដាក់កំហិតខាងផ្នែកសេដ្ឋកិច្ច ។ លទ្ធផលនៃកំណែទំរង់ក្នុងវិស័យហិរញ្ញវត្ថុទាំងនេះ ធ្វើអោយមូលធនហូរចេញ និងចូលដោយសេរីជាមួយសហរដ្ឋអាមេរិក ។ ការឡើងថ្លៃប្រេងកាតចាប់ផ្តើមពីអំឡុងឆ្នាំ ១៩៧៣ ធ្វើអោយប្រាក់បញ្ញើរបស់ប្រទេសនាំចេញប្រេងកាត នៅក្នុងធនាគារអាមេរិកកើនឡើងយ៉ាងខ្លាំង ដែលស្វែងរកនូវការវិនិយោគ ដែលផ្តល់ការប្រាក់ខ្ពស់ ។ ការសម្បូណ៌បែបនូវធនធានហិរញ្ញវត្ថុនៅលើទីផ្សារពិភពលោក និង សេរីភាវូបនីយកម្មទីផ្សារហិរញ្ញវត្ថុនៅប្រទេសអាមេរិកឡាទីន បង្កលក្ខណៈអោយសហគ្រាសឯកជន និង ធនាគារឯកជនអាចខ្ចីប្រាក់បានយ៉ាងងាយស្រួល ដោយគ្មានការត្រួតពិនិត្យ ។ ពោលប្រទេសអាមេរិកឡាទីនបានធ្វើសេរីភាវូបនីយកម្មគណនីមូលធនយ៉ាងពេញទំហឹង ដោយមិនបានគិតពីសមត្ថភាពត្រួតពិនិត្យ និង សមត្ថភាពស្ថាប័នរបស់ធនាគារកណ្តាល ដែលជាអាជ្ញាធរហិរញ្ញវត្ថុឡើយ ។

ក្នុងបរិការណ៍នេះហើយ ដែលប្រទេសម៉ិចស៊ិកបានខ្ចីប្រាក់យ៉ាងច្រើន ពីទីផ្សារពិភពលោកនៅក្នុងទសវត្សរ៍ទី ៧០ ។ ចំណុចសំខាន់ដែលធ្វើអោយវិបត្តិនេះកើតឡើង គឺការផ្លាស់ប្តូរនូវប្រភេទ និង សមាសធាតុនៃបំណុល ពីកម្ចីផ្លូវការសម្រាប់រយៈពេលវែង និង មានអត្រាការប្រាក់ទាបជាលក្ខណៈសម្បទាន ទៅជាកម្ចីពីធនាគារពាណិជ្ជឯកជន ដែលមានរយៈពេលខ្លី ហើយដែលមានអត្រាការប្រាក់ប្រែប្រួលតាមស្ថានភាពទីផ្សាររូបិយវត្ថុ ។ ចាប់តាំងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៨២ បំណុលរបស់ប្រទេសអាមេរិកឡាទីនចំពោះធនាគារឯកជនរបស់សហរដ្ឋអាមេរិក កើនឡើងជាមធ្យមចំនួន ២០ ភាគរយ ក្នុងមួយឆ្នាំ ។ បំណុលក្រៅប្រទេសរបស់ប្រទេសអាមេរិកឡានទាំងអស់កើនឡើងជាបួនដង ពីចំនួន ៧៥ ពាន់លានដុល្លារ ក្នុងឆ្នាំ ១៩៧៥ ដល់ ៣១៤ ពាន់លានដុល្លារ នៅក្នុងឆ្នាំ ១៩៨២ ឬ ស្មើនឹង ៥០ ភាគរយនៃផលិតផលសរុបក្នុងស្រុក ។ ការធ្វើសេវាបំណុល (ការសងការប្រាក់ និង ប្រាក់ដើម) បានកើនឡើងកាន់តែលឿនជាងនេះទៅទៀត ពី ១២ ពាន់លានដុល្លារនៅក្នុងឆ្នាំ ១៩៧៥ ដល់ ៦៦ ពាន់លានដុល្លារ នៅក្នុងឆ្នាំ ១៩៩៨ ។ កំណើននៃការសងការប្រាក់ ធ្វើអោយគណនីចរន្តជញ្ជីងទូទាត់កាន់តែមានឱនភាពខ្លាំងឡើងថែមទៀត។ នៅពេលដែលការនាំចេញកើនឡើងជាមធ្យម ចំនួន ១២ ភាគរយក្នុងមួយឆ្នាំ សេវាបំណុលបានឡើងចំនួន ២៤ ភាគរយ ក្នុងមួយឆ្នាំ ។ ដូច្នេះ ប្រទេសអាមេរិកឡាទីនបានខ្ចីលុយកាន់តែច្រើនពីបរទេស ដើម្បីសងការប្រាក់ និង ប្រាក់ដើមបំណុល ។ លំហូរមូលធនសុទ្ធចូលប្រទេសអាមេរិកឡានទីបន្តកើនឡើង ជាមធ្យម ២០ ភាគរយ ក្នុងមួយឆ្នាំ ។

វិបត្តិបំណុលចាប់ផ្តើមឡើង នៅពេលដែលទីផ្សារមូលធនពិភពលោកចាប់ផ្តើមយល់យ៉ាងច្បាស់ថា ប្រទេសអាមេរិកឡាទីននឹងពុំអាចសងបំណុលរបស់ខ្លួនបានឡើយ ។ ថ្វីត្បិតតែប្រទេសម៉ិកស៊ិកជាប្រទេសនាំចេញប្រេងកាត ដែលកើនឡើងពី ៦០០ លានដុល្លារ ក្នុងឆ្នាំ ១៩៧៦ ដល់ ១៤ ពាន់លានដុល្លារ ក្នុងឆ្នាំ ១៩៨១ ការនាំ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចេញ ទំនិញផ្សេងៗទៀតធ្លាក់ចុះយ៉ាងខ្លាំង ដោយសារតែអត្រាប្តូរប្រាក់ឡើងថ្លៃខ្លាំង ធ្វើអោយទំនិញរបស់ម៉ិកស៊ិកបាត់បង់នូវភាពប្រណាំងប្រជែងលើទីផ្សារអន្តរជាតិ ។ បំណុលភាគច្រើនរបស់ម៉ិកស៊ិក គឺជាបំណុលរយៈពេលខ្លី ដែល ៥០ ភាគរយជាបំណុល ដែលមានការប្រាក់ប្រែប្រួល ។ ម៉្យាងវិញទៀត ផ្នែកឯកជនរបស់ម៉ិកស៊ិកក៏ចាប់ផ្តើមនាំមូលធនចេញទៅបរទេស ។ គ្រាន់តែនៅចន្លោះឆ្នាំ ១៩៨១-១៩៨២ មូលធនចំនួន ២០ ពាន់លានដុល្លារបានហូរចេញពីប្រទេសម៉ិកស៊ិក ។ លំហូរចេញយ៉ាងគំហុកនៃមូលធន នៅក្នុងឆ្នាំ ១៩៨២ និង គួបផ្សំដោយ ការធ្លាក់ចុះនៃថ្លៃប្រេងឥន្ធនៈ ដែលជាមុខទំនិញនាំចេញយ៉ាងសំខាន់របស់ម៉ិកស៊ិកបានធ្វើអោយប្រទេសនេះ ធ្លាក់ចូលក្នុងរណ្តៅនៃវិបត្តិហិរញ្ញវត្ថុ ។ នៅពេលដែលអត្រាការប្រាក់កើនឡើងខ្លាំងពេក នៅដើមទស្សវត្សឆ្នាំ ៨០ រដ្ឋាភិបាលម៉ិកស៊ិកមិនអាចសងការប្រាក់បាន ។ អ្នកដឹកនាំ និង វិនិយោគិនក្នុងពិភពលោកលែងមានសេចក្តីទុកចិត្តលើប្រទេសម៉ិកស៊ិក ហើយមិនចង់ទិញទ្រព្យសកម្មនៅក្នុងប្រទេសនេះ ។

រដ្ឋាភិបាលបានដាក់ចេញនូវវិធានការត្រួតពិនិត្យការនាំចូល កាត់បន្ថយចំណាយ និង បញ្ចុះថ្លៃអត្រាប្តូរប្រាក់ ក៏ប៉ុន្តែវាដូចជាហួសពេលទៅហើយ ។ ប្រាក់ប៉េសូបាត់បង់តម្លៃចំនួន ៨០ ភាគរយនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៨២ ដោយមូលធនបន្តហូរចេញគ្មានឈប់ ធ្វើអោយសេដ្ឋកិច្ចជួបប្រទះនឹងអតិផរណាផង និង ការធ្លាក់ចុះនូវផលិតកម្មផង ។ ប្រទេសម៉ិកស៊ិកត្រូវការធនធានយ៉ាងច្រើន ដើម្បីធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្ត ។ ធនាគារកណ្តាលត្រូវបង្ខំចិត្តបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយយកទុនបម្រុងអន្តរជាតិយកមកប្រើប្រាស់ ជាហេតុធ្វើអោយទុនបម្រុងនេះធ្លាក់ចុះ ។ នៅក្នុងខែ សីហា ឆ្នាំ ១៩៨២ ទុនបម្រុងរបស់ម៉ិកស៊ិកត្រូវយកមកប្រើប្រាស់អស់គ្មានសល់ ហើយធនាគារអន្តរជាតិក៏លែងអោយឥណទានខ្ចីទៀត ។ នៅពេលនោះ រដ្ឋមន្ត្រីហិរញ្ញវត្ថុនៃប្រទេសម៉ិកស៊ិក លោក **យេស៊ូ ស៊ីលវ៉ា-ហែហ្សុក** (Jesus Silva-Herzog) បានប្រកាសថា «ប្រទេសម៉ិកស៊ិកនឹងមិនអាចសងបំណុលរបស់ខ្លួនបានឡើយ» ។ ប្រទេសអាមេរិក ប្រទេសជាសមាជិកនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនៅអ៊ឺរ៉ុប និង មូលនិធិរូបិយវត្ថុអន្តរជាតិបានប្រកាសផ្តល់ឥណទានចំនួន ១៩០ ពាន់លានដុល្លារ ទម្រាំកម្មវិធីពិនិត្យឡើងវិញនូវបំណុលអាចនឹងត្រូវបញ្ចប់ ។

## ៣- វិបត្តិហិរញ្ញវត្ថុនៅអាស៊ី ឆ្នាំ ១៩៩៧-១៩៩៨

វិបត្តិហិរញ្ញវត្ថុនៅអាស៊ី គឺជាវិបត្តិគណនីមូលធន ដែលបណ្តាលមកពីការហូរចូលយ៉ាងគំហុកនៃមូលធនលើសពីសេចក្តីត្រូវការសម្រាប់ធ្វើហិរញ្ញប្បទានឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ ។ ជារួម មុនពេលមានវិបត្តិតំបន់អាស៊ីអគ្នេយ៍ និង អាស៊ីបូព៌ាត្រូវបានសេដ្ឋវិទូទទួលស្គាល់ថា ជា «**អច្ឆរិយៈនៅអាស៊ី**» ដោយសារតែប្រទេសទាំងនេះសម្រេចបាននូវកំណើនសេដ្ឋកិច្ច ចំនួន ៧ ភាគរយក្នុងមួយឆ្នាំ កំណើនការនាំចេញយ៉ាងខ្ពស់ ក្នុងបរិការណ៍


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃស្ថេរភាពនៃមូលដ្ឋានគ្រឹះម៉ាក្រូសេដ្ឋកិច្ច ។ ទន្ទឹមនឹងនេះ ស្ថេរភាពនៃម៉ាក្រូសេដ្ឋកិច្ចបានលាក់បាំងនូវកំណើននៃឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ ដោយសារវិនិយោគមានទំហំធំធេង លើសពីសញ្ច័យក្នុងស្រុក ។ អត្រាវិនិយោគស្មើនឹង ៤១,៧%នៃផសស នៅប្រទេសថៃ ៤១,៥%នៃផសស នៅម៉ាឡេស៊ី ៣៨,៤%នៃផសស នៅកូរ៉េខាងត្បូង និង ៣០,៨%នៃផសស នៅឥណ្ឌូណេស៊ី ។ ក៏ប៉ុន្តែ គណនីរន្តនៃជញ្ជីងទូទាត់ស្មើនឹង -៨,៥%នៃផសស នៅប្រទេសថៃ ៣,៧%នៃផសស នៅម៉ាឡេស៊ី ៤,៨%នៃផសស នៅកូរ៉េខាងត្បូង និង ៣,៣%នៃផសស នៅឥណ្ឌូណេស៊ី ។ ក៏ប៉ុន្តែ ប្រទេសទាំងបួននេះមានអតិរេកថវិកាសរុបទាំងអស់ គឺ ០,៩%នៃផសស នៅប្រទេសថៃ ០,៧%នៃផសស នៅម៉ាឡេស៊ី ០,៤%នៃផសស នៅកូរ៉េខាងត្បូង និង ១,២%នៃផសស នៅឥណ្ឌូណេស៊ី ដែលមានន័យថា ឱនភាពនៃគណនីចរន្ត គឺបណ្តាលមកពីវិនិយោគមានទំហំធំជាងសញ្ច័យច្រើនពេក ហើយត្រូវធ្វើហិរញ្ញប្បទាន ដោយលំហូរមូលធនពីបរទេស ។

កំណើនសេដ្ឋកិច្ចដែលសម្រេចបានយ៉ាងខ្ពស់ដូច្នេះ គឺដោយសារតែការធ្វើហិរញ្ញប្បទានដោយសារបំណុលពីក្រៅប្រទេស ។ បំណុលរបស់ប្រទេសទាំងបួនមានទំហំយ៉ាងធំធេង ដែលភាគច្រើនជាបំណុលធនាគាររយៈពេលខ្លី ។ បំណុលក្រៅប្រទេសរបស់ថៃស្មើនឹង ៥០%នៃផសស (៨៥%ជាបំណុលធនាគារ) នៅម៉ាឡេស៊ី ៤០%នៃផសស (៧៣% ជាបំណុលធនាគារ) នៅកូរ៉េខាងត្បូង ២៨%នៃផសស (៧៨%ជាបំណុលធនាគារ) និង នៅឥណ្ឌូណេស៊ី ៥៦%នៃផសស (៤០% ជាបំណុលធនាគារ) ។ ពី ២០% ទៅ ៥០%នៃបំណុលនេះ ជាបំណុលរយៈពេលខ្លី ហើយបំណុលរយៈពេលខ្លីទាំងនេះ ស្មើនឹង ៩៩%នៃទុនបម្រុង នៅប្រទេសថៃ ៤១% នៅម៉ាឡេស៊ី ២០៣% នៅកូរ៉េខាងត្បូង និង ១៧៦%នៃទុនបម្រុង នៅឥណ្ឌូណេស៊ី ។

វិបត្តិហិរញ្ញវត្ថុនៅអាស៊ីចាប់ផ្តើមនៅក្នុងខែ កក្កដា ឆ្នាំ ១៩៩៧ នៅពេលដែលឈ្មួញរូបិយវត្ថុចាប់ផ្តើមវាយលុក ដើម្បីអោយរដ្ឋាភិបាលថៃទម្លាក់ថ្លៃប្រាក់បាត ។ ប្រទេសថៃមានរបបអត្រាប្តូរប្រាក់ថេរ ដោយភ្ជាប់ទៅនឹងប្រាក់ដុល្លារ ។ រដ្ឋាភិបាលថៃបានបង្កើនអត្រាការប្រាក់នៃលុយបាតថៃ ហើយបានធ្វើការប្តេជ្ញាចិត្តថា នឹងការពារអត្រាប្តូរប្រាក់នៃលុយបាត ទោះបីជាត្រូវបង់ថ្លៃប៉ុន្មានក៏ដោយ ។ ដោយយល់ឃើញថា ដើម្បីការពារអត្រាប្តូរប្រាក់នៃលុយបាត ប្រទេសថៃត្រូវបង់ថ្លៃមួយយ៉ាងខ្ពស់ ចុងបំផុតរដ្ឋាភិបាលថៃបានសម្រេចចិត្តថា ឈប់ការពារអត្រាប្តូរប្រាក់ ហើយចាប់ផ្តើមកាត់បន្ថយយ៉ាងខ្លាំងនូវអត្រាប្តូរប្រាក់បាត ។ ប្រការនេះនាំអោយមានវិបត្តិរូបិយវត្ថុ ។ ក៏ប៉ុន្តែ ធនាគារភាគច្រើនបានខ្ចីឥណទានរយៈពេលខ្លីជាប្រាក់ដុល្លារ ហើយយកមកអោយអតិថិជនខ្ចីបន្ត ជាប្រាក់បាត សម្រាប់រយៈពេលវែង ។ ដូច្នេះ វិបត្តិហិរញ្ញវត្ថុនៅអាស៊ីបណ្តាលមកពី ***វិសមិតភាពរវាងរយៈពេលសងប្រាក់ និង រូបិយប័ណ្ណ*** (ការខ្ចីឥណទានរយៈពេលខ្លី និង ជារូបិយប័ណ្ណបរទេស ជាប្រាក់ដុល្លារ ដើម្បីយកមកអោយអតិថិជនខ្ចី សម្រាប់រយៈពេលវែង និង ជារូបិយវត្ថុជាតិ) ដែលជាដើមចមនាំអោយមានវិបត្តិហិរញ្ញវត្ថុពីរយ៉ាងក្នុងពេលតែមួយ ÷ (១)


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**វិបត្តិរូបិយវត្ថុ** និង (២) **វិបត្តិធនាគារ** ។ បន្ទាប់ពីវិបត្តិនេះបានផ្ទុះឡើង វិនិយោគិនចាប់ផ្តើមជម្រុញការនាំចេញនូវមូលធនទៅកាន់បរទេស ដែលជាប្រការមួយធ្វើអោយអត្រាប្តូរប្រាក់ធ្លាក់ចុះកាន់តែខ្លាំងឡើង ។

## ៤- វិបត្តិហិរញ្ញវត្ថុពិភពលោក ឆ្នាំ ២០០៨

### *៤.១- បុព្វហេតុនៃវិបត្តិ*

វិបត្តិហិរញ្ញវត្ថុចាប់ផ្តើមនៅ ខែ សីហា ឆ្នាំ ២០០៧ ជា **វិបត្តិកម្ចីអនុគ្រោះ** (Subprime Crisis) ដែលកើតឡើងដោយសារអតុល្យភាពនៃហិរញ្ញវត្ថុពិភពលោក និង ក្នុងបរិបទសេរីភាវូបនីយកម្មទីផ្សារហិរញ្ញវត្ថុពិភពលោក ។ ទីផ្សារកម្ចីអនុគ្រោះ មានកំណើនយ៉ាងលឿនក្នុងរយៈពេលពីរ ឬ បីឆ្នាំចុងក្រោយ នៅសហរដ្ឋអាមេរិក ដែលទីផ្សារនេះមានប្រាក់ទុនមិនតិចជាង ១.០០០ ពាន់លានដុល្លារ ប្រៀបនឹងតម្លៃភាគហ៊ុនលើទីផ្សារដែលមានប្រាក់ទុន ២០.០០០ ពាន់លានដុល្លារ ឬ ទ្រព្យសម្បត្តិនៃគ្រួសារអាមេរិក ដែលមានទឹកប្រាក់ ៦០.០០០ ពាន់លានដុល្លារ ។

កត្តាដូចខាងក្រោមនេះ មានជាមូលហេតុដែលនាំឱ្យមានវិបត្តិកម្ចីអនុគ្រោះ ÷

- ***សាច់ប្រាក់លើសកម្រិតក្នុងពិភពលោក និង ជម្រៅកម្មហិរញ្ញវត្ថុ*** (ការផ្គត់ផ្គង់រូបិយវត្ថុចែកនឹង ផ.ស.ស នៃប្រទេសឧស្សាហកម្មទាំង ៦ មាន សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ជប៉ុន ចិន ចក្រភពអង់គ្លេស និងកាណាដា) បានកើនឡើងពី ២០% ក្នុងឆ្នាំ ១៩៨០-១៩៧០ ដល់ ៣០% ក្នុងឆ្នាំ ២០០៦-២០០៧ ។ ទុនបម្រុងអន្តរជាតិរបស់ប្រទេសកំពុងងើបឡើង និង ការពង្រីកឥណទានកើនឡើងលឿនពេក (កំណើនសេដ្ឋកិច្ច ការធ្លាក់ចុះអត្រាការប្រាក់ពិត និង ការបង្កើតផលិតផលហិរញ្ញវត្ថុថ្មីៗ) ។

- ***ការធ្លាក់ចុះអតិផរណា និង ភាពប្រែប្រួល*** ក្នុងពិភពលោក ។

- ***ការធ្លាក់ចុះលាភការហានិភ័យដោយសារតែឥរិយាបថហ៊ានទទួលយកហានិភ័យ*** ÷ សាច់ប្រាក់កើនខ្លាំងនាំឱ្យភ្នាក់ងារសេដ្ឋកិច្ចនាំគ្នាចាប់យកទ្រព្យសកម្មដែលមានហានិភ័យខ្ពស់ សម្រាប់ជាជំហរ និងស្វែងរកផលវិនិយោគខ្ពស់។ ផ្ទុយទៅវិញ ចាប់តាំងពីខែសីហា ឆ្នាំ ២០០៧មក ការហ៊ានទទួលយកហានិភ័យបានធ្លាក់ចុះយ៉ាងខ្លាំង ។

- ***ការធ្លាក់ចុះអត្រាការប្រាក់រយៈពេលវែង ការធ្លាក់ចុះអតិផរណា និង ការប្រែប្រួល*** ជាមួយនឹងការធ្លាក់ចុះលាភការហានិភ័យ នាំឱ្យអត្រាប្តូរប្រាក់រយៈពេលវែងធ្លាក់ចុះ ទោះបីជាមានការរឹតបន្តឹង (ដោយយឺតពេល) នូវគោលនយោបាយរូបិយវត្ថុនៅសហរដ្ឋអាមេរិក ។

- ***ការពង្រីកឥណទានក្នុងបរិបទអត្រាអតិផរណាទាប*** ÷ ការធ្លាក់ចុះអត្រាការប្រាក់និងលាភការហានិភ័យបង្កើត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លក្ខខណ្ឌឱ្យឃើញថា ឥណទានមានការប្រាក់ទាប និងសម្បូរណ៍ ។ កំណើនដែលមានអត្រាអតិផរណាទាបបានបន្តកើតឡើង ទោះបីជាតម្លៃវត្ថុធាតុដើម (ប្រេង លោហធាតុ និង ម្ហូប អាហារ) កើនឡើង ដោយសារតែកំណើនតម្រូវការពីប្រទេសកំពុងងើបឡើង ។ ការធ្លាក់អត្រាការប្រាក់ និងតម្លៃហានិភ័យផ្តល់ជាលក្ខខណ្ឌអនុគ្រោះសម្រាប់សកម្មភាពដែលមានបំណុលខ្ពស់ ក្នុងនោះរួមមាន កំណើនបំណុលនៃ **មូលនិធិគេចយកចំណេញ** (Hedge funds) ធនាគារពាណិជ្ជ និង មូលនិធិម្ចាស់ទុនឯកជន (Private equity fund)។

- ***កំណើនតម្លៃទ្រព្យសកម្ម*** : នៅពេលមានសាច់ប្រាក់លើស តែមិនជះឥទ្ធិពលលើតម្លៃទំនិញ និង សេវាកម្ម ឥទ្ធិពលរបស់វាបានជះទៅលើតម្លៃទ្រព្យសកម្មវិញ ដោយសារតែការផ្គត់ផ្គង់ទ្រព្យសកម្មតិច ។ កំណើនតម្លៃទ្រព្យសកម្មបង្កើតលក្ខខណ្ឌល្អសម្រាប់បង្កើនកម្ចីបញ្ចាំទ្រព្យ ។ កំណើនតម្លៃទ្រព្យសកម្ម ធ្វើឱ្យមានកំណើនសុខមាលភាព រួចនាំទៅរកកំណើនចំណាយប្រើប្រាស់ ។

- ***កំហុសផ្នែកមីក្រូសេដ្ឋកិច្ច*** ១)- ការស្វែងរកផលវិនិយោគខ្ពស់ វិនិយោគិនពឹងទៅលើទីផ្សារប័ណ្ណបំណុល (ការស្វែងរកគុណភាព) ២)- ធនាគារពាណិជ្ជប្រើយុទ្ធសាស្ត្រមុខពីរ ដោយបង្កើនទំហំសកម្មភាព របស់ខ្លួន និង បន្ធូរលក្ខខណ្ឌឱ្យខ្ចីប្រាក់ និង ការដាក់ចេញនូវផលិតផលហិរញ្ញវត្ថុថ្មី និង ៣)- បន្ធូរលក្ខខណ្ឌឱ្យខ្ចីបំណុល ទំហំនៃកម្ចីអនុគ្រោះ (ផ្តល់ជូនចំពោះអ្នកខ្ចីដែលមានហានិភ័យខ្ពស់) កើនឡើង ៧ដង ពី ៩៤ ពាន់លាន នៅឆ្នាំ ២០០១ ដល់ ៦៨៥ ពាន់លាន នៅឆ្នាំ ២០០៦ ។ កម្ចីដែលមានអត្រាការប្រាក់អណ្តែត កើនឡើងយ៉ាងខ្លាំងស្របនឹងថយចុះកម្ចីការប្រាក់ថេរ ។

***ការទទួលយកហានិភ័យខ្ពស់ក្នុងវិស័យហិរញ្ញវត្ថុ*** ភាពរឹងមាំមួយនៃការត្រួតពិនិត្យធនាគារពាណិជ្ជ គឺត្រូវបង្កើនដើមទុនរបស់ធនាគារ អោយសមស្របទៅនឹងទំហំឥណទាន ដើម្បីកំហិតធនាគារពាណិជ្ជមិនឱ្យផ្តល់ប្រាក់កម្ចីលើសពីសមត្ថភាពរបស់ខ្លួន ។ តែស្ថាប័នហិរញ្ញវត្ថុបានបង្កើតយុទ្ធសាស្ត្រ ដើម្បីជៀសវាងការអនុវត្តនូវបទបញ្ញត្តិនេះ ដោយប្រើការធានារ៉ាប់រងកម្ចី ។

### ៥ . ២- ដំណើរឆ្ពោះទៅវិបត្តិ

អ្នកផ្តល់ឥណទានសាងសង់យកកម្ចីអនុគ្រោះ បែងចែកបន្តឱ្យគេហជនដែលមានចំនូលទាប ដែលគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាននូវកម្ចីធម្មតា និង ដែលមានប្រវត្តិធ្លាប់មិនបានសងបំណុលពីពេលមុន ។ គេហជនទាំងនេះមិនដឹងថា អត្រាការប្រាក់ជាអត្រាអណ្តែត ឬនឹងកើនក្រោយពេល ១ ឬ ២ ឆ្នាំបន្ទាប់ឡើយ។

អ្នកផ្តល់ឥណទានសាងសង់បានលក់កម្ចីអនុគ្រោះទៅឱ្យធនាគារវិនិយោគ (ជួនកាល អ្នកផ្តល់ឥណទានសាងសង់ និង ធនាគារវិនិយោគ ជាក្រុមតែមួយ) ។

ដោយសារនវានុវត្តន៍ហិរញ្ញវត្ថុ វិស្វករហិរញ្ញវត្ថុបានបម្លែងកម្ចីអនុគ្រោះ តាមរយៈការធានាឱ្យទៅជាមូលបត្រ មានដូចជា **មូលបត្របញ្ចាំឥណទានសាងសង់** (Mortgage Backed Securities) ឬ ក៏


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មូលបត្របញ្ចាំទ្រព្យសកម្ម** (Asset Backed Securities) ហើយបន្ទាប់មកយកមូលបត្រទាំងពីរប្រភេទ នេះទៅបង្កើត **ភាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំ** (Collateralized Debt Obligation-CDOs) ។ **ភាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំ** ដែលបង្កើតឡើងដោយឈរលើមូលដ្ឋាននៃ **មូលបត្របញ្ចាំឥណទានសាងសង់** និង **មូលបត្របញ្ចាំទ្រព្យសកម្ម** ត្រូវបានដាក់ចំណាត់ថ្នាក់ដោយដោយភ្នាក់ងារចាត់ថ្នាក់ (Rating agencies) មានដូចជា ក្រុមហ៊ុន **មូឌី** ឬ **អេសនិងភី** ដើម្បីចាត់ថ្នាក់ និង បំបែកហានិភ័យ ។

ធនាគារវិនិយោគទិញ CDOs ដែលមានប្រភពពី ABS រាប់ពាន់លានដុល្លារ ដើម្បីទុកខ្លួនឯង និង ទិញអោយអតិថិជនរបស់ខ្លួន ពីព្រោះតែវាផ្តល់ប្រាក់ចំណេញខ្ពស់ជាង ប័ណ្ណរតនាគាអាមេរិក ។

ដើម្បីការពារហានិភ័យ ធនាគារវិនិយោគទិញសេវាធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងឯកទេស (ក្រុមហ៊ុនធានាឥណទាន) ឬ ក៏ទិញមូលបត្រពិសេសដែលហៅថា **បន្ទេរបំណុលខូច** (Credit Default Swap--CDS) ដែលបោះផ្សាយដោយធនាគារវិនិយោគ ។ **បន្ទេរបំណុលខូច** (CDS) បានក្លាយទៅជាទីផ្សារពេញទីតែម្តង ។ ប៉ុន្តែហានិភ័យប្រភេទនេះមិនមានលក្ខណៈអាចធានារ៉ាប់រងឡើយ ។

នៅពេលដែលអត្រាការប្រាក់ចាប់ផ្តើមកើនឡើងនៅចុងឆ្នាំ ២០០៦ គ្រួសារអាមេរិកជាច្រើនដឹងថាខ្លួនមិនអាចទូរទាត់សំណងប្រចាំខែបានទេ ។ ដោយសារតែមិនអាចសងការប្រាក់លើកម្ចីបញ្ចាំទ្រព្យ ធនាគាររឹបអូសយកផ្ទះសម្បែងដើម្បីយកលុយទូរទាត់បំណុល ។ ប៉ុន្តែដោយសារតែមានគ្រួសារច្រើនពេកជួបបញ្ហាដូចគ្នា ទីផ្សារអចលនវត្ថុត្រូវចុះថ្លៃដួលរលំ ។

វិនិយោគិនដែលទិញ (CDO) តាមរយៈ **មូលនិធិសន្សំហាធន** (Mutual Funds) ដឹងថាមូលបត្រមានការធានាដោយទ្រព្យបញ្ចាំមិនអាចផ្តល់ផលទៀតទេ ។ ដូចនេះ អ្នកដែលមានមូលបត្រទាំងនេះក៏ចាប់ផ្តើមលក់ CDO ចោល ហើយធ្វើឱ្យទីផ្សារCDO នេះដួលរលំ ។ ក្រុមហ៊ុនធានាឥណទាន ដែលត្រូវធានាលើតម្លៃមូលបត្រ CDO មិនអាចទូរទាត់សំណងបាន ក៏ប្រកាសក្ស័យធន ។ រួចហើយ ធនាគារវិនិយោគត្រូវបញ្ចុះតម្លៃ CDO ដែលមាននៅក្នុងគណនីរបស់ខ្លួន ។

ធនាគារទាំងអស់ដឹងច្បាស់ពីបរិមាណ និង តម្លៃនៃ «CDO**ចំពុល**» ដែលមានក្នុងបញ្ជីគណនីរបស់ខ្លួន ប៉ុន្តែមិនដឹងថា តើធនាគារផ្សេងទៀតមានបញ្ហាកម្រិតណាទេ ។ ធនាគារដោយមានការប្រុងប្រយ័ត្ន ក៏ចាប់ផ្តើមមិនផ្តល់ឥណទានឱ្យធនាគារមួយទៀត លើកលែងតែក្នុងករណីទទួលបាននូវអត្រាការប្រាក់ខ្ពស់តែប៉ុណ្ណោះ ។ ដូចនេះ ធនាគារដែលពឹងផ្អែកទៅលើ **ទីផ្សារអន្តរធនាគារ** ក្នុងការបំពេញហិរញ្ញប្បទានរបស់ខ្លួន ចាប់ផ្តើមមានបញ្ហាខាងផ្នែកហិរញ្ញវត្ថុ ។ ទីផ្សារកាន់តែស្មុគ្រស្មាញ និង មានភាពមិនច្បាស់លាស់ ហើយការក្ស័យធនរបស់ស្ថាប័នហិរញ្ញវត្ថុមួយបានជះឥទ្ធិពលដល់ធនាគារមួយទៀត ហៅថា ឥទ្ធិពលសម្លរកំពិស (Domino effect) ។ ដូចនេះការក្ស័យធនរបស់ធនាគារមួយជះរលកឥទ្ធិពលដល់ធនាគារដទៃទៀត ដែលពាក់ព័ន្ធ ។

# ផ្នែកទី ៤

# ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា

## ជំពូកទី ១៥

## ដុល្លារូបនីយកម្ម និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា

### ១ - ដុល្លារូបនីយកម្មនៅកម្ពុជា

មានអត្ថបទជាច្រើនសរសេរអំពីដុល្លារូបនីយកម្ម មានដូចជា Belino Bennet និង Borensztein (១៩៩៩) Berg & Borensztein (២០០០ក និង ២០០០ខ) Bogetic (២០០០) Calvo និង Vegh (១៩៩២) Ortiz (១៩៨៣) ជាដើម ។

ដុល្លារូបនីយកម្មកើតឡើងក្នុងរូបភាពជាច្រើនផ្សេងៗគ្នាទៅតាមសេដ្ឋកិច្ចនីមួយៗ ។ អត្ថបទសេដ្ឋកិច្ចអំពីដុល្លារូបនីយកម្មប្រើពាក្យពេចន៍ខុសៗគ្នា ដើម្បីពិពណ៌នាពីបាតុភូតនេះ ដូចជាវាក្យស័ព្ទ ដុល្លារូបនីយកម្ម ដុល្លារូបនីយកម្មផ្លូវការ ដុល្លារូបនីយកម្មក្រៅផ្លូវការ ដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការ ដុល្លារូបនីយកម្មពេញទំហឹង ការជំនួសរូបិយវត្ថុ ការជំនួសទ្រព្យសកម្មជាដើម ។ល។

លោក Ortiz (១៩៨៣) ឱ្យនិយមន័យ **ដុល្លារូបនីយកម្ម** ថាជាកម្រិតផលធៀបរវាងប្រតិបត្តិការជាក់ស្តែង និងហិរញ្ញវត្ថុ ធ្វើឡើងជាប្រាក់ដុល្លារ ដោយប្រៀបធៀបទៅនឹងរូបិយវត្ថុក្នុងស្រុក ។ និយមន័យដុល្លារូបនីយកម្មនេះ និយាយអំពីការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ជាមធ្យោបាយដោះដូរទូទាត់ នៅក្នុងសេដ្ឋកិច្ចមួយ នៅក្រៅព្រំដែនសហរដ្ឋអាមេរិច ។

យោងតាម Calvo និង Vegh (១៩៩២) *ការជំនួសរូបិយវត្ថុ* គឺជាការប្រើប្រាស់រូបិយប័ណ្ណបរទេសជាសាច់ប្រាក់ និង ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស នៅក្នុងសេដ្ឋកិច្ចជាតិ ។ McKinnon (១៩៩៦) វិភាគបន្ថែមកាន់តែស៊ីជម្រៅទៀត ដោយបែងចែកដាច់ពីគ្នារវាង *ការជំនួសរូបិយវត្ថុ* និង *ការជំនួសទ្រព្យសម្បត្តិ* ដោយបញ្ចូលទាំងពីរនេះ ជាមូលហេតុនាំឱ្យមានតម្រូវការទ្រព្យសកម្មជារូបិយប័ណ្ណបរទេស ដោយសង្កត់ធ្ងន់ទៅលើការប្រើប្រាស់ដុល្លារ ជាមធ្យោបាយដោះដូរ (**ការជំនួសរូបិយវត្ថុ**) និង សម្រាប់រក្សាតម្លៃ (**ការជំនួសទ្រព្យសកម្ម**) ។

ទន្ទឹមនឹងនេះ ក៏មានអត្ថបទសិក្សាជាច្រើនទៀត ឧទាហរណ៍ដូចជា ការសិក្សាធ្វើដោយ **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** (SNEC ២០០២) និង De Zamaroczy និង Sa (២០០២) ដែលវែកញែក ពីផលប្រយោជន៍ និងការខាតបង់បណ្តាលមកពីដុល្លារូបនីយកម្ម ។ ប៉ុន្តែមានការសិក្សាតិចតួចណាស់ ដែលសង្កត់លើទំនាក់ទំនងរវាងដុល្លារូបនីយកម្ម នឹងគោលនយោបាយរូបិយវត្ថុ និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។ ដោយផ្អែកលើ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ហេតុផលខាងលើនេះហើយ ទើបគោលបំណងរបស់អត្ថបទនេះ គឺដើម្បីបំពេញចន្លោះនោះ ដោយវែកញែកអំពីផលប៉ះពាល់នៃដុល្លារូបនីយកម្មមកលើ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុនៅក្នុងប្រទេសកម្ពុជា ។

ក្នុងបរិបទនៃប្រទេសកម្ពុជា ដុល្លារូបនីយកម្មអាចឱ្យនិយមន័យថា ជាការប្រើប្រាស់ដុល្លារអាមេរិក សម្រាប់មុខងារទាំង ៣ របស់រូបិយវត្ថុក្នុងសេដ្ឋកិច្ចមួយ ដែលនៅក្រៅដែនសេដ្ឋកិច្ចអាមេរិក គឺជា **ខ្នាតរង្វាស់តម្លៃ មធ្យោបាយដោះដូរ** និងជាពិសេស **ឧបករណ៍រក្សាតម្លៃ** ។ ជាទូទៅ ពាក្យ «ការជំនួសរូបិយវត្ថុ» ប្រើសំដៅលើការប្រើប្រាស់រូបិយប័ណ្ណបរទេស ជាមធ្យោបាយដោះដូរនៅក្នុងសេដ្ឋកិច្ច ។ ពាក្យ «ដុល្លារូបនីយកម្ម» ប្រើប្រាស់ជាពិសេសសម្រាប់រៀបរាប់អំពីរបបរូបិយវត្ថុនៅកម្ពុជា ដែលក្នុងនោះដុល្លារអាមេរិកជារូបិយប័ណ្ណចរាចរឈានមុខគេ ទោះបីជាមានរូបិយវត្ថុជាតិ គឺ ប្រាក់រៀលក៏ដោយ ។

ដុល្លារូបនីយកម្មកើតមានឡើងតាមវិធីជាច្រើន ។ ***ដុល្លារូបនីយកម្មដោយអន្លើ*** កើតឡើងពេលដែលប្រជាជនរក្សាទុកភាគនូវខ្លះនៃទ្រព្យសម្បត្តិហិរញ្ញវត្ថុរបស់ខ្លួន ក្នុងរូបភាពជាទ្រព្យសកម្មបរទេស ។ លក្ខណៈនេះដូចគ្នានឹង «ការជំនួសទ្រព្យសកម្ម» ដែរ ។ ក្នុងករណីខ្លះ ការជំនួសរូបិយវត្ថុកើតមានឡើង ទោះបីជារូបិយប័ណ្ណបរទេសគ្មានការទទួលស្គាល់ថាស្របច្បាប់ក៏ដោយ ។ ករណីនេះហៅថា ***ដុល្លារូបនីយកម្មក្រៅផ្លូវការ*** ។ ប្រាក់ឈ្នួលពន្ធ និងចំណាយប្រចាំថ្ងៃត្រូវបានទូទាត់ដោយប្រើប្រាស់នូវរូបិយវត្ថុក្នុងស្រុក នៅពេលដែលចំណាយសំខាន់ៗភាគច្រើនត្រូវបានទូទាត់ដោយប្រើប្រាស់រូបិយប័ណ្ណបរទេស ។

***ដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការ*** កើតមានឡើងនៅពេលដែលសេដ្ឋកិច្ចជាក់ស្តែងមានប្រព័ន្ធរូបិយវត្ថុប្រើប្រាស់នូវរូបិយវត្ថុពីរ ។ នៅក្នុងប្រព័ន្ធនេះ រូបិយប័ណ្ណបរទេស ដើរតួនាទីជារូបិយវត្ថុស្របច្បាប់ និង ត្រូវបានប្រើប្រាស់យ៉ាងខ្លាំងក្លាតែម្តង ជាប្រាក់បញ្ញើធនាគារ ។ ក៏ប៉ុន្តែ រូបិយប័ណ្ណបរទេសមិនដើរតួសំខាន់ ដូចរូបិយវត្ថុជាតិទេ ដែលប្រើប្រាស់សម្រាប់សម្រាប់បើកប្រាក់បៀវត្ស និងបង់ពន្ធ ។ សេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការ ដូចជាសេដ្ឋកិច្ចកម្ពុជា ក៏នៅមានធនាគារកណ្តាល ឬ អាជ្ញាធររូបិយវត្ថុ ដូចជា ធនាគារជាតិនៃកម្ពុជា ហើយមានភាពបទបែនទទន់ភ្លន់ ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។

***ដុល្លារូបនីយកម្មផ្លូវការ*** ឬហៅថា **ដុល្លារូបនីយកម្មពេញទំហឹង**កើតមានឡើង នៅពេលដែលរូបិយប័ណ្ណបរទេស មានឋានៈផ្តាច់មុខ ឬលើសលប់ជាងគេ ជារូបិយវត្ថុស្របច្បាប់សម្រាប់ដោះដូរ ។ ប្រការនេះមានន័យថា រូបិយប័ណ្ណបរទេសមិនត្រឹមតែមានតួនាទីស្របច្បាប់ សម្រាប់ប្រើប្រាស់ក្នុងកិច្ចសន្យារវាងភាគីឯកជនប៉ុណ្ណោះទេ តែរដ្ឋាភិបាលក៏ប្រើប្រាស់រូបិយប័ណ្ណបរទេសសម្រាប់រាល់ប្រតិបត្តិការក្នុងស្រុកដែរ ។ រូបិយវត្ថុជាតិនៅតែមានអត្ថិភាព ប៉ុន្តែមានមុខងារ និងតួនាទីមិនសូវសំខាន់ឡើយ ។

***ការជំនួសរូបិយវត្ថុ*** កើតមានឡើងនៅពេលដែល អាត្រាអតិផរណាខ្ពស់និងប្រែប្រួលឥតឈប់ឈរធ្វើឱ្យប្រជាជនមិនចង់ប្រើប្រាស់រូបិយវត្ថុជាតិ ។ ***ការជំនួសទ្រព្យសកម្ម*** អាចបណ្តាលមកពីប្រជាជនគេចមិន



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រើប្រាស់រូបិយវត្ថុជាតិ ដោយងាកទៅរកទ្រព្យសកម្មជារូបិយប័ណ្ណបរទេសជាមធ្យោបាយរក្សាទុកតម្លៃ ។ លើសពីនេះទៅទៀត ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដុល្លាររូបនីយកម្មបានរីកដុះដាលក្នុងប្រទេសមួយចំនួន ដោយសារការវិវត្តស្ថាប័ន ជាពិសេសសេរីភាវូបនីយកម្មនៃគណនីមូលធន ដែលបានសម្រួលដល់ដំណើរការនេះ ។ ដូចនេះហើយការកើនឡើងនៃទ្រព្យសកម្មជារូបិយប័ណ្ណបរទេសក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ជាផលវិបាកនៃការកើនឡើងនៃវិនិយោគជាមូលបត្រ (Portfolio) ក្រោមឥទ្ធិពលនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

ទន្ទឹមនឹងលំហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់នៃហិរញ្ញប្បទានផ្លូវការដើម្បីអភិវឌ្ឍន៍ និងបន្ទេរប្រាក់ឯកជនស្ថានភាពអតិផរណាខ្ពស់ និង ភាពមិនច្បាស់លាស់ខាងផ្នែកនយោបាយ ដុល្លាររូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជាចាប់ផ្តើមកើតឡើងនៅអំឡុងដើមទសវត្សទី ៩០ ។ ក្នុងដំណាក់កាលដំបូង ដុល្លាររូបនីយកម្មលេចឡើងក្នុងសេដ្ឋកិច្ចកម្ពុជា ដោយសារការបាត់បង់ទំនុកចិត្តរបស់សាធារណជនលើប្រាក់រៀល អតិផរណាខ្ពស់ហួសហេតុ និងការថយចុះយ៉ាងឆាប់រហ័សនៃអំណាចទិញរបស់រូបិយវត្ថុក្នុងស្រុក ។ ហើយ បាតុភូតសេដ្ឋកិច្ចនេះនៅតែបន្តទោះបីជាកម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងកំឡុងជាងមួយទសវត្សចុងក្រោយក៏ដោយ ។ កំណើនសាច់ប្រាក់ក្នុងចរាចរណ៍ ភាគច្រើនបណ្តាលមកពីកំណើននៃទ្រព្យសកម្មនៅបរទេស ដែលឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ។

បច្ចុប្បន្ននេះ កម្ពុជាជាសេដ្ឋកិច្ចមួយមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ ដោយទ្រព្យសកម្មធនាគារ ៩៧,៨% ត្រូវបានរក្សាទុកជាដុល្លារអាមេរិក ។ ទំនោរនេះនឹងពុំត្រលប់ក្រោយឆាប់ៗឡើយ ។ មកដល់ឆ្នាំ ២០០៦ ប្រាក់បញ្ញើជារៀលក្នុងធនាគារកើន ២៦% ខណៈដែលប្រាក់បញ្ញើជាដុល្លារកើន ៨៦% ។ ផលធៀបប្រាក់បញ្ញើរូបិយប័ណ្ណបរទេសជាមួយនឹងប្រាក់បញ្ញើសរុបកើនឡើងពី ៨៤,៣% នៅឆ្នាំ ១៩៩៣ ដល់ ៩៧% នៅឆ្នាំ ២០០៦ ។ ដូចនេះមានតែប្រាក់បញ្ញើ ៣% និង កម្ចី ៥% ប៉ុណ្ណោះ ដែលជាលុយរៀល ។

សេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លាររូបនីយកម្មយ៉ាងខ្លាំង ប៉ុន្តែពុំមែនទាំងស្រុងពេញធឹងទេ ទោះបីជាយើងមិនដឹងពីទំហំពិតប្រាកដនៃប្រាក់ដុល្លារ និងរូបិយប័ណ្ណដទៃទៀតដែលនៅក្រៅប្រព័ន្ធធនាគារក៏ដោយ (តែជាទូទៅយើងសន្មតថា រូបិយប័ណ្ណបរទេសគ្របដណ្តប់ប្រហែល ៩០% នៃសាច់ប្រាក់ចរាចរសរុប) ។ លុយដុងវៀតណាមនិងលុយបាតថៃត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងខេត្តដែលជាប់ព្រំដែនប្រទេសទាំងនោះ ប៉ុន្តែប្រាក់ដុល្លារអាមេរិកមានចំណែកធំជាងគេលើសលុប ក្នុងចំណោមរូបិយប័ណ្ណដែលកំពុងប្រើប្រាស់ក្នុងប្រទេសកម្ពុជា ។

ជំពូក ១៥ នេះព្យាយាមផ្តល់ជាវិភាគទានខ្លះដល់ការស្វែងយល់ អំពីទំនាក់ទំនងរវាងដុល្លាររូបនីយកម្ម និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ។

## ២. ដុល្លាររូបនីយកម្ម និង គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ដុល្លាររូបនីយកម្មជួយបង្កើនស្ថិរភាព និងជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ប៉ុន្តែក៏បានដាក់កំហិតយ៉ាងខ្លាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដល់វិសាលភាពនៃគោលនយោបាយរូបិយវត្ថុ ក្នុងការចាត់ចែងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ហើយក៏អាចប៉ះពាល់ដល់តួនាទីនៃគោលនយោបាយរូបិយវត្ថុជាឧបករណ៍សម្រាប់ជំរុញកំណើនដែរ ។ តារាងតុល្យភាពនៃប្រយោជន៍ និងការខាតបង់នៃដុល្លារូបនីយកម្ម នឹងត្រូវបង្ហាញខាងក្រោមដូចតទៅ ÷

## ២.១ ដុល្លារូបនីយកម្ម និងគោលនយោបាយរូបិយវត្ថុ

ដុល្លារូបនីយកម្មមានឥទ្ធិពលខ្លាំងដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ជាពិសេស ផលប្រយោជន៍ខាងក្រោមនេះបានរួមចំណែកដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រួមមាន÷

- **ស្ថិរភាព និងការការពារទប់ទល់នឹងហានិភ័យអត្រាប្តូរប្រាក់** ៖ ក្នុងសេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ប្រតិបត្តិការពាណិជ្ជកម្ម និងហិរញ្ញវត្ថុធំៗ ធ្វើឡើងជាប្រាក់ដុល្លារ ។ កត្តានេះកាត់បន្ថយលទ្ធភាពធ្លាក់ចុះនូវតម្លៃរូបិយវត្ថុជាតិ ។ ប្រតិបត្តិការជាលុយរៀលមានកម្រិតទាប ហើយទីផ្សារលុយរៀលក៏តូចដែរ ដោយសារមានឱកាសបន្តិចបន្តួចដើម្បីកេងយកចំណេញ ។ ហេតុដូចនេះហើយ លុយរៀលមានស្ថិរភាពយ៉ាងខ្លាំង អត្រាប្តូរប្រាក់រៀលធ្លាក់តម្លៃធៀបនឹងប្រាក់ដុល្លារ ស្ថិតនៅជុំវិញ ១% ជាមធ្យមប្រចាំឆ្នាំ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយគិតដល់ឆ្នាំ ២០០៥ ។ ជាលទ្ធផល ការកើនឡើងនៃថ្លៃទំនិញនាំចូលមិនបានធ្វើអោយទំនិញក្នុងស្រុកឡើងថ្លៃជាស្វ័យប្រវត្តិទេ ។ ដូច្នេះហើយ ទើបអតិផរណានៅកម្ពុជានៅមានកម្រិត ។

- **ការពារទប់ទល់នឹងវិបត្តិរូបិយវត្ថុ** ៖ ដោយសារគ្មានសម្ពាធដើម្បីការពារអត្រាប្តូរប្រាក់ ដូចនេះ ហានិភ័យនៃវិបត្តិតុល្យភាពជញ្ជីងទូទាត់ និងភាពងាយរងគ្រោះពីការរីកសាយនៃវិបត្តិ អាចកាត់បន្ថយបានជាច្រើន ហើយក៏មិនចាំបាច់ប្រើរូបិយវត្ថុជាតិ ដើម្បីកាត់បន្ថយតម្រូវការ តាមរយៈការកែប្រែថ្លៃក្នុងស្រុកដែរ ។ យ៉ាងណាក៏ដោយ ជម្រើសនេះមិនអាចអនុវត្តបានឡើយ ក្នុងសេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ។ ការកែសម្រួលថ្លៃអាចធ្វើបានតែក្នុងមុខទំនិញខ្លះ និងលើទីផ្សារកត្តាផលិតកម្មតែប៉ុណ្ណោះ ។

- **ការបាត់បង់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ** ៖ ការខាតបង់ដ៏ធំមួយទៀត គឺការបាត់បង់ភាពទន់ភ្លន់នៃគោលនយោបាយរូបិយវត្ថុ ។ ទោះតាមវិធីណាក៏ដោយ ធនាគារជាតិនៃកម្ពុជាដែលជាធនាគារកណ្តាលមិនមានឥទ្ធិពលលើរូបិយប័ណ្ណអន្តរជាតិ ដែលជាធាតុមួយដ៏ច្រើនលើសលប់នៃរូបិយវត្ថុក្នុងចរាចរ និង មិនអាចកំណត់ដោយផ្ទាល់នូវបរិមាណផ្គត់ផ្គង់សាច់ប្រាក់បានឡើយ ។ ការផ្គត់ផ្គង់សាច់ប្រាក់អាស្រ័យលើឥរិយាបថនៃភ្នាក់ងារសេដ្ឋកិច្ច ដែលមានទ្រព្យសកម្មជាប្រាក់រៀលផង និងជាប្រាក់ដុល្លារផងនៅក្នុងដៃ ។ ដូចនេះ សេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មពេញលេញមួយ គ្មានជម្រើសអ្វីក្រៅពីការអនុវត្តតាមគោលនយោបាយរូបិយវត្ថុនៃប្រទេសបោះពុម្ពប្រាក់នោះតែប៉ុណ្ណោះ គឺបានន័យថាកម្ពុជាតែងតែទទួលយកនូវផលប៉ះពាល់នៃការផ្លាស់ប្តូរនូវគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក តែមិនអាចមានឥទ្ធិពលទៅលើគោលនយោបាយរូបិយវត្ថុរបស់អាមេរិកឡើយ (Asymmetric shock) (Calvo ១៩៩៩)។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ធនាគារកណ្តាលបាត់បង់តួនាទីជាឥណទាយិកចុងក្រោយ**: ដុល្លារូបនីយកម្មមិនអាចលុបបំបាត់មិនឱ្យមានវិបត្តិធនាគារឡើយ ។ នៅពេលមានវិបត្តិ ធនាគារកណ្តាលមាននាទីជា **ឥណទាយិកចុងក្រោយ** ទៅឱ្យធនាគារពាណិជ្ជណាដែលខ្វះសាច់ប្រាក់ តែនៅមិនទាន់ក្ស័យធន ។ ដោយប្រាក់ដុល្លារជារូបិយវត្ថុចរាចរផ្លូវការ ដុល្លារូបនីយកម្មបិទផ្លូវមិនអោយធនាគារកណ្តាលផ្គត់ផ្គង់សាច់ប្រាក់រយៈពេលខ្លីទៅអោយប្រព័ន្ធធនាគារ ដើម្បីដោះស្រាយវិបត្តិគ្មានសាច់ប្រាក់គ្រប់គ្រាន់បានឡើយ ដោយសារតែទុនបម្រុងអន្តរជាតិរបស់ធនាគារកណ្តាលនៅមានកម្រិត ។ ប្រសិនបើប្រព័ន្ធធនាគារប្រើប្រាស់នូវរូបិយវត្ថុជាតិ នោះធនាគារកណ្តាលអាចបោះពុម្ពប្រាក់រៀលដើម្បីផ្គត់ផ្គង់ដល់ប្រព័ន្ធធនាគារដែលខ្វះសាច់ប្រាក់ ។ ការប្រើប្រាស់ប្រាក់ដុល្លារក្នុងប្រតិបត្តិការរបស់ធនាគារពាណិជ្ជ កាត់បន្ថយលទ្ធភាពរបស់ធនាគារកណ្តាលបន្តិចម្តងៗ ក្នុងនាមជាអ្នកធានាប្រព័ន្ធផាត់ទាត់ និងប្រាក់បញ្ញើក្នុងធនាគារ ។ ធនាគារកណ្តាលមិនអាចដាក់បញ្ចូលប្រាក់រៀលទៅក្នុងប្រព័ន្ធមួយ ដែលគ្របដណ្តប់ដោយប្រាក់ដុល្លារនោះឡើយ ។ មធ្យោបាយមួយគឺ ការរៀបចំឱ្យមានកម្ចីផ្តល់ដោយធនាគារបរទេស ។ ទោះបីជាវិធីនេះអាចធ្វើទៅរួច ក៏អស់សាហ៊ុយច្រើនដែរ ។ វិធីមួយទៀតគឺ ឱ្យធនាគារកណ្តាលសន្សំទុនបម្រុងអន្តរជាតិ ហើយធ្វើការជាមួយរតនាគារ ដើម្បីបង្កើតឱ្យមាន **មូលនិធិស្ថិរភាព** មួយ ដែលអាចប្រើប្រាស់ទប់ទល់នឹងការដកប្រាក់ចេញពីធនាគារដោយគំហុក ។ ដូចនេះ ធនាគារជាតិនៃកម្ពុជាមិនអាចបង្កើតឧបករណ៍គោលនយោបាយរូបិយវត្ថុមានប្រសិទ្ធភាពមួយបានឡើយ ហើយថែមទាំងបំបិទតួនាទីរបស់ខ្លួនជា **ឥណទាយិកចុងក្រោយ** ទៅឱ្យធនាគារដែលប្រឈមនឹងបញ្ហាខ្វះសាច់ប្រាក់ ។ ឧបករណ៍គោលនយោបាយដែលអាចប្រើប្រាស់បានតែមួយគត់ គឺទុនបម្រុងអន្តរជាតិ ដើម្បីផ្តល់កម្ចីទៅឱ្យធនាគារពាណិជ្ជ ។ ការធ្វើបែបនេះមិនអាចទប់ទល់បានយូរឡើយ ប្រសិនបើវិបត្តិសេដ្ឋកិច្ចអូសបន្លាយ ក្នុងរយៈពេលដ៏វែង ។

## ២.២ ដុល្លារូបនីយកម្ម និងគោលនយោបាយសារពើពន្ធ

ដុល្លារូបនីយកម្មអាចជះឥទ្ធិពលលើគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ ដូចតទៅ ÷

- **កែលម្អវិន័យថវិកា** : ដុល្លារូបនីយកម្មជួយកែលម្អវិន័យថវិកា ។ ខណៈដែលដុល្លារូបនីយកម្មមិនអាចលុបបំបាត់ឱនភាពថវិកា ឱនភាពទាំងនេះអាចផ្តល់ហិរញ្ញប្បទានតាមរយៈវិធីមានតម្លាភាព គឺ ហិរញ្ញប្បទានពីបរទេស ការតម្លើងពន្ធ ឬការបង្កើនបំណុលរដ្ឋាភិបាល ។ ដូចនេះ ដុល្លារូបនីយកម្មបានបង្កើនការយល់ដឹងរបស់អ្នករៀបចំគោលនយោបាយ អំពីភាពចាំបាច់ក្នុងការជៀសវាងការធ្វើហិរញ្ញប្បទាននៃឱនភាពថវិកាដោយប្រើហិរញ្ញប្បទានធនាគារ ដែលអាចធ្វើឱ្យអតិផរណាកាន់តែកើនឡើងខ្ពស់ទៅៗ ។ ហិរញ្ញប្បទានឱនភាពថវិកាដោយធនាគារ (មានន័យថារដ្ឋាភិបាលខ្ចីប្រាក់ពីធនាគារកណ្តាលដើម្បីបំពេញឱនភាពថវិកា) នឹងបង្កើនការផ្គត់ផ្គង់ប្រាក់រៀលដ៏ច្រើនលើសលប់ ដែលនឹងប៉ះពាល់ទៅដល់ទីផ្សាររូបិយវត្ថុ ហើយក៏ប៉ះពាល់ទៅដល់ការផ្គត់ផ្គង់ និងតម្រូវការប្រាក់ដុល្លារអាមេរិកផងដែរ ។ អត្រាប្តូរប្រាក់អាចឡើងចុះតាមរយៈរបៀបនេះ ។ ដូចនេះ ដុល្លារូបនីយកម្មតម្រូវឱ្យរដ្ឋាភិបាលធានាឱ្យបាននូវវិន័យថវិកា និងទូទាត់ឱនភាពថវិកា តាមរយៈជំនួយ ឬកម្ចីសម្បទានតែប៉ុណ្ណោះ មានន័យថាពីបរទេស (ជាដុល្លារអាមេរិក) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **គ្រប់គ្រងស្ថិរភាពអត្រាប្តូរប្រាក់** ៖ ដុល្លារូបនីយកម្មទាមទារឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសធនាគារជាតិផ្តល់សាច់ប្រាក់សម្រាប់ចំណាយថវិកាជាប្រាក់រៀល ក្នុងរបៀបមួយដែលអាចធានាស្ថិរភាពអត្រាប្តូរប្រាក់ ។ ដោយសារដុល្លារូបនីយកម្មកាត់បន្ថយសមត្ថភាពរបស់ធនាគារកណ្តាល ក្នុងការប្រើប្រាស់អត្រាការប្រាក់ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់សាច់ប្រាក់ និង តម្លៃនៃរូបិយវត្ថុជាតិ (អត្រាប្តូរប្រាក់) ហេតុដូចនេះហើយ គោលនយោបាយសារពើពន្ធមានតួនាទីសំខាន់ជាងគេ ក្នុងការធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ ការផ្គត់ផ្គង់ប្រាក់រៀលច្រើនពេកទៅក្នុងទីផ្សាររូបិយវត្ថុនឹងប៉ះពាល់ដល់អត្រាប្តូរប្រាក់ភ្លាមៗ ។ យ៉ាងណាក៏ដោយ ដោយសារការប្តូរប្រាក់ដោយសេរីសម្រាប់ប្រតិបត្តិការគណនីចរន្ត និងសេរីភាវូបនីយកម្មគណនីមូលធន គោលនយោបាយសារពើពន្ធគួរគិតទៅដល់លំហូរចេញ- ចូលនៃសាច់ប្រាក់ជាដុល្លារអាមេរិកតាមរយៈអត្រាប្តូរប្រាក់ ។ ជារួម ក្នុងបរិបទនៃដុល្លារូបនីយកម្ម គោលនយោបាយរូបិយវត្ថុត្រូវបានរៀបចំដើម្បីរក្សាលំនឹងអត្រាប្តូរប្រាក់តាមរយៈការគ្រប់គ្រងថវិកា ដូចជាគោលនយោបាយហិរញ្ញវត្ថុសាធារណៈជាដើម ។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចឱ្យបានរឹងមាំក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មមួយ ទាមទារឱ្យមានការសហការជិតស្និទ្ធរវាងធនាគារកណ្តាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ជួយរក្សាស្ថិរភាពថ្លៃ** ៖ គោលបំណងមួយនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គឺធានាស្ថិរភាពថ្លៃ និងកំណើនសេដ្ឋកិច្ច ។ កម្រិតអតិផរណាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងកំណើនសេដ្ឋកិច្ច ។ ក្នុងបរិការណ៍នៃសេដ្ឋកិច្ចដុល្លារូបនីយកម្ម ស្ថិរភាពថ្លៃអាចសំរេចបានតាមរយៈស្ថិរភាពអត្រាប្តូរប្រាក់ ដោយសារក្នុងប្រទេសកម្ពុជា ទំនិញប្រើប្រាស់ក្នុងប្រទេសមួយភាគធំនាំចូលពីបរទេស ។ ដូចនេះហើយបម្រែបម្រួលអត្រាប្តូរប្រាក់អាចជះឥទ្ធិពលភ្លាមៗទៅដល់បម្រែបម្រួលថ្លៃ ។ ក្នុងន័យនេះ ការគ្រប់គ្រងថវិកាអាចប្រើជាមធ្យោបាយមួយសម្រាប់ធានាស្ថិរភាពថ្លៃ ។

- **សម្រួលពាណិជ្ជកម្មអន្តរជាតិ និងសមាហរណកម្មសេដ្ឋកិច្ច** ៖ ដុល្លារូបនីយកម្មជួយកាត់បន្ថយចំណាយប្រតិបត្តិការ ដែលកើតឡើងមួយផ្នែក ដោយសារភាពខុសគ្នារវាងអត្រាទិញ និងលក់ ពេលដូររូបិយវត្ថុជាតិទៅរូបិយប័ណ្ណបរទេស ។ កត្តានេះបានរួមចំណែកទៅដល់កំណើនយ៉ាងឆាប់រហ័សនៃវិស័យកាត់ដេរ ។ ការការពារហានិភ័យរូបិយប័ណ្ណ ទប់ទល់នឹងដុល្លារអាមេរិក លែងមានភាពចាំបាច់ទៀតហើយ ។ កត្តានេះនឹងជួយដល់ការធ្វើសមាហរណកម្មទីផ្សារក្នុងស្រុកចូលទៅក្នុងទីផ្សារពិភពលោកទាំងមូល ។ ក្នុងសេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ទុនបម្រុងអន្តរជាតិប្រើប្រាស់ភាគច្រើន សម្រាប់ធានាបូរណភាពនៃប្រព័ន្ធធនាគារ ហើយប្រើបន្ទាប់បន្សំដើម្បីធានាស្ថិរភាពអាត្រាប្តូរប្រាក់ ។ ដូចនេះ ដុល្លារូបនីយកម្មអាចប្រើបាន សម្រាប់ជំរុញការកែលម្អស្ថាប័ន និង គណនេយ្យភាព និងតម្លាភាពហិរញ្ញវត្ថុ ។

- **បាត់បង់កម្រៃបោះផ្សាយក្រដាសប្រាក់** ៖ ការខាតបង់ដ៏សំខាន់នៃដុល្លារូបនីយកម្ម គឺការបាត់បង់កំរៃទទួលបានពីការបោះផ្សាយប្រាក់ ។ កំរៃនេះ ជាផលចំណេញកើតមានពីភាពខុសគ្នារវាងចំណាយការបោះពុម្ព និងបែងចែកក្រដាស់ប្រាក់ ទៅនឹងអំណាចទិញនៃក្រដាសប្រាក់ ។ អ្នកខ្លះប៉ាន់ស្មានថា ការបាត់បង់កម្រៃបោះផ្សាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាក់អាចមានចំនួនច្រើនសម្រាប់ប្រទេសកម្ពុជា ។ ការប៉ាន់ស្មាន ដោយធនាគារជាតិនៃកម្ពុជាចំពោះចំណូល ដែលបាត់បង់នេះ ស្ថិតនៅចន្លោះពី ២០ ទៅ ៩០ លានដុល្លារ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ១៦

# ការគ្រប់គ្រងរូបិយវត្ថុ

## ១ - គោលដៅនៃគោលនយោបាយរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុមានគោលបំណងដូចតទៅៈ ១) - ជំរុញឱ្យមាននិរន្តរភាពកំណើនសេដ្ឋកិច្ច ២) - លើកស្ទួយស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសស្ថេរភាពថ្លៃ ៣) - បង្កើតការងារ ៤) - ធានាស្ថេរភាពទីផ្សារហិរញ្ញវត្ថុ និង ទី៥) - លើកកំពស់ស្ថេរភាពទីផ្សារប្តូររូបិយប័ណ្ណបរទេស ។

ប្រទេសជាច្រើនដៅយកកម្រិតអតិផរណាទាប ជាគោលបំណងសំខាន់នៃគោលនយោបាយរូបិយវត្ថុរបស់ខ្លួន។ ប្រការនេះបង្កើតជាគោលបំណងអាចវាស់វែងបាន និងអាចយកជាបានការសម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និរន្តរភាពកំណើន និងការកាត់បន្ថយភាពក្រីក្រ ។ **ការកំណត់គោលដៅអតិផរណា** (Inflation targeting) ជាការផ្តល់អំណាចឱ្យធនាគារកណ្តាលគ្រប់គ្រង ចាត់ចែងការផ្គត់ផ្គង់រូបិយវត្ថុ និង ឥណទានក្នុងស្រុក ព្រមទាំងផ្តល់តួនាទីសំខាន់ដល់គោលនយោបាយរូបិយវត្ថុ ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ។ ក៏ប៉ុន្តែ របបសេដ្ឋកិច្ចដែលកំណត់គោលដៅអតិផរណា មិនអាចអនុវត្តបានក្នុងរបបសេដ្ឋកិច្ចដែលមានកម្រិតដុល្លាររូបនីយកម្មខ្ពស់បានទេ ។

ធនាគារកណ្តាលអាចកំណត់គោលដៅអថេរផ្សេងៗដែលផ្សំរួមគ្នា ដើម្បីសម្រេចគោលបំណងរបស់ខ្លួន ។ ឧទាហរណ៍ ធនាគារកណ្តាលអាចជ្រើសដៅយកស្ថិរភាពថ្លៃ និងកំណើនសេដ្ឋកិច្ចជាគោលបំនងរបស់ខ្លួន ហើយកំណត់យកសំណុំអថេរមួយ ដើម្បីសម្រេចគោលបំណងខាងលើនេះ ។ អថេរទាំងនេះហៅថា **គោលដៅពាក់កណ្តាលសម្រេច** (Intermediate target)។ ឧទាហរណ៍ ដើម្បីទទួលបានស្ថិរភាពថ្លៃ និងកំណើនសេដ្ឋកិច្ច ធនាគារកណ្តាលអាចដៅយកកំណើននៃរូបិយវត្ថុទូទៅ (M2) ឬអត្រាការប្រាក់ ដែលនឹងមានឥទ្ធិពលដោយផ្ទាល់លើកម្រិតកំណើន និងកម្រិតថ្លៃ ។

ប៉ុន្តែ ឧបករណ៍គោលនយោបាយរបស់ធនាគារកណ្តាល អាចគ្មានឥទ្ធិពលផ្ទាល់ សូម្បីតែទៅលើគោលដៅពាក់កណ្តាលសម្រេច ។ ជាធម្មតា ធនាគារកណ្តាលអាចជ្រើសគោលដៅជាសំណុំអថេរ ដែលរងឥទ្ធិពលពីឧបករណ៍គោលនយោបាយរបស់ខ្លួន មានដូចជាទុនបម្រុងសរុប (អាចជាទុនបម្រុងធនាគារ ឬ រូបិយវត្ថុគោល) ។ នេះហៅថា **គោលដៅប្រតិបត្តិ** (Operating target)។ ដោយប្រើ **គោលដៅពាក់កណ្តាលសម្រេច** និង **គោលដៅប្រតិបត្តិ** ធនាគារកណ្តាលអាចវាយតម្លៃបានរហ័ស ថាតើគោលនយោបាយរបស់ខ្លួនត្រឹមត្រូវឬទេ ប្រសើរជាងត្រូវរង់ចាំមើលរហូតដល់ឃើញផលនៃគោលនយោបាយរបស់ខ្លួន ដែលជាកំណើនសេដ្ឋកិច្ច និងកម្រិតថ្លៃ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឧទាហរណ៍មួយទៀត ធនាគារកណ្ដាលអាចសំដៅរក្សាគោលនយោបាយរូបិយវត្ថុឱ្យឆ្លើយតបនឹងកំនើន **ផ.ស.ស.** ដុល ១០% ។ ប្រសិនបើ ធនាគារកណ្ដាលប៉ាន់ស្មានថា ដើម្បីសម្រេចបានកំណើន ផ.ស.ស.ដុល ១០% គេត្រូវបង្កើនរូបិយវត្ថុទូទៅ ២០% (គោលដៅពាក់កណ្ដាលសម្រេច) ហើយដើម្បីសម្រេចគោលដៅពាក់កណ្ដាលសម្រេច គេត្រូវបង្កើនរូបិយវត្ថុគោល ១០% (គោលដៅប្រតិបត្តិ) ធនាគារកណ្ដាលនឹងប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុទាំងអស់ ដើម្បីសម្រេចឱ្យបានកំណើនរូបិយវត្ថុគោល ១០% ។ បើសិនជា ក្នុងកំឡុងពេលអនុវត្តគោលនយោបាយរូបិយវត្ថុ ធនាគារកណ្ដាលមើលឃើញថា រូបិយវត្ថុគោលកើនបានតែ ៦% នោះគេនឹងចាត់វិធានការដើម្បីបង្កើនថែម ៤% ទៀត ។

## ២ - ការកំណត់គោលដៅ

**គោលដៅប្រតិបត្តិ**មាន ២ ប្រភេទគឺៈ អត្រាការប្រាក់ និង ការផ្គត់ផ្គង់រូបិយវត្ថុ (មានដូចជា ទុនបម្រុងធនាគារ Mo, M1 ជាដើម) ។ ក្នុងឧទាហរណ៍របស់យើង ធនាគារកណ្ដាលដៅជ្រើសយកកំណើនរូបិយវត្ថុទូទៅ ២០% (គោលដៅពាក់កណ្ដាសម្រេច) ដើម្បីសម្រេចបានកំណើន ផ.ស.ស.ដុល ១០ % ។ គោលដៅនេះអាចសម្រេចបានដោយកម្រិតអត្រាការប្រាក់ ដែលឆ្លើយតបនឹងបរិមាណរូបិយវត្ថុទូទៅដែលយើងចង់បាន ។ ក៏ប៉ុន្តែក្នុងរបបដុល្លារូបនីយកម្មខ្ពស់ ធនាគារកណ្ដាលអាចកម្រិតបានតែបរិមាណរូបិយវត្ថុទូទៅប៉ុណ្ណោះ ដោយសារធនាគារពាណិជ្ជកំណត់អត្រាការប្រាក់ដោយឯករាជ្យ ដែលអត្រានេះស្មើនឹងតម្លៃហានិភ័យប្រទេស បូកនឹងអត្រាការប្រាក់អាមេរិក ។

លក្ខណៈសំខាន់ជាងគេក្នុងការរៀបចំគោលនយោបាយរូបិយវត្ថុ គឺការកំណត់យក **អថេរបង្គោល** (Nominal anchor) ដែលអ្នកធ្វើគោលនយោបាយរូបិយវត្ថុកម្រិតយកតម្លៃ ដូចជា អតិផរណា អត្រាប្តូរប្រាក់ ឬការផ្គត់ផ្គង់រូបិយវត្ថុ ។ ដោយប្រកាន់យក **អថេរបង្គោល** នោះការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្ដាលធ្វើឱ្យអថេរ ដូចជា អតិផរណា ឬការផ្គត់ផ្គង់រូបិយវត្ថុប្រែប្រួលនៅជុំវិញក្បែរតម្លៃបង្គោលនោះ ។ ឧទាហរណ៍ ប្រសិនបើថ្លៃត្រូវបានប្រើជាបង្គោល នោះធនាគារកណ្ដាលនឹងពិនិត្យតាមដានកម្រិតថ្លៃ ដើម្បីកុំឱ្យកើនឡើង ឬថយចុះលឿនពេក ដូច្នេះអាចរក្សាបានតម្លៃរូបិយវត្ថុ ។

### *២.១. ការកំណត់គោលដៅជាលក្ខខណ្ឌទីផ្សាររូបិយវត្ថុ*

វិធីសាស្ត្រនេះផ្អែកទៅលើការវិនិច្ឆ័យទីផ្សាររូបិយវត្ថុ តាមអព្ភន្តរញាណ (Intuition) និងតាមអារម្មណ៍ ។ វិធីដែលគេប្រើជាទូទៅគឺថា ធនាគារកណ្ដាលដាក់គោលដៅលក្ខខណ្ឌទីផ្សាររូបិយវត្ថុ ជាពិសេស អត្រាការប្រាក់ ។

លទ្ធផលនៃវិធីសាស្ត្រនេះគឺវាមានឥទ្ធិពលភាពស្របគ្នានឹងវដ្តសេដ្ឋកិច្ច មានន័យថានៅពេលសេដ្ឋកិច្ចកំពុងរីកចម្រើន ការផ្គត់ផ្គង់រូបិយវត្ថុមានកំណើនលឿនដែរ ហើយនៅពេលសេដ្ឋកិច្ចធ្លាក់ចុះ ការផ្គត់ផ្គង់រូបិយវត្ថុក៏មាន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កំណើនយឺតទៅតាមនោះដែរ ។ កំណើនចំណូលជាតិ កំឡុងពេលសេដ្ឋកិច្ចរីកចម្រើននាំឱ្យអត្រាការប្រាក់នៅទីផ្សារកើនឡើង បណ្ដាលមកពីកំណើនតម្រូវការកម្ចី ។ ពេលអត្រាការប្រាក់កើនឡើង ថ្លៃសញ្ញាប័ណ្ណនឹងធ្លាក់ចុះ ដូចនេះធនាគារកណ្ដាលត្រូវទិញសញ្ញាប័ណ្ណដើម្បីដេញថ្លៃឱ្យឡើង នោះអត្រាការប្រាក់នឹងថយមកត្រឹមគោលដៅដែលចង់បាន ។ ការកើនឡើងនៃ**មូលដ្ឋានរូបិយវត្ថុ** (Monetary base) នឹងធ្វើឱ្យការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង ហើយការពង្រីកវដ្ដធុរកិច្ចនឹងធ្វើឱ្យកំណើនរូបិយវត្ថុកើនកាន់តែលឿន ។ បញ្ហាមួយក្នុងការប្រើអត្រាការប្រាក់ជា**គោលដៅប្រតិបត្តិ** គឺវារួមចំណែកធ្វើឱ្យអតិផរណាកើនឡើងលឿនពេក មិនអាចគ្រប់គ្រងបាន ។ ក្នុងពេលសេដ្ឋកិច្ចធ្លាក់ចុះ ដំណើរការមានលក្ខណៈផ្ទុយពីខាងលើ ក្នុងនោះចំណូលធ្លាក់ចុះ ហើយកំណើនរូបិយវត្ថុក៏ថយចុះដែរ ។

## ២.២. ការកំណត់គោលដៅជារូបិយវត្ថុសរុប

ការកំណត់គោលដៅរូបិយវត្ថុ ជាការប្រើប្រាស់រូបិយវត្ថុសរុប ក្នុងគោលដៅពាក់កណ្ដាលសម្រេច ។ ប៉ុន្តែការអនុវត្តជាក់ស្ដែងខុសពីការលើកឡើងរបស់ **មីលតុន ហ្វ្រីដមែន** (Milton Friedman) ដែលថារូបិយវត្ថុសរុបត្រូវបានកំណត់គោលដៅឱ្យកើនក្នុងអត្រាមួយថេរ ។ ក្នុងការអនុវត្ត ធនាគារកណ្ដាលដាក់គោលដៅកំណើនរូបិយវត្ថុសរុប តាមអត្រាផ្សេងមួយចំនួន រួចពិនិត្យមើលថាតើគោលនយោបាយអត្រាការប្រាក់មួយណា (ឧទាហរណ៍ អត្រាការប្រាក់នៃមូលនិធិសហព័ន្ធ (Federal Fund) នៅអាមេរិក ឬអត្រាការប្រាក់នៃ **កម្ចីឆ្លងរាត្រី** រវាងធនាគារ) មានសង្គតិភាពជាមួយនឹងគោលបំណងដែលចង់បាន ។ គេអាចកំណត់គោលដៅនៃកំណើនរូបិយវត្ថុសរុបអោយ ទូលាយ ឧទាហរណ៍នៅសហរដ្ឋអាមេរិក គោលដៅធម្មតាសម្រាប់កំណើនរូបិយប័ណ្ណ (M1) គឺនៅចន្លោះពី ៣ % ទៅ ៦ % និង ពី ៤ % ទៅ ៧ % សម្រាប់កំណើនរូបិយវត្ថុក្នុងចរាចរណ៍ (M2) ។ ការកំណត់គោលដៅដូច្នេះ មានសង្គតិភាពទៅនឹងបម្រែបម្រួលអត្រាការប្រាក់នៃមូលនិធិសហព័ន្ធ នៅចន្លោះស្ទួគឺពី ៧,៥ % ទៅ ៨,២៥% ។ ក្នុងក្របខណ្ឌនេះ អត្រាការប្រាក់នៃមូលនិធិសហព័ន្ធជាគោលដៅប្រតិបត្តិនៃគោលនយោបាយរូបិយវត្ថុ ។

គុណសម្បត្តិនៃការកំណត់គោលដៅរូបិយវត្ថុ ធៀបជាមួយនឹងការកំណត់គោលដៅអោត្រាប្តូរប្រាក់មានដូចតទៅ៖

- **ទីមួយ**- គឺអនុញ្ញាតិឱ្យធនាគារកណ្ដាលកែសម្រួល សម្របគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍប្រទេស ។ ហើយអនុញ្ញាតិឱ្យធនាគារកណ្ដាលជ្រើសយក គោលដៅអតិផរណា ផ្សេងពីប្រទេសដ៏ទៃ ហើយគោលនយោបាយរូបិយវត្ថុមានភាពបត់បែនទន់ភ្លន់ អាចឆ្លើយតបបានទៅនឹងការឡើងចុះនៃធាតុចេញ ។

- **ទីពីរ**- ព័ត៌មានពីការសម្រេចគោលដៅរបស់ធនាគារកណ្ដាលអាចដឹងភ្លាមៗ ។ ដូចនេះ ការកំណត់គោលដៅបែបនេះអាចបញ្ជូនសញ្ញាភ្លាមៗ អំពីគោលជំហរគោលនយោបាយរូបិយវត្ថុ និងបំណងក្នុងការគ្រប់គ្រង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អតិផរណាទៅឱ្យសាធារណជន និង ទីផ្សារ ។

**ទីបី**- គណនេយ្យភាពរបស់ធនាគារកណ្តាលក្នុងការប្រើប្រាស់គោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាអតិផរណាឱ្យទាប មានភាពច្បាស់លាស់ ។

គុណវិបត្តិនៃការកំណត់គោលដៅរូបិយវត្ថុមានដូចតទៅ៖

- **ទីមួយ**- បើទំនាក់ទំនងរវាងគោលដៅរូបិយវត្ថុ និងអថេរបំណង (អតិផរណា ឬចំណូលដុល)ខ្សោយ ការដាក់គោលដៅរូបិយវត្ថុមិនបានការឡើយ ។ ដូចនេះ ការសម្រេចគោលដៅបាន មិនអាចបំពេញគោលបំណងដែលយើងចង់បានឡើយ ។ ក្នុងករណីបែបនេះ ការកំណត់គោលដៅរូបិយវត្ថុ នឹងមិនជួយបន្ថយអតិផរណា ដូចការរំពឹងទុកទេ និងមិនមែនជាវិធីប្រសើរសម្រាប់វាយតម្លៃគណនេយ្យភាពរបស់ធនាគារកណ្តាលឡើយ ។
- **ទីពីរ**- ទំនាក់ទំនងមិនច្បាស់លាស់រវាងគោលដៅរូបិយវត្ថុ និងគោលបំណងនៃគោលនយោបាយរូបិយវត្ថុ ធ្វើឱ្យការកំណត់គោលដៅរូបិយវត្ថុ មានការពិបាកយកទៅប្រើជាឧបករណ៍ ដើម្បីលើកកម្ពស់តម្លាភាពនៃគោល-នយោបាយរូបិយវត្ថុ ។

## ២.៣. ការកំណត់គោលដៅអត្រាប្តូរប្រាក់

ការកំណត់គោលដៅអត្រាប្តូរប្រាក់អាចធ្វើតាមរយៈ ការភ្ជាប់តម្លៃរូបិយវត្ថុជាតិទៅនឹងទំនិញមួយដូចជាមាស (**បទដ្ឋានមាស**—Gold standard) ឬ ក៏ទៅនឹងរូបិយប័ណ្ណប្រទេសធំ ដែលមានអាត្រាអតិផរណាទាបដូចជាអាមេរិកជាដើមជា **ប្រទេសបង្គោល** (Anchor country)។ វិធីសាស្រ្តមួយទៀត គឺ ជ្រើសយក **គោលដៅវំកិល** (Crawling target) ឬ **បង្គោល** (Peg) ដែលក្នុងនោះ យើងអាចអោយរូបិយវត្ថុក្នុងស្រុកបញ្ចុះតម្លៃពិតធ្លាក់ធៀបនឹងរូបិយប័ណ្ណនៃ **ប្រទេសបង្គោល** ។

ការកំណត់គោលដៅអាត្រាប្តូរប្រាក់មានគុណសម្បត្តិជាច្រើនដូចតទៅ៖

- **ទីមួយ**- គោលដៅអត្រាប្តូរប្រាក់បង្គោល រួមចំណែកដោយផ្ទាល់ក្នុងការរក្សាអតិផរណាឱ្យនៅកម្រិតអាចគ្រប់គ្រងបាន តាមរយៈការភ្ជាប់អត្រាអតិផរណានៃទំនិញពាណិជ្ជកម្មអន្តរជាតិទៅនឹង តម្លៃនៅក្នុងប្រទេសបង្គោល (តម្លៃទំនិញពាណិជ្ជកម្មអន្តរជាតិ កំនត់ដោយទីផ្សារអន្តរជាតិ ខណៈដែលតម្លៃក្នុងស្រុកជាការប្តូរតាមអត្រាប្តូរប្រាក់គោលដៅ) ។
- **ទីពីរ**- គោលដៅនៃអត្រាប្តូរប្រាក់ បង្កើតឱ្យមានវិធានស្វ័យប្រវត្តិមួយសម្រាប់អនុវត្តគោលនយោបាយរូបិយវត្ថុដោយជួយសម្រាលបញ្ហាសង្គតិភាពពេលវេលា ក្នុងពេលធ្វើគោលនយោបាយ ។ ឧទាហរណ៍ ការកំណត់គោលដៅអត្រាប្តូរប្រាក់ចាប់បង្ខំឱ្យមានការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ នៅពេលគេឃើញថាតម្លៃនៃរូបិយវត្ថុជាតិមាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និន្នាការធ្លាក់ចុះ ឬ បន្ធូរគោលនយោបាយរូបិយវត្ថុវិញ នៅពេលដែលរូបិយវត្ថុជាតិមានទំនោរឡើងតម្លៃ ។

- **ទីបី**- គោលដៅអត្រាប្តូរប្រាក់មានគុណសម្បត្តិដោយសារវាមានភាពងាយស្រួល និង ច្បាស់លាស់ ធ្វើឱ្យសាធារណជនងាយយល់ ។

- **ទីបួន**- ក្នុងប្រទេសដែលស្ថាប័ននយោបាយ និងស្ថាប័នរូបិយវត្ថុនៅទន់ខ្សោយ ហើយដែលធ្លាប់ជួបប្រទះ **មហាអតិផរណា** ( Hyperinflation ) ការកំណត់គោលដៅអត្រាប្តូរប្រាក់ជាវិធីតែមួយគត់ ដើម្បីបំបាត់ភាពស្លន់ស្លោរទៅនឹងមហាអតិផរណា និងបង្កើតស្ថេរភាពសេដ្ឋកិច្ច ។

យ៉ាងណាក៏ដោយ ការកំណត់គោលដៅអាត្រាប្តូរប្រាក់ក៏មានគុណវិបត្តិមួយចំនួនដែរ ដូចជា៖

- **ទីមួយ**- ដោយសារមូលធនអាចហូរចុះឡើងលឿន ប្រទេសដែលកំណត់គោលដៅអាត្រាប្តូរប្រាក់ មិនអាចអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ខ្លួនដោយឯករាជ្យបានទៀតឡើយ ។ ដូចនេះ គោលនយោបាយរូបិយវត្ថុបាត់បង់នូវសមត្ថភាពប្រើប្រាស់ ដើម្បីឆ្លើយតបទៅនឹងវិបត្តិ (Shocks) ក្នុងស្រុក ដែលផ្សេងពីវិបត្តិដែលកើតមាននៅប្រទេសបង្គោល ។

- **ទីពីរ**- វិបត្តិក្នុងប្រទេសបង្គោលមានឥទ្ធិពលដោយផ្ទាល់លើប្រទេសកំណត់គោលដៅ ព្រោះថាបម្រែបម្រួលអត្រាការប្រាក់ ដោយសារវិបត្តិក្នុងប្រទេសបង្គោល ធ្វើឱ្យអត្រាការប្រាក់នៃប្រទេសកំណត់គោលដៅប្រែប្រួលដូចគ្នាដែរ ។

- **ទីបី**- ការដាក់កំណត់គោលដៅអត្រាប្តូរប្រាក់ បើកឱកាសឈ្មួញដែលកេងយកចំណេញអាចមានឱកាសជ្រើសរើសយករូបិយវត្ថុជាតិ ជាគោលដៅដើម្បីវាយលុក ដើម្បីកេងយកចំណេញពីការឡើង ឬ ចុះនៃរូបិយវត្ថុជាតិ។

- **ទីបួន**- ការកំណត់គោលដៅអត្រាប្តូរប្រាក់អាចធ្វើឱ្យគណនេយ្យភាពរបស់អ្នកធ្វើគោលនយោបាយ ចុះខ្សោយដោយសារបាត់សញ្ញាពញ្ញាក់អារម្មណ៍ (Signal) ដ៏សំខាន់មួយ ដែលប្រាប់ឱ្យដឹងពីភាពជ្រុលហួស ក្នុងការពង្រីកគោលនយោបាយរូបិយវត្ថុ ។ សញ្ញាពញ្ញាក់អារម្មណ៍ពីទីផ្សារប្តូរប្រាក់អាចមានលក្ខណៈធូន់ធ្ងរ ហើយត្រូវការការឆ្លើយតបជាពិសេស សម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចកំពុងងើបឡើង (Emerging economies) ។

### *២.៤. ការកំណត់គោលដៅអតិផរណា (Inflation targeting)*

ដោយសារតែការបាត់ទំនាក់ទំនងរវាង **ការផ្គត់ផ្គង់រូបិយវត្ថុសរុប** (Monetary aggregates) និងគោលបំណងនៃគោលនយោបាយរូបិយវត្ថុ ដូចជា អតិផរណាជាដើម ប្រទេសជាច្រើន ដែលចង់រក្សាឯករាជ្យភាពនៃគោលនយោបាយរូបិយវត្ថុបានប្រើ **ការកំណត់គោលដៅអតិផរណា** (Inflation targeting) សម្រាប់ការ

គ្រប់គ្រងគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ។ **ការកំណត់គោលដៅអតិផរណា** ត្រូវមានសមាសភាគមួយចំនួន គឺ៖ ១)- ការប្រកាសជាសាធារណៈនៃតួលេខអត្រាអតិផរណាគោលដៅ សម្រាប់រយៈពេលមធ្យម ២)- ការប្តេជ្ញាចិត្តរបស់ស្ថាប័នរូបិយវត្ថុ ក្នុងការរក្សាស្ថេរភាពថ្លៃជាគោលដៅចំបងនៃគោលនយោបាយរូបិយវត្ថុរយៈពេលវែង និងរក្សាកម្រិតអតិផរណាឱ្យនៅក្រោមគោលដៅកំណត់ ៣)- យុទ្ធសាស្ត្រដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះប្រើប្រាស់អថេរជាច្រើន មិនគ្រាន់តែការផ្គត់ផ្គង់រូបិយវត្ថុនោះទេ សម្រាប់ធ្វើការសម្រេចចិត្តលើគោលនយោ-បាយរូបិយវត្ថុ ៤)- បង្កើនតម្លាភាពក្នុងការចាត់ចែងគោលនយោបាយរូបិយវត្ថុ តាមរយៈការប្រាស្រ័យទាក់ទងជាមួយសាធារណជន និងទីផ្សារអំពីផែនការ និងគោលបំណងរបស់អ្នកធ្វើគោលនយោបាយរូបិយវត្ថុ និង ទី៥)- បង្កើនគណនេយ្យភាពរបស់ធនាគារកណ្តាលក្នុងការសម្រេចឱ្យបានគោលបំណងអតិផរណារបស់ខ្លួន ។

ការកំណត់គោលដៅអតិផរណាមានគុណសម្បត្តិមួយធៀបនឹងការកំណត់គោលដៅអាត្រាប្តូរប្រាក់ និងការកំណត់គោលដៅរូបិយវត្ថុ ដូចជា៖

- **ទីមួយ**- អនុញ្ញាតឱ្យគោលនយោបាយរូបិយវត្ថុផ្តោតលើបញ្ហាក្នុងស្រុក និងឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ចក្នុងស្រុក ។

- **ទីពីរ**- អនុញ្ញាតឱ្យធនាគារកណ្តាលប្រើប្រាស់ព័ត៌មានទាំងអស់ដែលមាន មិនមែនត្រឹមតែអថេរតែមួយឡើយ ដើម្បីកំណត់អញ្ញាតិដែលប្រសើរបំផុត សម្រាប់គោលនយោបាយរូបិយវត្ថុ ។ ឧទាហរណ៍ ស្ថេរភាពនៃទំនាក់ទំនងរវាង **ការផ្គត់ផ្គង់រូបិយវត្ថុសរុប** និង **អតិផរណា** មិនកំណត់ពីជោគជ័យនៃគោលនយោបាយរូបិយវត្ថុឡើយ ដោយសារ មានកត្តាផ្សេងទៀតក្រៅនេះ ដែលជះឥទ្ធិពលលើអតិផរណាដែរ ។

- **ទីបី**- សាធារណជនងាយយល់ និង មានតម្លាភាពខ្ពស់ ។

- **ទីបួន**- បង្កើនគណនេយ្យភាពនៃធនាគារកណ្តាល ហើយអាចផ្តោតកាន់តែជាក់ស្តែងលើអ្វីដែលធនាគារកណ្តាលអាចធ្វើបានក្នុងរយៈវែង ពោលគឺ គ្រប់គ្រងអតិផរណា ជាជាងលើអ្វីដែលធ្វើមិនបាន គឺការជំរុញកំណើនសេដ្ឋកិច្ច និងបង្កើតការងារ តាមរយៈការពង្រីកគោលនយោបាយរូបិយវត្ថុ ។

- **ទីប្រាំ**- ផ្តោតការយកចិត្តទុកដាក់លើតម្លាភាពគោលនយោបាយ និង រក្សាទំនាក់ទំនងជាប្រចាំជាមួយសាធារណៈជន ។

គុណវិបត្តិនៃការកំណត់គោលដៅអតិផរណាមានមួយចំនួន ដូចជា៖

- **ទីមួយ - ពន្យារការផ្តល់សញ្ញាពញ្ញាក់អារម្មណ៍**៖ ដោយសារធនាគារកណ្តាលមិនអាចគ្រប់គ្រងអតិផរណាបានដោយងាយស្រួលឡើយ ។ ដោយសារតែមានគម្លាតដ៏យូរ ពីពេលអនុវត្តគោលនយោបាយ និង ការស្តែងចេញ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នូវផលប៉ះពាល់នៃគោលនយោបាយរូបិយវត្ថុ អត្រាអតិផរណាដែលជាលទ្ធផលនៃគោលនយោបាយដែលបានដាក់ចេញ នឹងសម្រេចបានក្នុងរយៈពេលមួយដ៏យូរបន្ទាប់ពីការអនុវត្តនូវគោលនយោបាយនេះ ។ ដូចនេះ គោលដៅនៃអតិផរណាមិនអាចបញ្ជូនសញ្ញាភ្លាមៗទៅឱ្យសាធារណៈជន និងទីផ្សារបានឡើយ អំពីជំហរគោលនយោបាយរូបិយវត្ថុ ។

- **ទីពីរ - ភាពរឹងត្អឹងខ្លាំងពេកក្នុងការធ្វើគោលនយោបាយ -** ពីព្រោះតែការដាក់វិធានរឹងត្អឹងទៅលើអ្នកធ្វើគោលនយោបាយ ដែលកម្រិតឆន្ទានុសិទ្ធរបស់ពួកគេ មិនអាចឆ្លើយតបទៅនឹងស្ថានភាព ដែលមិនបានគិតទុកជាមុន ឧទាហរណ៍ នៅពេលមានអតិផរណាខ្ពស់បណ្តាលមកពីល្បឿនចរាចរសាច់ប្រាក់ខ្ពស់ ។

- **ទីបី - សក្តានុពលភាពក្នុងការបង្កើនបម្រែបម្រួលធាតុចេញ**:ដែលបង្កើតឡើងដោយសារគោលនយោបាយរូបិយវត្ថុរឹងត្រឹល នៅពេលដែលអតិផរណាឡើងខ្ពស់ជាងគោលដៅ ដូចនេះនាំឱ្យធាតុចេញកើនឡើង ឬ ធ្លាក់ចុះយ៉ាងខ្លាំង ។

- **ទីបួន - អាចនាំឱ្យមានកំណើនធាតុចេញ និងការងារទាបជាងមុន:** ដោយសារការលើកទឹកចិត្តចំពោះផលិតករនៅមានកម្រិត ។

## *២.៥. ការកំណត់គោលដៅជាផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារ*

ក្នុងការអនុវត្ត **ការកំណត់គោលដៅជាផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ** ធនាគារកណ្តាលកំណត់អត្រាកំណើននៃ**ផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ** (ដែល ស្មើនឹង ផ.ស.ស.ពិត គុណនឹងថ្លៃ) ដោយមិនកំណត់គោលដៅអតិផរណាទេ ។ គុណសម្បត្តិនៃការកំណត់គោលដៅ **ផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ** គឺជាការផ្តល់ទម្ងន់លើធាតុចេញផងដែរ មិនគ្រាន់តែលើអតិផរណាតែប៉ុណ្ណោះទេ ក្នុងការធ្វើគោលនយោបាយ ។ ការធ្លាក់ចុះនៃការព្យាករណ៍កំណើន ផ.ស.ស.ពិត បានន័យថាត្រូវបង្កើនគោលដៅអតិផរណារបស់ធនាគារកណ្តាលដោយស្វ័យប្រវត្តិ ។ ការកើនឡើងនេះហាក់បញ្ជាក់នឹងវដ្តធុរកិច្ច និងស្ថិរភាពរូបនីយកម្ម ព្រោះវានឹងនាំឱ្យគោលនយោបាយរូបិយវត្ថុកាន់តែមានភាពធូររលុង ។

គុណវិបត្តិនៃ **ការកំណត់គោលដៅជាផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ** មានដូចតទៅ÷

- **ទីមួយ - ការកំណត់គោលដៅជាផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ** បង្ខំឱ្យរដ្ឋាភិបាលកំណត់គោលដៅកំណើន ផ.ស.ស (រយៈវែង) ។ ការងារនេះមានភាពពិបាក ព្រោះការព្យាករណ៍កំណើន ផ.ស.ស ពុំមានភាពសុក្រឹត្យគ្រប់គ្រាន់ ហើយប្រែប្រួលជានិច្ច ។

- **ទីពីរ -** ព័ត៌មានអំពីថ្លៃត្រូវបានរាយការណ៍ទាន់ពេលវេលា និង ញឹកញាប់ជាងទិន្នន័យពី **ផលិតផលសរុប**


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ក្នុងស្រុកតាមថ្លៃថេរ** ។

- **ទីបី**- សាធារណៈជនមានការយល់ពីអតិផរណា ច្រើន ផ.ស.ស ។

**ទីបួន**- ក្នុងការអនុវត្ត ដើម្បីសម្រេចបានស្ថេរភាពរយៈខ្លី ការកំណត់ **ការកំណត់គោលដៅជាផលិតផលសរុបក្នុងស្រុកតាមថ្លៃថេរ** ពុំប្រាកដថាមានប្រសិទ្ធភាពជាង ការកំណត់គោលដៅអតិផរណាឡើយ ។

## ៣- ឧបករណ៍គោលនយោបាយរូបិយវត្ថុ

ឧបករណ៍គោលនយោបាយរូបិយវត្ថុ គឺឧបករណ៍មួយចំនួនដែលធនាគារកណ្តាលប្រើប្រាស់ដើម្បីកែតម្រូវទីផ្សាររូបិយវត្ថុ និងល័ក្ខខ័ណ្ឌឥណទាន ដើម្បីសម្រេចគោលបំណងរបស់គោលនយោបាយរូបិយវត្ថុ ។ ក្នុងការងារអនុវត្ត គោលនយោបាយធនាគារកណ្តាលចាត់វិធានការណ៍ដោយផ្ទាល់ ដោយការប្រើអំណាចនិយ័តកម្ម ឬដោយប្រយោល ដើម្បីកែតម្រូវស្ថានភាពទីផ្សាររូបិយវត្ថុ ក្នុងឋានៈជាអ្នកគ្រប់គ្រងរូបិយវត្ថុគោល (រូបិយវត្ថុក្នុងចរាចរណ៍ និងទុនបម្រុង នៅធនាគារកណ្តាល) ។ ដូច្នេះឧបករណ៍គោលនយោបាយរូបិយវត្ថុអាចបែងចែកជា ២ ប្រភេទ គឺ **គោលនយោបាយរូបិយវត្ថុដោយផ្ទាល់** និង **គោលនយោបាយរូបិយវត្ថុដោយប្រយោល** ។

### *៣.១. ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយប្រយោល*

ឧបករណ៍ដោយប្រយោលធ្វើសកម្មភាពក្នុងទីផ្សារ តាមរយៈការកែសម្រួលតម្រូវការ និងការផ្គត់ផ្គង់ទុនបម្រុងរបស់ធនាគារ ។ ការប្រើប្រាស់ **ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយប្រយោល** គឺជាការពង្រឹងតួនាទីសញ្ញារបស់ថ្លៃ នៅក្នុងសេដ្ឋកិច្ចទំនើប ។ ឧបករណ៍ដោយប្រយោលមាន ៣ ប្រភេទ គឺ **ប្រតិបត្តិការទីផ្សារដោយចំហរ** (open market operation) **ទុនបម្រុងកាតព្វកិច្ច** (reserve requirement) និង **កម្ចីរបស់ធនាគារកណ្តាល (មុនអប្បហារ** (Rediscounting) រយៈពេលខ្លីលើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានគុណភាពខ្ពស់) ។

ដោយការប្រើឧបករណ៍ប្រយោល ធនាគារកណ្តាលអាចកំណត់កម្រិតទុនបម្រុង ។ ប៉ុន្តែបើសិនជាគណនីមូលធនមានលក្ខណៈបើកចំហរ ហើយអត្រាប្តូរប្រាក់កំណត់ថេរ (Fixed exchange rate) នោះការប្រើទុនបម្រុងដើម្បីសម្រេចគោលបំណងនៃគោលនយោបាយក្នុងស្រុក នឹងមិនមានប្រសិទ្ធភាពទេក្នុងរយៈវែង ។ ឧទាហរណ៍ បើសិនធនាគារកណ្តាលបង្កើនទុនបម្រុង ដើម្បីបន្ទាបអត្រាការប្រាក់ ក៏ប៉ុន្តែបរិមាណផ្គត់ផ្គង់រូបិយវត្ថុមានច្រើនជ្រុលហួសពីបរិមាណដែលត្រូវការដើម្បីរក្សាអត្រាប្តូរប្រាក់ឱ្យនៅថេរ នោះនឹងមានលំហូរទុនចេញដែលជះផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច ។ ទោះបីជានៅក្នុងប្រព័ន្ធរបបអត្រាប្តូរប្រាក់**ចង្គោល** (Pegged) ឬប្រព័ន្ធរបបអត្រាប្តូរប្រាក់**គ្រប់គ្រង** (Managed) ធនាគាកណ្តាលអាចប្រើឧបករណ៍ទុនម្រុងតែក្នុងរយៈខ្លីប៉ុណ្ណោះ។ បម្រែបម្រួលទុនបម្រុង ដោយសារប្រតិបត្តិការរបស់ធនាគារកណ្តាលមានឥទ្ធិពល លើស្ថានភាព


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សាច់ប្រាក់របស់ធនាគារឯកជន ដែលនាំឱ្យមានការកែតម្រូវ នៅក្នុងទីផ្សាររូបិយវត្ថុអន្តរធនាគារ និង អត្រាការប្រាក់លើកម្ចី និងបញ្ញើធនាគារ ដើម្បីស្តារសមតា រវាងតម្រូវការ និង ការផ្គត់ផ្គង់ទុនបម្រុងឡើងវិញ ។

ដូច្នេះ ឧបករណ៍ដោយប្រយោលនៃគោលនយោបាយរូបិយវត្ថុ គឺជាការជំរុញឱ្យមានអន្តរការីហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុផ្លូវការ ។ ហើយវាក៏ផ្តល់នូវភាពទន់ភ្លន់ច្រើនដល់អាជ្ញាធររូបិយវត្ថុ ក្នុងការអនុវត្តគោល-នយោបាយ ។ ការកែប្រែឧបករណ៍បន្តិចម្តងៗជាញឹកញាប់អាចអនុញ្ញាតឱ្យអាជ្ញាធរឆ្លើយតបបានទាន់ពេលវេលាទៅនឹងវិបត្តិ និងអាចកែប្រែកំហុសគោលនយោបាយបានឆាប់រហ័ស ។ ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយប្រយោលអាចធ្វើចំណាត់ថ្នាក់ដូចតទៅ៖

- **អន្តរាគមន៍ក្នុងទីផ្សារ : ប្រតិបត្តិការទីផ្សារបើកចំហ** និង **កម្ចីអប្បហារ** ។
- **ឧបករណ៍កំហិតទុនទំនេរ : ទុនបម្រុងកាតព្វកិច្ច** និង **សេចក្តីណែនាំចំហ** ។

## ៣.១.១ ប្រតិបត្តិការទីផ្សារបើកចំហ

**ប្រតិបត្តិការទីផ្សារបើកចំហ** គឺជាឧបករណ៍ដែល អាជ្ញាធររូបិយវត្ថុនៅប្រទេសអភិវឌ្ឍន៍ គេប្រើញឹកញាប់បំផុត ហើយក៏ជាឧបករណ៍គោលនយោបាយរបស់ធនាគារកណ្តាល ដែលមានសារៈសំខាន់ និងមានប្រយោជន៍ជាទីបំផុត ។ ប្រតិបត្តិការទីផ្សារចំហរ រួមមាន ការទិញដូរឧបករណ៍រូបិយវត្ថុដោយធនាគារកណ្តាលនៅលើទីផ្សារដំបូង (ជាប្រតិបត្តិការ ប្រភេទទីផ្សារចំហ) ឬទីផ្សារបន្ទាប់ (ជាប្រតិបត្តិការទីផ្សារបើកចំហពេញលេញ) ។ ឧបករណ៍រូបិយវត្ថុដែលប្រើប្រាស់ជា ទូទៅ ក្នុងគោលបំណងនេះរួមមាន **ប័ណ្ណរតនាគារ** ប័ណ្ណធនាគារកណ្តាល (សញ្ញាប័ណ្ណរដ្ឋ) ឬ **ផលបត្រពាណិជ្ជកម្ម** (commercial paper) គុណភាពខ្ពស់ ។

ក្នុងប្រទេសឧស្សាហកម្មជឿនលឿនដែលមានទីផ្សារហិរញ្ញវត្ថុរីកចម្រើនខ្ពស់ ប្រតិបត្តិការទីផ្សារបើកចំហប្រើប្រាស់ប័ណ្ណរតនាគារ ប័ណ្ណធនាគារជាតិ ជាឧបករណ៍គោលនយោបាយរូបិយវត្ថុ ។ សម្រាប់ប្រទេសដែលមានទីផ្សារហិរញ្ញវត្ថុមិនទាន់រីកចម្រើនគ្រប់គ្រាន់ ប្រតិបត្តិការទីផ្សារបើកចំហត្រូវធ្វើតាមរយៈអន្តរាគមន៍របស់ធនាគារកណ្តាល នៅក្នុងទីផ្សារមូលបត្រដំបូង ។ វិធីសាស្ត្រដែលនិយមប្រើគឺការដាក់ដេញថ្លៃប័ណ្ណរតនាគារឬប័ណ្ណធនាគារជាតិ ដោយកំណត់បរិមាណដេញថ្លៃសុទ្ធ ដើម្បីកែប្រែបរិមាណទុនបម្រុងធនាគារ ។ ជាញឹកញាប់ឧបករណ៍នេះត្រូវប្រើផ្សំនឹងមធ្យោបាយដ៏ទៃទៀត រួមមានការដាក់ដេញថ្លៃឥណទានធនាគារជាតិ ការប្រើ **កម្ចីបុនអប្បហារ** (Rediscount lending) និងការផ្លាស់ប្តូរបរិមាណទុនបម្រុងកាតព្វកិច្ច ដើម្បីអាចមានឥទ្ធិពលលើទុនបម្រុងតាមដែលចង់បាន ហើយធ្វើឱ្យសាច់ប្រាក់ប្រែប្រួល ដោយរលូនពីមួយថ្ងៃទៅមួយថ្ងៃ ។

ប្រតិបត្តិការទីផ្សារបើកចំហរ ត្រូវបានប្រើប្រាស់សម្រាប់តម្រែតម្រង់អត្រាការប្រាក់ក្នុងសេដ្ឋកិច្ច ។ រាល់ការទិញលក់មូលបត្រ មានឥទ្ធិពលផ្ទាល់លើបរិមាណទុនបម្រុងក្នុងប្រព័ន្ធធនាគារ ។ ដូច្នេះ ក៏មានឥទ្ធិពល



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លើអត្រាការប្រាក់ និង ការផ្គត់ផ្គង់រូបិយវត្ថុផងដែរ ។

នៅពេលធនាគារកណ្តាលទិញមូលបត្ររដ្ឋពីធនាគារពាណិជ្ជ ទុនបម្រុងរបស់ធនាគារពាណិជ្ជដែលតំកល់ទុកជាមួយធនាគារកណ្តាលនឹងកើនឡើង ជាហេតុនាំអោយធនាគារពាណិជ្ជអាចផ្តល់កម្ចីដល់អតិថិជនបានកាន់តែច្រើន ។ ដូច្នេះ ការទិញមូលបត្ររដ្ឋបង្កើនទុនបម្រុង ហើយបន្ធូរឥណទាន ។ ផ្ទុយទៅវិញ ការលក់មូលបត្ររដ្ឋនឹងបន្ថយទុនបម្រុង និង រឹតបន្តឹងឥណទាន ។ តាមរយៈការទិញមូលបត្រ ធនាគារកណ្តាលឱ្យឥណទានតាមគណនីទុនបម្រុងបញ្ញើរបស់អ្នកលក់ ។ គ្រឹះស្ថានបញ្ញើអាចចាប់ផ្តើមដំណើរការឱ្យខ្ចី និងទទួលប្រាក់បញ្ញើ ហើយធ្វើឱ្យមានកំណើនការផ្គត់ផ្គង់រូបិយវត្ថុ ស្របគ្នានឹងកំណើនកម្ចីក្នុងប្រព័ន្ធធនាគារ ។ ការទិញមូលបត្ររដ្ឋសមាសភាគទុនទំនេរ (portfolio compenent) របស់ផ្នែកសាធារណៈក្រៅពីធនាគារ និងប្រព័ន្ធធនាគារ ។ ផ្នែកសាធារណៈក្រៅពីធនាគារដោះដូរទ្រព្យសម្បត្តិ រូបិយវត្ថុ ជាមួយនឹងមូលបត្រ ខណៈដែលប្រព័ន្ធធនាគារបង្កើនការប្តេជ្ញារបស់ខ្លួន ក្នុងទម្រង់ជាប្រាក់បញ្ញើ និងជាសាច់ប្រាក់ ។ ការកើនឡើងសាច់ក្នុងប្រព័ន្ធធនាគារអាចឱ្យធនាគារបង្កើនកម្ចី ដូច្នេះនឹងនាំការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង ។ ច្រាស់មកវិញ ការលក់មូលបត្របន្ថយទុនបម្រុង និងរឹតបន្តឹងឥណទាន ពីព្រោះធនាគារកណ្តាលដកចេញពី គណនីទុនបម្រុងរបស់ធនាគារអ្នកទិញបន្ថយបរិមាណទុនបម្រុងសម្រាប់ឱ្យកម្ចី ។

ប្រតិបត្តិការទីផ្សារបើកចំហមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើអត្រាការប្រាក់ តែវាអាស្រ័យទៅលើបរិមាណទិញ និង លក់នូវមូលបត្ររដ្ឋ ។ ការទិញមូលប័ត្រដោយធនាគារកណ្តាល បង្កើនតម្រូវការមូលបត្រ ជាលទ្ធផលនាំឱ្យថ្លៃកើនឡើង ហើយអត្រាការប្រាក់ធ្លាក់ចុះ ។ សាច់ប្រាក់កើនបន្ថែមអាចឱ្យប្រព័ន្ធធនាគារធ្វើការផ្តល់កម្ចីបន្ថែមទៀត ដូច្នេះ វាបង្កើនសម្ពាធដើម្បីបញ្ចុះអត្រាការប្រាក់ពីភាគីផ្គត់ផ្គង់ ។ ការលក់មូលប័ត្រដោយធនាគារកណ្តាលនឹងមានផលប៉ះពាល់ផ្ទុយទៅវិញ ។ ប្រសិនបើ ចង់ឱ្យអត្រាការប្រាក់កើនឡើង ឬក៏កាត់បន្ថយបរិមាណផ្គត់ផ្គង់រូបិយវត្ថុ ធនាគារកណ្តាលត្រូវលក់មូលប័ត្រ តាមរយៈប្រតិបត្តិការទីផ្សារដោយចំហ ។

ប្រតិបត្តិការទីផ្សារបើកចំហអាចអនុវត្តប្រកបដោយប្រសិទ្ធភាព នៅក្នុងសេដ្ឋកិច្ចដែលបំណុលសាធារណៈមានកម្រិតខ្ពស់ ហើយម្ចាស់បំណុលទទួលកាន់មូលបត្ររដ្ឋយ៉ាងច្រើន ។ ជាគោលការណ៍ មួយភាគធំនៃទ្រព្យសកម្មរបស់ធនាគារកណ្តាល ដែលប្រើប្រាស់ក្នុងទីផ្សារបើកចំហរ ត្រូវតែជាមូលបត្ររដ្ឋ ដើម្បីបញ្ជូនសញ្ញាគោល-នយោបាយទៅកាន់ទីផ្សារ ។

ប្រតិបត្តិការទីផ្សារបើកចំហមានលក្ខណៈរស់រវើកផង និងការពារខ្លួនផង ។ ប្រតិបត្តិការរស់រវើក គឺការប្រើប្រាស់ ដើម្បីបន្ថយ ឬបង្កើនបរិមាណទុនបម្រុង និង ដើម្បីបន្ធូរ ឬ បន្តឹងឥណទាន ។ រីឯប្រតិបត្តិការការពារគឺប្រើប្រាស់ ដើម្បីទូទាត់កាត់កងផលប៉ះពាល់នៃកត្តាផ្សេងទៀត ដែលមានឥទ្ធិពលទៅលើទុនបម្រុង ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.១.២ កម្ចីអប្បហារ (Discount lending)

បញ្ច **កម្ចីអប្បហារ** របស់ធនាគារកណ្តាលដើរតួជា ក្បាលរ៉ូបីណេសុវត្ថិភាព សម្រាប់បន្ទុរបន្ថយសម្ពាធទុនបម្រុងកាតព្វកិច្ច ដែលគ្រឹះស្ថានទទួលប្រាក់បញ្ញើ តែងតែប្រឈមមុខជារៀងរាល់ពេល ។ ការឱ្យកម្ចីដោយមានដាក់វត្ថុធានា បើកលទ្ធភាពឱ្យធនាគារកណ្តាលផ្តល់សាច់ប្រាក់ដល់ស្ថាប័នហិរញ្ញវត្ថុ ។ ប្រការនេះ ធនាគារកណ្តាលជួយធានានូវស្ថិរភាពទីផ្សាររូបិយវត្ថុ និងប្រព័ន្ធធនាគារ ។

ក្នុងដំណាក់ដំបូងនៃការអភិវឌ្ឍប្រព័ន្ធធនាគារ ធនាគារពាណិជ្ជខ្ចីប្រាក់ពីធនាគារកណ្តាល ដោយយកមូលបត្រ និងឯកសារទ្រព្យសកម្មដ៏ទៃទៀត ដើម្បីដាក់ធានាបញ្ចាំ ក្នុងគោលដៅទទួលបាននូវកម្ចីអប្បហារ ។ បរិមាណទឹកប្រាក់ឱ្យខ្ចីស្មើ **តម្លៃចារឹក** (face value) នៃទ្រព្យសកម្ម ដកនឹងតម្លៃអប្បហារ (discount) ។ សព្វថ្ងៃនេះ ស្ថាប័នហិរញ្ញវត្ថុនៅតែសុំខ្ចីពីធនាគារកណ្តាល ។ ប៉ុន្តែ ពាក្យ **«បញ្ជរអប្បហារ»** គ្រាន់តែជាការរៀបរាប់អំពីកម្ចីពីធនាគាកណ្តាលដែលត្រូវសងរួមទាំងការប្រាក់នៅថ្ងៃកំណត់សង អាចធ្វើឡើងតាមទូរស័ព្ទ និងធានាដោយវត្ថុសន្យាបញ្ចាំ ។ ធនាគារពាណិជ្ជអាចចុះ **កិច្ចព្រមព្រៀងទិញយកវិញ** (Repurchase Agreement) និង **កិច្ចព្រមព្រៀងទិញយកវិញបញ្ច្រាស់** (Reverse repurchase Agreement) ជាមួយធនាគារពាណិជ្ជផ្សេងទៀត និង ជាមួយធនាគារកណ្តាល ដើម្បីដោះស្រាយបញ្ហាសាច់ប្រាក់រយៈពេលខ្លី ។ **កិច្ចព្រមព្រៀងទិញយកវិញ** គឺជាកិច្ចព្រមព្រៀង ដែលធនាគារពាណិជ្ជមួយលក់មូលបត្រអោយធនាគារពាណិជ្ជមួយទៀត ដើម្បីយកសាច់ប្រាក់សុទ្ធ ដោយសន្យាថានឹងទិញយកវិញនៅថ្ងៃខាងមុខ ។

**អត្រាអប្បហារ** (Discount rate) គឺអត្រាការប្រាក់ដែលធនាគារពាណិជ្ជត្រូវបង់លើកម្ចីដែលខ្លួនបានខ្ចីពីយន្តការកម្ចីអប្បហាររបស់ធនាគារកណ្តាល គឺ បញ្ចរអប្បហារ ។ ការកែប្រែអត្រាអប្បហារ ជាការផ្តួចផ្តើមគំនិតរបស់គណៈកម្មការរូបិយវត្ថុនៃធនាគារកណ្តាល ។ ជាទូទៅ អត្រាអបហារមិនប្រែប្រួលញឹកញាប់ទេ ។

ការកែប្រែអត្រាអប្បហារប៉ះពាល់លំកូខំណ្ឌឥណទាន ដូច្នេះក៏ប៉ះពាល់ដល់សេដ្ឋកិច្ចដែរ ។ ឧទាហរណ៍ ការបង្កើនអត្រាអប្បហារ ធ្វើឱ្យស្ថាប័នបញ្ញើត្រូវចំណាយថ្លៃដើមច្រើន លើកម្ចីដែលខ្ចីពីធនាគារកណ្តាល ។ ការកើនឡើងថ្លៃដើមសម្រាប់កម្ចីឥណទានពីធនាគារកណ្តាល នឹងរីកដាលលើគ្រប់ប្រភេទអត្រាការប្រាក់ទាំងអស់ក្នុងវិស័យធនាគារ ។ ថ្លៃដើមកាន់តែខ្ពស់ធ្វើឱ្យស្ថាប័នបញ្ញើរារែកនឹងប្រើប្រាស់បុព្វសិទ្ធអប្បហារ (discount privilege) ហើយឆ្លើយតបនឹងអត្រាអប្បហារខ្ពស់ ដោយបន្ថយការផ្តល់កម្ចី និង កម្រិតការផ្តល់កម្ចីទៅអ្នកខ្ចីដែលមានលក្ខសម្បត្តិខ្ពស់ និងមានហានិភ័យទាប ។

ក្រៅពីឥទ្ធិពលផ្ទាល់ខាងលើ បម្រែបម្រួលអត្រាអប្បហារអាចកែប្រែការរំពឹងទុកក្នុងទីផ្សារហិរញ្ញវត្ថុ ។ ឧទាហរណ៍ បើសិនជាទីផ្សារយល់ថាការបង្កើនអត្រាអប្បហារជាចំណុចចាប់ផ្តើមនៃកម្មវិធីរឹតបន្តឹងឥណទានរយៈពេលវែង អ្នកផ្តល់កម្ចីនឹងកាត់បន្ថយចំនួនគម្រោង សុខចិត្តរង់ចាំរហូតទទួលផលវិនិយោគទាក់ទាញជាងនេះ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អ្នកដែលអាចសុំខ្ចី នឹងព្យាយាមយកកម្ចីឱ្យបានមុនពេលអត្រាប្រាក់ខ្ពស់មកដល់ ។ សមតាទីផ្សារដែលជាលទ្ធផលនៃសកម្មភាពរបស់អ្នកឱ្យខ្ចី និងអ្នកសុំខ្ចី បង្កើតជាបរិស្ថានឥណទានមួយដែលមានលក្ខណៈតឹងរឹង ។

ឥណទានអប្បហារ និង ឥណទានប្រភេទផ្សេងទៀត ដែលធនាគារកណ្តាលផ្តល់អោយប្រព័ន្ធធនាគារត្រូវបានប្រើប្រាស់ក្នុងគោលបំណងបីយ៉ាង៖ ដើម្បីបន្ធូកង្វះសាច់ប្រាក់ (តួនាទីជា **ឥណទាយិកចុងក្រោយ**) ដើម្បីគ្រប់គ្រងល័ក្ខខ័ណ្ឌឥណទាន និងរូបិយវត្ថុ និងដើម្បីធ្វើវិភាជន៍ឥណទានតាមការជ្រើសរើស ។ បញ្ចអប្បហារ រួមមានបច្ចេកទេសមួយចំនួន ដើម្បីកំណត់កម្រិតឥណទានពីធនាគារកណ្តាលទៅប្រព័ន្ធធនាគារ ។ បច្ចេកទេសសំខាន់បំផុត គឺអត្រាអប្បហារ ។ បច្ចេកទេសដ៏ទៃរួមមានដូចជា ការកំណត់ល័ក្ខខ័ណ្ឌដើម្បីប្រើប្រាស់បញ្ចអប្បហារ ការកំណត់ប្រភេទទ្រព្យហិរញ្ញវត្ថុ ដែលធនាគារកណ្តាលនឹងទទួលយកជាវត្ថុធានា និងការកំណត់បរិមាណអតិបរមានូវឥណទាន ដែលធនាគារកណ្តាលអាចផ្តល់ដល់ស្ថាប័នទទួលប្រាក់បញ្ញើ ។

ក្នុងការអនុវត្តយន្តការអប្បហារ (discount facility) ធនាគាកណ្តាលអាចធ្វើតាមយុទ្ធសាស្ត្រខុសៗគ្នា ។ ធនាគារកណ្តាលខ្លះពឹងផ្អែកទៅលើទីផ្សារ ដើម្បីកម្រិតបរិមាណកម្ចី ដើម្បីឱ្យធនាគារនឹងរកមូលនិធិពីប្រភពដ៏ទៃដូច ជាពីទីផ្សារប្រាក់បញ្ញើ និងទីផ្សារអន្តរធនាគារ ជាដំបូងសិន ក្នុងករណីនេះ អត្រាអប្បហារត្រូវតែខ្ពស់ល្មម ។ ធនាគាកណ្តាលដ៏ទៃទៀត ដូចជា ធនាគារកណ្តាលអាមេរិកនិងអាល្លឺម៉ង់ រក្សាអត្រាអប្បហារឱ្យទាប ជាងកម្រិតទីផ្សារ ហើយប្រើវិធានការរដ្ឋបាល ដើម្បីកម្រិតបរិមាណទទួលបានកម្ចីពីយន្តការខាងលើ ។

ធនាគារកណ្តាលខ្លះ ប្រើប្រាស់បម្រែបម្រួលអត្រាអប្បហារ សម្រាប់តែការផ្តល់ជាសញ្ញាជាមុនពីបម្រែបម្រួលនៃគោលនយោបាយរូបិយវត្ថុប៉ុណ្ណោះ ។ ធនាគារកណ្តាលដ៏ទៃទៀតប្រើប្រាស់បញ្ចអប្បហារ ជាឧបករណ៍ដ៏សំខាន់ ដើម្បីគ្រប់គ្រងល័ក្ខខ័ណ្ឌទីផ្សាររូបិយវត្ថុ ។

ជាការពិតណាស់ អត្រាអប្បហារអាចមានឥទ្ធិពលលើអត្រាការប្រាក់បាន ទាល់តែធនាគារកណ្តាលអនុវត្តយន្តការនេះយ៉ាងញឹកញាប់ ។ ក្នុងករណី ដែលធនាគារកណ្តាលប្រើប្រាស់វា គ្រាន់តែដើម្បីបំពេញនាទីជា **ឥណទាយិកចុងក្រោយ** នោះមិនមានផលប៉ះពាល់ទេ ។ អត្រាអប្បហារអាចក្លាយទៅជាឧបករណ៍គោល-នយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព តែក្នុងករណីដែលការផ្គត់ផ្គង់កម្ចីមិនគ្រប់គ្រាន់តាមតម្រូវការ ។ ក្នុងករណីបែបនេះ អ្នកសុំខ្ចីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានបំណងកែលម្អស្ថានភាពសាច់ប្រាក់របស់ខ្លួន អាចប្រើប្រាស់បញ្ចអប្បហារ ដូច្នេះអាចឱ្យធនាគារកណ្តាលអាចកម្រិតទំហំសាច់ប្រាក់បាន ។

យន្តការអប្បហារ អាចប្រើប្រាស់ដើម្បីគាំទ្រនិងពង្រឹងប្រតិបត្តិការទីផ្សារបើកចំហ ។ ឧទាហរណ៍ ប្រសិនបើធនាគារកណ្តាលមានគោលបំណងអនុវត្តគោលនយោបាយរូបិយវត្ថុបង្រួម នៅពេលមានអតិផរណា ខ្លួនអាចប្រើប្រតិបត្តិការទីផ្សារបើកចំហ ដើម្បីកាត់បន្ថយបរិមាណរូបិយវត្ថុ នៅពេលដែលតម្រូវការកម្ចីកើនឡើង ។ ជាលទ្ធផល អត្រាការប្រាក់នឹងកើនឡើង ហើយធនាគារពាណិជ្ជដែលយល់ឃើញថាទុនបម្រុងរបស់ខ្លួនអាចមិនគ្រប់តាមនិយ័តកម្មនៃធនាគារកណ្តាល នឹងសុំយកកម្ចីពីធនាគារកណ្តាលដើម្បីបង្កើនទុនបម្រុង ។ ដើម្បីទប់ស្កាត់ការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើតទុនបម្រុងបន្ថែមតាមរយៈកម្ចី ធនាគារកណ្តាលអាចបង្កើនអត្រាអប្បហារ ស្របគ្នានឹងអត្រាការប្រាក់ទីផ្សារ ដែលជាលទ្ធផលពីប្រតិបត្តិការទីផ្សារបើកចំហ ។

### ៣.១.៣. ទុនបម្រុងកាតព្វកិច្ច

**ទុនបម្រុងកាតព្វកិច្ច** ជាបរិមាណប្រាក់បញ្ញើកំណត់ដោយច្បាប់ ដែលធនាគារពាណិជ្ជ ត្រូវរក្សាទុកនៅក្នុងធនាគារកណ្តាល ជាសាច់ប្រាក់ ឬជាបញ្ញើ ។ ទុនបម្រុងកាតព្វកិច្ចផ្សាភ្ជាប់តារាងតុល្យការ (balance sheet) របស់ធនាគារពាណិជ្ជ និងធនាគារកណ្តាល ។ គេអាចប្រើជាមធ្យោបាយ ដើម្បីបង្កើនបរិមាណរូបិយវត្ថុ ឬកាត់បន្ថយបរិមាណរូបិយវត្ថុ (Sterilizing) ។ កម្រិតទុនបម្រុងកាតព្វកិច្ច មានឥទ្ធិពលលើស្ថានភាពទីផ្សារហិរញ្ញវត្ថុ និងទីផ្សាររូបិយវត្ថុ ។ ឧទាហរណ៍ ការកាត់បន្ថយទុនបម្រុងកាតព្វកិច្ច បន្ថយបរិមាណទុនបម្រុង ដែលធនាគារពាណិជ្ជត្រូវផ្ញើនឹងធនាគារកណ្តាល ។ ដូច្នេះ ការកាត់បន្ថយទុនបម្រុងកាតព្វកិច្ចអាចអោយធនាគារពាណិជ្ជផ្តល់កម្ចីបន្ថែមទៀតបាន ។ បរិមាណកម្ចីច្រើនជាងមុន បង្កើតបរិមាណរូបិយវត្ថុ និងជំរុញសកម្មភាពសេដ្ឋកិច្ច ។

បង្កើនបរិមាណទុនបម្រុងមានផលប៉ះពាល់ផ្ទុយពីខាងលើវិញ ។ ទុនបម្រុងកាតព្វកិច្ចដែលគ្មានការប្រាក់មានន័យដូចជា ការយកពន្ធលើធនាគារពាណិជ្ជ ហើយអាចនាំឱ្យមានបដិអន្តរការីកម្មហិរញ្ញវត្ថុ (financial disintermediation) ។ ប្រការនេះមានន័យថា ប្រសិនបើកំណត់ទុនបម្រុងកាតព្វកិច្ចខ្ពស់ពេល ធ្វើអោយធនាគារពាណិជ្ជគ្មានការលើកទឹកចិត្តក្នុងការផ្តល់ឥណទាន ។ ជាងនេះទៅទៀត ទុនបម្រុងកាតព្វកិច្ចខ្វះភាពទន់ភ្លន់ ។ ទោះបីជា ទុនបម្រុងកាតព្វកិច្ច ជាឧបករណ៍ដ៏មានអានុភាព ធនាគារកណ្តាលកម្រនឹងកែប្រែកាតព្វកិច្ចនេះណាស់ ក្នុងប្រតិបត្តិការគោលនយោបាយរូបិយវត្ថុ ។ **ទុនបម្រុងកាតព្វកិច្ច** ត្រូវបានប្រើច្រើនជាយន្តការនិយ័តកម្ម ដើម្បីផ្តល់សុវត្ថិភាព និងស្ថិរភាពនៅក្នុងប្រព័ន្ធធនាគារ ។

### ៣.១.៤ ប្រតិបត្តិការអត្រាប្តូរប្រាក់ (Foreign Exchange Operation)

ដើម្បីកែលម្អស្ថានភាពសាច់ប្រាក់អន្តរជាតិ និងលុបបំបាត់ភាពរអាក់រអួលនៃលំហូរទុនអន្តរជាតិ ធនាគារកណ្តាលអាចទិញ និងលក់រូបិយប័ណ្ណបរទេស ។ ជាទូទៅ រូបិយប័ណ្ណបរទេសអាចទិញបាននៅលើទីផ្សារ ឬតាមរយៈ «ប្រតិបត្តិការ**ផ្លាស់ប្តូរ** ឬ SWAPs» ជាមួយធនាគារកណ្តាលបរទេស ដោយចុះឥណទានគណនីរបស់ធនាគារកណ្តាល ដែលជាអ្នកខ្ចី ជាការផ្លាស់ប្តូរនឹងការចុះឥណពន្ធនៃគណនីទ្រព្យសកម្មរបស់ធនាគារពាក់ព័ន្ធ ។ ឧទាហរណ៍ ប្រទេស «ក» ផ្លាស់ប្តូររូបិយវត្ថុជាតិជាមួយនឹងឥណទានជាប្រាក់ដុល្លារអាមេរិក ដែលផ្តល់ឱ្យដោយប្រទេស «ខ» ហើយប្រតិបត្តិការ SWAPs បញ្ច្រាស់នឹងត្រូវធ្វើនៅពេលដល់កាលកំណត់ ដែលបានព្រមព្រៀង ។ ដោយសារប្រតិបត្តិការអត្រាប្តូរប្រាក់មានសារៈសំខាន់លើការផ្គត់ផ្គង់រូបិយប័ណ្ណបរទេស ការងារត្រូវមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ជាមួយអជ្ញាធររូបិយវត្ថុបរទេសពាក់ព័ន្ធ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.២ ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយផ្ទាល់

ឧបករណ៍ផ្ទាល់ប្រើដើម្បីកំណត់ឬកម្រិត ទាំងអត្រាការប្រាក់ និងទាំងបរិមាណកម្ចី ដោយប្រើបទប្បញ្ញត្តិ ។ ឧបករណ៍ផ្ទាល់ដែលប្រើប្រាស់ជាញឹកញាប់គឺ ការគ្រប់គ្រងអត្រាការប្រាក់ ការកំណត់ពិដានឥណទាន និងការកំណត់ទិសដៅប្រាក់កម្ចី (ការផ្តល់ប្រាក់កម្ចីតាមបញ្ជារដ្ឋាភិបាល ជាជាងមូលហេតុពាណិជ្ជកម្ម) ។ វិធីគ្រប់គ្រងរូបិយវត្ថុដោយផ្ទាល់ មានភាពជាក់ស្តែង ហើយគេយល់ថា ជាវិធីអាចទុកចិត្តបាន សម្រាប់ការគ្រប់គ្រងឥណទានសរុប ទាំងការបែងចែក និងទាំងថ្លៃដើម យ៉ាងហោចក៏ក្នុងរយៈពេលខ្លីដែរ ។ វិធីទាំងនោះមានភាពងាយស្រួលអនុវត្តជាង ហើយចំណាយសារពើពន្ធក៏ទាបជាងដែរ ។ រដ្ឋាភិបាលចូលចិត្តប្រើវិធីនេះដើម្បីបង្វែរឥណទានដើម្បីសម្រេចគោលដៅជាក់លាក់ណាមួយ ។ ក្នុងប្រទេសដែលមានប្រព័ន្ធហិរញ្ញវត្ថុនៅខ្សោយ និងគ្មានការប្រកួតប្រជែង ការគ្រប់គ្រងផ្ទាល់ជាជម្រើសតែមួយគត់ លុះត្រាណាក្របខណ្ឌស្ថាប័នអភិវឌ្ឍរហូតអាចប្រើឧបករណ៍ប្រយោលបាន ។

ប៉ុន្តែ ការប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុផ្ទាល់ ធ្វើឱ្យការបែងចែកធនធានគ្មានប្រសិទ្ធភាព និង គ្មានសមធម៌ ។ អប្រសិទ្ធភាពកើតឡើងដោយសារការគេចបន្ធំ ។ ភ្នាក់ងារសេដ្ឋកិច្ចជាធម្មតារិះរកមធ្យោបាយដើម្បីគេចចេញ ។ ការកំណត់ពិដានឥណទានពាក់ព័ន្ធនឹងស្ថាប័នខ្លះ ដែលភាគច្រើនក្លាយជាឆ្អឹងខ្នងសម្រាប់បែងចែកឥណទាន កំហិតការប្រកួតប្រជែង និងរារាំងមិនឱ្យមានធនាគារថ្មីៗ ។ ការគ្រប់គ្រងផ្ទាល់អាចនាំឱ្យមានសាច់ប្រាក់ច្រើនជ្រុល ស្លៀតហិរញ្ញវត្ថុ និង បដិអន្តរការីយកម្មហិរញ្ញវត្ថុ ។ ជាងនេះទៅទៀត ឧបករណ៍ផ្ទាល់កាន់តែគ្មានប្រសិទ្ធភាព ប្រសិនបើសេដ្ឋកិច្ចកាន់តែបើកចំហ ក្នុងបរិការណ៍នៃការអនុវត្តនូវការប្តូរដោយសេរីនៃគណនីចរន្ត (Current account convertibility) ពោលគឺរដ្ឋអនុញ្ញាតអោយនិវាសនជនប្តូររូបិយវត្ថុជាតិដោយសេរី ដើម្បីយករូបិយប័ណ្ណអន្តរជាតិ ក្នុងគោលដៅអនុវត្តប្រតិបត្តិការគណនីចរន្ត និងដំណើរការឈានទៅចាប់ការអនុវត្តនូវគោលនយោបាយអនុញ្ញាតអោយនិវាសនជន អាចទូទាត់ជារូបិយប័ណ្ណបរទេសនូវរាល់ប្រតិបត្តិការនៃគណនីមូលធន (Full external account convertibility) ។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលអាចអនុវត្តនូវគោលនយោបាយដែលអនុញ្ញាតអោយនិវាសនជនអាចយករូបិយវត្ថុជាតិ ទៅប្តូរយករូបិយប័ណ្ណបរទេស រក្សាទុករូបិយប័ណ្ណបរទេស និងផ្ទេររូបិយប័ណ្ណបរទេសទៅអោយអនិវាសនជនបាន (Internal convertibility) ។

### ៣.២.១ ការកំណត់ពិដានឥណទាន (Credit Ceiling)

ការកំណត់ **ពិដានឥណទាន** ជាឧបករណ៍មួយគេប្រើប្រាស់ញឹកញាប់បំផុត ដើម្បីគ្រប់គ្រងឥណទាន ។ ***ពិដានឥណទាន ជាភាគរយកម្រិតអតិបរមាដែលធនាគារពាណិជ្ជ ទទួលបានការអនុញ្ញាតជាមុន ឱ្យបង្កើនសន្និធិទ្រព្យសកម្មតាមប្រភេទនីមួយៗ នៅក្នុងរយៈពេលណាមួយ*** ។ ជាធម្មតា គេកំណត់តម្លៃរបស់វា ដោយធៀបទៅនឹងសន្និធិទ្រព្យសកម្មដែលជាប់និយ័តកម្ម នៅចុងកាលកំណត់គោល ។ តាមរយៈការផ្លាស់ប្តូរលក្ខណៈពិដានឥណទាន ធនាគារកណ្តាលអាចប្រើពិដានឥណទានក្នុងគោលបំណងផ្សេងៗជាច្រើន (ឧទាហរណ៍ ការកំណត់គោលដៅ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការផ្គត់ផ្គង់រូបិយវត្ថុសរុប ការអនុវត្ត **វិធានប្រុយ៉ត្ចប្រយែទ** បង្វែរឥណទានទៅតាមវិស័យសេដ្ឋកិច្ចណាមួយ)។

ហេតុផលនៃការប្រើពិដានឥណទានជាឧបករណ៍គោលនយោបាយរូបិយវត្ថុ ស្តែងចេញអំពីសមមូលគណនេយ្យរវាងបរិមាណនៃរូបិយវត្ថុក្នុងស្រុក ដែលជាផ្នែកមួយនៃរូបិយវត្ថុទូទៅ (M2) និងផលបូក នៃបម្រែបម្រួល **មូលដ្ឋានរូបិយវត្ថុ** (Monetary base) (មូលដ្ឋានរូបិយវត្ថុដកនឹងទុនបម្រុងដែលធនាគារខ្ចីពីធនាគារកណ្តាល) និង ទ្រព្យសកម្មជារូបិយវត្ថុក្នុងស្រុកដែលផ្តល់ការប្រាក់របស់ធនាគារ ។ ដោយសារតែរូបិយប័ណ្ណអាចបង្កើតឡើងបាន ដោយធនាគារកណ្តាល ឬ ដោយធនាគារពាណិជ្ជ ការត្រួតពិនិត្យរូបិយវត្ថុត្រូវអនុវត្តទៅបានតាមរយៈប្រតិបត្តិការផ្តល់ឥណទានរបស់ធនាគារកណ្តាល និងធនាគារពាណិជ្ជ ។

ពិដានឥណទានអាចត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ តាមរយៈការកំណត់គោលដៅរូបិយវត្ថុសរុប ឬឥណទានសរុប ។ ធនាគារកណ្តាលអាចកំណត់គោលដៅ កំណើនការផ្គត់ផ្គង់រូបិយវត្ថុ និង កំណើនឥណទានសរុប ប្រកបដោយប្រសិទ្ធភាព តាមរយៈការកែប្រែទំហំបំណុលរបស់ខ្លួន និង ការប្រើប្រាស់មេគុណរូបិយវត្ថុ (money multiplier) ជាន់ស្ទាន ដើម្បីទស្សទាយបម្រែបម្រួលបរិមាណរូបិយវត្ថុ និងឥណទាន ។ ពិដានឥណទានមានពីរប្រភេទ អាស្រ័យលើទំហំទ្រព្យសកម្មដែលផ្តល់ប្រាក់ចំណេញរបស់ធនាគារនៅក្រោមនិយ័តកម្ម គឺ ពិដានឥណទានសរុប និងពិដានឥណទានដោយផ្នែក ។ ពិដានឥណទានសរុបកម្រិតអត្រាកំណើនលើទ្រព្យសកម្មដែលផ្តល់ប្រាក់ចំណេញទាំងអស់របស់ធនាគារ ។ ពិដានឥណទានដោយផ្នែកកម្រិតអត្រាកំណើនលើប្រភេទទ្រព្យសកម្មដែលផ្តល់ប្រាក់ចំណេញមួយចំនួនប៉ុណ្ណោះ ។

ពិដានឥណទានអាចប្រើប្រាស់ ផ្សំផ្សំជាមួយឧបករណ៍រូបិយវត្ថុដោយប្រយោល ដោយដំបូងគ្រាន់តែកែតម្រូវឧបករណ៍រូបិយវត្ថុប្រយោល ដើម្បីសម្រេចអត្រាកំណើនរូបិយវត្ថុគោលដៅដែលចង់បានសិន រួចសឹមកំណត់ពិដានឥណទាន ដើម្បីគ្រប់គ្រងមេគុណរូបិយវត្ថុ ។

ទាក់ទងនឹងឥទ្ធិពលនៃការកំណត់ពិដានឥណទានលើអត្រាការប្រាក់ បើសិនជាការកំណត់នោះ ទាបជាងកម្រិតសមតាទីផ្សារ នោះអត្រាការប្រាក់នឹងកើនឡើង ប្រសិនបើគ្មានការគ្រប់គ្រងអត្រាការប្រាក់ទេនោះ ។ ការប្រើប្រាស់រួមគ្នា រវាងពិដានឥណទាន និងការគ្រប់គ្រងអត្រាការប្រាក់ នាំឱ្យមានការបែងចែកធនធានហិរញ្ញវត្ថុគ្មានប្រសិទ្ធភាព ដោយសារធនាគារជ្រើសយកគម្រោង មិនផ្អែកទៅតាមគោលការណ៍សេដ្ឋកិច្ចឡើយ ។

## ៣.២.២. ការកំណត់ទិសដៅឥណទាន (Directed Lending)

**ការកំណត់ទិសដៅឥណទាន** ត្រូវបានអនុវត្ត នៅពេលដែលធនធានហិរញ្ញវត្ថុត្រូវបានបែងចែកតាមការបង្គាប់បញ្ជារបស់អាជ្ញាធរ ដើម្បីសម្រេចទិសដៅគោលនយោបាយជាជាងតាមគោលការណ៍ពាណិជ្ជកម្ម ។ វិស័យធនាគារត្រូវបានណែនាំឱ្យផ្តល់ហិរញ្ញប្បទានទៅដល់ វិស័យ សហគ្រាស ឬគម្រោង តាមទិសដៅរបស់រដ្ឋាភិបាល ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលបំណងសំខាន់ **ការកំណត់ទិសដៅឥណទាន** គឺបង្កើនប្រាក់កម្ចីចំពោះវិស័យអាទិភាព ដែលគោលនយោបាយបានកំណត់ ។ **ការកំណត់ទិសដៅឥណទាន** អាចមានទម្រង់ជាការកំណត់ល័ក្ខខ័ណ្ឌកម្ចី ដូចជាអាយុកម្ចី កម្ចីអតិបរិមាសម្រាប់គោលបំណងជាក់លាក់ ការកំណត់កម្រិតស្វ័យហិរញ្ញប្បទានដោយអ្នកសុំខ្ចីដែលអាស្រ័យតាមអាទិភាពគោលនយោបាយ និង ធ្វើបញ្ជីនៃវិស័យដែលត្រូវហាមឃាត់ ។ **ការកំណត់ទិសដៅឥណទាន** ភាគច្រើនអនុវត្ត ដោយផ្តល់អាទិភាពដល់វិស័យនាំចេញ និងអចលនវត្ថុ ។

### ៣.២.៣ ការត្រួតពិនិត្យអត្រាការប្រាក់ (Interest Rate Control)

**ការត្រួតពិនិត្យអត្រាការប្រាក់** ជាឧបករណ៍គោលនយោបាយរូបិយវត្ថុ ដែលអាជ្ញាធរត្រួតពិនិត្យថ្លៃនៅក្នុងទីផ្សារមូលដ្ឋានរូបិយវត្ថុ ដោយមិនត្រួតពិនិត្យលើបរិមាណឡើយ ។ ធនាគារកណ្តាលអាចមានឥទ្ធិពលដោយផ្ទាល់ ទៅលើអត្រាការប្រាក់មួយចំនួនតូចប៉ុណ្ណោះ ៖ គឺជាអត្រាដែលធនាគារកណ្តាលផ្តល់មូលនិធិបន្ថែមទៅឱ្យធនាគារពាណិជ្ជ ។ អត្រាការប្រាក់ទីផ្សារ ដែលពឹងផ្អែកលើសកម្មភាពពិត ជាធម្មតា វាខុសពីអត្រាការប្រាក់ផ្លូវការ ទោះបីជាអត្រាទីផ្សារវាមិនអាចឯករាជទាំងស្រុងពីអត្រាផ្លូវការឡើយ ។

ការត្រួតពិនិត្យអត្រាការប្រាក់ នាំឱ្យមានវត្តមានអត្រាការប្រាក់ពីរទន្ទឹមគ្នា គឺ **អត្រាការប្រាក់ផ្លូវការ** និង **អត្រាការប្រាក់ទីផ្សារ** ។ ដូច្នេះ អាជ្ញាធររូបិយវត្ថុជាដំបូងត្រូវយល់អំពីចរិតនៃយន្តការដែលអត្រាការប្រាក់ផ្លូវការមានឥទ្ធិពលលើអត្រាការប្រាក់ទីផ្សារសិន មុននឹងសម្រេចចិត្តពីកម្រិតសមស្របនៃឧបករណ៍គោលនយោបាយ ។ ទីពីរ អត្រាការប្រាក់ មានបូកបញ្ចូលនូវ **លាភការហានិភ័យ** (Risk premium) ។ ដូច្នេះ អត្រាទាំងពីរនេះប្រហែលជាមិនប្រែប្រួលស្របគ្នាទាំងស្រុងបានទេ ។ ទាំងអ្នកធ្វើគោលនយោបាយ ទាំងអ្នកអត្ថាធិប្បាយត្រូវយល់ដឹងថា អត្រាការប្រាក់ឆ្លុះបញ្ចាំងអំពីភាពចម្រុះនៃល័ក្ខខ័ណ្ឌទីផ្សារ នៅពេលវាយតម្លៃពីគោលនយោបាយរូបិយវត្ថុបង្រួម ឬ ពីគោលនយោបាយរូបិយវត្ថុពង្រីក ។

## ៤- គោលនយោបាយរូបិយវត្ថុនៅក្នុងប្រទេសកម្ពុជា

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់ និងដាក់ទិសគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថេរភាពថ្លៃ និងជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។ មុខងារសំខាន់គឺ៖

**១) ដើរតួនាទីជាអាជ្ញាធររូបិយវត្ថុ និង អនុវត្តគោលនយោបាយរូបិយវត្ថុ** ។ នៅក្នុងតួនាទីនេះធនាគារជាតិធ្វើអន្តរាគមន៍យ៉ាងសកម្មនៅក្នុងទីផ្សារប្តូរប្រាក់ ដើម្បីស្ថិរភាពអត្រាប្តូរប្រាក់ និងស្ថិរភាពថ្លៃក្នុងស្រុក។ ជាលទ្ធផល ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ តម្លៃប្រាក់រៀលបានធ្លាក់ចុះនៅក្នុងអត្រា ១% ជាមធ្យមប្រចាំឆ្នាំ ប៉ុន្តែនៅក្នុងឆ្នាំ ២០០៦ តម្លៃប្រាក់រៀលបានកើនឡើង ១% បើធៀបទៅនឹងប្រាក់ដុល្លារសហរដ្ឋអាមេរិក ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**២) - ដើរតួនាទីជាអ្នកបោះពុម្ពផ្សាយរូបិយប័ណ្ណជាតិផ្តាច់មុខ** ។ ព្រោះហេតុនេះហើយ ធនាគារជាតិបានបង្កើនបរិមាណរូបិយវត្ថុជាតិ ហើយប្តូរយកចេញក្រដាសប្រាក់ចាស់ រហែក និងកខ្វក់ ។

**៣) - ដើរតួជាអាជ្ញាធរត្រួតពិនិត្យ និងដាក់បទបញ្ញត្តិលើប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ** ។

**៤) - ត្រួតពិនិត្យលើប្រព័ន្ធទូទាត់នានានៅក្នុងប្រទេសកម្ពុជា** និង

**៥) - គ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ប្រទេស** ដែលកើនដល់ ២,២ ពាន់លានដុល្លារសហរដ្ឋអាមេរិក នៅចុងឆ្នាំ ២០០៨ កន្លងមកនេះ ។

## *៤.១. ឧបករណ៍គោលនយោបាយរូបិយវត្ថុនៅកម្ពុជា*

ដុល្លារូបនីយកម្មធ្វើអោយប៉ះពាល់ដល់ជម្រើសនូវ **គោលដៅរូបិយវត្ថុ** ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងរចនាសម្ព័ន្ធនៃការត្រួតពិនិត្យនៃ**បទបញ្ញាប្រុងប្រយ័ត្ន** ។ **ការជំនួសរូបិយវត្ថុ** មានន័យថា នៅពេលដែលយើងចង់កំណត់គោលដៅកម្រិតថ្លៃ យើងក៏ត្រូវគិតគូរផងដែរពី ទ្រព្យសកម្មរូបិយវត្ថុជាប្រាក់ដុល្លារ ដែលបានក្លាយទៅជាផ្នែកមួយនៃការផ្គត់ផ្គង់រូបិយវត្ថុ ។ សេដ្ឋកិច្ចដែលប្រើប្រាស់ប្រាក់ដុល្លារយ៉ាងច្រើន ទាមទារឱ្យធនាគារកណ្តាលត្រូវប្រើប្រាស់ឧបករណ៍ជាប្រាក់ដុល្លារ ដើម្បីគ្រប់គ្រងរូបិយវត្ថុ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ប្រសិទ្ធភាពនៃឧបករណ៍នេះវាអាស្រ័យទៅលើលទ្ធភាពជំនួសរវាង សញ្ញាប័ណ្ណរដ្ឋជាប្រាក់ដុល្លារ និងទ្រព្យសកម្មជាប្រាក់ដុល្លារដែលមាននៅក្រៅប្រទេស ។ កាលណាលទ្ធភាពជំនួសកាន់តែខ្ពស់ ឧបករណ៍មានប្រសិទ្ធភាពកាន់តែទាប (IMF ឆ្នាំ ១៩៩៩) ។ ប៉ុន្តែបញ្ហានេះគឺគ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ ពីព្រោះប្រទេសកម្ពុជានាពេលបច្ចុប្បន្នគ្មានទីផ្សារសញ្ញាប័ណ្ណរដ្ឋ ឬទីផ្សារមូលបត្រ នៅឡើយទេ ។

នៅក្នុងបរិបទនៃសេដ្ឋកិច្ចដុល្លារូបនីយកម្ម ធនាគារជាតិនៃកម្ពុជាប្រើប្រាស់ការធ្វើ **អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់** ជាឧបករណ៍គោលនយោបាយរូបិយវត្ថុប្រយោល ។ នៅមានឧបករណ៍ផ្សេងៗទៀតដែរ ដូចជា **ទុនបម្រុងកាតព្វកិច្ច** និង **អត្រាអប្បហារ** ដែលមានអាចប្រើបាន ប៉ុន្តែមិនយកមកអនុវត្ត ។ ការ **កំណត់គោលដៅអត្រាប្តូរប្រាក់** គឺជាឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់កម្ពុជា ។

### ៤.១.១. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

ដើម្បីធ្វើឱ្យអត្រាប្តូរប្រាក់មានស្ថិរភាព និងលំហូរទុនចូល- ចេញមានលំនឹងមិនរអាក់រអួល ធនាគារជាតិចូលរួមក្នុងការទិញនិងលក់រូបិយប័ណ្ណអន្តរជាតិ ជាពិសេសប្រាក់ដុល្លារសហរដ្ឋអាមេរិក ។ ឧទាហរណ៍ ក្នុងករណីប្រាក់រៀលធ្លាក់តម្លៃ ធនាគារជាតិនឹងដាក់ដេញថ្លៃប្រាក់ដុល្លារ ពីទុនបម្រុងអន្តរជាតិរបស់ខ្លួន ។ តែអន្តរាគមន៍នេះ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មានគោលដៅគ្រាន់តែបន្ធូរសម្ពាធលើប្រាក់រៀលបណ្ដោះអាសន្នតែប៉ុណ្ណោះ ។ ធនាគារជាតិគ្មានគោលនយោបាយធ្វើអន្តរាគមន៍លើការធ្លាក់ចុះប្រាក់រៀលទេ ប្រសិនបើវាកើតឡើងណ្ដាលមកពីអតុល្យភាពជារចនាសម្ព័ន្ធ ។ ការទិញប្រាក់រៀលដោយធនាគារជាតិមានឥទ្ធិពលពីរយ៉ាង ។ ទីមួយ គឺកាត់បន្ថយទុនបម្រុងរបស់ធនាគារជាតិ ។ ទីពីរ គឺបរិមាណរូបិយប័ណ្ណក្នុងស្រុកកំពុងចរាចរនឹងធ្លាក់ចុះ ។ ការធ្លាក់ចុះនៃមូលដ្ឋានរូបិយវត្ថុ អាចកាត់បន្ថយសម្ពាធលើប្រាក់រៀលកុំឱ្យធ្លាក់ថ្លៃ ។ ក្នុងករណីប្រាក់ដុល្លារធ្លាក់ថ្លៃ ធនាគារជាតិនឹងទិញចូលប្រាក់ដុល្លារសហរដ្ឋអាមេរិក (លក់រូបិយវត្ថុជាតិ) នៅលើទីផ្សារប្ដូរប្រាក់ បណ្ដាលឱ្យមូលដ្ឋានរូបិយវត្ថុ និងទុនបម្រុងអន្តរជាតិកើនឡើង ។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០០៧ ដោយសារតែតម្លៃមាសកើនឡើងខ្ពស់ និងការទិញប្រាក់ដុល្លារលើទីផ្សារ ទុនបម្រុងអន្តរជាតិរបស់កម្ពុជាបានកើន ឡើងពី ១,១ ពាន់លានដុល្លារ ដល់ ១,៦ ពាន់លានដុល្លារ ហើយកើនដល់ ២,២ ពាន់លានដុល្លារ នៅចុងឆ្នាំ ២០០៨ ។

ការធ្វើអន្តរាគមន៍នៅលើទីផ្សាប្ដូរប្រាក់ ដែលធនាគារជាតិទិញឬលក់រូបិយវត្ថុជាតិ ដើម្បីប្ដូរផ្លាស់មូលដ្ឋានរូបិយវត្ថុនោះ គឺជាឧទាហរណ៍នៃ **«ការធ្វើអន្តរាគមន៍រូបិយវត្ថុបរទេសដោយមិនបោះផ្សាយមូលបត្រ» (Unsterilized foreign exchange intervention)** ។ ការធ្វើអន្តរាគមន៍បែបនេះ គឺធនាគារកណ្ដាលយកដុល្លារទៅលក់យកលុយរៀល ដើម្បីកាត់បន្ថយបរិមាណរូបិយវត្ថុជារៀលនៅលើទីផ្សារ ក្នុងគោលដៅអោយតម្លៃប្រាក់រៀលកើនឡើង ។ ប្រការនេះធ្វើឱ្យទុនបម្រុងអន្តរជាតិធ្លាក់ចុះ ការផ្គត់ផ្គង់រូបិយវត្ថុជាប្រាក់រៀលធ្លាក់ចុះ និងតម្លៃប្រាក់រៀលកើនឡើង ។ ទន្ទឹមនឹងនេះ ដើម្បីកុំអោយថ្លៃប្រាក់រៀលកើនឡើងខ្លាំងពេក និង ដើម្បីបង្កើនទុនបម្រុងជារូបិយប័ណ្ណអន្តរជាតិផង ធនាគារជាតិយកប្រាក់រៀលទៅទិញដុល្លារនៅលើទីផ្សារប្ដូប្រាក់ ។ ប្រការនេះធ្វើអោយទុនបម្រុងជារូបិយប័ណ្ណអន្តរជាតិកើនឡើង ការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង និង ប្រាក់រៀលធ្លាក់តម្លៃ ។ ក្នុងករណីចុងក្រោយនេះ មូលដ្ឋានរូបិយវត្ថុរួមតូចជាងមុន ។

ផ្ទុយមកវិញ ក្នុងករណី **«ការធ្វើអន្តរាគមន៍រូបិយវត្ថុបរទេសដោយបោះផ្សាយមូលបត្រ» (Sterilized intervention)** ធនាគារកណ្ដាលគឺមិនចង់ឱ្យប្រតិបត្តិការរបស់ខ្លួន នៅលើទីផ្សារប្ដូរប្រាក់ប៉ះពាល់ដល់មូលដ្ឋានរូបិយវត្ថុទេ ។ ដើម្បីសម្រេចបានគោលនយោបាយនេះ ធនាគារកណ្ដាលអនុវត្តនូវប្រតិបត្តិការទីផ្សារបើកចំហ ដើម្បីកាត់បន្ថយមូលដ្ឋានរូបិយវត្ថុ ដែលប្រតិបត្តិការទីផ្សារប្ដូរប្រាក់ធ្វើអោយកើនឡើង ។ ពោលគឺធនាគារកណ្ដាលត្រូវបោះផ្សាយមូលបត្រ ហើយលក់អោយទីផ្សារ ដើម្បីស្រូបយកប្រាក់រៀលដែលធនាគារកណ្ដាលបានបញ្ចេញទៅក្នុងទីផ្សារ ដើម្បីទិញយកប្រាក់ដុល្លារ ។ ប្រតិបត្តិការទាំងពីរនេះ ធ្វើអោយមូលដ្ឋានរូបិយវត្ថុនៅដដែល ។ ឧទាហរណ៍ នៅក្នុងករណី យកប្រាក់រៀលចំនួន ៤០០.០០០ លានរៀល ទៅទិញយក ប្រាក់ដុល្លារចំនួន ១០០ លានដុល្លារ ពីទីផ្សារប្ដូរប្រាក់ ។ ធនាគារជាតិបានបង្កើននូវទុនបម្រុងជារូបិយប័ណ្ណអន្តរជាតិរបស់ខ្លួនចំនួន ១០០លានដុល្លារ ក៏ប៉ុន្តែ មូលដ្ឋានរូបិយវត្ថុក៏កើនឡើងចំនួន ៤០០.០០០ លានរៀល ផងដែរ ដែលអាចបណ្ដាលអោយមានអតិផរណា ។ ដើម្បីកាត់បន្ថយនូវបរិមាណប្រាក់រៀលដែលចរាចរនៅលើទីផ្សារ ធនាគារជាតិអាចបោះផ្សាយនូវមូលបត្រ ហើយលក់អោយសាធារណៈជន ឬ ក្រុមហ៊ុនឯកជន ដើម្បីស្រូបយកទឹកប្រាក់ចំនួន ៤០០.០០០ លានរៀល មកវិញ ។ ប្រតិបត្តិការទីពីរនេះ យើងហៅថាជាប្រតិបត្តិការទីផ្សារចំហ ហើយមូលដ្ឋាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រូបិយវត្ថុនៅដដែល ។ យើងហៅប្រតិបត្តិការនេះថា «**ការធ្វើអន្តរាគមន៍រូបិយវត្ថុបរទេសដោយបោះផ្សាយមូលបត្រ**» ។

### ៤.១.២. ទុនបម្រុងកាតព្វកិច្ច

ក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ **ទុនបម្រុងកាតព្វកិច្ច** ជារូបិយប័ណ្ណអន្តរជាតិ អាចដើរតួនាទីយ៉ាងសំខាន់ ជា **ឧបករណ៍ធ្វើឱ្យស្ថិរភាពសាច់ប្រាក់ដោយស្វ័យប្រវត្តិ** (IMF ១៩៩៩) ។ ទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស អាចប្រើប្រាស់ដើម្បីស្រូបយកកំណើននៃលំហូរចូលមូលធនដោយស្វ័យប្រវត្តិ មិនលើកទឹកចិត្តអោយមូលធនហូរចូលច្រើនពេក ។ ជាទូទៅ ទុនបម្រុងកាតព្វកិច្ចអាចប្រើជាមធ្យោបាយដើម្បី ស្រូបយក (Sterilize) អតិរេកសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារ ។ ជាឧទាហរណ៍ ការកាត់បន្ថយទុនបម្រុងកាតព្វកិច្ចបានកាត់បន្ថយទុនបម្រុងធនាគារពាណិជ្ជត្រូវរក្សាទុកនៅធនាគារកណ្តាល ។ ដូច្នេះហើយ ធនាគារពាណិជ្ជអាចបង្កើនឥណទានបន្ថែមអោយអតិថិជនបាន ដែលជាគោលនយោបាយរូបិយវត្ថុពង្រីក ។ បរិមាណកម្ចីកាន់តែច្រើន គឺវាបង្កើនរូបិយវត្ថុកាន់តែច្រើនដែរ និងជួយជំរុញកំណើនសេដ្ឋកិច្ចថែមទៀត ។

ក៏ប៉ុន្តែ នៅក្នុងបរិបទនៃកំណើនអតិផរណា ការបង្កើនទុនបម្រុងកាតព្វកិច្ចនឹងជួយស្រូបយកសាច់ប្រាក់ និង កំណើនរូបិយវត្ថុពីប្រព័ន្ធធនាគារ ដើម្បីកាត់បន្ថយកុំអោយធនាគារពាណិជ្ជបង្កើនឥណទានខ្លាំងពេក ក្នុងគោលដៅកាត់បន្ថយបរិមាណរូបិយវត្ថុ និង ជាលទ្ធផល កាត់បន្ថយអត្រាអតិផរណា ។

តែទោះជាយ៉ាងណាក្តី ការប្រើទុនទនបម្រុងកាតព្វកិច្ចមិនរើសមុខ អាចប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យហិរញ្ញវត្ថុ។ ការមិនផ្តល់កំរៃលើទុនបម្រុងកាតព្វកិច្ច ដូចជាពន្ធក្នុងវិស័យហិរញ្ញវត្ថុដែរ រួចនាំទៅរកបដិអន្តរករីយកម្មហិរញ្ញវត្ថុ។ ការបង្កើនទុនបម្រុងកាតព្វកិច្ច មានន័យដូចគ្នានឹងបង្កើនថ្លៃដើមរបស់ធនាគារពាណិជ្ជ ។ ដោយកម្ពុជាមានគណនីមូលធនបើកចំហ ពោលគឺមូលធនអាចហូរចូល- ចេញដោយសេរី ដូច្នេះ ការបង្កើនទុនបម្រុងកាតព្វកិច្ចប្រហែលជាមិនអាចសម្រេចបានទាំងស្រុង នូវគោលដៅកាត់បន្ថយបរិមាណរូបិយវត្ថុដែលកំពុងចរាចរឡើយ ដោយសារតែរូបិយវត្ថុជាប្រាក់ដុល្លារ ជាពិសេសប្រាក់បញ្ញើជាប្រាក់ដុល្លារ គឺជាផ្នែកមួយដ៏សំខាន់នៃការផ្គត់ផ្គង់រូបិយវត្ថុ ។ ទោះបីជា ធនាគារកណ្តាលសម្រេចបង្កើនទុនបម្រុងកាតព្វកិច្ចក៏ដោយ ក៏ប្រាក់ដុល្លារនៅតែបន្តហូរចូលក្នុងប្រទេស ដរាបណាអត្រាការប្រាក់ទីផ្សារក្នុងស្រុកខ្ពស់ជាង អត្រាការប្រាក់នៅបរទេស និង ដោយសារលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ចក្នុងប្រទេសមានភាពរឹងមាំ ឬមានឱកាសវិនិយោគទុនល្អក្នុងប្រទេស នោះវិនិយោគិន និវាសនជន និង អនិវាសនជនបន្តនាំយកប្រាក់ដុល្លារចូលមកកម្ពុជា ដោយសារតែធនាគារកណ្តាលមិនអាចត្រួតពិនិត្យលើលំហូរមូលធនបានឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ទុនបម្រុងកាតព្វកិច្ចអាចដោះស្រាយបានមួយចំណែកណាមួយនូវបញ្ហាអតិផរណា ដោយស្រូបយកមួយចំនួននូវបរិមាណរូបិយវត្ថុពីទីផ្សារ ។ ជាពិសេស នៅក្នុងបរិការណ៍សេដ្ឋកិច្ចដុល្លារូបនីយកម្ម ធនាគាជាតិអាចប្រើប្រាស់ទុនបម្រុងកាតព្វកិច្ច ដើម្បីដាក់បទបញ្ញត្តិលើធនាគារពាណិជ្ជ ដើម្បីធានាដល់សន្តិសុខរបស់អ្នកផ្ញើប្រាក់ និង ធានាស្ថេរភាពនៃប្រព័ន្ធធនាគារ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៤.១.៣. កម្ចីអប្បហារ

តាមរយៈប្រតិបត្តិការរបស់ខ្លួនក្នុង **បញ្ជរអប្បហារ** ធនាគារជាតិផ្តល់ជារូបិយណេសុវត្ថិភាព សម្រាប់បន្ទុរសម្ពាធលើទុនបម្រុង ។ តាមរយៈការផ្តល់ **កម្ចីអប្បហារ** ដោយមានវត្ថុបញ្ចាំ ធនាគារកណ្តាលអាចផ្តល់សាច់ប្រាក់ឱ្យទៅគ្រឹះស្ថានហិរញ្ញវត្ថុ និងធានានូវស្ថេរភាពជាមូលដ្ឋាននៃទីផ្សារហិរញ្ញវត្ថុ និងប្រព័ន្ធធនាគារ ។ ឧបករណ៍កម្ចីអប្បហារជាប្រាក់រៀល នៅមិនទាន់ប្រើប្រាស់ជាគោលនយោបាយរូបិយវត្ថុនៅកម្ពុជានៅឡើយទេ ដោយសារ ធនាគារពាណិជ្ជមានសាច់ប្រាក់ជាប្រាក់រៀលនៅសល់ទំនេរដ៏ច្រើនលើសលប់ ដោយមិនចាំបាច់ខ្ចីពីធនាគារជាតិនៃកម្ពុជាឡើយ ។ ក៏ប៉ុន្តែ កម្ចីអប្បហារជាប្រាក់ដុល្លារ ឬ ជារូបិយប័ណ្ណអន្តរជាតិផ្សេងទៀត អាចជាឧបករណ៍គោលនយោបាយរូបិយវត្ថុដ៏មានប្រយោជន៍ នៅពេលមានវិបត្តិសេដ្ឋកិច្ច នៅពេលដែលធនាគារពាណិជ្ជជួបប្រទះនឹងវិបត្តិកង្វះសាច់ប្រាក់ ។

## ៤.២. ដុល្លាររូបនីយកម្ម និងរបបអត្រាប្តូរប្រាក់នៅកម្ពុជា

ប្រសិនបើកើតមាន **ការជំនួសរូបិយវត្ថុ** ដំណោះស្រាយយ៉ាងសាមញ្ញគឺ អនុម័តយករបប **អត្រាប្តូរប្រាក់ថេរ** (Fixed exchange rate) ផ្តល់ជាតម្លៃបង្គោល ប្រកបដោយប្រសិទ្ធភាព (Calvo and Vegh, 1996)។ ការផ្លាស់ប្តូរញឹកញាប់ និងមិនដឹងជាមុន អំពីការប្រើប្រាស់រូបិយវត្ថុជាតិ និង រូបិយប័ណ្ណបរទេស ដោយសារតែមាន **ការជំនួសរូបិយវត្ថុ** នឹងនាំឱ្យអត្រាប្តូរប្រាក់ប្រែប្រួលខ្លាំងមិនទៀងទាត់ (IMF 1999) ។ បម្រែបម្រួលអត្រាប្តូរប្រាក់ ធ្វើឱ្យអាជ្ញាធររូបិយវត្ថុពិបាកគ្រប់គ្រងបរិមាណផ្គត់ផ្គង់រូបិយវត្ថុ ។ ម្យ៉ាងវិញទៀត តម្រូវការរូបិយវត្ថុជាតិងាយនឹងប្រែប្រួលទៅតាមតម្លៃឱកាសដែលរំពឹងទុក (Expected Opportunity Cost) នៃការរក្សាទុករូបិយវត្ថុជាតិ ។ ក្នុងករណីនៃ **ការជំនួសទ្រព្យសកម្ម**វិញ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស នៅក្នុងធនាគារក្នុងស្រុកនឹងបង្កើនការចលនាលំហូរទុន (Capital mobility) ។ ទាំងនេះនឹងជួយពង្រឹងដល់ទំនាក់ទំនងនៃអត្រាការប្រាក់បញ្ញើលុយបរទេសនៅក្នុងស្រុក អត្រាការប្រាក់អន្តរជាតិ និងអត្រាការប្រាក់រូបិយវត្ថុជាតិ ។ ផ្ទុយមកវិញធនាគារកណ្តាលមានលទ្ធភាពកំណត់ ដើម្បីគ្រប់គ្រងលក្ខខណ្ឌទីផ្សាររូបិយវត្ថុ ដូចជា ការកម្រិតអត្រាការប្រាក់លើរូបិយវត្ថុក្នុងស្រុក ។ នៅក្នុងន័យនេះ របបគ្រប់គ្រងអត្រាប្តូរប្រាក់អណ្តែត (Floated exchange rate) អាចជារបបសមរម្យជាងគេ (IMF 1990) ។

នៅខណៈនេះ ការជជែកវែកញែកលើដុល្លាររូបនីយកម្មពេញលេញ ដូចគ្នានឹងការជជែកវែកញែកទៅលើរបបអត្រាប្តូរប្រាក់សមស្រប ។ បន្ទាប់ពីកើតមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ី ប្រទេសភាគច្រើន លើកលែង តែប្រទេសម៉ាឡេស៊ី បានចាប់យករបបអត្រាប្តូរប្រាក់អណ្តែត ។ ហេតុផលចំបងគឺ ការប្រកាន់យកអត្រាប្តូរប្រាក់ថេរ គឺជាកត្តាចំបងនាំអោយមានវិបត្តិហិរញ្ញវត្ថុនេះ ។ មានការជជែកវែកញែកថាអត្រាប្តូរប្រាក់កាន់តែអណ្តែតបង្អាក់ទឹកចិត្តអ្នកខ្ចីជាប្រាក់បរទេស ជាពិសេស ពីផ្នែកមិនមែនពាណិជ្ជកម្ម ដោយសារតែអ្នកខ្ចីប្រាក់អាចនឹងប្រឈមមុខចំពោះហានិភ័យអត្រាប្តូរប្រាក់ខ្ពស់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទោះជាយ៉ាងណាក៏ដោយ ការពិភាក្សានេះភ្លេចគិតពីការពិតដែលថាសេដ្ឋកិច្ចភាគច្រើន យ៉ាងហោចណាស់ក៏ជាសេដ្ឋកិច្ចដុល្លារូបនីយកម្មដោយអន្លើដែរ (Partially dollarized) មានន័យថា នៅមានទ្រព្យអកម្មជាប្រាក់ដុល្លារ (Calvo and Reinhart, 1996)។ ដុល្លារូបនីយកម្មអន្លើធ្វើឱ្យអត្រាប្តូរប្រាក់ផ្លាស់ប្តូរជាញឹកញាប់ ហើយធនាគារកណ្តាលត្រូវធ្វើអន្តរាគមន៍ក្នុងទីផ្សារអត្រាប្តូរប្រាក់ ដើម្បីការពារអត្រាប្តូរប្រាក់កុំឱ្យប្រែប្រួលខ្លាំងពេក ក្នុងគោលបំណងកាត់បន្ថយការវាយតម្លៃសារចុះឡើងលើតារាងតុល្យការអាជីវកម្មញឹកញាប់ពេក ។ ការធ្វើបែបនេះធ្វើអោយរបបអត្រាប្តូរប្រាក់ក្លាយជារបប **បង្គោលទន់ភ្លន់** (Soft peg) ប៉ុន្តែវាក៏ធ្វើអោយភ្នាក់ងារសេដ្ឋកិច្ចកាន់តែអាងខ្លាំងឡើង (Moral hazard) ដោយយល់ថាធនាគារកណ្តាលច្បាស់ជាធ្វើអន្តរាគមន៍ ដើម្បីការពារអត្រាប្តូរប្រាក់ ដោយពុំគិតពីវិចារណៈញាណខាងផ្នែកសេដ្ឋកិច្ច ដូចក្នុងករណីវិបត្តិហិរញ្ញវត្ថុនៅអាស៊ីដូច្នេះដែរ ។ ប្រការនេះនឹងបង្កើតអោយមាននូវ **មច្ចុវដ្ត** (Vicious Cycle) ដែលពិបាករកផ្លូវចេញ ។

ដើម្បីចៀសវាងបញ្ហារូបិយប័ណ្ណមិនត្រូវគ្នា **(ធនាគារពាណិជ្ជខ្ចីប្រាក់ពីបរទេសជាប្រាក់ដុល្លារ ហើយដូរជារូបិយវត្ថុជាតិ ដើម្បីផ្តល់ឥណទានដល់អតិថិជន)** នៅក្នុងរបបអត្រាប្តូរប្រាក់ថេរ (Fixed) ជម្រើសដ៏ល្អគឺការធ្វើដុល្លារភាវូបនីយកម្មពេញលេញ ។ ការធ្វើបែបនេះនឹងធ្វើឱ្យប្រទេសអាចកាត់បន្ថយនូវការទទួលរងនូវបញ្ហាពីការបញ្ឈប់ភ្លាមៗនៃលំហូរមូលធន (Calvo and Reinhart, 1999) ។ ធនាគារពាណិជ្ជនឹងមិនជួបបញ្ហានៃការប្រែប្រួលភ្លាមៗនៃការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មរបស់គេឡើយ ហើយរូបិយវត្ថុជាតិនឹងមិនទទួលរងនូវការវាយប្រហារពីពួកកេងយកចំណេញ ដែលធ្វើយ៉ាងណាបន្ទាបតម្លៃរូបិយវត្ថុជាតិ ដើម្បីប្រមូលនូវប្រាក់ចំណេញដ៏ច្រើនសន្ធឹកសន្ធាប់ ។

នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសកម្ពុជាមានរបបអត្រាប្តូរប្រាក់ពីរនៅក្នុងពេលតែមួយ ។ ធនាគារជាតិនៃកម្ពុជាកំណត់អត្រាជាផ្លូវការមួយ នៅខណៈដែលទីផ្សារប្រើអត្រាប្តូរប្រាក់ទីផ្សារសេរីស្របគ្នាមួយទៀត ។ នៅដើមទសវត្សរ៍ឆ្នាំ ២០០០ ធនាគារជាតិ បានខិតខំប្រឹងប្រែង រក្សាអត្រាជាផ្លូវការអោយស្ថិតនៅចន្លោះពី +/- ២% នៃអត្រាទីផ្សារ ។ របបអត្រាប្តូរប្រាក់ត្រូវបានធ្វើឱ្យដូចគ្នានៅត្រឹមឆ្នាំ ២០០៥ ដោយ អត្រាផ្លូវការត្រូវបានកំណត់ដោយឈរលើមូលដ្ឋាននៃអត្រាទីផ្សារ ពោលគឺជារបបអត្រាប្តូរប្រាក់តែមួយ ។ របបអត្រាប្តូរប្រាក់របស់ប្រទេសកម្ពុជាបច្ចុប្បន្ន ត្រូវបានចាត់ទុកថាជាប្រព័ន្ធប្តូរប្រាក់អណ្តែតដោយគ្រប់គ្រង (Managed float) ។ អត្រាប្តូរប្រាក់អាចប្រែប្រួលជារៀងរាល់ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលទីផ្សារ ។ ការប្រែប្រួលនៃ **អត្រាប្តូរប្រាក់ស័ក្តិសិទ្ធពិត** (Real effective exchange rate) និង តាមថ្លៃទីផ្សារ (Nominal effective exchange rate) របស់ប្រាក់រៀលត្រូវបានបង្កើតឱ្យមាន ដោយអតិផរណានៅក្នុងអត្រាប្តូរប្រាក់នៃប្រាក់ដុល្លារសហរដ្ឋអាមេរិក ប្រៀបធៀបទៅនឹងរូបិយប័ណ្ណសំខាន់ៗផ្សេងទៀត ។ ទោះជាយ៉ាងណាក៏ដោយ ក៏ធនាគារជាតិមិនអនុញ្ញាតឱ្យមានការប្រែប្រួលនៃអត្រាប្តូរប្រាក់ខ្លាំងពេកទេ ដើម្បីឱ្យវាកាន់តែងាយស្រួលសម្រាប់ក្រុមហ៊ុន និងឯកត្តជន ទាំងឡាយធ្វើគម្រោងសម្រាប់អនាគត ។

អតិរេកនៃជញ្ជីងទូទាត់គួរតែធ្វើអោយតម្លៃនៃរូបិយវត្ថុជាតិកើនឡើង ប្រសិនបើធនាគារជាតិមិនមាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អន្តរាគមន៍លើទីផ្សារប្តូរប្រាក់នោះទេ ។ តែដោយសារហេតុថា កំណើនតម្លៃប្រាក់រៀលនឹងជះឥទ្ធិពលអវិជ្ជមានទៅលើវិស័យនាំចេញ ជាពិសេស ដូចជាឧស្សាហកម្មកាត់ដេរ ធនាគារជាតិកម្ពុជាតែងតែធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដោយយកប្រាក់រៀលទៅទិញប្រាក់ដុល្លារសហរដ្ឋអាមេរិកនៅលើទីផ្សារប្តូរប្រាក់ ដើម្បីបង្កើនទុនបម្រុងអន្តរជាតិ ។ ផ្ទុយទៅវិញ ឱនភាពជញ្ជីងទូទាត់នឹងនាំប្រាក់រៀលចុះថោក ។ ប្រការនេះហើយ ធ្វើឱ្យទំនិញនាំចូលពីបរទេសមានតម្លៃកាន់តែថ្លៃ សម្រាប់អ្នកប្រើប្រាស់ក្នុងប្រទេស និងអាចបណ្តាលឱ្យមានអតិផរណា ។ ដើម្បីរក្សាស្ថេរភាពនៃអត្រាប្តូរប្រាក់ រវាងប្រាក់រៀល និងប្រាក់ដុល្លារធនាគារកណ្តាលនឹងទិញរូបិយប័ណ្ណជាតិនៅលើទីផ្សារប្តូរប្រាក់ ដោយកាត់បន្ថយទុនបម្រុងអន្តរជាតិ ។

ទីផ្សាររូបិយវត្ថុរបស់ប្រទេសកម្ពុជា ជាពិសេស ទីផ្សារប្តូរប្រាក់នៅតូចចង្អៀតខ្លាំង និងមិនទាន់អភិវឌ្ឍនៅឡើយ ។ នៅក្នុងប្រទេសកម្ពុជា ជាពិសេស នៅក្នុងទីក្រុងភ្នំពេញ មានអាជីវករប្តូរប្រាក់ក្នុងទ្រង់ទ្រាយតូចជាច្រើន ដែលដើរតួជាភ្នាក់ងារទូទាត់សម្រាប់ពាណិជ្ជកម្មក្រៅប្រទេសផងដែរ ។ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការចុះបញ្ជីអាជីវករប្តូរប្រាក់ទាំងនេះ ដើម្បីពង្រឹងការគ្រប់គ្រងទីផ្សារប្តូរប្រាក់អោយមានសណ្តាប់ធ្នាប់ល្អ ។

## ៤.៣. សេរីភាវូបនីយកម្មហិរញ្ញវត្ថុ សេរីភាវូបនីយកម្មគណនីមូលធន និង គោលនយោបាយអត្រាប្តូរប្រាក់

ទស្សនទាននៃសេរីភាវូបនីយកម្មហិរញ្ញវត្ថុ មានន័យទូលំទូលាយជាងសេរីភាវូបនីយកម្មគណនីមូលធន ។ **សេរីភាវូបនីយកម្មហិរញ្ញវត្ថុ** គឺជាដំណើរការកាត់បន្ថយ ឬការរំលាយចោលការត្រួតពិនិត្យនៃរចនាសម្ព័ន្ធស្ថាប័ន ឧបករណ៍ និងសកម្មភាពរបស់ភ្នាក់ងារ នៅក្នុងគ្រប់ផ្នែកនៃវិស័យហិរញ្ញវត្ថុ (Chandrasekhar, 2005) ។ សេរីភាវូបនីយកម្មហិរញ្ញវត្ថុត្រូវមានលក្ខណៈដូចខាងក្រោមនេះ ÷

ទី១- ការលុបបំបាត់ការត្រួតពិនិត្យអត្រាការប្រាក់ និងការប្រើប្រាស់ដោយធនាគារកណ្តាលនូវយន្តការទីផ្សារ ដូចជា ការប្រើប្រាស់អត្រាអប្បហារ ឬប្រតិបត្តិការទីផ្សារចំហជាដើម ។ ការធ្វើសេរីភាវូបនីយកម្មបែបនេះគឺជួយជំរុញការប្រកួតប្រជែងក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ ។

ទី២- ការលុបបំបាត់ឧបសគ្គក្នុងការបង្កើតនូវស្ថាប័នហិរញ្ញវត្ថុថ្មីៗ ទាំងស្ថាប័ននៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីឱ្យស្ថាប័នទាំងពីរប្រភេទអាចប្រកួតប្រជែងដោយស្មើភាពគ្នា ។

ទី៣- លុបបំបាត់នូវរបាំងបែងចែកវិស័យហិរញ្ញវត្ថុជាអនុផ្នែកតូចៗផ្សេងគ្នា ក្នុងគោលដៅធ្វើនិយ័តកម្មរួម ដូចជា ផ្នែកធនាគារ ផ្នែកធនាគារជំនួញ ផ្នែកគ្រប់គ្រងទ្រព្យសកម្ម ផ្នែកមូលនិធិសង្គហធម៌ ផ្នែកធនាគារវិនិយោគ និងផ្នែកធានារ៉ាប់រង ឆ្ពោះទៅរក «ធនាគារសកល» ។

ទី៤- ពង្រីកប្រភពនៃឧបករណ៍ហិរញ្ញវត្ថុ អនុញ្ញាតឱ្យស្ថាប័នហិរញ្ញវត្ថុអាចទទួលបានប្រភពទុនកាន់តែទូលំទូលាយថែមទៀត ។

ទី៥- ធ្វើសេរីភាវូបនីយកម្មលើច្បាប់គ្រប់គ្រងឧបករណ៍ហិរញ្ញវត្ថុដែលអាចបោះផ្សាយ ឬ ទិញនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ។

ទី៦- លុបបំបាត់ការត្រួតពិនិត្យការប្តូរប្រាក់ ដើម្បីអោយមានសង្គតិភាពជាមួយនឹងសេរីភាវូបនីយកម្មនៃលំហូរមូលធន និង ការប្តូរប្រាក់ដោយសេរីសម្រាប់គ្រប់ប្រតិបត្តិការទាំងអស់នៃគណនីចរន្ត ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និង ការប្តូរប្រាក់ដោយសេរីសម្រាប់គណនីមូលធន ។

ទី៧- ធនាគារកណ្តាលដកខ្លួនពីសកម្មភាពធ្វើជាអន្តរការីយកម្មហិរញ្ញវត្ថុ ដើម្បីបង្កលក្ខណៈសម្បត្តិស្មើៗគ្នាគ្រប់ស្ថាប័នហិរញ្ញវត្ថុទាំងអស់ ដើម្បីប្រកួតប្រជែងគ្នាដោយស្មើភាព ។ ដោយឡែក នៅកម្ពុជារាជរដ្ឋាភិបាលបានធ្វើឯកជនភាវូបនីយកម្មនៃ **ធនាគារពាណិជ្ជកម្មក្រៅប្រទេស** ដើម្បីផ្ទេរសារទៅដល់ស្ថាប័នហិរញ្ញវត្ថុ ពីតួនាទីអព្យាក្រឹតរបស់ធនាគារជាតិនៃកម្ពុជាក្នុងឋានៈជានិយ័តករ ។

ទី៨- បង្កលក្ខណៈងាយស្រួលឱ្យ ទាំងក្រុមហ៊ុន និងទាំងវិនិយោគិន ចូលរួមក្នុងទីផ្សារភាគហ៊ុន ដោយផ្តល់សេរីភាពក្នុងការកំណត់តម្លៃផលប័ត្រថ្មី ដោយបើកសេរីភាពឱ្យបានច្រើនដល់អន្តរការី និងបន្ធូរលក្ខខណ្ឌសម្រាប់ការធ្វើ **សម្ព័ន្ធកម្ម** (Merger) និង **លទ្ធកម្ម** (Acquisition) ។

ទី៩- ពង្រឹងតួនាទីរបស់ធនាគារកណ្តាលនៅក្នុងការតាមដាន និងការត្រួតពិនិត្យ និងផ្លាស់ប្តូរពីរបបត្រួតពិនិត្យ ពីនិយ័តកម្ម មកជារបបណែនាំបែបបញ្ញត្តិកម្ម ពាក់ព័ន្ធនឹង សមត្ថភាពទុន បទដ្ឋានគណនេយ្យ និងការអនុវត្តល្អប្រសើរបំផុត ។

**សេរីភាវូបនីយកម្មគណនីមូលធន** មានលក្ខណៈតូចចង្អៀតខ្លាំងជាង **សេរីភាវូបនីយកម្មហិរញ្ញវត្ថុ**។ ការធ្វើសេរីភាវូបនីយកម្មគណនីមូលធន គឺជាការសម្រេចរបស់រដ្ឋាភិបាលដើម្បីផ្លាស់ប្តូរពីរបបគណនីមូលធនបិទ (ដែលមូលធនមិនអាចបង្វែរចេញ- ចូលពីប្រទេសបានដោយសេរី) អោយទៅជារបបគណនីមូលធនបើកចំហ (ដែលដើមទុនអាចបង្វែរចូល និងចេញទៅតាមបំណង) ។ មានទ្រឹស្តីយ៉ាងច្រើនពិភាក្សាពីគុណវិបត្តិ និងគុណសម្បត្តិនៃសេរីភាវូបនីយកម្មគណនីមូលធន ជាពិសេស ទំនាក់ទំនងនៃសេរីភាវូបនីយកម្មគណនីមូលធនទៅនឹងវិបត្តិរូបិយវត្ថុ និងមានទស្សនៈផ្សេងៗគ្នាទៅលើបញ្ហានេះ ÷

**ទស្សនៈទី១**- ចាត់ទុកថា គុណសម្បត្តិដ៏សំខាន់នៃសេរីភាវូបនីយកម្មគណនីមូលធន គឺ **ប្រសិទ្ធភាពវិភាជន៍ធនធាន** ។ សេរីភាវូបនីយកម្មគណមូលធនជួយសម្រួលដល់ការវិភាជន៍ធនធានជាអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព និងបង្កើតជាផលចំណេញគ្រប់ប្រភេទទាំងអស់ ។ ធនធានហូរពីប្រទេសអភិវឌ្ឍន៍ដែលសំបូរមូលធន

និងមានផលទុនវិនិយោគទាប ទៅប្រទេសកំពុងអភិវឌ្ឍន៍ដែលខ្វះមូលធន និងមានផលទុនវិនិយោគខ្ពស់ ។ លំហូរមូលធនចូលទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍កាត់បន្ថយថ្លៃដើមមូលធន ជំរុញឱ្យមានកំណើនវិនិយោគ និងកំណើនសេដ្ឋកិច្ច ដែលជួយលើកកម្ពស់ជីវភាពរស់នៅ (Fisher, 1997, 2001; Obstfeld, 1998) ។

**ទស្សនៈទី២-** លើកឡើងថា **ប្រសិទ្ធភាពវិភាជន៍ធនធាន** អាចកើតមានឡើងបាន ទាល់តែគ្មាន **វិរូបកម្មសេដ្ឋកិច្ច** (Economic distortion) ក្រៅពីរបាំងមិនឱ្យមូលធនហូរចេញ-ចូលដោយសេរីនោះ ។ ក៏ប៉ុន្តែ ដោយសារតែមានវិរូបកម្មសេដ្ឋកិច្ចជាច្រើននៅប្រទេសកំពុងអភិវឌ្ឍន៍ អ្នករិះគន់បានអះអាងថា ការវិភាគដោយមានតួលេខជាក់ស្តែងជាសំអាងរកឃើញថា គ្មានទំនាក់ទំនងគ្នារវាងការបើកចំហគណនីមូលធនរបស់ប្រទេសទៅនឹងទឹកប្រាក់ ឬអត្រាកំណើនវិនិយោគនោះទេ (Rodrik, 1998) ។ **រ៉ូឌ្រីក** បានសន្និដ្ឋានថា ផលចំណេញពីការបើកចំហគណនីមូលធន ប្រសិនបើមាន ក៏មិនទាន់មានស្តែងប្រាកដឡើយ ។ ក៏ប៉ុន្តែ បើគុណវិបត្តិគេឃើញយ៉ាងច្បាស់ ដែលមានវិបត្តិសេដ្ឋកិច្ចដែលកើតឡើងនៅក្នុងប្រទេសមានសេដ្ឋកិច្ចកំពុងងើបឡើងម្តងហើយម្តងទៀតជាសក្ខីភាពស្រាប់ ។

បទពិសោធន៍នៅទ្វីបអាស៊ី ក៏បានបញ្ជាក់ផងដែរ អំពីសារៈសំខាន់ពីលំដាប់ត្រឹមត្រូវនៃកំណែទម្រង់ ។ ឧទាហរណ៍ដូចជា ការត្រួតពិនិត្យការប្តូរប្រាក់ ការកម្រិតលទ្ធភាពអនិវាសនជនមិនឱ្យទិញ ភាគហ៊ុន និងសញ្ញាប័ណ្ណដែលបោះផ្សាយដោយសាជីវកម្មក្នុងស្រុក ក៏ដូចជា និវេសនជនមិនឱ្យខ្ចីប្រាក់ដោយផ្ទាល់ពីទីផ្សារអន្តរជាតិ ។ ជាលទ្ធផល ក្រុមហ៊ុនក្នុងស្រុកអាចពឹងផ្អែកខ្លាំងទៅលើបំណុលដែលផ្តល់ដោយ ឬ ដែលធានាដោយស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ។ ដោយសារកំណើនសេដ្ឋកិច្ចធ្លាក់ចុះ និង វិបត្តិហិរញ្ញវត្ថុនៅអាស៊ី នៅក្នុងឆ្នាំ១៩៩៧ ឥណទានមិនដំណើរការកើនយ៉ាងឆាប់រហ័ស ហើយធនាគារពាណិជ្ជមិនអាចខ្ចីឥណទានពីទីផ្សារមូលធនអន្តរជាតិ ។

ជាការពិត ការខ្ចីមូលធនពីទីផ្សារហិរញ្ញវត្ថុអន្តរជាតិមានហានិភ័យច្រើន ។ ដូច្នេះហើយ ប្រទេសទាំងឡាយគួរតែប្រុងប្រយ័ត្ន ។ ផ្សារមូលធនអន្តរជាតិងាយប្រែប្រួលណាស់ ទៅតាមគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ភាពរឹងប៉ឹងនៃប្រព័ន្ធធនាគារ និងការអភិវឌ្ឍសេដ្ឋកិច្ច និងនយោបាយ ។ ស្ថាបនិកគោលនយោបាយគួរតែផ្តោតការយកចិត្តទុកដាក់ ឱ្យបានច្រើនទៅលើសញ្ញាទីផ្សារ ដើម្បីពង្រឹងគោលនយោបាយឱ្យបានល្អ ។

ប៉ុន្តែមានពេលខ្លះ ទីផ្សារក៏បំពេញមុខងារមិនបានត្រឹមត្រូវដែរ ។ លំហូរចូលមូលធនក៏ចេះតែឡើងចុះ ។ ជួនកាល ទីផ្សារមានប្រតិកម្មហួសកម្រិត ដោយឆ្លើយតបទៅនឹងសញ្ញាផ្សេងៗ ហើយអាចធ្វើឱ្យមូលធនហូរចេញវិញយ៉ាងលឿន ដូចនៅក្នុងករណីវិបត្តិហិរញ្ញវត្ថុនាអាស៊ី នៅក្នុងឆ្នាំ ១៩៩៧-១៩៩៨ ។ ដូច្នេះហើយ ជោគជ័យនៃសេរីភាវូបនីយកម្មគណនីមូលធនតម្រូវឱ្យមានលក្ខខណ្ឌមួយចំនួន ដូចជា÷

ទី១- ប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុកត្រូវតែរឹងមាំ ដោយមានបទដ្ឋានត្រួតពិនិត្យល្អប្រសើរ និងប្រុងប្រយ័ត្នខ្ពស់។

ទី២- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរឹងប៉ឹង គោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុត្រូវមាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សង្គតិភាពទៅនឹងរបបអត្រាប្តូរប្រាក់ ។

ទី៣- ការធ្វើសេរីភាវូបនីយកម្មគណនីមូលធនតាមលំដាប់លំដោយ ដោយពិចារណាទៅលើស្ថានភាពទីផ្សារ និង ស្ថាប័ននៅក្នុងប្រទេស ។ និង

ទី៤- ប្រតិបត្តិការនៃធនាគារកណ្តាលប្រកបដោយតម្លាភាព ដើម្បីអោយវិនិយោគិនធ្វើការសម្រេចចិត្តអោយបានហ្មត់ចត់ ដោយមានព័ត៌មានគ្រប់គ្រាន់ ។




កម្ពុជាជាប្រទេស ដែលសេរីភាវូបនីយកម្មគណនីមូលធនឈានដល់កម្រិតមួយខ្ពស់ ។ សេដ្ឋវិទូមុនៗធ្លាប់មានទស្សនៈថា សេរីភាវូបនីយកម្មពាណិជ្ជកម្ម ត្រូវតែអនុវត្តដោយគួបផ្សំជាមួយនឹងការកាត់បន្ថយតម្លៃអត្រាប្តូរប្រាក់ ដើម្បីធានាថាសេរីភាវូបនីយកម្មបែបនេះ មិនបង្កើតការលំបាកដល់ជញ្ជីងទូទាត់ ។ ក៏ប៉ុន្តែបទពិសោធន៍កម្ពុជាបានបង្ហាញថា ស្ថិរភាពនៃអត្រាប្តូរប្រាក់មានសារៈសំខាន់ជាងការបញ្ចុះតម្លៃអត្រាប្តូរប្រាក់ក្នុងការជំរុញការនាំចេញផលិតផលកាត់ដេរ ។ ម៉្យាងវិញទៀត ក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្ម និង សេរីភាវូបនីយកម្មគណនីមូលធន បម្រែបម្រួលអត្រាប្តូរប្រាក់ទទួលរងឥទ្ធិពលពីលំហូរមូលធនចេញ- ចូល ដែលរួមមាន៖ ការបង្វែរឯកជន និង បង្វែរសាធារណៈ ព្រមទាំងការឡើងចុះវិនិយោគផ្ទាល់បរទេស ។

បទពិសោធន៍នៃវិបត្តិហិរញ្ញវត្ថុនៅទ្វីបអាស៊ីបានបង្ហាញថា **សេរីភាវូបនីយកម្មគណនីមូលធន** បង្កើតឱ្យមានចរន្តផ្ទុយគ្នារវាង **អត្រាប្តូរប្រាក់ថេរ** និង **ឯករាជ្យភាពនៃគោលនយោបាយរូបិយវត្ថុ** ។ និយាយរួមទៅនៅក្រោមរបបអត្រាប្តូរប្រាក់ថេរ និងរបបគណនីមូលធនបើកចំហ ប្រទេសត្រូវតែបាត់បង់ការគ្រប់គ្រងដោយឯករាជ្យនូវគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ។ នេះជាការបញ្ជាក់ពីសម្មិតកម្ម «**អសង្គតិភាពនាំទបី**» **(Impossible Trinity)** ឬ (The Inconsitent Trinity) ឬ ត្រីកោណផ្ទុមិនបាន (Triangle of Impossibility) ឬ ត្រីមុំមិនស័ក្តិសិទ្ធ (Unholy Trinity) ផងដែរ ដែលបានសិក្សា និង វិភាគនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដោយលោក **រ៉ូប៊ឺត មុនដែល** (Robert Mundell) និង **ម៉ាគូស ផ្លេមីង** (Marcus Fleming) ដែលជាទស្សនទានត្រឹមត្រូវ ។ ដូចពាក្យ «**ជ្រុងបីមិនស្រេច**» ផ្តល់តម្រុយថាលក្ខខណ្ឌទាំងបីខាងក្រោម មិនអាច

កើតមានក្នុងពេលតែមួយបានទេ ÷

- អត្រាប្តូរប្រាក់ថេរ (នឹងថ្កល់)
- ចលនាមូលធនដោយសេរី (របបគណនីមូលធនបើកចំហ)
- គោលនយោបាយរូបិយវត្ថុឯករាជ្យ

នៅក្រោមរបបគណនីមូលធនបើកចំហ ទ្រឹស្តី «**អសង្គតិភាពទាំងបី**» លើកឡើងថា ប្រទេសមួយត្រូវជ្រើសរើសលក្ខខណ្ឌពីរ ក្នុងចំណោមលក្ខខណ្ឌទាំងបី រវាង សមត្ថភាពក្នុងការកាត់បន្ថយបម្រែបម្រួលអត្រាប្តូរប្រាក់ និង គោលនយោបាយរូបិយវត្ថុស្ថេរភាពរូបនីយកម្ម គឺមិនអាចជ្រើសរើសយកទាំងបីបាននោះទេ ។

ប្រទេសមួយជ្រើសរើសបានតែពីរក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ ។ ប្រទេសនោះអាចអនុម័តយករបបអត្រាប្តូរប្រាក់ថេរ ក៏ប៉ុន្តែត្រូវត្រួតពិនិត្យអោយបានដិតដល់នូវលំហូរមូលធន (ដូចជា ប្រទេសចិនសព្វថ្ងៃនេះ ឬ ប្រទេសម៉ាឡេស៊ី នៅអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុ) ។ គេអាចទុកឱ្យមូលធនហូរដោយសេរី ហើយរក្សាឯករាជ្យភាពរូបិយវត្ថុ ប៉ុន្តែត្រូវទុកឱ្យអត្រាប្តូរប្រាក់អណ្តែត (ដូចជាចក្រភពអង់គ្លេស ឬ ប្រទេសកាណាដា) ឬប្រទេសនោះអាចជ្រើសរើសការបើកចំហគណនីមូលធន ហើយរក្សាស្ថេរភាពអត្រាប្តូរប្រាក់ ប៉ុន្តែត្រូវលះបង់ចោលនូវលទ្ធភាពកែសម្រួលអត្រាការប្រាក់ (ការគ្មានឯករាជ្យភាពនៃគោលនយោបាយហិរញ្ញវត្ថុ) ដើម្បីទប់ទល់ទៅនឹងអតិផរណា ឬការធ្លាក់ចុះសេដ្ឋកិច្ច (ដូចជា ប្រទេសអាហ្សង់ទីន សព្វថ្ងៃនេះ ឬ ប្រទេសនៅទ្វីបអឺរ៉ុបភាគច្រើន) ។

សេរីភាវូបនីយកម្មគណនីមូលធនអាចមានឥទ្ធិពលស្មុគស្មាញលើលំនាំពាណិជ្ជកម្ម ។ ទុនហូរចូលដោយការទាក់ទាញ និងកាលានុវត្តភាពរបស់វិនិយោគិន ដែលបើកចំហសម្រាប់ការវិនិយោគផ្ទាល់ផង និងវិនិយោគផលបត្រផង ។ កំណើនលំហូរចូលមូលធនអាចបង្កើនអត្រាប្តូរប្រាក់ពិត ។ ប្រការនេះតម្រូវឱ្យមានអន្តរាគមន៍របស់ធនាគារកណ្តាល ដើម្បីធានាស្ថិរភាពអត្រាប្តូរប្រាក់ ។

ដូច្នេះហើយ នៅក្នុងបរិបទដុល្លារូបនីយកម្ម និងសេរីភាវូបនីយកម្មគណនីមូលធន **អត្រាប្តូរប្រាក់អណ្តែត** (Floated exchange rate) នៅកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ដោយសារដែលដុល្លារភាវូបនីយកម្មនៃសេដ្ឋកិច្ច កម្ពុជាគ្មានគោលនយោបាយរូបិយវត្ថុឯករាជ្យឡើយ ដោយសារតែធនាគារកណ្តាលមិនអាចកំណត់អត្រាការប្រាក់ជាប្រាក់ដុល្លារបានទេ ។ ពោលគឺកម្ពុជាទទួលយកនូវគោលនយោបាយរបស់ធនាគារកណ្តាលនៃសហរដ្ឋអាមេរិក ។ ដោយហេតុថា មូលធនអាចហូរចេញ- ចូលដោយសេរី អត្រាប្តូរប្រាក់អណ្តែតកាត់បន្ថយសម្ពាធកំណើន ឬ ការធ្លាក់ចុះនៃតម្លៃអត្រាប្តូរប្រាក់បន្តិចម្តងៗ ។ លក្ខណៈបែបនេះបានកាត់បន្ថយហានិភ័យនៃវិបត្តិរូបិយប័ណ្ណ និងទប់ស្កាត់ការឡើងថ្លៃ ឬ ការចុះថ្លៃយ៉ាងគំហុក ដែលជាមូលហេតុនៃវិបត្តិរូបិយវត្ថុ ។ ឧទាហរណ៍ នៅពេលដែលមូលធនជាដុល្លារហូរចូលកម្ពុជាច្រើន នោះអត្រាប្តូរប្រាក់រៀល- ដុល្លារ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នឹងកើនឡើងបន្តិចម្តងៗ ។ ប្រការនេះមានន័យថា នៅពេលដែលមានប្រាក់ដុល្លារច្រើនចរាចរនៅលើទីផ្សារ តម្លៃរបស់វានឹងធ្លាក់ចុះ ដោយការផ្គត់ផ្គង់លើសពីតម្រូវការ ។ ប្រសិនបើបរិមាណប្រាក់រៀលចរាចរណ៍នៅដដែល នោះនឹងមានការកើនឡើងនូវតម្លៃប្រាក់រៀល ហើយអត្រាប្រាក់រៀល-ដុល្លារនឹងធ្លាក់ចុះ ឧទាហរណ៍ ពី ៤.១០០ រៀលក្នុងមួយដុល្លារ មកនៅត្រឹម ៤.០០០ រៀលក្នុងមួយដុល្លារ ។ ក៏ប៉ុន្តែ ប្រសិនបើមានលំហូរមូលធនចេញពីកម្ពុជា នោះបរិមាណប្រាក់ដុល្លារកាន់តែខ្សត់ទៅៗ ដែលនឹងធ្វើអោយប្រាក់រៀលបាត់បង់តម្លៃ ហើយអត្រាប្តូរប្រាក់រៀល-ដុល្លារនឹងកើនឡើង ឧទាហរណ៍ ពី ៤.០០០ រៀលក្នុងមួយដុល្លារ ដល់ ៤.២០០ រៀលក្នុងមួយដុល្លារ ។

ការប្រកាន់យកអត្រាប្តូរប្រាក់អណ្តែតមានសារៈសំខាន់ណាស់ ដើម្បីបន្ធូរសំពាធនៃអតិរេក ឬ ឱនភាពជញ្ជីងទូទាត់មកលើអត្រាប្តូរប្រាក់ជាបណ្តើរៗ ដោយមិនរង់ចាំអោយសំពាធនេះផ្ទុះឡើយ ។ ឧទាហរណ៍ ឱនភាពនៃគណនីចរន្តអាចធ្វើហិរញ្ញប្បទានដោយលំហូរមូលធន ដែលធ្វើអោយជញ្ជីងទូទាត់សរុបមានតុល្យភាព ។ ក៏ប៉ុន្តែ ប្រសិនបើ លំហូរនេះជាបំណុលរយៈពេលខ្លី ដែលងាយហូរចេញចូលដោយសេរី នោះនៅពេលដែលវិនិយោគិនបាត់ជំនឿ ហើយចាប់ផ្តើមយកមូលធនចេញពីប្រទេសវិញ សំពាធដ៏ធំធេងនេះនឹងធ្លាក់មកលើអត្រាប្តូរប្រាក់ជាមិនខាន។ ប្រសិនបើប្រកាន់យកអត្រាប្តូរប្រាក់អណ្តែត នោះសំពាធលំហូរចូល-ចេញនៃមូលធននឹងទុកពេល អោយអត្រាប្តូរប្រាក់កែតម្រូវបន្តិចម្តងៗ ។ ក៏ប៉ុន្តែ ប្រសិនបើប្រកាន់យកអត្រាប្តូរប្រាក់ថេរវិញ នោះសំពាធនេះនឹងនៅកកស្ទះ ។ បញ្ហានេះកើតឡើងនៅពេលវិបត្តិសេដ្ឋកិច្ចនៅអាស៊ី ដែលកើតឡើងនៅប្រទេសសៀម ក្នុងឆ្នាំ ១៩៩៧ ។

នៅពេល នោះ រដ្ឋាភិបាលសៀមប្តេជ្ញាមិនបញ្ចុះតម្លៃប្រាក់បាត ដោយសុខចិត្តចំណាយរាប់ពាន់លានដុល្លារ ធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ទាល់តែទុនបម្រុងអន្តរជាតិធ្លាក់ចុះដល់កម្រិតមួយយ៉ាងទាប ។ ដល់ពេលមួយដែលទប់លែងឈ្នះ ធនាគារកណ្តាលសៀមបានសុខចិត្តបណ្តែតអត្រាប្តូរប្រាក់ ដែលជាការផ្ទុះនៃវិបត្តិរូបិយវត្ថុ ។ ក៏ប៉ុន្តែ ដោយក្រុមហ៊ុនសៀម ជាពិសេសធនាគារពាណិជ្ជជាច្រើនបានខ្ចីប្រាក់ជាដុល្លារ ដើម្បីយកដូរជាប្រាក់បាត ហើយផ្តល់ជាឥណទានដល់អតិថិជន នោះវិបត្តិរូបិយវត្ថុបានក្លាយទៅជាវិបត្តិធនាគារ ដោយធនាគារ និង ក្រុមហ៊ុនមិនអាចសងបំណុល បានដោយសារតែអត្រាប្តូរប្រាក់កើនឡើងខ្លាំងពេក ។ វិបត្តិធនាគារធ្វើអោយរាលដាលដល់វិស័យពិត ហើយក្លាយទៅជាវិបត្តិសេដ្ឋកិច្ច ។ វិបត្តិនេះរាលដាលដល់ប្រទេសផ្សេងទៀត ដែលមានធនាគារជាច្រើនដែលរកទទួលទាននៅប្រទេសសៀម ដូចជាកូរ៉េ និង ជប៉ុន ជាដើម ។ វិនិយោគិនចាប់ផ្តើមដកមូលធនយ៉ាងគំហុកពីអាស៊ីអគ្នេយ៍ ធ្វើអោយវិបត្តិនេះរាលដាលដល់ប្រទេសអាស៊ីអគ្នេយ៍ទាំងអស់ ។

ក្នុងរយៈពេលកន្លងមកនេះ កម្ពុជាបានប្រកាន់យកនូវរបបអត្រាប្តូរប្រាក់ត្រឹមត្រូវ ដែលឆ្លុះបញ្ចាំងពីសភាពការណ៍ជាក់ស្តែងនៅកម្ពុជា ។ គោលបំណងនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ គឺការធ្វើស្ថិរភាវូបនីយកម្ម តាមរយៈអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ។ គោលនយោបាយនេះបាននាំមកនូវស្ថិរភាពអត្រាប្តូរប្រាក់ អត្រាអតិផរណាទាប និង ស្ថិរភាពថ្លៃក្នុងប្រទេស ។ ដែលស្តែង អត្រាអតិផរណាស្មើនឹង ០,៧% ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៣ ចំនួន ៣,៩ % ក្នុងឆ្នាំ ២០០៤ ហើយកើនឡើងដល់ ៥,៨% ក្នុងឆ្នាំ ២០០៥ ចុះមកនៅត្រឹម ៤,៧% ក្នុងឆ្នាំ ២០០៦ និង កើនឡើងដល់ ៥,៩ % ក្នុងឆ្នាំ ២០០៧ ។ ប្រាក់រៀលធ្លាក់តម្លៃជាមធ្យម ១% នៅអំឡុង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពេលបីឆ្នាំចុងក្រោយនេះ ហើយកើនតម្លៃ ១% ធៀបនឹងប្រាក់ដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ២០០៦ ។ ទិសដៅរយៈពេលវែងរបស់ធនាគារជាតិគឺបង្កើនការប្រើប្រាស់ប្រាក់រៀល និង កាត់បន្ថយកម្រិតដុល្លារូបនីយកម្ម ជាបណ្ដើរៗ ឆ្លុះបញ្ចាំងតាមសភាពការណ៍ជាក់ស្ដែងនៃកម្ពុជា ។

## ៥. កំណែទម្រង់ស្ថាប័នដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ

### ៥.១. កំណែទម្រង់វិស័យហិរញ្ញវត្ថុ

កំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេសការបង្កើតឱ្យមាន **ទីផ្សារអន្តរធនាគារ** ទីផ្សាររូបិយវត្ថុ និង ទីផ្សារមូលបត្រ ដែលជាយន្តការបើកផ្លូវឱ្យគោលនយោបាយរូបិយវត្ថុ អាចមានឥទ្ធិពលលើសកម្មភាពសេដ្ឋកិច្ច នឹងពង្រឹងភាពស័ក្ដិសិទ្ធនៃ **យន្តការបញ្ជូនរូបិយវត្ថុ** (Monetary transmission mechanism) ។ ប្រការនេះតម្រូវឱ្យមានការកសាងសមត្ថភាពយ៉ាងខ្លាំងក្លា នៅក្នុងការគ្រប់គ្រងរូបិយវត្ថុ និង ហិរញ្ញវត្ថុ ។ នៅពេលដែលសមត្ថភាពស្ថាប័នត្រូវបានកសាងរួច នោះយើងអាចកសាងជាបណ្ដើរៗនូវមូលដ្ឋានគ្រឹះ ដើម្បីផ្លាស់ប្ដូរទៅរកប្រព័ន្ធហិរញ្ញវត្ថុ ដែលយកប្រាក់រៀលជាមធ្យោបាយអន្តរការីយកម្ម ។

### ៥.២. បដិដុល្លារូបនីយកម្ម

មេរៀនជាច្រើនដែលបានរៀនពីបទពិសោធន៍អន្តរជាតិបានបង្ហាញពីជោគជ័យ និងបរាជ័យនៃគោល-នយោបាយបដិដុល្លារូបនីយកម្ម ។ នៅពេលដែលសេដ្ឋកិច្ចប្រទេសមួយមានដុល្លារូបនីយកម្មខ្ពស់ពេក គេពិបាកនឹងកាត់បន្ថយនូវឥទ្ធិពលដុល្លារូបនីយកម្ម ក្នុងសេដ្ឋកិច្ចប្រទេសនោះណាស់ ។ ការប៉ុនប៉ងខាងរដ្ឋបាល ដើម្បីចាប់បង្ខំការអនុវត្តបដិដុល្លារូបនីយកម្ម ដោយមិនកសាងទំនុកចិត្តលើរូបិយវត្ថុក្នុងស្រុកជាមុន នាំឱ្យមូលធនហូរចេញ កាត់បន្ថយអន្តរការីយកម្មហិរញ្ញវត្ថុ ហើយទីបញ្ចប់ គោលនយោបាយបដិដុល្លារូបនីយកម្មនឹងទទួលបរាជ័យតែម្ដង ។ ការអនុវត្តគោលនយោបាយបដិដុល្លារូបនីយកម្មប្រកបដោយជោគជ័យ រហូតទល់ពេលនេះ ដោយសារតែគួបផ្សំជាមួយនឹងកម្មវិធីប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយអតិផរណា ដោយកំណត់យកអត្រាប្ដូរប្រាក់បង្គោលខ្លាំង ។

លក្ខខណ្ឌចាំបាច់ដើម្បីធានាកំណើននៃការប្រើប្រាស់រូបិយប័ណ្ណជាតិ មានដូចតទៅ៖

- សន្តិភាព សុវត្ថិភាព និង ស្ថិរភាពនៃស្ថាប័ននយោបាយ និង ហិរញ្ញវត្ថុ
- ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលវែង ជាពិសេសការរក្សាការតាមដានអតិផរណា
- ទំនុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធធនាគារ គឺផ្អែកទៅលើការលើកកម្ពស់សមត្ថភាព ភាពជឿជាក់ និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពឯករាជ្យនៃវិស័យធនាគារ

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃដុល្លាររូបនីយកម្ម វិធានការគោលនយោបាយក្នុង «**យុទ្ធសាស្ត្រចតុកោណ**» និង ក្នុងគោលនយោបាយរបស់ធនាគារជាតិកម្ពុជា រួមមាន៖

១) - ការរក្សាតម្លៃលុយរៀល តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។

២) - បង្កើនប្រតិបត្តិការហិរញ្ញវត្ថុជាប្រាក់រៀលនៅក្នុងវិស័យសាធារណៈ (ការទូទាត់ថ្លៃទឹក ភ្លើង ការបង់ពន្ធ និងការបើកប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ)

៣) - បង្កើនភាពទាក់ទាញនៃប្រាក់រៀល ដោយផ្លាស់ប្តូរជាញឹកញាប់នូវក្រដាសប្រាក់ចាស់ និងងាយខូច និងបង្កើនបរិមាណប្រាក់រៀលចរាចរណ៍ឱ្យបានគ្រប់គ្រាន់ ។

សមត្ថភាពរបស់កម្ពុជានៅមានកម្រិតនៅឡើយ ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយរូបិយវត្ថុ។ ដូចនេះ ការប្តូរទៅរកប្រព័ន្ធបដិដុល្លាររូបនីយកម្មប្រញាប់ប្រញាល់ពេក នាពេលបច្ចុប្បន្ន ប្រហែលជាធ្វើមិនទាន់បានឡើយ ។ ប្រសិនបើ ស្ថានភាពរូបិយវត្ថុប្រែប្រួលឆាប់រហ័សនៅក្នុងតំបន់ ឧទាហរណ៍ដូចជាមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ី ឬ វិបត្តិធនាគារកើតឡើង កម្ពុជាមិនអាចបោះផ្សាយប្រាក់រៀល ដើម្បីជួយដល់ប្រព័ន្ធធនាគារឡើយ ដោយសារតែប្រព័ន្ធធនាគារកម្ពុជាឈរលើមូលដ្ឋាននៃប្រាក់ដុល្លារ ហើយធនាគារជាតិនៃកម្ពុជាអាចផ្តល់ឥណទានជាប្រាក់ដុល្លារ ដើម្បីជួយដល់ធនាគារពាណិជ្ជ តែក្នុងកម្រិតណាមួយតែប៉ុណ្ណោះ ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាអាចដើរតួនាទីមានកម្រិតជា **ឥណទាយិកចុងក្រោយ** ។

ទោះបីយ៉ាងណាក៏ដោយ ក្នុងរយៈពេលវែង កម្ពុជានឹងអាចធ្វើជាម្ចាស់វាសនារបស់ខ្លួនបាន ក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ដោយសារវាជាឧបករណ៍គោលនយោបាយដ៏ស័ក្តិសិទ្ធក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ។ ក៏ប៉ុន្តែ សេដ្ឋកិច្ចដុល្លាររូបនីយកម្មខ្ពស់ ឱ្យបផ្សំនឹងការបន្តធ្លាក់ចុះតម្លៃប្រាក់ដុល្លារ ធៀបនឹងរូបិយប័ណ្ណសំខាន់ៗផ្សេងទៀត កម្ពុជាងាយរងនឹងសម្ពាធអតិផរណាពីខាងក្រៅ និងខាតបង់នូវសុខមាលភាពសង្គមដោយសារតែអតិផរណា ។ តម្រូវការគន្លឹះសម្រាប់អនុវត្តនូវគោលនយោបាយបដិដុល្លាររូបនីយកម្ម គឺការបង្កើតឱ្យមានទីផ្សារមូលបត្ររដ្ឋ ។ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងអនុក្រឹត្យពាក់ព័ន្ធត្រូវបានអនុម័តរួចហើយ ។

## ៦ . អតិផរណា: មូលហេតុ និង ជម្រើសសម្រាប់ការគ្រប់គ្រងអតិផរណានៅកម្ពុជា

### *៦.១. សេចក្តីផ្តើម*

នាពេលថ្មីៗនេះ អតិផរណាបានក្លាយជាបញ្ហាប្រឈមដ៏ចំបង នៅលើវាលរាបសេដ្ឋកិច្ច និង នយោបាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៃប្រទេសកម្ពុជា និងនៅក្នុងពិភពលោក ។ កំណើនតម្លៃប្រេង និងចំណីអាហារជាបន្តបន្ទាប់តាំងពីឆ្នាំ ២០០៣ មកបានធ្វើអោយមានអតិផរណា នៅក្នុងប្រទេសមួយចំនួនក្នុងពិភពលោក ជាពិសេសប្រទេសនាំប្រេងចូល ។ ប្រភពពីរនៃអតិផរណាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នា ។ ប្រភពទីមួយ គឺអតិផរណាដែលធ្វើអោយថ្លៃដើមកើនឡើងដោយសារកំណើនថ្លៃថ្លៃប្រេង និងវត្ថុធាតុដើមកសិកម្ម ។ ម្យ៉ាងវិញទៀត ថ្លៃប្រេងខ្ពស់បានជំរុញឱ្យការអភិវឌ្ឍថាមពលជីវឥន្ធនៈក្នុងវិស័យកសិកម្ម អាចទទួលបានផលចំណេញខ្ពស់ ។ ផលិតកម្មចំណីអាហារមិនអាចប្រកួតប្រជែងលើប្រភពធនធាន និងកំពុងបាត់អាទិភាព ប្រៀបនឹងដំណាំពាណិជ្ជកម្ម ដែលរួមមានជីវឥន្ធនៈ ។ ផលិតកម្មចំណីអាហារបានធ្លាក់ចុះជាបន្តបន្ទាប់ និងធ្វើឱ្យថ្លៃចំណីអាហារកាន់តែខ្ពស់ ជាពិសេសនៅចុងឆ្នាំ ២០០៧ និងដើមឆ្នាំ ២០០៨ កន្លងទៅ ។

ក៏ប៉ុន្តែ ការកើនឡើងថ្លៃស្រូវបានបង្កើនប្រាក់ចំណូលរបស់កសិករ ។ កសិករខ្នាតតូចនៅកម្ពុជាអាចទទួលបាននូវជីវភាពរស់នៅសមស្របពីការងារស្រែចំការ ដោយសារតែថ្លៃកសិផលខ្ពស់ ជាលើកដំបូងក្នុងរយៈពេលជាច្រើនទសវត្សកន្លងមក ។ ដោយសារ ប្រជាជនកម្ពុជាជិត ៧០% រស់នៅជនបទ ហើយប្រជាជនក្រីក្រភាគច្រើនរស់នៅជនបទ និងពឹងផ្អែកលើផលិតផលកសិកម្ម កំណើនថ្លៃចំណីអាហារ អាចជួយកាត់បន្ថយអត្រានៃភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ ។ តម្លៃបន្ថែមពីកសិកម្មកើនឡើង និងទំនងជាផ្លាស់ប្តូរនិន្នាការធ្លាក់ចុះនៃចំណែកវិស័យកសិកម្មក្នុង ផ.ស.ស ។ ទោះបីយ៉ាងណាក៏ដោយ ចំណីអាហារជាធាតុមួយដ៏សំខាន់នៃប្រាក់ចំណូលរបស់អ្នកលក់ពលកម្មនៅតាមទីប្រជុំជន ។ កំណើនថ្លៃចំណីអាហារមានន័យថា ចំណូលរបស់ពួកគាត់ធ្លាក់ចុះ ។ ដូចនេះហើយកំណើនថ្លៃស្រូវអាចបង្ករការលំបាក ចំពោះអ្នករស់នៅទីប្រជុំជន ។ អ្នកធ្វើគោលនយោបាយត្រូវតែថ្លឹងថ្លែងលើផលប៉ះពាល់ផ្ទុយគ្នាទាំងពីរនេះ ស្របពេលនឹងការគ្រប់គ្រងអតិផរណា ។

## ៦.២. ក្របខ័ណ្ឌទ្រឹស្តីទូទៅ

ទ្រឹស្តីសេដ្ឋកិច្ចបានផ្តល់និយមន័យដ៏ច្រើនដល់ **អតិផរណា** ។ លោក **ឡៃនដល័រ** និង**ផាកគីន** បានឱ្យនិយមន័យអតិផរណា ថាជា «*ដំណើរកើនឡើងថ្លៃជាបន្តបន្ទាប់ ឬស្មើនឹង ដំណើរធ្លាក់ចុះតម្លៃលុយជាបន្តបន្ទាប់* » (Laindler and Parkin, 1975, page 741) ។ លោក **អាធ៉ើរ អូគុន** បានឱ្យនិយមន័យអតិផរណាថា «*ជាការកើនឡើងថ្លៃជាទូទៅ*» (Okun, 1970, page 3) ។ និយមន័យនេះទទួលស្គាល់ពីសារធាតុនៃអតិផរណាដែលជាបាតុភូត ក្នុងរយៈពេលវែង ។ លោក **មីលតុន ហ្វ្រីដមែន** បានឱ្យនិយមន័យអតិផរណាថាៈ «*ជាការកើនឡើងមិនស្រុតនិងជានិរន្តរ៍នៃកម្រិតថ្លៃទូទៅ*» ។ លោក **ហ្វ្រីដមែន** ក៏បានធ្វើការបែងចែកពីភាពខុសគ្នារវាងអតិផរណាដែលជាបាតុភូតមួយដែលកើតឡើង តិច ឬច្រើនក្នុងអត្រាមួយថេរ និង ការឡើងចុះថ្លៃដោយសារការប្រែប្រួលភ្លាមៗនៃការផ្គត់ផ្គង់ និងតម្រូវការ (Friedman, 1963, page 25) ។ សមាសធាតុដែលពាក់ព័ន្ធនឹងកំណើនថេរនៃអតិផរណានោះ នឹងបញ្ចូល និង រំពឹងគិតមុន ដែលធ្វើអោយអតិផរណានេះ មានលក្ខណៈទន់ភ្លន់ និង តិចតួចប៉ុណ្ណោះ ។ ប៉ុន្តែ អតិផរណាដែលឡើងចុះភ្លាមៗ នឹងមិនមានលក្ខណៈទន់ភ្លន់ឡើយដោយសារតែ តួអង្គសេដ្ឋកិច្ចមិនបានប្រមើលមើលជាមុនបាន ។ ដូច្នេះ អតិផរណា ទោះបីជាវាកើនឡើងដោយថេរ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឬ ដោយមិនបានគ្រោងទុកមុនក៏ដោយ នឹងធ្វើឱ្យបាត់បង់នូវអានុភាពទិញរបស់រូបិយវត្ថុ ។ ចំពោះកត្តាផលិតកម្ម ដែលមិនបានកែតម្រូវប្រាក់ចំណូលជាថ្មីនឹងការកើនឡើងនៃថ្លៃ អតិផរណានឹងបង្កឱ្យមានការខាតបង់ប្រាក់ចំណូលពិត និង សុខមាលភាពសង្គម ។ អតិផរណាត្រូវបានវាស់តាមអត្រាបម្រែបម្រួលសន្ទស្សន៍ថ្លៃ ។

### ៦.២.១. អតិផរណាសរុប (Headline Inflation)

អ្នកសេដ្ឋកិច្ចជាច្រើនបានបង្ហាញពីភាពខុសគ្នារវាង **អតិផរណាសរុប** (Headline inflation) និង **អតិផរណាស្នូល** (Core inflation) ។ **អតិផរណាសរុប** គឺជាការវាស់អតិផរណាសរុបក្នុងសេដ្ឋកិច្ច និងអតិផរណាដែលបង្កដោយការប្រែប្រួលនៃថ្លៃនៅក្នុងចំណែកទីផ្សារខុសៗគ្នា ដែលរួមបញ្ចូលក្នុងការគណនាសន្ទស្សន៍ថ្លៃដូចជាចំណីអាហារ និងថាមពល ។ អតិផរណាសរុប ជាទូទៅសំដៅទៅលើអត្រាប្រែប្រួលនៃសន្ទស្សន៍ថ្លៃប្រើប្រាស់ (CPI) ដែលជារង្វាស់តម្លៃមធ្យមនៃកន្ត្រកទំនិញ និង សេវា ដែលប្រើប្រាស់ដោយគ្រួសារជាទូទៅ។

**រូប ១៦.១- អតិផរណាសរុប និងអតិផរណាស្នូល**




*ប្រភព: មូនិធិរូបិយវត្ថុរូបិយវត្ថុអន្តរជាតិ*

រូបភាព ១៦.១ បង្ហាញថា អត្រាអតិផរណាសរុបអាចងាយនឹងប្រែប្រួលជាញឹកញាប់ ដោយសារតែបម្រែបម្រួលខ្លាំងគួរសមនៃថ្លៃប្រេង និង ចំណីអាហារ ។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណាសរុបមិនបានបង្ហាញពីគំរូនៃអតិផរណា ដែលអាចគួរឱ្យទុកចិត្តបានឡើយ ។ ដូចនេះហើយ ធនាគារកណ្តាលចូលចិត្តប្រើប្រាស់សូចនាករអតិផរណាស្នូលដែលមិនរាប់បញ្ចូល នូវសមាសធាតុដែលងាយនឹងប្រែប្រួលដូចជា ចំណីអាហារ និង ថាមពលនៅកន្ត្រកប្រើប្រាស់ នៅពេលរៀបចំរូបមន្តគោលនយោបាយរូបិយវត្ថុ ជាពិសេសក្នុងគោលបំណងគណនាអតិផរណា ។ រូបភាពទី ១៦.១ បង្ហាញពីឥរិយាបទដែលមិនងាយប្រែប្រួលនៃអតិផរណាស្នូល ក្នុងកំឡុងឆ្នាំ២០០២-២០០៨ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ៦.២.២. អតិផរណាស្នូល

*«រង្វាស់អតិផរណាស្នូលអាចជួយវាស់វែងនូវនិន្នាការទូទៅនៃអតិផរណា... ដោយសារតែវាមិនសូវប្រែប្រួលខ្លាំង ដូចអតិផរណាសរុប ។ អតិផរណាសរុបមានទំនោរប្រែប្រួលទៅរកអត្រាស្នូល ។»*

ទស្សនទានទានៃ **អតិផរណាស្នូល** (Core inflation) ជាការកើនឡើងថ្លៃសរុប ដោយមិនគិតបញ្ចូលមុខទំនិញចំណីអាហារ និង ថាមពល ដែលចាត់ទុកថាជាទំនិញងាយប្រែប្រួល គឺជាគំនិតរបស់លោក **រ៉ូប៊ើត ហ្គោដុន** នៅឆ្នាំ ១៩៧៥ ។ ដោយសារការដកចេញនូវឥទ្ធិពលបណ្តោះអាសន្ន មួយចំនួន ដែលបង្កឱ្យថ្លៃកើនឡើង ឬធ្លាក់ចុះ អតិផរណាស្នូលគឺជា សូចនាករវាស់ពីកំណើនថ្លៃទំនិញអ្នកប្រើប្រាស់ជាក់ស្តែងជាងគេ ។

**អេកស្តេន** បានឱ្យនិយមន័យអតិផរណាស្នូលថាជា «និន្នាការនៃការកើនឡើងថ្លៃដើមកត្តាផលិតកម្ម» (Eckstein, 1981, p.7) ហើយគាត់សង្កេតឃើញថា សញ្ញាណនៃអតិផរណាស្នូល «កើតដោយសារការគិតទុកអំពីអតិផរណារយៈពេលវែង របស់គេហជន និងអ្នកជំនួញ នៅពេលរៀបចំកិច្ចសន្យាដើម្បីទ្រទ្រង់ទំនាក់ទំនងរវាងថ្លៃឈ្នួល-ថ្លៃ និង នៅពេលបង់ពន្ធដារ» (ទំព័រទី ៧) ។ **អេកស្តេន** បានបែងចែករង្វាស់អតិផរណានេះ ឱ្យដាច់ពីអតិផរណាដែលកើតចេញវិបត្តិការផ្គត់ផ្គង់ និងវដ្តបន្លាស់ប្តូរតម្រូវការសរុប ។ **ឃ្វាហ** និង **វ៉ាហាយ** (Quah and Vahey, 1995, p. 1130) បានឱ្យនិយមន័យអតិផរណាស្នូលថាជា «រង្វាស់អតិផរណាដែលមិនមានផលប៉ះពាល់លើធាតុចេញពិត ក្នុងរយៈពេលមធ្យម និងវែង» ។ រង្វាស់អតិផរណាដោយមានធាតុចេញអត់ប្រែប្រួលក្នុងរយៈពេលវែង និងមធ្យម បានឆ្លុះបញ្ចាំងពីអតិផរណាដែលរំពឹងគិតទុក ។ ការឱ្យនិយមន័យរបស់ **ឃ្វាហ** និង **វ៉ាហាយ** ទៅលើអតិផរណាស្នូល រួមមាន វដ្តបម្រែបម្រួលនៃអតិផរណា ដោយសារសម្ពាធអតិរេកតម្រូវការពីព្រោះវាជាធាតុមួយនៃអតិផរណារំពឹងគិតទុកជាមុន ។ យោងតាម **ឃ្វាហ** និង **វ៉ាហាយ** អតិផរណាស្នូល ជាការរំពឹងគិតទុកជាមុន ហើយអតិផរណាផ្សេងទៀត មិនបានគិតទុកទេ ។ វិបល្លាសដែលមានឥទ្ធិពលលើអតិផរណាតែមួយឆាវ ជាទូទៅដោយសារវិបល្លាសនៃការផ្គត់ផ្គង់ គឺស្ថិតនៅខាងក្រៅនិយមន័យ **អតិផរណាស្នូល** ។

នៅពេលដែលអ្នកប្រើប្រាស់ វិនិយោគគិន និយោជិក និង កម្មករ គិតថានឹងមានអតិផរណា ថ្លៃទំនិញ និង សេវាទាំងអស់ព្រមទាំងប្រាក់ឈ្នួលនឹងកើនឡើង ក្នុងអត្រាដូចគ្នានឹងអតិផរណាដែរ ។ អតិផរណាកើតត្រឹមត្រូវតាមការរំពឹងគិតទុកបែបនេះ នឹងមិនប៉ះពាល់ដល់ចំណាយរស់នៅ ថ្លៃប្រៀបធៀប (Relative Price) និងធាតុចេញទេ ។ ដូចនេះហើយ បើថ្លៃមានភាពបត់បែន អតិផរណារំពឹងគិតទុកនឹងមិនប៉ះពាល់ដល់ធាតុចេញឡើយ ។ ប៉ុន្តែជាក់ស្តែង ថ្លៃកំណត់ដោយកិច្ចសន្យា ដែលអនុញ្ញាតអោយផ្លាស់ប្តូរការរំពឹងគិតទុកបាន ក្នុងរយៈពេលមួយក្រោយ ។ ដូចនេះហើយ អតិផរណារំពឹងគិតទុកមុនអាចមានឥទ្ធិពលលើធាតុចេញ ក្នុងរយៈពេលខ្លី ។ ក៏ប៉ុន្តែក្នុងរយៈពេលវែង ការគិតទុកមុននឹងក្លាយជាការពិត សមតាដំបូងនៃធាតុចេញ និង ថ្លៃប្រៀបធៀប នឹងត្រលប់មករកចំណុចដើមវិញ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ផ្ទុយមកវិញ ក្នុងករណីអតិផរណាមិនបានគិតទុកមុន នៅពេលអតិផរណាជាក់ស្តែងខុសពីអត្រាគិតទុក ថ្លៃដើមសេដ្ឋកិច្ចនឹងកើតឡើង ដោយសារមានការបែងចែកនៃប្រាក់ចំណូល និង ទ្រព្យសម្បត្តិឡើងវិញ ។ អ្នកដែលទទួលបាននូវការទូទាត់ពីកត្តាផលិតកម្ម លើសពីការគិតទុកមុននឹងទទួលបានផលចំណេញ ។ រីឯអ្នកដែលទទួលបានតិចជាងការរំពឹងគិតទុកមុន នឹងខាតបង់ ។ ប្រការនេះនឹងនាំទៅដល់ការកែតម្រូវការផ្គត់ផ្គង់ និងផ្លាស់ប្តូរធាតុចេញ ។ ដូចនេះហើយ អតិផរណាស្នូលមិនប៉ះពាល់ដល់ធាតុចេញ ក្នុងរយៈពេលវែងទេ ។ ក៏ប៉ុន្តែ អតិផរណាសរុប ឬអតិផរណាមិនបានគិតទុកមុន ធ្វើឱ្យប៉ះពាល់ដល់ធាតុចេញ ជាអចិន្ត្រៃយ៍ ។

ទោះបីជា ថ្លៃប្រៀបធៀបប្រែប្រួលបណ្តោះអាសន្នជាធម្មតា (ឧទា. ឥទ្ធិពលតាមរដូវកាលនៃថ្លៃចំណីអាហារ) ឬ ជាប្រែប្រួលអចិន្ត្រៃយ៍ (ឧទា. ដោយសារការប្រែប្រួលបច្ចេកវិទ្យា) លុះត្រាតែមានការឆ្លើយតបផ្នែករូបិយវត្ថុ នោះទើបការកើនឡើងនៃថ្លៃប្រៀបធៀបនឹងត្រូវកាត់កងជាមួយនឹងការធ្លាក់ចុះនៃថ្លៃប្រៀបធៀបផ្សេងទៀត ដែលធ្វើអោយវាមិនប៉ះពាល់ដល់កម្រិតថ្លៃសរុបឡើយ ។ អតិផរណាស្នូល អាចចាត់ទុកបានថា ជាអតិផរណាទូទៅ ដែលរួមមាន អតិផរណាគិតទុក និងកំណើនរូបិយវត្ថុ បូកបន្ថែមនឹងធាតុមួយទៀតដែលពាក់ព័ន្ធនឹងការប្រែប្រួលជាអចិន្ត្រៃយ៍នៃថ្លៃប្រៀបធៀប ។ ប្រសិនបើ ការកើនឡើងនៃថ្លៃប្រៀបធៀបមិនបានកាត់កង ដោយការធ្លាក់ចុះនៃថ្លៃប្រៀបធៀបផ្សេងទៀតទេ នោះចំណុចនេះត្រូវតែឆ្លុះបញ្ចាំងពីអតិផរណាស្នូល ដែលជាអតិផរណាពិតប្រាកដ ។

### ៦.២.៣. ប្រភេទនៃអតិផរណា

មានទ្រឹស្តីសេដ្ឋកិច្ចជាច្រើនបានចោទសួរពីមូលហេតុបង្កឱ្យមានអតិផរណា និងឥទ្ធិពលរបស់វាលើសេដ្ឋកិច្ច និងសុខមាលភាពសាធារណៈ ។ ទ្រឹស្តី **កេនសន៍និយម** យល់ឃើញថា អតិផរណាគឺជាលទ្ធផលនៃការកែតម្រូវទីផ្សារ ពេលតម្រូវការសរុប ឬការផ្គត់ផ្គង់សរុប ឬកត្តាទាំងពីរប្រែប្រួល និង ជាការឆ្លើយតបទៅនឹងសម្ពាធលើសេដ្ឋកិច្ចពិត (Real economy) ។ គំនិតគោលនៃការវិភាគរបស់ **ពួកកេនសន៍និយម** គឺជាការប្រទាញប្រទង់គ្នារវាង **អតិផរណា និង និកម្មភាព** ដែលហៅថា **ខ្សែកោងហ្វីលីព** ។ គំរូនេះបង្ហាញថា មានការប្រទាញប្រទង់គ្នារវាងអតិផរណា និង និកម្មភាព ។ កម្រិតនិកម្មភាពទាប ទាក់ទងនឹងអតិផរណាកម្រិតខ្ពស់ ។ ដូចនេះ អត្រាអតិផរណាក្នុងអត្រាណាមួយ ដែលធ្វើឱ្យមាននិកម្មភាពទាបបំផុត ចាត់ទុកការប្រសើរហើយ ។ គំនិតរបស់ **ពួកកេនស៍និយម** មួយទៀត គឺ ធាតុចេញសក្តានុពល ជាកម្រិត ផ.ស.ស ខ្ពស់បំផុតនៃផលិតកម្មក្នុងលក្ខខណ្ឌនៃកំហិតសេដ្ឋកិច្ច និងស្ថាប័ន ។ កម្រិតនៃធាតុចេញនេះស្ថិតនៅត្រង់ ចំណុចនៃ **និកម្មភាពដោយគ្មានកំណើនអតិផរណា** (Non-Accelerating Inflation Rate of Unemployment--NAIRU) ឬ **អត្រានិកម្មភាពធម្មជាតិ** (Natural Unemployment) ឬ **អត្រានិកម្មភាពពេញលេញ** (Full-employed Unemployment) ។ ប្រសិនបើ ផ.ស.ស លើសតម្លៃសក្តានុពល (ហើយអត្រានិកម្មភាពនៅក្រោមអត្រា NAIRU) ទ្រឹស្តីបាននិយាយថា អតិផរណានឹងច្រាលឡើង ដោយសារអ្នកផ្គត់ផ្គង់បង្កើនថ្លៃ ។ ប្រសិនបើ ផ.ស.ស នៅក្រោមកម្រិតសក្តានុពល (ហើយអត្រានិកម្មភាពលើសអត្រា NAIRU) អតិផរណានឹងច្រាលចុះ ដោយសារ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អ្នកផ្គត់ផ្គង់កាត់បន្ថយថ្លៃ ដើម្បីបំពេញសមត្ថភាពផលិតភាពដែលលើស ។ ក្នុងភាពជាក់ស្តែង ការប៉ាន់ស្មានអត្រា NAIRU សម្រាប់រៀបចំធ្វើគោលនយោបាយ មានការលំបាក ។

**អ្នករូបិយវត្ថុនិយម** យល់ឃើញថា: «**អតិផរណាជានិច្ចជាកាល និង នៅគ្រប់ទីកន្លែងទាំងអស់ គឺជា បាតុភូតរូបិយវត្ថុ**» ។ ទ្រឹស្តីបរិមាណរូបិយវត្ថុបាននិយាយថា ចំណាយសរុបនៅក្នុងសេដ្ឋកិច្ចកំណត់ដោយបរិមាណរូបិយវត្ថុចរាចរនៅក្នុងសេដ្ឋកិច្ច ។ ពួកគេធ្វើការប៉ាន់ស្មានថា បរិមាណរូបិយវត្ថុកើនឡើង ធ្វើឱ្យចំណាយសរុបកើនឡើង និងធ្វើឱ្យតម្រូវការសរុបទំនិញប្រើប្រាស់កើនឡើងដែរ ។ ដោយហេតុផលនេះហើយ អ្នករូបិយវត្ថុនិយមយល់ឃើញថា បុព្វហេតុនៃការកើនឡើងថ្លៃក្នុងសេដ្ឋកិច្ចកំពុងងើបឡើង (មានន័យថា ការផ្គត់ផ្គង់ទំនិញប្រើប្រាស់សរុបកំពុងកើន) គឺជាការកើនឡើងបរិមាណរូបិយវត្ថុនៅក្នុងចរាចរណ៍ ដែល ជាមុខងារមួយនៃគោលនយោបាយរូបិយវត្ថុ ។ ដូចនេះ ដោយការគ្រប់គ្រងកំណើនការផ្គត់ផ្គង់រូបិយវត្ថុ អាចគ្រប់គ្រងអតិផរណាបានដូចគ្នា ។

តាមទ្រឹស្តី **ការរំពឹងគិតជាមុនប្រកបដោយវិចារណញ្ញាណ** (Rational expectation) យល់ឃើញថា តួអង្គសេដ្ឋកិច្ចពិចារណាប្រមើលមើលជាស្រេចប្រកបដោយវិចារណញ្ញាណពីអនាគត ដោយព្យាយាមបង្កើនជាអតិបរមានូវសុខមាលភាពរបស់ខ្លួន ហើយមិនមានប្រតិកម្មតបភ្លាមៗ ទៅនឹងថ្លៃឱកាស និងសម្ពាធឡើយ ។ ចរិតថ្លៃពីអតីតកាលជាព្យាករណ៍ដ៏ល្អ សម្រាប់អតិផរណានៅអនាគត ។ ស្នូល នៃទ្រឹស្តី**ការរំពឹងគិតជាមុនប្រកបដោយវិចារណញ្ញាណ** គឺថា តួអង្គសេដ្ឋកិច្ចព្យាយាមបន្ថយឥទ្ធិពលនៃអន្តរាគមន៍របស់ធនាគារកណ្តាល ដោយធ្វើសកម្មភាពគ្រប់បែបយ៉ាង ដើម្បីឱ្យការព្យាករណ៍ថាអតិផរណាខ្ពស់ កើតមានឡើង ។ ប្រសិនបើ **ការរំពឹងគិតជាមុន** ពីអតិផរណាវិជ្ជមាន តួអង្គសេដ្ឋកិច្ចគិតស្រេចថា ការបន្តឹងគោលនយោបាយរូបិយវត្ថុក្នុងពេលអនាគត នឹងបង្កើនចំណាយចរន្ត ដែលនឹងធ្វើឱ្យការគិតទុកនោះក្លាយជាការពិត ។ ប្រការនេះមានន័យថា ធនាគារកណ្តាលត្រូវ ទប់ទល់នឹងអតិផរណា ដោយលើកទឹកចិត្តឱ្យតួអង្គសេដ្ឋកិច្ចមានជំនឿថា សេដ្ឋកិច្ចនឹងបន្តកើនឡើង ហើយធនាគារកណ្តាលនឹងបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ ជាជាងកាត់បន្ថយកំណើនសេដ្ឋកិច្ច ។

សរុបមក អតិផរណាកើតឡើងនៅពេលដែលបរិមាណតម្រូវការទំនិញសរុប នៅត្រង់កម្រិតថ្លៃណាមួយកើនឡើងលឿនជាងបរិមាណផ្គត់ផ្គង់សរុបនៅត្រង់កម្រិតថ្លៃនោះ (Abel, Bernanke et al.) ។ ក្នុងចំណោមប្រភពនៃអតិផរណាគឺមាន ការកើនឡើងនៃការប្រើប្រាស់ ឬចំណាយវិនិយោគ គោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក និង ការផ្លាស់ប្តូរខ្លាំងនៃការផ្គត់ផ្គង់ ។ ក៏ប៉ុន្តែ អត្រាកំណើនរូបិយវត្ថុខ្ពស់ គឺជាប្រភពដ៏សំខាន់នៃអតិផរណា ។

អតិផរណាចែកចេញជាបីប្រភេទធំៗ គឺ៖

**អតិផរណាបណ្តាលមកពីកំណើនតម្រូវការ** : ជាអតិផរណាដែលបណ្តាលមកពីការកើនឡើងនៃ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តម្រូវការសរុប ដោយសារការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង ហើយផ្នែកឯកជន និងរដ្ឋបង្កើនចំណាយរបស់ខ្លួន ។ ការកើនឡើងនៃតម្រូវការទំនិញ និងសេវាកម្មទាំងអស់ (ឬហៅថាតម្រូវការសរុប) គឺជាកត្តាដែល «ទាញ» តម្លៃទំនិញ និងសេវាកម្មសព្វសារពើអោយឡើងថ្លៃ ជាពិសេសនៅពេលដែលចំនួនផ្គត់ផ្គង់សរុប មិនអាចកើនឡើងបានដោយសារសមត្ថភាពផ្គត់ផ្គង់នៅមានកម្រិត ។ ចំណុចសំខាន់នៃទ្រឹស្តីអតិផរណា ដែលបណ្តាលមកពីកំណើនតម្រូវការ គឺផ្តោតទៅលើការផ្គត់ផ្គង់រូបិយវត្ថុ ពោលគឺ អតិផរណាបណ្តាលមកពីចំនួនរូបិយវត្ថុធ្វើចរាចរលើទីផ្សារកើនឡើង ធៀបនឹងសមត្ថភាពផ្គត់ផ្គង់សរុបរបស់សេដ្ឋកិច្ច (ធាតុចេញសក្តានុពល)។ ចំណុចនេះអាចមើលឃើញច្បាស់ នៅពេលរដ្ឋាភិបាលផ្តល់នូវហិរញ្ញប្បទានដល់ការចំណាយមិនគ្រោងទុក និងចំណាយក្រៅថវិកាដែលពាក់ព័ន្ធនឹងការការពារវិបត្តិ ការផ្តល់កម្ចីលើសលប់ពីសំណាក់ធនាគារកណ្តាល នាំឱ្យមានមហាអតិផរណា ។ មូលហេតុមួយទៀត គឺការធ្លាក់ចុះតម្រូវការរូបិយវត្ថុខ្លាំង បង្ករឱ្យល្បឿនចរាចរណ៍រូបិយវត្ថុកើនឡើង ។ ក៏ប៉ុន្តែក្នុងរយៈកាលប៉ុន្មានទសវត្សថ្មីៗនេះ អតិផរណាមាននិន្នាការកើនឡើង ក្នុងកំឡុងពេលដែលកំណើនសេដ្ឋកិច្ចធ្លាក់ចុះ។ បាតុភូតនេះត្រូវ បានគេហៅថា **បរិត្តផរណា** (Stagflation)។

**អតិផរណាបណ្តាលមកពីកំណើនថ្លៃដើម ឬ អតិផរណាបណ្តាលមកពីវិបត្តិផ្គត់ផ្គង់**: ជាអតិផរណាដែលបណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងនៃបរិមាណផ្គត់ផ្គង់សរុប ដោយសារតម្លៃធាតុចូលសំរាប់ផលិតកម្មកើនឡើង ។ កត្តាជំរុញថ្លៃដើមមួយចំនួន ដូចជាប្រេង ស្បៀង ឬថ្លៃឈ្នួលអាចបង្កើនក៏រិតតម្លៃទំនិញទូទៅ ។ ផលិតករដែលត្រូវបង់ថ្លៃដើមនៃធាតុចូលខ្ពស់ នឹងបញ្ជូនបន្ទុកនេះបន្តទៅអោយអតិថិជន ដោយវិធីបង្កើនតម្លៃធាតុចេញ ឬទំនិញលើទីផ្សារ ។

**អតិផរណាវដ្តសង្សារ (Built-in inflation)**: គឺបណ្តាលមកពីការរំពឹងគិតទៅពេលអនាគតដោយផ្អែកលើស្ថានភាពបច្ចុប្បន្ន (Adaptive expectation) ដោយភាគច្រើនគឺផ្សារភ្ជាប់នឹង «**វដ្តសង្សារនៃដំណើរប្រតិសកម្ម ទៅវិញទៅមក រវាងថ្លៃទំនិញ និង ប្រាក់បៀវត្ស**» ។ ដោយសារអតិផរណាកើនឡើងជាប្រចាំ និយោជិកទាមទារតម្លើងប្រាក់បៀវត្សរបស់ខ្លួន ដើម្បីទប់ទល់នឹងថ្លៃទំនិញ ដែលចេះតែកើនឡើងឥតឈប់ឈរ (ដោយប្រាក់បៀវត្សជុល ត្រូវតែកើនលើសសន្ទស្សន៍ថ្លៃទំនិញ ដើម្បីធ្វើអោយ ប្រាក់បៀវត្សសុទ្ធមានកម្រិតសមស្រប ជាមួយនឹងសន្ទស្សន៍ថ្លៃទំនិញបន្ទាប់ពីដកពន្ធចេញ) ហើយនិយោជកបញ្ចូលការឡើងប្រាក់បៀវត្សនេះ ទៅក្នុងថ្លៃដើមទំនិញ ពោលគឺបញ្ជូនការឡើងថ្លៃប្រាក់បៀវត្សទៅអោយអតិថិជន តាមរយៈវិធីតម្លើងថ្លៃទំនិញដែលជាផ្នែកមួយនៃវដ្តសង្សារនៃដំណើរការប្រតិសកម្មបន្ថែមគ្នាទៅវិញទៅមក រវាងអតិផរណា និង ប្រាក់បៀវត្ស ។ អតិផរណាវដ្តសង្សារបង្ហាញពីព្រឹត្តិការណ៍ក្នុងអតីតកាល ដូចនេះគេអាចចាត់ទុកវាជាអតិផរណា ដែលវិលចុះវិលឡើង ។

### ៦.២.៤. ផលប៉ះពាល់នៃអតិផរណា

អ្នកសេដ្ឋកិច្ចភាគច្រើនពិនិត្យឃើញថាអតិផរណាជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ហើយជាញឹកញាប់គេហៅថាជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«**ពន្ធអតិផរណា**» ។ អតិផរណាកាត់បន្ថយអំណាចទិញនៃរូបិយវត្ថុ ដែលមានក្នុងដៃវិស័យឯកជន ដោយធៀបដូច ពន្ធលើទ្រព្យសម្បត្តិ ។ ពន្ធនេះជាចំណាយសេដ្ឋកិច្ច ឬ «កំហាតប្រសិទ្ធភាព» នៅក្នុងសេដ្ឋកិច្ច ដោយបង្អាក់ទឹកចិត្តប្រជាជន និងអាជីវករមិនឱ្យរក្សាទុកសាច់ប្រាក់ ដែលគេហៅថា «**កំហាតសុខមាលភាពដោយសារអតិផរណា** » (Welfare Cost of Inflation) ។

អតិផរណាមានផលប៉ះពាល់ទាំងលើផ្នែកចំណាយ និងចំណូលថវិការរដ្ឋ ។ ខាងផ្នែកចំណូល ពន្ធលើប្រាក់បៀវត្សរ៍ ពន្ធលើប្រាក់ចំណេញ និង ពន្ធលើប្រាក់ចំណេញមូលធន ដែលមានអត្រាពន្ធអនុវឌ្ឍន៍ (Progressive Rate) នឹង ផ្ទេរបន្ទុកពន្ធពីក្រុមមានប្រាក់ចំណូលទាប ទៅក្រុមមានប្រាក់ចំណូលខ្ពស់ ។ ក៏ប៉ុន្តែ ពន្ធខ្ពស់ដែលយកពីប្រាក់បៀវត្សរ៍ និងមូលធន ដោយសារអតិផរណា នឹងកាត់បន្ថយសកម្មភាពផលិតកម្ម ដោយការផ្ទេរធនធាន ទៅលើមុខទំនិញណាដែលមិនជាប់ពន្ធ ។ ប្រការនេះមិនមែនជាស្ថានភាពល្អសម្រាប់ហិរញ្ញវត្ថុសាធារណៈឡើយ ។

ក្នុងបរិយាកាសអតិផរណាខ្ពស់ ជាទូទៅរដ្ឋាភិបាលតម្រូវឱ្យអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈបង្រួម ឬ តឹងរឹង ដើម្បីគ្រប់គ្រងអតិផរណា ។ ប្រសិនបើ ភាពយឺតនៃចំណូល ខ្ពស់ជាង ភាពយឺតនៃចំណាយថវិកានឹងមិនមានបញ្ហាឡើយ ។ ប្រសិនបើផ្ទុយទៅវិញ ថវិការរដ្ឋនឹងជួបប្រទះនឹងបញ្ហាកង្វះខាតសាច់ប្រាក់ ។ ក្នុងស្ថានភាពនេះ រដ្ឋាភិបាលអាចជ្រើសរើសដើម្បីរក្សាចំណាយអោយនៅដដែល ។ ក៏ប៉ុន្តែ ទង្វើបែបនេះនឹងធ្វើឱ្យមានអតិផរណា ។

ជាទូទៅអត្រាអតិផរណាខ្ពស់ និងមិនអាចព្យាករណ៍បានជារឿងមិនល្អទេ ដូចជា ÷

- ភាពមិនប្រាកដអំពីអតិផរណានៅអនាគត អាចនឹងបង្អាក់ទឹកចិត្តដល់ការវិនិយោគ និងសញ្ច័យ ។
- អតិផរណា បានបែងចែកប្រាក់ចំណូលឡើងវិញ ពីអ្នកដែលមានប្រាក់ចំណូលថេរ មានដូចជា អ្នកចូលនិវត្តន៍ ដោយផ្ទេរប្រាក់ចំណូលទៅឱ្យអ្នកដែលមានប្រាក់ចំណូលប្រែប្រួល មានដូចជា ប្រាក់ឈ្នួល និងប្រាក់ចំណេញ ដែលមានការកែតម្រូវតាមអតិផរណា ។
- កូនបំណុលអាចសម្រាលបន្ទុកបំណុល ដោយសារអតិផរណាអាចកាត់បន្ថយតម្លៃពិត ។
- អតិផរណា បែងចែកទ្រព្យពីម្ចាស់បំណុល ទៅអោយកូនបំណុល ។ ឧទាហរណ៍ ជាធម្មតា រដ្ឋាភិបាលគឺជាកូនបំណុលសុទ្ធ អតិផរណានឹងកាត់បន្ថយបំណុលនេះ ដោយបែងចែកទ្រព្យវិញ ជាប្រយោជន៍របស់រដ្ឋាភិបាល ។
- ក្នុងរបបអត្រាប្តូរប្រាក់ថេរ អតិផរណាក្នុងស្រុកខ្ពស់ធៀបជាងអតិផរណាអន្តរជាតិ នឹងមិនលើកទឹកចិត្តដល់ការនាំចេញ និង លើកទឹកចិត្តដល់ការនាំចូល ។
- អតិផរណាកាត់បន្ថយតម្រូវការរូបិយវត្ថុ និង បង្អាក់ទឹកចិត្តក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ក្រុមហ៊ុនត្រូវផ្លាស់ប្តូរថ្លៃទំនិញកាន់តែញឹកញាប់ជាងមុន ធ្វើឱ្យចំណាយចម្លងការកាន់ខ្ពស់ និង ថ្លៃកាន់តែថ្លៃ ។

- ក្រុមហ៊ុនដែលមិនកែប្រែតម្លៃ មានថ្លៃទាបធៀបនឹងក្រុមហ៊ុនដែលបានកែប្រែ ដែលនាំឱ្យមាន **វិរូបកម្ម** (Distortion) សេដ្ឋកិច្ច ដោយសារតែថ្លៃប្រៀបធៀបមិនបានឆ្លុះបញ្ចាំងពី ភាពកម្រនៃទំនិញ និងសេវាក្នុងសេដ្ឋកិច្ចឡើយ ។

- ការកើនឡើងអតិផរណាបង្កើតឱ្យមាន **វដ្តសង្សារនៃកំណើនថ្លៃនិងប្រាក់ឈ្នួល** ដែលពិបាកនឹងបំបែក។

- ប្រសិនបើមហាអតិផរណាកើតមាន យន្តការសេដ្ឋកិច្ចទាំងមូលនឹងច្របូកច្របល់ ដោយនាំគ្នាផ្លាស់ប្តូរលែងកាន់ទ្រព្យរូបិយវត្ថុ ទៅជាកាន់ទ្រព្យរូបវន្តវិញ ។

គោលដៅអតិផរណាស្មើសូន្យ អាចជាទណ្ឌកម្មមួយចំពោះវិស័យសេដ្ឋកិច្ចណាដែលថ្លៃឡើងមិនចុះ ។ វិស័យទាំងនោះនឹងទទួលបន្ទុកដោយសារការកើនឡើងនៃថ្លៃក្នុងវិស័យផ្សេងទៀត ក្នុងគោលបំណងធ្វើឱ្យក្លាយជាកាពិតនូវទិសដៅអតិផរណាសូន្យ ។ ថ្លៃប្រៀបធៀបនឹងប្តូរខុសពីថ្លៃប្រៀបធៀបពីមុន ក្នុងសេណារីយ៉ូនេះ ។ ប្រសិនបើថ្លៃទូទៅកើនឡើងស្បឹតៗ វានឹងធ្វើឱ្យកាន់តែមានភាពងាយស្រួល ដើម្បីអោយថ្លៃប្រៀបធៀបអាចកែតម្រូវយ៉ាងរលូន ។ ម្យ៉ាងវិញទៀត កិច្ចខំប្រឹងប្រែងដើម្បីរក្សាអតិផរណាសូន្យ អាចឈានដល់ **បរិត្តផរណា** ។

ក្នុងស្ថានភាពនៃការរំពឹងទុកអតិផរណាវិជ្ជមាន អ្នកប្រើប្រាស់ និងអ្នកជំនួញអាចជ្រើសរើសដោយធ្វើការទិញ ឱ្យបានលឿនជាងធម្មតា ។ ឥទ្ធិពលនេះមាននិន្នាការរក្សាសកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី ដោយការលើកទឹកចិត្តដល់ចំណាយ និងការផ្តល់កម្ចី ហើយក្នុងរយៈពេលវែង លើកទឹកចិត្តដល់ការវិនិយោគ ។ ក៏ប៉ុន្តែអតិផរណាក៏អាចកាត់បន្ថយការលើកទឹកចិត្តក្នុងសញ្ច័យផងដែរ ។ សរុបមក ផលប៉ះពាល់នៃអតិផរណាលើការបង្កើតមូលធនសរុបក្នុង រយៈពេលវែង គឺមិនច្បាស់លាស់ទេ ។

អតិផរណាក៏បានផ្តល់ការលើកទឹកចិត្តដល់អ្នកទាំងឡាយដែលមានសញ្ច័យ ដើម្បីធ្វើការវិនិយោគដោយវាគ្រាន់បើជាងរក្សាមូលនិធិអោយនៅទំនេរ ។ ប្រសិនបើ មិនបានយកសញ្ច័យទៅធ្វើការវិនិយោគក្នុងឧបករណ៍ដែលផ្តល់នូវអត្រាចំណេញពិតវិជ្ជមាន អំណាចទិញនៃសញ្ច័យនឹងត្រូវកាត់បន្ថយដោយសារអតិផរណា ។ អតិផរណាបានលើកទឹកចិត្តដល់អ្នកវិនិយោគ ជ្រើសរើសយកហានិភ័យជាប្រព័ន្ធ ដើម្បីអោយអត្រាចំណេញពីការវិនិយោគ ស្ថិតនៅខ្ពស់ជាងអតិផរណារំពឹងទុក ។

អតិផរណាក៏បានផ្តល់ឱ្យធានាគារកណ្តាល នូវជម្រើសមួយចំនួនក្នុងការគ្រប់គ្រងសេដ្ឋកិច្ច ដោយសារឧបរណ៍ដ៏ចំបងសម្រាប់ធ្វើការត្រួតពិនិត្យលើការផ្គត់ផ្គង់រូបិយវត្ថុ និង ល្បឿនចរាចររូបិយវត្ថុ គឺជាអត្រាអប្បហារដែលធនាគារពាណិជ្ជអាចខ្ចីពីធនាគារកណ្តាល ។ អត្រាអប្បហារនេះ ត្រូវតែខ្ពស់ជាងអត្រាអតិផរណា ដោយសារគេមិនដែលអោយឥណទានខ្ចី ដោយយកការប្រាក់ ទាបជាងអត្រាអតិផរណាឡើយ ។ អត្រាអតិផរណាវិជ្ជមាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នឹងអាចឱ្យធនាគារកណ្តាល ប្រើប្រាស់នូវអត្រាអប្បហារ ក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

## ៦.៣. រង្វាស់អតិផរណា

អតិផរណាអាចវាស់បាន ដោយគណនាបម្រែបម្រួលជាភាគរយនៃសន្ទស្សន៍ថ្លៃ ក្នុងរយៈពេលមួយច្បាស់លាស់ ។ សន្ទស្សន៍ផ្សេងៗគ្នាជាច្រើនសម្រាប់វាស់បម្រែបម្រួលថ្លៃ ដែលប៉ះពាល់ដល់ក្រុមផ្សេងៗគ្នារបស់សង្គម ។ **សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់** (Consumer Price Index--CPI) **បរិត្តផរណា** ផ.ស.ស (GDP Deflator) **សន្ទស្សន៍ថ្លៃផលិតករ** (Producer Price Index--PPI) និង **សន្ទស្សន៍ថ្លៃវត្ថុធាតុដើម** (Commodity Price Indices) គឺជាសន្ទស្សន៍ថ្លៃដែលប្រើប្រាស់ញឹកញាប់ជាងគេ ។ បរិត្តផរណា ផ.ស.ស និង **CPI** គឺជារង្វាស់អតិផរណាដែលគេប្រើប្រាស់ច្រើនជាងគេ ។ បរិត្តផរណា ផ.ស.ស គឺជាសូចនាករគ្រប់ជ្រុងជ្រោយជាងគេសម្រាប់វាស់អតិផរណា ដោយសារតែគិតបញ្ចូលមុខទំនិញទាំងអស់នៃ ផ.ស.ស ។ ទោះបីយ៉ាងណាក៏ដោយ ចំពោះគោលបំណងនៃគោលនយោបាយគេប្រើ **សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់** (CPI) ជាសូចនាករណ៍ដើម្បីវាស់អតិផរណា ពីព្រោះវាមានបញ្ចូលនូវមុខទំនិញ និងសេវាតូចៗជា ច្រើនដែលមានឥទ្ធិពលដោយផ្ទាល់លើជីវភាពរស់នៅរបស់សាធារណៈ ដូចនេះ គេងាយយល់ពីឥទ្ធិពលវា ។ ក្នុងប្រទេសកម្ពុជា **CPI** រួមមានទាំងទំនិញ និងសេវាប្រើប្រាស់ដែលកំណត់ចេញពីការសង្កេតសេដ្ឋកិច្ចសង្គមទូទាំងប្រទេស ដែលរៀបចំធ្វើជារៀងរាល់បួនទៅប្រាំឆ្នាំ ដោយវិទ្យាស្ថានជាតិស្ថិតិ (NIS)។

### ៦.៣.១. សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់ (CPI)

**សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់** គឺជាចំនួនសន្ទស្សន៍ដែលវាស់ពីកម្រិតថ្លៃជាមធ្យមនៃទំនិញ និង សេវារបស់អ្នកប្រើប្រាស់ដែលទិញដោយគេហកិច្ច ។ អតិផរណាត្រូវបានវាស់ដោយការបម្រែបម្រួលនៃ **CPI** ដូចដែលបានផ្តល់ក្នុងតារាង ១៦.១ ។

**CPI** ត្រូវបានបង្កើតឡើងដោយការប្រើប្រាស់នូវដំណើរការបី ដែលនីមួយៗមានការទាក់ទងនឹងការកំណត់ថ្លៃខុសគ្នាតិចតួចដូចជា ដំណើរការផ្អែកលើការប្រើប្រាស់ ដំណើរការនៃចំណាយផ្អែកទៅលើចំណាយគ្រួសារ និង ដំណើរការចំណាយដែលផ្អែកលើការទទួលរបស់គ្រួសារ ។ ចំពោះទំនិញ និងសេវាភាគច្រើនដែលមាននូវក្នុង **CPI** ការទទួលបាន ចំណាយ និងការប្រើប្រាស់របស់គ្រួសារ សឹងតែធ្វើឡើងនៅពេលជាមួយគ្នា ។ ដូចនេះ ជាក់ស្តែងភាពខុសគ្នា ក្នុងអភិក្រមនេះ មានតិតតួចបំផុត ។

| តារាង ១៦.១- សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់នៅកម្ពុជា | | | | | |
|---|---|---|---|---|---|
| **សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់** | **ទម្ងន់** | **២០០៣** | **២០០៤** | **២០០៥** | **២០០៦** |
| **គ្រប់ទំនិញ និងសេវា** | ១០០,០ | ១,២% | ៣,៩% | ៥,៨% | ៤,៧% |
| ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ | ៤៦,៤ | ១,៥% | ៦,៤% | ៨,៦% | ៦,៤% |
| សំលៀកបំពាក់ និងស្បែកជើង | ៣,០ | -២,១% | -០,៩% | ៣,៧% | ៣,៩% |
| ការស្នាក់នៅ និងការប្រើប្រាស់ទឹកភ្លើង | ២២,៩ | -០,១% | ១,៣% | ២,៩% | ២,៥% |
| គ្រឿងសង្ហារឹម និង HH operation | ២,៧ | -០,១% | -០,៧% | -០,៦% | ២,១% |
| ការថែរក្សាសុខភាព | ៥,១ | -១,៨% | -០,៩% | ០,០% | ១,៣% |
| ការដឹកជញ្ជូន និងការទំនាក់ទំនង | ១៣,៤ | ៤,៩% | ៩,៧% | ១១,៤% | ៩,១% |
| ការស្តារឡើងវិញ និង ការអប់រំ | ៤,១ | -០,៧% | ០,៦% | ០,៨% | ១,១% |
| ការថែរក្សាសុខភាពផ្ទាល់ខ្លួន | ២,៣ | ០,១% | ១,៩% | ៣,០% | ៤,៩% |

*ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ (ឆ្នាំគោលស្មើ ១០០)*

ទិន្នន័យពីរចាំបាច់ណាស់ដើម្បីគណនា **CPI** គឺ ទិន្នន័យថ្លៃ និងតារាងទម្ងន់ ។ ទិន្នន័យថ្លៃត្រូវបានប្រមូលតាមគំរូនៃទំនិញ និងសេវា ដែលប្រមូលពីគំរូនៃចំណាយលើការលក់ នៅតាមទីកន្លែងគំរូ និងពេលគំរូ ។ ឆ្នាំគោលត្រូវបានជ្រើសរើសដើម្បីបង្កើតនូវសេរីចំនួនសន្ទស្សន៍ ។ ទម្ងន់ជាច្រើនត្រូវបានប្រើប្រាស់សម្រាប់ធ្វើការសរុបចូលគ្នានូវថ្លៃឱ្យទៅជាសន្ទស្សន៍ ដែលបានជ្រើសរើសជាឆ្នាំគោល ។

ក្នុងប្រទេសកម្ពុជា ទម្ងន់ទាំងនេះផ្អែកទៅលើទិន្នន័យចំណាយដែលទទួលបានពីគំរូថវិកាចំណាយរបស់គេហកិច្ចនៅក្នុង **អង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា** ។ សន្ទស្សន៍នេះត្រូវបានគណនាប្រចាំខែ ដោយ **វិទ្យាស្ថានជាតិស្ថិតិ** ជាមធ្យមទម្ងន់ នៃសន្ទស្សន៍រងសម្រាប់សមាសធាតុផ្សេងៗ ដូចជា (ទី១)- ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ (៤៦,៤%) (ទី២)- សំលៀកបំពាក់ និងស្បែកជើង (៣%) (ទី៣)- ការស្នាក់នៅ និងថ្លៃទឹកភ្លើង (២២,៩%) (ទី៤)- គ្រឿងសង្ហារឹម និងសំភារៈផ្សេងៗ (២,៧%) (ទី៥)- ការដឹកជញ្ជូន និងគមនាគមន៍ (១៣,៤%) (ទី៥)- ការថែទាំសុខភាព (៥,១%) (ទី៦)- ការស្តារឡើងវិញ និង ការអប់រំ (៤,១%) និង (ទី៧)- ការថែរក្សាសុខភាពផ្ទាល់ខ្លួន (២,៣%) ។ ក្រុមរងនីមួយៗនៃក្រុមរងទាំងនេះ ផ្តល់មកវិញនូវទំងន់មធ្យមនៃសន្ទស្សន៍រងនៅក្នុងក្រុមរង ។ ទម្ងន់ក្នុង **CPI** បង្ហាញពីចំណែកនៃចំណាយ ដែលបែងចែកតាមទំនិញ និងសេវានីមួយៗ តាមប្រភេទគ្រួសារដែលប្រើប្រាស់ទិន្នន័យដែលប្រមូលដោយការស្រាវជ្រាវលើគ្រួសារក្នុងឆ្នាំគោល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**CPI** មានចំណុចខ្សោយមួយចំនួន ដោយសារការកែប្រែទម្ងន់រវាងឆ្នាំគោល និង ឆ្នាំជាក់ស្តែងនៃការគណនាសន្ទស្សន៍ ការជ្រើសរើសឆ្នាំគោល និង ការប្រែប្រួលនៃថ្លៃប្រៀបធៀប រវាងអនុ-សន្ទស្សន៍ដែលតែង ផ្លាស់ប្តូរក្នុងរយៈពេលដប់ឆ្នាំម្តង ។ យើងនឹងពិភាក្សាអោយបានលម្អិតខាងក្រោមនេះ នូវបញ្ហាដែលកើតមានឡើង ក្នុងការគណនានូវសន្ទស្សន៍ ។

ទម្ងន់នៃកម្រងទំនិញ និងសេវាត្រូវរក្សាទុកអោយថេរ ដើម្បីគណនានូវសន្ទស្សន៍ នៅក្នុងគ្រប់ពេលទាំងអស់ ។ នៅពេលដែលគំរូនៃការប្រើប្រាស់មានការប្រែប្រួលយ៉ាងខ្លាំង ទម្ងន់ត្រូវបានកែប្រែ ហើយឆ្នាំគោលត្រូវបានផ្លាស់ប្តូរ ។ ឧទាហរណ៍ ក្នុង **CPI** ដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ ទម្ងន់នេះត្រូវបានកែប្រែដោយប្រើ CSES ២០០៤ ។ ឆ្នាំ ២០០៤ ជាឆ្នាំទទួលការរងគ្រោះដោយសារទឹកជំនន់ និង គ្រោះរាំងស្ងួត ។ ការកើនឡើងថ្លៃចំណីអាហារជាបន្តបន្ទាប់ ហើយអ្នកប្រើប្រាស់បានចំណាយកាន់តែច្រើនជាងមុន នូវចំណូលរបស់គេលើចំណីអាហារ ។ ក៏ប៉ុន្តែ ក្នុងឆ្នាំ ២០០៧ ចំណាយរបស់អ្នកប្រើប្រាស់មានសភាពខុសពីមុន ដោយសារតែប្រជាជនមួយចំនួនត្រូវបាន់ខាងលក់ដីធ្លី និង ផ្ទះសម្បែង ដោយសារតែថ្លៃអចលនវត្ថុកើនឡើងយ៉ាងខ្លាំង ។ ការប្រើប្រាស់ទម្ងន់ដែលកំណត់ដោយគំរូប្រើប្រាស់ ឆ្នាំ ២០០៤ ដើម្បីគណនាអតិផរណាក្នុងឆ្នាំ ២០០៧ អាចនឹងទទួលបានលទ្ធផលខុស ។

បញ្ហាមួយទៀតរបស់ **CPI** គឺការជ្រើសរើសឆ្នាំគោល ។ ប្រសិនជាឆ្នាំគោលដែលជ្រើសរើសគឺជាឆ្នាំដែលដោយការចៃដន្យ ដោយប្រការណាមួយ ធ្វើអោយថ្លៃ ឬ អាកប្បកិរិយារបស់អ្នកប្រើ មានការខុសគ្នាខ្លាំងពីឆ្នាំគោល ឬខុសពីសភាពធម្មតា នោះការគណនាអតិផរណាក្នុងឆ្នាំបន្តបន្ទាប់ នឹងមានកំហុស ។ ឧទាហរណ៍កម្ពុជាធ្លាប់មានអតិផរណាទាប ៤,៧% ក្នុងឆ្នាំ ២០០៦ នៅពេលដែលអតិផរណាស្មើ ៥,៨% ក្នុងឆ្នាំ ២០០៧ ។ ពេលដែលឆ្នាំ ២០០៦ ត្រូវបានជ្រើសរើសជាឆ្នាំគោល ដើម្បីគណនាអតិផរណានៅដើមឆ្នាំ ២០០៨ ពេលនោះអតិផរណាសម្រេចបានក្នុងកម្រិតមួយដ៏ខ្ពស់ខ្លាំង ចំនួន ១៨% ។

**CPI** មិនអាចវាស់វែងនូវការប្រែប្រួលគុណភាពទំនិញ និងសេវាឡើយ ។ មានសេណារីយ៉ូខុសគ្នាក្នុងករណីនេះ ។ គេហកិច្ចអាចប្រើប្រាស់ទំនិញ និងសេវាដែលមានគុណភាពកាន់តែខ្ពស់ ប៉ុន្តែនេះមិនអាចគណនាចូលក្នុង CPI បានឡើយ ។ ការបញ្ចូលនូវមុខទំនិញ និងសេវាបន្ថែមក្នុងកន្ត្រកថ្មីនៃការប្រើប្រាស់សរុបរបស់គេហកិច្ច ដោយសារតែសេដ្ឋកិច្ចជាតិកាន់តែមានការវិវត្តស្មុគ្រស្មាញឡើងៗ ក៏បង្កើតជាបញ្ហា សម្រាប់ការគណនា CPI ផងដែរ ។

**CPI** មិនអាចវាស់វែងបាននូវការប្រែប្រួលនៃថ្លៃប្រៀបធៀបរបស់ទំនិញ និងសេវាបានឡើយនៅក្នុងសន្ទស្សន៍រង ។ កំណើនថ្លៃនៃទំនិញ និង សេវាក្នុងអនុ-សន្ទស្សន៍មួយ ត្រូវបានកាត់កងជាមួយការចុះថ្លៃ នៃទំនិញនិង សេវាក្នុងអនុ-សន្ទស្សន៍មួយទៀត ។ **CPI** មិនអាចបង្ហាញពីការធ្លាក់ចុះ ឬការកើនឡើងនៃការចំណាយជីវភាពរស់នៅឡើយ ទោះបីជា ការឡើងថ្លៃទំនិញ និង សេវាក្នុងអនុ-សន្ទស្សន៍ខ្លះ អាចធ្វើអោយអ្នកប្រើប្រាស់មួយចំនួន អាចនឹងរងគ្រោះយ៉ាងខ្លាំង ។ ដូចនេះ ការវិភាគពីអតិផរណាតាមវិស័យ មានសារៈសំខាន់ខ្លាំងណាស់ដើម្បីស្វែងយល់ ពីការប្រែប្រួលនៃថ្លៃប្រៀបធៀបរបស់ទំនិញ និងសេវា ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការកែប្រែវិធីសាស្ត្រក្នុងការគណនាទស្នស្សន៍ថ្លៃ ពីពេលមួយទៅពេលមួយទៀត ធ្វើអោយសេរីពេលវេលា របស់ CPI ដាច់ចេញពីគ្នា និង មិនអាចប្រៀបធៀបគ្នាអោយបានត្រឹមត្រូវ ។ ឧទាហរណ៍ វិទ្យាស្ថានជាតិស្ថិតិ បានកែប្រែទម្ងន់ និងឆ្នាំគោលសម្រាប់គណនា **CPI** ពីខែមករាឆ្នាំ ២០០៨។ ប្រការនេះនាំឱ្យមានកំហុសមួយចំនួន ក្នុងសេរីនៃ **CPI** ។ ជាចុងបញ្ចប់ ដោយមានវង្វាស់ច្រើនពេកបានផ្អែកលើស្ថិតិ ដែលមានភាពស្មុគស្មាញ យើងពិបាកនឹងប្រើប្រាស់នូវសន្ទស្សន៍នេះ ដើម្បីពន្យល់ប្រាប់សាធារណៈជនណាស់ ។

ទោះបីជាមានចំណុចខ្វះខាតទាំងនេះក៏ដោយ **CPI** នៅតែជាវង្វាស់អតិផរណាមួយដែលងាយយល់បំផុត គួរឱ្យទុកចិត្ត និង ងាយស្រួលគណនា ។ វាត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្នុងប្រទេសភាគច្រើន ជាមូលដ្ឋានសម្រាប់ធ្វើការកែប្រែគោលនយោបាយដែលទាក់ទងនឹងអតិផរណា ដូចជាសម្រាប់គណនានូវការចាំបាច់ត្រូវតម្លើងប្រាក់បៀវត្សជូនពលករ ដែលរងគ្រោះដោសសារអតិផរណា ។

## ៦.៣.២. រូបមន្តសម្រាប់គណនាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់

ដើម្បីគណនាសន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់នៅកម្ពុជា គេប្រមូលថ្លៃទំនិញ និងសេវាចំនួន ២៥៩មុខ ពីទីផ្សារចំនួន ៥ ក្នុងក្រុងភ្នំពេញ និងទីផ្សារចំនួន ០៨ ក្នុងទីរួមខេត្តចំនួនប្រាំ ។ សន្ទស្សន៍ថ្លៃទំនិញត្រូវបានគណនាសម្រាប់ទីក្រុងភ្នំពេញ និងខេត្ត ដោយឡែក ៗពីគ្នា តាមមធ្យមធរណីមាត្រនៃទំហៀបថ្លៃនីមួយៗ:

$$I_{Oct06-Dec06;i}^{my;Area}=100\times\frac{\coprod_{s=1}^{S}\left(\frac{P_{s;i}^{m}}{P_{s;i}^{oct06}}\right)^{\frac{1}{s}}}{\frac{1}{3}\left[1+\coprod_{s=1}^{S}\left(\frac{P_{s;i}^{Nov06}}{P_{s;i}^{Oct06}}\right)^{\frac{1}{s}}+\coprod_{s=1}^{S}\left(\frac{P_{s;i}^{Dec06}}{P_{s;i}^{Oct06}}\right)^{\frac{1}{s}}\right]} \qquad (១)$$

$P_{s;i}^{m}$ គឺជាថ្លៃបច្ចុប្បន្នទំនិញ និងសេវា i នៅទីផ្សារ s ៖ ហើយ

$P_{s;i}^{oct\,06}$ គឺជាថ្លៃយោងក្នុងខែតុលា ២០០៦ (២០០៦ គឺជាឆ្នាំគោល)

ចំពោះសន្ទស្សន៍ទំនិញនិងសេវា សម្រាប់កម្ពុជាត្រូវបានគណនាជាមធ្យមទំងន់នៃសន្ទស្សន៍នៅក្រុងភ្នំពេញ និង នៅតាមបណ្តាខេត្តផ្សេងៗ ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

$$I_{Oct06-Dec06;i}^{m;Cambodia} = \frac{V_i^{Phnom_Penh}}{V_i^{Phnom_Penh} + V_i^{Provinces}} I_{Oct06-Dec06;i}^{m;Phnom_Penh} + \frac{V_i^{Provinces}}{V_i^{Phnom_Penh} + V_i^{Provinces}} I_{Oct06-Dec06;i}^{m;Provinces}$$

(២)

$V^{Phnom_Penh}$ និង $V^{Province}$ គឺជាតម្លៃប្រើប្រាស់សម្រាប់ក្រុងភ្នំពេញ និងតាមបណ្ដាខេត្ត (CSES ២០០៤)

សន្ទស្សន៍សរុបសម្រាប់ COICOP ប្រភេទ c និងសន្ទស្សន៍ទំនិញ និងសេវាទាំងអស់ ត្រូវបានគណនាជាមធ្យមទម្ងន់នៃសន្ទស្សន៍តាមប្រភេទទំនិញក្នុងតំបន់នីមួយៗ (ទូទាំងកម្ពុជា ក្រុងភ្នំពេញ និងខេត្តផ្សេងៗ)។

$$I_{Oct06-Dec06}^{m;Area} = \sum_{i \in c} \frac{W_i^{Area} I_{Oct06-Dec06}^{m;Area}}{\sum_{i \in c} W_i^{Area}}$$

(៣)

ដែល $W_i^{Area}$ គឺជាទម្ងន់ចំណាយធៀបគ្នានៃទំនិញនីមួយៗ ដែលស្រង់ចេញពីការអង្កេតសេដ្ឋកិច្ច-សង្គម ឆ្នាំ ២០០៤ និងកែតម្រូវទៅតាមកម្រិតថ្លៃ ពីខែ តុលា- ធ្នូ ២០០៦ ។ ដូចនេះ និយមន័យជាមូលដ្ឋានរបស់ CPI សម្រាប់ខែ m គឺជាប្រភេទសន្ទស្សន៍មួយនៃប្រភេទ **ឡាស្ពេយ៏រ៉េស** ដែល q ជាទម្ងន់ឆ្នាំ ២០០៤ និងថ្លៃ p ជាថ្លៃយោង ខែតុលា- ធ្នូ ឆ្នាំ ២០០៦ ។

$$I_{Oct06-Dec06}^{m} = \frac{\sum p_m q_{2004}}{\sum P_{Oct06-Dec06} q_{2004}}$$

(៤)

យោងតាមការគណនាថ្មី ការចំណាយប្រើប្រាស់របស់គ្រួសារក្នុងក្រុងភ្នំពេញមានភាគរយតិចជាង ២០%នៃចំណាយប្រើប្រាស់របស់គ្រួសារសរុបនៅកម្ពុជា ។ យោងតាម CPI ថ្មី ថ្លៃទំនិញប្រើប្រាស់នៅទីក្រុងភ្នំពេញកើនឡើង ១៤% ពី ខែធ្នូ ២០០៦ ដល់ខែធ្នូ ២០០៧ ។ ប្រសិនប្រើសន្ទស្សន៍ចាស់ ការកើនឡើងនៅនៅក្រុងភ្នំពេញមានអត្រា ១០,៨ % ។ ភាពខុសគ្នា ៣,២ % រវាងការប៉ាន់ស្មានទាំងពីរនៃអត្រាអតិផរណានេះ ដោយសារហេតុផលខាងក្រោម ÷

សាច់ជ្រូកបានរួមចំនែក ២,៨ % ឯកតា ក្នុងសន្ទស្សន៍ថ្មី ប៉ុន្តែមានតែ ១,៩ % ឯកតា ក្នុងសន្ទស្សន៍ចាស់។ ថ្លៃសាច់ជ្រូកកើនឡើងយ៉ាងខ្លាំងកំឡុងពេលពាល់កណ្ដាលឆ្នាំ ២០០៧ ។ ទម្ងន់របស់សាច់ជ្រូកគឺមានទំហំធំគួរឱ្យកត់សំគាល់ក្នុងសន្ទស្សន៍ថ្មី (៥,៦%) ធៀបនឹងសន្ទស្សន៍ចាស់ (៣,៧%) ។ ការរួមចំនែកនេះគឺកើតមានចំពោះសាច់ជ្រូកជាប់ខ្លាញ់ ដែលបានកើនឡើងខ្លាំងជាងគេគឺប្រហែលជា ៥៥ % ។ ដូចនេះហើយ ការកើនឡើងនេះ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានផលប៉ះពាល់កាន់តែខ្លាំងទៅលើសន្ទស្សន៍ថ្មី ។ សាច់ជ្រូកសុទ្ធក៏កើនឡើងខ្លាំងដែរក្នុងសន្ទស្សន៍ថ្មីធៀបនឹងសន្ទស្សន៍ចាស់ ។ ចំណុចនេះក៏បានរួមចំណែកដល់ភាពខុសគ្នាដែរ ។

ត្រីរួមចំណែក ២,១ %ឯកតាទៅនឹងសន្ទស្សន៍ថ្មី និង ១,៦ % ឯកតាទៅនឹងសន្ទស្សន៍ចាស់ ។ ថ្លៃត្រីបានកើនឡើងជាមធ្យម ២៤,៤ % ជាមធ្យម ដែលទាបជាងការប៉ាន់ស្មាន ៣០ % ក្នុងសន្ទស្សន៍ចាស់ ដោយសារទម្ងន់បានកែប្រែដោយសារត្រីមានកំណើនថ្លៃទាបជាង ។ តែ ទម្ងន់ចំណាយសរុបលើត្រីកើនឡើងរហូតដល់ ៩,៣ % ក្នុងសន្ទស្សន៍ថ្មី ធៀបនឹង ៥,៤ % ក្នុងសន្ទស្សន៍ចាស់ ។ ឥទ្ធិពលសរុបគឺជាកើនឡើងនៃអត្រាអតិផរណាសរុប ។

ឧស្ម័នធម្មជាតិសម្រាប់ការចំអិនគឺជាប្រភេទថ្មីដែលមិនបានដាក់បញ្ចូលក្នុង CPI ចាស់ ។ ក្នុងកំឡុងឆ្នាំ ២០០៧ ថ្លៃឧស្ម័នធម្មជាតិកើនឡើង ៥៥ % ។ ជាក់ស្តែង កំណើននេះមានឥទ្ធិពលលើសន្ទស្សន៍ថ្មីប៉ុណ្ណោះ ដោយបានរួមចំនែក ១,៥ % ឯកតា ចំពោះអត្រាអតិផរណាសរុប ១៤ % ក្នុងក្រុងភ្នំពេញទាំងមូល ។

**រូបភាព ១៦.២. អត្រាប្រែប្រួល CPI ក្នុងរយៈពេល ១២ខែ នៅភ្នំពេញ**




*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ*

សម្ភារៈដឹកជញ្ជូនផ្ទាល់ខ្លួនមានផលប៉ះពាល់ចំនួន ០,៨ % ឯកតា ច្រើនជាងនៅក្នុងសន្ទស្សន៍ថ្មីធៀបនឹងសន្ទស្សន៍ចាស់ ។ ប្រការនេះ ដោយសារការដាក់បញ្ចូលរថយន្តជាមុខទំនិញថ្មី ។ ថ្លៃរបស់រថយន្តកើនឡើងយ៉ាងខ្លាំងលើសមធ្យោបាយដឹកជញ្ជូនផ្សេងទៀត នៅក្នុងឆ្នាំ ២០០៧ កន្លងទៅនេះ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាស្រ័យទៅលើបម្រែបម្រួលនៃថ្លៃប្រៀបធៀប អត្រាអតិផរណានៃ **CPI** ថ្មី និង ចាស់ តែងតែខុសគ្នាជានិច្ចគ្រប់ពេលវេលា ។ តាំងពីពាក់កណ្ដាលឆ្នាំ ២០០៥ មកម្ល៉េះ សន្ទស្សន៍ថ្មីដែលគណនាចេញពីសន្ទស្សន៍ចាស់ដោយដកឈ្នួលផ្ទះចេញបង្ហាញថា សន្ទស្សន៍ចាស់មានអត្រាអតិផរណាទាបជាង ។

### ៦.៣.៣. សូចនាករសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់

សូចនាករដែលប្រើប្រាស់ជាញឹកញាប់បំផុតគឺ **អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំខែប្រៀបធៀបនឹងឆ្នាំមុន** និង **អត្រាអតិផរណាមធ្យមរំកិលនៅត្រីមាសទីមួន** ។ អតិផរណាអាចប្រែប្រួលយ៉ាងខ្លាំងក្នុងរយៈពេលមួយឆ្នាំ ដែលឆ្លុះបញ្ចាំងទាំងការប្រែប្រួលនៃថ្លៃតាមរដូវកាល និងការប្រែប្រួលជាប្រចាំនៃការផ្គត់ផ្គង់ និងតម្រូវការ ។ ការប្រើប្រាស់នូវអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ នឹងជួយធ្វើអោយបម្រែបម្រួលក្នុងឆ្នាំកាន់តែរលូន ដែលបណ្ដាលមកពីកត្តាតាមរដូវ និង ជួយញែកចេញទំនោរអតិផរណាពីវិបត្តិ ។ អតិផរណាមធ្យមប្រចាំឆ្នាំ អាចបង្ហាញពីទំនោរមធ្យម ប៉ុន្តែមិនបានបង្ហាញពីទិសដៅធ្លាក់ចុះ ឬ កើនឡើងនៃអតិផរណាឡើយ ។ តារាងទី ផ្ដល់នូវការពន្យល់អំពីសូចនាករខ្លះរបស់កម្ពុជា ។

| **តារាងលេខ ១៦.២ អតិផរណាមធ្យម និង ត្រីមាសចុងឆ្នាំ** | | | | | |
|---|---|---|---|---|---|
| | *2003* | *2004* | *2005* | *2006* | *2007* |
| អតិផរណាមធ្យម | 1.2 | 3.9 | 5.8 | 4.7 | 5.8 |
| អតិផរណាត្រីមាសចុងឆ្នាំ | 0.5 | 5.6 | 6.7 | 2.8 | 10.8 |

*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ*

សូចនាករ **អតិផរណាប្រចាំត្រីមាសចុងឆ្នាំ** ត្រូវបានប្រើប្រាស់ជាញឹកញាប់ដោយបេសកម្មនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីព្យាករណ៍អតិផរណាសំរាប់ឆ្នាំបន្ទាប់ ។ អត្រាអតិផរណានៅត្រីមាសទី៤ទាបជាងអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ប្រសិនបើអតិផរណាកំពុងធ្លាក់ចុះ ហើយខ្ពស់ជាងអត្រាប្រចាំឆ្នាំមធ្យម ប្រសិនបើអតិផរណាកំពុងកើនឡើង ។ ឧទាហរណ៍ ប្រសិនបើអតិផរណាត្រីមាសចុងឆ្នាំ ២០០៧ ស្មើ ១០,៨% ហើយអតិផរណាមធ្យមប្រចាំឆ្នាំ ២០០៧ ស្មើនឹង ៥,៨% មានន័យថាអតិផរណានៅក្នុងឆ្នាំ ២០០៨ នឹងមាននិន្នាការកើនឡើង ។

រង្វាស់ អតិផរណាប្រចាំត្រីមាសត្រូវបានប្រើប្រាស់ជាញឹកញាប់ដោយធនាគារជាតិនៃកម្ពុជាសម្រាប់ដើម្បីកំណត់ទិសដៅអតិផរណា ។ ការប្រើអត្រាមធ្យមរំកិល ឬ អត្រាប្រៀបធៀបនឹង១២ខែឆ្នាំមុន ជួយកាត់បន្ថយបម្រែបម្រួលឡើងចុះខ្លាំងនៃរង្វាស់អតិផរណា ។ ក៏ប៉ុន្តែ វាក៏កាត់បន្ថយផងដែរនូវភាពទាន់ពេលនៃព័ត៌មានស្ដីពីអតិផរណាស្នូល ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### រូប ១៦.៣ អតិផរណាមធ្យមប្រចាំឆ្នាំ និង ចុងឆ្នាំ




| | Jan-08 | Feb-08 | Mar-08 | Apr-08 | May-08 | Jun-08 | Jul-08 | Aug-08 | Sep-08 | Oct-08 | Nov-08 | Dec-08 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| % Change (Year Average) | 6.80% | 7.80% | 9.20% | 10.90% | 12.70% | 14.30% | 15.70% | 17.10% | 18.30% | 19.10% | 19.70% | 20.20% |
| % Change (Year End) | 13.70% | 15.50% | 20.30% | 24.20% | 25.70% | 24.80% | 22.30% | 22.60% | 20.30% | 18.00% | 18.10% | 17.40% |

## ៦.៣.៤. តួនាទីរបស់សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់ ក្នុងគោលនយោបាយរូបិយវត្ថុ

**CPI** ត្រូវបានប្រើប្រាស់ដោយធានាគារកណ្តាល ដែលអនុវត្ត **ការកំណត់គោលដៅអតិផរណា** ជាឧបករណ៍គោលនយោបាយរូបិយវត្ថុ ដោយឈរលើមូលដ្ឋានទ្រឹស្តី និង ការអនុវត្តជាក់ស្តែង ។ ដោយឈរលើទស្សនៈវិស័យនៃទ្រឹស្តី គោលដៅចុងក្រោយបំផុតនៃគោលនយោបាយរូបិយវត្ថុ គឺការបង្កើនជាអតិបរមានូវសុខមាលភាពរបស់ប្រជាជន ។ ដោយ **សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់** ឆ្លុះបញ្ចាំងបានប្រសើរជាងគេ ពីការប្រែប្រួលនៃចំណាយ សម្រាប់ជីវភាពរស់របស់ប្រជាជន បានប្រសើរជាង **បរិត្តផរណានៃផលិតផលសរុបក្នុងស្រុក (GDP Deflator)** ដូច្នេះ CPI គឺជារង្វាស់មួយដ៏សំខាន់សម្រាប់ការវាស់វែងផលប៉ះពាល់នៃអតិផរណាទៅលើសុខមាលភាពរបស់អ្នកប្រើប្រាស់ ។ បរិត្តផរណា ផ.ស.ស ត្រូវគេប្រើប្រាស់ជាចំបង ដើម្បីបង្ហាញពី ភាពខុសគ្នារវាង ផ.ស.ស.ពិត និង ផ.ស.ស.តាមថ្លៃទីផ្សារ ។ **ផ.ស.ស.** តាមថ្លៃទីផ្សារ ចែកនឹង **បរិត្តផរណា ផ.ស.ស.** ស្មើនឹង ផ.ស.ស.ពិត ។

ដោយឈរលើទស្សនៈវិស័យនៃការអនុវត្ត មានអំណះអំណាងដ៏ខ្លាំងមួយក្នុងការការប្រើប្រាស់ **CPI** ដើម្បី **កំណត់គោលដៅអតិផរណា** ។ សម្រាប់គេហកិច្ចទូទៅ អត្រាអតិផរណាសរុប គឺជាបញ្ហាចំបងរបស់គេ ។ គឺថា អតិផរណាសរុប ដែលវាស់ពីអត្រាកំណើននៃចំណាយក្នុងជីវភាពរស់នៅដែលកំពុងកើនឡើង ។ គឺថា អតិផរណាសរុប ធៀបទៅនឹងកំណើននៃចំណូលដែលកំណត់ថា តើជីវភាពរស់នៅរបស់គេហកិច្ចកំពុងកើនឡើងឬថយចុះ ។ **CPI** គឺជាសន្ទស្សន៍ដែលត្រូវបានប្រើប្រាស់ជាទូទៅ ដើម្បីវាស់អតិផរណាសរុប ។ ដោយពិនិត្យមើលទៅលើធនធានដែលប្រើប្រាស់ក្នុងការគណនា **CPI** គឺជាសន្ទស្សន៍ដែលមានគុណភាពខ្ពស់ និង គណនាបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាន់ពេលវេលា ជាងសន្ទស្សន៍ថ្លៃដ៏ទៃទៀត ។

ទោះបីយ៉ាងណាក៏ដោយ ក្នុងគោលបំណងដើម្បីធ្វើការពិសោធន៍គោលនយោបាយរូបិយវត្ថុ ធនាគារកណ្ដាលបានផ្ដោតទៅលើអត្រា **អតិផរណាស្នូល** ៖ អត្រាអតិផរណាដែលមិនគិតពីថ្លៃចំណីអាហារ និង ថាមពល ។ ប្រការនេះ ដោយសារតែអត្រាស្នូល មិនសូវប្រែប្រួលខ្លាំង និង ឆ្លុះបញ្ចាំងបានប្រសើរជាងនូវអន្តរកម្មរវាងការផ្គត់ផ្គង់ និង តម្រូវការក្នុងទីផ្សារក្នុងស្រុក ។ ដូចនេះហើយ ជាធម្មតា អត្រាស្នូលនេះជារង្វាស់មួយដ៏ប្រសើរអំពីអត្រាមូលដ្ឋាននៃអតិផរណា ដែលច្រើនលេចឡើងនៅពេលដែលគ្មានវិបត្តិការផ្គត់ផ្គង់ ដែលមិនរំពឹងទុក និង ត្រូវដោះស្រាយនៅពេលបន្ទាប់ទៀត ។

## ៦.៣.៥. ការគណនាអតិផរណាស្នូល

**អតិផរណាស្នូល** អាចត្រូវបានគណនាដោយការប្រើវិធីសាស្ត្រដូចខាងក្រោម៖

***រង្វាស់ដែលបានដកចេញជាអចិន្ត្រៃយ៍នូវសមាសភាគដែលបានកំណត់ជាមុននៃ CPI*** នេះគឺជាវិធីទូទៅបំផុត ដែលប្រើដោយប្រទេសជាច្រើន ។ អតិផរណាស្នូលត្រូវបានគណនាដោយមិនរាប់បញ្ចូល នៅក្នុងកន្ត្រក **CPI** នូវថ្លៃទំនិញ និងសេវាមួយចំនួន ដូចជា ចំណីអាហារ និងថាមពល ដែលងាយនឹងរងឥទ្ធិពលពីវិបត្តិការផ្គត់ផ្គង់ ។ វិធីនេះត្រូវបានជ្រើសរើស តាមហេតុផលដូចខាងក្រោម ÷ ងាយស្រួលបង្កើត ងាយស្រួលយល់ដោយសាធារណៈជន ងាយស្រួលគណនាតាម និងផ្ទៀងផ្ទាត់ មានគណនេយ្យភាពនិងតម្លាភាពខ្ពស់ក្នុងការវាស់វែង និងមានភាពទាន់ពេលវេលា ។ ប្រទេសមួយចំនួនបានបោះពុម្ពរង្វាស់អតិផរណាស្នូល ដែលបានដកចេញជាប្រព័ន្ធ នូវថ្លៃចំណីអាហារ និង ថាមពល (ដោយកំណត់ទម្ងន់ស្មើរសូន្យ) ។

***ការកំណត់ទម្ងន់ឡើងវិញនូវស៊េរីថ្លៃជាប្រព័ន្ធ*** (Systematic re-weighting of Price series) ៖ ដោយធ្វើការកែប្រែនូវប្រព័ន្ធទម្ងន់ធម្មតា (normal weight system) ក្នុង CPI ដើម្បីបន្ថយទម្ងន់ (down-weight) ជាប្រព័ន្ធ ឬដកចេញនូវស៊េរីថ្លៃពិសេសដែលគេជឿថាត្រូវបានកំណត់ជាសំខាន់ ដោយល័ក្ខខ័ណ្ឌផ្គត់ផ្គង់ ហើយបង្កើនទម្ងន់ (up-weight) សមាសភាគដែលនៅសល់ ដែលមិនសូវប្រែប្រួលទៅតាមវិបត្តិការផ្គត់ផ្គង់ ។ ចំនុចខ្សោយចំបងនៃវិធីកំណត់ទម្ងន់ឡើងវិញ គឺថាវិធីសាស្ត្រនេះមិនគួរជាទីទុកចិត្តបានគ្រប់ពេលនោះទេ ជាពិសេសនៅពេលដែលសេដ្ឋកិច្ចកំពុងទទួលរងការប្រែប្រួលរចនាសម្ពន្ធ័យ៉ាងខ្លាំងក្លា ។ បញ្ហាដ៏ធំមួយទៀតគឺថា ***ការកំណត់ទម្ងន់ឡើងវិញ*** នៃអនុក្រុមរបស់ CPI អាចនាំមកនូវការវាស់អតិផរណាស្នូលដែល មានទំនោរខុសគ្នាជាងអតិផរណាសរុប ។

បទពិសោធន៍របស់ពិភពលោករយៈពេល ៤ ឆ្នាំ កន្លងទៅនេះ បង្ហាញពីបញ្ហាប្រឈមមុខនឹងមូលហេតុដែលត្រូវយកអតិផរណាស្នូលមកធ្វើជាអញ្ញត្តិនៃគោលនយោបាយរូបិយវត្ថុ ។ ក្នុងរយៈពេលនេះ ថ្លៃប្រេងឆៅឡើង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ្ពស់កប់ពពក ដោយកើនឡើងពី ២០ ដុល្លារ ក្នុងមួយធុងនៅដើមឆ្នាំ ២០០២ រហូតដល់ ១៤៦ ដុល្លារ ក្នុងមួយធុងនៅពាក់កណ្តាលខែ កក្កដាឆ្នាំ ២០០៨ មុននឹងធ្លាក់ចុះមកវិញត្រឹម ៦០-៧០ ដុល្លារក្នុងមួយធុងនៅចុងឆ្នាំ ២០០៨ ដោយសារមានវិបត្តិហិរញ្ញវត្ថុពិភពលោក ។ នៅពេលខ្លះ ការកើនឡើងនៃប្រេងឆៅគឺ ទាក់ទងនឹងការអាក់ខាននៃការផ្គត់ផ្គង់ ដូចជាសង្គ្រាមនៅប្រទេសអ៊ីរ៉ាក់ និងព្យុះសង្ឃរា ។ ប៉ុន្តែវិតតែសំខាន់ទៀត នោះនិន្នាការកើនឡើងនៃថ្លៃប្រេងឆៅបានឆ្លុះបញ្ចាំងពីការកើនឡើងតម្រូវការថាមពលយ៉ាងខ្លាំងរបស់ពិភពលោក ។ ក្នុងករណីណាក៏ដោយ លទ្ធផលគឺថា អតិផរណាសរុបមានភាពលើសឆ្ងាយពីអតិផរណាស្នូល ក្នុងរយៈពេល៤ឆ្នាំជាបន្ទាប់បន្តបន្ទាប់ ។ ហើយបញ្ហាគឺថា តើវាសមស្របដែរឬទេ ដែលធនាគារកណ្តាលផ្តោតលើតែអតិផរណាស្នូល ក្នុងស្ថានការណ៍នៃកំណើនថ្លៃម្ហូបអាហារ និង ប្រេងឥន្ធនៈបែបនេះ ។

ថ្វីបើមានកង្វល់ដូចបានពិភាក្សាខាងលើក៏ដោយ អតិផរណាស្នូលត្រូវបានប្រើប្រាស់ដោយធនាគារកណ្តាល ដើម្បីកំណត់ថាតើ បម្រែបម្រួលនាពេលបច្ចុប្បន្ននៃថ្លៃរបស់អ្នកប្រើប្រាស់ ជាការរំខានរយៈពេលខ្លី ឬក៏ជាផ្នែកមួយនៃទំនោរអចិន្ត្រៃយ៍ ។ ចំណេះដឹងបែបនេះ គឺមានសារៈសំខាន់សម្រាប់ការរៀបចំគោលនយោបាយរូបិយវត្ថុ ។

## ៦.៤. ការវិវឌ្ឍថ្មីៗនៃអតិផរណាក្នុងតំបន់ និងក្នុងពិភពលោក

### ៦.៤.១. បទពិសោធន៍ក្នុងបណ្តាប្រទេសអាស៊ានបូកបី

អតិផរណាសរុប (Headline Inflation) បានកើនឡើងពាសពេញពិភពលោកក្នុងរវាងចន្លោះឆ្នាំ ២០០៤-២០០៧ ដោយសារការកើនថ្លៃម្ហូបអាហារ និងថាមពល ។ នៅបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង អតិផរណាស្នូល (Core Inflation) បានកើនឡើងនាពេលប៉ុន្មានខែចុងក្រោយនេះ បើទោះបីកំណើនសេដ្ឋកិច្ចបានធ្លាក់ចុះក៏ដោយ ។ នៅក្នុងប្រទេសដែលសេដ្ឋកិច្ចកំពុងងើបឡើង អតិផរណាសរុប បាននិងកំពុងកើនឡើង ដែលឆ្លុះបញ្ចាំងពីកំណើនតម្រូវការដ៏ខ្លាំង និង ទំងន់នៃម្ហូបអាហារ និងថាមពល នៅក្នុងកន្ត្រកប្រើប្រាស់ ។ គេរំពឹងថា អតិផរណាទូទៅពិភពលោក នឹងស្ថិតក្នុងកម្រិតខ្ពស់នៅក្នុងឆមាសទី ១ ឆ្នាំ ២០០៨ ប៉ុន្តែនឹងធ្លាក់ចុះបន្តិចម្តងៗ ដោយសារការថយចុះនៃសកម្មភាពសេដ្ឋកិច្ច ។

អតិផរណាបន្តកើនឡើងក្នុងតំបន់អាស៊ានបូកបី ដែលភាគច្រើនបណ្តាលមកពីកំណើនដ៏សំបើមនៃតថ្លៃប្រេងឥន្ធនៈ និងទំនិញផ្សេងៗ និងដោយសារតម្រូវការក្នុងស្រុកដ៏ខ្លាំង នៅក្នុងសេដ្ឋកិច្ច ដូចជាប្រទេសចិន សឹង្ហបុរី និងវៀតណាម ផងដែរ ។ នៅពេលប៉ុន្មានខែថ្មីៗនេះ អតិផរណាថ្លៃអ្នកប្រើប្រាស់ បានក្លាយជាបញ្ហាព្រួយបារម្ភសម្រាប់តំបន់ (កម្រិតខ្ពស់បំផុត (៦,៦%) ក្នុងរយៈពេល ២៥ ឆ្នាំ សម្រាប់ប្រទេសសឹង្ហបុរី កម្រិតខ្ពស់បំផុត (៨,៧%) ក្នុងរយៈពេល ១១ ឆ្នាំ សម្រាប់ប្រទេសចិន និង (១៥,៧%) សម្រាប់ប្រទេសវៀតណាម និងកម្រិតខ្ពស់បំផុត (៣,៨%) ក្នុងរយៈពេល ១០ ឆ្នាំ សម្រាប់ទីក្រុងហុងកុង) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### តារាង ១៦ . ៣ កំណើនផលិតផលក្នុងស្រុកសរុប និងអតិផរណានៅក្នុងពិភពលោក

| | *Real GDP Growth* | | | *CPI Inflation* | | |
|---|---|---|---|---|---|---|
| | Year-on-year per cent change | | | Year-on-year per cent change | | |
| | | Projection | | | Projection | |
| | 2007 | 2008 | 2009 | 2007 | 2008 | 2009 |
| World | 4.9 | 3.7 | 3.8 | 4.0 | 4.7 | 3.7 |
| Advanced economies | 2.7 | 1.3 | 1.3 | 2.1 | 2.6 | 2.0 |
| United States | 2.2 | 0.5 | 0.6 | 2.9 | 3.0 | 2.0 |
| Euro area | 2.6 | 1.3 | 1.1 | 2.1 | 2.7 | 1.9 |
| Japan | 2.1 | 1.4 | 1.5 | 0.0 | 0.6 | 1.3 |
| Emerging and developing econo- | 7.9 | 6.7 | 6.6 | 6.3 | 7.4 | 5.6 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ*

ក្នុងខណៈដែលអតិផរណាដំបូងឆ្លុះបញ្ចាំងពីវិបត្តិនៃការផ្គត់ផ្គង់ចំណីអាហារ និងកំណើនតថ្លៃទំនិញ នៅលើពិភពលោក (ពេលដែលគ្មានការទប់ស្កាត់) នាពេលបច្ចុប្បន្ននេះកំណើនថ្លៃមានប្រភពកាន់តែទូលំទូលាយ ។ អតិផរណាស្នូល បានកើនឡើងជាពិសេសនៅប្រទេសឥណ្ឌា និងតំបន់ អាស៊ាន ៤ ដែលកត្តានេះឆ្លុះបញ្ចាំងពីកំណើនថ្លៃថាមពល និងវត្ថុធាតុដើម ដែលប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងប្រទេសថៃឡង់ដ៍ ទទួលកំណើនលើសពី ៥% ក្នុងខែកុម្ភៈ ឆ្នាំ ២០០៨ ។

នៅក្នុងសេដ្ឋកិច្ចឧស្សាហកម្មថ្មី ៣ ជាពិសេសប្រទេសសឹង្ហបូរី អតិផរណាក៏កំពុងកើនឡើងដែរ ។ ក្នុងអំឡុងត្រីមាសទី ១ ឆ្នាំ ២០០៨ សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់ នៅប្រទេសវៀតណាម បានកើនឡើង ៩,១៩ % ធៀបនឹងខែ ធ្នូ ឆ្នាំ ២០០៧ ។ ថ្លៃចំណីអាហារនៅវៀតណាមកើនឡើង ២៥,៩២% ផ្ទះសម្បែង និង គ្រឿងសំណង់ ១៧,៩៤% ដឹកជញ្ជូននិងទូរគមនាគមន៍ ១០,០៥% ។ ផ្អែកលើមូលដ្ឋានឆ្នាំធៀបនឹងឆ្នាំ អតិផរណានៅត្រីមាស ទី ១ ឆ្នាំ ២០០៨ កើនឡើង ១៦,៣៨% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ ២០០៧ ។ ជារួម កំណើនសេដ្ឋកិច្ចដែលនៅតែខ្លាំង ទោះបីធ្លាក់ចុះបន្តិចក៏ដោយទីផ្សារការងារចង្អៀត និងកំណើនថ្លៃម្ហូបអាហារ និងថាមពលត្រូវគេរំពឹងថានឹងជំរុញឱ្យមានអតិផរណានៅទូទាំងតំបន់ក្នុងឆ្នាំ ២០០៨ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### រូបទី ១៦.៤ អតិផរណាតំបន់ (ឆ្នាំធៀបនឹងឆ្នាំ គិតជាភាគរយ)




*ប្រភព: ធនាគារអភិវឌ្ឍន៍អាស៊ី*

## ៦.៤.២. មូលហេតុនៃអតិផរណាបច្ចុប្បន្ន

### ៦.៤.២.១. កំណើនថ្លៃប្រេងឥន្ធនៈ:

ចាប់តាំងពីឆ្នាំ ២០០៣ ថ្លៃប្រេងឥន្ធនៈបានកើនឡើងយ៉ាងលឿនបំផុត ពី ២២ ដុល្លារក្នុងមួយធុង ដល់ ១២០ ដុល្លារក្នុងមួយធុង នា ខែមីនា ឆ្នាំ ២០០៨ (កើនឡើង ៥ ដង) និងរហូតដល់ ១៤៦ ដុល្លារក្នុងមួយធុង នា ខែកក្កដា ឆ្នាំ ២០០៨ ។ តម្លៃដ៏ខ្ពស់នេះ បណ្តាលមកពីមូលហេតុសំខាន់ៗដូចខាងក្រោម (តាមប្រភព UNDP ឆ្នាំ ២០០៧)÷

**តម្រូវការដ៏សម្បើមដែលជំរុញដោយកំណើនសេដ្ឋកិច្ចខ្ពស់** នៅក្នុងពិភពលោក ។ យោងតាមភ្នាក់ងារថាមពលអន្តរជាតិ ក្នុងអំឡុងពេលឆ្នាំ ២០០៥-២០០៧ តម្រូវការប្រេងឥន្ធនៈពិភពលោកកើនឡើង ៧% គឺមានចំនួន ៨៤ លានធុងក្នុងមួយថ្ងៃ ។ មួយភាគធំនៃកំនើននេះមានប្រភពពីសហរដ្ឋអាមេរិក និង ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅតំបន់អាស៊ី ជាពិសេសប្រទេសចិន ដែលតំណាងឱ្យ ៣០% នៃ តម្រូវការសរុប ។ កំណើននេះស្រូបយកអស់មួយភាគធំនៃអតិរេកផលិតកម្មរបស់អង្គការអូប៉ិក ដែលបណ្តាលឱ្យទីផ្សារប្រេងងាយរងសម្ពាធពីការផ្គត់ផ្គង់ រយៈពេលខ្លី និង បម្រែបម្រួលតម្រូវ និងវិបត្តិទីផ្សារ ។

**កំណើនតម្រូវការចំពោះផលិតផលប្រើប្រាស់ប្រេងស្រាល** *(Light-oil)* ជាពិសេសប្រេងសាំងសម្រាប់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការធ្វើដំណើរ និងប្រេងម៉ាហ្សូត ។

**បទប្បញ្ញត្តិតឹងរ៉ឹងលើគុណភាព**ផលិតផលប្រេងឥន្ធនៈ ។

**កំណើនថ្លៃដើមឯកតាបន្ថែម**៖ នៅតំបន់អូប៉ិក ភាគច្រើននៃផលិតផលបានមកពីអណ្ដូងប្រេងតូចៗ ដែលមានថ្លៃដើមឯកតាខ្ពស់ ក្នុងខណៈដែលក្នុងប្រទេសមិនមែនសមាជិកអូប៉ិក ផលិតផលជាច្រើនបានមកពីអណ្ដូងប្រេងដែលចាស់ទៅហើយ ហើយដែលច្រើនតែមានថ្លៃដើមឯកតាខ្ពស់ផងដែរ ។

**កត្តាភូមិសាស្ត្រនយោបាយ** ភាពតានតឹង និងជំលោះនៅតំបន់ផលិតប្រេងសំខាន់ៗ ពិសេសនៅមជ្ឈិមបូព៌ា បានបង្កើនឱកាសនៃការអាក់ខានការផ្គត់ផ្គង់ ដែលបានបន្ថែមបុព្វលាភហានិភ័យ ទៅលើតម្លៃប្រេង ។

**ការរួញចុះនៃលទ្ធភាពទប់ស្កាត់** កាលពីអតីតកាល បម្រែបម្រួលផ្គត់ផ្គង់ និងតម្រូវការត្រូវបានសម្រាលដោយកត្តាបីៈ អតិរេកសមត្ថភាពផលិតកម្មក្នុងចំណោមសមាជិកអូប៉ិក សន្និធិប្រេងច្រើន និង អតិរេកសមត្ថភាពចម្រាញ់ ។ លទ្ធភាពទប់ស្កាត់ទាំងបីនេះបាននឹងកំពុងរួញថយចុះ ។ ប្រការនេះនាំឱ្យតម្លៃប្រេងប្រែប្រួលកាន់តែខ្លាំង។

**ការវិនិយោគមិនគ្រប់គ្រាន់ក្នុងការរុករក និងចម្រាញ់** កំសោយសមត្ថភាពចម្រាញ់ប្រេងឆៅធ្ងន់ ឬដែល មានជាតិស៊ុលហ្វួរខ្ពស់ (Heavy or high-sulphur crudes) និង

**ការធ្លាក់ចុះតម្លៃប្រាក់ដុល្លារអាមេរិក** តម្លៃប្រេងស្ទើរតែទាំងអស់កំណត់ជាប្រាក់ដុល្លារ ។ កិច្ចសន្យាប្រេងឆៅក៏ធ្វើឡើងក្នុងរូបិយប័ណ្ណអាមេរិកដែរ ។ ផលិតករបានប្រតិកម្មតបចំពោះការធ្លាក់ចុះតម្លៃនៃប្រាក់ដុល្លារដោយការតម្លើងថ្លៃប្រេង ។

### ៦.៤.២.២. តម្លៃម្ហូបអាហារខ្ពស់

ម្ហូបអាហារបានកើនឡើងទូទាំងពិភពលោក ដោយសារតម្រូវការកើនឡើងលើសពីសមត្ថភាពផ្គត់ផ្គង់ ដែលនាំឱ្យគិតដល់ប្រផ្នូលរបស់លោក **ម៉ាល់ធូស** (Malthus) ។ ការផ្គត់ផ្គង់ម្ហូបអាហារបានក្លាយជាការប្រឈមដ៏ចំបងសម្រាប់សតវត្សទី ២១ ។ ក្នុងឆ្នាំ ២០០៧ យោងតាម **សន្ទស្សន៍អាហារពិភពលោក** របស់ **អង្គការស្បៀង និងម្ហូបអាហារពិភពលោក** តម្លៃនៃផលិតផលប្រើប្រាស់ប្រចាំថ្ងៃបានកើនឡើង ៨៥% គ្រាប់ធុញ្ញជាតិ ៤២% ។ ថ្លៃម្ហូបអាហារលើពិភពលោកបានកើនឡើង ៣៥% ក្នុងមួយឆ្នាំ គិតត្រឹមចុងខែមករា ឆ្នាំ២០០៨ ។ កំណើនថ្លៃដែលបានចាប់ផ្ដើមយឺតៗ កាលពីឆ្នាំ ២០០២ នោះ បាននិងកំពុងតែបង្កើនល្បឿន ។ ក្នុងអំឡុងឆ្នាំ ២០០២-២០០៧ ថ្លៃម្ហូបអាហារបានកើនឡើង ៦៥% ។

សន្និធិស្រូវសាលីលើពិភពលោកបានធ្លាក់ដល់កម្រិតទាបបំផុតក្នុងអំឡុងពេល ៣០ឆ្នាំ ដែលបណ្ដាលមកពីអាកាសធាតុអាក្រក់នៅប្រទេសផលិតករ និងកំណើនតម្រូវការដ៏លឿនពីប្រទេសកំពុងអភិវឌ្ឍន៍លឿន ។ ភាពរាំ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ងស្ងួត ការថយចុះតម្លៃប្រាក់ដុល្លារ ការបង្វែការវិនិយោគទៅលើទំនិញទូទៅ ការបង្វែដីសម្រាប់ដាំដុះគ្រាប់ធុញ្ញជាតិជីវ ឥន្ធនៈ កំណើនប្រជាជន និងកំណើនតម្រូវការពីប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសចិន បានជំរុញឱ្យតម្លាតតម្រូវការ និង ផ្គត់ផ្គង់សម្រាប់ចំណីអាហារកាន់តែឆ្ងាយពីគ្នា ។

**រូបទី ១៦.៥ តម្លៃពិភពលោកនៃចំណីអាហារចំបងៗមួយចំនួន (ដុល្លារក្នុងមួយតោន)**




*ប្រភពៈ ធនាគារអភិវឌ្ឍន៍អាស៊ី*

ការប្ញូកបញ្ចូលគ្នារវាងអាកាសធាតុអាក្រក់នៅប្រទេសបង់ក្លាដេស ជំងឺមមាចត្នោតនៅប្រទេសវៀតណាម និងបញ្ហានយោបាយនៅប្រទេសភូមា (ជាប្រទេសនាំមុខគេខាងនាំចេញស្រូវ-អង្ករ រហូតដល់ទសវត្សរ៍ ឆ្នាំ ៥០) បានរុញតម្លៃស្រូវឱ្យជិតដល់ ១.០០០ ដុល្លារក្នុងមួយតោន ។ នេះជាកម្រិតថ្លៃដែលគេមិនដែលជួបប្រទះឡើយ ចាប់តាំងពីរបកគំហើញវិទ្យាសាស្ត្រនៃបដិវត្តន៍បៃតង នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ដែលបានជួយបង្កើនទិន្នផល និងបន្ថយតម្លៃស្រូវយ៉ាងខ្លាំង មកក្រោមតម្លៃ ៤០០ ដុល្លារក្នុងមួយតោន ។ ថ្លៃនៃផលិតផលកសិកម្មផ្សេងៗទៀត បានកើនឡើងស្រដៀងគ្នានឹងកំណើនថ្លៃអង្ករ ។ នៅប្រទេសវៀតណាម ថ្លៃអង្ករនាំចេញ បានកើនតម្លៃពី ៥០០ ដុល្លារក្នុងមួយតោន នាខែកុម្ភៈ ឆ្នាំ ២០០៨ ដល់ ៧០០ ដុល្លារក្នុងមួយតោននា ខែមីនា ដែលកើនឡើង ៧២ % បើធៀបនឹងឆ្នាំ ២០០៧ ។ នៅប្រទេសកម្ពុជា ថ្លៃអង្ករបានឡើងដល់កម្រិតមិនធ្លាប់មានគឺចន្លោះរវាង ៥០០-៧០០ ដុល្លារក្នុងមួយតោនសម្រាប់តំបន់ខេត្តខាងជើង និង ចន្លោះរវាង ៤០០-៥០០ដុល្លារក្នុង មួយតោនសម្រាប់តំបន់ខេត្តភាគខាងត្បូង នៅចុងខែមិនា ២០០៨ ។

កំណើនថ្លៃម្ហូបអាហារ និងថាមពល បានជំរុញអតិផរណាឱ្យកើតតែខ្ពស់ ទោះជាក្នុងពេលដែលកំណើនមានការថយចុះនៅក្នុងសេដ្ឋកិច្ចរបស់តំបន់អាស៊ីានបូកបី ដែលពឹងផ្អែកយ៉ាងខ្លាំងលើការនាំចូលប្រេង ។ ក្នុងឆ្នាំ ២០០៧ តំបន់នេះបាននាំចូលប្រេងធៅថ្លៃ ២៥៨,១ កោដិដុល្លារ ដែលស្មើរតែស្មើនឹង ១០ ភាគរយ នៃថ្លៃ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាំចូលសរុប ។ ដោយសារចំណីអាហារ និងទំនិញផ្សេងៗសុទ្ធតែឡើងថ្លៃក្នុងកំរិតដែលមិនធ្លាប់មានកំណើន ដ៏ខ្ពស់ថ្លៃដើមនៃធាតុចូល អាចបណ្តាលឱ្យមានវដ្តសង្សារនៃកំណើប្រាក់ឈ្នួលនិងថ្លៃ ដែលបង្កជាការគំរាមកំហែង ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច នៅក្នុងសេដ្ឋកិច្ចតំបន់ ។

បម្រែបម្រួលថ្លៃ និងកង្វះខាតការផ្គត់ផ្គង់អង្ករអាចជះឥទ្ធិពលផ្នែកនយោបាយដល់សេដ្ឋកិច្ចតំបន់អាស៊ាន ។ បរិមាណនៃពាណិជ្ជកម្មស្រូវអង្ករពិភពលោកសរុប ត្រូវបានរំពឹងថានឹងឈានដល់ ២៩,៤ លានតោន ក្នុង ឆ្នាំ ២០០៨ ដែលកើនឡើង ២,១% ធៀបឆ្នាំ ២០០៧ ។ ការនាំចូលមកតំបន់អាស៊ី ត្រូវបានរំពឹងថានឹងកើនឡើង ៧% គឺឈានដល់ ១៣,៥ លានតោន ។ ថ្លៃអង្ករនៅលើពិភពលោកបានកើនឡើងយ៉ាងឆាប់រហ័ស ចាប់តាំងពីចុងឆ្នាំ ២០០៧ ។

## ៦.៥ អតិផរណា និងការគ្រប់គ្រងអតិផរណានៅក្នុងប្រទេសកម្ពុជា

អតិផរណា (មធ្យមប្រចាំឆ្នាំ) កើនពី ៤,៧% ក្នុងឆ្នាំ ២០០៦ ដល់ ៥,៨% ក្នុងឆ្នាំ ២០០៧ ។ កំណើនយ៉ាងលឿននៃថ្លៃប្រេង និងម្ហូបអាហារ ការកើនតម្លៃប្រាក់បាតថៃ និងការធ្លាក់តម្លៃប្រាក់ដុល្លារ បានចូលរួមចំណែកធ្វើឱ្យអតិផរណាកើនឡើង ។ ថ្លៃអង្ករលក់រាយបានកើនឡើង ១៦,៨% ពី ១.៤១០ រៀល ក្នុងមួយគីឡូក្រាម ដល់ ១.៦០២ រៀល ក្នុងមួយគីឡូក្រាម សម្រាប់អង្ករលេខមួយ ដែលឆ្លុះបញ្ចាំងពីកំហិតលទ្ធភាពផ្គត់ផ្គង់ ដោយសារការកើនឡើងការនាំចេញទៅប្រទេសជិតខាង ។ ថ្លៃប្រេងលក់រាយបានកើនឡើង ១០% ក្នុងឆ្នាំ ២០០៦ ក្នុងខណៈដែលប្រេងម៉ាហ្សូតកើន ១៨% ។ ដោយសារប្រទេសកម្ពុជានាំចូលផលិតផលប្រើប្រាស់មួយផ្នែកធំពីប្រទេសថៃឡង់ដ៏ ការកើនតម្លៃប្រាក់បាត ក៏ជាមូលហេតុនាំឱ្យថ្លៃទំនិញប្រើប្រាស់កើនឡើងផងដែរ ។

**រូប ១៦.៦ - អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ (%)**




*ប្រភព: វិទ្យាស្ថានស្ថិតិជាតិ*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងឆ្នាំ ២០០៧ ការប្រែប្រួល CPI ក្នុងរយៈពេល ១២ ខែ បានបង្ហាញនូវកំណើនថ្លៃយ៉ាងខ្ពស់ឃើញមានក្នុងអនុក្រុមចំនួន ៨ ដែលក្នុងនោះអនុក្រុមចំណីអាហារ ភេសជ្ជៈ និងបារី មានកំណើនខ្ពស់បំផុត ១៩,៧% ។ អនុក្រុមការធ្វើដំណើរ និងទូរគមនាគមន៍ បានចូលរួមចំណែកផងដែរក្នុងការកំណើនថ្លៃទូទៅ ដែលកើនឡើង ១៣,១ % ។ អនុក្រុមផ្សេងៗទៀតកើនឡើងក្នុងកម្រិតមធ្យម មានដូចជា សំលៀកបំពាក់ និងស្បែកជើង កើនឡើង ៤,៦% ចលនវត្ថុ និងផ្ទះសំបែងកើនឡើង ៥,៤% និងសេវាសុខភាព កើនឡើង ៥,៥% ។

**រូបទី ១៦ . ៧ សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់ និងអនុសន្ទស្សន៍ (ភាគរយនៃការប្រែប្រួល ឆ្នាំធៀបនឹងឆ្នាំ)**




*ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ*

នៅក្នុងសន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់ អនុក្រុមចំបងៗរួមមាន ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ ដែលតំណាងឱ្យ ៤២,៧% ផ្ទះសំបែង និងទឹកភ្លើង ៣៣,៣% និងការធ្វើដំណើរ និងទូរគមនាគមន៍ ៨,៧% ។ ការកើនឡើងសន្ទស្សន៍អនុក្រុមចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ មានប្រភពចំបងពីកំណើនតម្លៃអង្ករ ត្រី សាច់ និងផ្លែឈើ ។ អង្ករ និងត្រី ជាអាហារមូលដ្ឋានសម្រាប់ប្រជាជនកម្ពុជា ។ ដូចនេះ កំណើនថ្លៃអង្ករ និងត្រី អាចបង្កជាវិបាកសង្គមយ៉ាងធ្ងន់ធ្ងរ ។ ក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កត់ធ្ងន់លើការអភិវឌ្ឍវិស័យកសិកម្ម ស្របពេលដែលធនាគារជាតិកំពុងចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយមីក្រូហិរញ្ញវត្ថុ និងផ្តល់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម ។

ថ្វីត្បិតតែថ្លៃប្រេងខ្ពស់ ប្រទេសកម្ពុជានៅតែអាចគ្រប់គ្រងអតិផរណា និងបន្តកំណើនសេដ្ឋកិច្ច ។ ក្នុងឆ្នាំ ២០០៧ បើទោះជាមានអតិផរណា ៥,៨% ប្រទេសកម្ពុជានៅតែអាចសម្រេចបានកំនើន GDP ក្នុងកម្រិត ៩,៧% ។ ក៏ប៉ុន្តែ ប្រទេសកម្ពុជាជាប្រទេសនាំចូលប្រេង ។ ដូចនេះកំណើនថ្លៃប្រេងនឹងអាចបង្អាក់កំណើនសេដ្ឋកិច្ចជាយថាហេតុ ។ តាមប្រវត្តិកន្លងមក កំណើនសេដ្ឋកិច្ចមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងអតិផរណា ។ ឧទាហរណ៍ ក្នុងចន្លោះឆ្នាំ ១៩៩៥-២០០០ អត្រាមធ្យមនៃអតិផរណាបានស្ថិតក្នុងកម្រិតខ្ពស់ ៦,៤% ក្នុងខណៈដែល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណើនសេដ្ឋកិច្ចមានជាមធ្យម ៧,២% ។ ក្នុងចន្លោះឆ្នាំ ២០០១-២០០៧ អត្រាអតិផរណាស្ថិតក្នុងកម្រិតទាប ត្រឹមតែ ៣,៦% ក្នុងខណៈដែលកំណើនសេដ្ឋកិច្ចមានជាមធ្យម ៩,៦% ។

**រូបទី ១៦ . ៨ កំណើនផ.ស.ស. ពិត និង អតិផរណា**




*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ*

## ៦ . ៥ . ១. ការឆ្លើយតបផ្នែកគោលនយោបាយ ដើម្បីគ្រប់គ្រងអតិផរណា

ការវាយតម្លៃដោយសង្ខេបលើកត្តានានា ដែលអាចនឹងក្លាយជាឧបករណ៍ឆ្លើយតបនឹងអតិផរណាមានដូចខាងក្រោមនេះ÷

អត្រាប្តូរប្រាក់ថេរ មានសារៈសំខាន់ក្នុងការគ្រប់គ្រងអតិផរណា ។ អត្រាប្តូរប្រាក់លុយរៀលត្រូវបានរក្សាឱ្យមានស្ថិរភាពក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ។ កម្រិតនៃដុល្លារូបនីយកម្មហាក់ដូចជាឈានដល់កម្រិតកំពូលដែលមិនទំនងជានឹងបង្កការគំរាមកំហែងដល់កម្រិតអតិផរណានាពេលអនាគតឡើយ ។ ប៉ុន្តែ ហេតុការណ៍អាចផ្ទុយពីការរៀបរាប់ខាងលើ ប្រសិនណាជាមានការបាត់បង់ជំនឿលើប្រាក់រៀល ។

កំណើនថ្លៃប្រេងឥន្ធនៈត្រូវបានបញ្ជូនទៅសន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់ តាមរយៈថ្លៃដើមដឹកជញ្ជូន និង ផលិតកម្ម ។ យើងត្រូវដឹងអោយបានច្បាស់ថែមទៀត នូវរចនាសម្ព័ន្ធធាតុចូល- ធាតុចេញនៃទីផ្សារប្រេងឥន្ធនៈនៅកម្ពុជា និង យន្តការផ្ទេរថ្លៃ ដើម្បីពិចារណាអំពីជម្រើសគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រួតពិនិត្យអតិផរណាអោយមានប្រសិទ្ធភាព ។

ឱនភាពថវិកាទូទៅ អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់អតិផរណា ។ ប៉ុន្តែ គោលនយោបាយហិរញ្ញវត្ថុសាធារណៈចង្អៀតដែលអនុវត្តដោយរាជរដ្ឋាភិបាល ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ជាឧបករណ៍ចំបងនៃ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យុទ្ធសាស្ត្រគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច បានបំបាត់ចោលនូវហានិភ័យខាងលើ ។ ក្នុងទិដ្ឋភាពនៃតួនាទីដ៏ចាំបាច់របស់គោលនយោបាយសារពើពន្ធក្នុងការគ្រប់គ្រងតម្រូវការ ក្នុងបរិស្ថានដុល្លារូបនីយកម្ម គេមិនអាចបន្ធូបន្ថយអភិក្រមយុទ្ធសាស្ត្រនេះបានឡើយ ។

ថ្លៃក្នុងស្រុកមាននិន្នាការកើនឡើងក្នុងរវាងខែមិថុនា-តុលា (រដូវឈប់សំរាក) និងធ្លាក់ចុះ ក្នុងរវាង ខែវិច្ឆិកា- ធ្នូ (រដូវប្រមូលផល) ។ ឥទ្ធិពលនៃរដូវកាលអាចកាត់បន្ថយបានតាមរយៈវិនិយោគបន្ថែម នៅក្នុងទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធថែរក្សាទុក ។

ប្រទេសកម្ពុជានៅតែងាយរងគ្រោះដោយអាកាសធាតុអាក្រក់ បើទោះណាជារដ្ឋាភិបាលបានធ្វើវិនិយោគយ៉ាងក្រាស់ក្រែលទៅលើប្រព័ន្ធធារាសាស្ត្រ ។ ជាយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់កាត់បន្ថយអតិផរណា ប្រទេសកម្ពុជាគួរតែបង្កើនមូលដ្ឋានផលិតកម្ម ជាពិសេសនៅក្នុងវិស័យកសិកម្មដែលចូលរួមចំណែក មួយភាគធំដល់ការប្រើប្រាស់របស់ប្រជាជនក្រីក្រ ។ ការអភិវឌ្ឍន៍បច្ចេកវិទ្យា ដែលអាចជួយសម្រាលភាពងាយរងគ្រោះនៃវិស័យកសិកម្មចំពោះអាកាសធាតុអាក្រក់ខ្លាំង និងវិធានដែលមានការគិតគូរបានម៉ត់ចត់ ដើម្បីកាត់បន្ថយ ឬទប់ទល់នឹងគ្រោះមហន្តរាយជាយថាហេតុ មានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់អតិផរណា និងឥទ្ធិពលអវិជ្ជមានរបស់វា ។

ជាចុងបញ្ចប់ រដ្ឋាភិបាលប្រកបដោយទំនុកចិត្ត នឹងធ្លាប់បង្ហាញពីសមត្ថភាពគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងឆ្លើយតបអតិផរណាបានល្អនឹងជួយបន្ថយការរំពឹងអតិផរណា ។ លក្ខណៈនេះនឹងជួយសម្រួលដល់ការធ្វើអន្តរកាលដ៏ល្អឆ្ពោះទៅកាន់សេដ្ឋកិច្ចប្រាក់រៀល ដើម្បីអាចប្រើបទដ្ឋានគោលនយោបាយរូបិយវត្ថុសម្រាប់ការគ្រប់គ្រង ។

ជាការឆ្លើយតបផ្នែករូបិយវត្ថុចំពោះអតិផរណា សំខាន់បំផុតត្រូវញែកឱ្យដាច់ពីគ្នារវាង កត្តាជាវដ្តដែលបង្កឱ្យមានអតិផរណា និងអតិផរណារំពឹងទុករយៈពេលវែង ។ «វិធីមួយដោះស្រាយគ្រប់បញ្ហា» មិនមែនជាអភិក្រមប្រសិទ្ធភាពក្នុងការរៀបចំគោលនយោបាយរូបិយវត្ថុឡើយ ។ ទិដ្ឋភាពគន្លឹះមួយនៃការរៀបចំគោលនយោបាយរូបិយវត្ថុ គឺ ត្រូវយល់ពីរចនាសម្ព័ន្ធការផ្គត់ផ្គង់រូបិយវត្ថុរយៈពេលខ្លី ។ ចាំបាច់ត្រូវបែងចែកឱ្យដាច់រវាងបម្រែបម្រួលតម្រូវការសរុប និងបម្រែបម្រួលការផ្គត់ផ្គង់សរុប ដើម្បីផ្ទោចគោលនយោបាយរូបិយវត្ថុទប់ទល់នឹងអតិផរណា ។

ក្នុងហេតុការណ៍ដែលតម្រូវការបង្កឱ្យមានអតិផរណា គោលនយោបាយរូបិយវត្ថុគួរសំដៅជំរុញសេដ្ឋកិច្ចឱ្យបង្កើនសមត្ថភាពផលិត ឱ្យកៀកនឹងតម្រូវការ ឬឱ្យអស់សក្តានុពល ។ ប្រសិនណាជា ការផ្គត់ផ្គង់បង្កឱ្យមានអតិផរណា ការឆ្លើយតបគួរសំដៅកែសម្រួលតម្រូវការសរុប ។ ប៉ុន្តែលក្ខណៈនេះ អាចខ្វែងគ្នានឹងគោលបំណងនៃកំណើនសេដ្ឋកិច្ច ។ ជាទូទៅ ធនាគារកណ្តាលគួរតែដាក់ចេញគោលនយោបាយរូបិយវត្ថុ ដែលកាត់បន្ថយជាអតិបរិមានូវគម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវការ បើទោះបីជាគោលដៅចំបងគឺដើម្បីគ្រប់គ្រងអតិផរណាក៏ដោយ ។

ប្រទេសកម្ពុជា ជាប្រទេសតូចមួយ បើកទូលាយ និងមានកម្រិតដុល្លារូបនីយកម្មខ្ពស់ មានគណនីមូលធនសេរី និងអត្រាប្តូរប្រាក់អណ្តែតដោយគ្រប់គ្រង ។ ក្នុងន័យនេះ បើទោះជាមានគោលនយោបាយរូបិយវត្ថុចង្អៀត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក៏ដោយ ក៏មូលធននៅតែបន្តហូរចូល ដែលឆ្លុះបញ្ចាំងពីតម្រូវការវិនិយោគិនចំពោះទ្រព្យសកម្មក្នុងស្រុក និង ការរំពឹងទុកពីសេដ្ឋកិច្ចក្នុងស្រុកដ៏រឹងមាំ ។ លំហូរចូលនៃមូលធន នាំឱ្យតម្លៃទ្រព្យសកម្មកើនឡើង ដែលធ្វើឱ្យបរិស្ថានអតិផរណាបច្ចុប្បន្នកាន់តែធ្ងន់ធ្ងរ លើសភាពធ្ងន់ធ្ងរស្រាប់ ។ លក្ខណៈនេះទាមទារគោលនយោបាយសេដ្ឋកិច្ចប្រុងប្រយ័ត្ន ដែលលើកឡើងក្នុងពេលព្រមៗគ្នា ពីស្ថិរភាពថ្លៃ និងស្ថិរភាពអត្រាប្តូរប្រាក់ និង ការគ្រប់គ្រងលើលំហូរចូលនៃមូលធន ។

## ៦.៥.២. ការឆ្លើយតបផ្នែកគោលនយោបាយរូបិយវត្ថុ ចំពោះអតិផរណា

ទ្រឹស្តីសេដ្ឋកិច្ចបានពិភាក្សាលើឧបករណ៍គោលនយោបាយរូបិយវត្ថុផ្សេងៗ ដើម្បីទប់ទល់អតិផរណា ។ អ្នករូបិយវត្ថុនិយមបានផ្តោតលើការបង្កើនអត្រាការប្រាក់ដើម្បីទប់ទល់អតិផរណា ។ អ្នកទ្រឹស្តី **កេនស៍** បានផ្តោតលើការបន្ថយតម្រូវការទូទៅ ដែលជាទូទៅអនុវត្តតាមរយៈគោលនយោបាយសារពើពន្ធ ដោយបង្កើនពន្ធ ឬបន្ថយចំណាយថវិការដ្ឋ រួមជាមួយនឹងគោលនយោបាយរូបិយវត្ថុ ។ សេដ្ឋវិទូផ្នែកផ្គត់ផ្គង់គាំទ្រការប្រឆាំងអតិផរណាតាមរយៈការកំណត់អត្រាប្តូរប្រាក់រវាងរូបិយវត្ថុក្នុងស្រុក និងរូបិយប័ណ្ណអន្តរជាតិណាមួយ ។ ក្នុងការអនុវត្ត ការទប់ទល់នឹងអតិផរណាទាមទារ កញ្ចប់គោលនយោបាយរូបិយវត្ថុ ហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយផ្សេងៗទៀត ។

**រូបទី ១៦.៩ តួនាទីមានកម្រិតនៃអត្រាការប្រាក់ក្នុងការឆ្លើយតបនឹងអតិផរណា**




*ប្រភព: ធនាគារអភិវឌ្ឍន៍អាស៊ី*

**គោលនយោបាយអត្រាការប្រាក់:** អត្រាការប្រាក់ខ្ពស់ និងកំណើនយឺតៗនៃការផ្គត់ផ្គង់រូបិយវត្ថុជាមធ្យោបាយ ដែលធនាគារកណ្តាលទប់ទល់ ឬបង្ការអតិផរណា ។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងសេដ្ឋកិច្ច


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដុល្លារូបនីយកម្មដូចជាករណីប្រទេសកម្ពុជា គោលនយោបាយអត្រាការប្រាក់មិនមានប្រសិទ្ធភាពឡើយ ។ ពិតណាស់ រូបទី ១៦.៩ បានបង្ហាញថា អត្រាការប្រាក់មិនមានតួនាទីចំបងក្នុងការឆ្លើយតបនឹងអតិផរណានៅក្នុងតំបន់ឡើយ ។ ឧបករណ៍គោលនយោបាយរូបិយវត្ថុផ្សេងទៀតដូចជា **ទុនបម្រុងកាតព្វកិច្ច** អាចប្រើប្រាស់បានដើម្បីទប់ទល់នឹងឥទ្ធិពលអវិជ្ជមាននៃការផ្គត់ផ្គង់រូបិយវត្ថុ ។ ដើម្បីពង្រឹងទំនុកចិត្តសាធារណៈជនទៅលើប្រព័ន្ធធនាគារ ដែលជាកត្តាចាំបាច់បំផុតនៃស្ថិរភាពវិស័យហិរញ្ញវត្ថុ ធនាគារកណ្តាលគួរពង្រឹងសមត្ថភាពស្ថាប័ន និងបង្កើនទំនុកចិត្តលើវិស័យធនាគារដោយកែលម្អការត្រួតពិនិត្យ និងបទប្បញ្ញត្តិធនាគារពាណិជ្ជកម្ម ដោយរួមបញ្ចូលការត្រួតពិនិត្យនៅនឹងកន្លែង ។ ជាងនេះទៅទៀត ធនាគារកណ្តាលគួរត្រួតពិនិត្យមើលហានិភ័យហិរញ្ញប្បទាន និង រៀបចំផែនការពង្រឹងជំហរទុនរបស់ធនាគារ ។

**រូបទី ១៦ . ១០ អត្រាប្តូរប្រាក់សក្តិសិទ្ធពិត (សន្ទស្សន៍ដើម ឆ្នាំ២០០៤ = ១០០)**




[1] Weighted average of a basket of 51 bilateral exchange rates adjusted by relative consumer prices. The weights are derived from manufacturing trade flows. An increase is an appreciation.
Source: Bank for International Settlements.

*ប្រភព: ធនាគារអភិវឌ្ឍន៍អាស៊ី*

ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងបរិស្ថានដែលគ្របដណ្តប់ដោយអតិផរណាមានប្រភពពីថ្លៃដើមផលិតកម្ម ការរឹតត្បិតឥណទានអាចបណ្តាលឱ្យតម្រូវការក្នុងស្រុកធ្លាក់ចុះ ជាពិសេសនៅខណៈដែលឥណទានសម្រាប់បន្តនិរន្តភាព ផ.ស.ស មានការចាំបាច់ ។ លើសពីនេះទៅទៀត គោលនយោបាយរូបិយវត្ថុដើម្បីគ្រប់គ្រងអតិផរណាមិនអាចអនុវត្តបានពេលដែលសម្ពាធតម្លៃមានប្រភពភាគច្រើនពីខាងក្រៅតំបន់ ។ ហានិភ័យដែលនាំឱ្យកំណើនធ្លាក់ទាប អាចមានទំហំធំ ប្រសិនណាបើមិនមានការឆ្លើយតបគោលនយោបាយរូបិយវត្ថុគ្រប់គ្រាន់ ដែលនាំឱ្យកំណើនថ្លៃដែលមានប្រភពពីថ្លៃដើមផលិតកម្ម ជំរុញការរំពឹងទុកពីអតិផរណាកាន់តែខ្លាំងឡើងៗ ដែលជាបន្តទៀត នាំទៅដល់វដ្តសង្សារនៃកំណើនប្រាក់បៀវត្សរ៍និងថ្លៃ បង្កើតស្ថានភាពកាន់តែអាក្រក់ ។ ការឆ្លើយតបទាន់ពេលវេលានិងមានលក្ខណៈបង្ការទុកជាមុន ក្នុងខណៈដែលថ្លៃប្រែប្រួល មានសារៈសំខាន់បំផុតសម្រាប់ទប់ស្កាត់ការរំពឹង

ទុកពីអតិផរណា និងដើម្បីរក្សាទំនុកចិត្តគោលនយោបាយ ដែលជាបន្តធានាបានថាសកម្មភាពសេដ្ឋកិច្ចបន្តតាមគន្លងមួយដែលមានស្ថិរភាពថ្លៃ ។

**គោលនយោបាយអត្រាប្តូរប្រាក់** គោលនយោបាយអត្រាប្តូរប្រាក់ដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចតូច បើកចំហ ជាពិសេស សេដ្ឋកិច្ចដុល្លារូបនីយកម្ម ។ ការទប់ទល់អតិផរណា ទាមទារឱ្យអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារកើនតម្លៃធៀបនឹងអត្រាប្តូរប្រាក់ពិត ។ ការកើនតម្លៃរូបិយវត្ថុ នឹងបន្ថយសម្ពាធអតិផរណាតាមរយៈការកាត់បន្ថយថ្លៃនាំចូល ។ គោលនយោបាយអត្រាប្តូរប្រាក់មានសារៈសំខាន់ណាស់សម្រាប់ប្រទេសដូចជាកម្ពុជា និងសិង្ហបុរី ដែលពឹងផ្អែកយ៉ាងខ្លាំង លើគោលនយោបាយអត្រាប្តូរប្រាក់ ជាឧបករណ៍គោលនយោបាយរូបិយវត្ថុដ៏មានប្រសិទ្ធភាព ។

ការរក្សាលំនឹងអត្រាប្តូរប្រាក់ និងជំហរគោលនយោបាយរូបិយវត្ថុ តាមរយៈការបោះផ្សាយមូលបត្រវិញ ត្រូវចំណាយច្រើនបំផុត បន្ទាប់ពីកំណើនថ្មីៗដ៏សំបើមនៃលំហូរចូលមូលធនឯកជន ។ ទោះជាយ៉ាងនេះក៏ដោយ បើគ្មានការបោះផ្សាយមូលបត្រដើម្បីស្រូបយករូបិយវត្ថុទេនោះ លំហូរចូលមូលធនដ៏ច្រើននឹងបណ្តាលឱ្យរូបិយវត្ថុជាតិឡើងថ្លៃ កំណើនសាច់ប្រាក់លើសលប់ និងតម្លៃទ្រព្យសកម្មពុះកញ្ជ្រោលឡើង ។ គម្លាតកាន់តែធំរវាងអត្រាការប្រាក់រូបិយវត្ថុក្នុងស្រុក និងប្រាក់ដុល្លារ នឹងបន្តទាក់ទាញលំហូរចូលនៃមូលធន ។ ប្រទេសខ្លះក្នុងតំបន់បានអនុវត្តការគ្រប់គ្រងមូលធន ដើម្បីអាចគ្រប់គ្រងលើគោលនយោបាយរូបិយវត្ថុ ។ ប៉ុន្តែ ការគ្រប់គ្រងមូលធនអាចបណ្តាលខូចទំនុកចិត្តវិនិយោគិន និងគួរតែអនុវត្តដោយការប្រុងប្រយ័ត្នបំផុត ។

**រូបទី ១៦.១១ បម្រែបម្រួលអត្រាប្តូរប្រាក់នៅកម្ពុជា**




*ប្រភព: ធនាគារជាតិនៃកម្ពុជា*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការបង្កើតទីផ្សារហិរញ្ញវត្ថុមានប្រសិទ្ធភាព និងមានភាពសំបូរបែបជាងមុន មិនត្រឹមតែអាចជួយតំរង់ទិសមូលធនទៅរកការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ថែមទាំងអាចបង្កើតឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើលំហូរមូលធន និងទុនបម្រុងអន្តរជាតិ ។ ករណីរយៈពេលវែង ការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ និង អនុវត្តកំណែទម្រង់ទីផ្សារ ជាមធ្យោបាយដើម្បីកសាងស្ថិរភាពហិរញ្ញវត្ថុ ។ វិធានការណ៍ដើម្បីអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ឱ្យបានស៊ីជំរៅ ទូលំទូលាយ និងមានតម្លាភាព អាចជំរុញការបែងចែកធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព និង ពង្រឹងសមត្ថភាពប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុក ដើម្បីទប់ទល់វិបត្តិនៃការគំរាមកំហែង ដែលបណ្ដាលមកពីភ័យតាមគ្នារបស់វិនិយោគិនអន្តរជាតិ ។

## ៦.៥.៣. ការឆ្លើយតបផ្នែកគោលនយោបាយហិរញ្ញវត្ថុសាធារណៈចំពោះអតិផរណា

ដោយសារតួនាទីនៃគោលនយោបាយរូបិយវត្ថុមានកម្រិត នៅក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មកម្ពុជា គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ផ្ដល់ជាឧបករណ៍ដ៏មានសក្ដានុពលដើម្បីទប់ទល់នឹងអតិផរណា ។ ជំហរថវិកាបែបអភិរក្ស នៅប៉ុន្មានឆ្នាំចុងក្រោយនេះ បានចូលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការគ្រប់គ្រងអតិផរណា ។ ទិដ្ឋភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាខាងក្រោម មានការពាក់ព័ន្ធយ៉ាងខ្លាំង ដល់ការទប់ទល់នឹងអតិផរណា៖

គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រយ័ត្នប្រយែងក្នុងចន្លោះឆ្នាំ ២០០៤-២០០៧ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណើនសេដ្ឋកិច្ចខ្ពស់បាននាំឱ្យចំណូលកើនឡើង និងចំណាយមានភាពល្អប្រសើរ ។ លក្ខណៈសម្បត្តិនេះ បង្កើតឱ្យមានអតិរេកថវិកាសមស្រប ដែលអាចប្រើប្រាស់សម្រាប់ទប់ទល់នឹងការស្រុតចុះកំណើន ដែលបណ្ដាលមកពីការគំរាមកំហែងនៃអតិផរណា ។ កំណែទម្រង់សារពើពន្ធបានដាក់ឱ្យដំណើរការប្រព័ន្ធស្ថិរភាពស្វ័យប្រវត្តិ (Automatic Stabilizers) ។ ប្រសិនបើកំណើនសេដ្ឋកិច្ចធ្លាក់ចុះ ប្រព័ន្ធស្ថិរភាពស្វ័យប្រវត្តិ នឹងបន្ថយឥទ្ធិពលអវិជ្ជមានទៅលើវិស័យធុរកិច្ច និងផ្ដល់លទ្ធភាពឱ្យសេដ្ឋកិច្ចងើបឡើងវិញបានឆាប់រហ័ស ។

គោលនយោបាយថវិកាផ្ដោតលើអភិក្រមថវិកាប្រកបដោយតុល្យភាព ។ សម្រាប់ផ្នែកចំណូល កំណើនយឺតអាចនាំឱ្យចំណូលធ្លាក់ចុះ ។ ការបញ្ចុះអត្រាពន្ធនាំចូលបណ្ដោះអាសន្ន លើមុខទំនិញប្រើប្រាស់ដែលមានវេទយិតភាពបំផុត អាចត្រូវបានអនុវត្តដើម្បីបន្ថយចំណាយពន្ធរបស់ជនក្រីក្រ ។ វិធានការណ៍នេះ អាចនាំឱ្យបាត់បង់ចំណូលថវិកា ។ សម្រាប់ផ្នែកចំណាយ សកម្មភាពបន្ទាប់បន្សំអាចត្រូវបានអនុវត្តយ៉ាងឆាប់បំផុត នៅក្នុងថវិកាឆ្នាំ ២០០៨ ដើម្បីធានាថា ចំណាយផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ផ្ដោតចំទិសដៅក្រុមប្រជាជនដែលងាយរងគ្រោះ និងជៀសវាងការខ្វះខាតថវិកា ។ ការបង្កើនឧបត្ថម្ភកធនទៅលើថាមពលប្រើប្រាស់ និងការឱ្យរួចពន្ធលើការនាំចូលប្រេង អាចត្រូវអនុវត្តបន្ត ដើម្បីបន្ថយឥទ្ធិពលអតិផរណាដែលមានប្រភពពីការនាំចូល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៦.៥.៤ ការគ្រប់គ្រងឥទ្ធិពលអតិផរណានៃតម្លៃប្រេងខ្ពស់

ការកើនថ្លៃប្រេង គឺនាំឱ្យមានអតិផរណា សម្រាប់គ្រប់ប្រទេសនាំចូលប្រេង ដោយសារវាជ្រាបចូលសព្វរចនាសម្ព័ន្ធធាតុចូល- ធាតុចេញ ។ ឥទ្ធិពលអតិផរណា មានលក្ខណៈធ្ងន់ធ្ងរ ជាពិសេសសម្រាប់ប្រទេសកម្ពុជា ក្នុងទិដ្ឋភាពនៃរចនាសម្ព័ន្ធផលិតកម្មដែលប្រើប្រាស់ថាមពលច្រើន ។ ឥទ្ធិពលនេះ ត្រូវតែគ្រប់គ្រងដោយប្រុងប្រយ័ត្នដែលរួមមាន ÷

១. កំណត់កម្រិត «ការផ្ទេរ» កំណើនថ្លៃប្រេងទៅជាតម្លៃក្នុងស្រុក

២. ឧបត្ថម្ភកធនអាជីវកម្មថាមពល ដើម្បីទប់ទល់ការផ្ទេរថ្លៃប្រេងខ្ពស់ទៅជាថ្លៃថាមពល

**តារាង ១៦.៤- របៀបគណនាពន្ធនាំចូលនៅកម្ពុជា**

| Types of Taxes | Tax Calculation |
|---|---|
| **1– Gasoline**<br>-Tax base:<br>-Import Tax<br>-Additional Tax<br>-Excise Tax<br>-VAT<br>-Taxes payable | <br>CIF = 309 USD/T (1T=1390L)<br>CD = 309 × 35% = 108.15USD<br>AT = 1390L × 0.02USD = 27.80USD<br>ST =(309USD+108.15USD+27.80)×33.33%= 148.30USD<br>VAT= (309+108.15+27.80+148.3+3.80)×10% = 59.71USD<br>Total = 343.96USD |
| **2- Kerosene**<br>-Tax base:<br>-Import Tax<br>-Excise Tax<br>-VAT<br>-Taxes payable | <br>CIF = 230 USD/T (1T=1250L)<br>CD = 2030× 7% = 16.10USD<br>ST = (230USD+16.10USD)×10% = 24.61USD<br>VAT = (230+16.10+24.61+3.80)×10% = 27.45USD<br>Total = 68.16USD |
| **3- Diesel Oil**<br>-Tax base:<br>-Import Tax<br>-Additional Tax<br>-Excise Tax<br>-VAT<br>-Taxes payable | <br>CIF = 267 USD/T (1T=1190L)<br>CD = 267 × 35% = 40.05USD<br>AT = 1190L × 0.04USD = 47.60USD<br>ST = (267USD+40.05USD+47.60)×4.35% = 15.43USD<br>VAT = (267+40.05+47.60+15.43+3.80)×10% = 37.39USD<br>Total = 140.47USD |
| **4- Fuel Oil**<br>-Tax base:<br>-Import Tax<br>-VAT<br>-Taxes payable | <br>CIF = 129 USD/T (1T=1050L)<br>CD = 129USD × 7% = 9.03USD<br>VAT = (129+9.03+3.80)×10% = 14.18USD<br>Total = 23.21USD<br>Gas and lubricants are also subject to the above taxation procedures. |

*ប្រភពៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

រដ្ឋាភិបាលបានផ្តល់ឧបត្ថម្ភកធន ១៧០ លានដុល្លារជំនួសអ្នកប្រើប្រាស់នៅក្នុងឆ្នាំ ២០០៧ តាមរយៈការឱ្យរួចពន្ធ ។ នៅក្នុងឆ្នាំ ២០០៨ ការឱ្យរួចពន្ធត្រូវបានប៉ាន់ប្រមាណក្នុងកម្រិតទឹកប្រាក់ ២៤០ លានដុល្លារ ។ ការផ្ទេរកំណើនថ្លៃប្រេងទៅជាថ្លៃក្នុងស្រុក ត្រូវបន្ថយដោយការកំណត់មូលដ្ឋានយកពន្ធតាមថ្លៃរដ្ឋបាល ៣០២ ដុល្លារ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងមួយតោន ។ ក្នុងឆ្នាំ ២០០៧ អ្នកនាំចូលបង់ពន្ធ ៣៨៤ ដុល្លារ ក្នុងប្រេងមួយតោន ។ នៅក្នុងឆ្នាំ ២០០៧ អ្នកនាំចូលបានបង់ពន្ធចំនួន ៣៨៤ ដុល្លារក្នុងមួយតោនប្រេង ដោយឈរលើមូលដ្ឋានថ្លៃរដ្ឋបាល ៣០២ ដុល្លារ បើទោះបីជាថ្លៃទីផ្សារកើនឡើងលើសពី ១០០០ ដុល្លារ មួយតោនក៏ដោយ ។ ដើម្បីបន្ថយឥទ្ធិពលនៃថ្លៃប្រេងខ្ពស់ទៅលើប្រជាជនក្រីក្រ រាជរដ្ឋាភិបាលបានកំណត់ពន្ធទាបលើការនាំចូលប្រេងម៉ាស៊ូត (៧ សេនសម្រាប់ពន្ធនាំចូល បើប្រៀបនឹង ៣៥ សេន សម្រាប់ប្រេងសាំង អាករលើតម្លៃបន្ថែម ១០% បើប្រៀបនឹង ៣៣,៣៣ % សម្រាប់ប្រេងសាំង) ។ រដ្ឋាភិបាលមិនបានយកអាករបន្ថែម លើការនាំចូលប្រេងម៉ាស៊ូតឡើយ ។ តារាងទី ១៦.៤ ពន្យល់ពីរូបមន្ត ដែលប្រើសម្រាប់គណនាពន្ធលើផលិតផលប្រេងនៅក្នុងឆ្នាំ ២០០៧ ។ ដើម្បីបន្ថយឥទ្ធិពលនៃតម្លៃប្រេងខ្ពស់ទៅលើថ្លៃថាមពល រដ្ឋាភិបាលបានផ្តល់ឧបត្ថម្ភកធនក្នុងចន្លោះឆ្នាំ ១៩៩៩ ដល់ ២០០៧ ដល់ក្រុមហ៊ុនអគ្គិសនីកម្ពុជាចំនួន ៣៧,៥ លានដុល្លារ ។ ទំហំនៃឧបត្ថម្ភកធន បានកើនឡើងយ៉ាងលឿនក្នុងចន្លោះឆ្នាំ ២០០៥ ដល់ ២០០៧ ។ ក្នុងឆ្នាំ ២០០៨ ដោយប្រមើលមើលពីថ្លៃប្រេងខ្ពស់ រដ្ឋាភិបាលបានរៀបចំគម្រោងឧបត្ថម្ភកធនរហូតដល់ ៤១ លានដុល្លារ ។

### ៦.៥.៥. វិធានការរដ្ឋបាល

ឧបត្ថម្ភកធន និងការគ្រប់គ្រងថ្លៃប្រេងជាចំណាត់ការរដ្ឋបាលដ៏ទូទៅបំផុត ដែលត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងអតិផរណា ។ ប៉ុន្តែ ការកំណត់ថ្លៃរដ្ឋបាល និង ឧបត្ថម្ភកធន អាចត្រឹមបានសម្រាលកំណើនថ្លៃប្រេងលើទីផ្សារ តែមិនបានផ្តល់ជាដំណោះស្រាយយូរអង្វែងឡើយ ដោយសារនេះជាបញ្ហាអតុល្យភាពរវាងតម្រូវការ និងការផ្គត់ផ្គង់ ។ ក្នុងន័យនេះ ចំណាត់ការរដ្ឋបាល និងឧបត្ថម្ភកធនគួរអនុវត្តបណ្តោះអាសន្ន ដោយមានគោលដៅច្បាស់លាស់ដើម្បីធ្វើបន្ថយវិរូបកម្មទីផ្សារឱ្យទាបបំផុត ។ ជាឧទាហរណ៍ ប្រសិនបើឧបត្ថម្ភកធនលើចំណីអាហារ និងប្រេងមានលក្ខណៈអចិន្ត្រៃយ៍ នោះគ្មានការលើកទឹកចិត្តឱ្យកែលម្អសេដ្ឋកិច្ច ដែលជាដំណោះស្រាយយូរអង្វែងលើបញ្ហាអតុល្យភាព ។ លើសពីនេះទៅទៀត ឧបត្ថម្ភកធនចំណីអាហារ និងថាមពលអាចនឹងបន្ថយលំហសារពើពន្ធសម្រាប់វិញ្ញាបនសេដ្ឋកិច្ចដែលថមថយ និងបន្ថយចំណាយសាធារណៈ ។

ក្នុងរយៈពេលមធ្យមទៅវែង ចំណាត់ការរដ្ឋបាលអាចរាំងស្ទះដល់ការកែតម្រូវឡើងវិញ និងបង្កឱ្យមានវិរូបកម្មសេដ្ឋកិច្ចធ្ងន់ធ្ងរ ។ ជាឧទាហរណ៍ ការកំណត់ថ្លៃម្ហូបអាហារទាប មិនលើកទឹកចិត្តកសិករឱ្យផលិតច្រើនបង្កឱ្យមានកង្វះខាត និងបង្កជាសម្ពាធអតិផរណាបន្ថែមទៀត ។

ការគ្រប់គ្រងប្រាក់បៀវត្សរ៍ ឬគោលនយោបាយចំណូល ជាបច្ចេកទេសមួយទៀតក្នុងការគ្រប់គ្រងថ្លៃ ។ ក្នុងខណៈដែលឧបករណ៍នេះអាចត្រូវបានប្រើប្រាស់ដើម្បីទប់ទល់អន្តរកម្មប្រាក់បៀវត្សរ៍ ចំណាត់ការនេះមានលក្ខណៈធ្ងន់ធ្ងរ និងមិនលើកទឹកចិត្តឱ្យធ្វើការងារ ដែលអាចបណ្តាលឱ្យមានវិបាកសង្គមដ៏អាក្រក់ ។ ឧបករណ៍នេះជាទូទៅ មិនមានប្រសិទ្ធភាពទេនៅក្នុងទីផ្សារសេរី ដែលដំណើរការជាមួយនឹងយន្តការថ្លៃ និងជារឿងកម្របំផុតដែលត្រូវបានគេយកមកប្រើប្រាស់ក្នុងការទប់ទល់អតិផរណា ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៦.៥.៦. ការសន្សំសំចៃថាមពល និង ការធ្វើពិពិធកម្មប្រភពថាមពល

ដោយសារទីផ្សារប្រេងអន្តរជាតិមានសភាពតានតឹងនាពេលអនាគត ប្រទេសកម្ពុជាដែលជាប្រទេសនាំចូលប្រេង គួរពិចារណាលើការសន្សំសំចៃថាមពល ដោយ (១) ការបន្ថយឧបត្ថម្ភកធន និងទាញឱ្យថ្លៃប្រេងក្នុងស្រុកអោយត្រូវគ្នានឹងថ្លៃអន្តរជាតិ ដើម្បីកាត់បន្ថយការប្រើប្រាស់ខ្ជះខ្ជាយ (២) ចៀសវាងការធ្វើឱ្យខូចថ្លៃ និងចំណាត់ការរដ្ឋបាលទៅលើថ្លៃដែលមិនមានប្រសិទ្ធភាព (៣) ការដាក់ពន្ធ និងលើកទឹកចិត្តទីផ្សារ ដើម្បីជំរុញការប្រើប្រាស់ថាមពលឱ្យមានប្រសិទ្ធភាព និង (៤) ការជំរុញឱ្យមានការប្រកួតប្រជែងលើទីផ្សារថាមពល ដែលលើកទឹកចិត្តដល់ការបង្កើតថ្មីក្នុងវិស័យថាមពល ។

តម្លៃប្រេងខ្ពស់បានជំរុញឱ្យមានផលិតកម្មលើប្រភពថាមពលផ្សេងៗទៀត ។ ប្រទេសកម្ពុជាបានចូលរួមក្នុងទីផ្សារជីវៈឥន្ធនៈ ។ ទំនាក់ទំនងរវាងថ្លៃជីវៈឥន្ធនៈ និងប្រេងឥន្ធនៈ មានភាពជិតស្និតយ៉ាងខ្លាំង ។ ពេលដែលថ្លៃប្រេងកើនឡើង ថ្លៃជីវៈឥន្ធនៈក៏កើនឡើងដែរ ។ ក្នុងឆ្នាំ ២០០៧ និង ២០០៨ ថ្លៃពោត និងម្សៅមីកើនឡើងដែលជាលទ្ធផលនៃកំណើនតម្រូវការនាំចេញ ។ កត្តាបង្កឱ្យមានកំណើនថ្លៃទូទៅ លើផលិតផលកសិកម្ម ដោយសាររាល់ថ្លៃផលិតផលកសិកម្មមានទំនោរប្រែប្រួលក្នុងទិសដៅដូចគ្នា ។ កសិករជាទូទៅទទួលបានអត្ថប្រយោជន៍ពីបម្រែបម្រួលនេះ ។ ផលិតកម្មជីវៈឥន្ធនៈ មានលក្ខណៈទាក់ទាញបំផុតក្នុងន័យពាណិជ្ជកម្ម ប៉ុន្តែកាត់បន្ថយផលិតកម្មចំណីអាហារ និងនាំទៅដល់ស្ថានភាពចំណេញស្មើខាត (Zero-sum game) ។

ការផលិតថាមពលរបស់កម្ពុជាពឹងផ្អែកជាចំបងលើរោងចក្រដើរដោយប្រេងសាំង និងប្រេងម៉ាស៊ូត ។ ដើម្បីការពារអ្នកប្រើប្រាស់ ពីថ្លៃថាមពលខ្ពស់ រដ្ឋាភិបាលបានជំរុញឱ្យមានការធ្វើពិពិធកម្មប្រភពថាមពល ដោយលើកស្ទួយឱ្យមានការវិនិយោគលើវារីអគ្គិសនី និងរោងចក្រធ្យូងថ្ម ក៏ដូចជានាំចូលអគ្គិសនីពីប្រទេសវៀតណាម និងថៃឡង់ដ៍ ។ រដ្ឋាភិបាលក៏បានជំរុញវិនិយោគលើខ្សែបណ្តាញថាមពលជាតិ ព្រោះវាផ្តល់ថាមពលថោកជាងថាមពលដែលទទួលបានពីការផលិតដាច់ៗ ។ គោលដៅ គឺដើម្បីកាត់បន្ថយថ្លៃអគ្គិសនីមកត្រឹមប្រហែល ១១ សេនក្នុងមួយគីឡូវ៉ាតម៉ោង ត្រឹមឆ្នាំ ២០១១ ។ ការប្រើប្រាស់ប្រភពថាមពលផ្សេង ដូចជាប្រព័ន្ធព្រះអាទិត្យ កាកសំណល់កសិកម្ម ដូចជាកាកអំពៅ អង្កាម និងកំទេចឈើ ត្រូវបានលើកទឹកចិត្ត ។

### ៦.៥.៧ កម្មវិធីសកម្មភាពដើម្បីទប់ទល់សម្ពាធអតិផរណាដែលកើនឡើង

ដើម្បីឆ្លើយតបទៅនឹងកំណើនអតិផរណា រដ្ឋាភិបាលបានអនុវត្តវិធានការណ៍ដូចខាងក្រោម៖

- ជាបណ្តោះអាសន្នចែកស្បៀងដល់ជនក្រីក្រនៅជនបទ ។ វិធានការណ៍នេះទប់ស្កាត់ភាពអាសន្ន និង ទាញថ្លៃអង្ករពី ១០០០ ដុល្លារក្នុងមួយតោនមកត្រឹម ៥០០ ដុល្លារវិញ ។
- បញ្ចេញមូលនិធិបន្ថែមចំនួន ១០ លានដុល្លារដើម្បីរក្សាការផ្គត់ផ្គង់អង្ករនាពេលអនាគត ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ផ្អាកការនាំអង្ករចេញរយៈពេលពីរខែ ដើម្បីរក្សាការផ្គត់ផ្គង់អង្ករ ។

វិធានការផ្សេងទៀតអាចត្រូវបានអនុវត្ត ដូចជាពន្ធលើការនាំចេញអង្ករ រួមមានវិធានការសារពើពន្ធដែលស្របគ្នានឹងបទប្បញ្ញត្តិរបស់អង្គការពាណិជ្ជកម្មអន្តរជាតិ ក្នុងខណៈដែលវិធានការណ៍មិនមែនសារពើពន្ធដូចជា អាជ្ញាប័ណ្ណនាំចេញ និងការផ្អាកនាំចេញបណ្តោះអាសន្ន ដែលត្រូវបានចាត់ទុកថាជា ការបំពានលើរបបពាណិជ្ជកម្មនៃអង្គការពាណិជ្ជកម្មពិភពលោក ។ ទោះជាយ៉ាងនេះក៏ដោយ ការយកពន្ធខាងលើមិនទទួលបាននូវការគាំទ្រពីប្រជាកសិករឡើយ ។

បរិស្ថាននៃអតិផរណាខ្ពស់នាពេលបច្ចុប្បន្ន បង្កឱ្យមានការជជែកក្នុងកម្រិតគោលនយោបាយលើហេតុផលនៃការបន្តសេដ្ឋកិច្ចដុល្លារូបនីយកម្ម ។ ដុល្លារូបនីយកម្មមានន័យថាបាត់បង់អំណាចគ្រប់គ្រងលើ គោល-នយោបាយរូបិយវត្ថុ ។ ប៉ុន្តែដោយសារ ៩៥ % ទៅ ៩៧% នៃប្រតិបត្តិការធនាគារ ធ្វើឡើងជារូបិយប័ណ្ណដុល្លារ ការដូរមកជាប្រព័ន្ធរូបិយវត្ថុរៀលនាពេលនេះមិនមែនជាជម្រើសថិតថេរយូរអង្វែងឡើយ ។ អតិផរណាបច្ចុប្បន្នបណ្តាលមកពីសម្ពាធកំណើនថ្លៃ និងតម្រូវការ ។ ដោយសារប្រទេសកម្ពុជានាំចូលមួយផ្នែកធំនៃទំនិញប្រើប្រាស់ ការភ្ជាប់ប្រាក់រៀលទៅនឹងដុល្លារធ្វើឱ្យសេដ្ឋកិច្ចងាយរងគ្រោះពីតិផរណាខាងក្រៅ ។ ប៉ុន្តែការភ្ជាប់ប្រាក់រៀលទៅនឹងដុល្លារធ្វើឱ្យធនាគារជាតិអាចបង្កើនទុនបម្រុងអន្តរជាតិ និងរក្សាបានការប្រកួតប្រជែងលើការនាំចេញ ជាថ្នូរនឹងការបង្កើនការផ្គត់ផ្គង់រូបិយវត្ថុជាតិ និងកំណើនតម្រូវការ ។ ការអនុញ្ញាតឱ្យប្រាក់រៀលឡើងថ្លៃបន្តិចម្តងៗ អាចជាជម្រើសមួយដើម្បីគ្រប់គ្រងអតិផរណា ។ ប៉ុន្តែកម្មករនិយោជិតកម្ពុជាមួយចំនួនទទួលប្រាក់បៀវត្សរ៍ជាប្រាក់ដុល្លារ។ ការធ្វើឱ្យអំណាចទិញធ្លាក់ចុះចំពោះប្រជាពលរដ្ឋដែលទទួលប្រាក់បៀវត្សរ៍ជាប្រាក់ដុល្លារ ក៏ជារឿងមួយមិនអាចទទួលបានឡើយ ។ ក្នុងន័យនេះ យើងត្រូវពិចារណាពីជម្រើស ដោយផ្អែកលើអនុគមន៍សុខមាលភាព រវាងការភ្ជាប់ប្រាក់រៀលទៅនឹងដុល្លារ និងការអនុញ្ញាតឱ្យប្រាក់រៀលឡើងថ្លៃធៀបនឹងប្រាក់ដុល្លារ ។

វិធានការណ៍ទប់ទល់នឹងអតិផរណា គួរត្រូវបានពិចារណាក្នុងលក្ខណៈជាចង្កោមគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ និងចំណាត់ការរដ្ឋបាលដែលមានគោលដៅបន្ថយថ្លៃដើម និងបន្ថយតម្រូវការសរុប។ គោលនយោ-បាយក្នុងការបង្កើនការផ្គត់ផ្គង់ផលិតផលកសិកម្ម មានសារៈសំខាន់បំផុតដើម្បីកាត់បន្ថយសម្ពាធអតិផរណា ។

**គោលនយោបាយរូបិយវត្ថុ** បង្កើនទុនបម្រុងសម្រាប់ធនាគារពាណិជ្ជពី ៨ ទៅ ១១% និងអាចច្រើនជាងនេះ អាចបន្ថយឥណទានសម្រាប់វិស័យឯកជន ដែលកើនឡើងយ៉ាងលឿនក្នុងចន្លោះឆ្នាំ ២០០៥-២០០៧។ កត្តានេះអាចជះឥទ្ធិពលប្រយោល និងលើរូបិយវត្ថុក្នុងចរាចរណ៍ (M2) ។ ដោយសារប្រទេសកម្ពុជាបើកចំហ មានរបបគណនីមូលធនសេរី ការបង្កើនទុនបម្រុងនឹងមិនបញ្ឈប់ការហូរចូលនៃមូលធនឡើយ ។ រូបិយវត្ថុក្នុងចរាចរណ៍អាចបន្តកើនឡើង ប៉ុន្តែធនាគារពាណិជ្ជអាចប្រឈមនឹងកំណើនប្រាក់ទុនបម្រុង ដែលមិនទទួលបានការប្រាក់នៅធនាគារជាតិ ។ លទ្ធផលនៃចំណាយអន្តរការីធនាគាខ្ពស់ ដែលមិនលើកទឹកចិត្តការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**គោលនយោបាយអត្រាប្តូរប្រាក់** ការអនុញ្ញាតឱ្យប្រាក់រៀលឡើងថ្លៃបន្តិចម្តងៗ អាចនាំឱ្យការនាំចូល គិតជាប្រាក់រៀលថោកជាងមុន ប៉ុន្តែមិនបានបង្ហាញពីបញ្ហាចំបង ដែលថាអតិផរណាកើតឡើងដោយសារការថយចុះតម្លៃប្រាក់ដុល្លារ និងកំណើនតម្លៃប្រេង និងចំណីអាហារ ។ អ្នកទទួលបានអត្ថប្រយោជន៍ គឺប្រជាជនដែលរកចំណូលជាប្រាក់រៀល និងទិញទំនិញនាំចូល ។ អ្នកទទួលការខាតបង់ គឺ ប្រជាជនដែលរកចំណូលជាប្រាក់ដុល្លារ រួមមាន អ្នកនាំចូល និងអ្នកកាន់ប្រាក់ដុល្លារ ។ លើកលែងតែទិញទំនិញដែលនាំមកពីសហរដ្ឋអាមេរិក ពួកគេនឹងយល់ឃើញថា អំណាចទិញធ្លាក់ចុះ ។ ដោយសារតែប្រជាជនកម្ពុជាភាគច្រើនទុកប្រាក់ដុល្លារ ជាឧបករណ៍សន្សំ វិធានការនេះមិនទទួលបានការពេញចិត្តឡើយ ។ ក៏ប៉ុន្តែ ការអនុញ្ញាតឱ្យប្រាក់រៀលឡើងថ្លៃ អាចជំរុញភ្នាក់ងារសេដ្ឋកិច្ចឱ្យប្តូរមកប្រើប្រាស់ប្រាក់រៀល និងធ្វើបដិដុល្លារូបនីយកម្ម ។

**គោលនយោបាយសារពើពន្ធ** ការរក្សាជំហរសារពើពន្ធរឹងមាំ តាមរយៈវិធានការជំរុញការប្រមូលចំណូល ការលើកលែងពន្ធជាបណ្តោះអាសន្នលើផលិតផលដែលងាយនាំឱ្យមានអតិផរណា ការផ្តល់ឧបត្ថម្ភធនលើការផលិតថាមពល និងរក្សាចំណាយឱ្យសមស្រប ដោយកំណត់គោលដៅចំណាយលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច និងកាត់បន្ថយចំណាយខ្ជះខ្ជាយ ។

**ចំណាត់ការរដ្ឋបាល** គួរត្រូវអនុវត្តនូវវិធានការរដ្ឋបាលជាបណ្តោះអាសន្នប៉ុណ្ណោះ ដោយមានគោលដៅកំណត់ច្បាស់លាស់ ដើម្បីឱ្យវិរូបកម្មទីផ្សារមានកម្រិតអប្បបរិមា ។ ក៏ប៉ុន្តែ ការបង្កើនចំណាយឧបត្ថម្ភធនលើចំណីអាហារ និង ថាមពលអាចជំរុញកំណើនសេដ្ឋកិច្ច តែនឹងកាត់បន្ថយចំណាយសាធារណៈដទៃទៀត ។

**បន្តពង្រឹងវិស័យហិរញ្ញវត្ថុ** តាមរយៈការធ្វើសវនកម្មនៃស្ថាប័នហិរញ្ញវត្ថុ ដោយធ្វើការកែលម្អថែមទៀត ដើម្បីធានាថាស្ថាប័នទាំងនេះមិនបំពានលើ **បទប្បញ្ញត្តិប្រយ័ត្នប្រយែង** (Prudential norms) ។ គួរយកចិត្តទុកដាក់ផងដែរ ដើម្បីកុំអោយធនាគារពាក់ព័ន្ធខ្លាំងពេកនឹងវិស័យអចលនវត្ថុ ជាពិសេសតាមរយៈការផ្តល់ឥណទានសម្រាប់ពាណិជ្ជកម្មដីធ្លី ដើម្បីកេងយកចំណេញ ។

ជាការសន្និដ្ឋាន ថ្លៃកសិផលខ្ពស់សម្រាប់ប្រទេសកសិកម្មដូចកម្ពុជា មិនមែនជាបញ្ហាអាក្រក់នោះទេ ។ បញ្ហាប្រឈមគឺ ត្រូវគ្រប់គ្រងកំណើនថ្លៃអោយបានសមស្រប ដើម្បីផ្តល់ការលើកទឹកចិត្តដល់ផលិតករ ដោយមិនត្រូវអោយខាតបង់ដល់សុខមាលភាពរបស់អ្នកប្រើប្រាស់ធ្ងន់ធ្ងរពេកទេ ។ ក៏ប៉ុន្តែ ដោយសមត្ថភាពផលិតមានកម្រិតធៀបនឹងតម្រូវការសរុប នឹងនាំឱ្យមានអតិផរណាកើតឡើង ។ ក្នុងរយៈពេលវែង កត្តានេះនឹងបង្កើនសមត្ថភាពបង្កបង្កើនផលនៃសេដ្ឋកិច្ចជាតិ ។ អតិផរណាអាចកើតមានដែរក្នុងពេលសេដ្ឋកិច្ចនៅទ្រឹង ។ ដូចនេះ ការអនុវត្តគោលនយោបាយរូបិយវត្ថុ គួរឈរលើការវិភាគលើអតិផរណាដែលកើតឡើងដោយថ្លៃ ឬ ដោយតម្រូវការ ។

អតិផរណានាពេលបច្ចុប្បន្ន គឺ ជាលទ្ធផលនៃកត្តាពីររួមគ្នា គឺកំណើនថ្លៃដើម និងកំណើនតម្រូវការ ។ ការពឹងផ្អែកទាំងស្រុងលើការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ប្រហែលជាមិនផ្តល់លទ្ធផលដូចការរំពឹងទុកទាំង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រុងនោះទេ ដោយសារតែវិធានការនេះមិនបានដោះស្រាយពីមូលហេតុ ដែលនាំអោយមានការឡើងនៃថ្លៃដើមផលិតកម្ម តែវាអាបណ្តាលអោយកំណើនសេដ្ឋកិច្ចធ្លាក់ចុះទៅវិញ ។ ក៏ប៉ុន្តែ គោលនយោបាយរូបិយវត្ថុចង្អៀតក្នុងកម្រិតណាមួយសមល្មម អាចកាត់បន្ថយកម្រិតតម្រូវការដ៏ច្រើនលើសលុប ។ ការកែតម្រូវការផ្គត់ផ្គង់ជាដំណោះស្រាយយូរអង្វែងដើម្បីទប់ទល់អតិផរណា ។ កំណែទម្រង់រចនាសម្ព័ន្ធគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅត្រូវតែបានអនុវត្ត ដើម្បីកសាងនូវបរិស្ថានអំណោយផលសម្រាប់ការវិនិយោគ និងធុរកិច្ច ។ កត្តានេះរួមមានការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ច និងទីផ្សារនាំចេញ ការពង្រឹងវិស័យហិរញ្ញវត្ថុ ការអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធគ្រប់ជ្រុងជ្រោយ ដើម្បីកែលម្អប្រសិទ្ធភាព និងសមត្ថភាពប្រកួតប្រជែង ការលុបចោលរបាំងបទប្បញ្ញត្តិដែលមិនចាំបាច់ ការផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន ការជំរុញអភិបាលល្អក្នុងផ្នែកធុរកិច្ច ការបង្កើតបរិស្ថានស្មើភាពគ្នាសម្រាប់គ្រប់វិស័យ និង ការជម្រុញការប្រកួតប្រជែងដើម្បីអភិវឌ្ឍសមត្ថភាពស្ថាប័ន ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ជំពូកទី ១៧
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ១. សេចក្តីផ្តើម

ផលប៉ះពាល់ម៉ាក្រូសេដ្ឋកិច្ចនៃចំណាយថវិកា ការយកពន្ធ និង បំណុលសាធារណៈ គឺសារៈសំខាន់ខ្លាំងណាស់ ហើយចាំបាច់ត្រូវតែគ្រប់គ្រងដោយប្រុងប្រយ័ត្ន ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈមានឥទ្ធិពលទៅលើតម្រូវការសរុប ការបែងចែកទ្រព្យសម្បត្តិ និង សមត្ថភាពរបស់សេដ្ឋកិច្ចក្នុងការផលិតទំនិញ និងសេវា។ នៅក្នុងរយៈពេលខ្លី ការផ្លាស់ប្តូរនៃចំណាយ ឬ ពន្ធអាចធ្វើអោយប្រែប្រួល ទាំងបរិមាណ និង របៀបរបបនៃតម្រូវការទំនិញ និង សេវា ។ ក្នុងរយៈពេលយូរ គោលនយោបាយហិរញ្ញវត្ថុសាធារណៈមានផលប៉ះពាល់លើការបែងចែកនូវធនធាន និង សមត្ថភាពផលិតភាពនៃសេដ្ឋកិច្ច តាមរយៈឥទ្ធិពលរបស់វាទៅលើប្រាក់ចំណេញពីកត្តាផលិតកម្ម ការវិនិយោគនៅក្នុងបច្ចេកវិទ្យា ការអភិវឌ្ឍធនធានមនុស្ស និង វិភាជន៍នៃចំណាយមូលធន ។ តាមរយៈផលប៉ះពាល់ទៅលើប្រាក់ចំណេញសុទ្ធពីកំលាំងពលកម្ម សញ្ជ័យ និង ការវិនិយោគ អត្រាពន្ធមានឥទ្ធិពលផងដែរ ទៅលើកត្តាផ្គត់ផ្គង់ និង ជម្រើសនៃបច្ចេកទេសផលិតកម្ម ។

ជារួម មានទស្សនៈពីរនៅក្នុងវិទ្យាសាស្ត្រម៉ាក្រូសេដ្ឋកិច្ច ពាក់ព័ន្ធនឹងសមត្ថភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើអោយមានស្ថិរភាព ឬ មានឥទ្ធិពលទៅលើសកម្មភាពសេដ្ឋកិច្ច÷

- **ទស្សនៈទីមួយ**- យល់ឃើញថា សេដ្ឋកិច្ចដែលដំណើរការនៅចំណុចធាតុចេញសក្តានុពល នឹងវិលត្រឡប់យ៉ាងឆាប់រហ័សទៅចំណុចសមតានៃសមត្ថភាពពេញលេញវិញ នៅគ្រប់កាលទេសទាំងអស់ដែលវិបល្លាសរំកិលវាពីចំណុចអនិកម្មភាពពេញលេញ ។ ដូចនេះ ការផ្លាស់ប្តូរនៅក្នុងនយោបាយហិរញ្ញវត្ថុសាធារណៈមានសក្តានុពលតិចតួចណាស់ ក្នុងការធ្វើអោយសេដ្ឋកិច្ចមានស្ថិរភាព ។

- **ទស្សនៈទីពីរ**- យល់ឃើញថា ភាពបរាជ័យទីផ្សារដែលបណ្តាលអោយសេដ្ឋកិច្ចត្រូវកែសម្រួលដោយលំបាកលំបិន នៅពេលមានវិបល្លាសសេដ្ឋកិច្ច ។ ភាពបរាជ័យនេះរួមមាន អវត្តមាននៃការរំពឹងគិតមុនអំពីតម្រូវការទីផ្សារ ជាពិសេសតម្រូវការក្នុងពេលអនាគតនៃទំនិញ និងសេវា ។ នៅក្នុងពេលដែលគ្មានព័ត៌មាននេះ ផលិតករអាចកាត់បន្ថយការជួលពលកម្ម និងការវិនិយោគមូលធន ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈអាចជួយសម្រួលផលប៉ះពាល់នៃវិបល្លាសបែបនេះ តាមរយៈការលើកទឹកចិត្ត (ការកាត់បន្ថយពន្ធ) និង វិនិយោគសាធារណៈ ។

ជារួម ឥទ្ធិពលរបស់សេដ្ឋកិច្ចទៅលើគោលនយោបាយហិរញ្ញវត្ថុសាធារណៈ អាស្រ័យទៅលើស្ថានភាពថាតើសេដ្ឋកិច្ចកំពុងដំណើរការដោយមានអនិកម្មភាពពេញលេញ ឬ នៅក្រោមសមត្ថភាពផលិតរបស់ខ្លួន ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ២. គោលនយោបាយហិរញ្ញវត្ថុសាធារណៈ: ក្របខ័ណ្ឌទស្សនទាន

**គោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាគោលនយោបាយរបស់រដ្ឋាភិបាល ដែលមានគោលបំណងកាច់ចង្កូតតម្រង់ទិសសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនឬកាត់បន្ថយចំណាយថវិការដ្ឋ ឬ ការបង្កើន ឬ កាត់បន្ថយពន្ធ** ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានលក្ខណៈខុសពីប្រភេទគោល-នយោបាយសេដ្ឋកិច្ចសំខាន់ៗដទៃទៀត ដូចជា **គោលនយោបាយរូបិយវត្ថុ ដែលមានគោលបំណងធ្វើអោយមានស្ថិរភាពសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់អត្រាការប្រាក់ និង ការផ្គត់ផ្គង់រូបិយប័ណ្ណ** ។

គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏អាចអោយនិយមន័យថាជា «**យន្តការនៃការប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈរបស់ជាតិ ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់**» ។ លោក Adam Smith បានលើកឡើងពីគោលការណ៍គ្រឹះនេះថា ÷ « *គោលការណ៍នៃភាពប្រុងប្រយ័ត្ន នៅក្នុងការគ្រប់គ្រងគ្រួសារឯកជនមួយ អាចយកទៅអនុវត្តនៅក្នុងអាណាចក្រមួយ*» (Premchand 1983) ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈផ្តល់នូវមធ្យោបាយសម្រាប់ប្រទេសជាតិ ដើម្បីបំពេញនូវការទទួលខុសត្រូវរបស់ខ្លួនខាងផ្នែកហិរញ្ញវត្ថុ។

គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម័យទំនើប ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃទ្រឹស្តីរបស់សេដ្ឋវិទូអង់គ្លេសដ៏ល្បីល្បាញម្នាក់ឈ្មោះ លោក **ចន ម៉ៃណាដ កេនស៍** (John Maynard Keynes) ដែលលោកបានសសេរនៅក្នុងស្នាដៃដ៏ល្បីល្បាញរបស់លោក គឺ «**ទ្រឹស្តីទូទៅស្តីពីអនិកម្មភាព ការប្រាក់ និង រូបិយវត្ថុ**» ។ **កេនស៍**បានធ្វើការវិភាគ និង ផ្តល់នូវអនុសាសន៍ពាក់ព័ន្ធនឹងគោលនយោបាយសេដ្ឋកិច្ច ដើម្បីដោះស្រាយនូវមហាវិបត្តិសេដ្ឋកិច្ច ក្នុងអំឡុងទសវត្ស ឆ្នាំ ១៩៣០ ក្នុងគោលដៅរិះរកមធ្យោបាយដើម្បីស្រោចស្រង់លទ្ធិមូលធននិយមអោយរស់រានមានជីវិតឡើងវិញ ជាពិសេស អោយសេដ្ឋកិច្ចមូលធននិយម អាចរកច្រកផ្លូវចេញពីវិបត្តិដ៏សាហាវនេះ ។ យោងតាមទស្សនៈសេដ្ឋកិច្ចកេនស៍និយម រដ្ឋាភិបាលអាចមានឥទ្ធិពលលើតម្រូវការសរុបដោយការបង្កើន ឬ បន្ថយអត្រាពន្ធ និង ដោយបង្កើន ឬ បន្ថយចំណាយថវិកា ។ តាមរយៈការប្រើប្រាស់នូវឧបករណ៍រួមផ្សំនៃគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ រដ្ឋាភិបាលអាចបង្កើននូវការប្រើប្រាស់ និង ការវិនិយោគ និង បង្កើតការងារនៅក្នុងសេដ្ឋកិច្ចដែលដំណើរការទាបជាងសមិទ្ធកម្មរបស់ខ្លួន ។ ទោះបីទស្សនៈភាគច្រើនរបស់ **កេនស៍** ត្រូវបានយកទៅអនុវត្តនៅក្នុងសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ក៏ដោយ ក៏ក្របខណ្ឌវិភាគរបស់ **កេនស៍** ចំពោះតម្រូវការសរុប ក៏អាចប្រើប្រាស់បាននៅក្នុងសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ ។

**គោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាការប្រើប្រាស់ពន្ធ ចំណាយថវិកា និង ប្រតិបត្តិការបំណុលសាធារណៈ** ដើម្បីកាច់ចង្កូតសកម្មភាពសេដ្ឋកិច្ចនៃប្រទេស អោយតម្រង់ទិសដៅទៅតាមការចង់បាន ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈពាក់ពន្ធ័ជាមួយនឹងការវិភាជន៍ធនធាន រវាងផ្នែកសាធារណៈ និង ផ្នែកឯកជន និងការប្រើប្រាស់នូវធនធានទាំងនេះ សម្រាប់ការសម្រេចបាននូវស្ថិរភាព និង កំណើន (Premchand 1983) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**គោលនយោបាយហិរញ្ញវត្ថុសាធារណៈ** មានឥទ្ធិពលលើអនិកម្មភាព ស្ថិរភាពថ្លៃ សញ្ជ័យ ការវិនិយោគ និងជញ្ជីងទូទាត់ ។ ការពិភាក្សាលើគោលនយោបាយហិរញ្ញវត្ថុសាធារណៈផ្តោតទៅលើផលប៉ះពាល់នៃថវិកាជាតិទៅលើអញ្ញត្តិម៉ាក្រូសេដ្ឋកិច្ច មានដូចជា ផសស (GDP) អនិកម្មភាព និង អតិផរណា ។ ជាពិសេស ការផ្លាស់ប្តូរកម្រិត និង សមាសភាពពន្ធអាករ និង ចំណាយថវិការដ្ឋ អាចមានឥទ្ធិពលទៅលើអញ្ញត្តិម៉ាក្រូសេដ្ឋកិច្ចដូចខាងក្រោម៖

- តម្រូវការសរុប និង កម្រិតនៃសកម្មភាពសេដ្ឋកិច្ច
- គំរូនៃការបែងចែកធនធាន
- ការបែងចែកប្រាក់ចំណូល

**គោលនយោបាយហិរញ្ញវត្ថុសាធារណៈ** អាចប្រកាន់យកនូវជំហរបីសំខាន់ៗ គឺ ភាពអព្យាក្រឹត្យ ការពង្រីក និង ការបង្រួម៖

- **គោលនយោបាយហិរញ្ញវត្ថុសាធារណៈអព្យាក្រឹត្យ:** មានន័យថាថវិកាមានតុល្យភាព ដោយចំណាយថវិការដ្ឋ **G** ស្មើនិងចំណូលពន្ធ **T** **(G = T)** ។ ចំណាយថវិកាធ្វើហិរញ្ញប្បទានដោយពេញលេញដោយ ចំណូលថវិកា ហើយលទ្ធផលនៃការអនុវត្តថវិកា មានឥទ្ធិពលអព្យាក្រឹត្យសម្រាប់សកម្មភាពសេដ្ឋកិច្ច ។
- **គោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក** (Expansionary) : នាំអោយចំណាយថវិកាកើនឡើង **(G > T)** ដោយសារការកើនឡើងនៃចំណាយថវិការដ្ឋ ឬ ដោយសារការធ្លាក់ចុះនៃចំណូលថវិកា ឬ ដោយសារកត្តាទាំងពីររួមគ្នា ។ គោលនយោបាយនេះនឹងនាំអោយមានឱនភាពថវិកាកាន់តែធំ ឬ ក៏ធ្វើអោយអតិរេកធ្លាក់ចុះ ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក ជាធម្មតានឹងធ្វើអោយមាន **ឱនភាពថវិកា** ។
- **គោលនយោបាយហិរញ្ញវត្ថុសាធារណៈបង្រួម** (Contractionary) : **(G < T)** កើតមានឡើងនៅពេលដែល ចំណាយថវិការដ្ឋសុទ្ធត្រូវបានកាត់បន្ថយ តាមរយៈកំណើនចំណូលពន្ធកាន់តែខ្ពស់ ឬ ការកាត់បន្ថយចំណាយថវិការដ្ឋ ឬ ដោយសារកត្តាទាំងពីររួមគ្នា ។ ប្រការនេះនឹង កាត់បន្ថយឱនភាពថវិកា ឬ កំណើនអតិរេកថវិកា បើប្រៀបធៀបជាមួយនឹងថវិកាឆ្នាំមុន ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈបង្រួម ជាធម្មតានឹងអោយមាន **អតិរេកថវិកា** ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣. គោលដៅនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

គោលដៅចម្បងនៃ**គោលនយោបាយហិរញ្ញវត្ថុសាធារណៈ** គឺ ការស្វែងរកស្ថិរភាពរូបនីយកម្មដែលពាក់ព័ន្ធដល់ ផែនការនីយកម្មថវិកា និង ការវាយតម្លៃប្រកបដោយជវភាពនៃការអនុវត្តថវិកា និង ផលប៉ះពាល់របស់វា ។ ការគ្រប់គ្រងតម្រូវការសរុប គឺជា មុខងាររយៈពេលខ្លីនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានយកមកប្រើសម្រាប់ជំរុញតម្រូវការសរុប ក្នុងគោលដៅធានាអោយបានទីផ្សារសម្រាប់ទំនិញ និងសេវា ដោយលើកទឹកចិត្តដល់ការប្រើប្រាស់កម្លាំងពលកម្ម និងមូលធនដើម្បីបង្កើនការងារ ។

នៅក្នុងបរិបទនៃការអភិវឌ្ឍ គោលដៅមួយទៀតនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ បង្កើនន្ទូវលំហូរនៃសញ្ច័យអោយទៅដល់ផ្នែករដ្ឋាភិបាល ដើម្បីធ្វើហិរញ្ញប្បទានចំណាយអភិវឌ្ឍន៍ និងផ្តល់នូវហេដ្ឋា-រចនាសម្ព័ន្ធដើម្បីលើកស្ទួយកំណើនសេដ្ឋកិច្ច ។ ហេតុដូចនេះគោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានគោល-បំណង ធ្វើអោយមានស្ថិរភាព នៅក្នុងសេដ្ឋកិច្ចដែលកំពុងមានកំណើន ។

គោលដៅទីបីនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ ធានានូវការបែងចែកប្រាក់ចំណូលប្រកបដោយសមធម៌ ក្នុងចំណោមប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ ។ បើទោះបីជាការប្រើប្រាស់នូវ គោលនយោបាយហិរញ្ញវត្ថុសាធារណៈតែឯកឯងនឹងមិនអាចកាត់បន្ថយ នូវវិសមភាព ដែលកើតចេញមកពីគោលនយោបាយរដ្ឋាភិបាល និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលជម្រុញដោយទីផ្សារក៏ដោយ ក៏ប៉ុន្តែ ប្រសិនបើយើងអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដោយគួបផ្សំជាមួយនឹងគោលនយោបាយសង្គមកិច្ចដទៃទៀត និង កំណែទម្រង់ យើងអាចជួយកែលម្អ និង ធានានូវសមភាពនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចបាន ។ នៅក្នុងកម្រិតអប្បរមា គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវមានគោលដៅកាត់បន្ថយនូវវិសមភាពក្នុងកម្រិតតំបន់ និង តាមវិស័យ ។

## ៤. ផលប៉ះពាល់សេដ្ឋកិច្ចនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**ឧបករណ៍ទាំងបី**ដ៏សំខាន់នៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ **ចំណាយថវិកា ពន្ធដារ** និង **កម្ចី** ។ ការរៀបចំដ៏ហ្មត់ចត់ និង គ្រប់ជ្រុងជ្រោយនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ តម្រូវអោយកំណត់នូវអត្តសញ្ញាណកម្មនៃទិដ្ឋភាពផ្សេងៗនៃហិរញ្ញវត្ថុសាធារណៈ ដោយរាប់បញ្ចូលផងដែរនូវការរៀបចំ និង ការអនុវត្តថវិកា ប្រព័ន្ធសារពើពន្ធ ផលប៉ះពាល់ និងការផ្លាស់ប្តូរនៃចំណាយថវិកា និង ពន្ធ និង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

### *៤.១. គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង តម្រូវការសរុប*

គោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេសអភិវឌ្ឍន៍ ជាធម្មតាតែងតែពាក់ព័ន្ធជាមួយនឹង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការគ្រប់គ្រងតម្រូវការសរុប ដើម្បីធ្វើនិយ័តកម្មនៃសកម្មភាពសេដ្ឋកិច្ច និង កាត់បន្ថយនិកម្មភាព ។ នៅក្នុងប្រទេសអភិវឌ្ឍន៍ គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានប្រើប្រាស់ ដើម្បីកាត់បន្ថយជាអតិបរិមានូវផលប៉ះពាល់នៃវដ្តអាជីវកម្មទៅលើសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយនូវការឡើងចុះញឹកញាប់នៃតម្រូវការ ។ នៅពេលមានវិបត្តិសេដ្ឋកិច្ច ដែលធ្វើអោយតម្រូវការចុះខ្សោយ រដ្ឋាភិបាលអាចអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក ក្នុងគោលដៅបង្កើនធាតុចេញ អោយត្រលប់មកដល់កម្រិតធម្មតារបស់វាវិញ និង បង្កើតការងារសម្រាប់កម្មករ ដែលអត់ការងារធ្វើ និង ប្រើប្រាស់នូវមូលធនវិញ ។ នៅពេលដែលសេដ្ឋកិច្ចកើនឡើងខ្លាំងនៅពេលដែល អតិផរណាបានក្លាយទៅជាបញ្ហាប្រឈមខ្លាំងជាងបញ្ហានិកម្មភាព រដ្ឋាភិបាលអាចអនុវត្តនូវអតិរេកថវិកា ក្នុងគោលដៅកាត់បន្ថយកំណើនសេដ្ឋកិច្ច ។ ដូច្នេះ គោលនយោបាយហិរញ្ញវត្ថុសាធារណៈផ្ទុយនឹងវដ្តអាជីវកម្ម (Countercyclical) នឹងជួយអោយថវិកាសម្រេចបាននូវតុល្យភាពនៅក្នុងកម្រិតមធ្យម ។

ហិរញ្ញវត្ថុសាធារណៈពង្រីក អាចកើតមានឡើងតាមច្រកពីរ គឺ៖

**ទីមួយ-** រដ្ឋាភិបាលបង្កើនចំណាយ ដោយរក្សាពន្ធអោយនៅដដែល

**ទីពីរ-** រដ្ឋាភិបាលកាត់បន្ថយពន្ធ ឬ បង្កើនការផ្ទេរជំនួយអោយប្រជាជន ដែលនឹងធ្វើអោយចំណូលក្រោយកាត់ពន្ធរបស់ប្រជាពលរដ្ឋកើនឡើង ដែលនឹងបង្កើនការប្រើប្រាស់ ។

ផលប៉ះពាល់ទីមួយនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក គឺ បង្កើននូវតម្រូវការទំនិញនិងសេវា។ កំណើនតម្រូវការនេះនឹងបង្កើនទាំងធាតុចេញ និង ថ្លៃទំនិញ ។ កម្រិតដែលធ្វើអោយកំណើនតម្រូវការ នាំអោយមានកំណើនធាតុចេញ និងថ្លៃនេះ គឺវាអាស្រ័យទៅលើរាងនៃខ្សែកោងការផ្គត់ផ្គង់សរុប និង សភាពនៃខួបអាជីវកម្ម។ ប្រសិនបើខ្សែកោងការផ្គត់ផ្គង់សរុបក្លាយទៅជាខ្សែឈរវិញ នៅពេលដែលខិតជិតដល់ចំណុចធាតុចេញសក្តានុពលនោះកំណើននៃតម្រូវការសរុប នឹងធ្វើអោយមានអតិផរណា ដោយធាតុចេញកើនយ៉ាងតិចតួច ។ ខ្សែកោងការផ្គត់ផ្គង់សរុបទំនងជាមានរាងរាបស្មើ នៅពេលដែលសេដ្ឋកិច្ចកំពុងជួបវិបត្តិ ដោយសារមានសមត្ថភាពផលិតភាពដែលនៅទំនេរ និង កំលាំងកម្មករដែលអត់ការងារធ្វើ ។ កំណើនតម្រូវការនៅក្នុងស្ថានភាពនេះ ភាគច្រើននឹងនាំអោយមានកំណើនធាតុចេញយ៉ាងខ្លាំង ដោយគ្មានការផ្លាស់ប្តូរនៃកម្រិតថ្លៃច្រើនឡើយ ។

ក៏ប៉ុន្តែគួរអោយស្តាយ ផលប៉ះពាល់នៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីកអាចនឹងទូទាត់ជាមួយនឹងផលប៉ះពាល់បង្រួមនៃកំណើនអត្រាការប្រាក់ ដែលបណ្តាលមកពីការធ្វើហិរញ្ញប្បទានឱនភាពថវិកា ។ មូលនិធិសម្រាប់ធ្វើហិរញ្ញប្បទានឱនភាពថវិកា បានមកពីកម្ចីសាធារណៈ (ដូចជា ការបោះផ្សាយនូវសញ្ញាប័ណ្ណរដ្ឋ) កម្ចីពីបរទេស ឬ ការបោះពុម្ពនិងដាក់អោយចរាចរនូវក្រដាសប្រាក់ថ្មីជាដើម ។ នៅពេលដែលរដ្ឋាភិបាលធ្វើហិរញ្ញប្បទានឱនភាព តាមរយៈកម្ចីពីទីផ្សារសាធារណៈ នោះនឹងនាំអោយមានកំណើនអត្រាការប្រាក់នៅលើទីផ្សារ ដោយសារការកាត់បន្ថយវិនិយោគឯកជន និង ការរឹតបន្តឹងនៃលក្ខខណ្ឌផ្តល់ឥណទាន ។ ប្រការនេះនឹងនាំអោយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការវិនិយោគ និងការប្រើប្រាស់ត្រូវកាត់បន្ថយ ។ អត្រាការប្រាក់ខ្ពស់នឹងលើកទឹកចិត្តដល់សញ្ចយ តែមិនលើកទឹកចិត្តដល់ការវិនិយោគ និងការប្រើប្រាស់ឡើយ ។ ហេតុដូចនេះ ផលប៉ះពាល់ទាំងពីរនៃឱនភាពថវិកាអាចមានចលនាបញ្ច្រាស់ទិសគ្នា ហើយយើងមិនអាចធ្វើការសន្និដ្ឋានទុកជាមុនបានឡើយថា តើផលប៉ះពាល់ណាមួយនឹងមានកម្លាំងខ្លាំងជាងគេ ។

នៅពេលដែលរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក តាមរយៈការកាត់បន្ថយពន្ធ ឬ ការបង្កើនការប្រើប្រាស់ នោះវានឹងបង្កើនតម្រូវការសរុប ។ ក៏ប៉ុន្តែ កំណើនខ្លាំងពេកនៃតម្រូវការសរុបដោយគ្មានវិធានការទប់ស្កាត់នឹងនាំអោយមានអតិផរណា ។ ហេតុដូចនេះ រដ្ឋាភិបាលត្រូវបង្កើតឡើងនូវយន្តការត្រួតពិនិត្យ ។ បញ្ហាមួយទៀត គឺ គម្លាតដ៏ឆ្ងាយដែលមិនអាចប៉ាន់ស្មានបាន រវាងការអនុវត្តនូវគោលនយោបាយ និងលទ្ធផលនៃគោលនយោបាយ ដែលស្តែងចេញនៅក្នុងសេដ្ឋកិច្ច ។

គោលនយោបាយហិរញ្ញវត្ថុសាធារណៈក៏អាចផ្លាស់ប្តូរផងដែរ នូវសមាសភាពនៃតម្រូវការសរុប ។ នៅពេលដែលរដ្ឋាភិបាលធ្វើហិរញ្ញប្បទានឱនភាពថវិកា រដ្ឋាភិបាលដកហូតចេញនូវធនធានពីផ្នែកឯកជន ហើយប្រើប្រាស់នូវធនធាននោះជាថ្មី ដែលនាំអោយមានផលប៉ះពាល់ក្នុងវិភាជន៍ឡើងវិញនូវធនធាននេះនៅក្នុងសេដ្ឋកិច្ច ហើយផលប៉ះពាល់លើភាពស័ក្តិសិទ្ធ និងសុខមាលភាពនៃវិភាជន៍ឡើងវិញបែបនេះមិនមានអ្វីច្បាស់លាស់ទេ ។

នៅក្នុងសេដ្ឋកិច្ចបើកចំហ គោលនយោបាយហិរញ្ញវត្ថុសាធារណៈក៏ជះឥទ្ធិពលផងដែរទៅលើអត្រាប្តូរប្រាក់ និង ជញ្ជីងពាណិជ្ជកម្ម ។ នៅក្នុងករណីអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក អត្រាការប្រាក់នឹងកើនឡើង ដោយសារកម្ចីរបស់រដ្ឋាភិបាលទាក់ទាញនូវលំហូរចូលនៃមូលធនបរទេស ។ កំណើននៃលំហូរនូវរូបិយប័ណ្ណបរទេសចូលក្នុងប្រទេស នឹងបណ្តាលអោយថ្លៃនៃរូបិយវត្ថុជាតិកើនឡើង ពោលគឺធ្វើអោយអត្រាប្តូរប្រាក់កើនឡើង ។ ការកើនឡើងនៃអត្រាប្តូរប្រាក់នឹងធ្វើអោយថ្លៃទំនិញនាំចូលចុះថោកជាងមុន ចំណែកឯទំនិញនាំចេញទៅក្រៅប្រទេសនឹងកាន់តែថ្លៃជាងមុន ។ ប្រការនេះនឹងធ្វើអោយភាពប្រកួតប្រជែងរបស់ប្រទេសនឹងធ្លាក់ចុះ ។ ដោយកំណើនអត្រាប្តូរប្រាក់ធ្វើអោយការនាំចូលថោក និង ការនាំចេញថ្លៃ នោះតុល្យភាពពាណិជ្ជកម្មនឹងធ្លាក់ចុះ ។ ទំនិញនាំចូលហូរចូលមកកាន់តែច្រើនពីបរទេស ហើយទំនិញនាំចេញហូរចេញកាន់តែតិចៗទៅ ។ វិនិយោគិនបរទេសនឹងទិញទ្រព្យសកម្មកាន់តែច្រើនឡើងៗនៅក្នុងប្រទេស ។ ក្នុងករណីនេះ ការធ្លាក់ចុះនៃជញ្ជីងចរន្តត្រូវបានទូទាត់ដោយការពង្រឹងជញ្ជីងមូលធន ។ ការគិតគូរបៀបនេះ គឺជាបេះដូងនៃ **គំរូដែលមានគម្លាតពីរ** របស់ Chenery ដែលក្នុងនោះ គម្លាតរវាងវិនិយោគ និង សញ្ចយ ស្មើនឹងឱនភាពគណនីចរន្ត ។

សេដ្ឋវិទូបុរាណនិយម និង កេនស៍និយមមានទស្សនៈផ្សេងគ្នាអំពីឥទ្ធិពលនៃការផ្លាស់ប្តូរពន្ធទៅលើតម្រូវការសរុប ។ សេដ្ឋវិទូបុរាណនិយមសន្មតថា ការផ្លាស់ប្តូរនៃបរិមាណប្រាក់បង់ពន្ធ គ្មានឥទ្ធិពលអ្វីឡើយទៅលើសញ្ចយជាតិ ហេតុដូចនេះវាគ្មានផលប៉ះពាល់ទៅលើខ្សែកោង IS ឬ តម្រូវការសរុបឡើយ ។ ពួកគេទាត់ចោលនូវការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការប្រើប្រាស់នូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឬ មធ្យោបាយ

ឯទៀត ដើម្បីធ្វើអោយខួបអាជីវកម្មមានភាពរលូន ។

សេដ្ឋវិទូកេនស៍និយមយល់ឃើញថា ការកាត់បន្ថយពន្ធនឹងជំរុញលើកទឹកចិត្តអោយមានការប្រើប្រាស់ ដោយសារប្រាក់ចំណូលក្រោយកាត់ពន្ធកើនឡើង និង សញ្ជ័យជាតិនឹងធ្លាក់ចុះ ។ ស្ថានភាពនេះ គឺជាការវិវត្ត ដែលគួរអោយចង់បាន នៅពេលដែលតំរូវការសរុបចុះខ្សោយ នៅក្នុងពេលពេលដែលសេដ្ឋកិច្ចមានវិបត្តិ ។ ការបង្កើននូវចំណាយថវិកាក៏នឹងនាំអោយមានផលប៉ះពាល់ដូចគ្នានេះដែរ ។ មេគុណការប្រើប្រាស់នឹងបណ្តាល អោយធាតុចេញកើនឡើង ប្រសិនបើមានសមត្ថភាពផលិតកម្មនៅទំនេរចោលឥតប្រើការ ។ ក៏ប៉ុន្តែ សេដ្ឋវិទូខាងផ្នែកអភិវឌ្ឍន៍បានចង្អុលបង្ហាញថា នៅពេលដែលគ្មានសមត្ថភាពទំនេរចោលឥតប្រើការ ការបង្កើន ដោយសាមញ្ញនូវចំណាយសាធារណៈ នឹងធ្វើអោយមានអតិផរណា ។

ស្វម្បីតែសេដ្ឋវិទូកេនស៍និយមក៏ទទួលស្គាល់ថា ការប្រើប្រាស់គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជាឧបករណ៍ស្ថិរភាវូបនីយកម្ម ពិតជាផ្តល់ផលវិបាកពីរយ៉ាងគឺៈ

- **ទីមួយ**- បញ្ហាសំខាន់គឺកង្វះខាតនូវភាពទន់ភ្លន់ នៅក្នុងការប្រើនូវឧបករណ៍គោលនយោបាយហិរញ្ញវត្ថុ សាធារណៈ ។ ថវិកាគឺ ជាឧបករណ៍គោលនយោបាយ ដែលមានគោលបំណងច្រើន ក្រៅពីស្ថិរភាវូបនីយកម្ម ម៉ាក្រូសេដ្ឋកិច្ចៈ ឧទាហរណ៍ បញ្ហាសន្តិសុខ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសង្គមជាដើម ។ ចំណាយ ថវិកាត្រូវធានាដើម្បីអនុវត្តគម្រោងដែលមានអាយុកាលពីរឬបីឆ្នាំ ។ ដូចនេះ ការអនុវត្តនូវគោលនយោបាយ ហិរញ្ញវត្ថុសាធារណៈពង្រីក ឬ បង្រួម ក្នុងគោលដៅស្ថិរភាវូបនីយកម្មម៉ាក្រូសេដ្ឋកិច្ច ពិតជាមានការលំបាក ។ រដ្ឋមានការងាយស្រួលក្នុងការបង្កើន ឬ កាត់បន្ថយពន្ធ ជាងចំណាយ ។ ក៏ប៉ុន្តែ ច្បាប់ស្តីពីសារពើពន្ធក៏មាន គោលដៅច្រើនផ្សេងៗគ្នាដែរ ។
- **ទីពីរ**- គម្លាតពេលវេលាយ៉ាងយូររវាង ការសំរេចចិត្តអនុវត្តនូវឧបករណ៍គោលនយោបាយហិរញ្ញវត្ថុ សាធារណៈ និង ការអនុវត្តជាក់ស្តែងនៃគោលនយោបាយនេះ ដោយសារចំណាត់ការនយោបាយមានភាព យឺតយ៉ាវ ។ នៅពេលដែលគេចាប់ផ្តើមអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រឆាំងនឹងវិបត្តិ សេដ្ឋកិច្ចនៅពេលនោះវិបត្តិប្រហែលជាត្រូវចប់រួចទៅហើយ ។

មធ្យោបាយមួយដើម្បីជៀសវាងបញ្ហាកង្វះខាតនូវភាពទន់ភ្លន់ និង គម្លាតរយៈពេលដ៏យូរ នៅក្នុងការ អនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺត្រូវបង្កើតឡើងនូវ **ឧបករណ៍ស្ថិរភាពភូបនីយកម្មដោយ ស្វ័យប្រវត្តិ** នៅក្នុងថវិកា ។ **ឧបករណ៍ស្ថិរភាពភូបនីយកម្មដោយស្វ័យប្រវត្ត** គឺជាបទប្បញ្ញត្តិ ពិសេសនៅក្នុងច្បាប់ថវិកា ដែលអនុញ្ញាតអោយបង្កើនចំណាយ ឬ បញ្ចុះពន្ធដោយស្វ័យប្រវត្តិ ដោយមិនចាំ បាច់ត្រូវឆ្លងរដ្ឋសភា ដើម្បីអនុវត្តនូវគោលនយោបាយប្រឆាំងនឹងវដ្តអាជីវកម្ម (Countercyclical)។ នៅពេលដែលសេដ្ឋកិច្ចកើនឡើង ពន្ធនឹងកើនឡើង ហើយការចំណាយធ្លាក់ចុះ ហើយនៅពេលមានវិបត្តិសេដ្ឋកិច្ច ចំណាយនឹងកើនឡើង ហើយពន្ធ នឹងធ្លាក់ចុះ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឧទាហរណ៍មួយនៃ **ឧបករណ៍ស្ថិរភាពរូបនីយកម្មដោយស្វ័យប្រវត្តិ**នោះ គឺ ប្រាក់ឧបត្ថម្ភសម្រាប់និកម្មជន ។ រដ្ឋាភិបាលចំណាយច្រើនទៅលើប្រាក់ឧបត្ថម្ភសម្រាប់និកម្មជន នៅពេលមានវិបត្តិសេដ្ឋកិច្ច (នៅពេលដែលនិកម្មភាពមានកម្រិតខ្ពស់) និង ចំណាយលើមុខចំណាយនេះតិច នៅពេលដែលសេដ្ឋកិច្ចមានកំណើនខ្ពស់ ។ ប្រព័ន្ធពន្ធលើប្រាក់ចំណូលក៏មានសមាសធាតុដ៏សំខាន់នៃ**ឧបករណ៍ស្ថិរភាពរូបនីយកម្មដោយស្វ័យប្រវត្តិ** ផងដែរ ។ ឧទាហរណ៍ នៅពេលដែលសេដ្ឋកិច្ចកំពុងតែកើនឡើងនោះ ការប្រមូលពន្ធនឹងកើនឡើងយ៉ាងខ្លាំង ហើយនៅក្នុងពេលដែលសេដ្ឋកិច្ចធ្លាក់ចុះ នោះការប្រមូលពន្ធនឹងធ្លាក់ចុះ ។ សមិទ្ធកម្មទៅតាមវដ្តអាជីវកម្មនៃការប្រមូលពន្ធនេះ នឹងជួយអោយប្រាក់ចំណូលក្រោយបង់ពន្ធ សញ្ច័យ និង ការប្រើប្រាស់អនុវត្តទៅប្រកបដោយភាពរលូនជាមួយនឹងវដ្តអាជីវកម្ម ។

ប៉ុន្តែអ្វីដែលខុសពី **ឧបករណ៍ស្ថិរភាពរូបនីយកម្មដោយស្វ័យប្រវត្តិ** នោះគឺថា ឱនភាពថវិកានឹងមានទំនោរទៅរកការកើនឡើងនៅក្នុងពេលសេដ្ឋកិច្ចធ្លាក់ចុះ និង ថយចុះនៅពេលសេដ្ឋកិច្ចកើនឡើង ។ នៅខណៈពេលដែលពន្ធអាចកែតម្រូវបានយ៉ាងឆាប់រហ័ស ចំណាយថវិកានឹងកែតម្រូវយ៉ាងយឺត ដោយមានគម្លាតពេលដ៏យូរ ។ ឧទាហរណ៍ នៅពេលសេដ្ឋកិច្ចកើនឡើងនោះ នៅក្នុងការប្រមូលពន្ធនឹងប្រព្រឹត្តទៅយ៉ាងលឿនជាងកំណើនចំណាយថវិកា ។ ប្រការនេះនឹងធ្វើអោយឱនភាពថវិកាធ្លាក់ចុះ ។

ជម្រើសផ្ទុយគ្នារវាងអតិផរណា និង និកម្មភាព នៅក្នុងសម្មតិកម្មខ្សែកោង**ហ្វីលីព**បែបបូរាណនិយមមិនបានដាក់អោយជាក់លាក់ទេ នៅពេលដែលរៀបចំ និង អនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។

ឧទាហរណ៍ ការជំរុញលើកទឹកចិត្តទៅដល់សេដ្ឋកិច្ចដែលនៅនឹងថ្កល់បង្កើតឡើងនូវហានិភ័យ ដោយដុតភ្នក់បង្កើតជាអតិផរណា ដោយសារការអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុពង្រីកនឹងជំរុញសកម្មភាពសេដ្ឋកិច្ចក៏ប៉ុន្តែដោសសមត្ថភាពផលិតនៅមានកម្រិត នោះអាចនឹងមានអតិផរណា ។ ការព្យាយាមស្វែងរក **អត្រានិកម្មភាពដោយគ្មានអតិផរណា** ឬ NAIRU គឺជាបេះដូងនៃការរៀបចំនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅក្នុងសេដ្ឋកិច្ចទីផ្សារ ។

នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះ ក៏រឹតនិកម្មភាពនឹងកើនឡើង ការចំណាយសម្រាប់ការប្រើប្រាស់ថយចុះហើយអាជីវកម្មគ្មានប្រាក់ចំណេញឡើយ ។ នៅក្នុងស្ថានភាពបែបនេះ រដ្ឋាភិបាលអាចជំរុញសេដ្ឋកិច្ចតាមរយៈការបង្កើននូវចំណូលក្រោយកាត់ពន្ធរបស់ប្រជាពលរដ្ឋ ។ ការជំរុញសេដ្ឋកិច្ចអាចសម្រេចបានដោយប្រើប្រាស់នូវឧបករណ៍មួយចំនួន រួមទាំង ចំណាយថវិកាលើការទិញនូវទំនិញ និងសេវា និង ការកាត់បន្ថយពន្ធលើប្រាក់ចំណូលបុគ្គល ។ នៅពេលដែលការប្រើប្រាស់ និងការវិនិយោគបានកើនឡើង តាមរយៈការអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈលើកទឹកចិត្ត អត្រានិកម្មភាពធ្វើនឹងធ្លាក់ចុះ ។ បើទោះបីជាយ៉ាងណា ក៏ដោយនៅពេលសេដ្ឋកិច្ចឈានទៅដល់អនិកម្មភាពពេញលេញ កំណើនបន្ថែមទៀតនៃតម្រូវការសរុបដែលកើតចេញពីការធ្វើអន្តរាគមន៍ខាងផ្នែកនយោបាយហិរញ្ញវត្ថុសាធារណៈ នឹងធ្វើអោយមានអតិផរណា ។ ដូច្នេះ ការកាច់ចង្កូត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេដ្ឋកិច្ច តាមរយៈការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈតែមួយមុខអាចនឹងពិបាក បើទោះជាវាមិនមែនមិនអាចធ្វើបានក៏ដោយ ។ ប្រសិនបើយើងមិនតាមដានអោយបានដិតដល់ទេនោះ ការអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈលើកទឹកចិត្ត នឹងបាត់បង់នូវតួនាទីប្រកបដោយផលិតភាពរបស់វា ហើយនឹងនាំអោយមានអតិផរណា ។

នៅពេលដែលសម្ពាធអតិផរណាកើនឡើង កំណើនសេដ្ឋកិច្ចនឹងធ្លាក់ចុះ ។ នៅក្នុងស្ថានភាពនេះ រដ្ឋាភិបាលអាចបង្កើនពន្ធ ហើយបន្ថយនូវតម្រូវការលើសចេញពីសេដ្ឋកិច្ច ។ រដ្ឋាភិបាលអាចកាត់បន្ថយចំណាយថវិកាអោយនៅទាបជាងមុន ដើម្បីកាត់បន្ថយនូវសំពាធតម្រូវការ ។ ប្រសិនបើគោលនយោបាយ **បរិត្តផរណា** នេះអនុវត្តមិនបានស្រួល ដើម្បីកាច់ចង្កូតសេដ្ឋកិច្ចទេនោះ សេដ្ឋកិច្ចនឹងអាចបោលដូចសេះដាច់បង្ហៀរ ហើយធ្លាក់ចូលទៅក្នុងវិបត្តិ ដោយធ្វើអោយការងារ និងប្រាក់ចំណូលធ្លាក់ចុះជាបន្តបន្ទាប់ ។

គោលនយោបាយហិរញ្ញវត្ថុសាធារណៈនឹងធ្វើអោយផ្លាស់ប្តូរផងដែរ នូវបន្ទុកពន្ធនាពេលអនាគត ។ នៅពេលដែលរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីក ដែលមិនមែនធ្វើហិរញ្ញប្បទានដោយជំនួយឥតសំណងពីបរទេស ចំណាយនេះនឹងបន្ថែមទៅលើសន្និធិបំណុលសាធារណៈនាពេលបច្ចុប្បន្ន ។ ដោយសាររដ្ឋាភិបាលនឹងត្រូវសងការប្រាក់ទៅលើបំណុលនេះ និង ត្រូវសងទាំងប្រាក់ដើមនៅក្នុងពេលប៉ុន្មានឆ្នាំខាងមុខ គោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីកបង្កើននូវបន្ទុកពន្ធបន្ថែមទៀត ទៅលើអ្នកបង់ពន្ធនៅពេលអនាគត ។ ពន្ធអាចត្រូវបានប្រើប្រាស់ដើម្បីបែងចែកឡើងវិញនូវចំណូលរវាងវណ្ណៈសង្គមផ្សេងៗគ្នា ។ ដូចគ្នានេះដែររដ្ឋាភិបាលអាចអនុវត្តនូវគោលនយោបាយអោយមានអតិរេកថវិកា ឬ ឱនភាពថវិកា ដើម្បីបែងចែកឡើងវិញនូវបន្ទុកសារពើពន្ធរវាងជំនាន់មនុស្សជំនាន់នេះ និង មនុស្សជំនាន់ក្រោយ ។

សេដ្ឋវិទូខ្លះបានអះអាងថា ផលប៉ះពាល់បែបនេះនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈទៅលើពន្ធនាពេលអនាគត នឹងជំរុញអោយអ្នកប្រើប្រាស់ផ្លាស់ប្តូរនូវចរិតសញ្ច័យរបស់ពួកគេ ។ ដោយទទួលស្គាល់ថាការកាត់បន្ថយពន្ធនៅពេលបច្ចុប្បន្ន មានន័យថាពន្ធនឹងកើនឡើងកាន់តែខ្ពស់នៅថ្ងៃអនាគតនោះ នោះប្រជាពលរដ្ឋនឹងសន្សំនូវតម្លៃដែលពួកគេទទួលពីការកាត់បន្ថយពន្ធនៅពេលបច្ចុប្បន្ន ដើម្បីទុកសម្រាប់បង់នូវពន្ធនៅថ្ងៃក្រោយ ។ អំណះអំណាងជ្រុលនិយមបែបនេះ ដែលជាឧទាហរណ៍មួយនៃគោលការណ៍គ្រឹះនៃ **សមមូលរីកាដូ** ចាត់ទុកថាការកាត់បន្ថយពន្ធ នឹងគ្មានឥទ្ធិពលអ្វីទៅលើសញ្ច័យជាតិឡើយ ពីព្រោះការផ្លាស់ប្តូរនៃសញ្ច័យឯកជននឹងត្រូវជាឥទ្ធទាត់សងដោយការផ្លាស់ប្តូរនៃសញ្ច័យរដ្ឋាភិបាល ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកប្រើប្រាស់សម្រេចចិត្តចាយខ្លះពីប្រាក់ចំណូលក្រោយបង់ពន្ធ ដែលពួកគេបានទទួលបន្ថែមពីការកាត់បន្ថយពន្ធ ដែលជាបេះដូងនៃសម្មតិកម្មនៃអនុគមន៍ការប្រើប្រាស់កេនស៍និយម នោះ សម្មតិកម្មនៃ **សមមូលរីកាដូ** នឹងមិនពិតឡើយ ។ ការកាត់បន្ថយពន្ធនឹងកាត់បន្ថយសញ្ច័យជាតិ និង បង្កើនតម្រូវការសរុប ។ បទពិសោធន៍នៅអំឡុងទស្សវត្សទី ៨០ បានបង្ហាញ អោយឃើញថាសញ្ច័យឯកជនបានធ្លាក់ចុះ នៅពេលដែលរដ្ឋាភិបាលកាត់បន្ថយពន្ធ គឺជាតឹកតាងមួយ ដែលបង្ហាញអោយឃើញថា សម្មតិកម្មនៃ **សមមូលរីកាដូ** មិនពិតឡើយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.២. គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ស្ថិរភាវូបនីយកម្មម៉ាក្រូសេដ្ឋកិច្ច

ដោយសារតែ**ឧបករណ៍ស្ថិរភាពូបនីយកម្មដោយស្វ័យប្រវត្តិ** គឺជា ឧបករណ៍ហិរញ្ញវត្ថុសាធារណៈ គ្មានភាពស័ក្តិសិទ្ធ ឬ មិនគ្រប់គ្រាន់ដើម្បីធ្វើអោយវដ្តអាជីវកម្មមានសភាពរលូន សេដ្ឋវិទូខ្លះបានផ្តល់អនុសាសន៍អោយផ្លាស់ប្តូរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីឆ្លើយតបទៅលក្ខខណ្ឌសេដ្ឋកិច្ចជាក់ស្តែង ដោយអនុវត្តនូវ**គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយឆន្ទានុសិទ្ធិ** (Discretionary fiscal policy) ដែលជាវិធីជួយវដ្តអាជីវកម្មមានស្ថិរភាព ។ មានទស្សនៈផ្សេងៗគ្នាច្រើនពាក់ព័ន្ធនឹងការប្រើប្រាស់គោលនយោ-បាយហិរញ្ញវត្ថុសាធារណៈប្រកបដោយឆន្ទានុសិទ្ធិ ជាឧបករណ៍សម្រាប់ស្ថិរភាវូបនីយកម្មម៉ាក្រូសេដ្ឋកិច្ច ។ ចាប់តាំងពីដើមទស្សវត្ស ១៩៦០ សេដ្ឋវិទូមានសុភវិនិច្ឆ័យជាទូទៅថា គោលនយោបាយស្ថិរភាវូបនីយកម្មឆន្ទានុសិទ្ធិមានប្រសិទ្ធិភាព និង គួរអោយពេញចិត្តដើម្បីធ្វើអោយវដ្តអាជីវកម្មមានស្ថិរភាព ហើយគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជា ឧបករណ៍ដ៏សំខាន់បំផុត ដើម្បីធ្វើអោយវដ្តអាជីវកម្មមានភាពរលូន ។ ក៏ប៉ុន្តែ ទ្រឹស្តី និងភស្តុតាងជាក់ស្តែងក្នុងពេលថ្មីៗនេះ មិនបានគាំទ្រខ្លាំងក្លានូវទស្សនៈនេះទេ ។ ការយឺតយ៉ាវយ៉ាងខ្លាំង ក្នុងការរៀបចំ និង ការអនុវត្តគោលនយោបាយស្ថិរភាវូបនីយកម្ម គឺជារឿងដែលចៀសមិនរួច ហើយជាពិសេស នៅពេលដែលឧបករណ៍គោលនយោបាយគឺជា ចំណាយថវិកាលើការទិញ ។ ប្រសិនបើសេដ្ឋវិទូព្យាករណ៍ពីការយឺតយ៉ាវនេះបានល្អ នោះទោះជាមានការយឺតយ៉ាវក៏គ្មានបញ្ហាអ្វីទេ ។ ក៏ប៉ុន្តែ នៅពេលដែលគ្មានការព្យាករណ៍ច្បាស់លាស់ ការព្យាយាមប្រើប្រាស់នូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆន្ទានុសិទ្ធិ ដើម្បីទប់ទល់នឹងវដ្តអាជីវកម្មបង្កើតឡើងនូវបញ្ហាច្រើនជាងផ្តល់ផលល្អ ។ ដូចនេះ ដោយឈរលើទស្សនៈវិស័យកាត់បន្ថយនូវគម្លាតនៃភាពយឺតយ៉ាវរវាង ការរៀបចំគម្រោងនយោបាយ និង ការអនុវត្ត ការផ្លាស់ប្តូរពន្ធ និងការផ្ទេរត្រូវបានគេយល់ថា ជាឧបករណ៍ហិរញ្ញវត្ថុសាធារណៈដ៏មានប្រសិទ្ធភាព សម្រាប់គោលដៅស្ថិរភាវូបនីយកម្ម ។ ក៏ប៉ុន្តែ ការផ្លាស់ប្តូរពន្ធ និងការផ្ទេរត្រូវតែអនុវត្តអោយចំទិសដៅចំពោះក្រុមដែលនឹងបង្កើនការចំណាយការប្រើប្រាស់របស់ពួកគេ បន្ទាប់ពីទទួលបាននូវការលើកទឹកចិត្តនោះ ។ ក៏ប៉ុន្តែ ប្រសិនបើក្រុមដែលទទួលការលើកទឹកចិត្តនេះ មានឧបនិស្ស័យដ៏តិចតួចក្នុងការប្រើប្រាស់ នោះការផ្លាស់ប្តូរពន្ធ និងការផ្ទេរនឹងមិនមានផលប៉ះពាល់ដ៏ខ្លាំងក្លាលើតម្រូវការសរុបឡើយ ។ ការពង្រីកវិសាលភាព នៃប្រាក់ឧបត្ថម្ភសម្រាប់និកម្មជន គឺជាឧទាហរណ៍មួយនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលអនុវត្តចំទិសដៅ ដើម្បីបង្កើនការប្រើប្រាស់ ។

អំណះអំណាងដើម្បីប្រើប្រាស់នូវ **គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយឆន្ទានុសិទ្ធិ** ដើម្បីធ្វើអោយវដ្តអាជីវកម្មមានស្ថេរភាពកាន់តែសាបរលាភទៅ ដោយសារតែមានឧបករណ៍មួយផ្សេងទៀត គឺ **គោលនយោបាយរូបិយវត្ថុ** ដែលមានភាពប៉ិនប្រសព្វច្រើនជាង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។ ក៏ប៉ុន្តែ គេក៏អាចទិតៀនឧបករណ៍នេះបានដែរ ដោយសាតែមានគម្លាតយូររវាងការរៀចំគោលនយោបាយ និង ការអនុវត្តនូវគោលនយោបាយនេះ ។

គោលនយោបាយលើកទឹកចិត្តជាបណ្តោះអាសន្ននូវតម្រូវការសរុប ដូចជាការកាត់បន្ថយអត្រាពន្ធ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លើការលក់ជាបណ្តោះអាសន្ន អាចបង្កើតនូវការលើកទឹកចិត្តអោយអតិថិជនទិញទំនិញប្រើប្រាស់បានយូរ មុនពេលដែលគេត្រូវទិញ ។ ដូចគ្នាផងដែរ ការផ្តល់ឥណទានពន្ធវិនិយោគជាបណ្តោះអាសន្ន អាចលើកទឹកចិត្តអោយក្រុមហ៊ុនអនុវត្តគម្រោងវិនិយោគថ្មីរបស់គេមុនកាលកំណត់ ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយឆន្ទានុសិទ្ធិអាចដើរតួនាទីស្ថិរភាវូបនីយកម្មដ៏សំខាន់ ក្នុងកាលៈទេសៈដ៏លំបាក ដូចជា នៅពេលដែលវិបត្តិសេដ្ឋកិច្ចមានរយៈពេលវែងខុសធម្មតា ឬ នៅពេលដែលអត្រាការប្រាក់រយៈពេលខ្លីជិតដល់សូន្យ ដែលធ្វើអោយគោលនយោបាយរូបិយវត្ថុមិនមានប្រសិទ្ធភាព ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈអាចមានសារៈសំខាន់ក្នុងការជំរុញតម្រូវការសរុប និងផាតុចេញនៅក្នុងរយៈពេលខ្លី បើទោះបីជាផលប៉ះពាល់រយៈពេលវែងរបស់វាមានភាពមិនច្បាស់លាស់ក៏ដោយ ។

ជារួម គោលនយោបាយហិរញ្ញវត្ថុសាធារណៈលើកទឹកចិត្ត នឹងធ្វើអោយឱនភាពថវិកា និងបំណុលសាធារណៈកើនឡើង ។ ប្រសិនបើសាធារណជនជឿជាក់ថា ការចាំបាច់ក្នុងការបង្កើនពន្ធដើម្បីយកទៅសងបំណុលនឹងកើតឡើងនៅក្នុងរយៈពេលយូរប៉ុណ្ណោះ នោះសញ្ញ័យនឹងធ្លាក់ចុះនៅពេលបច្ចុប្បន្ននេះ ហើយបន្ទុកពន្ធនឹងត្រូវផ្ទេរទៅលើអ្នកជំនាន់ក្រោយ ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈលើកទឹកចិត្ត ដើម្បីបង្កើនការប្រើប្រាស់នឹងមានប្រសិទ្ធភាពនៅក្នុងសេណារីយ៉ូនេះ ។ ប្រសិនបើសាធារណៈជនជឿជាក់ថា បន្ទុកសងបំណុលនឹងមិនត្រូវផ្ទេរទៅលើអ្នកជំនាន់ក្រោយទេនោះ គោលនយោបាយហិរញ្ញវត្ថុសាធារណៈលើកទឹកចិត្តប្រហែលជានឹងមិនអាចសម្រេចបាននូវកំណើនការប្រើប្រាស់តាមបំណងបានឡើយ ។

លទ្ធភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីមានឥទ្ធិពលលើកំរិតនៃផាតុចេញ កាន់តែបាត់បង់ប្រសិទ្ធភាពបន្តិចម្តងៗ ។ កំណើនតម្រូវការសរុបដែលបណ្តាលមកពីការលើកទឹកចិត្តសារពើពន្ធ នឹងធ្វើអោយតៃថ្លៃឡើងខ្ពស់ជាងមុន ដោយមានកំណើនផាតុចេញតែបន្តិចបន្តួចប៉ុណ្ណោះ ដោយសារតែភ្នាក់ងារសេដ្ឋកិច្ចធ្វើការកែតម្រូវទៅលើការលើកទឹកចិត្តនេះ ។ នៅក្នុងរយៈពេលយូរ មានតែកត្តាផលិតកម្មប៉ុណ្ណោះ (ដូចជាមូលធន កំលាំងពលកម្ម និង បច្ចេកវិទ្យា) ដែលកំណត់នូវសមត្ថភាពរបស់ទីផ្សារដើម្បីបំពេញតាមតម្រូវការ ។ ផាតុចេញមិនអាចកើនឡើងរហូត ដោយគ្រាន់តែរុញអនុគមន៍តម្រូវការអោយកើនឡើងឡើយ ។ កត្តាផលិតកម្មទាំងនេះកំណត់នូវ «**អត្រាកំណើនធម្មជាតិ**» ។ វដ្តអាជីវកម្ម និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចអាចធ្វើអោយផាតុចេញងាកចេញជាបណ្តោះអាសន្នប៉ុណ្ណោះពីអត្រានេះ ។ ការព្យាយាមប្រឹងប្រែងបង្កើនផាតុចេញអោយកើនលើសអត្រាធម្មជាតិរបស់វា តាមរយៈការអនុវត្តនូវគោលនយោបាយតម្រូវការសរុប នឹងគ្រាន់តែអាចពន្លឿនអតិផរណាតែប៉ុណ្ណោះ ។

ជាការពិតណាស់ នៅពេលដែលផាតុចេញត្រឡប់ទៅរក «**អត្រាកំណើនធម្មជាតិ**» របស់វានៅក្នុងរយៈពេលវែង គឺមិនមែនជាទីបញ្ចប់នៃរឿងរ៉ាវឡើយ ។ ទន្ទឹមនឹងបង្កើនផាតុចេញនៅក្នុងរយៈពេលខ្លី គោលនយោបាយហិរញ្ញវត្ថុសាធារណៈអាចផ្លាស់ប្តូរអត្រាធម្មជាតិ ហើយគួរអោយខ្មាស់ផងដែរ ផលប៉ះពាល់រយៈពេលវែងនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈមានទិសដៅផ្ទុយនឹងផលប៉ះពាល់រយៈពេលខ្លី ។ គោលនយោ-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បាយហិរញ្ញវត្ថុសាធារណៈពង្រីក នឹងបង្កើនធាតុចេញកាន់តែកើនឡើងខ្ពស់នៅពេលបច្ចុប្បន្ន ក៏ប៉ុន្តែវានឹងធ្វើអោយ **«អត្រាកំណើនធម្មជាតិ»** នៃធាតុចេញធ្លាក់ចុះទាបជាងអត្រារបស់វានៅពេលអនាគត ។ ដូចគ្នានេះដែរ គោលនយោបាយហិរញ្ញវត្ថុសាធារណៈបង្រួម បើទោះបីជាធ្វើអោយធាតុចេញធ្លាក់ចុះក្នុងរយៈពេលខ្លីក៏ដោយ នៅពេលអនាគត វានឹងបង្កើននូវធាតុចេញ ។

គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ធ្វើអោយប៉ះពាល់ដល់កម្រិតនៃធាតុចេញនៅក្នុងរយៈពេលវែង ដោយសារវាមានឥទ្ធិពលលើអត្រាសញ្ជ័យជាតិ ។ សញ្ជ័យសរុបរបស់ប្រទេសជាតិ ចែកចេញជាពីរផ្នែកគឺ ÷ សញ្ជ័យឯកជន (បុគ្គល និង ក្រុមហ៊ុន) និង សញ្ជ័យរដ្ឋាភិបាល (អតិរេកថវិកា) ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីកនឹងកាត់បន្ថយសញ្ជ័យរដ្ឋាភិបាល ។ ការកាត់បន្ថយសញ្ជ័យមានន័យថា ឬមួយប្រទេសនេះនឹងវិនិយោគតិចជាមុននៅក្នុងរោងចក្រ និងគ្រឿងសម្ភារៈបរិក្ខារ ឬមួយប្រទេសនេះត្រូវបង្កើនកម្ចីពីបរទេស ។ កត្តាទាំងពីរនឹងផ្តល់លទ្ធផលដូចគ្នា គឺការកាត់បន្ថយនូវធនធានសម្រាប់ការវិនិយោគ ដែលនឹងធ្វើអោយ **«អត្រាកំណើនធម្មជាតិ»** នឹងធ្លាក់ចុះនៅក្នុងរយៈពេលវែង ។ កំណើនបំណុលបរទេសមានន័យថា ធាតុចេញរបស់ប្រទេសមួយភាគធំនឹងត្រូវនាំចេញទៅក្រៅប្រទេសនាពេលអនាគត ។ ដូច្នេះ ការប្រើប្រាស់នៅក្នុងប្រទេសនឹងត្រូវកាត់បន្ថយ ។

## ៤.៣. ផលប៉ះពាល់ការលើកទឹកចិត្តនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ទន្ទឹមនឹងផលប៉ះពាល់លើតម្រូវការសរុប និង សញ្ជ័យ គោលនយោបាយហិរញ្ញវត្ថុសាធារណៈក៏មានឥទ្ធិពលទៅលើរចនាសម្ព័ន្ធលើកទឹកចិត្តនៅក្នុងសេដ្ឋកិច្ចផងដែរ ។ ការដាក់ពន្ធលើសកម្មភាពមួយ មានន័យថាមិនជំរុញលើកទឹកចិត្តចំពោះសកម្មភាពនោះទេ ។ ការដាក់អត្រាពន្ធបន្ថែមខ្ពស់លើប្រាក់ចំណូល វាកាត់បន្ថយការលើទឹកចិត្តអោយប្រជាជនបង្កើនចំណូល ។ តាមរយៈការកាត់បន្ថយពន្ធ ឬ ទោះបីជារក្សាអត្រាមធ្យមដូចគ្នាប៉ុន្តែបន្ថយអត្រាពន្ធបន្ថែម និង បង្កើនចំណាយដែលអនុញ្ញាតឱ្យកាត់កងពីមូលដ្ឋានយកពន្ធ នោះរដ្ឋាភិបាលអាចបង្កើនការលើកទឹកចិត្ត និងបង្កើនធាតុចេញ ។ សេដ្ឋវិទូខាងផ្នែកផ្គត់ផ្គង់បានអះអាងថា ការបន្ថយអត្រាពន្ធនឹងផ្តល់បច្ច័យជាវិជ្ជមានដ៏ធំធេង ដល់បរិមាណផ្គត់ផ្គង់ពលកម្ម និង នាំឱ្យមានកំណើនធាតុចេញ ។ ផលប៉ះពាល់នៃការលើកទឹកចិត្តនៃពន្ធក៏ដើរតួនាទីខាងផ្នែកតម្រូវការផងដែរ ។ ឧទាហរណ៍ គោលនយោបាយ ដូចជាឥណទានពន្ធវិនិយោគ អាចមានផលប៉ះពាល់ច្រើនលើតម្រូវការទំនិញវិនិយោគ ។

ឧបសគ្គដ៏ធំជាងគេចំពោះការប្រើប្រាស់គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាពទាំងក្នុងតួនាទីធ្វើឱ្យមានស្ថិរភាព និងតួនាទីគាំទ្រកំណើន នោះគឺការប្រែប្រួលក្នុងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ តែងតែនាំអោយមានការផ្លាស់ប្តូរផ្សេងៗទៀតជានិច្ច ដែលធ្វើតួអង្គខ្លះសើចសប្បាយ តែធ្វើអោយតួអង្គខ្លះទៀតយំ ។ គេប្រហែលជាអាចកសាងផ្លូវ ប្រសិនបើគេអាចរិចខ្ចប់វាជាផ្នែកមួយ នៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈផ្ទុយនឹងវដ្តសេដ្ឋកិច្ច ។ គេអាចអនុវត្តដូចគ្នានេះដែរចំពោះការកាត់បន្ថយពន្ធ ដើម្បីផ្គាប់ចិត្តមណ្ឌល


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បោះឆ្នោតដែលគេពេញចិត្ត ។ ប្រការនេះនឹងនាំអោយមានការអបអរសាទរ ចំពោះការអនុវត្តនូវគោលនយោបាយពង្រីក នៅក្នុងពេលមានវិបត្តិសេដ្ឋកិច្ច ក៏ប៉ុន្តែ ពួកគេប្រហែលជាមិនអាចទទួលបាននូវការអនុវត្តគោលនយោបាយបង្រួម នៅពេលដែលសេដ្ឋកិច្ចកំពុងកើនឡើងខ្លាំងឡើយ ។ ម៉្យាងវិញទៀត គោលនយោបាយពង្រីកមានផលប៉ះពាល់ឆាប់រហ័ស ។ ទន្ទឹមនឹងនេះ ចំណាយរបស់វានឹងខ្ពស់នៅពេលអនាគត ដោយសារការតម្លើងពន្ធ និង ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ច នឹងកើតមានឡើងនៅពេលក្រោយតែប៉ុណ្ណោះ ។ ដោយត្រូវប្រឈមមុខនឹងឧបសគ្គបែបនេះ បើតាមការវិភាគចុងក្រោយរបស់យើង ការរៀបចំគោលនយោបាយហិរញ្ញវត្ថុសាធារណៈឱ្យបានល្អ មិនមែនបញ្ហាសេដ្ឋកិច្ចទេ តែវាជាបញ្ហានយោបាយទេវិញ ។

### ៤.៣.១. ផលប៉ះពាល់នៃការកាត់បន្ថយពន្ធទៅលើចំណាយការប្រើប្រាស់

ការបញ្ចុះពន្ធនាំឱ្យកើនចំណូលក្រោយបង់ពន្ធរបស់គេហជន ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់បង្កើនការចាយវាយរបស់ពួកគេ ។ វិបាកនៃការកាត់ពន្ធអាស្រ័យលើក្រុមគ្រួសារធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងសញ្ជ័យបច្ចុប្បន្ន និងសញ្ជ័យអនាគត និង អាស្រ័យលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ។ ការរំពឹងទុកថា ការកាត់ពន្ធគ្រាន់តែបណ្ដោះអាសន្ន ឬ ជាអចល័ន្ត នឹងជះឥទ្ធិពលទៅលើរបៀបឆ្លើយតបរបស់អ្នកប្រើប្រាស់ ។

ការកាត់ពន្ធជាបណ្ដោះអាសន្ន នៅពេលដែលសេដ្ឋកិច្ចប្រកបដោយអនិកម្មភាពពេញលេញ នឹងធ្វើឱ្យប្រែប្រួលតែបន្តិចបន្តួចប៉ុណ្ណោះ នូវចំណូលក្រោយបង់ពន្ធក្នុងមួយជីវិតរបស់គេហជន ។ ដូចនេះ វាអាចមានឥទ្ធិពលតែបន្តិចបន្តួចទៅលើការប្រើប្រាស់តែប៉ុណ្ណោះ ។ ដូចនេះ ការកាត់ពន្ធនឹងឆ្លុះបញ្ចាំងនូវការកើនឡើងនៃសញ្ជ័យរបស់គេហជន ។ ប្រសិនបើការកាត់ពន្ធត្រូវបានប៉ាន់ប្រមាណថា ជាអចល័ន្ត នោះគេហកិច្ចនឹងតម្រឹមការបង្កើនចំណូលរបស់គេ និង ប្រាកដជាបង្កើនចំណាយ ។

ប៉ុន្តែការកាត់ពន្ធនឹងបន្ថយចំណាយរបស់រដ្ឋាភិបាល ឬក៏បង្កើនឱនភាពថវិកា ។ ទោះបីជាការកាត់ពន្ធមានលក្ខណៈជារៀងរហូតក៏ដោយ ពន្ធដែលត្រូវប្រមូលនៅពេលអនាគតនឹងត្រូវតែខ្ពស់ជាងនេះ ដើម្បីអាចយកទៅទូទាត់បំណុលសាធារណៈ ដែលកើតមានឡើងដោយសារការកាត់ពន្ធនេះ ។ ក្នុងករណីនេះ គេហជននឹងមិនមានអារម្មណ៍ថា ចំណូលក្រោយបង់ពន្ធរបស់ពួកគេកើនឡើងទេ ពីព្រោះគេយល់ថាមានការកើនបំណុលសាធារណៈដោយសារការកាត់ពន្ធ និងគិតថាវាជាបំណុលរបស់ខ្លួន ។ ប៉ុន្តែអ្នកប្រើប្រាស់មួយចំនួន ដែលគិតចំពោះតែប្រាក់ចំណូលបច្ចុប្បន្ន និងរស់នៅតែមួយគ្រប់ ពួកគេនឹងបង្កើនចំណាយរបស់ខ្លួន ។

ការប្រើប្រាស់អាចកើនឡើងច្រើន នៅពេលដែលសេដ្ឋកិច្ចមិនមានអនិកម្មភាពពេញលេញ និងប្រសិនបើការកាត់ពន្ធត្រូវបានយល់ថា ជាការបន្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចមានស្ថិរភាព ។ អ្នកប្រើប្រាស់នឹងធ្វើផែនការកែលម្អចំណូលឱ្យប្រសើរឡើង នៅខណៈដែលសេដ្ឋកិច្ចបោះជំហានឆ្ពោះទៅរកចំណុចខ្ពស់បំផុតនៃវដ្តធុរកិច្ច និង ដោយហេតុនេះនឹងបង្កើនការប្រើប្រាស់ដែលជំរុញកំណើនសេដ្ឋកិច្ច ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៤.៣.២. ផលប៉ះពាល់នៃការកាត់បន្ថយពន្ធទៅលើអត្រាការប្រាក់ វិនិយោគ និង លំហូរមូលធន

ការកើនឡើងនៃឱនភាពថវិកាដែលបណ្ដាលមកពីការកាត់បន្ថយពន្ធ នឹងធ្វើឱ្យបំណុលសាធារណៈកើនឡើង ប្រសិនបើគេធ្វើហិរញ្ញប្បទានក្នុងប្រទេស ។ បញ្ហានេះដាក់ចេញជាចំណោទ ពាក់ព័ន្ធទៅនឹងឥទ្ធិពលរយៈពេលវែងនៃការកាត់បន្ថយពន្ធ ទៅលើអត្រាការប្រាក់ វិនិយោគជាមូលធន និង សុខមាលភាពសេដ្ឋកិច្ចនាពេលអនាគត ។

គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឱ្យកើនបំណុលសាធារណៈ នឹងនាំអោយមានកំណើនពន្ធនៅពេលអនាគត ។ ក៏ប៉ុន្តែ បើបំណុលកើតឡើងដោយសារការវិនិយោគលើធនធានមនុស្ស និង មូលធនរូបវន្តចំណូលថវិកានឹងកើនឡើងនៅពេលអនាគត ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់ជាង ។ គោលនយោបាយដែលស្រូបយកធនធានទៅទំនេរ ឬគោលនយោបាយបង្កើនវិនិយោគ អាចកាត់បន្ថយសញ្ជ័យ ដូចឆ្លុះបញ្ចាំងតាមរយៈកំណើននៃឱនភាពថវិកា ។ ក៏ប៉ុន្តែ ប្រការនេះនឹងបង្កើនសញ្ជ័យជាតិ ដោយសារចំណូលក៏កើនឡើងខ្ពស់ផងដែរ ។ កំណើននៃឱនភាពនេះក៏អាចធ្វើហិរញ្ញប្បទានពីប្រភពខាងក្រៅបានដែរ ។ ទោះបីជាហិរញ្ញប្បទានមកពីប្រភពណាក៏ដោយ ប្រសិនបើបំណុលបន្ថែមទាំងនោះមិនអាចធ្វើឱ្យចំណូល និងវិនិយោគកើនឡើង នោះការសងបំណុលទៅអនាគតមុខជាជួបប្រទះនឹងបញ្ហា ។

នៅពេលដែលសេដ្ឋកិច្ចស្ថិតក្នុងអនិកម្មភាពពេញលេញ និងការកាត់ពន្ធបច្ចុប្បន្នត្រូវបានរំពឹងទុកថាអាចបំពេញមកវិញតាមរយៈការបង្កើនពន្ធទៅអនាគត ។ នោះការបញ្ចុះពន្ធនឹងមិនច្បាស់ជានាំឱ្យកើនចំណាយប្រើប្រាស់ទេ ។ ក្នុងករណីដ៏ជ្រុលនិយមនេះ ការកើនឱនភាពថវិការដ្ឋ នឹងស៊ីសង្វាក់គ្នាជាមួយការកើនឡើងសញ្ជ័យឯកជន ។ ដូច្នេះ **សមមូលរីកាដូ** នៅមានអានុភាពនៅឡើយ ហើយសញ្ជ័យជាតិ អត្រាការប្រាក់ និង វិនិយោគនៅថេរដដែល ហាក់ដូចជាមិនមានការប្រែប្រួលនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈឡើយ ។

ប្រសិនបើអ្នកប្រើប្រាស់ធ្វើការចាយវាយច្រើន ពីប្រាក់ចំណូលក្រោយពន្ធបន្ថែមរបស់ខ្លួន ក្នុងខណៈដែលសេដ្ឋកិច្ចមាននិកម្មភាពពេញលេញ នោះសញ្ជ័យផ្ទាល់ខ្លួននឹងមិនកើនឡើងគ្រប់គ្រាន់ សម្រាប់ទូទាត់បំពេញឱ្យការធ្លាក់ចុះសញ្ជ័យសាធារណៈឡើយ ។ ក្នុងករណីនេះ អត្រាការប្រាក់នឹងកើនឡើង និងចំណាយវិនិយោគនឹងធ្លាក់ចុះ លើកលែងតែសញ្ជ័យធុរកិច្ច (បានពីប្រាក់ចំណេញខ្ពស់ ដោយសារចំណាយប្រើប្រាស់បន្ថែម) ឬ លំហូរមូលធនពីបរទេសកើនឡើងគ្រប់គ្រាន់ សម្រាប់បំពេញគម្លាតនេះ ។

ក៏ប៉ុន្តែ ប្រសិនបើគោលនយោបាយហិរញ្ញវត្ថុសាធារណៈកាត់បន្ថយការវិនិយោគ នោះទាំងសន្និធិមូលធននិងធាតុចេញសេដ្ឋកិច្ចនឹងធ្លាក់ចុះនៅពេលអនាគត ។ ការធ្លាក់ចុះនៃសន្និធិមូលធនអាចនឹងកើតឡើងស្របពេលជាមួយកំណើននៃអត្រាការប្រាក់ពិត ។

ប្រសិនបើលំហូរមូលធនពីបរទេសកើនឡើងគ្រប់គ្រាន់ ដើម្បីទូទាត់បំពេញឱ្យការធ្លាក់ចុះនៃសញ្ជ័យ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងប្រទេស ដែលកើតឡើងដោយសារការប្រែប្រួលគោលនយោបាយហិរញ្ញវត្ថុសាធារណៈ នោះវិនិយោគមិនធ្លាក់ចុះទេ ។ ក្នុងករណីនេះ ឱនភាពគណនីចរន្ត ដែលស្មើនឹងបរិមាណលំហូរមូលធនពីបរទេស នឹងកើនឡើងយ៉ាងហោចណាស់គ្រប់គ្រាន់សម្រាប់បំពេញឱ្យកំណើនឱនភាពថវិកា ដកកំណើនសញ្ច័យឯកជន ។ វិបាកនៃការវិវត្តនេះគឺថា រូបិយវត្ថុជាតិនឹងឡើងថ្លៃ ដើម្បីសម្របនឹងឱនភាពគណនីចរន្តខ្ពស់ ។

នៅពេលដែលឱនភាពត្រូវបានទទួលហិរញ្ញប្បទានពីកម្ចីបរទេស បរិមាណសន្និធិមូលធន និងធាតុចេញពិត នៅពេលអនាគត នឹងមិនធ្លាក់ចុះទេ ។ ក៏ប៉ុន្តែ ការប្រើប្រាស់ក្នុងប្រទេសនៅអនាគត នឹងត្រូវកាត់បន្ថយដោយសារភាគចំណែកនៃចំណេញពីមូលធនដែលបានកើននោះ នឹងផ្ទេរទៅឱ្យបរទេសវិញ លើកលែងតែគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រឹងកាប្រើប្រាស់សន្និធិមូលធន ប្រកបដោយប្រសិទ្ធភាព ពង្រឹងការបង្កើតមូលធនកាន់តែច្រើន ឬ បង្កើនផលចំណេញពីមូលធន ដើម្បីបំពេញការហូរចេញនៃមូលធន ។

## ៥. ឧបករណ៍គោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

**គោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាផ្នែកមួយដ៏សំខាន់នៃគោលនយោបាយសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងគោលដៅសម្រេចអោយបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព** ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈដើរតួនាទីយ៉ាងសំខាន់ នៅក្នុងសេដ្ឋកិច្ចបែបដុល្លារូបនីយកម្ម ដូចកម្ពុជា ដោយសារសារៈសំខាន់នៃប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និង កង្វះឧបករណ៍គោលនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព ទីផ្សារហិរញ្ញវត្ថុនៅមិនទាន់រីកចំរើន និង សេដ្ឋកិច្ចមួយផ្នែកដំណើរការដោយមិនប្រើរូបិយវត្ថុ ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា មានលក្ខណៈដូចខាងក្រោម៖

- ដោយសារកម្ពុជាមិនធ្លាប់មានវដ្តធុរកិច្ច ដូច្នេះ ***គោលដៅចម្បងនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺត្រូវជំនះនូវរាល់ការលំបាកខាងផ្នែករចនាសម្ព័ន្ធសេដ្ឋកិច្ច ដើម្បីគាំទ្រការហក់ឡើងនៃសេដ្ឋកិច្ចជាតិ*** តាមរយៈការកែតម្រូវរចនាសម្ព័ន្ធសេដ្ឋកិច្ចសមស្រប ។

- ***គោលនយោបាយហិរញ្ញវត្ថុសាធារណៈផ្តោតខ្លាំងទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** ដែលជាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចរយៈពេលប្រាំឆ្នាំ មានគោលដៅពង្រីកសមត្ថភាពផលិត តាមរយៈហិរញ្ញប្បទានគម្រោងដែលមានផលចំណេញខ្ពស់ខាងផ្នែកសង្គម និងសេដ្ឋកិច្ច ។

- ***គោលនយោបាយហិរញ្ញវត្ថុសាការណៈមានគោលបំណងគៀងគរចំណូលក្នុងប្រទេស ដើម្បីធានាការបែងចែកធនធានថវិកាប្រកបដោយប្រសិទ្ធភាព ទៅតាមគោលដៅអាទិភាព និង ជាទូទៅជំរុញការអនុវត្តហិរញ្ញវត្ថុសាធារណៈប្រកបដោយស្ថិរភាព និងមាំមួន*** ។ កំណើនចំណាយសាធារណៈទាមទារការប្រឹងប្រែងបន្តទៀតរហូតប្រមូលចំណូលបានច្រើន ដែលនាពេលបច្ចុប្បន្នមានចំណែកប្រមាណ ១២% នៃ ផសស ។ គោលនយោបាយគៀងគរចំណូលត្រូវអនុវត្តនៅក្នុងបរិការណ៍នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ***គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានប្រើប្រាស់ សម្រាប់ទប់ការប្រែប្រួលអត្រាប្តូរប្រាក់*** ឱ្យនៅត្រឹមកម្រិតអប្បបរមា ។ នៅប្រទេសតូច និងមានសេដ្ឋកិច្ចបើកចំហដូចកម្ពុជា ការប្រែប្រួលអត្រាប្តូរប្រាក់អាចកាត់បន្ថយបានតាមរយៈការធានានូវការបើកផ្តល់ឥណទានប្រកបដោយរបៀបរៀបរយល្អ ដែលមិនធ្វើឱ្យកើនឡើងគំហុកនូវបរិមាណផ្គត់ផ្គង់ប្រាក់រៀល នៅក្នុងសេដ្ឋកិច្ច នៅខណៈណាមួយ ។ ឧបករណ៍គោលនយោបាយហិរញ្ញវត្ថុសាធារណៈនេះ អាចប្រើប្រាស់គួបផ្សំជាមួយឧបករណ៍គោលនយោបាយរូបិយវត្ថុ ដូចជាប្រតិបត្តិការរូបិយប័ណ្ណបរទេស (ការទិញ ឬ ការលក់ប្រាក់ដុល្លារ) ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ។

- ***គោលនយោបាយហិរញ្ញវត្ថុសាធារណៈក៏ត្រូវបានប្រើប្រាស់ ដើម្បីទប់ទល់នឹងសម្ពាធអតិផរណា*** ។ តាមរយៈការកាត់បន្ថយការប្រែប្រួលអត្រាប្តូរប្រាក់ យើងអាចរក្សាបាននូវស្ថិរភាពថ្លៃ ដោយសារទំនិញប្រើប្រាស់ភាគច្រើននៅកម្ពុជាត្រូវបាននាំចូលពីបរទេស ។ ក៏ប៉ុន្តែ សម្ពាធអតិផរណានៅកម្ពុជាអាចកើតឡើង ដោយសារការប្រែប្រួលទិន្នផលកសិកម្ម និងការប្រែប្រួលថ្លៃកសិផលតាមរដូវកាល ដោយឆ្លុះបញ្ចាំងនូវការប្រែប្រួលអាកាសធាតុ ការប្រែប្រួលការផ្គត់ផ្គង់បន្ទាប់ពីរដូវប្រមូលផល និងការវិវត្តនៃទីផ្សារកសិផលក្នុងតំបន់ ។ ដើម្បីរក្សាស្ថិរភាពថ្លៃកសិផល រាជរដ្ឋាភិបាលបានផ្តល់ឥណទានដល់សមាគមម៉ាស៊ីនកិនស្រូវកម្ពុជា ដើម្បីបង្កើនការស្តុកស្រូវ ។ ឧបករណ៍នយោបាយហិរញ្ញវត្ថុសាធារណៈនេះត្រូវបានប្រើប្រាស់ ដោយគួបផ្សំជាមួយនឹងឧបករណ៍នយោបាយផ្សេងៗទៀត ដូចជាការបង្កើនវិនិយោគសម្រាប់ការកែច្នៃ និងការធានាការប្រកួតប្រជែងស្មើភាពរវាងពាណិជ្ជករ និងឈ្មួញ តាមរយៈការកែលម្អផ្លូវថ្នល់សម្រួលការដឹកជញ្ជូន និងបង្កើនការសម្របសម្រួលពាណិជ្ជកម្ម សំដៅចូលរួមរក្សាស្ថិរភាពថ្លៃកសិផល ។

- ***ការគ្រប់គ្រងបំណុលបានល្អ គឺជាឧបករណ៍ដ៏សំខាន់មួយនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា*** ។ ប្រសិនបើចំណាយកើនឡើងច្រើន ធ្វើឱ្យមានឱនភាពថវិកាកាន់តែធំ នោះបញ្ហានៃចំណាយដោយចីរភាពត្រូវស៊ីសង្វាក់គ្នាជាមួយនឹងបញ្ហាឱនភាពថវិកាដោយចីរភាព ។ ចីរភាពនៃឱនភាពថវិកាអាស្រ័យលើផលប៉ះពាល់នៃហិរញ្ញប្បទានផ្សេងៗ ទោះបីជាត្រូវខ្ចីពីប្រភពក្នុងប្រទេស ឬពីបរទេសក៏ដោយ ។ បញ្ហាសំខាន់ គឺត្រូវកំណត់ថាតើហិរញ្ញប្បទានបរទេសប៉ុន្មានទើបសមល្មមក្នុងក្របខ័ណ្ឌចំណូល- ចំណាយដែលបានគ្រោង ដើម្បីធានាចីរភាពបំណុល ។ ប្រការនេះត្រូវតែកំណត់ បន្ទាប់ពីការវាយតម្លៃសក្តានុពលនៃកំណើនសេដ្ឋកិច្ច ការខិតខំប្រមូលចំណូល និងលទ្ធផលនៃការចរចារបំណុលចាស់របស់កម្ពុជា ជាមួយម្ចាស់បំណុលធំៗពីគឺសហរដ្ឋអាមេរិក និងរុស្ស៊ី ។

- ***គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំ និងអនុវត្តស្របនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការរបស់ព្រះរាជាណាចក្រកម្ពុជា*** ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានអនុវត្ត ដើម្បីគាំទ្រគំនិតផ្តួចផ្តើមវិមជ្ឈការ ដោយប្រគល់ភារកិច្ចក្នុងការប្រមូលចំណូលមួយចំនួន ក៏ដូចជាការទទួលខុសត្រូវខាងផ្នែកចំណាយទៅថ្នាក់ខេត្ត ស្រុក និង ឃុំ ។

## ៥.១ ឧត្តមភាពនៃគោលនយោបាយចំណាយ

ចំណាយសាធារណៈគឺជាទម្រង់អន្តរាគមន៍មួយក្នុងចំណោមទម្រង់អន្តរាគមន៍ជាច្រើនទៀតរបស់រដ្ឋាភិបាល ដែលធ្វើឡើងដើម្បីបំពេញកង្វះខាតនៃទីផ្សារប្រកួតប្រជែង និងធានាសមធម៌នៃការបែងចែក (Chu និង Hemming ១៩៩១)។ កង្វះខាតនៃទីផ្សារកើតមានឡើងដោយសារៈ (១) ទីផ្សារគ្មានអត្ថិភាពសម្រាប់គ្រប់ទំនិញទេ (២) មានផលប៉ះពាល់ខាងក្រៅ ពោលគឺថ្លៃមិនឆ្លុះបញ្ចាំងនូវចំណាយ និងផលចំណេញសង្គម ដែលពាក់ព័ន្ធជាមួយផលិតកម្ម និងការប្រើប្រាស់ទំនិញ ឬសេវា (៣) អត្ថិភាពនៃភាពផ្តាច់មុខធម្មជាតិ (Natural Monopoly) ។ល។ បាតុភូតនៃកង្វះខាតទីផ្សារពាក់ព័ន្ធទៅនឹងការផ្គត់ផ្គង់ទំនិញសាធារណៈ (ថ្លៃទីផ្សារនៃទំនិញទាំងនោះមានលក្ខណៈមិនសមស្រប) និង ទំនិញសម្ហូហភាព (ដែលមានឥទ្ធិពលប៉ះពាល់ខាងក្រៅ) ការលេចឡើងនៃភាពផ្តាច់មុខធម្មជាតិ (នៅពេលដែលដំណើរផលិតកម្មមានផលចំណេញខ្ពស់) និង តម្រូវការធានារ៉ាប់រងសង្គម (កើតឡើងពីព័ត៌មានមិនស្មើភាព) ។ អសមត្ថភាពនៃសេដ្ឋកិច្ចទីផ្សារក្នុងបែងចែកចំណូល និងសុខមាលភាពសង្គមឱ្យបានសមរម្យ ក៏អាចចាត់ទុកថា ជាកង្វះខាតទីផ្សារ ។

ចំណាយសាធារណៈបម្រើឱ្យគោលដៅសេដ្ឋកិច្ច សង្គម និងនយោបាយ ។ អន្តរាគមន៍របស់រដ្ឋាភិបាលបែបនេះត្រូវបានរៀបចំឡើង ដើម្បីធានា***ភាពល្អប្រសើរប៉ារេតូ*** (Pareto optimality) ក្នុងការបែងចែកធនធាននៅក្នុងសេដ្ឋកិច្ចប្រកួតប្រជែងដូចជាៈ (១) ធាតុចូលមិនអាចយកទៅប្រើប្រាស់ ដើម្បីបង្កើនផលទំនិញមួយឱ្យខ្ពស់ដោយគ្មានការកាត់បន្ថយផលទំនិញផ្សេងទៀតទេ និង (២) បរិមាណផលសរុប មិនអាចយកទៅចែករំលែកដើម្បីធ្វើឱ្យអ្នកប្រើប្រាស់ម្នាក់មានសុខមាលភាពកាន់តែខ្ពស់ ដោយគ្មានការកាត់បន្ថយសុខមាលភាពអ្នកប្រើប្រាស់ដទៃទេ (Chu និង Hemming ១៩៩១) ។ ភាពល្អប្រសើរប៉ារេតូ (Pareto optimality) ក្នុងចំណាយសាធារណៈតម្រូវថា ការខាតបង់សង្គមនៃចំណាយសាធារណៈមួយឯកតាបន្ថែម ស្មើនឹងផលចំណេញសង្គមពីចំណាយមួយឯកតាបន្ថែមនោះ ។

ចំណាយរដ្ឋាភិបាលដ៏ច្រើនត្រូវបានប្រើប្រាស់ សម្រាប់ផលិតកម្មទំនិញសាធារណៈ ។ ទំនិញសាធារណៈអាចចែកចេញជា សុទ្ធ និងមិនសុទ្ធ (pure and impure)។

ទំនិញសាធារណៈសុទ្ធ អាចត្រូវបានកំណត់ដូចខាងក្រោម (Rosen, 2005) ÷

- នៅខណៈដែលទំនិញត្រូវបានផ្គត់ផ្គង់ ចំណាយធនធានបន្ថែមសម្រាប់ការប្រើប្រាស់ទំនិញនេះរបស់អ្នកដទៃទៀត ស្មើនឹងសូន្យ ពោលគឺគ្មានប្រជែង (non-rivalry) និងមិនអាចចែកដាច់ដោយឡែកបាន (indivisibility) ក្នុងការប្រើប្រាស់ ។

- ការហាមឃាត់នរណាម្នាក់មិនឱ្យប្រើប្រាស់ ត្រូវចំណាយខ្ពស់បំផុត ឬមិនអាចធ្វើបាន ពោលគឺគ្មានការលើកលែង (non-excludability) ក្នុងការប្រើប្រាស់ ។ (ផ្ទុយទៅវិញ ទំនិញឯកជនដូចជា


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ភិតសា គឺមានលក្ខណៈប្រជែង និង អាចលើកលែង) ។

ឧទាហរណ៍នៃទំនិញសាធារណៈសុទ្ធ មានតិចតួច រួមមាន សេវាសុខភាពសាធារណៈ ការពារជាតិ ការបន្ថយការបំពុលបរិយាកាស ការគ្រប់គ្រងទឹកជំនន់ ការព្យាករណ៍អាកាសធាតុ និង ការផ្តល់ព័ត៌មានបង្ការគ្រោះអាសន្ន (Lighthouses) ។ ការប្រើប្រាស់ទំនិញសាធារណៈមិនសុទ្ធ នៅពេលខ្លះមានការប្រជែង (Rival) និង អាចលើកលែង (Excludable) ។

ប៉ុន្តែ មានទំនិញជាច្រើនមានឈ្មោះថា **ទំនិញរួម** (Collective goods) ដែលមានលក្ខណៈខ្លះដូចទំនិញសាធារណៈ ។ ទំនិញទាំងនេះបង្ហាញនូវផលប៉ះពាល់ខាងក្រៅ ក្នុងការប្រើប្រាស់ ឬក្នុងផលិតកម្ម ប៉ុន្តែមានលក្ខណៈប្រជែងពេលប្រើប្រាស់ ។ ទំនិញទាំងនេះអាចលើកលែងបាន ប៉ុន្តែផលចំណេញ និងចំណាយមួយចំនួនពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទំនិញប្រភេទនេះ ធ្លាក់ទៅលើបុគ្គលដទៃ ឬសង្គម ។ ទោះបីជាផ្នែកឯកជនអាចផ្គត់ផ្គង់ទំនិញ និងសេវា ដែលមានផលប៉ះពាល់ខាងក្រៅ បរិមាណដែលផ្គត់ផ្គង់មិនសមស្របទៅនឹងកម្រិតតម្រូវការសង្គមឡើយ ។ ដូចនេះ ជាចាំបាច់ត្រូវមានចំណាត់ការរបស់រដ្ឋាភិបាល ដើម្បីជួយសង្គមសម្រេចបានបរិមាណផលិតផលដ៏សមរម្យ ។ ទំនិញសាធារណៈ ដូចជាការអប់រំ ការចាក់ថ្នាំបង្ការ ការបោះចោលកាកសំណល់ និង ការដឹកជញ្ជូនមួយចំនួនបង្ហាញពីផលប៉ះពាល់ខាងក្រៅនៃប្រភេទនេះ ។ កម្រិតផលិតកម្មដ៏សមរម្យនៃទំនិញទាំងនេះ ដែលសង្គមត្រូវការអាចនឹងសម្រេចបាន តាមរយៈការប្រើប្រាស់ថវិកាសម្រាប់ឧបត្ថម្ភធនដល់ផលិតកម្ម និងការប្រើប្រាស់របស់ពួកគេ ។

ភាពផ្តាច់មុខធម្មជាតិ (Natural Monopoly) កើតមានឡើងនៅពេលដែលក្រុមហ៊ុនមួយគ្រប់គ្រងវិស័យទាំងមូល ព្រោះថា មានការធ្លាក់ចុះ ជាបន្តបន្ទាប់នូវចំណាយមធ្យមនៃខ្សែកោងផលិតកម្ម ។ ជានិច្ចកាលវាអាចពង្រីកសមត្ថភាពផលិត ដោយមានចំណាយទាបជាងនេះ ក្នុងកម្រិតដែលក្រុមហ៊ុនថ្មីអាចបង្កើតសមត្ថភាពបន្ថែមដូចគ្នា ។ ក្នុងករណីនេះ ការដាក់តម្លៃស្មើចំណាយបន្ថែម (Marginal cost) នឹងនាំឱ្យមានការខាតបង់ដោយសារចំណាយបន្ថែមជារឿយៗទាបជាងចំណាយមធ្យម ។ ប្រសិនបើសង្គមទាញផលចំណេញពីតម្លៃទាបជាង និង ផលិតច្រើនជាងអ្នកផ្តាច់មុខឯកជន ដែលកំពុងតែរកចំណេញជាអតិបរមា នោះផលិតករឯកជនត្រូវទទួលបានឧបត្ថម្ភធន ឬ ផ្នែករដ្ឋត្រូវកាន់កាប់វិស័យទាំងស្រុង និងទទួលខាតដោយផ្ទាល់ ។ ឧទាហរណ៍ ក្រុមហ៊ុនដែលមានចំណាយកំពុងធ្លាក់ចុះរួមមាន ឧស្ម័ន អគ្គិសនី រដ្ឋាករទឹក ទូរគមនាគមន៍ និង ការដឹកជញ្ជូនគ្រប់ប្រភេទទាំងអស់នេះមានលក្ខណៈជាបណ្តាញទូលំទូលាយ ដែលអាចមានចំណាយខ្ពស់ និងគ្មានប្រសិទ្ធភាពសម្រាប់អ្នកផ្គត់ផ្គង់ធ្វើការប្រកួតប្រជែងគ្នា ។ ការផ្គត់ផ្គង់ទំនិញ និងសេវាទាំងនេះជាសាធារណៈ គឺសមហេតុផល ។

បន្ទាប់ពីមានការពិចារណាដូចខាងលើ ចំណាយថវិកាត្រូវបានរៀបចំ សម្រាប់បម្រើគោលនយោបាយមួយចំនួនដូចខាងក្រោម៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ការផ្គត់ផ្គង់ទំនិញសាធារណៈ** ពោលគឺដើម្បីធានាថា សម្រេចបានបរិមាណដ៏សមរម្យនៃផលិតផលសង្គមជាតិ និងបំពេញតួនាទីវិភាជន៍នៃគោលនយោបាយថវិកា ។

- **ការកែតម្រូវលើវិភាជន៍ចំណូល និងទ្រព្យសម្បត្តិ** ដើម្បីធានាពីការគោរពទៅតាមអ្វីដែលសង្គមយល់ឃើញថា ជាវិភាជន៍ដោយ «ស្មើភាព» ឬ «យុត្តិធម៌» ពោលគឺតួនាទីនៃវិភាជន៍ ។

- **ការប្រើប្រាស់គោលនយោបាយថវិកា ជាមធ្យោបាយរក្សាអនិកម្មភាពខ្ពស់** ស្ថិរភាពថ្លៃសមរម្យ និងកំណើនសេដ្ឋកិច្ចសមស្រប ដែលមានផលប៉ះពាល់លើពាណិជ្ជកម្ម និងជញ្ជីងទូទាត់ ពោលគឺតួនាទីនៃការធ្វើឱ្យមានស្ថិរភាព ។

ប៉ុន្តែការជ្រើសយកបង្គំនៃគោលនយោបាយចំណាយទាំងនោះ អាចមានភាពស្មុគ្រស្មាញ ។ តាមមតិរបស់ **ប្រេមចានដ៍** (Premchand) ផលប៉ះពាល់បីសំខាន់ៗរបស់ថវិកា គឺ៖

- **ទីមួយ**- ការរៀបចំថវិកាទាក់ទងនឹងការរកឱ្យឃើញ និងការវាស់វែងផលប៉ះពាល់នៃប្រតិបត្តិការថវិកា លើសេដ្ឋកិច្ច និង ផលប៉ះពាល់សេដ្ឋកិច្ចលើថវិកា និងទំនាក់ទំនងនៃប្រតិបត្តិការទាំងនេះ ជាមួយគោលដៅគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជារួម ។

- **ទីពីរ**- គោលដៅនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈអាចសម្រេចបាន តាមរយៈឧបករណ៍ថវិកាចម្រុះរួមមាន ពន្ធ ចំណាយ និងកម្ចី ។

- **ទីបី**- គោលដៅនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានត្រូវបានអនុវត្ត តាមរយៈប្រតិបត្តិការដោយផ្ទាល់របស់រដ្ឋាភិបាល ដោយរួមទាំងរដ្ឋបាលថ្នាក់ផ្សេងទៀត គឺ ថ្នាក់ខេត្ត និងឃុំសង្កាត់ ក៏ដូចជាតាមរយៈសហគ្រាសសាធារណៈ ។

ទំនិញសាធារណៈ ផលប៉ះពាល់ខាងក្រៅ ទីផ្សារផ្តាច់មុខធម្មជាតិ និងសេចក្តីត្រូវការធានារ៉ាប់រងសង្គមសុទ្ធតែផ្តល់ឱ្យរដ្ឋាភិបាលនូវតួនាទីវិភាជន៍ ។ កង្វះខាតទីផ្សារ អាចបង្កើតលក្ខខណ្ឌ ដែលងាកចេញពីភាពប្រសើរដ៏ល្អបំផុត ។ ដូចនេះ ដើម្បីដឹកនាំសេដ្ឋកិច្ចទៅរកភាពប្រសើរថ្មីមួយទៀត រដ្ឋាភិបាលត្រូវប្រើពន្ធ ការឧបត្ថម្ភធន និងការត្រួតពិនិត្យជាប្រចាំ ដែលអាចធ្វើឱ្យមានភាពខុសប្រក្រតីដោយខ្លួនឯង ។ ដូចនេះ គោលនយោបាយហិរញ្ញវត្ថុសាធារណៈអាចសម្រេចបានជោគជ័យនូវដំណោះស្រាយល្អទីពីរ ។

រដ្ឋាភិបាលក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងវិភាជន៍ប្រាក់ចំណូលឡើងវិញ ។ លក្ខខណ្ឌសម្រាប់ **ភាពប្រសើររបស់ប៉ារេតូ** (Pareto) តម្រូវឱ្យវិភាជន៍ចំណូល និងសុខមាលភាព នៅពេលដំបូង មានលក្ខណៈស្មើភាព ។ ដោយមូលហេតុថាលក្ខខណ្ឌនេះមិនអាចសម្រេចបានក្នុងការអនុវត្តជាក់ស្តែង សារៈសំខាន់នៃ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គោលនយោបាយវិភាជន៍ឡើងវិញរបស់រដ្ឋាភិបាល គឺត្រូវផ្តល់សេវាសុខភាពសាធារណៈ ការអប់រំ ផ្ទះសម្បែង និង សេវាសង្គមផ្សេងៗទៀត ។ ក៏ប៉ុន្តែ បណ្តាគោលនយោបាយ ដែលនាំទៅរកការកែលម្អវិភាជន៍ធនធាន និងវិធានការវិភាជន៍ចំណូលឡើងវិញ ទាមទារអោយមានចំណាយដើម្បីធានានូវប្រសិទ្ធភាព ។

***កម្រិត និងសមាសភាពនៃចំណាយសាធារណៈ អាចមានផលប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច*** ។ ដូចនេះ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចមានសារៈសំខាន់សម្រាប់ធានាកំណើនប្រកបដោយចីរភាព តាមរយៈការជំរុញសញ្ជ័យក្នុងប្រទេស ការវិនិយោគប្រកបដោយផលិតភាព និងប្រសិទ្ធភាពនៃការវិភាជន៍ធនធាន ។

ផលប៉ះពាល់នៃគោលនយោបាយចំណាយទៅលើវិភាជន៍ចំណូល ចាត់ទុកថាជា **ឧប្បត្តិហេតុចំណាយ** (expenditure incidence) ។ រដ្ឋាភិបាលគ្រប់គ្រងវិភាជន៍ចំណូលតាមរយៈការយកពន្ធ ក៏ដូចជាគោលនយោបាយចំណាយ ។

កម្មវិធីរបស់រដ្ឋាភិបាលបង្កើតខ្សែសង្វាក់នៃការផ្លាស់ប្តូរថ្លៃ ដែលជះឥទ្ធិពលទៅលើចំណូលប្រជាជន ទាំងក្នុងតួនាទីជាអ្នកប្រើប្រាស់ទំនិញ ទាំងតួនាទីជាអ្នកផ្គត់ផ្គង់ធាតុចូល ។ កម្មវិធីចំណាយដែលបង្កើនថ្លៃទំនិញប្រៀបធៀបនឹងធ្វើឱ្យអ្នកប្រើប្រាស់ទំនិញទាំងនោះទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ។ ដូចគ្នានេះដែរ កម្មវិធីដែលបង្កើនថ្លៃកត្តាផលិតកម្ម នឹងបង្កើនសុខមាលភាពអ្នកផ្គត់ផ្គង់កត្តាផលិតកម្មទាំងនោះ ។ ប៉ុន្តែ គេពិបាកធ្វើការព្យាករណ៍ ដោយច្បាស់លាស់ពីការប្រែប្រួលថ្លៃ ដោយសារគោលនយោបាយពិសេសណាមួយ ។

ការកើនចំណាយត្រូវស្មើនឹងកំណើនចំណូលពន្ធ ធ្វើឱ្យឱនភាពថវិកានៅដដែល ។ ដោយយោងតាមគោលការណ៍នៃ **មេគុណតុល្យភាពថវិកា** វានឹងមានផលប៉ះពាល់ជាវិជ្ជមាន ទៅលើតម្រូវការសរុប និង ធាតុចេញ ។ ចំពោះសេដ្ឋកិច្ចមិនបើកចំហ ចំណូលសរុបនឹងកើនឡើងស្មើនឹងចំនួនកំណើនចំណាយ ប៉ុន្តែចំពោះសេដ្ឋកិច្ចបើកចំហ កំណើនចំណូលមានចំនួនទាបជាង ដោយសារផ្នែកខ្លះនៃកំណើនចំណាយហូរចេញពីសេដ្ឋកិច្ចតាមរយៈការនាំចូល ។

ផលវិបាកនៃការបង្កើនចំណាយថវិកាប្រកបដោយតុល្យភាព ទៅលើធាតុចេញអាចនៅមានកម្រិត ។ ជាពិសេស ការផ្គត់ផ្គង់សរុបប្រហែលមិនអាចកើនឡើងទៅតាមកំណើននៃតម្រូវការសរុបបានឡើយ ប្រសិនបើមានកំហិតសមត្ថភាពផលិត ឬការដាក់ពន្ធបន្ថែមសម្រាប់បំពេញឱ្យចំណាយនឹងមិនលើកទឹកចិត្តដល់ការបំពេញការងារ និង សញ្ជ័យ ។

### *៥.២- ថវិកាជាតិ និង ការធ្វើហិរញ្ញប្បទាន*

**គោលបំណងនៃការរៀបចំថវិកា គឺការសម្រេចបាននូវប្រសិទ្ធភាពប្រតិបត្តិការ និងប្រសិទ្ធភាព**


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**វិភាជន៍ធនធានក្នុងវិស័យសាធារណៈ** **និងគោរពទៅតាមគោលដៅនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ។ ដូចនេះថវិកាបម្រើឱ្យកម្មវិធីនយោបាយ និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងជាឧបករណ៍ដ៏សំខាន់សម្រាប់បំពេញតួនាទីហិរញ្ញវត្ថុចំនួនបួនរបស់រដ្ឋគឺៈ ១) ការកៀងគរធនធាន ២) ការវិភាជន៍ធនធាន ៣) ការបែងចែកចំណូល និង ៤) ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

### ៥.២.១ គោលការណ៍នៃថវិកា

ថវិកាមានគោលការណ៍ដូចតទៅៈ ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ឯកត្តភាព សកលភាព វិសេសភាព និងតុល្យភាព ។

- **ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ** - ច្បាប់ហិរញ្ញវត្ថុ ផ្តល់សិទ្ធិ និងអនុញ្ញាតសម្រាប់ចំណូលនិងចំណាយរៀងរាល់ឆ្នាំ ។ ឆ្នាំថវិកានៅកម្ពុជា ចាប់ផ្តើមពីថ្ងៃ ១ ខែមករា និង បញ្ចប់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ។

- **ឯកត្តភាពនៃថវិកា** - គោលការណ៍នេះនាំអោយមានផលប៉ះពាល់ពីគឺៈ តម្រូវឱ្យរដ្ឋាភិបាលរៀបចំថវិកាដែលមានចំណូល និងចំណាយថវិកាសរុប ទៅអោយសភាជាតិអនុម័ត ជារៀងរាល់ឆ្នាំ ។ ចំណូល និងចំណាយទាំងនេះត្រូវតែរៀបចំឡើងក្នុងពេលតែមួយ ដើម្បីធានាតុល្យភាពគ្រប់ទិដ្ឋភាពនៃថវិកា ។

- **សកលភាពនៃថវិកា** - មានផលវិបាកពីរគឺៈ ហាមឃាត់ដាច់ខាតការកាត់កងចំណូល ដើម្បីទូទាត់ចំណាយថវិកា និងមិនអនុញ្ញាតអោយរក្សាទុកចំណូល សម្រាប់តែមុខចំណាយពិសេសណាមួយ ។ ចំណូលត្រូវតែកត់ត្រាទាំងស្រុង ដោយមិនទូទាត់ជាមួយចំណាយ ពោលគឺបរិមាណចំណូលសរុប ត្រូវប្រើដើម្បីធ្វើហិរញ្ញប្បទាននូវបរិមាណចំណាយសរុប ។

- **វិសេសភាពនៃថវិកា** - ចំណូល និងចំណាយថវិកា ត្រូវបង្ហាញដាច់ដោយឡែកពីគ្នាក្នុងថវិកា ស្របទៅនឹងចំណាត់ថ្នាក់ ដែលតម្រូវដោយសភាជាតិ ។

- **តុល្យភាពនៃថវិកា** - គោលការណ៍នេះតម្រូវឱ្យចំណាយថវិកា ចំណូលថវិកា និងហិរញ្ញប្បទាន ត្រូវតែរៀបចំទៅតាមទម្រង់ចំណាត់ថ្នាក់សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមាន និង បង្ហាញអោយឃើញថា ថវិកាមានតុល្យភាព ។

ថវិកាជាតិនៅព្រះរាជាណាចក្រកម្ពុជា ចែកចេញជាៈ ថវិការដ្ឋ ដែលចែកជាថវិការដ្ឋបាលកណ្តាល ថវិកាខេត្ត-ក្រុង និង ថវិកាឃុំសង្កាត់ ។ បណ្តាក្រសួង-ស្ថាប័នថ្នាក់កណ្តាល ដែលជាអាណាប័កដើមខ្សែ ផ្តល់សិទ្ធិក្នុងការគ្រប់គ្រងថវិការបស់មន្ទីរក្រោមឱវាទខ្លួននៅតាមខេត្ត-ក្រុង ទៅឱ្យអភិបាលខេត្ត-ក្រុង ជាអ្នកដើរតួអាណាប័កផ្ទេរសិទ្ធិ លើថវិកាមន្ទីរ- ខេត្តក្រុង ។ អភិបាលខេត្ត-ក្រុង ដើរតួនាទីជាអាណាប័កដើមខ្សែ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សម្រាប់ថវិកាខេត្ត-ក្រុង និងជាអាណាប័កផ្ទេរសិទ្ធិសម្រាប់ថវិកាមន្ទីរខេត្ត-ក្រុង ។

### ៥.២.២ ចំណាត់ថ្នាក់ថវិកា

ចំណាយថវិកាចែកចេញជាចំណាយចរន្ត និងចំណាយមូលធន ។ ចំណាយចរន្តរួមមានប្រភេទចំណាយមួយចំនួនដូចជា៖ ចំណាយសេវាកម្ម ចំណាយហិរញ្ញវត្ថុ (ការបង់ការប្រាក់) អន្តរាគមន៍សាធារណៈ (អំណោយឧបត្ថម្ភ និងឧបត្ថម្ភធនចំពោះស្ថាប័ន និង វិភាគទានចំពោះអង្គការអន្តរជាតិ) ចំណាយផ្សេងៗ (ឧបត្ថម្ភធនចំពោះថវិកាខេត្ត ឧបត្ថម្ភធនចំពោះថវិកាឃុំសង្កាត់ ចំណាយមិនបានគ្រោងទុក ។ល។)

ចំណាយមូលធនរួមមាន៖ ការសងបំណុល ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស ចំណាយដោយហិរញ្ញប្បទានពីក្រៅប្រទេស ។ ចំណាយវិនិយោគ ដែលទទួលហិរញ្ញប្បទានពីប្រភពក្នុងប្រទេសរួមមានការទិញទ្រព្យសកម្ម (យានយន្ត ឧបករណ៍និងគ្រឿងម៉ាស៊ីន និងអាគារ) និង ការសាងសង់ (ហេដ្ឋារចនាសម្ព័ន្ធ) ។

មាតិកាគណនីផ្តល់នូវលេខកូដគណនេយ្យ សម្រាប់ចំណាត់ថ្នាក់ចំណាយតាមមុខងារ និងមុខងាររង និងសម្រាប់ស្ថាប័នសាធារណៈ ។ ចំណាត់ថ្នាក់ថវិការៀបរាប់អំពីបរិបទនៃការរៀបចំថវិកា និងរចនាសម្ព័ន្ធថវិកា ។ គោលដៅនៃចំណាត់ថ្នាក់ថវិកាគឺ៖

- ***បែងចែកថវិកា ទៅតាមក្រសួង-ស្ថាប័នសាធារណៈ និងកម្មវិធីរបស់ក្រសួងទាំងនោះ អង្គភាពចំណុះ អនុកម្មវិធី និង គម្រោងនានា*** ។ តាមរយៈប្រភេទ និងលេខកូដនៃថវិកាទូទៅ ចំណាយចរន្ត និងចំណាយមូលធនបង្ហាញនូវសង្គតិភាព និងការប្រទាក់ក្រឡាគ្នា ។
- ***ជំរុញការទទួលខុសត្រូវ*** តាមរយៈការអនុវត្តនូវទស្សទានមណ្ឌលថ្លៃ ដោយការគ្រោងថវិកាយ៉ាងហ្មត់ចត់ទៅតាមរចនាសម្ព័ន្ធនៃអង្គភាពទាំងអស់ដែលនៅក្រោមឱវាទរបស់ក្រសួង- ស្ថាប័នសាធារណៈនីមួយៗ ។
- ***បញ្ជាក់ពីប្រភពហិរញ្ញប្បទាន*** ទៅតាមបន្ទាត់ថវិកា សម្រាប់អង្គភាពក្រោមចំណុះ និងប្រភេទថវិកាគម្រោង ។ មានប្រភពហិរញ្ញប្បទានបួនគឺ រតនាគារជាតិ ចំណូលរក្សាទុក ជំនួយបរទេស និងកម្ចីបរទេស ។

#### ក-ចំណាត់ថ្នាក់តាមមុខងារ

ចំណាត់ថ្នាក់តាមមុខងារនៃចំណាយថវិកាចរន្ត ចែកប្រភេទចំណាយទៅតាមគោលដៅប្រតិបត្តិការដែលបានអនុវត្ត ដោយបែងចែកក្រសួង- ស្ថាប័នទៅតាមផ្នែកមួយចំនួន ដូចជា៖ រដ្ឋបាលទូទៅ សេដ្ឋកិច្ច សង្គមកិច្ច និង ចំណាយមានគោលដៅទូទៅ ដូចជា សេវាបុគ្គលិក ទំនិញនិងសេវា ការធ្វើដំណើរ ការថែទាំជួសជុល និង សេវាកិច្ចសន្យា ។ល។ ចំណាត់ថ្នាក់តាមមុខងារក៏អាចបង្ហាញតាមបែបកម្មវិធី ឬ គោលដៅចំណាយបែបទូលំ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទូលាយ ។ ចំណាត់ថ្នាក់តាមមុខងារត្រូវបានប្រើប្រាស់ សម្រាប់កំណត់វិភាជន៍ធនធានតាមរយៈរដ្ឋាភិបាល ដើម្បីជំរុញសកម្មភាព និងគោលដៅផ្សេងៗ និងឆ្លុះបញ្ចាំងយ៉ាងទូលំទូលាយ ជាមួយចំណាត់ថ្នាក់តាមវិស័យ ពោលគឺ អប់រំ សុខាភិបាល ដឹកជញ្ជូន ។ល។

## ខ- ចំណាត់ថ្នាក់សេដ្ឋកិច្ច

ចំណាយថវិកាអាចចាត់ថ្នាក់ទៅតាមសារធាតុសេដ្ឋកិច្ចនៃប្រតិបត្តិការហិរញ្ញវត្ថុ ។ ជារួម យើងឃើញថា វាជាមធ្យោបាយមួយដើម្បីវាស់វែងផលប៉ះពាល់ខាងផ្នែកសេដ្ឋកិច្ច តាមរយៈប្រតិបត្តិការរបស់រដ្ឋាភិបាល ទាក់ទងទៅនឹងការទូទាត់ផ្តល់អោយអ្នកផ្គត់ផ្គង់កត្តាផលិតកម្មផ្សេងៗ ។

ការរៀបចំថវិកា ទៅតាមមាតិកាថវិកាអោយបានល្អ គឺជាមូលដ្ឋានសម្រាប់ចំណាត់ថ្នាក់សេដ្ឋកិច្ច ។ នៅក្នុងប្រព័ន្ធថវិកាតាមមាតិកាថវិកា ចំណាយអាចរៀបចំស្របនឹងគោលដៅចំណាយ ឬ «ខ្ទង់ថវិកា» ។ មាតិកានីមួយៗមានលក្ខណៈលម្អិត ដែលបង្ហាញអំពីថាតើក្រសួង និងមន្ទីរនៅតាមខេត្ត ត្រូវចាយប៉ុន្មានលើមុខចំណាយនីមួយៗដូចជា៖

- **សេវាបុគ្គលិក** រួមមានប្រាក់បំណាច់ (ប្រាក់បៀវត្ស និង ប្រាក់ឈ្នួល) ប្រាក់ឧបត្ថម្ភ ប្រយោជន៍ផ្សេងៗ និងវិភាគទានសោធននិវត្តន៍ ។
- **ទំនិញ និងសេវា** រួមមានសម្ភារៈការិយាល័យ ថ្នាំពេទ្យ សម្ភារៈសិក្សា អាហារ ប្រេងឥន្ធនៈ និងប្រេងរំអិល។
- **សេវាដឹកជញ្ជូន និងសេវាកំសាន្តផ្លូវការ** ។
- **សេវាថែទាំ និងជួសជុល** ។
- **សេវាតាមកិច្ចសន្យា** រួមមាន ថ្លៃអគ្គិសនី ទូរស័ព្ទ ទឹក និងអត្ថប្រយោជន៍ផ្សេងៗដូចជា ថ្លៃឈ្នួលកម្រៃផ្សេងៗទៀត ។

គោលដៅនៃការធ្វើថវិកាតាមមាតិកានីមួយៗ គឺដើម្បីទប់ស្កាត់ការចាយលើស និងធានាទូវវិន័យថវិកា ។ ថវិកាកំណត់កម្រិតចំណាយតាមមាតិកា ដើម្បីធានាថា ក្រសួង និងស្ថាប័ននីមួយៗ មិនចាយលើសពីវិភាជន៍ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ បានបង្កើតទម្រង់ការ (នីតិវិធី) ដើម្បីតាមដាន និងត្រួតពិនិត្យចំណាយ ។ ការផ្ទេរឥណទានថវិកាពីក្រសួងមួយទៅក្រសួងមួយទៀត តម្រូវអោយមានការយល់ព្រមពីរដ្ឋសភា ។ ការផ្ទេរឥណទានថវិកាពីជំពូកមួយទៅជំពូកមួយទៀតក្នុងក្របខ័ណ្ឌឥណទានរបស់ក្រសួង- ស្ថាប័ន ត្រូវមានការអនុញ្ញាតពីនាយករដ្ឋមន្ត្រី ។ ការផ្ទេរឥណទានថវិកាក្នុងជំពូក តម្រូវអោយមានការសម្រេចពីរដ្ឋមន្ត្រី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ៥.២.៣ ថវិកាតាមកម្មវិធី

ដើម្បីបំពេញកង្វះខាតនៃប្រព័ន្ធថវិកាតាមមាតិកាថវិកា ចាប់ពីឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាប់ផ្តើមអនុវត្តនូវការធ្វើថវិកាតាមកម្មវិធី ជាដំណាក់កាលៗ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់អោយអនុវត្តសាកល្បង នូវទស្សនទាននៃការរៀបចំថវិកាតាមកម្មវិធី ចាប់តាំងពីឆ្នាំ ២០០០ មកម្ល៉េះ តាមរយៈកម្មវិធីសកម្មភាពជាអាទិភាព (PAP) ដែលត្រូវបានចាប់ផ្តើមអនុវត្តដំបូងចំពោះក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសុខាភិបាល បន្ទាប់មកត្រូវបានពង្រីកដល់ក្រសួងផ្សេងៗទៀត ដូចជា ក្រសួងកសិកម្ម និង ក្រសួងអភិវឌ្ឍន៍ជនបទ ។

ការរៀបចំថវិកាតាមកម្មវិធីផ្តោតជាសំខាន់ លើជម្រើសផ្សេងៗក្នុងចំណោមគោលនយោបាយប្រកួតប្រជែង ដើម្បីដាក់ចូលក្នុងថវិកា ។ គោលដៅគោលនយោបាយ ត្រូវបានចាត់ទុកថាជាអញ្ញត្តិនៃកម្មវិធី ។ **ឥណទានថវិកាត្រូវបានវិភាជតាមកម្មវិធី ដែលជាប្រព័ន្ធវិភាជន៍ធនធាន** ។ ការធ្វើថវិកាតាមកម្មវិធីមានគោលដៅផ្សារភ្ជាប់ចំណាយកម្មវិធី ទៅនឹងលទ្ធផលនៃកម្មវិធីសាធារណៈ ។

សមាសធាតុចម្បងនៃការធ្វើថវិកាតាមកម្មវិធី គឺថា គ្រប់ក្រសួងទាំងអស់ ត្រូវរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យ ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រ ។ កម្មវិធីត្រូវបានប្រើជាគោលដៅគោល-នយោបាយសាធារណៈ ដោយមានវិធានការចាំបាច់សម្រាប់សម្រេចគោលដៅទាំងនោះ ។ ថវិកាត្រូវបានបែងចែកតាមកម្មវិធី ដោយមិនឆ្លុះបញ្ចាំងនូវរចនាសម្ព័ន្ធស្ថាប័នឡើយ ។ ការធ្វើថវិកាតាមកម្មវិធីតម្រូវឱ្យរៀបចំនូវគោលដៅកម្មវិធី អោយបានច្រើនជាងមួយឆ្នាំ ។ កម្មវិធីចែកចេញជា អនុកម្មវិធី ដែលជាបណ្តុំសកម្មភាពប្រហាក់ប្រហែលគ្នា។ អនុកម្មវិធីចែកជា គម្រោង ដែលជាសកម្មភាពមួយ ឬច្រើន ដែលមានគោលដៅជាក់លាក់ និង ដែលមានធាតុចេញ និង លទ្ធផល ដែលអាចកំណត់បាន ។

កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាក់ព័ន្ធកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ននេះ គឺជាការខិតខំផ្សារភ្ជាប់ការរៀបចំថវិកាតាមកម្មវិធីទៅនឹងសមិទ្ធកម្ម ។ បណ្តាក្រសួងពាក់ព័ន្ធត្រូវធ្វើសមាហរណកម្មព័ត៌មាន អំពីសកម្មភាពរបស់ខ្លួនផ្ទាល់ ចូលក្នុងដំណើរការរៀបចំថវិកា ជាហេតុធ្វើឱ្យការសម្រេចខាងផ្នែកថវិកាត្រូវឈរលើមូលដ្ឋាននៃទំនាក់ទំនងរវាងសកម្មភាពរដ្ឋាភិបាល និងចំណាយដែលត្រូវអនុវត្តសកម្មភាពទាំងនោះ ។ កំណែទម្រង់នាពេលបច្ចុប្បន្នបង្ហាញពីការផ្លាស់ប្តូរ ពីការធ្វើថវិកាដែលផ្អែកលើការត្រួតពិនិត្យចំណាយ ទៅការធ្វើថវិកា ដែលផ្អែកលើការគ្រប់គ្រង និងសមិទ្ធកម្ម ។ ថវិកាតាមកម្មវិធី គឺជាឧបករណ៍សម្រាប់វិភាជន៍ឥណទានថវិកា និងផ្តល់នូវធាតុចូល ដើម្បីសម្រេចបាននូវសមិទ្ធកម្មដែលរំពឹងទុក ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៥.២.៤ ចំណាត់ថ្នាក់ចំណាយ

ចំណាយចរន្តនៃថវិកាទូទៅរបស់រដ្ឋត្រូវបានបែងចែកជា ៦ ប្រភេទៈ មធ្យោបាយសេវា បន្ទុកហិរញ្ញវត្ថុ អន្តរាគមន៍សាធារណៈ ចំណាយផ្សេងៗ ចំណាយតាមដីការ (មិនឆ្លងសាច់ប្រាក់) និង ចំណាយមិនបានគ្រោងទុក។

ចំណាយប្រភេទទី១-**មធ្យោបាយសេវា** ចែកជាៈ

-**ការទិញ (ជំពូក ៦០)**: សម្ភារៈផ្គត់ផ្គង់ថែទាំ ប្រេងឥន្ធនៈ ប្រេងរំអិល សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល ស្បៀងអាហារ សំលៀកបំពាក់ និង ឯកសណ្ឋាន សង្ហារឹម និង សម្ភារៈបរិក្ខារ ថាមពល និង ទឹក ។

-**សេវាខាងក្រៅ (ជំពូក ៦១)**: កិច្ចសន្យាផ្តល់សេវា ការជួលមធ្យោបាយដឹកជញ្ជូន សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ការថែទាំជួសជុល ការថែទាំ និង ជួសជុលផ្លូវ សោហ៊ុយធានារ៉ាប់រង សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយដឹកជញ្ជូន ។

-**សេវាខាងក្រៅផ្សេងៗ (ជំពូក ៦២)**: ភ្នាក់ងារជាប់កិច្ចសន្យា ទំនាក់ទំនងសាធារណៈ សោហ៊ុយជាវសារព័ត៌មាន និង ឯកសារ ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស សោហ៊ុយទូរគមនាគមន៍ សោហ៊ុយធនាគារ ។

-**បន្ទុកបុគ្គលិក**នៃមន្រ្តីរាជការសាធារណៈ **(ជំពូក ៦៤)**: ជាចំណែកដ៏ធំនៃចំណាយថវិកាចរន្ត ។ លាភការ និង ប្រាក់បំណាច់ផ្សេងៗ រួមមានបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់គ្រួសារ ប្រាក់បំណាច់ទទួលខុសត្រូវ រង្វាន់ កន្សោមអាទិភាព ប្រាក់វិភាជន៍សង្គម ឧបត្ថម្ភនិវត្តជន ។ល។ ដូចនេះ គោលនយោបាយបៀវត្ស និងគោលនយោបាយអនិកម្មភាព ក្នុងផ្នែកសាធារណៈមានផលប៉ះពាល់យ៉ាងខ្លាំងលើចំណាយសរុប ។

ចំណាយប្រភេទទី២-**បន្ទុកហិរញ្ញវត្ថុ (ជំពូក ៦៦)**: ការប្រាក់នៃបំណុលក្នុងប្រទេស ការប្រាក់នៃបំណុលក្រៅប្រទេស និង បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ។ ចំណាយការប្រាក់កាន់តែសំខាន់ឡើងនាបច្ចុប្បន្ន ដោយសារដល់ពេលត្រូវបង់ការប្រាក់នៃកម្ចីសម្បទាន ទៅតាមកិច្ចសន្យា ។

ចំណាយប្រភេទទី៣-**អន្តរាគមន៍សាធារណៈ (ជំពូក ៦៣)**: រដ្ឋាភិបាលក៏ផ្តល់ឧបត្ថម្ភកធន ដែលជាមធ្យោបាយបែងចែក ចំណូលឡើងវិញ និងបំពេញកង្វះខាតទីផ្សារ ។ ចំណាយឧបត្ថម្ភកធនរួមមាន ឧបត្ថម្ភកធនដល់ខេត្ត- ក្រុង ឧបត្ថម្ភកធនដល់ស្រុក ឃុំ- សង្កាត់ ឧបត្ថម្ភកធនដល់អង្គភាពសាធារណៈ ការចូលរួមក្នុងការអនុវត្តគំរោង ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈ វិភាគទានដល់អង្គការអន្តរជាតិ ជំនួយសង្គម និង ប្រាក់វិភាជន៍ ។

ការផ្ទេររវាងកម្រិតផ្សេងៗរបស់រដ្ឋ ពោលគឺ ការផ្ទេរពីថវិការដ្ឋ ទៅថវិកាខេត្ត និងថវិកាឃុំ-សង្កាត់ គឺជាការផ្ទេរច្រើនជាងគេក្នុងថវិកាជាតិ ។ ជំនួយពីរដ្ឋាភិបាលកណ្តាល (ថវិកាជាតិ) ទៅរដ្ឋបាលមួយកម្រិតទៀត (ថវិកាខេត្ត ឬ ថវិកាឃុំ-សង្កាត់) គឺជាវិធីសាស្ត្រដ៏សំខាន់នៃការផ្លាស់ប្តូរធនធានហិរញ្ញវត្ថុ នៅក្នុងប្រព័ន្ធថវិកា ។ ជំនួយដើរតួនាទីយ៉ាងសំខាន់ក្នុងហិរញ្ញវត្ថុសាធារណៈមូលដ្ឋាននៅកម្ពុជា ។ រចនាសម្ព័ន្ធជំនួយមានផលប៉ះពាល់សេដ្ឋកិច្ចរបស់វា ។ ជំនួយមានពីរប្រភេទគឺ ជំនួយមានលក្ខខណ្ឌ និងជំនួយគ្មានលក្ខខណ្ឌ ។

ជំនួយមានលក្ខខណ្ឌកំណត់គោលបំណង ដែលអ្នកទទួលផលត្រូវប្រើមូលនិធិធនធានថវិកា ពោលគឺ មូលនិធិត្រូវបានតម្រង់ការប្រើប្រាស់ សម្រាប់គោលដៅជាក់លាក់ ។ វិធានសម្រាប់ចំណាយ ជាទូទៅមានចែងលម្អិតដែលភ្ជាប់ជាលក្ខខណ្ឌ ។

ជំនួយគ្មានលក្ខខ័ណ្ឌ ជាចំនួនទឹកប្រាក់សរុប ដែលផ្តល់ដោយរដ្ឋាភិបាលកណ្តាល ចំពោះថវិកាខេត្ត-ក្រុង ឬ ថវិកាឃុំ-សង្កាត់ ។

ការផ្ទេរទៅគណនីសហគ្រាសសាធារណៈ ជាចំណែកដ៏តិចតួចនៃចំណាយរដ្ឋាភិបាល (ឧទាហរណ៍ ក្រុមហ៊ុនអយស្ម័យយានកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា) និងការទូទាត់ការប្រាក់ ចំពោះសញ្ញាប័ណ្ណរដ្ឋដែលប្រើដើម្បី បំពេញដើមទុនឱ្យក្រុមហ៊ុនធានារ៉ាប់រង ។

ចំណាយប្រភេទទី៤-**ចំណាយផ្សេងៗ** : មានការបង់ពន្ធ និង អាករជាចំណូលថវិការដ្ឋ ការទិញលតាប័ត្រសម្រាប់រថយន្តរបស់រដ្ឋ ។

ចំណាយប្រភេទទី៤-**ចំណាយតាមដីកា (មិនឆ្លងសាច់ប្រាក់)** : ដែលមានបន្ទុកពិសេស និងទាយជ្ជទានអោយដល់រំលស់អចលនកម្ម ។

ចំណាយប្រភេទទី៥-**ចំណាយមិនបានគ្រោងទុក** : មានចំណាយត្រៀមបម្រុង និង ចំណាយផ្សេងៗ ។

ចំណាយជាមូលធនមានបីប្រភេទ៖

ចំណាយប្រភេទទី១-**ការទូទាត់ប្រាក់ខ្ចី និង ចំណូលប្រហាក់ប្រហែល** : មានការទូទាត់ប្រាក់ខ្ចីក្នុងប្រទេស ការទូទាត់ប្រាក់ខ្ចីក្រៅប្រទេស បរិវិសករប័ណ្ណរតនាគារ និង សញ្ញាប័ណ្ណ ។

ចំណាយប្រភេទទី២-**អចលនកម្ម** : មានអចលនកម្មអរូបី (ជំពូក ២០) ដូចជា សោហ៊ុយសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍ ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និង សិទ្ធិប្រហាក់ប្រហែល អចលនកម្មរូបី (ជំពូក ២១) មាន ដីធ្លី និង ធនធានធម្មជាតិ សំណង់ ហេដ្ឋារចនាសម្ព័ន្ធ ថបនកម្មបច្ចេកទេស សម្ភារៈ និង ហត្ថុបករណ៍ ស្នាដៃសិល្បៈ សំភារៈដឹកជញ្ជូន សង្ហារឹម ប្រាក់រំដោះលើការវិនិយោគ ភាគកម្ម និង ឥណទេយ្យពាក់ព័ន្ធ អចលកម្មហិរញ្ញវត្ថុផ្សេងៗ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចំណាយប្រភេទទី៣- **ចំណាយតាមបញ្ជា** : ចំណាយដែលគ្មានសាច់ប្រាក់ ។

ចំណាយវិនិយោគសាធារណៈ តំណាងឱ្យភាគចំណែកដ៏ធំនៃចំណាយសរុប (ប្រហែល ៥% នៃ ផសស) ដែលឆ្លុះបញ្ចាំងពី ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដើម្បីផ្តល់ហេដ្ឋារចនាសម្ព័ន្ធដ៏សមស្រប ។ ការសម្រេចលើចំណាយឱ្យបានច្បាស់លាស់តម្រូវឱ្យមានព័តិមានលម្អិត ទាក់ទងទៅនឹងលក្ខណៈសម្បត្តិនៃគម្រោងផ្សេងៗ ។ ការវាយតម្លៃគម្រោង ទាក់ទងនឹងការកំណត់វិធីសាស្ត្រ ដែលអាចប្រើប្រាស់ធនធានដ៏កម្រ ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ។ បញ្ហាគឺថា តើត្រូវកំណត់សមាសធាតុថវិកាបែបណា ឬ តើត្រូវវិភាជន៍ធនធានសរុបយ៉ាងណាដែលត្រូវផ្តល់ឱ្យគម្រោងផ្សេងៗ ដើម្បីសម្រេចបានប្រសិទ្ធភាព និងសុខមាលភាព ជាអតិបរមា ។

## ៦. ផលប៉ះពាល់នៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម និង វិនិយោគ

### *៦.១- ក្របខ័ណ្ឌទស្សនទាននៃសេរីភាពូបនីយកម្មពាណិជ្ជកម្ម*

មានអត្ថបទស្រាវជ្រាវជាច្រើនដែលនិយាយអំពីឥទ្ធិពលនៃសេរីភាវូបនីយកម្ម មកលើលំហូរពាណិជ្ជកម្ម និងជញ្ជីងទូទាត់ ។ ឯកសារទាំងនោះបង្ហាញថា នៅក្នុងដំណាក់កាលដំបូងនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មជញ្ជីងទូទាត់អាចនឹងវិវត្តជាអវិជ្ជមាន ដោយសារបន្ទាប់ពីការធ្វើសេរីភាវូបនីយកម្ម ការនាំចូលនឹងកើនឡើងខ្លាំងជាងការនាំចេញ (Palanivel, 2005) ។ សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការវិនិយោគទុន អាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើហិរញ្ញវត្ថុសាធារណៈ សូចនាករម៉ាក្រូសេដ្ឋកិច្ច ជញ្ជីងទូទាត់ និកម្មភាព និងភាពក្រីក្រ ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ពន្ធលើពាណិជ្ជកម្មអន្តរជាតិ គឺជាប្រភពដ៏សំខាន់នៃប្រាក់ចំណូល ។ ដូច្នេះហើយ ផលប៉ះពាល់នៃសេរីភាវូបនីយកម្មពាណិជ្ជកម្មទៅលើថវិការដ្ឋ អាស្រ័យលើផលប៉ះពាល់ផ្ទាល់របស់វា ទៅលើចំណូលពន្ធគយ ក៏ដូចជាប្រតិកម្មនៃសេដ្ឋកិច្ចជាតិចំពោះការប្រែប្រួលថ្លៃប្រៀបធៀប ។ ឯកសារស្រាវជ្រាវបង្ហាញឱ្យឃើញថា ផលប៉ះពាល់អាស្រ័យដោយផ្ទាល់លើទំហំនៃការកាត់បន្ថយអត្រាពន្ធគយ ការឆ្លើយតបនៃការនាំចូលចំពោះការកាត់បន្ថយអត្រាពន្ធគយ និងធាតុផ្សំនៃកញ្ចប់កំណែទម្រង់ដែលពាក់ព័ន្ធ និងសារៈសំខាន់នៃចំណូលពន្ធពីការនាំចូល នៅក្នុងចំណូលថវិការដ្ឋ ។

ទន្ទឹមនឹងនេះ សេរីភាវូបនីយកម្មពាណិជ្ជកម្មនឹងលើកកម្ពស់ប្រសិទ្ធកម្មសេដ្ឋកិច្ច ដែលជាលទ្ធផលនៃការផ្ទេរបច្ចេកវិទ្យា ដែលទាក់ទងជាមួយសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងវិនិយោគទុន និង កំណើនប្រសិទ្ធភាពដែលកើតឡើងពីការប្រកួតប្រជែង ។

ដូចករណីនៅក្នុងប្រទេសកម្ពុជា សេរីភាវូបនីយកម្មពាណិជ្ជកម្មតម្រូវឱ្យមានការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលអនុញ្ញាតឱ្យសេដ្ឋកិច្ចផ្តោតលើវិស័យដែលមានឧត្តមភាពប្រៀបធៀប ដែលអាចឆ្លុះបញ្ចាំងពីទាយជ្ជទានធនធានរបស់ប្រទេសជាតិ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីផ្សារក្រៅប្រទេសរបស់ប្រទេសកម្ពុជា ។ ឧទាហរណ៍ សេរីភាវូបនីយកម្មពាណិជ្ជកម្មនៅប្រទេសកម្ពុជានាំអោយមានកំណើននៃចំណែកវិស័យឧស្សាហកម្ម


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលជាលទ្ធផលនៃការអភិវឌ្ឍឧស្សាហកម្មកាត់ដេរសម្រាប់បម្រើអោយការនាំចេញទៅសហរដ្ឋអាមេរិក និង សហភាពអ៊ឺរ៉ុប ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញនូវការធ្លាក់ចុះនៃចំណែកវិស័យកសិកម្ម នៅក្នុងផលិតផលសរុបក្នុងស្រុក (GDP) និងការកើនឡើងនៃចំណែកវិស័យសេវាកម្ម ដូចជាទេសចរណ៍ សេវាកម្មហិរញ្ញវត្ថុ និង ពាណិជ្ជកម្មជាដើម ។ ដូច្នេះ សេរីភាវូបនីយកម្មអាចបណ្តាលឱ្យមានការផ្លាស់ប្តូរនៅលើទីផ្សារការងារ ។ ការធ្វើសេរីភាវូបនីយកម្មទីផ្សារកសិកម្ម នឹងនាំឱ្យមានឯកទេសកម្ម ក៏ប៉ុន្តែក៏អាចនាំឱ្យមានការធ្លាក់ចុះនៃការផលិតកសិផលមួយចំនួន ដែលប្រទេសកម្ពុជាមិនមានការប្រណាំងប្រជែងខ្លាំងក្លា ។ ឧទាហរណ៍ ពេលដែលប្រទេសកម្ពុជាបន្តនាំចេញកសិផលជាច្រើន ដូចជាស្រូវ សណ្តែកសៀង សណ្តែកបាយ ដំឡូងឈើ និង ពោត ទៅកាន់ប្រទេសជិតខាង នោះបន្លែភាគច្រើនសម្រាប់ការបរិភោគក្នុងស្រុកនាពេលបច្ចុប្បន្ននេះ ត្រូវបាននាំចូលពីប្រទេសវៀតណាម និងប្រទេសថៃ ។ ដូច្នេះហើយ ដើម្បីធានាប្រសិទ្ធភាព សេរីភាវូបនីយកម្មត្រូវតែអនុវត្តដោយព្រមគ្នាជាមួយនឹងកំណែទំរង់ទីផ្សារការងារ និង ការអនុវត្តកម្មវិធីរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការប្រកួតប្រជែងតាមវិស័យ ដើម្បីកាត់បន្ថយផលប៉ះពាល់សង្គម ដែលបណ្តាលមកពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។

សេរីភាវូបនីយកម្មពាណិជ្ជកម្ម គឺជាការធ្វើវិចារណកម្មនៃរចនាសម្ព័ន្ធតារាងពន្ធគយ ដើម្បីធ្វើឱ្យវាមានភាពសាមញ្ញជាងនេះ ដោយបន្ថយរបាំងពន្ធ និង របាំងពុំមែនពន្ធ ការលុបបំបាត់ចោលនូវការកំណត់បរិមាណនៃទំនិញដែលអនុញ្ញាតឱ្យនាំចូល ការធ្វើឱ្យនីតិវិធីក្នុងការនាំទំនិញចូលមានភាពសាមញ្ញ ការលុបបំបាត់ការឧបត្ថម្ភធនចំពោះការនាំចេញ និង ការអនុវត្តនូវកំណែទម្រង់គោលនយោបាយអត្រាប្តូរប្រាក់ជាដើម ។

ផ្ទុយទៅវិញ បទពិសោធន៍របស់កម្ពុជាបានបង្ហាញអោយឃើញថា ពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគផ្ទាល់ពីបរទេស (FDI) អាចក្លាយជាក្បាលម៉ាស៊ីននៃកំណើន និង អភិវឌ្ឍន៍ ។ គួរកត់សម្គាល់ផងដែរថា ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាកើតឡើងដោយសារកំណើននៃការនាំចេញ វិស័យទេសចរណ៍ សកម្មភាពសំណង់ និង ផលិតកម្មកសិកម្ម។ ដូច្នេះហើយ សេរីភាវូបនីយកម្មពាណិជ្ជកម្ម និង វិនិយោគមានផលប៉ះពាល់ខាងម៉ាក្រូសេដ្ឋកិច្ចយ៉ាងសំខាន់ ។ អត្រាកំណើនសេដ្ឋកិច្ចខ្ពស់អាចសម្រេចបាន ដោយសារកំណើនសេដ្ឋកិច្ចដែលនាំមុខដោយការនាំចេញ ។ ទន្ទឹមនឹងនេះ អត្រាកំណើនសេដ្ឋកិច្ចខ្ពស់អាចសម្រេចបានដោយសារកំណើនយ៉ាងខ្លាំងនៃការនាំចូល ។ ឱនភាពពាណិជ្ជកម្មត្រូវបានធ្វើហិរញ្ញប្បទានដោយលំហូរចូលមូលធន ក្នុងរូបភាពជាការផ្ទេរឯកជន ជំនួយដើម្បីអភិវឌ្ឍន៍ និងកម្ចីសម្បទាន ។ លោក **Rodrik (2002)** សង្កត់ធ្ងន់ថា កំណើននៃសមាហរណកម្មទូទាំងពិភពលោក គឺជាលទ្ធផលនៃដំណើរការកំណើន និង អភិវឌ្ឍន៍ ហើយកំណើន និង ការអភិវឌ្ឍមិនមែនជាលក្ខខណ្ឌសម្រាប់សមាហរណកម្មឡើយ ។ នៅពេលដែលប្រទេសមួយសម្រេចបាននូវពិពិធកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍកម្រិតខ្ពស់ ប្រទេសនោះអាចចូលរួមក្នុងដំណើរការពិភពលោកបានកាន់តែច្រើន ។ ជាការពិតណាស់ ភាពបើកចំហផ្នែកពាណិជ្ជកម្ម មិនមែនសុទ្ធតែនាំអោយមានកំណើនខ្ពស់នោះទេ ។

គួរកត់សម្គាល់ផងដែរថា ការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្មអាចផ្លាស់ប្តូរយ៉ាងសំខាន់នូវខ្លឹមសារអភិវឌ្ឍន៍នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (Ghosh, 2002) ។ គោលនយោបាយពាណិជ្ជកម្មអាចមាន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឥទ្ធិពលមកលើនយោបាយហិរញ្ញវត្ថុសាធារណៈ តាមរយៈការប្រមូលចំណូល និង ការគ្រប់គ្រងចំណាយថវិកា ។ ការកាត់បន្ថយអត្រាពន្ធគយអាចធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំង ទៅលើការប្រមូលប្រាក់ចំណូលពន្ធ ។ ម៉្យាងវិញទៀត គោលនយោបាយពាណិជ្ជកម្មក៏អាចជះឥទ្ធិពលផងដែរ មកលើគោលនយោបាយរូបិយវត្ថុ ។ បទពិសោធន៍នៅតាមបណ្តាប្រទេសជាច្រើនបង្ហាញអោយឃើញថា ការកាត់បន្ថយអត្រាប្តូរប្រាក់ពិតអាចបង្កើនការនាំចេញ ។ ផ្ទុយទៅវិញ គោលនយោបាយរូបិយវត្ថុ និងសេរីភាវូបនីយកម្មហិរញ្ញវត្ថុ អាចជួយបង្កើនពាណិជ្ជកម្ម ។

សេរីភាវូបនីយកម្មពាណិជ្ជកម្មក៏អាចនាំអោយមានសេរីភាវូបនីយកម្មនៃការនាំចូលដែរ ។ ផ្ទុយទៅវិញ សេរីភាវូនីយកម្មនៃទំនិញប្រើប្រាស់ក៏អាចបំផ្លាញផងដែរ នូវមូលដ្ឋានផលិតកម្មនៃទំនិញក្នុងស្រុក ។ ប្រការនេះអាចមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរមកលើការបង្កើតការងារ ។ ផ្ទុយទៅវិញ សេរីភាវូបនីយកម្មនៃការនាំចូលបរិក្ខារជាទំនិញមូលធនអាចមានឥទ្ធិពលល្អមកលើការកើនឡើងនៃវិស័យផលិតកម្មផងដែរ ។

ទិសដៅចំបងនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា គឺ ដើម្បីពង្រីក និងពង្រឹងចំណងសេដ្ឋកិច្ច និង កិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ គោលដៅនេះ គឺដើម្បីប្រើប្រាស់អោយអស់នូវអត្ថប្រយោជន៍នៃការបែងចែកពលកម្មជាអន្តរជាតិ ដើម្បីបង្កើនការអភិវឌ្ឍសេដ្ឋកិច្ច និង ពង្រឹងសុខមាលភាពរបស់ប្រជាជន ។

តាំងពីចុងទស្សវត្សទី៨០ និង ជាពិសេសនៅដើមទស្សវត្សទី៩០ ប្រទេសកម្ពុជាបានផ្តើមអនុវត្តនូវគោលនយោបាយសេរីភាវូបនីយកម្ម និង សមាហរណកម្មពាណិជ្ជកម្ម ។ រាជរដ្ឋាភិបាលបានអនុញ្ញាតអោយវិស័យឯកជនបង្កើតឡើងនូវក្រុមហ៊ុនពាណិជ្ជកម្ម ដោយមានការចូលរួមហ៊ុនពីភាគីបរទេស ដែលមានចំនួន ៤៩% ជាអតិបរិមា ។ ចាប់តាំងពីឆ្នាំ ១៩៩៣ មក រាជរដ្ឋាភិបាលបានលប់ចោលនូវអាជ្ញាប័ណ្ណនាំចូលសម្រាប់ទំនិញភាគច្រើន ដើម្បីបង្កលក្ខណៈអោយក្រុមហ៊ុនដែលបានចុះបញ្ជី អាចធ្វើពាណិជ្ជកម្មបានដោយសេរី ។

## ៦.២- ការផ្លាស់ប្តូរនូវគោលនយោបាយអត្រាពន្ធគយ

រាជរដ្ឋាភិបាលបានលុបចោលនូវរបាំងពុំមែនពន្ធភាគច្រើន ដើម្បីសម្រួលដល់ពាណិជ្ជកម្មអន្តរជាតិ ។ របាំងដែលនៅសេសសល់ គឺ តម្រូវការអោយមានអាជ្ញាប័ណ្ណនាំចូលឱសថ ។ ការនាំចេញនៃផលិតផលឈើត្រូវមានកូតានាំចេញប្រចាំឆ្នាំ និង អាជ្ញាប័ណ្ណពិសេស ។ ដោយសារតែមានអត្រាពន្ធគយទាប ប្រទេសកម្ពុជាបានក្លាយជាចំណុចដ៏សំខាន់មួយសម្រាប់ពាណិជ្ជកម្មឆ្លងកាត់នៅក្នុងតំបន់ ជាពិសេសជាមួយប្រទេសវៀតណាម ។ ក៏ប៉ុន្តែ ការនាំចេញបន្តទៅប្រទេសវៀតណាម កាន់តែថយចុះបន្តិចម្តងៗ ចាប់តាំងពីឆ្នាំ ១៩៩៦ មកម្ល៉េះ ដោយសារវៀតណាមបានអនុវត្តនូវគោលនយោបាយការបើកទូលាយទៅក្នុងពិភពលោក ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| តារាង ១៧.១ រចនាសម្ព័ន្ធអត្រាពន្ធគយ | | | | | | |
|---|---|---|---|---|---|---|
| **អត្រាពន្ធ** | **1997** | | **2000** | | **2001** | |
| % | **ចំនួន** | % | **ចំនួន** | % | **ចំនួន** | % |
| 0 | 107 | 2.1 | 290 | 4.3 | 297 | 4.4 |
| 3 | 7 | 0.1 | 9 | 0.1 | | |
| 7 | 2,112 | 40.7 | 2,731 | 40.0 | 2,758 | 40.4 |
| 10 | 14 | 0.3 | 14 | 0.2 | | |
| 15 | 1,184 | 22.8 | 1,861 | 27.3 | 1,936 | 28.4 |
| 20 | 46 | 0.9 | 68 | 1.0 | | |
| 30 | | | 4 | 0.1 | | |
| 35 | 1,575 | 30.4 | 1,569 | 23.0 | 1,832 | 26.9 |
| 40 | | | 8 | 0.1 | | |
| 50 | 133 | 2.6 | 256 | 3.8 | | |
| 90 | | | 6 | 0.1 | | |
| 120 | | | 6 | 0.1 | | |
| **សរុប** | 5,186 | 100.0 | 6,823 | 100.0 | 6,823 | 100.0 |
| អត្រាមធ្យម | | | | | | |
| មធ្យមធម្មតា | | 18.4 | | 17.3 (13.6) | | 16.5 (11.9) |
| មធ្យមថែកនឹងការនាំចេញ | | 15.9 | | 15.4 | | 14.2a |
| មធ្យមពិត | | n.a. | | 10.8 (12.4) | | n.a. |

*ប្រភព: ទីចាត់ការគយ និង រដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

កម្ពុជាបានអនុវត្តនូវសេរីភាវូបនីយកម្មពាណិជ្ជកម្មយ៉ាងពេញទំហឹង តាមរយៈការកាត់បន្ថយយ៉ាងគំហុកនូវអត្រាពន្ធគយ ហើយទន្ទឹមនឹងនេះ បង្កើននូវអត្រាអាករពិសេស ដើម្បីជៀសវាងការធ្លាក់ចុះនូវចំណូលថវិកា ។

គោលបំណងនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម គឺជំរុញឱ្យមានការនាំចេញ និងត្រៀមលក្ខណៈសម្បត្តិ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់អោយកម្ពុជាធ្វើសមាហរណកម្មសេដ្ឋកិច្ច ចូលក្នុងក្របខណ្ឌនៃសមាគមអាស៊ាន និងត្រៀមលក្ខណៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ។ ការកាត់បន្ថយអត្រាពន្ធគយ មានផលប៉ះពាល់ជាវិជ្ជមានទៅលើសកម្មភាពសេដ្ឋកិច្ចជារួម និង ទៅលើការបង្កើតការងារ តាមរយៈការអភិវឌ្ឍឧស្សាហកម្មកាត់ដេរ ។

តួលេខក្នុងវង្វង់ក្រចកគឺជា Standard Deviations ដែលវាស់ពីគម្លាតនៃអត្រាពន្ធគយ ។ អត្រាពន្ធជាក់ស្តែង គឺជាផលចែកនៃចំណូលពន្ធគយ ចែកអោយតម្លៃទំនិញនាំចូល ។

នៅក្នុងខែមេសា ឆ្នាំ ២០០១ រាជរដ្ឋាភិបាលបានកាត់បន្ថយនូវចំនួនអត្រាពន្ធ (Tariff band) ពីចំនួន ១២ មកចំនួន ៤ ដោយកាត់បន្ថយអត្រាអតិបរិមាពី ១២០% មកនៅត្រឹម ៣៥% ។ ការកាត់បន្ថយនេះពាក់ព័ន្ធនឹងផលិតផលសម្រេចសំខាន់ៗមួយចំនួន ក៏ដូចជាផលិតផលពាក់កណ្តាលសម្រេច និងវត្ថុធាតុដើមខ្លះៗផងដែរ ។

ឧទាហរណ៍ អត្រាពន្ធលើរថយន្តផលិតរួចរាល់ទាំងស្រុងបានធ្លាក់ចុះពី ៤០-១២០% មកនៅត្រឹមតែ ៣៥% អត្រាពន្ធលើគ្រឿងបន្លាស់វិញ (ពី ៥០% មកត្រឹម ៣៥%) ផលិតផលថ្នាំជក់ (ពី ៥០% មកត្រឹម ៣៥%) និងគ្រឿងភេសជ្ជៈស្រវឹង ដូចជាស្រា និង ស្រាបៀរ (ពី ៥០% មកនៅត្រឹម ៣៥%) ។

យ៉ាងណាមិញ ការប្រែប្រួលទាំងនេះបានជះឥទ្ធិពលយ៉ាងតិចតួចបំផុត មកលើរចនាសម្ព័ន្ធពន្ធរួមទាំងមូល ព្រោះថា បរិមាណភាគរយដ៏តូចស្តួចស្តើងប៉ុណ្ណោះ (៣,៨%) នៃអត្រាពន្ធ ដែលមានអត្រាលើ ៣៥% នៅក្នុងឆ្នាំ ២០០១ កន្លងទៅ ។ ឧទាហរណ៍ ភាគរយនៃអត្រាពន្ធដែលរួចពន្ធ ឬ ដែលមានអត្រាពន្ធអប្បបរិមា ៧% កើនឡើងពី ៤៤,៣% ក្នុងឆ្នាំ ២០០០ ដល់ ៤៤,៨% ក្នុងឆ្នាំ ២០០១ ។ ហើយភាគរយនៃអត្រាពន្ធ ចំនួន ១៥% ឬ ក៏តិចជាងនេះកើនឡើងពី ៧១,៦% ដល់ ៧៣,២% តែប៉ុណ្ណោះ។

លទ្ធផលនៃកំណែទម្រង់អត្រាពន្ធគយ ដូចបានរៀបរាប់ខាងលើនេះ អត្រាពន្ធមធ្យមបានធ្លាក់ចុះ យ៉ាងតិចតួចណាស់ គឺពី ១៧,៣% មកនៅត្រឹម ១០,៥% ដែលបង្ហាញថា អត្រាពន្ធ ជាមធ្យម នៅតែមានកម្រិតខ្ពស់ដដែល ។ Standard deviation ស្មើនឹង ១១,៩% បង្ហាញថា មានគម្លាតបែកខ្ញែកដ៏ធំមួយនៃអត្រាពន្ធគយនេះ (unweighted average tariff rate) ។

រាជរដ្ឋាភិបាលបានកាត់បន្ថយអត្រាពន្ធគយមធ្យម (unweighted average tariff rate) អោយមកត្រឹមក្រោម ១៥% ក្នុងឆ្នាំ ២០០៣ ។ បើនិយាយដោយសង្ខេប ចំនួនអត្រាពន្ធគយកាន់តែតិច គម្លាតរវាងអត្រាពន្ធកាន់តែជិតគ្នា ហើយអត្រាពន្ធគយមធ្យមកាន់តែទាប នោះរចនាសម្ព័ន្ធអត្រាពន្ធគយនឹងនាំអោយមានតម្លៃ ដែលបណ្តាលមកពីការបែងចែកធនធានមិនបានត្រឹមត្រូវ កាន់តែទាបសម្រាប់សេដ្ឋកិច្ចជាតិ ។

ចំណូលពន្ធស្ទើរតែពាក់កណ្តាលបានមកពីពន្ធលើពាណិជ្ជកម្មអន្តរជាតិ ។ ការកាត់បន្ថយអត្រាពន្ធគយលើមុខទំនិញនាំចូលដែលគេអាចផ្តល់ឱ្យប្រាក់ចំណូលខ្ពស់ (ដូចជាប្រេងឥន្ធនៈ និងផលិតផលតេលសិលា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យានយន្ត ទោចក្រយាន ភេសជ្ជៈ និងបារី) បានធ្វើឱ្យមានការបារម្ភថា ការកាត់បន្ថយអត្រាពន្ធអាចធ្វើឱ្យមានការធ្លាក់ចុះនូវចំណូលសារពើពន្ធនៃថវិកាជាតិ ។ ជាវិធានការប៉ះប៉ូវ ចំពោះការកាត់បន្ថយអត្រាពន្ធគយនេះ រាជរដ្ឋាភិបាលបានតំឡើងអត្រាអាករពិសេសលើផលិតផលមួយចំនួន ។ ជាលទ្ធផល អត្រាពន្ធគយមធ្យមជាក់ស្តែងលើមុខទំនិញនាំចូល (ពន្ធនាំចូល និង អាករ) សឹងតែនៅដដែលដោយគ្មានការប្រែប្រួលឡើយ គឺនៅត្រឹម ១៨% នៅចន្លោះឆ្នាំ ២០០០ និង ២០០១ ។

អត្ថប្រយោជន៍នៃការផ្លាស់ប្តូរ ពីការយកពន្ធគយ ទៅយកអាករពិសេស គឺជាវិធានការបង្កើនចំណូល ដើម្បីជៀសវាងឥទ្ធិពលអវិជ្ជមាន ដែលបណ្តាលមកពីការយកពន្ធខ្ពស់ លើការបែងចែកធនធានក្នុងស្រុក ព្រោះថា អាករពិសេសត្រូវតែអនុវត្ត ទាំងលើផលិតផលក្នុងស្រុក ទាំងលើទំនិញនាំចូល ដោយស្មើៗគ្នា ។

ក៏ប៉ុន្តែ មួយភាគប្រាំនៃទំនិញនាំចូលទាំងអស់ត្រូវអនុវត្តតាមអត្រាពន្ធគយខ្ពស់បំផុត គឺ ៣៥% ។ អត្រាពន្ធគយខ្ពស់ជាងគេ (៣៥%) នេះ គឺសម្រាប់ការពារទំនិញពាក់កណ្តាលសម្រេចមួយចំនួន និង ទំនិញប្រើប្រាស់ដូចជាផលិតផលទឹកដោះគោ សាច់កំប៉ុង បន្លែបង្ការកំប៉ុង និងផ្លែឈើ ម្សៅស្រូវសាឡី ភេសជ្ជៈ និងថ្នាំជក់ សំលៀកបំពាក់ និងស្បែកជើង ក្តាបន្ទះ និងគ្រឿងអលង្កា ។ រាល់ «ទំនិញជាប់អាករ» សំខាន់ៗទាំងអស់ ត្រូវបានបញ្ចូលទៅក្នុងអត្រាខ្ពស់ ក្នុងគោលដៅបង្កើនចំណូលថវិកា ។

យោងតាមទិន្នន័យនៃការនាំចូល ក្នុងឆ្នាំ ២០០០ អត្រាពន្ធមធ្យម (Import weighted average tariff rate) បានធ្លាក់ចុះ ពី ១៥,៤% ក្នុងឆ្នាំ ២០០០ មកនៅត្រឹម ១៤,២% ក្នុងឆ្នាំ ២០០១ ។ ទិន្នន័យស្ថិតិនេះមិនរាប់បញ្ចូលការអនុវត្តយ៉ាងទូលំទូលាយ នៃការលើកលែងពន្ធ ក្នុងក្របខ័ណ្ឌនៃការអនុវត្តនូវការលើកទឹកចិត្ត ក្នុងក្របខណ្ឌនៃច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

**តារាង ៦.២- រចនាសម្ព័ន្ធអត្រាពន្ធគយនៅកម្ពុជា**

| អត្រាពន្ធ | បន្ទាត់ពន្ធ | %នៃការនាំចូល |
|---|---|---|
| % | % | % |
| 0 | 4.4 | 8.1 |
| 7 | 40.4 | 45.6 |
| 15 | 28.4 | 25.9 |
| 35 | 26.9 | 20.4 |

*ប្រភព : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រៅពីពន្ធគយ នៅមានពន្ធដោយប្រយោលពីរប្រភេទទៀត ដែលត្រូវប្រមូលលើតម្លៃទំនិញនាំចូលគឺ អាករពិសេសលើទំនិញមួយចំនួន និង អាករលើតម្លៃបន្ថែម (VAT) ។ ជាទូទៅ នៅក្នុងប្រទេសកម្ពុជា ចំណូលពីការយកពន្ធលើការនាំចូលស្មើនឹងប្រមាណជា ៨០%នៃចំណូលសារពើពន្ធ ដែលស្មើនឹង ៥១% នៃពន្ធលើការនាំចូលសរុបនៅក្នុងឆ្នាំ ២០០០ ។

អាករត្រូវបានអនុវត្តលើមុខទំនិញពិសេសៗចំនួនប្រាំ រួមមាន៖ ភេសជ្ជៈ (រួមទាំង ទឹកពិសារបរិសុទ្ធផងដែរ) ថ្នាំជក់ យានយន្តដឹកអ្នកដំណើរ ទោចក្រយានយន្ត និងផលិតផលប្រេងឥន្ធនៈ ។ អាករលើតម្លៃបន្ថែមមានអត្រា ១០% លើគ្រប់មុខទំនិញទាំងអស់ ។ ប្រភេទពន្ធទាំងពីរនេះត្រូវបានអនុវត្តលើមុខទំនិញនាំចូល តាមអត្រា និង លក្ខខណ្ឌដូចគ្នានឹងការអនុវត្តលើទំនិញក្នុងស្រុកដែរ ដោយមានករណីលើកលែងមួយចំនួនតូចប៉ុណ្ណោះ ។ អាករលើតម្លៃបន្ថែមលើទំនិញនាំចេញ ត្រូវអនុវត្តតាមអត្រា ០% ដោយអ្នកនាំចេញអាចទទួលបាននូវការបង្វិលសងវិញបាន ។

## ៦.៣- ការប៉ះប៉ូវលើចំណាយនៃកំណែទំរង់អត្រាពន្ធគយ

បញ្ហាចុងក្រោយ គឺថ្លៃចំណាយលើកំណែទំរង់គោលនយោបាយអត្រាពន្ធគយ ។ ប្រទេសដែលបានធ្វើសេរីភាវូបនីយកម្មរបបគោលនយោបាយពាណិជ្ជកម្ម បានជួបប្រទះនឹងបញ្ហាមួយចំនួន នៅក្នុងរយៈពេលខ្លី ទាក់ទងជាមួយនឹងថ្លៃចំណាយដែលត្រូវបង់ក្នុងការកែសម្រួលអត្រាពន្ធនេះ ។ ជាក់ស្តែង ចំពោះប្រទេសដែលធ្លាប់អនុវត្តយ៉ាងខ្លាំងក្លា នូវរបាំងពន្ធ និងរបាំងមិនមែនពន្ធ ដើម្បីការពារមូលដ្ឋានគ្រឹះឧស្សាហកម្មដែលគ្មានប្រសិទ្ធភាពរបស់គេ តែងតែត្រូវបង់ថ្លៃកែសម្រួលយ៉ាងខ្លាំងក្លា ។ ជារឿយៗ ថ្លៃចំណាយទាំងនេះរួមមាន ការកើនឡើងជាបណ្តោះអាសន្ន តែក្នុងកម្រិតមួយយ៉ាងខ្ពស់ នូវភាពអត់ការងារធ្វើ ដោយសារតែការផ្លាស់ប្តូររចនាសម្ព័ន្ធនៃវិស័យ ដែលគ្មានប្រសិទ្ធភាព ហើយប្រភពធនធានបានងាកទៅរកវិស័យ ដែលធានានូវការប្រើប្រាស់ ប្រកបដោយផលិតភាពខ្ពស់ ។

ទោះជាយ៉ាងណាក៏ដោយ កម្ពុជាមិនបានជួបប្រទះនឹងបញ្ហាថ្លៃចំណាយសំរួល ក្នុងរយៈពេលខ្លីដូចប្រទេសដទៃទៀត នៅពេលដែលប្រទេសទាំងនេះធ្វើសេរីភាវូបនីយកម្មនៃពាណិជ្ជកម្មរបស់គេ ។ មូលហេតុ គឺស្ថិតត្រង់ថា ទោះបីជាកម្ពុជាមានរចនាសម្ព័ន្ធអត្រាពន្ធមិនរលូនក៏ដោយ កម្ពុជាគ្មានឧស្សាហកម្មអត់ប្រសិទ្ធភាព ដែលលូតលាស់ដោយសារតែអត្រាពន្ធខ្ពស់ ដែលចាំការពារនោះ ។ សម្រាប់សកម្មភាពជាច្រើន ការទុកអត្រាពន្ធគយអោយនៅខ្ពស់គ្មានផលប្រយោជន៍អ្វីឡើយ ដោយសារតែគ្មានសកម្មភាពអ្វីជាដុំកំភួននៅក្នុងវិស័យទាំងនោះ ឬ ដោយសារតែការរត់ពន្ធទំនិញ ដែលធ្វើឱ្យថ្លៃទំនិញក្នុងស្រុកនៅមិនខ្ពស់ប៉ុន្មានឡើយបើប្រៀបធៀបនឹងថ្លៃលើពិភពលោក ។

កំណើនដ៏ឆាប់រហ័សនៅក្នុងវិស័យឧស្សាហកម្ម ភាគច្រើនបណ្តាលមកពីការអភិវឌ្ឍនូវវិស័យផលិតសម្រាប់តែនាំចេញ ដូចជា សំលៀកបំពាក់ និង ស្បែកជើងជាដើម ។ កំណែទម្រង់អត្រាពន្ធនៅក្នុងពេលអនាគតនឹងនាំមកនូវផលប្រយោជន៍បន្ថែមច្រើនថែមទៀត នៅក្នុងរយៈពេលមធ្យម ។ អត្រាពន្ធគយទាប អនុវត្តយ៉ាងដូចៗគ្នា ជាសារដល់វិនិយោគគិនថា កម្ពុជាប្រាថ្នាចង់ក្លាយទៅជាវេទិកាសម្រាប់ការវិនិយោគ ក្នុងវិស័យដែលខ្លួនមានឧត្តមភាពប្រកួតប្រជែងខ្ពស់ ។ ចំណុចនេះនឹងទាក់ទាញវិនិយោគផ្ទាល់ពីបរប្រទេស (FDI) អោយបានកាន់តែ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ច្រើនឡើងថែមទៀត នៅក្នុងវិស័យនេះ ។

អត្រាពន្ធគយទាប អនុវត្តយ៉ាងដូចៗគ្នា នឹងអនុញ្ញាតអោយវិនិយោគិនអាចប្រើប្រាស់នូវវត្ថុធាតុដើមតាមថ្លៃពិភពលោក (ឬ ក៏កៀកទៅនឹងថ្លៃនេះ) ។ ប្រការនេះធានាដែរថា អ្នកផលិតដែលផ្គត់ផ្គង់ទីផ្សារក្នុងស្រុក (រួមទាំងសហគ្រាសតូច និង មធ្យម) នឹងមិនបាត់បង់នូវផលប្រយោជន៍របស់ខ្លួនឡើយពាក់ព័ន្ធនឹងការនាំចូល។ ប្រការនេះនឹងលើកទឹកចិត្តអោយមានការអភិវឌ្ឍនូវឧស្សាហកម្ម ដែលប្រណាំងប្រជែងជាមួយការនាំចូល ។

ដូច្នេះ សេរីភាវូបនីយកម្មពាណិជ្ជកម្ម ក៏មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងការប្រមូលផ្តុំធនធាន និងយុទ្ធសាស្ត្រវិនិយោគផងដែរ ។

## ៧. ការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

ចាប់តាំងពីឆ្នាំ ១៩៩៨ មក រដ្ឋាភិបាលបានពង្រឹងបានយ៉ាងច្រើន នូវការប្រើប្រាស់ធនធានហិរញ្ញវត្ថុអោយចំទិសដៅនៃការអភិវឌ្ឍ ដោយបង្កើនវិភាជន៍ថវិកាសម្រាប់វិស័យអាទិភាព ដូចជាវិស័យអប់រំ និងសុខាភិបាល ។ ចំណាយថវិកាក្នុងវិស័យអាទិភាពបានកើនឡើងពី ១,៤% នៃផលិតផលសរុបក្នុងស្រុកសរុប នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៣,៧%នៃផសស នៅក្នុងឆ្នាំ ២០០១ ។ ម៉្យាងវិញទៀត ដូចបានបង្ហាញឱ្យឃើញនៅក្នុងយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តយ៉ាងខ្ពង់ខ្ពស់ ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយគោលដៅមហិច្ឆិតាដើម្បីបង្កើនចំណាយលើវិស័យអាទិភាព ។ កំណើនវិភាជន៍ថវិកាសម្រាប់វិស័យអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានដោយកំណើននៃចំណូលថវិកា និងការកាត់បន្ថយចំណាយសម្រាប់វិស័យការពារនិងសន្តិសុខជាតិ ។

យើងសង្កេតឃើញថា វិស័យនីមួយៗសម្រេចបាននូវប្រសិទ្ធភាពខុសៗគ្នា ក្នុងការអនុវត្តចំណាយថវិកាក្នុងគោលដៅកែលម្អសុខមាលភាពសង្គម ដែលជាសក្ខីភាពនៃសមត្ថភាពស្ថាប័នមិនស្មើគ្នា នៅក្នុងការគ្រប់គ្រងចំណាយថវិកា ។ នៅក្នុងវិស័យអប់រំ យើងសម្រេចបាននូវវឌ្ឍនភាពជាប្រចាំចាប់តាំងពីឆ្នាំ ១៩៩៩ ក្នុងការពង្រីកកាលានុវត្តភាពអប់រំ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនសិស្សដែលបានចូលរៀន ។ យើងសម្រេចបាននូវសមិទ្ធផលសំខាន់ជាច្រើនផងដែរ ក្នុងវិស័យសុខាភិបាល ដោយឆ្លុះបញ្ចាំងតាមរយៈការកាត់បន្ថយនូវអត្រាជំងឺឆ្លង និងការពង្រីកនូវការគ្របដណ្តប់នៃចំនួនមន្ទីរពេទ្យ និង មណ្ឌលសុខភាព នៅក្នុងប្រព័ន្ធសុខភាពសាធារណៈ ។ ក៏ប៉ុន្តែ យើងចាំបាច់ត្រូវកែលំអការប្រើប្រាស់នូវសេវាសុខាភិបាលថែមទៀត ។ អត្រានៃការប្រើប្រាស់សេវាសាធារណៈសុខាភិបាលនៅទាបនៅឡើយ ហើយការបើកផ្តល់ថវិកាសម្រាប់វិស័យនេះត្រូវតែកែលំអថែមទៀត ។ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទោះបីជារាជរដ្ឋាភិបាលបានចាប់ផ្តើមសាងសង់ និងស្តារឡើងវិញនូវប្រព័ន្ធផ្លូវ-ស្ពានក៏ដោយ ស្ថានភាពប្រព័ន្ធផ្លូវជនបទនៅមិនទាន់បានល្អប្រសើរនៅឡើយ ។ ដូច្នេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវបង្កើនចំណាយថវិកាថែមទៀត ជាពិសេសថវិកាសម្រាប់ចំណាយជួសជុលខួប និង ជួសជុលជាប្រចាំ ។ ក្នុងវិស័យកសិកម្ម យើងមានការលំបាកក្នុងការវាយតម្លៃនូវសមិទ្ធផលដែលសម្រេចបាន ដោយសារតែគ្មានព័ត៌មាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ច្បាស់លាស់ស្តីពីធាតុចូល និង ធាតុចេញ និង ទំហំនៃវិនិយោគទុនក្នុងវិស័យនេះ ។

បទពិសោធន៍ថ្មីៗបង្ហាញឱ្យឃើញថា ដើម្បីឈានទៅដល់គោលដៅនៃការកាត់បន្ថយភាពក្រីក្រដែលបាននិយាយខាងដើម ចាំបាច់ត្រូវធ្វើការកែលំអប្រសិទ្ធភាពនៃចំណាយថវិកា ដោយផ្សារភ្ជាប់ចំណាយថវិកាទៅនឹងលទ្ធផលដែលត្រូវសម្រេចបានតាមអាទិភាព ។ ការកើនឡើងនូវប្រសិទ្ធិភាពថវិកាអាចសម្រេចបាន តាមរយៈការកែលំអនូវចំណាយសម្រាប់កាត់បន្ថយភាពក្រីក្រអោយចំទិសដៅ តាមរយៈការរៀបចំផែនការ និងការធ្វើថវិកាតាមផ្នែកនីមួយៗ ដែលមានទិសដៅច្បាស់លាស់ ។ ដូច្នេះហើយ ទើបចំណាយសាធារណៈ និង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានក្លាយទៅជាអាទិភាពដ៏ចម្បងនៃកម្មវិធីកំណែទំរង់ ។ ប្រសិនបើគ្មានកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទេនោះ ការកែលម្អបន្ថែមទៀតនៃគោលនយោបាយចំណាយថវិកានឹងមានកម្រិត ។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងរបៀបវារៈនៃកម្មវិធីអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្ររបស់ខ្លួន ។ គំនិតផ្តួចផ្តើមថ្មីៗនេះត្រូវបានរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃកម្មវិធីកំណែទំរង់លើកមុនៗ ដែលត្រូវបានអនុវត្តបន្ទាប់ពីការប្រកាសដាក់ឱ្យប្រើប្រាស់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ នៅក្នុងឆ្នាំ ១៩៩៣ ដែលបង្កើតឡើងនូវស្ថាបត្យកម្មស្ថាប័នសម្រាប់ការរៀបចំថវិកា ការរៀបចំផែនការ និង ការអនុវត្តថវិកា ។ រាជរដ្ឋាភិបាលបានផ្តល់នូវអាទិភាពលើបង្កើតប្រព័ន្ធដែលធានាអោយបាននូវវិន័យថវិកា តាមរយៈដំណើរការនៃការធានាចំណាយ ការត្រួតពិនិត្យ និង ការរៀបចំប្រព័ន្ធទូទាត់ប្រមូលផ្តុំ ។ កំណែទំរង់ខាងលើនេះសម្រេចបានតាមគោលដៅរបស់ខ្លួន ប្រកបដោយជោគជ័យ ដោយឆ្លុះបញ្ចាំងតាមរយៈការសម្រេចបាននូវអតិរេកថវិកាចរន្តជាង ១,២% នៃផលិតផលក្នុងស្រុកសរុប ក្នុងមួយឆ្នាំ ក្នុងរយៈពេល៤ ឆ្នាំជាប់ៗគ្នា លើកលែងតែក្នុងរយៈពេលដែលមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ី និង វិបត្តិនយោបាយផ្ទៃក្នុងប៉ុណ្ណោះ ។ កំណែទំរង់ទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្កើនចំណាយថវិកាលើវិស័យអាទិភាព ដូចជា វិស័យអប់រំ សុខាភិបាល កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ ក្នុងខណៈដែលរាជរដ្ឋាភិបាលត្រូវកាត់បន្ថយចំណាយយោធា និងសន្តិសុខ ។

ជាការពិតណាស់ ចំណុចខ្សោយនៃចំណាយសាធារណៈ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនគ្រាន់បណ្តាលអោយប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការបែងចែក និងអនុវត្តថវិកាប៉ុណ្ណោះទេ វាថែមទាំងបង្កើតឡើងនូវហានិភ័យហិរញ្ញវត្ថុដ៏ធំធេងថែមទៀតចំពោះមូលនិធិសាធារណៈ ដែលយើងមិនអាចទទួលយកបាន ។ ប្រព័ន្ធទូទាត់ដោយផ្អែកលើសាច់ប្រាក់បានក្លាយទៅជាកង្វះខាតដ៏សំខាន់មួយ ។ ការអនុវត្តថវិកាកាន់តែមានការលំបាក ដោយសារការយឺតយ៉ាវក្នុងការបញ្ចេញសាច់ប្រាក់ និង ការបញ្ចេញសាច់ប្រាក់មិនទៀងទាត់ដោយសារតែការខ្វះខាតសាច់ប្រាក់ ជាហេតុធ្វើអោយការអនុវត្តថវិកាខុសស្រឡះពីផែនការ ដែលបានដាក់ចេញ និងធ្វើអោយបំណុលសាច់ប្រាក់កើនឡើងជាប្រចាំ ។ ប្រព័ន្ធនេះកាន់តែជួបប្រទះនឹងការលំបាកបន្ថែមទៀត ដោយសារតែមានការត្រួតពិនិត្យច្រើនគន្លាក់ពេក ហើយប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរបាយការណ៍ទៀតសោតក៏មានចំណុចខ្សោយមួយចំនួន ដែលជាកត្តានាំអោយការត្រួតពិនិត្យមិនសូវមានប្រសិទ្ធភាព ហើយជាបញ្ហាមិនសូវល្អសម្រាប់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អភិបាលកិច្ចល្អ ។

ការកែលំអការគ្រប់គ្រងហិរញ្ញប្បទានផ្លូវការដើម្បីអភិវឌ្ឍន៍ ដើម្បីធានាអោយបាននូវសង្គតិភាពជាមួយនឹងតម្រូវការ និង អាទិភាពរបស់រដ្ឋាភិបាល មានសារៈសំខាន់ខ្លាំងណាស់ ដោយបរិមាណនៃជំនួយបរទេស មានទំហំធំនៅក្នុងថវិកាជាតិ ។ ហិរញ្ញប្បទានផ្លូវការដើម្បីអភិវឌ្ឍន៍ត្រូវបានកំពុងអនុវត្តក្រៅប្រព័ន្ធថវិកា ហើយវិភាជន៍ធនធានមិនបានឆ្លុះបញ្ចាំងនៅក្នុងថវិកា ចំណែកឯការបើកផ្តល់ទៀតសោត ក៏អនុវត្តក្រៅប្រព័ន្ធរតនាគារផងដែរ ។ កង្វះខាតព័ត៌មាន និងអវត្តមានឧបករណ៍ប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់វិធីសាស្ត្របែងចែកហិរញ្ញប្បទានផ្លូវការដើម្បីអភិវឌ្ឍន៍ឱ្យបានម៉ត់ចត់ បានធ្វើអោយប៉ះពាល់ដល់ជំនឿជឿជាក់ និងប្រសិទ្ធភាពនៃប្រព័ន្ធថវិកា ។ នៅពេលបច្ចុប្បន្ននេះ យើងមិនអាចវាយតម្លៃអោយបានត្រឹមត្រូវនូវផលប៉ះពាល់នៃហិរញ្ញប្បទានផ្លូវការដើម្បីអភិវឌ្ឍន៍ទៅលើការវិភាជន៍ធនធានរួមបានទេ ក៏ដូចជាយើងមិនអាចវាយតម្លៃពីផលប៉ះពាល់នៃទ្រព្យសកម្មដែលត្រូវបានបង្កើតថ្មី និង ចីរភាពរបស់វា តាមរយៈការផ្តល់ថវិកាសម្រាប់ដំណើរការ និងការថែទាំ ជួសជុលអោយបានគ្រប់គ្រាន់ ។ យើងក៏ឃើញមាននូវហានិភ័យដែលបណ្តាលមកពីការកើនឡើងនូវចំនួនគំរោង ដែលធ្វើហិរញ្ញប្បទានដោយប្រទេសផ្តល់ជំនួយ ដើម្បីគាំទ្រនូវគំរោងវិនិយោគដែលមិនមែនជាស្នូលនៃសកម្មភាពយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួង-ស្ថាប័នផ្សេងៗ ជាហេតុធ្វើអោយការអនុវត្តគោលនយោបាយតាមផ្នែកមានសភាពប្រទាញប្រទង់គ្នា ។ ក្នុងន័យនេះ ការដាក់អោយអនុវត្តនូវក្របខ័ណ្ឌចំណាយរយៈពេលមធ្យមមានទិសដៅធានានូវសង្គតិភាពនៃហិរញ្ញប្បទានផ្លូវការដើម្បីអភិវឌ្ឍន៍ជាមួយនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

ដើម្បីសំរេចបាននូវគោលដៅនៃយោបាយជាយុទ្ធសាស្ត្រក្នុងអាណត្តិទីពីររបស់រាជរដ្ឋាភិបាល ហើយជាពិសេស ដើម្បីបង្កើតឡើងនូវមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព ការកាត់បន្ថយភាពក្រីក្រ និងការធ្វើសមាហរណកម្មកម្ពុជា ចូលទៅក្នុងតំបន់ និងក្នុងពិភពលោក សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវ «**យុទ្ធសាស្ត្រចតុកោណ**» ដោយផ្តោតការយកចិត្តទុកដាក់លើៈ (១) ការធានាបាននូវសុខសន្តិភាព ស្ថេរភាព និងសន្តិសុខ សម្រាប់ប្រទេសជាតិ និងប្រជាពលរដ្ឋទាំងមូល (២) ការធ្វើសមាហរណកម្មកម្ពុជាចូលទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ (៣) ការអភិវឌ្ឍប្រទេស ដោយផ្អែកទៅលើការអនុវត្តយុទ្ធសាស្ត្រពីរដំបូង ។ ដោយឈរលើមូលដ្ឋាននៃ **យុទ្ធសាស្ត្រចតុកោណ** កម្មវិធីកំណែទំរង់ជាក់ស្តែង៤យ៉ាងត្រូវបានបង្កើត និងអនុវត្តប្រកបដោយជោគជ័យ ដែលរួមមាន៖ (១) កំណែទំរង់កងកំលាំងប្រដាប់អាវុធ ជាពិសេស កម្មវិធីកាត់វិសាយកងទ័ព (២) កំណែទំរង់រដ្ឋបាលសាធារណៈ ដែលផ្តោតលើការលើកកំពស់សេវាសាធារណៈ (៣) កំណែទំរង់ប្រព័ន្ធតុលាការ ដែលសំដៅពង្រឹងលទ្ធិប្រជាធិបតេយ្យ កែលំអ និងពង្រឹងការអនុវត្តច្បាប់ និងការគោរពសិទ្ធិមនុស្ស និង កំណែទំរង់សេដ្ឋកិច្ច ដើម្បីធានាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចិរភាព ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ជាពិសេស ការអនុវត្តកំណែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលបានរួមចំណែកយ៉ាងសំខាន់ ក្នុងការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពង្រឹងអភិបាលកិច្ច ការធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ ការអនុវត្តកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ការលើកកំពស់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការបង្កើនវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង សង្គម ការជំរុញឱ្យមានការអភិវឌ្ឍផ្នែកឯកជន និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ នៅក្នុងការអនុវត្តកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើតឡើងនូវកម្មវិធីកំណែទំរង់សំខាន់ៗ ៤ យ៉ាង ដែលរួមមាន ÷(១) កំណែទំរង់រដ្ឋបាល និងគោលនយោបាយគយ (២) កំណែទំរង់រដ្ឋបាល និងគោលនយោបាយពន្ធដារ (៣) កំណែទំរង់រតនាគារ និង (៤) កំណែទំរង់ការរៀបចំ និងការអនុវត្តថវិកា ។

កំណែទំរង់ការគ្រប់គ្រងរដ្ឋបាលគយរួមមាន ការផ្សព្វផ្សាយអោយបានទូលំទូលាយនូវច្បាប់ និងកាត់បន្ថយនីតិវិធីគយ ការរៀបចំច្បាប់ស្តីពីក្រមគយ ការធ្វើស្វ័យប្រវត្តិកម្មនៃការវាយតម្លៃពន្ធគយ ការពង្រឹងរដ្ឋបាល និងអភិបាលកិច្ចនៅក្នុងទីចាត់ការគយ និងរដ្ឋាករ ការពង្រឹងវិន័យ ការលើកទឹកចិត្ត និងការបណ្តុះបណ្តាលដល់មន្ត្រីគយ ការបន្តពង្រឹងយន្តការត្រួតពិនិត្យមុនពេលផ្ទុក ការកែលំអនីតិវិធីរបាយការណ៍ និងការត្រួតពិនិត្យ ការកែលំអក្របខណ្ឌគតិយុត្តិ នីតិវិធី និងរចនាសម្ព័ន្ធស្ថាប័នឱ្យស្របទៅនឹងនិយាមអន្តរជាតិ ជាពិសេសការអនុវត្តពន្ធគយ និងក្រមគយ ដែលកំណត់នូវនីតិវិធីនាំចូល- នាំចេញ ការអនុវត្តនូវវិធានការប្រឆាំងនឹងអំពើរត់ពន្ធគ្រប់ប្រភេទ និងការបណ្តុះបណ្តាលមន្ត្រីគយអាស៊ាន ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន ។

កម្មវិធីកំណែទំរង់សារពើពន្ធរួមមាន÷ ការពង្រីកមូលដ្ឋានអនុវត្តអាករលើតម្លៃបន្ថែម ការពង្រីកមូលដ្ឋានយកពន្ធ (ឧទាហរណ៍ : ពន្ធលើប្រាក់បៀវត្ស និង ពន្ធលើប្រាក់ចំណេញ) ការកែលម្អនូវក្របខណ្ឌគតិយុត្តិ និងនីតិវិធីប្រមូលពន្ធ ការពង្រឹងការប្រមូលបំណុលពន្ធ ការពង្រឹងយន្តការបង្វិលសងអាករលើតម្លៃបន្ថែម ការបន្តពង្រីករបបពិតទៅកាន់បណ្តាខេត្តផ្សេងៗទៀត ការបង្កើនចំនួនមន្ត្រីពន្ធតាមរយៈការប្រឡងជ្រើសរើស និងការបណ្តុះបណ្តាលមន្ត្រីពន្ធនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ពង្រឹងសមត្ថភាពអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈការបណ្តុះបណ្តាលជំនាញសវនកម្មពន្ធ ។

កម្មវិធីកំណែទំរង់រតនាគាររួមមាន÷ ការប្រមូលផ្តុំ និង ការធ្វើបញ្ជីសារពើភ័ណ្ឌនៃគណនីរដ្ឋាភិបាល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ តាមរយៈការបង្កើតគណកម្មការគ្រប់គ្រងសាច់ប្រាក់ ការកែលំអប្លង់គណនី និងនីតិវិធីគណនេយ្យ ការរៀបចំបង្កើតនូវប្រព័ន្ធដើម្បីគ្រប់គ្រង និងលុបបំបាត់បំណុលថវិកា ការបង្កើតប្រព័ន្ធគណនេយ្យសម្រាប់ក្រុមប្រឹក្សាឃុំ- សង្កាត់ និង ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីរតនាគារ ។

កម្មវិធីកំណែទំរង់ទីបួន ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងកម្មវិធីកំណែទំរង់ទី៣ ដែរ គឺរួមមានវិធានការកំណែទំរង់សំខាន់ៗដូចជា÷ ការអនុវត្តផែនការសកម្មភាពជាអាទិភាព (PAP) ដែលជាកម្មវិធីអនុវត្តសាកល្បងក្នុងការរៀបចំថវិកាតាមកម្មវិធី ការពង្រីក និង ពង្រឹងការអនុវត្តវិធានលទ្ធកម្មសាធារណៈ ការដាក់អោយអនុវត្តនូវក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ការធ្វើវិមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការបណ្តុះបណ្តាលមន្ត្រីក្នុងការអនុវត្ត និង ការគ្រប់គ្រងថវិកា ។ កំណែទំរង់នេះបានកែលម្អ និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធានាអោយបាននូវការប្រើប្រាស់ធនធានថវិកា ដោយចំទិសដៅនៃគោលនយោបាយ ដោយបែងចែក និង បើកផ្តល់ថវិកា អោយបានដល់អង្គភាពប្រតិបត្តិការ ។ ក៏ប៉ុន្តែ កំណែទំរង់នេះមិនបានសម្រេចលទ្ធផលអោយបានទូលំទូលាយទេ ដោយសារតែបញ្ហាកង្វះខាតសាច់ប្រាក់ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលបានទទួលស្គាល់ស្គាល់ថា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជានៅទន់ខ្សោយនៅឡើយ ហើយអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតែជាការព្រួយបារម្ភដ៏ចម្បងរបស់រាជរដ្ឋាភិបាល ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តការប្តេជ្ញាចិត្តដើម្បីជំរុញការអនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលស៊ីជំរៅ មានលក្ខណៈជាប្រព័ន្ធ និងទូលំទូលាយជាងមុន ។

«**យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា**» ដែលត្រូវបានដាក់ចេញដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ថាជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានអនុម័តយល់ព្រមដោយរដ្ឋសភានីតិកាលទី៣ នៅក្នុងឆ្នាំ ២០០៤ កន្លងទៅនេះ បានគូសបញ្ជាក់ឡើងវិញនូវភាពចាំបាច់ ក្នុងការបន្តកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ។

នៅក្នុងក្របខ័ណ្ឌនៃ **យុទ្ធសាស្ត្រចតុកោណ** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាប់ផ្តើមពិនិត្យនិងវាយតម្លៃជាប្រព័ន្ធនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយឈរលើពត៌មានដែលមានស្រាប់ រួមមានរបាយការណ៍វាយតម្លៃ របាយការណ៍វិភាគ និងវាយតម្លៃ ក៏ដូចជារបាយការណ៍ផ្សេងៗទៀត ខាងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាបទពិសោធន៍នៃកម្មវិធីកំណែទំរង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ **កម្មវិធីជំនួយសហប្រតិបត្តិការបច្ចេកទេស** (TCAP) និងរបាយការស្តីពី **ការវាយតម្លៃខាងផ្នែកហិរញ្ញវត្ថុអោយគ្រប់ជ្រុងជ្រោយ និងការពិនិត្យឡើងវិញលើចំណាយសាធារណៈ** (IFAPER) ដែលជាកម្មវិធីសហប្រតិបត្តិការបច្ចេកទេស ដែលគាំទ្រដោយទីភ្នាក់ងារ និងប្រទេសផ្តល់ជំនួយជាច្រើន ។ គោលដៅសំខាន់នៃការគំនិតផ្តួចផ្តើមនេះ គឺដើម្បីបង្កើតនូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានចក្ខុវិស័យរយៈពេលវែង និង មានកម្មវិធីអនុវត្តតាមដំណាក់កាល មានផែនការសកម្មភាពជាក់ស្តែងប្រាកដនិយមសម្រាប់ដំណាក់កាលនីមួយៗ សំដៅសំរេចអោយបាន នូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ។

កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានទទួលស្គាល់ និងត្រូវបានគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់ដៃគូអភិវឌ្ឍន៍របស់យើង ដោយរួមទាំងដៃគូអភិវឌ្ឍន៍ទ្វេភាគី និងទីភ្នាក់ងារអន្តរជាតិ តាមរយៈកិច្ចព្រមព្រៀងរួមស្តីអំពីការអនុម័តអភិក្រមគ្របដណ្តប់តាមផ្នែក ជាគំរូសម្រាប់ការរៀបចំ និងការអនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយ៉ាងទូលំទូលាយ ។ អភិក្រមគ្របដណ្តប់តាមផ្នែកបានកំណត់នូវផែនការសកម្មភាព ដែលសម្រេចអោយបានតាមទិសដៅនៃកម្មវិធី និង ការទទួលខុសត្រូវរបស់គ្រប់តួអង្គដែលពាក់ព័ន្ធ ដោយរួមបញ្ចូលទាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រទេសផ្តល់ជំនួយដើម្បីអនុវត្តកម្មវិធីទាំងអស់នេះផងដែរ ។

ដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់ដៃគូរអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានរៀបចំនូវឯកសារចក្ខុវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ដែលជាមគ្គុទ្ទេសក៍សម្រាប់ការអនុវត្ត មួយដំណាក់កាលម្តងៗ នូវកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈជាប្រព័ន្ធ ដែលនឹងត្រូវបញ្ចប់នៅឆ្នាំ ២០១៥ ។ ចំណុចខ្លាំងនៃកម្មវិធីកំណែទំរង់នេះ បើប្រៀបធៀបទៅនឹងកម្មវិធីកំណែទំរង់លើកមុនៗ គឺថា កម្មវិធីនេះត្រូវ បានរៀបចំឡើងដោយមានរចនាសម្ព័ន្ធច្បាស់លាស់ ហើយនិងមានផែនការសកម្មភាពជាក់លាក់ ដែលត្រូវបានបង្កើតឡើងមួយជំហានម្តងៗ ដោយយុទ្ធសាស្ត្រដើម្បីកសាងនូវសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដែលរួមមានការផ្តល់នូវសំភារៈបរិក្ខា និងការគាំទ្រចាំបាច់ផ្សេងៗទៀត ក៏ដូចជាបច្ចេកវិទ្យាសមស្រប ។

ដោយស្របទៅនឹង **យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ** រាជរដ្ឋាភិបាលបានរៀបចំនូវយុទ្ធសាស្ត្រកែលម្អ និងកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ។ ដើម្បីកំណត់នូវទិសដៅច្បាស់លាស់ចំពោះយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានអនុមតិយកនិយាមអន្តរជាតិក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ថាជាគោលដៅរយៈពេលវែងរបស់កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ យុទ្ធសាស្ត្រនៃកំណែទំរង់នេះ គឺការប្រែក្លាយប្រព័ន្ធថវិការតាមបែបប្រពៃណីយ ដែលផ្អែកលើមូលដ្ឋានសាច់ប្រាក់ ឱ្យក្លាយទៅជាប្រព័ន្ធមួយដែលមានការគ្រប់គ្រងយ៉ាងសមស្របនូវទ្រព្យសកម្ម និងធនធានទាំងអស់របស់រដ្ឋាភិបាល ។ ប្រការនេះទាមទារអោយដាក់អោយអនុវត្តនូវនិយាមគណនេយ្យបង្គរ ។

គោលដៅនៃកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការលើកកំពស់ស្តង់ដារនៃការគ្រប់គ្រង និងការទទួលខុសត្រូវក្នុងការកៀងគរនូវគ្រប់ប្រភេទនៃចំណូលចរន្ត និងមូលធនរបស់រាជរដ្ឋាភិបាល និងការកែលម្អប្រសិទ្ធភាព និង ភាគស័ក្តិសិទ្ធក្នុងការប្រើប្រាស់ធនធានក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និងកម្មវិធីជាអាទិភាពដទៃទៀត ។

បន្ទាប់ពីដាក់អោយអនុវត្តអោយបានជោគជ័យ នូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) តាមការគ្រោងមក ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជានឹងចរិតលក្ខណៈសំខាន់ៗ ដូចតទៅៈ

***ទី១.*** ការបែងចែកតួនាទី និងអំណាចសារពើពន្ធ ស្របទៅតាមច្បាប់ សម្រាប់ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ប៉ុន្តែត្រូវស្ថិតនៅក្រោមប្រព័ន្ធថវិកាឯកភាពមួយ ដែលគ្របដណ្តប់នៅគ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល និង ទៅតាមមុខងារ កម្មវិធី និង គម្រោងនានា ។

***ទី២.*** គ្របខ័ណ្ឌការងារផែនការនីយកម្ម និង កម្មវិធីមួយ ដែលមានសង្គតិភាព ហើយមានវិសាលភាពគ្របដណ្តប់លើគ្រប់វិស័យ នៅក្នុងនោះ ប្រតិបត្តិការថវិកាត្រូវធ្វើចំណាត់ថ្នាក់លើមូលដ្ឋានកម្មវិធី មុខងារ រដ្ឋបាល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និង សេដ្ឋកិច្ច ដែលកំណត់ច្បាស់អំពីចំណាយផ្ដោតលើការកាត់បន្ថយភាពក្រីក្រ និង ការគាំទ្រដល់ទិសដៅរួមនៃការគ្រប់គ្រងចំណាយសាធារណៈ ក្នុងគោលបំណងសម្រេចលទ្ធផលជាគោលនយោបាយនេះ ។

***ទី៣.*** ក្របខ័ណ្ឌការងារចំណាយរយៈពេលមធ្យម ដែលជាប្រតិបត្តិការមួយសម្រាប់គ្រប់គ្រងកម្មវិធីរយៈពេលច្រើនឆ្នាំ ។

***ទី៤.*** ថវិកាត្រូវគ្របដណ្ដប់លើគ្រប់ទិដ្ឋភាពនៃប្រតិបត្តិការរបស់រាជរដ្ឋាភិបាល រួមទាំងហិរញ្ញប្បទានថវិការយៈពេលវែង និងផែនការគ្រប់គ្រងបំណុល ព្រមទាំងផែនការរកប្រភពធនធានផ្សេងទៀត ដែលបញ្ចូលគ្រប់ផ្នែកហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល មានដូចជាអចលនៈទ្រព្យ និង ទ្រព្យសម្បត្តិផ្សេងៗ រួមទាំងបំណុលផងដែរ ។

***ទី៥.*** ការរៀបចំថវិកាមានឥទ្ធិពលលើសមាសធាតុលើកទឹកចិត្ត ទំហំការបណ្ដុះបណ្ដាល ការបែងចែកមន្ត្រីរាជការ និង មានឥទ្ធិពលផ្សេងៗទៀតទៅលើកម្មវិធី និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ម្យ៉ាងទៀតប្រព័ន្ធថវិកាក៏ត្រូវធានាផងដែរថា រាល់ឥណទានចំណាយបន្ថែមក្រោយការអនុមតិថវិកា ត្រូវតែមានប្រភពហិរញ្ញប្បទានឱ្យបានពេញលេញ ។

***ទី៦.*** ការទិញ ការបែងចែក ការប្រើប្រាស់ និងការទូទាត់បញ្ចេញរាល់ទ្រព្យសម្បត្តិ និង ធនធានរបស់រាជរដ្ឋាភិបាល រួមទាំងធនធានមនុស្សផងដែរ គឺត្រូវមានលក្ខណៈបើកចំហ ប្រកួតប្រជែង អព្យាក្រឹត្យ មិនប្រកាន់ពូជសាសន៍ និង មានតម្លាភាព ។ រាជរដ្ឋាភិបាលនឹងបង្កើត និង អនុវត្តវិធានច្បាប់យ៉ាងច្បាស់លាស់ដើម្បីលើកតម្កើង «តម្លៃនៃប្រាក់» (Value of money) សម្រាប់លទ្ធកម្មទំនិញ និងសេវា រួមទាំងការអនុវត្តឯកជនភាវូបនីយកម្ម ការចុះកិច្ចសន្យា និងដំណើរការគ្រប់គ្រងចំពោះវិស័យឯកជន ព្រមជាមួយការជ្រើសរើសការតាំងពង្រាយ និង ការតម្លើងឋានៈមន្ត្រីរាជការ ។

***ទី៧.*** រាជរដ្ឋាភិបាលមានកាតព្វកិច្ចឆ្លើយតបយ៉ាងឆាប់រហ័ស ច្បាស់លាស់ និងជាសាធារណៈចំពោះគ្រប់បញ្ហាទាំងអស់ ដែលកើតមានឡើងក្នុងកំឡុងពេលអនុវត្តថវិកា ។ របាយការណ៍ថ្មីៗប្រចាំខែនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយបង្ហាញអំពីវឌ្ឍនភាពក្នុងការអនុវត្តថវិកា រួមទាំងការត្រួតពិនិត្យឡើងវិញដោយគ្រប់ជ្រុងជ្រោយក្នុងមួយឆ្នាំពីរដង ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចផ្ដល់អនុសាសន៍ជូនទៅរាជរដ្ឋាភិបាល ដោយស្នើឡើងនូវវិធានការបង្ការទប់ស្កាត់ជាមុន ក្នុងករណីផែនការកំពុងអនុវត្តស្ថិតក្រោមការគម្រាមកំហែង ឧទាហរណ៍ ដូចជាការអនុវត្តមិនបានល្អនៃលំហូរចំណូលសាច់ប្រាក់ ឬ ការកើនឡើងនូវតម្រូវការចំណាយបន្ថែមមិនបានគ្រោងទុកជាមុន ។

***ទី៨.*** ការដាក់ចេញប្រព័ន្ធគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានថវិកា និង ហិរញ្ញវត្ថុមួយ ដោយប្រើប្រាស់កុំព្យូទ័រជាលក្ខណៈសមាហរណកម្ម និង គ្រប់ជ្រុងជ្រោយ ។ ប្រព័ន្ធនេះនឹងជួយសម្រួលដល់ការធ្វើរបាយការណ៍បានឆាប់រហ័ស និង ទៀងទាត់អំពីប្រតិបត្តិការហិរញ្ញវត្ថុ ដែលអនុវត្តដោយទីភ្នាក់ងាររដ្ឋាភិបាល ហើយជួយដល់ការផ្ទៀងផ្ទាត់ទិន្នន័យសារពើពន្ធ ជាមួយនឹងគណនីរដ្ឋាភិបាលនៅធនាគារ រួមទាំងគណនីបុរេប្រទាន និង គណនីបណ្ដោះអាសន្ន ។

***ទី៩.*** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងរៀបចំស្តង់ដារណែនាំ និង ការពិនិត្យតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ទីភ្នាក់ងារចំណាយនានា ក្នុងនោះមានស្តង់ដារសវនកម្មផ្ទៃក្នុងផងដែរ ។

***ទី១០.*** ក្រសួង និងទីភ្នាក់ងារចំណាយនីមួយៗ ត្រូវបង្កើតគណៈកម្មាធិការសវនកម្មផ្ទៃក្នុងមួយ ដើម្បី (ក). ដឹកនាំការរៀបចំ និង គ្រប់គ្រងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ (ខ). ត្រួតពិនិត្យ និង ផ្តល់ការគាំទ្រដល់ការអនុវត្តន៍សវនកម្មនានា ។ ទន្ទឹមនឹងនោះ ត្រូវមានសវនកម្មពីខាងក្រៅ ដែលឯករាជ្យ និង អនុវត្តទៀងទាត់តាមកាលបរិច្ឆេទច្បាស់លាស់ ។

***ទី១១.*** អាជ្ញាធរជាតិសវនកម្មត្រូវផ្តល់របាយការណ៍សវនកម្ម ដែលត្រូវប្រកាសផ្សាយជាសាធារណៈ ហើយ រាជរដ្ឋាភិបាលត្រូវធ្វើសកម្មភាព ឬ ចំណាត់ការជាបន្ទាន់ ទៅតាមអនុសាសន៍ដែលលើកឡើងក្នុងរបាយការណ៍សវនកម្មទាំងនោះ ។

***ទី១២.*** ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំឡើង ដើម្បីស្វែងរកការអនុវត្តទាំងក្នុងការប្រើប្រាស់ធនធាន និង ការសម្រេចលទ្ធផលជាគោលនយោបាយ តាមរយៈការគ្រប់គ្រងហិរញ្ញវត្ថុសាធារ-ណៈឱ្យបានល្អប្រសើរ ។ ទន្ទឹមនឹងនោះ ជាបណ្តើៗប្រព័ន្ធនេះត្រូវស្វែករក ឬ ធានា «តម្លៃនៃប្រាក់ជាអតិបរមា» ក្នុងរយៈពេលវែងចំពោះការប្រើប្រាស់ធនធាន ឬ ទ្រព្យសម្បត្តិរបស់រដ្ឋ ។ ដោយឡែក ចំពោះការអនុវត្តការងារបានល្អចាំបាច់ត្រូវផ្តល់រង្វាន់លើកទឹកចិត្ត ចំណែកការប្រព្រឹត្តិខុសដោយល្មើសនឹងច្បាប់ ត្រូវស្រាវជ្រាវរកទោសកំហុស និង ដាក់ទណ្ឌកម្មឱ្យបានសមស្រប ។

### *៧.១. អនុប្រព័ន្ធប្រតិបត្តិការនានានៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ*

ដើម្បីស្ថាបនាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយមានលក្ខណៈល្អប្រសើរ ដូចដែលយើងបានបរិយាយនៅខាងលើ ប្រព័ន្ធនេះចាំបាច់ត្រូវតួបផ្សំជាមួយនឹងអនុប្រព័ន្ធប្រតិបត្តិការមួយចំនួនទៀត ។ អនុប្រព័ន្ធប្រតិបត្តិការទាំងនោះ រួមមាន÷ (ទី១). ប្រព័ន្ធនៃដំណើរប្រតិបត្តិការ និង គណនេយ្យ (ទី២). ប្រព័ន្ធថវិកា (ទី៣). ប្រព័ន្ធចំណូល (ទី៤). ប្រព័ន្ធច្រកចូល *(Access systems)* ។ អនុប្រព័ន្ធទាំងបួននេះ ចាំបាច់ត្រូវមានសង្គតិភាព និង មានចំណងទាក់ទងគ្នាទៅវិញទៅមក ។ ជាសង្ខេប អនុប្រព័ន្ធប្រតិបត្តិការទាំងនេះ មានលក្ខណៈសង្ខេបដូចខាងក្រោម÷

#### ទី១. ប្រព័ន្ធនៃដំណើរប្រតិបត្តិការ និង គណនេយ្យ:

-អភិក្រមសង្គតិភាពនៃគណនេយ្យ *(consistent approach to accounting)* ត្រូវបានប្រើប្រាស់នៅក្នុងគ្រប់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដែលជាបឋមផ្អែកលើមូលដ្ឋាន «គណនេយ្យសាច់ប្រាក់» ក្នុងឆ្នាំសារពើពន្ធនីមួយៗ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ក្នុងពេលអនាគត យើងនឹងពិចារណាដល់ការផ្លាស់ប្តូរទៅរក «គណនេយ្យបង្គរ» *(Accrual Accounting)* នូវអ្វីដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានក្នុងមួយឆ្នាំៗ ដូចជាថ្លៃពលកម្ម ព្រមទាំងទំនិញ និង សេវា ។

- ការផ្តល់អំណាចដល់អាណាប័កនៃថវិកា ដើម្បីអនុវត្តដោយគ្មានការរាំងស្ទះ ទៅតាមការកំណត់ក្នុងគម្រោងថវិកា (តាមថវិកាកែ សម្រួលក្នុងឆ្នាំនីមួយៗ) ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការត្រួតពិនិត្យក្រោយពេលចំណាយ ជាងការពិនិត្យពិច័យមុនពេលចំណាយ ។

- ទន្ទឹមនឹងនេះ ត្រូវបង្កើតយន្តការដោយឡែកសម្រាប់ប្រមូល និង តាមដានព័ត៌មានអំពីកិច្ចសន្យាចំណាយដែលមិនទាន់បានទូទាត់បញ្ជី ។

**ទី២. ប្រព័ន្ធថវិកា:**

- ជាទូទៅ ថវិកាប្រចាំឆ្នាំរបស់អណាប័កទាំងអស់ ត្រូវរៀបចំក្នុងបរិការណ៍នៃការប៉ាន់ស្មានដោយប្រាកដនិយម សម្រាប់រយៈពេលច្រើនឆ្នាំ ហើយតួលេខនោះត្រូវបានផ្សព្វផ្សាយភ្ជាប់ជាមួយថវិកា ។

- ការអនុវត្តដំណើរវិលវិល នៅក្នុងការប៉ាន់ស្មានថវិកាច្រើនឆ្នាំ មានន័យថាឆ្នាំទី ២ ក្នុងជុំនីមួយៗ គឺជាមូលដ្ឋានចាប់ផ្តើមសម្រាប់រៀបចំថវិកាឆ្នាំបន្ទាប់ ។

- គ្រប់ការបែងចែកធនធានសាធារណៈសំខាន់ៗទាំងអស់ ដែលទទួលបានហិរញ្ញប្បទានត្រូវរំលេចឱ្យបានច្បាស់ និង មានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

- រាល់ការបែងចែក និង ពិនិត្យតាមដានការប្រើប្រាស់ធនធានទាំងអស់ ត្រូវបញ្ចូលទៅក្នុង «ការវិភាគដែលពឹងផ្អែកលើកម្មវិធី» ។

- ត្រូវធ្វើវិមជ្ឈការ ដោយប្រគល់ទាំងសមត្ថកិច្ច និង ការទទួលខុសត្រូវឱ្យដល់អ្នកអនុវត្តថវិកា ។

**ទី៣. ប្រព័ន្ធកៀងគរធនធាន:**

- ត្រូវប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវសមត្ថភាពបង្កើនចំណូល របស់យើង តាមរយៈការអនុវត្តអភិក្រមតុល្យភាព *(balanced approach)* ក្នុងការប្រមូលចំណូលពន្ធដារ (ពន្ធផ្ទាល់ និង ប្រយោល) និង ការយកកម្រៃផ្សេងៗពីសាធារណៈជន ព្រមទាំងការកៀងគរចំណូលពីប្រភពហិរញ្ញប្បទានផ្សេងទៀត (រួមមានជំនួយពីក្រៅប្រទេស និង កម្ចីក្នុង និង ក្រៅស្រុក) ។

- ប្រព័ន្ធកៀងគរចំណូលនឹងធានាបាននការអនុលោមដោយពេញលេញតាមច្បាប់ និង បទប្បញ្ញត្តិដទៃទៀតជាធរមាន ជាពិសេស ច្បាប់សារពើពន្ធ ច្បាប់គយ និង ច្បាប់វិនិយោគ ព្រមទាំងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និង មានតម្លាភាពចំពោះជំនួយ និង ហិរញ្ញប្បទានកម្ចីពីក្រៅប្រទេស ដោយកាត់បន្ថយជាអប្បបរមា នូវបន្ទុកលើអ្នកបង់ពន្ធ ក៏ដូចជាបន្ទុករបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនោះ ប្រព័ន្ធកៀងគរចំណូលនេះ នឹងបង្កើនប្រសិទ្ធភាពជា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អតិបរមាលើការប្រើប្រាស់ចំណូល សម្រាប់រាជរដ្ឋាភិបាលអនុវត្តគោលនយោបាយរបស់ខ្លួន តាមរយៈកម្មវិធីចំណាយសាធារណៈ ។

**ទី៤. ប្រព័ន្ធច្រកចូល** *(access system)* :

- ការធានាឱ្យគ្រប់អ្នកពាក់ព័ន្ធអាចទទួលបាននូវទិន្នន័យដែលត្រឹមត្រូវ អាចទុកចិត្តបាន និង ទាន់ពេលវេលា តាមរយៈការប្រើប្រាស់ដោយមានលក្ខណៈ សមាហរណកម្មនូវបច្ចេកវិទ្យាព័ត៌មានទំនើប ។

- បើកចំហដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ (ក្នុង និងក្រៅរដ្ឋាភិបាល) ដែលមានចំណាប់អារម្មណ៍ចំពោះការពិនិត្យឡើងវិញនូវលទ្ធផលការអនុវត្តថវិកា ដោយប្រៀបធៀបនឹងផែនការប្រចាំឆ្នាំ តាមរយៈតារាងទិន្នន័យមួយច្បាស់លាស់ និង មានតម្លាភាព ។

- ប្រព័ន្ធសវនកម្មទាំងផ្ទៃក្នុង និង ផ្ទៃក្រៅមួយប្រកបដោយប្រសិទ្ធភាព ហើយទទួលបានការគាំទ្រពីគ្រប់បណ្តាភាគីពាក់ព័ន្ធទាំងអស់ក្នុងការគ្រប់គ្រង និង ការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព ។

រាជរដ្ឋាភិបាលកំពុងដំណើរការអភិវឌ្ឍអនុប្រព័ន្ធពិនិត្យតាមដាន និង វាយតម្លៃមួយ ដើម្បីអាចមានលទ្ធភាពអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលនឹងត្រូវស្ថិតនៅក្រោមការពិនិត្យតាមដាន និង វាយតម្លៃជាប្រចាំ ។ ហេតុដូច្នេះ លក្ខណៈគន្លឹះនៃចក្ខុវិស័យសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបានកំណត់ដោយសូចនាករនានា ដែលមានសង្គតិភាព មានលក្ខណៈស្របតាមស្តង់ដារអន្តរជាតិ និង ស្របតាមការអនុវត្តដ៏ល្អប្រសើរនៅលើពិភពលោក និង គ្របដណ្តប់លើផ្នែកមួយចំនួនដូចខាងក្រោម៖

**១. ភាពប្រាកដនិយមនៃថវិកា:** ថវិកា គឺត្រូវមានភាពប្រាកដនិយម និង អនុវត្តទៅបានជាលទ្ធផលដូចដែលគេរំពឹងទុកក្នុងរបៀបមួយដែលគេអាចទស្សទាយទុកជាមុន (ឧទាហរណ៍ សមាសភាពចំណាយធៀបទៅនឹងថវិកាដែលបានអនុម័ត ដោយសមាមាត្រទៅនឹងមូលនិធិ ដែលអង្គភាពនីមួយៗទទួលបានសម្រាប់ផ្តល់សេវានានាជាដើម ។ល។)

**២. ថវិកាពឹងផ្អែកលើគោលនយោបាយ និង ភាពគ្រប់ជ្រុងជ្រោយ:** ថវិកាប្រមូលផ្តុំរាល់ប្រតិបត្តិការសារពើពន្ធ ដែលពាក់ព័ន្ធនានា ។ ថវិកាក៏ត្រូវបានរៀបចំឡើង ក្នុងវិធីមួយដែលមានរបៀបរៀបរយ និង អាចទស្សទាយទុកជាមុន ដោយអនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល (ឧទាហរណ៍ ការរៀបចំថវិកាត្រូវមានបរិបថឯកភាពរួមមួយ ដែលរួមបញ្ចូលដំណើរការ និងប្រតិទិនរៀបចំ ហើយថវិកាមានលក្ខណៈសម្របសម្រួលពេញលេញ ទាំងសម្រាប់ថវិកាវិនិយោគ ទាំងចំណាយចរន្ត មានការកំណត់កញ្ចប់ថវិកាដោយ អនុលោមតាមអាទិភាពចំណាយរបស់រាជរដ្ឋាភិបាល ដែលកំណត់ដោយថ្នាក់ដឹកនាំនយោបាយ ។ល។) ។

**៣. ការគ្រប់គ្រងសារពើពន្ធ:** ស្ថានភាពសារពើពន្ធសរុប និង ហានិភ័យក្នុងកម្រិតម៉ាក្រូ នឹងត្រូវបានពិនិត្យតាមដាន និង គ្រប់គ្រងយ៉ាងហ្មត់ចត់ (ឧទាហរណ៍មានបំណុលទូទាត់កកស្ទះខ្លះ ឬ គ្មានសោះ? មានប្រព័ន្ធគ្រប់គ្រងបំណុលក្នុង និង ក្រៅប្រទេសបានសមស្រប ឬ មិនទាន់មាន?)។

**៤. ព័ត៌មាន:** ត្រូវមានកំណត់ត្រា និងព័ត៌មានគ្រប់គ្រាន់ស្ដីពីសារពើពន្ធ ចំណូល និងចំណាយដែលត្រូវបានចងក្រងរក្សាទុក និង ផ្សព្វផ្សាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រេចចិត្ត ការត្រួតពិនិត្យ និង ការគ្រប់គ្រង (ឧទាហរណ៍រាជរដ្ឋាភិបាល ត្រូវមានរបាយការណ៍ថវិកា ដែលមានចំណាត់ថ្នាក់ថវិកាសមស្រប និងដែលអាចប្រៀបធៀបបានសម្រាប់ចុងខែ ឬ ចុងត្រីមាសនីមួយៗ ។ របាយការណ៍នេះត្រូវបានផ្ទៀងផ្ទាត់ជាប្រចាំដោយធនាគារប្រកបដោយគុណភាពខ្ពស់) ។

**៥. ការត្រួតពិនិត្យ:** ត្រូវមានការត្រួតពិនិត្យ និង កាតព្វកិច្ចទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពក្នុងប្រតិបត្តិការប្រើប្រាស់មូលនិធិសាធារណៈ (ឧទារហណ៍ ប្រព័ន្ធសវនកម្មផ្ទៃក្នុងមានប្រសិទ្ធភាព ប្រព័ន្ធលទ្ធកម្មសាធារណៈ ដែលពឹងផ្អែកលើវិធានច្បាប់ មានសង្គតិភាពច្បាស់លាស់ និង អាចអនុវត្តបាននូវតារាងប្រាក់បៀវត្សរ៍ និង បញ្ជីឈ្មោះមន្ត្រីរាជការ ដោយផ្សារភ្ជាប់ជាមួយប្រព័ន្ធកុំព្យូទ័រនីយកម្ម ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន និង កំពុងប្រើប្រាស់)។

**៦. គណនេយ្យភាព និងតម្លាភាព:** ត្រូវមានយន្តការដែលមានលក្ខណៈប្រកបដោយគណនេយ្យភាព និង តម្លាភាព ក្នុងផ្នែកហិរញ្ញវត្ថុ សម្រាប់មជ្ឈដ្ឋានខាងក្រៅអនុវត្ត (ឧទាហរណ៍ សហគមន៍ត្រូវបានទទួលព័ត៌មានដោយទៀងទាត់អំពីការបែងចែកថវិកា និង មូលនិធិដែលអង្គភាព ឬ ស្ថាប័នផ្ដល់សេវានីមួយៗទទួលបាន ។ សវនកម្មផ្ទៃក្រៅត្រូវគ្របដណ្ដប់លើគ្រប់អង្គភាពសាធារណៈសំខាន់ៗ និងត្រូវអនុវត្តសវនកម្មហិរញ្ញវត្ថុឱ្យពេញលេញ) ។

**៧. ភាពច្បាស់លាស់ និង គណនេយ្យភាព:** ត្រូវមានក្របខ័ណ្ឌការងារច្បាប់ និង ស្ថាប័នប្រកបដោយច្បាស់លាស់ សម្រាប់ទទួលខុសត្រូវលើមុខងារ និង ចំណាយនៅគ្រប់លំដាប់ថ្នាក់របស់រាជរដ្ឋាភិបាល ព្រមទាំងការគ្រប់គ្រងរបស់អាណាប័កថវិកាប្រកបដោយគណនេយ្យភាព (ឧទាហរណ៍ អ្នកគ្រប់គ្រងកម្មវិធីត្រូវមានភាពបត់បែនបានជាអតិបរមា ក្នុងការជ្រើសរើស ការកៀងគរ និងការប្រើប្រាស់ធនធាន ដើម្បីសម្រេចឱ្យបាននូវគោលដៅរបស់កម្មវិធី ។ ទន្ទឹមនឹងនោះ ត្រូវមានគណនេយ្យភាពចំពោះមុខសភាជាតិ និង ប្រជាជនក្នុងការប្រើប្រាស់ធនធានសាធារណៈ ។ ដោយឡែក ការទទួលខុសត្រូវជាសាធារណៈចំពោះលទ្ធផលនៃការអនុវត្តកម្មវិធីក៏ត្រូវតែបានផ្ទេរទៅឱ្យក្រសួងសាម៉ីផងដែរ) ។

**៨. តម្លៃនៃប្រាក់:** ត្រូវធានាឱ្យបានក្នុងកំរិតអតិបរមាតម្លៃនៃប្រាក់ ក្នុងការប្រើប្រាស់ធនធាន សាធារណៈ (ឧទាហរណ៍ ការកាត់បន្ថយតម្លៃសំភារៈផ្គត់ផ្គង់តាមរយៈការធ្វើលទ្ធកម្មជាប្រចាំ) ។

**៩. ប្រតិកម្មឆ្លើយតប** *(responsiveness)***:** ការគ្រប់គ្រងសារពើពន្ធ និង ថវិកា ត្រូវមានលក្ខណៈ រស់រវើក (ឧទាហរណ៍ ត្រូវមានការត្រួតពិនិត្យឡើងវិញ ក្នុងរយៈពេលពាក់កណ្ដាលឆ្នាំដំបូងនូវការងាររបស់ស្ថាប័នស្ដីពីលទ្ធផលអនុវត្តន៍ថវិកា ដែលនឹងត្រូវក្លាយជាមូលដ្ឋាន សម្រាប់ពិចារណាក្នុងការអនុវត្តថវិកានៅពាក់

កណ្ដាលឆ្នាំបន្ទាប់ និង សម្រាប់ការរៀបចំថវិកានៅឆ្នាំក្រោយៗទៀត)។

**១០. វិជ្ជាជីវនិយម:** ត្រូវបង្កើតឱ្យមានវិជ្ជាជីវនិយម ក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និង ការលើកទឹកចិត្ត (ឧទាហរណ៍ការកសាងក្រុមស្នូលនៃអ្នកជំនាញការផ្នែកបច្ចេកទេស) ។

## ៧.២. យុទ្ធសាស្ត្ររយៈពេលវែង

កម្មវិធីកំណែទម្រង់នឹងត្រូវអនុវត្តជាបួនដំណាក់កាល៖ **ដំណាក់កាលទី១:** គឺការអនុវត្តនូវផែនការសកម្មភាពរយៈពេលខ្លី ដោយរាប់បញ្ចូលទាំងសកម្មភាពសំខាន់ៗដែលចាំបាច់ក្នុងការសម្រេចអោយបាននូវដំណាក់កាលទី១ និង សកម្មភាពដែលត្រូវប្រើប្រាស់រយៈពេលវែង និងដែលចំបាច់សម្រាប់ដដំណាក់កាលក្រោយៗទៀត។ **ដំណាក់កាលទី២** និង **ដំណាក់កាលទី៣:** គឺជាគម្រោងកម្មវិធីរយៈពេលមធ្យម ដែលត្រូវរៀបចំឡើងនៅពេលបញ្ចប់ដំណាក់កាលទី១ ក្នុងពេលដែលយើងអាចឃើញថាគោលដៅនៃដំណាក់កាលទី១ត្រូវបានសម្រេចជាបណ្ដើរៗ ។ **ដំណាក់កាលទី៤:** គឺជាគម្រោងរយៈពេលវែង ឆ្ពោះទៅរកការសម្រេចនូវចក្ខុវិស័យជារួម ។

**ដំណាក់កាលទី១. ថវិកាដែលគួរអោយជឿទុកចិត្តបាន:** នៅដំណាក់កាលដំបូង រាជរដ្ឋាភិបាលនឹងប្រឹងប្រែងសម្រេចឱ្យបាននូវស្ថានភាពមួយ ដែលថវិកាទទួលបានជំនឿទុកចិត្តច្រើន ក្នុងន័យជាឧបករណ៍យុទ្ធសាស្ត្រមួយសម្រាប់ការគ្រប់គ្រងធនធានសាធារណៈប្រចាំថ្ងៃ ពីព្រោះថវិកាផ្ដល់ជាធនធាន ដែលអាចទស្សទាយទុកជាមុន និង មានការទទួលខុសត្រូវចំពោះមន្ត្រីគ្រប់គ្រងថវិកានីមួយៗ ។ ប្រព័ន្ធនេះបង្ហាញលំអិតថា ថវិកាឆ្លុះបញ្ចាំងពីប្រភព និង ការបែងចែកថវិកា ។ ដូច្នេះគេអាចឈានទៅអនុវត្តជំហានបន្ត ដែលជម្រុញឱ្យមន្ត្រីគ្រប់គ្រងថវិកាមានគណនេយ្យភាពចំពោះការប្រើប្រាស់ ដែលមានលក្ខណៈប្រកបដោយភាពត្រឹមត្រូវ ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិ ។

**ដំណាក់កាលទី២. គណនេយ្យភាពហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព:** បន្ទាប់ពីទទួលបានជោគជ័យនូវការអនុវត្តនូវកម្មវិធីកំណែទំរង់ដំណាក់កាលទី១ និង លុបបំបាត់នូវរាល់ភាពអសកម្មរបស់អ្នកគ្រប់គ្រងថវិកា រាជរដ្ឋាភិបាលនឹងរិតបន្តឹងការគ្រប់គ្រង ដើម្បីជម្រុញអាណាប័កថវិកាឱ្យមានការទទួលខុសត្រូវ និង ផ្ដល់ការលើកទឹកចិត្តចំពោះការអនុវត្តការងារល្អ ។ កិច្ចការនេះត្រូវកែលំអជាបឋមលើការត្រួតពិនិត្យផ្ទៃក្នុង និង ប្រព័ន្ធគណនេយ្យភាពនៅគ្រប់កម្រិតទាំងអស់ ។ ប្រព័ន្ធនេះនឹងផ្ដោតការយកចិត្តទុកដាក់ទៅលើអ្វីដែលបានអនុវត្តដោយផ្ដល់ទិន្នន័យច្បាស់លាស់ ប្រកបដោយប្រសិទ្ធភាព និង មានតម្លាភាពផ្ទៃក្នុង ។

**ដំណាក់កាលទី៣. របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលត្រូវបានកំណត់ជាអាទិភាពត្រឹមត្រូវ និង មានលទ្ធភាពពេញលេញ:** ផ្អែកលើមូលដ្ឋានដែលបានរៀបចំឡើងក្នុងជំហានមុនដែលក្នុងនោះ ថវិកាបានក្លាយទៅជាឧបករណ៍ដែលអាចទុកចិត្តបាន សម្រាប់ការអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលនឹងផ្ដោតលើការរៀបចំបច្ចេកទេស និងសមត្ថភាពសម្រាប់វិភាគអំពីផលប៉ះពាល់គោលនយោបាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថវិកា និងភ្ជាប់ទំនាក់ទំនងអាទិភាព គោលនយោបាយ និងគោលដៅសេវា ទៅនឹងផែនការ និងការអនុវត្តថវិកា ដែលធានាថា គោលនយោបាយរបស់រាជរដ្ឋាភិបាល នឹងត្រូវបានកំណត់អាទិភាពច្បាស់លាស់ និង មានលទ្ធភាពអាចអនុវត្តបានយ៉ាងពេញលេញ ។ ការងារនេះ នឹងជម្រុញឱ្យមានគណនេយ្យភាពច្រើនឡើង ចំពោះលទ្ធផលការអនុវត្តកម្មវិធីថវិកា ។

**ដំណាក់កាលទី៤. មន្ត្រីគ្រប់គ្រងរបស់រាជរដ្ឋាភិបាល នឹង មានគណនេយ្យភាពពេញលេញចំពោះលទ្ធផលនៃការអនុវត្តកម្មវិធី:** ដោយជម្រុញឱ្យមានស្ថិរភាព សុក្រឹតភាព និងគោលនយោបាយឈានឆ្ពោះទៅរកការអនុវត្តផែនការ និង ការគ្រប់គ្រងថវិកា រាជរដ្ឋាភិបាលអាចចាប់ផ្តើមជំរុញឱ្យមន្ត្រីគ្រប់គ្រងថវិកា មានគណនេយ្យភាព និង លើកទឹកចិត្តពួកគេឱ្យសម្រេចគោលបំណងទៅតាមគោលដៅ និងស្តង់ដារអនុវត្តដែលបានគ្រោងទុក ។ ដំណើរការគណនេយ្យភាព និង ការត្រួតពិនិត្យឡើងវិញ ទាំងការគ្រប់គ្រងលទ្ធផលនៃការអនុវត្ត និង ហិរញ្ញវត្ថុ នឹងត្រូវធ្វើសមាហរណកម្មយ៉ាងពេញលេញ ដោយឆ្លុះបញ្ចាំងអំពីតម្លាភាព និង ការផ្តល់យោបល់ ប្រកបដោយប្រសិទ្ធភាពពីមជ្ឈដ្ឋានខាងក្រៅចំពោះការអនុវត្តគោលនយោបាយនេះ ។

ដើម្បីសម្រេចបានចក្ខុវិស័យ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ យើងត្រូវការពេលវេលា និងត្រូវធ្វើដំណើរនៅលើផ្លូវដ៏វែងឆ្ងាយ និង ត្រូវពុះពារឆ្លងកាត់ការខិតខំប្រឹងប្រែងជាច្រើនថែមទៀត ។ ទន្ទឹមនឹងនោះជោគជ័យនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ អាស្រ័យទៅលើលទ្ធផលនៃកំណែទម្រង់វិស័យតុលាការ និងយុត្តិធម៌ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងការចូលរួមពីសំណាក់គ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ក្នុងនោះរួមមានសហគមន៍អ្នកផ្តល់ជំនួយ ផ្នែកឯកជន សង្គមស៊ីវិល ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៅគ្រប់ក្រសួងស្ថាប័នផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការអនុវត្តអោយបានតាមពេលវេលា និង តាមដំណាក់កាលដែលបានដាក់ចេញ នូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញាវត្ថុសាធារណៈនេះ ហើយកម្មវិធីនេះទាមទារអោយប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ នូវធនធានដ៏កម្រ តាមរយៈការខិតខំប្រឹងប្រែងរួមគ្នា ដើម្បីរួមចំណែកជម្រុញ ***កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ។

### ៧.៣- សមាសភាពនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈចែកជា ៧ ផ្នែកដូចខាងក្រោម៖

### ៧.៣.១- កំណែទម្រង់ថវិកា និង រតនាគារ

កំណែទំរង់ផ្នែកនេះមានគោលដៅធ្វើទំនើបភាវូបនីយកម្មនៃកាគ្រប់គ្រងរតនាគារ ដើម្បីកែលម្អការអនុវត្ត និង ការត្រួតពិនិត្យថវិកា រួមទាំងការបង្កើតឡើងនូវ **ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុ**


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សាធារណៈ** (FMIS) ។ កម្មវិធីកំណែទំរង់ផ្សេងៗទៀតមរួមមាន៖ (ក). ពិពណ៌នាយ៉ាងលំអិតនូវដំណើរការអនុវត្តថវិកា (ពីដំណាក់កាលធានាចំណាយ ការប្រគល់ទទួលទំនិញនិងសេវា ដល់ការរៀបចំអាណត្តិបើកប្រាក់ និង ការទូទាត់) ដោយបង្កើតឡើងនូវផែនការនៅក្នុងដំណាក់កាលអន្តរកាល មុននឹងអនុម័តនូវដំណើរការថវិកាថ្មីមួយ ដែលមានលក្ខណៈកាន់តែសាមញ្ញ និង កាន់តែមានប្រសិទ្ធភាព (ខ). បង្កើនការទូទាត់រវាងរដ្ឋាភិបាល ជាមួយនឹងតួអង្គដទៃទៀតតាមប្រព័ន្ធធនាគារ ដូចជា ការបង់ពន្ធ ការបើកប្រាក់បៀវត្សអោយមន្ត្រីរាជការ និង ការទូទាត់កិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន (គ). រៀបចំ និង អនុវត្តវិធានការពង្រឹងវិន័យថវិកា ដោយកាត់បន្ថយនូវកំណើននៃបំណុលថវិកា (ឃ). រៀបចំលក្ខខណ្ឌបច្ចេកទេស ដើម្បីវាយតម្លៃអោយបានត្រឹមត្រូវនូវក្របខ័ណ្ឌ និង នីតិវិធីនៃ**ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** (FMIS) ដោយសង្កត់ធ្ងន់លើការកាត់បន្ថយ និង ការពង្រឹងតម្លាភាពនៃដំណើរការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មុននឹងចាប់ផ្តើមអនុវត្តកម្មវិធីគ្រប់គ្រងតាមបែបកុំព្យូទ័រ (ង). ស្វែងរកការផ្តល់អនុសាសន៍ស្តីពីគោលនយោបាយ ប្រព័ន្ធរៀបចំល្អ និង ខ្លឹមសារ ដើម្បីដោះស្រាយបញ្ហាសមត្ថភាព និងបច្ចេកវិទ្យា ដោយរួមទាំងកម្មវិធីដាក់ឱ្យប្រើប្រាស់នូវកម្មវិធី និង សម្ភារៈប្រព័ន្ធព័ត៌មានវិទ្យា រួមទាំងការសាកល្បង និង ការធានារ៉ាប់រងគុណភាព (ឆ). កសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់កិច្ចដំណើរការ**គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** (FMIS) និងប្រើប្រាស់របាយការណ៍របស់ប្រព័ន្ធនេះ និង (ជ) បណ្តុះបណ្តាល និង កសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ ក្នុងការប្រើប្រាស់នូវប្រព័ន្ធដែលបានរៀបចំរួចស្រេច ។ សមាសភាពនេះតម្រូវឱ្យមានការចូលរួមការងារពីសំណាក់ក្រសួងនានា ដែលស្ថិតក្នុងភាពខុសគ្នានៃការអនុវត្តកម្មវិធីកំណែទម្រង់។

### ៧.៣.២ លទ្ធកម្មសាធារណៈ

កម្មវិធីកំណែទម្រង់ផ្នែកនេះនឹងជួយកែលម្អការងារធ្វើលទ្ធកម្ម ដើម្បីពង្រឹងតម្លាភាព ធានាអោយបាននូវការសន្សំសំចៃ និងប្រសិទ្ធភាព ដោយកាត់បន្ថយ និងសម្រួចដល់ដំណើរការអនុមតិចំណាយថវិកា និង ពន្លឿនដល់ការធ្វើវិមជ្ឈការឱ្យបានឆាប់រហ័ស ។ ប្រការនេះនឹងជួយជំរុញការអនុវត្តនីតិវិធីលទ្ធកម្មថ្មី ដោយបានកែលម្អនូវក្របខ័ណ្ឌគតិយុត្តិ និង លិខិតបទដ្ឋានពាក់ព័ន្ធនឹងការងារលទ្ធកម្ម រួមទាំងការប្រើប្រាស់សៀវភៅណែនាំការងារលទ្ធកម្ម និងឯកសារដេញថ្លៃគំរូ ។ សកម្មភាពការងារដទៃទៀតមានដូចជា៖ (ក). ពិនិត្យឡើងវិញនូវដំណើរការលទ្ធកម្ម ដើម្បីឱ្យសមស្របតាមនីតិវិធីថវិកាថ្មី (ខ). ជួយរៀបចំនូវសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្ម (គ). ការធ្វើវិមជ្ឈការការងារលទ្ធកម្មអោយទៅក្រសួង និង ខេត្ត (ឃ). មានការកសាងសមត្ថភាពស្ថាប័ន ដោយរួមមានការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពរបស់អង្គភាពលទ្ធកម្ម ក្រុមហ៊ុនដេញថ្លៃ និង អ្នកផ្គត់ផ្គង់ពាក់ព័ន្ធនឹងការអនុវត្តនូវនីតិវិធីលទ្ធកម្មថ្មី ។ ការងារនេះទាមទារឱ្យមានកិច្ចសហការជាមួយគ្រប់ក្រសួង- ស្ថាប័នទាំងអស់ដែលស្ថិតនៅក្នុងដំណាក់កាលផ្សេងៗគ្នាក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ ។

### ៧.៣.៣ កំណែទម្រង់សារពើពន្ធ

កម្មវិធីកំណែទម្រង់ផ្នែកនេះមានគោលដៅជួយគាំទ្រ ដល់ការងារទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារតាមរយៈការពង្រឹងសមត្ថភាព និង កំណែទម្រង់ស្ថាប័ន និង រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាន ។ វិធានការកំណែទម្រង់នឹងផ្តោតផងដែរលើការពង្រឹងទីស្នាក់ការធំរបស់នាយកដ្ឋានពន្ធដារ ។ ជាជំហានដំបូង គម្រោងនឹងពិនិត្យឡើងវិញនូវកម្មវិធីកំណែទម្រង់ដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានពន្ធដារ ។ ការត្រួតពិនិត្យឡើងវិញនេះនឹងផ្តល់នូវកាលានុវត្តិភាព ដើម្បីជួយបង្កើនភាពជាម្ចាស់ ដោយមានការចូលរួមពីសំណាក់បុគ្គលិក និង មន្ត្រីរាជការ ការពិគ្រោះយោបល់ជាមួយអ្នកបង់ពន្ធស្តីពីបញ្ហាដែលពួកគេព្រួយបារម្ភ ។ យើងនឹងយកចិត្តទុកដាក់លើការផ្តល់ការលើកទឹកចិត្តសម្រាប់បុគ្គលិក ដើម្បីអោយពួកគេបំពេញតួនាទីអោយបានត្រឹមត្រូវ ។ សកម្មភាពការងារដទៃទៀតរួមមាន៖ (ក). កំណែទម្រង់រចនាសម្ព័ន្ធចាត់តាំង ដើម្បីអោយស្ថាប័ននេះអាចបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ (ខ). ការរៀបចំ និង ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពរបស់អគ្គនាយកដ្ឋានពន្ធដារ និង (គ). ការកែលម្អការផ្តល់សេវាដល់អ្នកបង់ពន្ធ ដោយផ្តោតជាសំខាន់ទៅលើការសម្រួលការចុះបញ្ជី និង ការគ្រប់គ្រងគណនីរបស់អ្នកបង់ពន្ធ ការពង្រឹងការងារសវនកម្ម និង ការពង្រីកការធ្វើសវនកម្មអោយបានទូលំទូលាយ (ឃ). ការរៀបចំយន្តការដើម្បីពង្រឹងតម្លាភាព និង គណនេយ្យភាព រួមទាំងការបង្កើតនូវការិយាល័យដោះស្រាយវិវាទផងដែរ ។

### ៧.៣.៤ គំនិតផ្តួចផ្តើមផ្តល់លាភការដោយផ្អែកលើសមត្ថភាពការងារ (MBPI)

កម្មវិធីកំណែទម្រង់ផ្នែកនេះ គឺជាកម្មវិធីប្រកបដោយតក្កកម្ម និង មានលក្ខណៈចាំបាច់ដើម្បីជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តសាកល្បងនូវកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ រាជរដ្ឋាភិបាលកម្ពុជា និង ដៃគូរអភិវឌ្ឍន៍ទទួលស្គាល់ថាការដោះស្រាយបញ្ហាប្រាក់បៀវត្ស និង លាភការដល់មន្ត្រីរាជការ គឺជាបញ្ហាសំខាន់ និង ជាលក្ខខណ្ឌចាំបាច់សម្រាប់ការងារកំណែទំរង់ និង ការកសាងសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង ។ នាពេលបច្ចុប្បន្ន ការគ្រប់គ្រងមន្ត្រីរាជការនៅជួបនឹងបញ្ហាប្រាក់បៀវត្សនៅទាប ដែលធ្វើអោយប៉ះពាល់ដល់សមត្ថភាពការងាររបស់មន្ត្រីរាជការ និង ធ្វើអោយការគ្រប់គ្រងនៅធូររលុង ដោយសារបញ្ហាអវត្តមានញឹកញាប់ មកមិនទាន់ពេល គ្មានការលើកទឹកចិត្ត និង គ្មានឆន្ទៈក្នុងការបំពេញការងារ ។

ការខិតខំធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមុនៗធ្លាប់ជួបនឹងបញ្ហាលំបាក ជាពិសេសការកសាងសមត្ថភាពស្ថាប័នមិនសូវបានទទួលជោគជ័យ ដោយសារតែគ្មានយន្តការដោះស្រាយបញ្ហាប្រាក់បៀវត្ស ។ ដូច្នេះ **គំនិតផ្តួចផ្តើមផ្តល់លាភការដោយផ្អែកលើសមត្ថភាពការងារ (MBPI)** មានគោលដៅដាក់អោយអនុវត្តសាកល្បង ក្នុងការធ្វើកំណែទម្រង់ប្រាក់បៀវត្សមន្ត្រីរាជការនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំណុចសំខាន់របស់ **MBPI** គឺ៖ ដៃគូអភិវឌ្ឍន៍ផ្តល់មូលនិធិដើម្បីបើកផ្តល់ប្រាក់បៀវត្សបន្ថែមដល់មន្ត្រីរាជការ ដោយ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រាជរដ្ឋាភិបាលផ្តល់ជាមូលនិធិបដិភាគ ដើម្បីបើកផ្តល់ប្រាក់បៀវត្សអោយបានគ្រប់គ្រាន់ដល់មន្ត្រីរាជការជាន់ខ្ពស់ មន្ត្រីគ្រប់គ្រង និង មន្ត្រីជំនាញ ដោយឈរលើមូលដ្ឋានសមត្ថភាពជាក់ស្តែង និង សមិទ្ធកម្មរបស់គេដែលសម្រេចបាន។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចាត់វិធានការចាំបាច់ ដើម្បីរៀបចំការវិភាគមុខងារ ក្នុងគោលដៅរៀបចំនូវរចនាសម្ព័ន្ធតាមនាយកដ្ឋានអោយបានសមស្រប ដោយមានមន្ត្រីជំនាញគ្រប់គ្រាន់ អនុវត្តនូវវិធានការគ្រប់គ្រងធនធានមនុស្សអោយបានហ្មឹងម៉ាត់ ។

## ៧.៣.៥ ពង្រឹងសមត្ថភាពត្រួតពិនិត្យថវិការបស់សភាជាតិ

កម្មវិធីកំណែទម្រង់ផ្នែកនេះមានគោលដៅជួយដល់គណៈកម្មាធិការហិរញ្ញវត្ថុ និង ធនាគារនៃរដ្ឋសភា ដើម្បីពង្រឹងសមត្ថភាព និង បង្កើនការយល់ដឹងក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ និង ច្បាប់ទូទាត់ ដើម្បីឱ្យរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវនៅបទដ្ឋានគណនេយ្យភាពក្នុងកម្រិតខ្ពស់ ។ កម្មវិធីកំណែទម្រង់នេះនឹងជួយដល់គណៈកម្មការហិរញ្ញវត្ថុ និង ធនាគាររបស់រដ្ឋសភា ក្នុងការវិភាគ និង ត្រួតពិនិត្យការអនុវត្តច្បាប់ថវិកា ដើម្បីអោយគណៈកម្មការអាចដើរតួនាទីដ៏សំខាន់ ក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងដំណើរការអនុវត្តថវិកា និង ប្រើប្រាស់នូវធនធានសាធារណៈ ។ នៅក្នុងន័យនេះ កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានបង្កើតឡើង ជាពិសេសដោយផ្តោតលើកម្មវិធីពង្រឹងសមត្ថភាព ដូចជា ការរៀបចំសន្និសិទ ឬ សិក្ខាសាលាថ្នាក់ជាតិ ឬ ថ្នាក់តំបន់ ការធ្វើទស្សនកិច្ចសិក្សានៅបរទេស លើប្រធានបទដូចតទៅ៖ តួនាទីរបស់រដ្ឋសភា និង ថវិកា ការត្រួតពិនិត្យ និង ការគ្រប់គ្រងការអនុវត្តថវិកា ការវាយតម្លៃផលប៉ះពាល់នៃចំណាយសាធារណៈ ការធានាតម្លាភាព និង ការរៀបចំថវិកា ដោយមានការចូលរួមពីគ្រប់តួអង្គទាំងអស់ ។

## ៧.៣.៦ ការគ្រប់គ្រងដំណើរការផ្លាស់ប្តូរ

កម្មវិធីកំណែទម្រង់ផ្នែកនេះមានគោលដៅ ផ្តល់ការគាំទ្រ ការផ្សព្វផ្សាយ និងការពារដើម្បីបង្កើតលក្ខខណ្ឌអនុគ្រោះដល់ការអនុវត្តប្រកបដោយជោគជ័យ នូវគម្រោងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះដោយរួមទាំងសកម្មភាពពិគ្រោះយោបល់ជាមួយនឹងតួអង្គសំខាន់ៗនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង- ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ។ កម្មវិធីនេះមានគោលដៅពង្រឹងការកសាងសមត្ថភាពស្ថាប័នក្នុងការរៀបចំ និង អនុវត្តប្រកបដោយតម្លាភាពនូវដំណើរការគ្រប់គ្រងការផ្លាស់ប្តូរ ដោយមានការចូលរួម និង អនុវត្តនូវយុទ្ធសាស្រ្តទំនាក់ទំនង តាមគ្រប់ជាន់ថ្នាក់ ។ ការគ្រប់គ្រងដំណើរកាផ្លាស់ប្តូរ គឺជាកត្តាយ៉ាងសំខាន់ ដើម្បីធានាអោយគម្រោងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុវត្តទៅបានទទួលជោគជ័យ ដោយសារតែមានបញ្ហាប្រឈមមួយចំនួន ពាក់ព័ន្ធនឹងការដាក់អោយអនុវត្តនូវបរិបទថវិកា និង នីតិវិធីថវិកាថ្មី ការដាក់អោយអនុវត្តនូវ**គម្រោងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** ដែលទាមទារអោយមានការផ្លាស់ប្តូរជាច្រើន នៅក្នុងរចនាសម្ព័ន្ធរបស់នាយកដ្ឋានសំខាន់ៗ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៧.៣.៧ ការកសាងសមត្ថភាពស្ថាប័ន

ការកសាងសមត្ថភាពស្ថាប័ន និង សមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការ ដែលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន ដើម្បីធានាអោយបាននូវការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈអោយបានជោគជ័យ ជាពិសេស ដើម្បីគាំទ្រខាងផ្នែកបច្ចេកទេស ដល់ការអនុវត្តនូវផែនការសកម្មភាព និង សម្រេចអោយបានតាមគោលដៅនៃដំណាក់កាលនីមួយៗនៃការងារកំណែទម្រង់ ។ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាអង្គភាពប្រមូលផ្តុំ ដើម្បីសម្របសម្រួលកិច្ចការកសាងសមត្ថភាពស្ថាប័នជាមួយនឹងគ្រប់នាយកដ្ឋានពាក់ព័ន្ធទាំងអស់របស់ក្រសួង ។ កម្មវិធីកសាងសមត្ថភាពស្ថាប័នរួមមាន ការរៀបចំធ្វើសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មន្ត្រីនៃក្រសួង- ស្ថាប័នពាក់ព័ន្ធ ការបណ្តុះបណ្តាលមន្ត្រីរយៈពេលខ្លី និង ការធ្វើកម្មសិក្សានៅបរទេស ការផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិត និង ថ្នាក់បណ្ឌិតដើម្បីទៅសិក្សានៅបរទេស ។

## ៧.៤. ថវិកាតាមកម្មវិធី

ផ្នែកនេះនឹងធ្វើការពន្យល់ពីគោលបំណង និង អត្ថប្រយោជន៍នៃការរៀបចំថវិកាតាមកម្មវិធី សារៈសំខាន់នៃការពង្រឹងទំនាក់ទំនងរវាងគោលនយោបាយនិងថវិកា ។

### ៧.៤.១. និយមន័យនៃកម្មវិធី

កម្មវិធីគឺជាចង្កោមនៃអនុកម្មវិធី និងសកម្មភាពការងារដែលមានគោលដៅច្បាស់លាស់ ហើយដែលនឹងបង្កើតឡើងយ៉ាងហោចណាស់នូវលទ្ធផលមួយ និង ទិន្នផលមួយចំនួន ។ សូចនាករអនុវត្តបានផ្តល់នូវយន្តការតាមដានមួយ ដើម្បីវាស់វែង និងធ្វើរបាយការណ៍ពីលទ្ធផល និងទិន្នផលរបស់កម្មវិធី និងអនុកម្មវិធី ។ ថ្លៃចំណាយទាំងមូលធន និងចរន្តរបស់សកម្មភាពការងារត្រូវរួមបញ្ចូលទៅក្នុងថវិកាតាមកម្មវិធី ដើម្បីធ្វើអោយថវិកាតាមកម្មវិធីគឺជាថវិកាដែលបានធ្វើសមាហរណកម្ម (Integrated Budget)។

### ៧.៤.២. ទំនាក់ទំនងរវាងគោលនយោបាយ និងថវិកា

ទំនាក់ទំនងដ៏ល្អរវាងគោលនយោបាយ និងថវិកាតម្រូវអោយមាននូវដំណើរការធ្វើគោលនយោបាយ និងដំណើរការថវិកា ពីព្រោះថវិកាគឺជាឧបករណ៍នៃគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ហើយវាមានទំនាក់ទំនងទៅនឹងកម្រិតនៃចំណាយសម្រាប់សកម្មភាពការងារផ្សេងៗគ្នា ។ ដំណើរការថវិការួមបញ្ចូលទាំងការពិនិត្យទៅលើគោលនយោបាយដែលបានដាក់ចេញ ហើយគឺជាឧបករណ៍ដ៏សំខាន់ ដើម្បីជួយអោយគោលនយោបាយទាំងនោះអាចអនុវត្តបាន ។ ចំណុចខ្លាំងនៃទំនាក់ទំនងរវាងគោលនយោបាយ និងថវិកាមានសារៈសំខាន់ចំពោះ យុទ្ធសាស្ត្រ ក្នុងការអនុវត្តគោលនយោបាយជាតិ ក៏ដូចជាគោលនយោបាយតាមវិស័យនានាផងដែរ ។

### ៧.៤.៣. ផលប្រយោជន៍ការអនុវត្តថវិកាតាមកម្មវិធី

ថវិកាតាមកម្មវិធីនឹងជួយពង្រឹងដល់ទំនាក់ទំនងរវាងថវិកា និង គោលនយោបាយ ។ ការភ្ជាប់ទំនាក់ទំនងពីថវិកាទៅគោលដៅគោលនយោបាយ តាមរយៈកម្មវិធីនឹងជួយអោយយើង ផ្តោតការយកចិត្តទុកដាក់ទៅលើមូលហេតុនៃចំណាយ ហើយនិងធ្វើអោយអ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះលទ្ធផលដែលសម្រេចបាន ។

ថវិកាតាមកម្មវិធីផ្តល់នូវមធ្យោបាយមួយដើម្បីធ្វើការវិភាជន៍ធនធានឡើងវិញ ពីគោលដៅគោល-នយោបាយចាស់ ទៅគោលដៅគោលនយោបាយថ្មី ។ ទស្សនទាននេះមានលក្ខណៈសាមញ្ញបំផុត ពោលគឺការកំណត់ពីលទ្ធផល និងទិន្នផលគន្លឹះ ដើម្បីសម្រេចបានគោលដៅគោលនយោបាយ ហើយនិងការកំណត់ពីសកម្មភាពការងារដែលត្រូវអនុវត្តដើម្បីបង្កើតឡើងនូវទិន្នផល ដើម្បីទទួលបានលទ្ធផលដែលមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃថ្លៃចំណាយ ។ ដោយការវាយតម្លៃកម្មវិធីជាប្រចាំ ធនធានអាចត្រូវបានវិភាជឡើងវិញជាថ្មី នៅក្នុងឬរវាងកម្មវិធីនានា ដោយឈរលើមូលដ្ឋាននៃលទ្ធផល (លទ្ធផល និង ទិន្នផល) ។

| តារាង ១៧.៣ អន្តរក្រមការរៀបចំថវិកា និង លទ្ធផល | | |
|---|---|---|
| **កម្មវត្ថុ** | **ដំណើរការ** | **ធាតុចេញ** |
| ដំណាក់ការធ្វើផែនការយុទ្ធសាស្ត្រ | ត្រួតពិនិត្យឡើងវិញពីការអនុវត្តរបស់ក្រសួង ។ កំណត់ពីគោលដៅ ដែលត្រូវសម្រេចអោយបាន និង មធ្យោបាយដើម្បីសម្រេចបានគោលដៅនោះ ដោយរួមទាំងលទ្ធផលរំពឹងទុក និងធនធានចរន្ត និងមូលធនដែលត្រូវប្រើប្រាស់ ហើយនឹងចំណូលដែលត្រូវប្រមូលសំរាប់ឆ្នាំថវិកាបន្ទាប់ និង ពីរឆ្នាំផ្សេងទៀត ។ | ផែនការយុទ្ធសាស្ត្រថវិកា |
| ដំណាក់ការប៉ាន់ស្មានថវិកា | រៀបចំការប៉ាន់ស្មានថវិកាលម្អិត | ថវិកាតាមកម្មវិធី និង ថវិកាមិនមែនកម្មវិធី |
| ដំណាក់ការបញ្ចប់ និង ការអនុម័តថវិកា | ការសម្រេចជាចុងក្រោយ ចំពោះថវិកាបន្ទាប់ពីបានធ្វើការវិភាគជាយុទ្ធសាស្ត្រក្នុងកំឡុងពេលនៃដំណើរការរៀបចំថវិកា និងអនុម័តថវិកាប្រចាំឆ្នាំ | ច្បាប់ថវិកាប្រចាំឆ្នាំ |

ការធ្វើថវិកាតាមបន្ទាត់ថវិកាមិនអាចអោយយើងសម្រេចបានគោលបំណងខាងលើនេះទេ ពីព្រោះការអនុវត្តថវិកាតាមបន្ទាត់ថវិកា យើងគ្រាន់តែអាចធ្វើការកត់ត្រាថាតើសាច់ប្រាក់បានចំណាយទៅលើអ្វីតែប៉ុណ្ណោះ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វាមិនបានភ្ជាប់ការចំណាយលើធាតុចូលទៅនឹងទិន្នផល និងលទ្ធផលដែលត្រូវសំរេចបានគោលដៅគោលនយោបាយឡើយ ។ ជាលទ្ធផល ការអនុវត្តថវិកាតាមបន្ទាត់ថវិកាបានលើកទឹកចិត្តអោយកើតមានឡើងនូវអភិក្រមសំរាប់ការផ្តល់មូលនិធិទៅអនាគត ដែលពឹងផ្អែកតែទៅលើការចំណាយកន្លងមក ដោយមិនបានធ្វើការពិនិត្យទៅលើលទ្ធផលនៃការចំណាយកន្លងមកនោះទេ ។

ការធ្វើថវិកាតាមកម្មវិធីផ្តល់នូវវិធីដ៏ប្រសើរមួយ ដើម្បីពិចារណាទៅលើអ្វីដែលយើងត្រូវផ្តល់មូលនិធិ កម្រិតនៃមូលនិធិ ហើយនិងការប៉ះពាល់ទៅលើគោលនយោបាយ (Policy Impact) ។ ថវិកាតាមកម្មវិធីបានរំលេច អោយឃើញពីការផ្លាស់ប្តូរជាជុំកំភួនទៅលើថវិកាតាមជំពូក នៅក្នុងការរៀបចំថវិកា ការអនុម័តថវិកា ការតាមដាន និងការធ្វើរបាយការណ៍ ។

ការអនុវត្តថវិកាតាមកម្មវិធីនឹងបង្កើតឡើងនូវមូលដ្ឋានគ្រឹះ ក្នុងការកែលម្អ ÷

- ផែនការថវិកា តាមរយៈការភ្ជាប់ទំនាក់ទំនងរវាងថវិកា និង គោលដៅគោលនយោបាយ
- ការអនុវត្តថវិកា ដោយបង្កើតអោយមានបន្ទាត់គណនេយ្យភាព
- ការតាមដាន និងការធ្វើរបាយការណ៍ថវិកា ដោយភ្ជាប់ការអនុវត្តកម្មវិធីទៅនឹងរបាយការណ៍អនុវត្តជាក់ស្តែង ហើយនិងលទ្ធផលរំពឹងទុក ។

**រូប ១៧.១ អភិក្រមនៃការរៀបចំថវិកាតាមកម្មវិធី**






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៧.៤.៤. ដំណាក់កាលនៃការរៀបចំថវិកាតាមកម្មវិធី

#### ក. ការបង្កើតកម្មវិធី

ផ្តល់ការណែនាំពីវិធីសាស្ត្រក្នុងការបង្កើតរចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី និង ផ្តល់ការណែនាំពីរបៀបកំណត់ និងឯកភាពទៅលើគោលដៅ លទ្ធផល ទិន្នផល និង សកម្មភាពការងារ ។

#### ខ. ការកំណត់ថ្លៃសម្រាប់កម្មវិធី

ផ្តល់ការណែនាំពីវិធីសាស្ត្រក្នុងការកំណត់ថ្លៃសម្រាប់ធាតុចូលនៃកម្មវិធី និងផ្តល់បញ្ជីសំណួរ ដើម្បីវាយតំលៃថា តើការកំណត់ថ្លៃសម្រាប់កម្មវិធីមានភាពសមស្របដែរឬទេ ។

#### គ. ជ្រើសរើសសូចនាករអនុវត្តសម្រាប់កម្មវិធី

ផ្តល់ការណែនាំពីប្រភេទនៃសូចនាករអនុវត្តដែលត្រូវជ្រើសរើសដើម្បីតាមដានវឌ្ឍនភាព និងសមិទ្ធផលនៃកម្មវិធី និងផ្តល់បញ្ជីសំណួរ ដើម្បីវាយតម្លៃថាតើសូចនាករដែលជ្រើសរើសមានភាពសមស្របដែរឬទេ ។

#### ឃ. ការតាមដាន និងការធ្វើរបាយការណ៍ពីកម្មវិធី

ផ្តល់ការណែនាំពីការតាមដាន និងធ្វើរបាយការណលើការអនុវត្តកម្មវិធី ហើយនិងការការកំណត់អោយបានជាក់លាក់ពីតម្រូវការសំរាប់ធ្វើរបាយការណ៍ ស្តីពីកម្មវិធីជូនដល់នាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងទម្រង់នៃរបាយការណ៍ ។

### ៧.៤.៥. ការតភ្ជាប់កម្មវិធីជាមួយ និង វិស័យយុទ្ធសាស្ត្រនីមួយៗ

ការរៀបចំបង្កើតឡើងនូវកម្មវិធី គឺចាប់ផ្តើមជាមួយការកំណត់គោលដៅនៃកម្មវិធីស្នើសុំ ហើយនេះត្រូវមានការយល់ដឹង និង ចំណេះវិជ្ជាខ្ពស់លើ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ២០០៦-២០១០ (NSDP) ហើយឯកសានេះបង្ហាញនូវទិសដៅ គោលបំណង វិស័យគោលនយោបាយ និង កម្មវត្ថុនៃសកម្មភាពគាំទ្ររបស់ក្រសួងនីមួយៗ ។ NSDP ក៏បានផ្តល់នូវគម្រោងសម្រាប់របាយការណ៍ប្រចាំឆ្នាំ និង ដាក់កំណត់ជាអាទិភាពនៃគោលនយោបាយ ក្នុងដំណាក់កាលគម្រោង យុទ្ធសាស្ត្រសម្រាប់ការរៀបចំថវិកា ដូចដែលបានបញ្ជាក់នៅក្នុង **ផែនការយុទ្ធសាស្ត្រថវិកា** (BSP) ដោយបានរៀបចំឡើងដោយក្រសួងនីមួយៗ ហើយអភិក្រមនេះ គឺបានបង្ហាញក្នុងរូប ១៧.១ ។

ម៉ូដែលរបស់កម្ពុជាសម្រាប់ផែនការជាយុទ្ធសាស្ត្របានសង្កត់ធ្ងន់ទៅលើលទ្ធផល ដែលក្រសួងនានាបាន

អនុវត្តកម្មវិធី និង អនុកម្មវិធី ។ **ផែនការយុទ្ធសាស្ត្រថវិកា** ត្រូវបានបង្កើតឡើងដើម្បីកំណត់ពីទិសដៅជាយុទ្ធសាស្ត្រ កំណត់ពីបញ្ហាជាយុទ្ធសាស្ត្រនានា កំណត់ពីលទ្ធផលរំពឹងទុក ជួយសម្រួលដល់ការវិភាជធនធាន ជួយដល់ការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការតាមដានការអនុវត្ត និងផ្តល់នូវក្របខណ្ឌ និងគាំទ្រដល់សំណើសុំថវិការបស់ក្រសួង ។

នាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានដាក់ចេញគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ហើយគោលការណ៍ណែនាំនេះនឹងត្រូវធ្វើបច្ចុប្បន្នភាព និងចេញផ្សាយរួមគ្នាជាមួយសារាចរថវិកា ដែលបានកំណត់នៅក្នុងដំណាក់កាលធ្វើផែនការជាយុទ្ធសាស្ត្រនៃការរៀបចំថវិកា ។

**ផែនការយុទ្ធសាស្ត្រថវិកា**របស់ក្រសួងនីមួយៗបានភ្ជាប់ការរៀបចំថវិកា ទៅនឹងគោលនយោបាយតាមវិស័យ ដែលផែនការយុទ្ធសាស្ត្រថវិកានេះនឹងផ្តល់នូវមូលដ្ឋានដើម្បីបង្កើតកម្មវិធីអោយបានសមស្រប ពីព្រោះកម្មវិធីនីមួយៗបានកើតមកពីក្របខណ្ឌគោលនយោបាយតាមវិស័យរបស់ក្រសួងនានា ។ លើសពីនេះទៅទៀត កម្មវិធីនីមួយៗមាននូវគោលដៅច្បាស់លាស់មួយ។ រូបភាពខាងលើបង្ហាញអោយឃើញពីដំណើរការនេះ ។

NSDPគឺជាឯកសារផែនការដែលមានកម្រិតខ្ពស់បំផុត ហើយគោលនយោបាយជាអាទិភាព បានបង្កើតអោយមានការរៀបចំថវិកាប្រចាំឆ្នាំ ។ គោលនយោបាយជាអាទិភាពនៃ NSDP គឺចែកចេញជា ថវិកាតាមក្រសួង និង ថវិកាតាមវិស័យដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។

**ផែនការយុទ្ធសាស្ត្រថវិកា**គឺជាយន្តការសម្រាប់ភ្ជាប់ទំនាក់ទំនងរវាង NSDP ដែលបានកំណត់ពីបណ្តាវិស័យជាអាទិភាពនៃសេវាសាធារណៈ ហើយបញ្ជាក់យ៉ាងច្បាស់ពីទិន្នផល និង សមិទ្ធផលដែលជាទិសដៅ ព្រមទាំងថវិកាប្រចាំឆ្នាំ ដែលផ្តល់នូវធនធានដែលមាន ដើម្បីអនុវត្តសកម្មភាពការងារ ដើម្បីសម្រេចបានទិសដៅនៃ NSDP ។

**ផែនការយុទ្ធសាស្ត្រថវិកា**នឹងផ្តល់នូវមូលដ្ឋានសម្រាប់បង្កើតកម្មវិធីរបស់ក្រសួងនានា ដែលធ្វើការគាំទ្រ ដល់គោលនយោបាយតាមវិស័យជាក់លាក់ណាមួយ ។ កម្មវិធីដែលសម្រាប់បម្រើអោយគោលនយោបាយ គឺមានត្រូវលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់កម្ពុជា ហើយក៏ត្រូវមានគោលដៅនៃកម្មវិធី ដែលផ្តល់នូវយុត្តិកម្មសម្រាប់កម្មវិធីនោះផងដែរ ។ ដូចគ្នានេះដែរ គោលដៅអនុកម្មវិធីត្រូវកំណត់នៅក្នុងគោលដៅកម្មវិធី ហើយផ្តល់នូវយុត្តិកម្ម សម្រាប់អនុកម្មវិធីនោះ ។

ដំណើរការចុងក្រោយក្នុងការធ្វើផែនការយុទ្ធសាស្ត្រថវិកាគឺការសំរេចចិត្តថាតើត្រូវរក្សាទុក លុបចោល ឬក៏កែសម្រួលចំពោះកម្មវិធី ឬ អនុកម្មវិធី ដោយផ្អែកទៅលើការវាយតម្លៃរបស់ក្រសួងផ្ទាល់ ។ ការធ្វើដូច្នេះអាចជួយដល់រចនាសម្ព័ន្ធថវិកា និង ការវិភាជថវិកា ដែលទាក់ទិនទៅនឹងគោលដៅគោលនយោបាយ ហើយវាបានផ្តល់នូវមូលដ្ឋានសំរាប់ប្រព័ន្ធថវិកា និង ហិរញ្ញវត្ថុ ដែលភ្ជាប់គោលដៅគោលនយោបាយរបស់កម្មវិធី ហើយនិង

សមិទ្ធិផលជាមួយ នឹងការធ្វើផែនការ និងគណនេយ្យភាព ។

### ៧.៤.៦. ការបង្កើតរចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី

នៅពេលដែលផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំរួចរាល់ហើយ ជំហានបន្ទាប់គឺត្រូវកំណត់ពីថវិកាសម្រាប់កម្មវិធី ។ តារាងខាងក្រោមនឹងផ្តល់ក្របខ័ណ្ឌ និង វិសាលភាពនៃការងារដែលត្រូវបំពេញ ។

តារាង ១៧.៤ នេះ អាចត្រូវបានប្រើប្រាស់ដើម្បីណែនាំដល់ការបង្កើតកម្មវិធី ដោយចាប់ផ្តើមជាមួយនឹងការកំណត់ពីរចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី ។

| តារាង ១៧.៤- កម្មវិធី- អនុកម្មវិធី និង សកម្មភាព | | |
|---|---|---|
| **មុខសញ្ញា** | **និយមន័យ** | **ការពន្យល់** |
| កម្មវិធី | ជាចង្កោមនៃអនុកម្មវិធី និង សកម្មភាពការងារ ដែលមានគោលដៅច្បាស់លាស់ | បង្កើតឡើងយ៉ាងហោចណាស់ លទ្ធផលមួយ និងទិន្នផលមួយចំនួន |
| អនុកម្មវិធី | ចង្កោមសកម្មភាពការងារ ដែលមានគោលដៅច្បាស់លាស់ នៅក្នុងគោលដៅកម្មវិធី | បង្កើតឡើងយ៉ាងហោចណាស់ ទិន្នផលមួយ និង លទ្ធផលមួយ |
| សកម្មភាពការងារ | ចង្កោមសកម្មភាពដែលមានគោលដៅច្បាស់លាស់នៅក្នុងអនុកម្មវិធី | ត្រូវបង្កើតទិន្នផលមួយ |

ថវិកាតាមកម្មវិធីគឺជាដំណើរការដែលត្រូវបន្ត ។ មានសមាសធាតុ ៧ ដែលត្រូវរំលេចអោយឃើញនៅក្នុងរចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី ÷

- រចនាសម្ព័ន្ធកម្មវិធីត្រូវរំលេចអោយឃើញពីបេសកកម្មរបស់ក្រសួង ។ ក្រសួងគឺ ជានិតិបុគ្គល ដែលមានសិទ្ធិអំណាចកំណត់ដោយច្បាប់ដើម្បីសម្រេចនូវបេសកកម្ម ដែលជាកាតព្វកិច្ចដែលត្រូវសម្រេចអោយខាងតែបាន។
- រចនាសម្ព័ន្ធកម្មវិធីត្រូវរំលេចអោយឃើញពីគោលដៅគោលនយោបាយរបស់ក្រសួង ។ រចនាសម្ព័ន្ធកម្មវិធីក៏ត្រូវរំលេចអោយឃើញផងដែរពីគោលនយោបាយថ្មី ដើម្បីធានានូវភាពស្របគ្នារវាងផែនការ (NSDP/BSP) ហើយនឹងថវិកាសម្រាប់បណ្តាឆ្នាំខាងមុខ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- វចនាសម្ព័ន្ធកម្មវិធីត្រូវបង្កើតឡើងស្របទៅតាមស្ថានភាពជាក់ស្តែងរបស់ក្រសួងនីមួយៗ ពោលគឺកម្មវិធីត្រូវរៀបចំសម្រាប់តែក្រសួងណាមួយដោយឡែកតែប៉ុណ្ណោះ ដើម្បីធានាបាននូវគណនេយ្យភាព ។ នៅពេលដែលកម្មវិធីណាមួយត្រូវអនុវត្តដោយក្រសួងលើសពីមួយ ការទទួលខុសត្រូវធ្វើការចែករំលែករវាងក្រសួងទាំងនោះដែរ ហើយការធ្វើដូចនេះអាចអោយយើងមានការពិបាកក្នុងការកំណត់ពីលទ្ធផល ទិន្នផល និងសកម្មភាពការងាររបស់ក្រសួងនីមួយៗ ហើយការកំណត់ថ្លៃសំរាប់កម្មវិធីនោះក៏មានភាពស្មុគ្រស្មាញដែរ។

- ក្រសួងនីមួយៗត្រូវកំណត់អោយមានត្រឹមតែ ៥ កម្មវិធីប៉ុណ្ណោះ ។ ការកំណត់ចំនួនកម្មវិធីបានបង្កភាពងាយយល់ពីអ្វីដែលក្រសួងនីមួយៗព្យាយាមសំរេចអោយបាន ។

- កម្មវិធីមួយអាចមានសមាសភាគផ្សេងៗគ្នាមួយចំនួន ដែលធ្វើអោយយើងមានការពិបាកដើម្បីដាក់ចេញនូវវិធានការសំរាប់អនុវត្តវិធានការទាំងមូល ។ នៅក្នុងករណីនេះ កម្មវិធីត្រូវបំបែកជាអនុកម្មវិធីមួយចំនួន ។ នៅពេលដែលកម្មវិធីមួយ ឬ ច្រើនជាផ្នែកមួយនៃកម្មវិធីដ៏ធំមួយ កម្មវិធីទាំងនោះត្រូវបានចាត់ទុកថាជាអនុកម្មវិធីដើម្បីកំណត់ថវិកាសម្រាប់អនុវត្តដោយផ្អែកលើលទ្ធផល ។ ចំនួននៃអនុកម្មវិធីមិនមានចំនួនកំណត់ទេ ។

- ប៉ុន្តែ ចំពោះការងារមួយចំនួនដែលស្ថិតនៅក្រោមកម្រិតអនុកម្មវិធី គឺមានលក្ខណៈលម្អិតពេក ។ ដូច្នេះឋានានុក្រមនៃកម្មវិធីគឺត្រូវកំណត់ត្រឹមតែពីរថ្នាក់ប៉ុណ្ណោះគឺ កម្រិតកម្មវិធី និង កម្រិតអនុកម្មវិធី ។ ការកំណត់កម្រិតនេះគឺដោយសារ កម្រិតនៃការងារលំអិតដែលចាំបាច់សម្រាប់ក្រសួងក្នុងការអនុវត្តនៅផ្ទៃក្នុងក្រសួងមិនមានលក្ខណៈចាំបាច់សំរាប់អនុវត្តការងារនៅក្រៅក្រសួងឡើយ ។ ការងារដែលមានលក្ខណៈលម្អិតពេកដែលមិនស្របគ្នាទៅនឹងវចនាសម្ព័ន្ធកម្មវិធី អាចបង្កអោយការអនុវត្តកម្មវិធីមានភាពមិនច្បាស់លាស់ ។ អ្នកដែលធ្វើសេចក្តីសំរេចចិត្តមានព័ត៌មានជាច្រើន ប៉ុន្តែមានពេលវេលាតិចតួចដើម្បីស្វែងយល់ពីការអនុវត្តរបស់រាជរដ្ឋាភិបាល ហើយថាតើក្រសួងអាចសំរេចបាននូវបេសកកម្មរបស់ខ្លួនដែរឬទេ ។ ដូច្នេះហើយ បានជាគ្មានអនុនៃអនុកម្មវិធីនៅក្នុងឋានានុក្រមនៃកម្មវិធី ។

- ចំពោះឈ្មោះនៃកម្មវិធីនិងអនុកម្មវិធី ត្រូវមានលក្ខណៈជាការពិព័ណ៌នា ពោលគឺមានន័យថា ឈ្មោះទាំងនេះអាចជួយអោយអ្នកអាន ដែលមិនសូវស្គាល់ក្រសួងណាមួយ យល់ដឹងពីបញ្ហាដែលកម្មវិធីត្រូវរំលេចអោយឃើញ ។ គោលបំណងគឺដើម្បីបង្ហាញថា កម្មវិធី និង អនុកម្មវិធីដែលបានស្នើឡើង ត្រូវឆ្លើយតបទៅនឹងបេសកកម្ម និងគោលនយោបាយ ។

## ៧.៥. គោលនយោបាយសារពើពន្ធ

**ពន្ធ** គឺជាបន្ទុកកាតព្វកិច្ច ចំណែកឯបន្ទុក និង កម្ម៉វិញ គឺជាប្រតិបត្តិការតាមការស្ម័គ្រចិត្ត ។ ដោយពន្ធត្រូវបានប្រើប្រាស់ក្នុងការធ្វើហិរញ្ញប្បទានទំនិញសាធារណៈ ផលប្រយោជន៍ដែលទទួលបានពីទំនិញ និងសេវាកម្ម ដែលបានហិរញ្ញប្បទានដោយពន្ធ នឹងផ្តល់ជូនដល់ប្រជាជនកម្ពុជាគ្រប់ៗរូប ។ ដូចបានរៀបរាប់ពីខាង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដើម រាជរដ្ឋាភិបាលអនុវត្តការបែងចែកចំណូលឡើងវិញ តាមរយៈពន្ធ ក៏ដូចជាគោលនយោបាយចំណាយ ។ ពន្ធ និង បន្ទុក ត្រូវបានប្រមូលយកពីវិស័យឯកជន ដោយគ្មានការទូទាត់សងវិញពីរដ្ឋាភិបាលឡើយចំពោះអ្នកបង់ពន្ធ ។ ឧប្បត្តិហេតុសេដ្ឋកិច្ចនៃពន្ធ គឺការផ្លាស់ប្តូរនៅក្នុងការបែងចែកចំណូលពិតឯកជនតាមរយៈពន្ធ ។ ប្រព័ន្ធពន្ធផ្លាស់ប្តូរនូវការបែងចែកចំណូល ក្នុងចំណោមម្ចាស់កម្មសិទ្ធិមូលធន ពលករ និង ម្ចាស់ដី ។ បញ្ហាចម្បងនៅក្នុងការវិភាគលើឧប្បត្តិហេតុរបស់ពន្ធ គឺស្ថិតនៅលើរបៀប ដែលពន្ធមានឥទ្ធិពលលើថ្លៃប្រៀបធៀប ។

ពន្ធក៏មានឥទ្ធិពលលើចំណូល និងនាំឱ្យមានបន្ទុកបន្ថែមដោយការផ្លាស់ប្តូរឥរិយាបថសេដ្ឋកិច្ច ហើយនាំសេដ្ឋកិច្ចឱ្យចាកចេញពី**ភាពប្រសើរបារ៉េតូ** (Pareto optimality) ។ ដោយសារពន្ធមានឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យសេដ្ឋកិច្ច ពន្ធបង្កើតនូវបន្ទុកបន្ថែម គឺ ការបាត់បង់នូវសុខមាលភាពខាងលើ ក្នុងកម្រិតដែលលើសពីទំហំនៃចំណូលពន្ធដែលត្រូវបានប្រមូលទៅទៀត ។ បន្ទុកបន្ថែមនេះ អាចហៅម៉្យាងទៀតថាជា តម្លៃនៃសុខមាលភាព ឬ ជាការបាត់បង់ក្នុងសេដ្ឋកិច្ច (Deadweight loss) ។ ពន្ធមានប្រសិទ្ធភាពនឹងកាត់បន្ថយដល់កម្រិតអប្បបរមានូវការបាត់បង់ប្រសិទ្ធភាព ដែលបង្កើតដោយបន្ទុកពន្ធបន្ថែម ក្នុងការប្រមូលចំណូលពន្ធ (Hillman, 2004)។ ដំណោះស្រាយនៃការប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព អាចហៅម៉្យាងទៀតថាជាវិធាន Ramsey គឺជាអ្នកប្រាជ្ញអង់គ្លេសម្នាក់ឈ្មោះ Frank Ramsey ដែលបង្កើតវិធាននេះឡើង នៅក្នុងឆ្នាំ ១៩២៧ ។ វិធាន Ramsey នេះចែងថា ***«ដើម្បីកាត់បន្ថយការបាត់បង់បន្ទុកបន្ថែមអោយដល់កម្រិតអប្បបរិមា អត្រាពន្ធត្រូវតែកំណត់យ៉ាងណា ដើម្បីឱ្យការកាត់បន្ថយនូវបរិមាណនៃទំនិញនីមួយៗដែលត្រូវការមានភាគរយដូចៗគ្នា»*** (Rosen, 2005) ។

រដ្ឋាភិបាលមានឧបករណ៍ជាច្រើននៅក្នុងដៃ ដែលអាចមានឥទ្ធិពលលើការបែងចែក និង បែងចែកឡើងវិញនៃចំណូល ។ ឧបករណ៍ដ៏សំខាន់មួយ គឺ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ **ពន្ធ** ។ អភិក្រមក្នុងការវាយតម្លៃផលប៉ះពាល់នៃការបែងចែកឡើងវិញនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ ការវិភាគនៃ **ឧប្បត្តិហេតុពន្ធ** (Tax incidence)។ គេធ្វើសេចក្តីសន្និដ្ឋានថា ពន្ធលើប្រាក់ចំណូល ជាធម្មតា ជា**ពន្ធកើនច្រើន** ពោលគឺ សមាមាត្រនៃប្រាក់ចំណូលសរុបដែលត្រូវបង់ជាពន្ធនឹងកើនឡើង នៅពេលដែលប្រាក់ចំណូលសរុបកើនឡើង ។ ចំណែកឯពន្ធលើការប្រើប្រាស់ ជាធម្មតាជា **ពន្ធថយចុះ** មានន័យថា សមមាត្រពន្ធនឹងធ្លាក់ចុះ នៅពេលដែលចំណូលសរុបកើនឡើង ។

### ៧.៥.១. វិធានការកៀរគរចំណូល

ចាប់តាំងពីឆ្នាំ ១៩៩៩ គោលនយោបាយ និង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានក្លាយទៅជាចំណុចក្តៅនៃកម្មវិធីកំណែទម្រង់ ។ យុទ្ធសាស្ត្រដ៏សំខាន់បំផុតនៃកម្មវិធីកំណែទម្រង់នេះគឺ ការបង្កើនចំណូល ដើម្បីបំពេញតម្រូវការចំណាយថវិកា ។ ជាលទ្ធផល ចំណូលថវិកាបានកើនឡើងពី ៨,៣% នៃ ផ.ស.ស នៅក្នុងឆ្នាំ ១៩៩៨


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដល់ ១១,៩% នៅឆ្នាំ ២០០៤ តាមការគ្រោងទុក ។ ចំណូលកើនឡើង ដោយសារកំណើននៃមូលដ្ឋានយកពន្ធ ។ នៅក្នុងឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលបានដាក់អោយអនុវត្តនូវអាករលើតម្លៃបន្ថែម ១០% ចំពោះសហគ្រាសនៃរបបពិត ជំនួសអាករលើផលរបរ និង ពន្ធលើការប្រើប្រាស់សម្រាប់ទំនិញនាំចូល ដែលរួមចំណែកជាវិជ្ជមានដល់ការកើនឡើងនៃចំណូលថវិកា ។ ទន្ទឹមនឹងនេះ អាករលើតម្លៃបន្ថែមបានពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធសារពើពន្ធ ដោយធ្វើឱ្យរចនាសម្ព័ន្ធពន្ធមានលក្ខណៈកាន់តែងាយស្រួល ពង្រីកដែនគ្របដណ្តប់របស់ពន្ធ និង ការកាត់បន្ថយនូវការយកពន្ធត្រួតគ្នា ។ ជាទូទៅ ការកែលម្អគោលនយោបាយសារពើពន្ធបានរួមចំណែកក្នុងការបង្កើននូវសមិទ្ធកម្មក្នុងការយកពន្ធ ។

វឌ្ឍនភាពនៅក្នុងការពង្រឹងរដ្ឋបាលគយ និង រដ្ឋបាលសារពើពន្ធ និង ការអនុវត្តនូវគោលនយោបាយគ្រប់គ្រងចំណូលពុំមែនសារពើពន្ធនៅមានកម្រិតនៅឡើយ ។ ការពង្រឹងរដ្ឋបាលគយ និង រដ្ឋាករបានផ្តោតជាសំខាន់លើការអនុវត្តការត្រួតពិនិត្យទំនិញមុនពេលផ្ទុកឱ្យកាន់តែមានប្រសិទ្ធភាព និង ការបង្កើនតម្លាភាព ក្នុងការកាត់បន្ថយតម្លៃក្រៅផ្លូវការដែលពាក់ព័ន្ធនឹងនីតិវិធីគយ ។ ការប្រយុទ្ធប្រឆាំងនឹងអំពើរត់គេចពន្ធត្រូវបានពង្រឹងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន និង ការបង្កើតអង្គភាពប្រឆាំងនឹងអំពើរត់គេចពន្ធ នៅតាមបណ្តាខេត្តជាប់ព្រំដែនសំខាន់ៗ ។ នៅក្នុងផ្នែកគ្រប់គ្រងការប្រមូលពន្ធ រាជរដ្ឋាភិបាលបានបង្កើតអង្គភាពអ្នកបង់ពន្ធធុនធំ និង មធ្យម នៅក្នុងឆ្នាំ ២០០១ ហើយការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបង់ពន្ធតាមធនាគារ សម្រាប់អ្នកបង់ពន្ធធុនធំ និង មធ្យម ។ នាពេលថ្មីៗនេះ នាយកដ្ឋានពន្ធដារបានដាកដាក់ចេញនូវវិធានការមួយចំនួន ក្នុងការពង្រឹងការគ្រប់គ្រងការប្រមូលពន្ធ ដូចជា ការពង្រឹងសវនកម្ម ការពង្រឹងការគ្រប់គ្រងបំណុល ការអនុវត្តវិធានការតឹងទារបំណុលពន្ធ (ដូចជា ការរឹបអូសគណនីធនាគារ ឬ រតនាគាររបស់អ្នកបង់ពន្ធ ដែលប្រព្រឹត្តបទល្មើស ការផ្អាកដំណើរការនាំចេញ និង នាំចូល ការបដិសេធចំពោះសិទ្ធិអនុញ្ញាតនាំចូល ។ល។) និង ការធ្វើឱ្យប្រសើរឡើងនៃការចុះបញ្ជីអ្នកបង់ពន្ធ ។ ការអនុវត្តនូវវិធានការទាំងនេះបង្កើនឡើងនូវយន្តការនៃការប្រមូលបំណុលពន្ធ ជាលក្ខណៈប្រព័ន្ធ ។ ក៏ប៉ុន្តែបទពិសោធន៍នាពេលថ្មីៗនេះបានបង្ហាញ នូវភាពមានកម្រិតនៃសមត្ថភាពការគ្រប់គ្រងប្រមូលចំណូល ក្របខ័ណ្ឌច្បាប់ និង បទដ្ឋានគតិយុត្តិ និង ប្រភពធនធានមនុស្ស ដែលជាឧបសគ្គសម្រាប់ការប្រឹងប្រែង ក្នុងការពង្រឹងការប្រមូលចំណូលពន្ធ និង ចំណូលពុំមែនសារពើពន្ធ ។ បញ្ហាស្នូលនោះគឺ កង្វះខាតមន្ត្រីគយ និង ពន្ធដារដែលមានកម្រិតវិជ្ជាជីវៈខ្ពស់ និង ភាពទន់ខ្សោយនៃរចនាសម្ព័ន្ធលើកទឹកចិត្តនៅក្នុងប្រព័ន្ធប្រមូលពន្ធ ។

វិស័យចំនួន ៣ ត្រូវបានកំណត់ថាជាវិស័យអាទិភាព ដើម្បីអនុវត្តការកែទម្រង់ពន្ធដារ គឺ ១-អភិក្រមនៃការផ្លាស់ប្តូរ ២-គោលនយោបាយពន្ធ និង ៣-រដ្ឋបាលពន្ធ ។ យើងនឹងរៀបរាប់ដោយសង្ខេបដូចខាងក្រោមនូវសកម្មភាពនៃកំណែទម្រង់ទាំងអស់នេះ ។

**អភិក្រមនៃការផ្លាស់ប្តូរ** រួមមានការបង្កើតវិធីសាស្ត្រដោះស្រាយ ដែលមានទម្រង់ជាក់លាក់ និង មានតម្លាភាពសម្រាប់អភិក្រមនៃការផ្លាស់ប្តូរតាមរយៈការប្រើប្រាស់ក្របខ័ណ្ឌបច្ចេកវិទ្យាស្ថាប័ន និងការកំណត់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អត្តសញ្ញាណធាតុសំខាន់ៗ ការផ្តល់ការភ្ជាប់ធាតុសំខាន់ៗទាំងនោះឱ្យមានទំនាក់ទំនងគ្នាទៅវិញទៅមក ការបង្កើតចក្ខុវិស័យសម្រាប់នាយកដ្ឋាន និង ផ្សព្វផ្សាយចក្ខុវិស័យនេះឱ្យបានដឹងពួទាំងនៅខាងក្នុង និង ខាងក្រៅនាយកដ្ឋាន ការរៀបចំពិនិត្យឡើងវិញនូវតួនាទី និង ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារបច្ចុប្បន្ន និង ផ្តល់នូវការណែនាំ និង ជំនួយនៅក្នុងការអនុវត្តសកម្មភាពក្នុងការបង្កើតតួនាទី និង ភារកិច្ចដ៏ត្រឹមត្រូវជាក់លាក់សម្រាប់ទីស្នាក់កណ្តាល សាខាពន្ធដារតាមតំបន់ ខេត្ត និង ស្រុកនានា (តាមគំរូនៃការវិភាគមុខងារ) ។

**ការកែទម្រង់គោលនយោបាយពន្ធ** ទាក់ទិនទៅនឹងការកំណត់អត្តសញ្ញាណ និង ការកែតម្រូវភាពមិនប្រក្រតីនៅក្នុងច្បាប់ពន្ធស្តីពីសារពើពន្ធ និង ការចាប់ផ្តើមផ្លាស់ប្តូរ ឈរលើមូលដ្ឋាននៃតម្រូវការក្នុងការធ្វើទំនើបកម្មគោលនយោបាយពន្ធផ្សារភ្ជាប់ទៅនឹងទិសដៅណែនាំ និង គោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល ស្តីពីរបបពន្ធសារពើពន្ធ រួមមាន ពន្ធលើប្រាក់ចំណេញសម្រាប់របបម៉ៅការ ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម អាករលើផលរបរ អាករពិសេសលើទំនិញមួយចំនួន និង ការវិភាគគោលនយោបាយពន្ធ ។

**កំណែទម្រង់រដ្ឋបាលសារពើពន្ធ** : ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ទីស្នាក់កណ្តាលនៃនាយកដ្ឋានពន្ធដារ ការអនុវត្តរបបពិតនៅតាមទីស្នាក់តំបន់សំខាន់ៗចំនួន ៥ ការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានដ៏មុតមាំមួយ ដែលមានទិន្នន័យសមស្របដើម្បីបំពេញតាមតម្រូវការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទីស្នាក់ការកណ្តាលរបស់នាយកដ្ឋាន និង ទីស្នាក់ការស្រុក ការកសាងសៀវភៅនីតិវិធីប្រតិបត្តិសម្រាប់រដ្ឋបាលពន្ធសារពើពន្ធគ្រប់ជាន់ថ្នាក់ និង ការកំណត់បទដ្ឋានស្នាដៃតាមផ្នែក និង មន្ត្រីម្នាក់ៗ ។ ការបង្កើតអង្គភាពអ្នកបង់ពន្ធធុនធំ និង អង្គភាពអ្នកបង់ពន្ធធុនមធ្យមនៅក្នុងរាជធានីភ្នំពេញ ដើម្បីពង្រឹងកែលម្អការគ្រប់គ្រងអ្នកបង់ពន្ធធំបំផុត ការកសាងប្រព័ន្ធរបាយការណ៍ស្ថិតិប្រចាំខែ ការធានាបានថារបបពិតនឹងគ្របដណ្តប់គ្រប់អាជីវកម្មខ្នាតធំ និង មធ្យម ដោយបែងចែកអង្គភាពរបបពិតទៅតាមអង្គភាពអ្នកបង់ពន្ធធុនធំ និង អង្គភាពអ្នកបង់ពន្ធធុនមធ្យម ជាមួយនឹងសមាហរណកម្មការគ្រប់គ្រងពន្ធគ្រប់ប្រភេទ និង ស្របទៅតាមមុខងារនីមួយៗ ការអនុវត្តរបបពិត នៅតាមបណ្តាខេត្តដែលនៅសេសសល់នៅក្នុងរយៈពេលមធ្យម ការបង្កើតឯកសារសវនកម្ម និង នីតិវិធីពន្ធ និង ប្រព័ន្ធគ្រប់គ្រងព័ត៌មានទំនើបសម្រាប់ប្រតិបត្តិការសវនកម្ម ការកសាងយុទ្ធសាស្ត្រសវនកម្ម ដែលផ្តល់នូវការគ្របដណ្តប់លើអ្នកបង់ពន្ធ បានកាន់តែទូលំទូលាយ និង ការប្រើប្រាស់បច្ចេកទេសជ្រើសរើសថ្មី ឈរលើការវិភាគហានិភ័យ និង ការធានាបាននូវព័ត៌មានស្តីពីការនាំចូលរបស់អ្នកបង់ពន្ធបានចុះបញ្ជី ឬ ពុំទាន់បានចុះបញ្ជី ដែលទទួលបានពីទីចាត់ការគយ និង រដ្ឋាករ ។

ថ្នាក់ដឹកនាំនាយកដ្ឋានបានរៀបចំនូវសេចក្តីព្រាងនៃប្រកាស ស្តីពីរចនាសម្ព័ន្ធចាត់តាំងរបស់នាយកដ្ឋាន និង បានដាក់ចេញនូវអនុសាសន៍ថ្មីៗ បានពិភាក្សា និង ដាក់ចេញនូវយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន និង អនុសាសន៍ពាក់ព័ន្ធនឹងសេវាអ្នកបង់ពន្ធ ។ ដំណើរការផ្លាស់ប្តូរនៅក្នុងអង្គភាពអ្នកបង់ពន្ធធុនធំ និង អង្គភាពអ្នកបង់ពន្ធធុនមធ្យមនឹងត្រូវបន្តធ្វើឡើងទៀត ដោយយោងតាមមុខងារ និង ការទទួលខុសត្រូវរបស់អង្គភាព

ទាំងនេះ ។ ថ្នាក់ដឹកនាំនាយកដ្ឋានក៏បានពិនិត្យឡើងវិញផងដែរ នូវគោលនយោបាយស្តីពីរបបសារពើពន្ធ ច្បាប់ អនុក្រឹត្យ និង ប្រកាស ដើម្បីរកឱ្យឃើញនូវភាពមិនប្រក្រតីទាំងឡាយ និង ពិនិត្យឡើងវិញនូវច្បាប់ទាំងឡាយ ដែលបានអនុម័តដោយរដ្ឋសភា ។ នាយកដ្ឋានបានរៀបចំឡើងនូវរបបរិលស់យ៉ាងច្បាស់លាស់ អោយស្របទៅ តាមតម្រូវការរបស់អ្នកជាប់ពន្ធ និង ពិនិត្យឡើងវិញនូវវិធីសាស្រ្តយកពន្ធកាត់ទុកលើការបែងចែកភាគលាភ អោយមានសង្គតិភាពជាមួយនឹងច្បាប់ស្តីពីវិនិយោគ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគ ។ នាយកដ្ឋាន បានពិនិត្យឡើងវិញនូវកម្រិតកំណត់ពន្ធអប្បបរមា ហើយបានឯកភាពមិនឱ្យមានការផ្លាស់ប្តូរក្នុងពេលនេះ ។

### ៧.៥.២. របបសារពើពន្ធនៅកម្ពុជា

អ្នកជាប់ពន្ធទាំងឡាយត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ ថ្ងៃ ក្រោយ មានសកម្មភាពសេដ្ឋកិច្ច ។ ជាការអនុវត្ត អ្នកជាប់ពន្ធនៅព្រះរាជាណាចក្រកម្ពុជាមានពីរប្រភេទគឺ អ្នកជាប់ពន្ធ តាម **របបស្វ័យប្រកាស** និង អ្នកជាប់ពន្ធតាម **របបម៉ៅការ** ។

#### *ក. របបស្វ័យប្រកាស*

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស គឺជានីតិបុគ្គលទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា និង បុគ្គលទាំងឡាយ ដែលប្រកបធុរកិច្ចដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៥០០ លានរៀល ឡើងទៅសម្រាប់ការផ្គត់ផ្គង់ ទំនិញ ចាប់ពី ២៥០ លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា និងចាប់ពី ១២៥ លានរៀលឡើងទៅសម្រាប់ការ ធ្វើកិច្ចសន្យាជាមួយរដ្ឋ ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ ដោយខ្លួនឯង ។ ក្នុងអំឡុងពេលមួយមានកំណត់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសនឹងត្រូវបានទទួលការធ្វើសវនកម្ម ពីមន្ត្រីសវនកម្មពន្ធដារដើម្បីធានាភាពត្រឹមត្រូវនៃការប្រកាសរបស់ខ្លួន ។

នៅចុងឆ្នាំ ២០០៨ មានអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានចំនួន ១២.០៨៩ សហគ្រាស ក្នុងនោះមាន សហគ្រាសជាអ្នកជាប់ពន្ធធំចំនួន ១.១៧១ សហគ្រាសនៅទូទាំងប្រទេស និងអ្នកជាប់ពន្ធមធ្យមចំនួន ៩.១៤៤ សហគ្រាស នៅភ្នំពេញ ១.៧៧៤ នៅតាមខេត្ត-ក្រុងទាំង ២៤ ។ ចំណូលដែលទទួលបានពីអ្នកជាប់ពន្ធទាំងនេះមាន ចំនួនប្រមាណ ៨៥% នៃចំណូលពន្ធដារសរុបដែលនាយកដ្ឋានពន្ធដារប្រមូលបាន ។

#### *ខ. របបម៉ៅការ*

អ្នកជាប់ពន្ធតាមរបបម៉ៅការ គឺជាអ្នកជាប់ពន្ធតូចៗ ដែលស្ថិតក្រោមកម្រិតអប្បបរមា ដែលត្រូវចុះបញ្ជីជាអ្នក ជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវបានកំណត់ឱ្យបង់ប្រាក់ពន្ធជាស្ថេរវត្ត ក្នុងរយៈពេលកំណត់ណាមួយ (៣ ខែ ឬ ៦


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខែ) នៃឆ្នាំប្រតិទិន ។ នៅក្នុងរបបនេះ មានសហគ្រាសចំនួន ៤៨,៥១០ ។ ចំណូលពន្ធដែលប្រមូលបានពីសហគ្រាសតាមរបបមៅការមានប្រមាណ ១៥% នៃចំណូលពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ។ នៅក្នុងប្រព័ន្ធនេះ អគ្គនាយកដ្ឋានពន្ធដារផ្ទាល់បានរៀបចំមូលដ្ឋានត្រូវបង់ពន្ធ ស្របតាមបញ្ជីទាំងឡាយដែលប្រគល់មកដោយការប៉ាន់ប្រមាណ ។ ជាក់ស្តែងណាស់ដែលថាប្រព័ន្ធនេះនឹងត្រូវចំណាយច្រើន ដើម្បីគ្រប់គ្រងអោយបានប្រសើរឡើង ។

### ៧.៥.៣. ប្រភេទពន្ធ និង អាករ

យើងអាចធ្វើចំណាត់ថ្នាក់ពន្ធ ទៅតាមភ្នាក់ងារសេដ្ឋកិច្ច ដែលត្រូវបង់ពន្ធទាំងនោះដូចខាងក្រោម÷

- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធនៅលើទីផ្សារកត្តា ឬ ទីផ្សារផលិតកម្ម
- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធលើអ្នកទិញ និង អ្នកលក់នៅទីផ្សារ
- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធលើគ្រួសារ ឬ សហគ្រាស

យើងអាចធ្វើចំណាត់ថ្នាក់ពន្ធ ទៅតាមការគិតគូរលើប្រភេទពន្ធសំខាន់ៗ ដូចខាងក្រោម÷

- ពន្ធលើបុគ្គល ដែលអាស្រ័យលើលទ្ធភាពរបស់អ្នកបង់ពន្ធអាចបង់បាន និង តាមឯកតាពន្ធ ឬ ពន្ធលើប្រតិបត្តិការ និង សកម្មភាពនានា ដូចជា ការទិញ លក់ ឬ ការកាន់កាប់ទ្រព្យសម្បត្តិ ។
- ពន្ធផ្ទាល់ និង ពន្ធប្រយោល
- ពន្ធវិជ្ជមាន និង ពន្ធអវិជ្ជមាន

ពន្ធផ្ទាល់នៅកម្ពុជារួមមាន÷

- ពន្ធលើប្រាក់ចំណេញ
- ពន្ធលើប្រាក់បៀវត្ស និង
- ពន្ធលើការជួលទ្រព្យសម្បត្តិ
- ពន្ធលើជំនិះយានយន្ត
- ពន្ធប្រថាប់ត្រា

នៅកម្ពុជាមាន ពន្ធប្រយោលចំនួន ៦ ប្រភេទ÷

- ពន្ធលើផលរបរ
- អាករលើតម្លៃបន្ថែម
- អាករពិសេសលើផលិតផលមួយចំនួន
- ពន្ធគយលើការនាំចូល

ការបង្វែរ ឬ ការទូទាត់ជំនួយដោយរដ្ឋាភិបាលអាចចាត់ទុកជាពន្ធអវិជ្ជមាន ដោយសារការបង្វែរផ្តល់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រលប់មកវិញជាចំណូលទៅកាន់អង្គភាពនានា ខណៈដែលពន្ធដកយកចំណូលពីអង្គភាពទាំងនោះវិញ ។ ឧទាហរណ៍ វិភាគទានសន្តិសុខសង្គម ត្រូវបានគិតជាពន្ធលើប្រាក់ចំណូលអវិជ្ជមាន ហើយឧបត្ថម្ភធនដល់អាជីវកម្មអាចគិតថាជាពន្ធលើអាជីវកម្មអវិជ្ជមាន ។

បណ្ដាពន្ធខាងក្រោមនេះត្រូវបង់ចូលថវិការដ្ឋ៖

- ពន្ធលើប្រាក់ចំណេញ
- ពន្ធកាត់ទុក
- ពន្ធអប្បបរមា
- ពន្ធលើប្រាក់បៀវត្ស
- អាករលើតម្លៃបន្ថែម
- អាករពិសេសលើទំនិញនិងសេវាមួយចំនួន

បណ្ដាពន្ធខាងក្រោមនេះត្រូងបង់ចូលថវិកាខេត្ត-ក្រុង៖

- អាករសម្រាប់បំភ្លឺសាធារណៈ
- អាករលើការស្នាក់នៅ
- ពន្ធប៉ាតង់
- ពន្ធលើដីទំនេរ
- ពន្ធប្រថាប់ត្រា
- ពន្ធសត្តឃាត
- ពន្ធតែមប្រិ៍
- ពន្ធលើមធ្យោបាយដឹកជញ្ជូន ។ល។

លក្ខណៈសំខាន់ៗនៃរចនាសម្ព័ន្ធសារពើពន្ធល្អ មានដូចខាងក្រោម លក្ខណៈសំខាន់ៗនៃរចនាសម្ព័ន្ធសារពើពន្ធល្អ មានដូចខាងក្រោម (Musgrave, 2004) ៖

- ចំណូលដែលប្រមូលបានត្រូវតែគ្រប់គ្រាន់
- ការបែងចែកបន្ទុកពន្ធត្រូវតែប្រកបដោយសមធម៌
- អ្វីដែលសំខាន់នោះមិនមែនស្ថិតនៅលើមុខសញ្ញាយកពន្ធទេ តែអ្នកណាដែលត្រូវរងបន្ទុកពន្ធ
- ត្រូវជ្រើសរើសពន្ធណា ដែលកាត់បន្ថយអោយដល់កម្រិតអប្បបរមា នូវអន្តរាគមន៍ជាមួយនឹងការសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ច នៅក្នុងបរិការណ៍ទីផ្សារមានប្រសិទ្ធភាព ។ ត្រូវកាត់បន្ថយជាអតិបរិមានូវ «បន្ទុកបន្ថែម» ។
- រចនាសម្ព័ន្ធពន្ធត្រូវជួយសម្រួលដល់ការអនុវត្តគោលនយោបាយសារពើពន្ធ ដើម្បីឱ្យមានស្ថិរភាព និង កំណើន

• ប្រព័ន្ធសារពើពន្ធត្រូវមានរដ្ឋបាលប្រកបដោយភាពយុត្តិធម៌ ឥតលំអៀង ហើយងាយយល់ សម្រាប់អ្នកបង់ពន្ធ
• តម្លៃរដ្ឋបាល និង តម្លៃអនុវត្តច្បាប់ត្រូវតែមានកម្រិតទាបសមស្រប ។

## ៧.៥.៤. ការពិពណ៌នាអំពីប្រភេទពន្ធនៅកម្ពុជា

### ១. ពន្ធដែលត្រូវបង់ចូលថវិការដ្ឋ

### ក. ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ និង ផលចំណេញមូលធន

**១.១. ពន្ធលើប្រាក់បៀវត្ស:** ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែ កំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួល ក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ ។ រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស ។ រូបវន្តបុគ្គលអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ។ សហគ្រាសដែលជានិយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស នៅមុនពេលបើកប្រាក់បៀវត្សឱ្យដល់និយោជិត និងបង់ប្រាក់ពន្ធនេះជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សត្រូវបានបើក ។

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុក តាមអត្រាកំណើនតាមថ្នាក់ដូចតទៅ ÷

តារាង ១៧.៥ អត្រាពន្ធលើប្រាក់បៀវត្ស

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ៥00.000 ៛ | 0% |
| ពី | ៥00.00១ ៛ | ដល់ | ១.២៥0.000 ៛ | ៥% |
| ពី | ១.២៥0.00១ ៛ | ដល់ | ៨.៥00.000 ៛ | ១0% |
| ពី | ៨.៥00.00១ ៛ | ដល់ | ១២.៥00.000 ៛ | ១៥% |
| | | លើសពី | ១២.៥00.000 ៛ | ២0% |

សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២0% នៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក ។ ពន្ធកាត់ទុកនេះគឺជាពន្ធចុងក្រោយនៃប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែ សហគ្រាស ក្រុមហ៊ុន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២០% នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់ ។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់ ។

**១.២. ពន្ធលើប្រាក់ចំណេញ:** ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស ។ សំរាប់អ្នកជាប់ពន្ធអនិវាសនជនពន្ធលើប្រាក់ចំណេញកំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ ។

**ប្រាក់ចំណេញជាប់ពន្ធ**- ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និងសួយសារផង ។ ប្រាក់ចំណេញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ ដែលសម្រេចបានមកពីប្រតិបត្តិការនានា ក្រៅពីប្រតិបត្តិការអាជីវកម្ម ។

**អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ**- អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ មានដូចតទៅ៖

១- ២០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។

២- ៣០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬ ត្បូងថ្មមានតម្លៃនានា ។

៣- ៩ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់រយៈពេលអន្តរកាល ៥ ឆ្នាំ ដោយគិតចាប់ផ្តើមពីថ្ងៃប្រកាសឱ្យប្រើ **ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ**នៃព្រះរាជាណាចក្រកម្ពុជា ។

៤- ០ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៥- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គលនិង ចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្មដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ÷

៦- ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ ក្នុងការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ខាងក្រោម ÷


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| តារាង ១៧.៦. អត្រាពន្ធសម្រាប់ក្រុមហ៊ុននៅក្រោមរបបពិត | | | | |
|---|---|---|---|---|
| គោលនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវបង់ | | | | អត្រាពន្ធ |
| ពី | ០ ៛ | ដល់ | ៦.០០០.០០០ ៛ | ០% |
| ពី | ៦.០០០.០០១ ៛ | ដល់ | ១៥.០០០.០០០ ៛ | ៥% |
| ពី | ១៥.០០០.០០១ ៛ | ដល់ | ១០២.០០០.០០០ ៛ | ១០% |
| ពី | ១០២.០០០.០០១ ៛ | ដល់ | ១៥០.០០០.០០០ ៛ | ១៥% |
| | | លើសពី | ១៥០.០០០.០០០ ៛ | ២០% |

ក. ៥% នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តនូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា

ខ. តាមអត្រាទាំងឡាយដូចមានចែងក្នុងចំណុច ១-២-៣-៤ និង ៥ ខាងលើ ចំពោះសកម្មភាពដទៃទៀត ដែលមិនមែនជាការធានារ៉ាប់រងឬធានារ៉ាប់រងបន្ត ។

**ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ**- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែ តាមអត្រា ១% នៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ផលរបរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធត្រូវបាន លើកលែងពីការបង់ប្រាក់រំដោះនេះ ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនឹងត្រូវបានយកទៅកាត់កងពីពន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

**ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ**- នៅពេលបែងចែកភាគលាភ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបង់ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ដូចតទៅ÷

១- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ ភាគរយ នៃទឹកប្រាក់ត្រូវបែងចែក ចំពោះ÷

ក. ការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញ តាមអត្រា ០ ភាគរយ ។

ខ. ការបែងចែកដទៃទៀត វៀរលែងតែការបែងចែកដែលបានកំណត់ក្នុងចំណុច ២ និង ចំណុច ៣ ខាងក្រោមនេះ និងការបង់សងវិញនូវមូលធន ។

២- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ ភាគ ៨១ នៃទឹកប្រាក់ត្រូវបែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ ។

៣- ពន្ធលើប្រាក់ចំណេញបន្ថែមមិនត្រូវអនុវត្តទេ ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំ ក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ ឬអត្រា ៣០ ភាគរយ ។

## ១.៣. ពន្ធកាត់ទុក

**ពន្ធកាត់ទុកលើនិវាសនជន**- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុកនិង បង់ប្រាក់ពន្ធទៅតាមអត្រាដូចខាងក្រោមលើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ ÷

ក. អត្រា ១៥% ចំពោះ ÷

- ប្រាក់ចំណូល ដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬ សេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបីនិងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ. អត្រា ១០% ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនឬ អចលនទ្រព្យ

គ. អត្រា ៦% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់

ឃ. អត្រា ៤% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីសន្សំគ្មានកាលកំណត់ ។

ការកាត់ទុកខាងលើនេះមិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារ និងស្ថាប័នសញ្ជ័យក្នុងស្រុក និង ការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ។

**ពន្ធកាត់ទុកលើអនិវាសនជន**- អ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មដែលធ្វើការទូទាត់ប្រាក់ចំណូលដូចខាងក្រោមនេះឱ្យទៅអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធតាមអត្រា ១៤% នៃទឹកប្រាក់ត្រូវបើក ÷


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក- ការប្រាក់

ខ- ស្នួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ- ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

ឃ- ភាគលាភ ។

សហគ្រាសក្រុមហ៊ុន ត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកក្នុងរយៈពេល ១៥ ថ្ងៃក្រោយដំណាច់ខែដែលមានការកាត់ទុក ។ ពេលកាត់ទុក គឺជាពេលដែលចំណាយត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ។

## ១.៤. ពន្ធអប្បបរមា

ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែកនិងផ្សេងពីពន្ធលើប្រាក់ចំណេញ ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមអត្រា ១ ភាគរយលើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ។

## ១.៥. ពន្ធលើប្រាក់ចំណេញមូលធន

ការយកពន្ធទ្វេដងលើប្រាក់ចំណេញសារជីវកម្មអាចត្រូវចៀសវាងបាន ដោយការផ្តល់ភាគចំណេញក្រោយកាត់ពន្ធដល់បុគ្គលទាំងឡាយ ដែលទទួលផលពីប្រាក់ចំណេញ ដែលបែងចែកដោយសារជីវកម្ម ដែលបានទូទាត់ពន្ធលើប្រាក់ចំណេញរួច ។ នៅពេលគ្មានភាគចំណេញក្រោយកាត់ពន្ធផ្ទាល់ខ្លួនចំពោះការបែងចែកប្រាក់ចំណេញសារជីវកម្ម មានការជំរុញលើកទឹកចិត្តក្នុងការមិនបែងចែកប្រាក់ចំណេញសារជីវកម្មជាភាគលាភ ក៏ប៉ុន្តែរក្សាទុកប្រាក់ចំណេញទាំងនោះនៅក្នុងក្រុមហ៊ុន ដើម្បីការវិនិយោគបន្តទៅថ្ងៃមុខ ជាហេតុនាំឱ្យរួចពន្ធផ្ទាល់ខ្លួន ។ ប្រាក់ចំណេញមិនបានបែងចែកទៅសមាជិករួមទុន ត្រូវបានបន្ថែមទៅលើតម្លៃមូលធនរបស់ក្រុមហ៊ុន ហើយអាចប្រើប្រាស់ក្នុងការធ្វើហិរញ្ញប្បទានវិនិយោគដែលឥតត្រូវបានគិតពន្ធ ។ ដោយការរក្សាទុក ជាជាងការទូទាត់ប្រាក់ចំណេញនោះឱ្យសមាជិករួមទុនសារជីវកម្មផ្តល់សមាជិករួមទុនម្នាក់ៗ នូវផលប្រយោជន៍លើប្រាក់ចំណេញមូលធន។

ពន្ធលើប្រាក់ចំណេញមូលធន ទោះជាយ៉ាងណាត្រូវបានគិតជាកាតព្វកិច្ចពន្ធនៅពេលដែលបុគ្គលម្នាក់លក់ទ្រព្យ ឬ ភាគហ៊ុនរបស់ក្រុមហ៊ុន ។ ពន្ធលើប្រាក់ចំណេញមូលធនត្រូវបានគិតអត្រាថេរ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ខ. ពន្ធលើកម្មសិទ្ធិ និង ទ្រព្យសម្បត្តិ

ពន្ធលើកម្មសិទ្ធិ និង ទ្រព្យសម្បត្តិអាចត្រូវបានគិតលើចំណែកនៃកម្មសិទ្ធិ (អាចទូទាត់បាន) និង អាចគិតពន្ធជារឿយៗ តាមប្រភេទឯកតា ឬ អាចគិតលើការកាន់កាប់កម្មសិទ្ធិសរុបរបស់បុគ្គលម្នាក់ ឬ តាមតម្លៃពិតតាមធម្មជាតិនៃពន្ធផ្ទាល់ខ្លួន ។ ការជជែកវែកញែកលើការពន្ធលើទ្រព្យសម្បត្តិអាចនឹងត្រូវគិតលើផល-ប្រយោជន៍ និង លទ្ធភាពក្នុងការបង់ពន្ធ ។ នៅកម្ពុជា ពន្ធលើកម្មសិទ្ធិមានទម្រង់ជាពន្ធលើការជួលកម្មសិទ្ធិ ។

**១.៦. ពន្ធលើការជួលកម្មសិទ្ធិ ឬ ទ្រព្យសម្បត្តិ អាជីវកម្ម** (ក្រៅពីអាជីវកម្មទាំងឡាយដែលស្ថិតនៅក្នុងរបបស្វ័យប្រកាស) ការជួលដីធ្លី អាគារ សម្ភារៈ ឃ្លាំង ជាដើម ត្រូវជាប់ពន្ធលើការជួលកម្មសិទ្ធិទាំងអស់ ។ ពន្ធដែលត្រូវគិតនៅអត្រា ១០% លើតម្លៃជួល ។ ពន្ធនេះគិតដោយផ្ទាល់លើម្ចាស់កម្មសិទ្ធិ ប៉ុន្តែមិនកាត់យកពីការទូទាត់ប្រាក់ជួល ដែលធ្វើឡើងដោយសហគ្រាសស្ថិតនៅក្រោមរបបស្វ័យប្រកាសឡើយ ។ ម្ចាស់កម្មសិទ្ធិដែលមានប្រាក់ចំណូលប្រចាំខែ បានមកពីការជួលតិចជាង ៥០០.០០០ រៀល ត្រូវទទួលបានការអនុគ្រោះពន្ធ ។

### គ. ពន្ធលើការប្រើប្រាស់

ពន្ធលើការលក់ ក៏ដូចជាពន្ធលើប្រាក់ចំណូលដែរ ត្រូវបានគិតពន្ធលើលំហូរសាច់ប្រាក់ចូល ដែលបង្កើតឡើងនៅក្នុងផលិតកម្មនៃទិន្នផលបច្ចុប្បន្ន ។ ពន្ធលើប្រាក់ចំណូលត្រូវបានគិតលើប្រាក់ចំណូលសុទ្ធ ដែលរកបានដោយគ្រួសារ ។ ពន្ធលើការលក់ ត្រូវគិតលើការលក់របស់ក្រុមហ៊ុនអាជីវកម្ម ។ ពន្ធលើការលក់ខុសពីពន្ធលើប្រាក់ចំណូលត្រង់ថា ពន្ធទាំងនេះមានឯកតាមិនដូចពន្ធផ្ទាល់ខ្លួនឡើយ ។

**១.៧. អាករលើតម្លៃបន្ថែម:** អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន ។

ទំនិញ សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លី និងប្រាក់កាស រីឯសេវាសំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស ។

ការផ្គត់ផ្គង់ជាប់អាករ សំដៅដល់៖

- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ៖

- សេវាប្រៃសណីយ៍សាធារណៈ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- សេវារបស់មន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ ដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ការនាំចូលនិងការទិញទំនិញសម្រាប់ ឬដោយបេសកកម្មទូត និងកុងស៊ុលបរទេសអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ។

អត្រាអាករលើតម្លៃបន្ថែមមាន ÷

- ១០% សម្រាប់ការនាំចូល ឬការផ្គត់ផ្គង់ទំនិញឬសេវាក្នុងព្រះរាជាណាចក្រកម្ពុជា
- ០% សម្រាប់ការនាំចេញ ។

ការគណនាប្រាក់អាករត្រូវបង់ ÷

- ប្រាក់អាករដែលបានបង់នៅពេលនាំចូលទំនិញ ឬប្រាក់អាករដែលបានបង់លើការទិញ ទំនិញឬ សេវាសម្រាប់ប្រកបអាជីវកម្ម ហៅថា «**អាករលើធាតុចូល**»
- ប្រាក់អាករដែលបានគិតយកពីអតិថិជនពីការផ្គត់ផ្គង់ទំនិញឬសេវា ហៅថា «**អាករលើធាតុចេញ**»

**ប្រាក់អាករត្រូវបង់ = អាករលើធាតុចេញ - អាករលើធាតុចូល ៕**

អាករលើធាតុចូលដែលមិនអាចកាត់កងបាន ÷

អាករលើធាតុចូលដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើ ÷

- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ ។
- ការទិញឬការនាំចូល រថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត។
- ការទិញឬការនាំចូលផលិតផលគេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលគេលសិលាទាំងនោះ ។

អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា ត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**១.៨. អាករលើផលរបរ** អាករលើផលរបរអាជីវកម្មប្រចាំខែ ត្រូវអនុវត្តលើបុគ្គលទាំងឡាយនៅក្រោមរបបម៉ៅការ។ កសិផលលក់ដោយផលិតករដំបូងគេ (ប៉ុន្តែមិនមែនជាឈ្មួញ) និងឈ្មួញចល័ត និងការកសាងអចិន្ត្រៃយ៍ខ្នាតតូច ដែលត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងសហគ្រាសដែលធ្វើប្រតិបត្តិការដោយច្បាប់ស្តីពីវិនិយោគ ដែលនឹងត្រូវគិតអត្រាពន្ធតែមួយ ២% ។

**១.៩. អាករពិសេសលើទំនិញ និង សេវាមួយចំនួន** ពន្ធលើផលិតផលមួយចំនួន ទាំងផលិតនៅក្នុងស្រុក និងនាំចូល និងសេវាផ្សេងៗ ។ ការបង់ពន្ធអាករពិសេសលើបារីត្រូវបានធានាដោយការបិទតែម ។

ទំនិញដែលត្រូវជាប់អាករពិសេសលើទំនិញ និង សេវាមួយចំនួន ÷

- រថយន្ត (៣០%)
- គ្រឿងបន្លាស់ (២០%) និង
- ម៉ូតូ និង គ្រឿងបន្លាស់ (១០%)
- ផលិតផលតេលសិលា (២០%)
- ភេសជ្ជៈ និង គ្រឿងស្រវឹង (១០%)
- ស្រាបៀរ (២០%)

សេវាខាងក្រោមនេះត្រូវជាប់អាករលើសេវាកម្ម ÷

- សេវាកំសាន្ត (១០%)
- សេវាដឹកជញ្ជូនអ្នកដំណើរតាមអាកាស និង សេវាទូរស័ព្ទ (១០%) ។

**១.១០. ពន្ធគយលើការនាំចូល** ពន្ធគយលើការនាំចូល ជាពន្ធលើការលក់ផលិតផលនាំចូលពីបរទេសនៅក្នុងស្រុក ។ ដូច្នេះ ពន្ធនាំចូល គឺជាពន្ធរើសអើង ដែលធ្វើឱ្យទំនិញបរទេសមានតម្លៃថ្លៃជាងទំនិញផលិតនៅក្នុងស្រុក ។

តារាងពន្ធគយ (ផ្អែកលើចំណាត់ថ្នាក់របស់ប្រព័ន្ធសុខុដុមនីយកម្ម) ដែលបានគិតពន្ធលើទំនិញនាំចេញទាំងអស់ ។ អត្រាសំខាន់ៗមាន ៤ ប្រភេទ÷

១- អត្រា ០%

២- អត្រា ៧% លើទំនិញចាំបាច់ និង វត្ថុធាតុ ដើមមូលដ្ឋាន

៣- អត្រា ១៥% លើទំនិញពាក់កណ្តាលសម្រេច គ្រឿងម៉ាស៊ីន និង សម្ភារៈ និង

៤- អត្រា ៣៥% លើទំនិញប្រើប្រាស់ និង វត្ថុធាតុដើមសម្រាប់សំណង់ ។ មាស និង ប្រាក់ត្រូវគិតពន្ធធម្មតា ០,៣% ។

អត្រាទាំងអស់ត្រូវគិតតាមតម្លៃ និងពន្ធគយទាំងអស់ត្រូវគិតតាមមូលដ្ឋាន CIF លើកតែផលិតផល


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តេលសិលា ជីតីមី ដែលតម្លៃនៃគោលបំណងយកពន្ធគយត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការលើកលែងអាករលើការនាំចូលរួមមាន៖

១- ការនាំចូលសម្រាប់គម្រោង និង ការវិនិយោគអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិ នៅពេលនាំចូល

២- ថ្នាំបាណកឃាត ថ្នាំកំចាត់សត្វល្អិតចង្រៃ និង គ្រឿងយន្តកសិកម្ម (លើកលែងតែត្រាក់ទ័រ) និង

៣- ការនាំចូលរបស់ស្ថានទូត អង្គការអន្តរជាតិ ដែលផ្តល់ជំនួយមនុស្សធម៌ និង គម្រោងហិរញ្ញប្បទានដោយអំណោយ និង ជំនួយទ្វេភាគី ។

### ១.១១. ការផ្ទេរតម្លៃ (Transfer pricing)

នៅក្នុងមាត្រា ១៨ នៃច្បាប់ពន្ធអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា មានសិទ្ធិអំណាចទូលំទូលាយក្នុងការបែងចែកឡើងវិញ លើប្រាក់ចំណូល និងចំណាយរវាងបុគ្គលជាប់ទាក់ទិន (Related Parties) ដើម្បីការពារការគេចវេសពន្ធ តាមរយៈការផ្ទេរតម្លៃ ដើម្បីកាត់បន្ថយប្រាក់ចំណេញជាប់ពន្ធ ។

## ២. ពន្ធដែលត្រូវបង់ចូលថវិកាខេត្ត-ក្រុង

**២.១. ពន្ធលើដីទំនេរ** ពន្ធលើដីធ្លី ដែលមាននៅក្នុងទីក្រុង និង តំបន់ ដែលពុំមានសំណង់ ឬ មានសំណង់ប៉ុន្តែមិនបានប្រើប្រាស់ ។ ពន្ធត្រូវបានគណនានៅអត្រា ២% នៃតម្លៃដី ដែលត្រូវបានវាយតម្លៃដោយគណៈកម្មការវាយតម្លៃដីទំនេរនៅថ្ងៃទី ៣០ មិថុនា ជារៀងរាល់ឆ្នាំ ។ ដីមានទំហំ ១.២០០ ម៉ែត្រការេពុំត្រូវបានគិតពន្ធឡើយ ។ ម្ចាស់ដីត្រូវបានតម្រូវឱ្យបង់ពន្ធនៅរៀងរាល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ជារៀងរាល់ឆ្នាំ ។

**២.២. ពន្ធប្រថាប់ត្រា** (ពន្ធលើការផ្ទេរកម្មសិទ្ធិ) មានឯកសារមួយចំនួនទាក់ទងនឹងការបង្កើត ការរំលាយ ឬ បង្រួមចូលគ្នានៃអាជីវកម្ម ឬ ការផ្ទេរឈ្មោះកម្មសិទ្ធិទ្រព្យសម្បត្តិមួយចំនួន (ដូចជា ដី សំណង់អាគារ ជំនិះយានយន្ត និង នាវា) នឹងត្រូវជាប់ពន្ធប្រថាប់ត្រា ។ ពន្ធនេះនឹងត្រូវគិតលើអត្រា ៤% នៃតម្លៃត្រូវផ្ទេរ ។

ការផ្ទេរកម្មសិទ្ធិ ដែលបញ្ជាដោយរដ្ឋត្រូវបានអនុគ្រោះពន្ធ ដូចជាការផ្ទេររបស់រដ្ឋាភិបាល ការប្រើប្រាស់សាធារណៈ និង អង្គការសប្បុរសធម៌មិនរកប្រាក់ចំណេញ ។ ការលក់ជំនិះយានយន្តក៏ត្រូវបានអនុគ្រោះពន្ធដែរ ប្រសិនបើអ្នកលក់ត្រូវបង់ពន្ធលើផលរបរ ឬ ពន្ធលើប្រាក់ចំណេញ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | | |
|---|---|---|---|---|---|
| ពី | ០ | ទៅ | ៧.៥០០.០០០ រៀល | ត្រូវបង់ពន្ធប៉ាតង់ | ១៥.០០០៛ |
| ពី | ៧.៥០០.០០០ ៛ | ទៅ | ១១២.៥០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២១.០០០ ៛ |
| ពី | ១២.៥០០.០០១ ៛ | ទៅ | ២៥.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២៧.០០០៛ |
| ពី | ២៥.០០០.០០១៛ | ទៅ | ៣០.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ៤០.០០០ ៛ |
| ពី | ៣០.០០០.០០១៛ | ទៅ | ៣៧.៥០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ៦០.០០០៛ |
| ពី | ៣៧.៥០០.០០១ ៛ | ទៅ | ៥០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ៩០.០០០ ៛ |
| ពី | ៥០.០០០.០០១ ៛ | ទៅ | ៦២.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ១៤០.០០០ ៛ |
| ពី | ៦២.០០០.០០១៛ | ទៅ | ៧៥.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ១៨០.០០០ ៛ |
| ពី | ៧៥.០០០.០០១ ៛ | ទៅ | ១០០ លាន ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២៤០.០០០ ៛ |
| ពី | ១០០.០០០.០០១៛ | ទៅ | ១ កោដិ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ០,១% នៃផលរបរ |

**២.៣. ពន្ធប៉ាតង់** ការចុះបញ្ជីប្រចាំឆ្នាំ ឬ តម្លៃអជ្ជាប័ណ្ណ ត្រូវបានគិតពន្ធលើគ្រប់អាជីវកម្មឧស្សាហកម្ម និង សេវាកម្ម (ទាំង អ្នកបង់ពន្ធរបបស្វ័យប្រកាស និង របបម៉ៅការ) ។ មូលដ្ឋានគិតពន្ធគឺ ផលរបរពីឆ្នាំមុន ឬ

| | | | | | |
|---|---|---|---|---|---|
| ពី | ០៛ | ទៅ | ៣.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ១៥.០០០ ៛ |
| ពី | ៣.០០០.០០១៛ | ទៅ | ៥.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២១.០០០៛ |
| ពី | ៥.០០០.០០១ ៛ | ទៅ | ១០.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ២៧.០០០៛ |
| ពី | ១០.០០០.០០១៛ | ទៅ | ១២.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ៤០.០០០ ៛ |
| ពី | ១២.០០០.០០១៛ | ទៅ | ១៥.៥០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ៦០.០០០៛ |
| ពី | ១៥.០០០.០០១ ៛ | ទៅ | ២០.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ៩០.០០០ ៛ |
| ពី | ២០.០០០.០០១ ៛ | ទៅ | ២៤.៨០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ១៤០.០០០ ៛ |
| ពី | ២៤.៨០០.០០១ ៛ | ទៅ | ៣០.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ១៨០.០០០៛ |
| ពី | ៣០.០០០.០០១ ៛ | ទៅ | ៤០.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២៤០.០០០ ៛ |
| ពី | ៤០.០០០.០០១ ៛ | ទៅ | ៤០០.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ០,២៥% នៃផលរបរ |

ការប៉ាន់ប្រមាណលើផលរបរ ។ អាជីវកម្មថ្មីត្រូវបានគិតពន្ធលើមូលដ្ឋាននៃការប៉ាន់ប្រមាណ ។ កសិករ និង គ្រួសារ ធ្វើអាជីវកម្មត្រូវបានទទួលការអនុគ្រោះពន្ធប៉ាតង់ ។ ប្រកាសនីយប័ត្រពន្ធប៉ាតង់ត្រូវបានបង្ហាញនៅបរិវេណ ឬ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទីតាំងអាគារអាជីវកម្ម ។ អ្នកបង់ពន្ធត្រូវបញ្ជូនបញ្ជីពន្ធប៉ាតង់ និងទូទាត់ពន្ធនេះនៅចុងខែ មីនា ជារៀងរាល់ឆ្នាំ ។ ចំពោះអាជីវកម្ម និង ឧស្សាហកម្ម និង ចំពោះសេវាកម្ម ពន្ធប៉ាតង់ត្រូវបានគិតតាមផលរបរប្រចាំ ។

## ២.៤. អាករបំភ្លឺសាធារណៈ

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបានកំណត់តាមអត្រា ៣% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវសុរាមេរ័យនិង បារី ។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃ ទី១៥ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ ។

## ២.៥. ពន្ធលើសត្តឃាត

ពន្ធនេះយកពីមណ្ឌលសត្តឃាតនានាផ្អែកតាមតម្លៃនៃបសុសត្វ ។ ពន្ធសត្តឃាតត្រូវបានលើកលែងចំពោះ÷

១- សត្តឃាត ដើម្បីអបអរពិធីបុណ្យប្រពៃណី

២- សត្តឃាតសម្រាប់គោលដៅស្រាវជ្រាវ និង

៣- សត្វសម្លាប់ដោយគ្រោះថ្នាក់ ។

អត្រាពន្ធតែមួយ ៣% ត្រូវបានកំណត់យកលើតម្លៃសត្វមួយក្បាលៗ ។

## ២.៦. ពន្ធលើជំនិះយានយន្ត

ពន្ធលើជំនិះយានយន្តត្រូវបានយកពីរថយន្ត និង ទូកជាប្រចាំឆ្នាំតាមការកំណត់ដូចតទៅ÷

- រថយន្តសណ្តោង: ១៦០.០០០ រៀល
- ឡាន÷
  - ចាប់ពីកម្លាំង ៩ សេះទៅ យកពន្ធ ៣៧.៥០០ និង ៥០.០០០ រៀល
  - កម្លាំងពី ៩ ទៅ ១២ សេះ យកពន្ធ ៥០.០០០ តៅ ៧៥.០០០ រៀល
  - កម្លាំងលើសពី ១២ សេះ យកពន្ធ ៨៧.៥០០ ទៅ ១២៥.០០០ រៀល
- ម៉ូតូត្រូវគិតពន្ធ ៣.០០០ ទៅ ៧.៥០០ រៀល
- ទូកកម្លាំងតូច ត្រូវគិតពន្ធ ៥.០០០ រៀល
- នាវាដឹកទំនិញ (លើសពី ២.០០០ តោន) ត្រូវគិតពន្ធ ១.២០០.០០០ រៀល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- នាវានេសាទសមុទ្រ (មានកម្លាំងលើសពី ៥០០ សេះ) ត្រូវគិតពន្ធ ៣០០.០០០ រៀល ។

**២.៧. ពន្ធតែមប្រ៍** ពន្ធអាចយកបានតាមរយៈតែមប្រ៍ ដែលបិទភ្ជាប់ទៅនឹងឯកសារផ្លូវការនានា និង បដាផ្សាយពាណិជ្ជកម្មធំៗ ។ អត្រាពន្ធមានខុសៗគ្នាទៅតាមកត្តាកំណត់ផ្សេងៗដូចជាទីតាំងដាក់បដា ការតាំងភ្លើងបំភ្លឺ និង ការប្រើប្រាស់ភាសា (ភាសាបរទេស ឬ ភាសាខ្មែរ) ។

## ៧.៥. បន្ទុកសេវា

បន្ទុកសេវាត្រូវបានប្រមូលពីសាធារណជន ដែលស្ម័គ្រចិត្តប្រើប្រាស់សេវាសាធារណៈប្រភេទណាមួយ ដែលមានលក្ខណៈប្រកួតប្រជែង និង មិនអាចហាមឃាត់មិនអោយគេប្រើប្រាស់បាន ។ បន្ទុកសេវាទាមទារឱ្យរដ្ឋមិនផ្តល់នូវសេវាដល់អ្នកដែលមិនបង់បន្ទុកសេវា ជាឧទាហរណ៍ រដ្ឋអាចហាមឃាត់ប្រជាពលរដ្ឋដែលមិនបង់សេវា មិនអោយប្រើប្រាស់ពីផ្លូវ ប្រសិនបើពួកគេមិនបានបង់ប្រាក់សេវា ។

បន្ទុកសេវាជួនកាលអាចអនុវត្តក្រោមរូបភាពជាពន្ធលើទំនិញ និង សេវាចាំបាច់ណាមួយ ដែលសាធារណៈជនតែមួយចំនួនប៉ុណ្ណោះអាចប្រើប្រាស់បាន ។ ឧទាហរណ៍ ពន្ធលើប្រេងសាំង គឺជាពន្ធលើការប្រើប្រាស់ផ្លូវ ។ ពន្ធលើយានយន្ត គឺជាពន្ធលើការប្រើប្រាស់ផ្លូវ ។ បន្ទុកសេវាអាចអនុវត្តដោយពុំគោរពតាមគោលការណ៍ស្ម័គ្រចិត្ត ប្រសិនបើរដ្ឋាភិបាលប្រមូលបន្ទុកទាំងនោះ ដោយពុំគិតពីថាតើសេវានោះត្រូវបានប្រើ ឬ មិនបានប្រើដោយអ្នកបង់បន្ទុកសេវានោះ ។ ឧទាហរណ៍ ប្រសិនបើរដ្ឋាភិបាលបានសម្រេចចិត្តធ្វើហិរញ្ញប្បទានដល់កាតព្វកិច្ចចូលរៀនតាមរយៈបន្ទុកសេវា ពួកគេនឹងត្រូវប៉ះពាល់ដោយពន្ធនេះ ព្រោះថាគ្មានជម្រើសក្នុងការមិនបង់បន្ទុកសេវា ដោយសំអាងថាអ្នកបង់ពន្ធមិនចង់ប្រើប្រាស់សេវានោះទេ ។

ចំណុចអវិជ្ជមាននៃបន្ទុកសេវា គឺស្ថិតនៅត្រង់ថា សេវាសាធារណៈគួរត្រូវបានហិរញ្ញប្បទានតាមរយៈការយកពន្ធកើនឡើង (សមមាត្រពន្ធកើនឡើងតាមប្រាក់ចំណូល) ដោយមិនគួរយកបន្ទុកសេវា ដែលជាប្រភេទពន្ធថយចុះ (សមាមាត្រពន្ធនឹងធ្លាក់ចុះ នៅពេលប្រាក់ចំណូលកើនឡើង) ។ ឧទាហរណ៍ ដោយឈរលើមូលដ្ឋាននៃទស្សនៈសមធម៌ សាលារៀន ឬ មណ្ឌលសុខភាពត្រូវធ្វើហិរញ្ញប្បទានដោយការយកពន្ធ ដែលកើនឡើងតាមប្រាក់ចំណូល ដោយមិនត្រូវយកបន្ទុកសេវា ដែលជាប្រភេទពន្ធថយចុះដែលធ្លាក់ចុះនៅពេលដែលចំណូលកើនឡើង ។ ការអប់រំរបស់កុមារមិនត្រូវអាស្រ័យនឹងឆន្ទៈ ឬ លទ្ធភាពរបស់ឪពុកម្តាយ ក្នុងការបង់បន្ទុកសេវាឡើយ ។ កុមារត្រូវតែមានលទ្ធភាពចូលរៀន ទោះបីជាប្រាក់ចំណូលរបស់ឪពុកម្តាយមិនអនុញ្ញាត ឬ ឪពុកម្តាយបានជ្រើសរើសមិនឱ្យកូនចូលរៀនក៏ដោយ ។

ទោះជាយ៉ាងនេះក្តី បន្ទុកសេវាអាចត្រូវបានអនុវត្តក្នុងការទប់ទល់ទៅនឹងអប្រសិទ្ធភាព ឬ ភាពគ្មាន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការធ្វើហិរញ្ញប្បទានលើការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ដោយសារខ្វះសមត្ថភាពក្នុងការប្រើប្រាស់ចំណូល ។ ឧទាហរណ៍ប្រព័ន្ធអប់រំសាធារណៈ អាចត្រូវបានផ្តល់សេវាអប់រំមានគុណភាពទាបជាងអ្វីដែលសហគមន៍ត្រូវការ ។ ក្នុងករណីទាំងនេះ បន្ទុកសេវាអាចត្រូវបានប្រមូលដើម្បីមានលទ្ធភាពផ្តល់នូវសេវាអប់រំប្រកបដោយគុណភាព តាមតម្រូវការចង់បានរបស់សហគមន៍ ដែលមានឆន្ទៈក្នុងការបង់បន្ទុកសេវានេះ ។

## *៧.៦ ផលប៉ះពាល់នៃចំណូលប្រេងលើគោលនយោបាយហិរញ្ញវត្ថុសាធារណៈ*

គោលនយោបាយសារពើពន្ធត្រូវតែមានសង្គតិភាព ជាមួយនឹងការសម្រេចគោលបំណងម៉ាក្រូសេដ្ឋកិច្ចផ្សេងៗដូចជា ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ អាចដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងការឡើងចុះរយៈពេលខ្លីនៃចំណូលប្រេង ដើម្បីធ្វើអោយប្រសើរឡើងការចាត់ចែងម៉ាក្រូសេដ្ឋកិច្ច និងជំរុញសញ្ជ័យជាតិ ដែលមានសង្គតិភាពជាមួយនឹងកំណើនប្រកបដោយនិរន្តរភាព ។

ឧបស័គ្គផ្នែកសារពើពន្ធសំខាន់បំផុតក្នុងការចាត់ចែងចំណូលប្រេងគឺ ÷

- **លំហូរចំណូលប្រេងមិនប្រាកដប្រជា និង ងាយប្រែប្រួល ។**
- **ចំណូលប្រេងនឹងអស់នៅពេលណាមួយ** ហើយការចាត់ចែងចំណូលប្រេងនេះ ទាមទារអោយគិតដល់សមធម៌រវាងមនុស្សសម្រាប់ជំនាន់នេះ និង មនុស្សជំនាន់ក្រោយៗទៀត ។
- ***កំរិតចំណូលប្រេងមិនទៀងទាត់សម្រាប់ប្រើប្រាស់លើការចំណាយរបស់រដ្ឋាភិបាល ដោយសារការឡើងចុះនៃថ្លៃប្រេង ។***

### ៧.៦.១ ការគេចពីបណ្តាសារប្រេង

ចំណូលប្រេងដ៏ច្រើនសន្ធឹកសន្ធាប់អាចប៉ះពាល់ដល់អត្រាប្តូរប្រាក់ តាមរយៈការប្រែប្រួលនៃចំណូលក្រោយពន្ធ ឥទ្ធិពលទ្រព្យសម្បត្តិ (Wealth effect) ចំណាយថវិការដ្ឋ ដែលកើនឡើង និង ធ្លាក់ចុះតាមវដ្តសេដ្ឋកិច្ច និងវិសមតារូបិយវត្ថុរយៈពេលខ្លី ។ គោលនយោបាយហិរញ្ញវត្ថុសាធារណៈអាចដើរតួយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាទាំងនេះ ដោយការរក្សាលំនឹងចំណាយលើទំនិញ ឬសេវាកម្មដែលមិនអាចដោះដូរជាអន្តរជាតិបាន ។ បន្ថែមលើគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឧបករណ៍របស់គោលនយោបាយរូបិយវត្ថុអាចត្រូវប្រើប្រាស់ដើម្បីការពារកុំអោយរូបិយវត្ថុក្នុងស្រុកឡើងថ្លៃ តាមរយៈប្រតិបត្តិការរូបិយប័ណ្ណបរទេសពោលគឺការទិញលុយដុល្លារដើម្បីបង្កើនទុនបំរុងអន្តរជាតិ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការពង្រឹងសមត្ថភាពស្ថាប័នដើម្បីចាត់ចែងចំណូលប្រេង និងឧស្ម័នមានសារៈសំខាន់ណាស់ដើម្បីគេចពីបណ្តាសារប្រេង ។ បើពុំមានសមត្ថភាពខាងក្នុងខ្ពស់ ដើម្បីវាយតម្លៃចំណាយរបស់គម្រោងនីមួយៗនោះទេ នឹងមានការប្រថុយដែលថា ចំណូលមួយផ្នែកដែលកើនឡើងអាចត្រូវបានយកទៅវិនិយោគក្នុងគម្រោងដែលផ្តល់ផលប្រយោជន៍អវិជ្ជមាន ឬពុំអស់លទ្ធភាព ។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ទៅលើការកសាងសមត្ថភាពវិភាគនៃមន្ត្រីរបស់ខ្លួន អោយរឹងមាំជាងមុន និងប្រព័ន្ធកែលំអការបែងចែកវិនិយោគមូលធន ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល កំពុងអនុវត្តកំណែទម្រង់មួយចំនួន រួមមានកម្មវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ដែលត្រូវបានរៀបចំជាពិសេស ដើម្បីធានាថាថវិកាគួរទុកចិត្តបាន បង្កើនប្រសិទ្ធភាព និងការទទួលខុសត្រូវក្នុងការសម្រេចចិត្តស្តីពីចំណូល និងចំណាយសាធារណៈ និងឈានទៅរកប្រព័ន្ធថវិកាដែលផ្អែកលើលទ្ធផល ។ ការអនុវត្តកម្មវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ដើម្បីធានាសម្រេចបានលទ្ធផលគាប់ប្រសើរ ពីការប្រើប្រាស់ចំណូលធនធានធម្មជាតិក្នុងពេលអនាគត ។ រដ្ឋាភិបាលត្រូវពង្រឹងសមត្ថភាពវិភាគ ដើម្បីបើកផ្លូវអោយស្ថាបនិកគោលនយោបាយសំខាន់ៗ អាចពិនិត្យវាយតម្លៃ និង ប្រៀបធៀបដោយហ្មត់ចត់លើសំណើវិនិយោគផ្សេងៗគ្នា ដើម្បីធ្វើការបែងចែកមូលនិធិសម្រាប់ផលប្រយោជន៍សង្គម និងសេដ្ឋកិច្ចកម្ពុជា ។

## ៧.៦.២ ជម្ងឺហុល្លង់

បទពិសោធន៍នៃការអភិវឌ្ឍក្នុងកំឡុងទសវត្សន៍ថ្មីៗចុងក្រោយនេះបង្ហាញថា ប្រទេសនាំចេញរ៉ែភាគច្រើន ជាពិសេសប្រទេសនាំចេញប្រេង មានសមិទ្ធកម្មអន់ជាងប្រទេសដែលមិនសូវសំបូរធនធានធម្មជាតិ ទោះបីប្រទេសសំបូររ៉ែទាំងនេះ មានប្រៀបជាងដោយអាចទទួលចំណូលពីការនាំចេញរ៉ែលើសការគ្រោងទុកក៏ដោយ ។ ប្រទេសមួយចំនួន ដូចជាម៉ាឡេស៊ី ជៀសផុតពីស្ថានការនេះ ដោយផ្តោតទៅលើសកម្មភាពក្រៅពីផ្នែករ៉ែ និងប្រើប្រាស់ចំណូលពីរ៉ែដែលលើសការគ្រោងទុក ក្នុងការកសាងហេដ្ឋារចនាសម្ព័ន ជាជាងបង្កើនការប្រើប្រាស់ ។

អ្នកទ្រឹស្តីជាច្រើនកំណត់មូលហេតុនៃបណ្តាសារធនធាន ទៅលើ ១)- ជម្ងឺហុល្លង់ ២)- អភិបាលកិច្ចខ្សោយ និង៣)- ឥទ្ធិពលមិនល្អនៃការឡើងចុះនៃលំហូរធនធាន និងតម្លៃទីផ្សារពិភពលោករបស់ទំនិញចំបងៗដូចជារ៉ែជាដើម ។

ក្នុងបរិបទនៃជម្ងឺ **ហុល្លង់** ការកើនឡើងយ៉ាងឆាប់រហ័សនៃការនាំចេញប្រេង នាំអោយផលិតកម្មក្នុងស្រុកធ្លាក់ចុះ ដោយសារការនាំចេញថយចុះ និងការនាំចូលកើនឡើង ដែលបណ្តាលមកការឡើងថ្លៃនៃរូបិយវត្ថុក្នុងស្រុក ។ កំណើនចំណូលពីធនធាន (ឧទាហរណ៍ ចំណូលប្រេង) បង្កើនសមត្ថភាពនាំចូលកាន់តែខ្លាំងជាងមុន តែក៏បង្កើនតម្រូវការទំនិញទាំងអស់ដែរ ដោយរាប់បញ្ចូលទាំងទំនិញដែលមិនអាចជួញដូរជាអន្តរជាតិ ដែលមិនអាចនាំចូលកើត ហើយត្រូវតែផលិតក្នុងស្រុក ។ បញ្ហានេះ ទាមទារអោយសេដ្ឋកិច្ចដកធនធានចេញពីវិស័យដែលអាចនាំចេញនាំចូលបាន ឧទាហរណ៍ដូចជា វិស័យផលិតកម្ម ដើម្បីពង្រីកផលិតកម្មនៃទំនិញដែលមិនអាចធ្វើពាណិជ្ជកម្ម


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អន្តរជាតិ ដូចជាសំណង់ (Corden 1982, Corden & Neary 1982) ។

បណ្តាសារធនធានអាចពន្យល់បានថាជាការសំបូរធនធានធម្មជាតិច្រើនលើសលប់ ដែលធ្វើអោយសេដ្ឋកិច្ចប្រកាន់យកជំនាញនីយកម្មលើវិស័យធនធានធម្មជាតិ ហើយជាវិស័យដែលមិនងាយនឹងមានកំណើនពេលដែលទំហំកាន់តែធំដូចជាវិស័យផលិតកម្មនោះឡើយ (Matsuyama, 1992) ។ ជាលទ្ធផល សេដ្ឋកិច្ចនឹងមិនអាចពង្រីកផលិតកម្មដោយថ្លៃដើមថយចុះនោះឡើយ ហើយនឹងក្លាយជាសេដ្ឋកិច្ចដែលមានថ្លៃដើមខ្ពស់ ។

លើសពីនេះទៅទៀត ជាមួយនឹងការផ្តោតទៅលើវិស័យប្រេង និងឧស្ម័ន ម្ចាស់ក្រុមហ៊ុននីមួយៗគិតថា វាចំណេញច្រើនជាងបើពួកគេរកស៊ីក្នុងសកម្មភាពដែលពាក់ព័ន្ធនឹងវិស័យប្រេងនិងឧស្ម័ន ជាជាងខិតខំប្រឹងប្រែងផលិតទ្រព្យបន្ថែមទៀត និងធ្វើពិពិធកម្មសេដ្ឋកិច្ច ។ ដូចនេះ ទម្រង់សេដ្ឋកិច្ចរបស់ប្រទេសកាន់តែខ្វះប្រសិទ្ធភាពទៅៗ ដោយផ្តោតទៅលើតែវិស័យប្រេង និងឧស្ម័នប៉ុណ្ណោះ (Davis et al. 2003) ។ ការផ្គត់ផ្គង់ធនធានច្រើនជ្រុល ក៏ធ្វើអោយជម្រើសគម្រោងតិចតួច ដែលនឹងនាំទៅដល់ការវិនិយោគខ្ជះខ្ជាយ និង មិនមានលក្ខណៈសេដ្ឋកិច្ច ដែលឈានទៅដល់បរាជ័យនៃគម្រោង ។

**ករណីសិក្សា: សញ្ញាណនៃជម្ងឺហូល្លង់ក្នុងប្រទេសអាហ៊្សែបៃហ្សង់** (Azerbaijan)

ផលិតកម្មប្រេងក្នុងប្រទេសអាហ៊្សែបៃហ្សង់ក្នុងឆ្នាំ ២០០៧ គឺ ១លានធុង ក្នុងមួយថ្ងៃ ។

- កំណើនសេដ្ឋកិច្ច ២៥% ក្នុងឆ្នាំ ២០០៧ ដែលបណ្តាលមកពីវិស័យប្រេង ដោយបានកើន ២៤ ភាគរយ ។
- រូបិយវត្ថុក្នុងស្រុកកើនតំលៃខ្លាំង
- អត្រាអតិផរណាខ្ពស់ (១៦% ក្នុងឆ្នាំ ២០០៧)
- ការបាត់បង់ភាពប្រកួតប្រជែងក្នុងវិស័យដែលមិនអាចជួញដូរជាអន្តរជាតិបាន
- ភាពនៅទ្រឹងនៃវិស័យកសិកម្ម
- ការវិនិយោគយ៉ាងច្រើនលើសលុបក្នុងហេដ្ឋារចនាសម្ព័ន្ធ ធ្វើអោយសកម្មភាព និងថ្លៃដើមសំណង់កើនឡើងយ៉ាងខ្លាំង ដែលរុញអោយអតិផរណាអោយខ្ពស់ ។

ភាព**ងាយប្រែប្រួល**នៃតម្លៃប្រេង មានឥទ្ធិពលទៅលើរបបសារពើពន្ធ ។ បទពិសោធន៍អន្តរជាតិបង្ហាញថាភាពងាយប្រែប្រួលនៃចំណូលប្រេងអាចមានឥទ្ធិពលអវិជ្ជមានលើកំណើនសេដ្ឋកិច្ច ការវិនិយោគ ការបែងចែកចំណូល ការកាត់បន្ថយភាពក្រីក្រ និងសមិទ្ធផលអប់រំក្នុងសង្គម ។ ភាពប្រែប្រួលនៃតម្លៃប្រេងអាចបង្ករ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អស្ថិរភាពដល់ចំណាយថវិកា អត្រាប្តូរប្រាក់ពិត និងផលិតផលពិត ។ ដូចនេះ ដោយការកាត់បន្ថយភាពប្រែប្រួលនៃចំណាយសាធារណៈ រដ្ឋាភិបាលអាចធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចបាន ។

ការរៀបចំរបបសារពើពន្ធដែលសមស្រប មានសារៈសំខាន់ណាស់សំរាប់ប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍវិស័យប្រេង និងឧស្ម័ន ។ ដូចនេះ ក្នុងការរៀបចំឧបករណ៍ពន្ធ និងឧបករណ៍មិនមែនពន្ធ នៃគោលនយោបាយសារពើពន្ធ រាជរដ្ឋាភិបាលកម្ពុជាត្រូវថ្លឹងថ្លែងឥទ្ធិពលនៃរបបសារពើពន្ធលើការ វិនិយោគក្នុងវិស័យប្រេង និងឧស្ម័នដោយផ្ចិតផ្ចង់ ។ ភាពសមល្មមនៃរបបសារពើពន្ធ ដែលក្នុងនោះ ការលើកទឹកចិត្តវិនិយោគ និងការកៀងគរចំណូលត្រូវបានបញ្ចូលគ្នាដោយសុខដុម អាចបង្កើតបាននូវស្ថានភាព ឈ្នះ - ឈ្នះ សម្រាប់ទាំងរដ្ឋាភិបាល និងក្រុមហ៊ុនប្រេង ដែលអនុញ្ញាតអោយភាគីទាំងពីរ ចែកចំណែកហានិភ័យ និងចំណូលសមស្របជាមួយគ្នា ។

រាជរដ្ឋាភិបាលកម្ពុជា អាចប្រមូលចំណូលពីវិស័យប្រេង និងឧស្ម័នតាមរយៈវិធីសាស្ត្រផ្អែកលើផលិតកម្ម និងវិធីសាស្ត្រផ្អែកលើប្រាក់ចំណេញ ។ វិធីសាស្ត្រផ្អែកលើផលិតកម្មអាចធានាថា រដ្ឋាភិបាលទទួលបានយ៉ាងហោចណាស់ ក៏កម្រិតអប្បរមាមួយពីធនធានធម្មជាតិរបស់ខ្លួន ខណៈដែលវិធីសាស្ត្រផ្អែកលើចំណូលអនុញ្ញាតអោយរដ្ឋាភិបាលទទួលបានចំណែក ក្នុងផ្នែកខាងលើនៃគម្រោង ដែលមានប្រាកចំណេញខ្ពស់ ជាមួយនឹងការកើនឡើងនៃចំណែកហានិភ័យរបស់រដ្ឋាភិបាល ។

### ៧.៦.៣. សួយសារ

សួយសារ- ជាឧបករណ៍ពន្ធផ្អែកលើផលិតកម្ម- ដែលអនុញ្ញាតអោយរដ្ឋាភិបាល ធានាបាននូវកម្រិតចំណូលកម្រិតអប្បបរមាភ្លាមៗ បន្ទាប់ពីផលិតកម្មចាប់ផ្តើម ។ សួយសារត្រូវបានរៀបចំតាមវិធីងាយយល់ និងស្រួលគ្រប់គ្រង ។ សួយសារក្នុងប្រទេសកម្ពុជា ត្រូវបានកំណត់ក្នុងកិច្ចព្រមព្រៀងបែងចែកផលិតកម្ម (Production Sharing Agreement) ដោយអត្រា ១២,៥ ភាគរយ ។ សួយសារអាចប្រមូលតាមការជាក់ស្តែងដោយផ្អែក លើបរិមាណប្រេង និងឧស្ម័នដែលបានផលិត ឬ ប្រមូលផ្អែកលើតម្លៃប្រេង និងឧស្ម័នដែលបានផលិត ។ សួយសារដែលផ្អែកលើតម្លៃ គឺប្រមូលដោយផ្អែកលើមូលដ្ឋាននៃតម្លៃលក់ ឬតំលៃនាំចេញ **FOB** ។

សួយសារគឺសម្រាប់ធានាថា រដ្ឋាភិបាលទទួលចំណែកសមស្របនៃចំណូលពីធនធានធម្មជាតិ ។ ទោះជាយ៉ាងណាក៏ដោយ ការយកសួយសារខ្ពស់អាចបំបាក់ទឹកចិត្តអ្នកវិនិយោគមិនអោយអភិវឌ្ឍអណ្តូងប្រេងតូចតាច និងឈានទៅដល់ការឆាប់បោះបង់ចោលអណ្តូងប្រេង និងឧស្ម័ន ។

គុណវិបត្តិនៃសួយសារសម្រាប់អ្នកវិនិយោគ គឺថាសួយសារមិនត្រូវបានអនុញ្ញាតអោយចាត់ទុកជាឥណទានពន្ធបរទេស សម្រាប់យកទៅដកចេញពីពន្ធប្រាក់ចំនេញនៅក្នុងប្រទេសខ្លួនឡើយ ។

### ៧.៦.៤. កិច្ចព្រមព្រៀងបែងចែកផលិតកម្ម

ក្រោមកិច្ចព្រមព្រៀងបែងចែកផលិតកម្ម (Production Sharing Contract) ធនធានគឺជាកម្មសិទ្ធិរបស់រដ្ឋ ហើយក្រុមហ៊ុនប្រេងគឺត្រូវបានជួលអោយមកផលិត និងអភិវឌ្ឍធនធានធម្មជាតិ ដោយទទួលមកវិញនូវចំណែកនៃផលិតកម្ម ។ បន្ទាប់ពីបង់សួយសារ ១២,៥ %ទៅអោយរដ្ឋាភិបាល ផលិតកម្មប្រេងដែលនៅសេសសល់នឹងត្រូវបែងចែកជា ប្រេងថ្លៃដើម និងប្រេងចំណេញ ។ កិច្ចព្រមព្រៀងបែងចែកផលិតកម្មធ្វើការបែងចែកប្រេងដែលនៅសល់បន្ទាប់ពីបង់សួយសារហើយ ទៅជា «ប្រេងថ្លៃដើម» ក្នុងអត្រា ៩០% ដើម្បីអោយអ្នកវិនិយោគស្រង់ដើមមកវិញ និងមួយទៀតជា «ប្រេងចំណេញ» ក្នុងអត្រា ១០% ។ ចំណែកខ្ពស់សំរាប់ប្រេងថ្លៃដើមអនុញ្ញាតអោយក្រុមហ៊ុនស្រង់ដើមចំណាយរុករក និងអភិវឌ្ឍន៍បានឆាប់រហ័ស ។ បើមានការកំណត់កម្រិតអតិបរមាទៅលើការសងថ្លៃដើមក្នុងឆ្នាំណាមួយ ហើយប្រេងថ្លៃដើមកើនលើសពីដែនកំណត់នេះ ការកំណត់ចំនួនអតិបរិមានឹងមានឥទ្ធិពលសេដ្ឋកិច្ច ប្រៀបបាននឹងសួយសារ ដែលអនុញ្ញាតអោយរដ្ឋាភិបាលទទួលចំណូលភ្លាមៗបន្ទាប់ពីផលិតកម្មចាប់ផ្តើមដំណើរការ ។

«ថ្លៃដើមប្រេង» គឺជាថ្លៃដើមនិងចំណាយទាំងអស់ដែលកើតឡើងក្នុងសកម្មភាព ឬពាក់ព័ន្ធទៅនឹងប្រតិបត្តិការប្រេង ។ ថ្លៃដើមនេះរួមមានថ្លៃដើមទាំងអស់ ÷

១. ដែលចំណាយដោយអ្នកម៉ៅការ ដោយស្របតាមនីតិវិធីគណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងឧស្សាហកម្មប្រេងអន្តរជាតិ ហើយស្របជាមួយនឹងវិធីសាស្រ្ត និង នីតិវិធីគណនេយ្យរបស់អ្នកម៉ៅការនោះ ។

២. ឬអនុញ្ញាតដោយបទប្បញ្ញត្តិប្រេងរបស់ប្រទេស ។

«**ថ្លៃដើមប្រេង**» អាចបែងចែកជា៖

ក. **ចំណាយរុករក** ៖ គឺជាចំណាយផ្ទាល់ និងចំណាយមិនផ្ទាល់ដែលត្រូវយកមកគិត ដែលបានកើតឡើងសំរាប់ប្រតិបត្តិការរុករក ដោយរួមទាំងចំណាយសម្រាប់ការបោះបង់ចោលគម្រោងផងដែរ ។

ខ. **ចំណាយអភិវឌ្ឍន៍** ៖ ១) ចំណាយផ្ទាល់ និងមិនផ្ទាល់យកមកគិត ដែលបានកើតឡើងពាក់ព័ន្ធនឹងប្រតិបត្តិការអភិវឌ្ឍ ដោយរួមបញ្ចូលចំណាយសម្រាប់ការបោះបង់ចោលគម្រោង ២) ចំណាយដើម្បីទទួលបានហិរញ្ញប្បទានដែលបង់ដោយអ្នកម៉ៅការ ពាក់ព័ន្ធនឹងការស្វែងរកទុនសំរាប់យកទៅដំណើរការអភិវឌ្ឍ ។

គ. **ថ្លៃដើមផលិតកម្ម** ៖ ចំណាយផ្ទាល់ និងមិនផ្ទាល់ដែលយកមកគិត ដែលបានកើតឡើងពាក់ព័ន្ធនឹង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រតិបត្តិការផលិតកម្ម ។

ឃ. **ចំណាយទូទៅ និងចំណាយរដ្ឋបាល** ៖ ១) គឺជាចំណាយចាត់ចែងចំណាយរដ្ឋបាល និងចំណាយទូទៅទាំងអស់ដែលបង់ដោយការិយាល័យតំណាង និងការិយាល័យនៅការដ្ឋាន ក្នុងប្រទេសកម្ពុជា ដែលរួមមាន សេវាកម្មគ្រប់គ្រង គណនេយ្យ ច្បាប់ បច្ចេកទេស និងទំនាក់ទំនងបុគ្គលិក ២)រាល់ចំណាយចាត់ចែង ចំណាយរដ្ឋបាល និងចំណាយទូទៅទាំងអស់ ដែលបង់ដោយអ្នកម៉ៅការ និងសម្ព័ន្ធក្រុមហ៊ុនរបស់ខ្លួននៅក្រៅប្រទេសកម្ពុជា ហើយដែលអាចយកមកគិតជាចំណាយលើប្រតិបត្តិការប្រេងក្នុងប្រទេសកម្ពុជាដែលរួមមាន ចំណាយសេវាកម្មលើគ្រប់គ្រង គណនេយ្យ ច្បាប់ បច្ចេកទេស និងទំនាក់ទំនងនិយោជិក ៣) ចំណាយទូទៅទាំងអស់បង់នៅក្រៅប្រទេសកម្ពុជា សម្រាប់បម្រើអោយប្រតិបត្តិការប្រេង ជាមួយនឹងជំនួយខាងក្នុងដែលផ្តល់ពីផ្នែកសេវាកម្ម ហិរញ្ញវត្ថុ ការិយាល័យ និងបុគ្គល ។

ង. **ចំណាយនៅការិយាល័យ**: គឺជាចំណាយដែលបង់ដោយអ្នកម៉ៅការសំរាប់សេវាកម្ម មានលក្ខណៈទូទៅដែលអាចយកមកគិតក្នុងប្រតិបត្តិការប្រេង ហើយត្រូវបានគិតក្នុងកម្រិតភាគរយមួយនៃថ្លៃដើមប្រេង ដូចដែលបង្ហាញខាងក្រោមនេះ ។

| **តារាង ១៧.៧. ការបែងចែកចំណាយការិយាល័យ** | |
|---|---|
| **ចំណាយផលិតកម្មប្រេងប្រចាំឆ្នាំ** | **ចំណាយអាជីវកម្មប្រចាំថ្ងៃ** |
| ក្រោម ១ ០០០ ០០០ ដុល្លារ | ១០ % |
| ១ ០០០ ០០០ ដល់ ៥ ០០០ ០០០ | ៥ % |
| ៥ ០០០ ០០០ ដល់ ២០ ០០០ ០០០ | ៣ % |
| លើសពី ២០ ០០០ ០០០ | ២ % |

យ៉ាងណាក៏ដោយ ថ្លៃដើម និងចំណាយដូចខាងក្រោមនេះត្រូវបានដកចេញពីថ្លៃដើមប្រេង ÷

ក. ថ្លៃដើម និងចំណាយដែលមិនពាក់ព័ន្ធប្រតិបត្តិការប្រេងនៅក្នុងតំបន់កិច្ចសន្យា

ខ. ពន្ធលើប្រាក់ចំណេញ និងប្រាក់ពិន័យដែលបង់ក្នុងប្រទេសកម្ពុជា ឬនៅបរទេស

គ. ការខាតបង់ដែលអាចស្រង់យកមកវិញ តាមរយៈធានារ៉ាប់រង ឬកិច្ចសន្យាធានាសង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឃ. ចំណាយមានលក្ខណៈផ្ទាល់ខ្លួន អំណោយ ឬការបរិចាក ដែលពុំមានការព្រមព្រៀង ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរប្រេងកាតជាតិ

ង. ប្រាក់ចំណេញ ឬប្រាក់ខាតពីអត្រាប្តូរប្រាក់

ច. ថ្លៃឈ្នួលបង់ទៅអោយអាជ្ញាធរប្រេងកាតជាតិ ឬរដ្ឋាភិបាល

«**ប្រេងចំណេញ**» ត្រូវបានបែងចែករវាងរដ្ឋាភិបាល និងអ្នកម៉ៅការ ដោយយោលទៅតាមការរៀបចំដូចខាងក្រោមនេះ ÷

ផលិតកម្មខុស្ម៍នសុទ្ធសាធសរុប នឹងត្រូវបែងចែក ៦៥ % ទៅអោយអ្នកម៉ៅការ និង ៣៥ % ទៅអោយរាជរដ្ឋាភិបាល ។ ថ្លៃដើមដែលមិនអាចស្រង់មកវិញក្នុងឆ្នាំណាមួយ ត្រូវបានយកមកគិត ក្នុងឆ្នាំបន្តបន្ទាប់ទៀត ។ ចំណាយលើការប្រាក់ មិនមែនជាចំណាយដែលត្រូវស្រង់យកវិញឡើយ ។

**តារាង ១៧.៨. ការបែងចែកប្រេងសុទ្ធសាធ**

| ផលិតកម្មប្រេងសុទ្ធសាធ | ចំណែកអ្នកម៉ៅការ | ចំណែករដ្ឋាភិបាល |
|---|---|---|
| ១ - ១០ ០០០ បារ៉ែល | ៥៨ % | ៤២ % |
| ------ | ៥៣ % | ៤៧ % |
| ------ | ៤៨ % | ៥២ % |
| ------ | ៣៨ % | ៦២ % |

ទោះបីជាកិច្ចព្រមព្រៀងបែងចែកផលិតកម្ម គឺជាឯកសារដែលត្រូវបានថ្លឹងថ្លែង ដែលមានបំណងបែងចែកចំណូលប្រេងដោយយុត្តិធម៌រវាងរដ្ឋាភិបាល និងអ្នកម៉ៅការក៏ដោយ ភាពលំបាកអាចកើតឡើងពីការកំណត់លើខ្ទង់ដែលអាចចាត់ជាចំណាយបាន ។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងដែល ផ្អែកលើការព្យាករណ៍ទុកជាមុន អាចក្លាយជាមិនសមស្របនៅពេលដឹងលទ្ធភាពចំណេញពិតប្រាកដ កំឡុងពេលប្រតិបត្តិការ ។

ប្រទេសជាច្រើនបានងាកចេញពីវិធីសាស្ត្របែងចែកផលិតកម្ម ដែលផ្អែកលើអត្រាផលិតកម្មប្រចាំថ្ងៃ ដោយអនុវត្តការបែងចែកផលិតកម្ម ដែលផ្អែកលើមូលដ្ឋាននៃ ១) «កត្តា R» ឬអនុបាតស្រង់ដើម និង ២) ការបែងចែកដែលផ្អែកលើអត្រាចំណេញពីការវិនិយោគដែលអ្នកម៉ៅការទទួលបាន ។ ហេតុផល គឺដោយសារថា ក្នុងវិធីសាស្ត្រទាំងពីរនេះ ការបែងចែកកែសម្រួលដោយស្វ័យប្រវត្តិទៅតាម បម្រែបម្រួលនៃតម្លៃទីផ្សារ ថ្លៃដើម ឬបរិមាណផលិតកម្មប្រេង ។ វិធីសាស្ត្រទាំងពីរនេះ កាត់បន្ថយហានិភ័យរបស់អ្នកម៉ៅការ ហើយគួរតែធ្វើអោយចំណែកសរុបរបស់រដ្ឋាភិបាលខ្ពស់ជាងក្នុងរយៈពេលវែង ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ក. វិធីសាស្ត្រ «កត្តា R»

វិធីសាស្ត្រ កត្តា R កំណត់ចំណែកប្រេងចំណេញរបស់រដ្ឋាភិបាល និងអ្នកម៉ៅការ ដោយយោលទៅតាមទំហំដែលកើនឡើង ជាមួយនឹងផលចែករវាងចំណូលរបស់អ្នកម៉ៅការសរុបក្នុងឆ្នាំទាំងអស់ ចែកនឹងចំណាយសរុបក្នុងឆ្នាំទាំងអស់ ដោយដកចំណាយការប្រាក់ចេញ ដែលគេហៅថា កត្តា R ។ វិធីសាស្ត្រ កត្តា R បែងចែកចំណែកមួយភាគធំទៅអោយអ្នកម៉ៅការ នៅពេលដែលលទ្ធភាពចំណេញរបស់គម្រោងទាំងមូល (វាស់ដោយ កត្តា R) មានកំរិតទាប ។ ក្នុងវិធីសាស្ត្រកត្តា R ការកំណត់នៃចំណែកប្រេងចំណេញរបស់អ្នកម៉ៅការ គឺដូចតទៅ ÷

**តារាង ១៧.៩. វិធីសាស្ត្រ កត្តា R នៃការបែងចែកផលិតកម្មប្រេងសុទ្ធសាធ**

| កត្តា R | ចំណែកប្រេងចំណេញរបស់អ្នកម៉ៅការ |
|---|---|
| - ១ | ៩៥ % |
| - ១,៣ | ៩០ % |
| ១,៣ ទៅ ១,៦ | ៨៥ % |
| ១,៦ ទៅ ២,០ | ៦០ % |
| ២,០ ទៅ ៣,០ | ៣០ % |
| លើសពី ៣,០ | ១០ % |

- ចំណូលរបស់អ្នកម៉ៅការ ស្មើនឹងថ្លៃដើមប្រេងដែលបានស្រង់យកវិញ បូកជាមួយចំណែកប្រេងចំណេញរបស់អ្នកម៉ៅការ
- ថ្លៃដើមរបស់អ្នកម៉ៅការ ស្មើថ្លៃដើមប្រេង (ដូចដែលបានកំណត់រួចហើយ)

### ខ. វិធីសាស្ត្រអត្រាចំណូលពីវិនិយោគ (Rate of Return)

អត្រាចំណូលពីវិនិយោគកំណត់ចំណែកប្រេងចំណេញរបស់អ្នកម៉ៅការ និងរដ្ឋាភិបាល ដោយផ្អែកទៅលើទំហំនៃអត្រាចំណូលផ្ទៃក្នុងពីវិនិយោគដែលទទួលបាន (Internal Rate of Return) ពីលំហូរសាច់ប្រាក់ក្នុងកំឡុងអាយុកាលនៃគម្រោង ។ ការកំណត់នៃចំណែកប្រេងចំណេញរបស់អ្នកម៉ៅការ ក្នុងវិធីសាស្ត្រអត្រាចំណូលពីវិនិយោគ ត្រូវបានបង្ហាញក្នុងតារាង ១៧.១០ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងកំឡុងឆ្នាំ ទី ១ នៃកិច្ចព្រមព្រៀងបែងចែកផលិតកម្ម អ្នកម៉ៅការត្រូវស្រង់ដើមវិនិយោគមូលធនដ៏ច្រើនក្នុងការរុករក អភិវឌ្ឍន៍ និងផលិតកម្មប្រេង និងឧស្ម័ន ។ ពេលផលិតកម្មកើនឡើង អត្រាចំណូលពីវិនិយោគសម្រាប់ក្រុមហ៊ុននឹងកើនដែរ ដែលអនុញ្ញាតអោយរដ្ឋាភិបាលបង្កើនចំណែកនៃប្រេងចំណេញរបស់ខ្លួន ។

**តារាង ១៧.១០ វិធីនៃអត្រាទទួលផ្លែក្នុងពីវិនិយោគនៃការបែងចែកប្រេងសុទ្ធ**

| អត្រាទទួលផ្លែក្នុងពីវិនិយោគ | ចំណែកប្រេងចំណេញរបស់អ្នកម៉ៅការ |
|---|---|
| ក្រោម ១០ | ៩៥% |
| ១០ ទៅ ១៥ | ៧០% |
| ១៥ ទៅ ២០ | ៥០% |
| ២០ ទៅ ២៥ | ៤០% |
| ២៥ ទៅ ៣០ | ២០% |
| លើសពី ៣០ | ១០% |

**តារាង ១៧.១១ ការបែងចែកចំណូលរបស់អាហ៊្វើរប៉ៃហ្សង់ក្រោមកិច្ច**

| អត្រាទទួលពីវិនិយោគ | ចំណែករបស់អ្នកម៉ៅការ | ចំណែករបស់រដ្ឋាភិបាល |
|---|---|---|
| ROR <16% | ៧០ % | ៣០ % |
| 16% < ROR < 22% | ៥០ % | ៥០ % |
| ROR <22% | ២០ % | ៨០ % |


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៧.៦.៥ ពន្ធប្រេង

### ក. ពន្ធលើប្រាក់ចំណេញ

ប្រាក់ចំណេញរបស់ក្រុមហ៊ុនប្រេងត្រូវយកពន្ធ ៣០ % ដែលជាទូទៅសម្រាប់ក្រុមហ៊ុនប្រភេទផ្សេងៗទៀតយក ២០ % ។ ដើម្បីការពារមូលដ្ឋានគិតពន្ធ ច្បាប់ពន្ធដាក់កំណត់ដល់ការប្រើប្រាស់ហិរញ្ញប្បទានតាមរយៈបំណុល ដើម្បីដាក់កម្រិតទៅលើ «ការកាត់បន្ថយចំណូល» ដែលអាចធ្វើតាមរយៈការបង់ការប្រាក់នៅបរទេស ។

### ខ. ពន្ធកាត់ទុក

ពន្ធកាត់ទុក ១៤% ត្រូវយកពីការបង់ប្រាក់មួយចំនួនទៅអោយអនិវាសនជន ដែលរួមមានការបង់ការប្រាក់ និងការបង់សម្រាប់ «សេវាកម្មគ្រប់គ្រង និងបច្ចេកទេស» នៃក្រុមហ៊ុនប្រេង ។

### គ. អាករលើតម្លៃបន្ថែម

អាករលើតម្លៃបន្ថែម ១០% ត្រូវយកពីការលក់ផលិតផលប្រេងក្នុងស្រុក ។ ការនាំចេញពុំមានជាប់អាករលើតម្លៃបន្ថែមទេ ។ ក្រុមហ៊ុនប្រេងអាចនឹងទទួលបានប្រាក់សំណងនៃអាករលើតំលៃបន្ថែមវិញ បើអាករលើតម្លៃបន្ថែមនៃការនាំចូល លើសពីអាករលើតម្លៃបន្ថែមនៃការលក់ ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារអាចសងអាករលើតម្លៃបន្ថែមនៃការនាំចូលដែលលើស ដោយបង់ប្រចាំខែទៅអោយអ្នកនាំចេញ ។

### ឃ. ពន្ធអប្បបរមា

ពន្ធអប្បបរមា ១% លើប្រាក់ចំណូលត្រូវអនុវត្តលើក្រុមហ៊ុនប្រេងដែលប្រើរបបពិត ។ យ៉ាងណាក៏ដោយពន្ធនេះត្រូវបង់នៅពេលណាដែលវាលើសពន្ធលើប្រាក់ចំណេញតែប៉ុណ្ណោះ ។

ក្នុងការអនុវត្ត អ្នកបង់ពន្ធមានកាតព្វកិច្ចបង់ប្រចាំខែជាមុនរៀងរាល់ខែនៃពន្ធលើប្រាក់ចំណេញក្នុងអត្រា ១% នៃចំណូលប្រចាំខែ ។ យ៉ាងណាក៏ដោយ ក្រោមកិច្ចព្រមព្រៀងនៃការយកពន្ធត្រួត ជាធម្មតាពន្ធអប្បបរមាមិនអាចយកទៅធ្វើជាឥណទានពន្ធបរទេសទេ ។ ការលំបាកមួយទៀតក្នុងការយកពន្ធអប្បបរមាលើក្រុមហ៊ុនប្រេង គឺថាកំឡុងឆ្នាំដំបូងៗនៃប្រតិបត្តិការ ក្រុមហ៊ុនទាំងនោះនឹងរកស៊ីខាតយ៉ាងច្រើន ដោយសារតែការវិនិយោគមូលធនយ៉ាងច្រើនលើសលុប ។ ពន្ធអប្បបរមានឹងពិបាក អនុវត្តសំរាប់ក្រុមហ៊ុនដែលទើបតែបង្កើតថ្មី ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៧.៦.៦. បញ្ហាក្នុងការគ្រប់គ្រងពន្ធប្រេង

### ក. ការកំណត់ដែនកាត់កងចំណាយពន្ធ (Ring-fencing)

ការកំណត់ព្រំដែននៃគណនីពន្ធ មានគោលដៅបង្ការមិនអោយក្រុមហ៊ុនប្រេងបំប៉ោងចំណាយ ដើម្បីគេចពីការបង់ពន្ធ ដោយដាក់កម្រិត ឬ ញែកអោយដាច់ពីគ្នានូវចំណូល និងចំណាយដែលត្រូវបានអនុញ្ញាតអោយកាត់កង ក្នុងការអនុវត្តសកម្មភាព ឬ គម្រោងផ្សេងទៀត ដែលអនុវត្តដោយអ្នកបង់ពន្ធតែមួយ ។ ច្បាប់កម្ពុជាកំណត់យកតំបន់កិច្ចសន្យា ជាដែលសម្រាប់កាត់កងចំណាយ ពីចំណូលដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ ។ ប្រការនេះមានន័យថា ចំណាយប្រតិបត្តិការប្រេងក្នុងតំបន់ណាមួយ អាចយកទៅកាត់កងបានតែជាមួយនឹងចំណូលដុលដែលបានមកពីតំបន់ដដែលនោះតែប៉ុណ្ណោះ ។ ចំនួនលើសពីការកាត់កងដែលអនុញ្ញាត អាចយកទៅទូទាត់ជាមួយចំណូលនៅឆ្នាំខាងមុខទៀត ។ ក៏ប៉ុន្តែ ច្បាប់ស្តីពីសារពើពន្ធអនុញ្ញាតអោយកាត់កងតែក្នុងរយៈពេល ៥ ឆ្នាំប៉ុណ្ណោះ ក្នុងករណីដែលខាតបន្តបន្ទាប់ ។ ការកំណត់ព្រំដែននៃគណនីពន្ធអនុញ្ញាតអោយយកប្រាក់ខាតទៅកាត់កងជាមួយឆ្នាំក្រោយៗទៀត ដោយមិនកំណត់ ។ ប្រទេសជាច្រើនការកំណត់ព្រំដែននៃគណនីពន្ធ សម្រាប់សកម្មភាព ឬ គម្រោងប្រេង និងឧស្ម័នដាច់ដោយឡែកពីគ្នា ។

ការកំណត់ព្រំដែននៃគណនីកាត់កងចំណាយពន្ធ មានសារៈសំខាន់ខ្លាំងណាស់ ដោយហេតុថា ÷ ១) ប្រសិនបើពុំមានយន្តការនេះទេ ចំណូលពន្ធអាចត្រូវបានពន្យារ ព្រោះក្រុមហ៊ុនណាមួយដែលមានគំរោងច្រើន អាចដកចំណាយស្រាវជ្រាវរុករក ឬ ចំណាយអភិវឌ្ឍន៍នៃគម្រោងថ្មីៗ ជាមួយនឹងចំណូលពីគម្រោងដែលបានបង្កើតចំណូលជាប់ពន្ធរួចហើយ និង ទី ២) ពេលវិស័យផលិតកម្មប្រេង និងឧស្ម័នរីកចម្រើន អវត្តមាននៃការបែងចែកអោយដាច់ពីគ្នានេះ អាចជាការរើសអើងប្រឆាំងនឹងក្រុមហ៊ុនដែលចាប់ផ្តើមថ្មីៗ ដែលពុំមានចំណូលសម្រាប់យកទៅទប់ជាមួយ នឹងចំណាយស្រាវជ្រាវរុករក និងអភិវឌ្ឍន៍ ។

ការកំណត់ព្រំដែននៃគណនីពន្ធអាចមានលក្ខណៈស្មុគស្មាញ ប្រសិនបើគំរោងនោះមានសកម្មភាពផលិត កែច្នៃ និងដឹកជញ្ជូន ក្នុងពេលតែមួយ ។ បើរបបពន្ធប្រេង និងឧស្ម័នមានលក្ខណៈធូររលុងជាងរបបពន្ធទូទៅ អ្នកបង់ពន្ធអាចនឹងចង់អោយសកម្មភាពពាក់ព័ន្ធគម្រោង ត្រូវបានចាត់ទុកជាសកម្មភាព ដែលនៅផ្នែកខាងក្រោម (Downstream) ដែលនៅខាងក្រៅរបងនៃការកំណត់ព្រំដែននៃគណនីពន្ធ ។ បើសិនជាសកម្មភាពនេះត្រូវបានអនុញ្ញាតអោយចាត់ទុកដូច្នេះ អ្នកបង់ពន្ធអាចនឹងព្យាយាមបង្វែរប្រាក់ចំណេញ ទៅសកម្មភាព Downstream ដែលជាប់ពន្ធទាបជាង តាមរយៈការកំណត់ថ្លៃបង្វែរ (Transfer pricing) ។

### ខ. ការកំណត់ថ្លៃបង្វែរ

តាមរយៈការកំណត់ថ្លៃបង្វែរ អ្នកបង់ពន្ធព្យាយាមបន្ថយចំណូលអោយដល់កម្រិតអប្បបរមា និងតម្លើង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណាយដែលអាចកាត់ពន្ធបានអោយឡើងដល់កម្រិតអតិបរមា តាមរយៈប្រតិបត្តិការរវាងភាគីដែលមានសម្ព័ន្ធនឹងគ្នា។ ដើម្បីកំហិតការកំណត់ថ្លៃបង្វែរផ្ដេសផ្ដាសរវាងក្រុមហ៊ុនដែលមានសម្ព័ន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវមានអំណាចកែសម្រួលចំណូល និងចំណាយដែលកំណត់ថ្លៃខ្ពស់ ឬទាបខុសធម្មតារវាងក្រុមហ៊ុនដែលមានសម្ព័ន្ធនឹងគ្នា បណ្ដាលអោយមានចំណូលជាប់ពន្ធទាប ។ បច្ចេកទេសគេចពន្ធមាន ÷

- ការផ្ដល់ហិរញ្ញវត្ថុដែលមានបំណុលមានអត្រាការប្រាក់ខ្ពស់ជាងអត្រាការប្រាក់ទីផ្សារ រវាងក្រុមហ៊ុនដែលមានសម្ព័ន្ធនឹងគ្នា ។ ជាពិសេស ប្រសិនបើអត្រាពន្ធលើចំណូលប្រេង ខ្ពស់ជាងអត្រាពន្ធទូទៅ អាចនឹងមានការលើកទឹកចិត្តអោយក្រុមហ៊ុនប្រេងបង្កើតក្រុមហ៊ុនស្រមោលមួយ ដើម្បីផ្ដល់ឥណទានជាមូលធនបន្តពីក្រុមហ៊ុនដែលមានសម្ព័ន្ធ ទៅអោយក្រុមហ៊ុនប្រេង ដែលនាំអោយមានការកាត់កងចំណាយការប្រាក់ខ្ពស់ពីប្រាក់ចំណូលរបស់ក្រុមហ៊ុនប្រេង ។ ចំណូលពីការប្រាក់ត្រូវបានចាត់ជាចំណូលរបស់ក្រុមហ៊ុនហិរញ្ញវត្ថុហើយជាប់ពន្ធក្នុងអត្រាមួយដែលទាបជាង ពន្ធប្រាក់ចំណេញរបស់ក្រុមហ៊ុនប្រេង ។

- ការទាមទារកាត់កងច្រើនហួសហេតុនូវថ្លៃឈ្នួលសម្រាប់ការគ្រប់គ្រង ការកាត់កងចំណាយរបស់ការិយាល័យកណ្ដាល ឬថ្លៃសេវាផ្ដល់យោបល់ ដែលត្រូវបង់ទៅអោយភាគីដែលមានសម្ព័ន្ធ ។

- ការផ្គត់ផ្គង់ទំនិញមូលធន និងគ្រឿងចក្រ តាមរយៈការជួលពីភាគីដែលមានសម្ព័ន្ធ ក្នុងអត្រាលើសពីទីផ្សារ ។

### គ. បទប្បញ្ញត្តិស្ថិរភាពសារពើពន្ធ

ការធានានូវស្ថិរភាពចំណូលសម្រាប់ក្រុមហ៊ុន គឺជាការលើកទឹកចិត្តវិនិយោគដ៏សំខាន់មួយ ដោយសារការវិនិយោគប្រេង និងឧស្ម័នមានលក្ខណៈយូរអង្វែង មានទំហំធំ និងត្រូវចំណាយមូលធនជាមុន ។ ការផ្លាស់ប្ដូរវិធានពន្ធក្នុងពេលអនាគត (ការធ្វើវិសោធនកម្មច្បាប់) ឬការផ្ដើមអនុវត្តច្បាប់ថ្មីទៀត ដែលអាចបង្កើនបន្ទុកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាមទារអោយធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបែងចែកផលិតកម្ម ដើម្បីគិតដល់បញ្ហានេះ ។

## ៧.៦.៧. ការបង់ចំណូលពុំមែនសារពើពន្ធ

### ក. ថ្លៃឈ្នួលផ្ទៃដី

ក្រុមហ៊ុនបង់ថ្លៃជួលផ្ទៃតំបន់សម្រាប់តំបន់នានានៅក្នុងកិច្ចសន្យាតាមអត្រាខាងលើ ។ ក្រុមហ៊ុនក៏ត្រូវបង់ប្រាក់រង្វាន់ហត្ថលេខា និងថ្លៃឈ្នួលសម្រាប់សេវាកម្ម និងមូលនិធិអភិវឌ្ឍន៍សង្គមទៅអោយរដ្ឋាភិបាលដែរ ។ ថ្លៃឈ្នួលផ្ទៃដី ប្រាក់រង្វាន់ និងថ្លៃផ្សេងៗទៀតធានាអោយរដ្ឋាភិបាលទទួលបាននូវចំណូលជាមុន និង ជំរុញលើកទឹកចិត្តអោយក្រុមហ៊ុនប្រេងធ្វើការស្រាវជ្រាវ រុករក និងអភិវឌ្ឍតំបន់កិច្ចសន្យាលឿនជាងមុន ដែលនឹង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អនុញ្ញាតអោយក្រុមហ៊ុនអាចយកចំណូលដែលទទួលបានមកទូទាត់ចំណាយលើថ្លៃឈ្នួលផ្ទៃដី ។

| តារាង ១៧.១១ អត្រាឈ្នួលផ្ទៃដី | |
|---|---|
| **ថ្លៃឈ្នួលផ្ទៃដី** | **អត្រា** |
| សម្រាប់តំបន់ស្រាវជ្រាវរុករកក្នុងដំណាក់កាល ទី ១ នៃរយៈពេលរុករក | $១០ ក្នុងមួយគីឡូម៉ែត្រក្រឡា |
| សម្រាប់តំបន់ស្រាវជ្រាវរុករកក្នុងដំណាក់កាលទី ២ និង ៣ នៃរយៈពេលរុករក | $២០ ក្នុងមួយគីឡូម៉ែត្រក្រឡា |
| សម្រាប់តំបន់រុករកក្នុងរយៈពេលពន្យាការរុករក | $៤០ ក្នុងមួយគីឡូម៉ែត្រក្រឡា |
| សម្រាប់តំបន់ផលិតកម្ម | $៥០០ ក្នុងមួយគីឡូម៉ែត្រក្រឡា |

### ខ. ថ្លៃឈ្នួលដឹកឆ្លងកាត់

ក្រុមហ៊ុនត្រូវបង់ថ្លៃឆ្លងកាត់សម្រាប់ការបញ្ជូនឧស្ម័នតាមបំពង់បង្ហូរ ។

## ៧.៧. ផលប៉ះពាល់សម្រាប់គោលនយោបាយហិរញ្ញវត្ថុសាធារណៈនៃចំណូលប្រេង

### ៧.៧.១. ការគ្រប់គ្រងចំណូលប្រេង

វិធានការខាងក្រោមនេះ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពខ្ពស់បំផុតសម្រាប់កម្ពុជា ដើម្បីកាត់បន្ថយជាអប្បបរមានូវហានិភ័យនៃជំងឺហូឡង់ និង បង្កើនឥទ្ធិពលជាអតិបរមាដល់ការអភិវឌ្ឍសេដ្ឋកិច្ច- សង្គមពីប្រាក់ចំណូលបានពីប្រេង ÷

- វិនិយោគនូវចំណែកច្រើនគួរសមនៃប្រាក់ចំណូលប្រេង និងឧស្ម័ននាពេលអនាគត នៅក្នុងទីជនបទ ជាពិសេសលើការអភិវឌ្ឍធនធានមនុស្ស ដើម្បីកែលម្អកាន់តែខ្លាំងឡើងនូវការអប់រំជាមូលដ្ឋាន អនាម័យទឹក និង សុខភាព និង ហេដ្ឋារចនាសម្ព័ន្ធនៅជនបទ ជាពិសេស អគ្គិសនីយកាវូបនីយកម្មជនបទ ផ្លូវជនបទ និង ប្រព័ន្ធធារាសាស្ត្រ ។
- ដោយប្រជាជនច្រើនជាង ៦០% ពឹងផ្អែកលើវិស័យកសិកម្ម រដ្ឋាភិបាលអាចចំណាយប្រាក់ចំណូលប្រេង និង ឧស្ម័ន ទៅលើហេដ្ឋារចនាសម្ព័ន្ធជនបទដែលត្រូវការចាំបាច់ខ្លាំង ដូចជា ប្រព័ន្ធធារាសាស្ត្រ ផ្លូវ អគ្គិសនី


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងការផ្គត់ផ្គង់ទឹក ។ ការសិក្សាជាក់ស្តែងបានអោយឃើញពី ទំនាក់ទំនងរួមជាវិជ្ជមានរវាងការវិនិយោគនៅទីជនបទ និង សូចនាករសមធមិ ។ ប្រាក់ចំណូលប្រេងអាចត្រូវបានវិនិយោគក្នុងគម្រោងនានា ដែលនឹងផ្តល់ប្រាក់ចំណេញសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរយៈពេលវែងជាវិជ្ជមាន ។ ប្រការនេះនឹងជួយកម្ពុជាអោយសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចរយៈពេលវែង រួមមានការបង្កើតការងារផងដែរ ។ កំណើននៃការវិនិយោគនៅទីជនបទក៏អាចធានានូវយុត្តិធមិសង្គម និងការអភិវឌ្ឍប្រកបដោយសមធមិផងដែរ ។ មូលធនមនុស្ស និងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធនៅទីជនបទក៏នឹងគាំទ្រផងដែរ ដល់ការធ្វើឱ្យមានពិពិធកម្មសេដ្ឋកិច្ចកាន់តែទូលំទូលាយឡើង ការបង្កើតការងារ និង ប្រាក់ចំណូលនៅតំបន់ជនបទ ព្រមទាំងការធ្វើឱ្យមានចីរភាពនូវអត្រាកំណើនសេដ្ឋកិច្ច ដែលមានលក្ខណៈល្អប្រសើរក្នុងរយៈពេលវែង ។ ស្របពេលជាមួយគ្នានេះ កម្រៃបានមកពីការវិនិយោគនូវប្រាក់ចំណូលប្រេង អាចត្រូវបានប្រើដើម្បីបង្កើនជាលំដាប់នូវប្រាក់បៀវត្សរបស់មន្ត្រីរាជការដែលអ្នកទាំងនោះបច្ចុប្បន្នទទួលបានប្រាក់បៀវត្សមិនគ្រប់គ្រាន់ ដែលជាលទ្ធផលធ្វើឱ្យមន្ត្រីរាជការមានផលិតភាពទាប ។ កត្តាទាំងនេះ នឹងចូលរួមចំណែកដល់ស្ថិរភាពសង្គមផងដែរ ។

- របកគំហើញប្រេង និង ឧស្ម័ន អាចនាំឱ្យថ្លៃថាមពលកាន់តែចុះថោក ។ ថ្លៃថាមពលក្នុងស្រុកកាន់តែចុះថោក (ថ្លៃប្រេង និង ឧស្ម័ន) នឹងធ្វើឱ្យអ្នកផលិតក្នុងស្រុកកាន់តែមានការប្រកួតប្រជែងខ្ពស់ក្នុងតំបន់ ។ សេដ្ឋកិច្ចក្នុងស្រុកខ្លាំង នឹងបង្កើតការងារ និង ប្រាក់ចំណូលកាន់តែច្រើនសម្រាប់ប្រជាជនកម្ពុជា ។

- ប្រាក់ចំណូលប្រេងអាចលើកកម្ពស់ជញ្ជីងទូទាត់របស់កម្ពុជា ដែលនាំឱ្យបរិស្ថានម៉ាក្រូសេដ្ឋកិច្ចមានលក្ខណៈប្រសើរឡើង ដែលអាចទាក់ទាញអ្នកវិនិយោគក្នុង និង ក្រៅប្រទេសកាន់តែច្រើន និង បង្កើតការងារច្រើន ។

- ចំណូលប្រេងមួយផ្នែកអាចយកទៅចាយដើម្បីពង្រឹងវិស័យអប់រំ ។ រាជរដ្ឋាភិបាលផ្តល់អាទិភាពទៅលើការអប់រំកម្រិតបឋមសិក្សា មធ្យមសិក្សា និង ឧត្តមសិក្សា (រួមទាំងការផ្តល់អាហារូបករណ៍ទៅក្រៅប្រទេស) វិស័យសុខាភិបាល ប្រព័ន្ធធារាសាស្ត្រ និង គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ព្រមទាំងការលើកកម្ពស់ជីវភាពរបស់ប្រជាជនដែលមិនមែនជាកសិករ ។ រាជរដ្ឋាភិបាលកម្ពុជាអាចលៃទុកប្រាក់ចំណូលប្រេងសម្រាប់ការចំណាយសាធារណៈដែលមានអាទិភាពខ្ពស់ ។ អាទិភាពទាំងនេះត្រូវទទួលហិរញ្ញប្បទានតាមកម្រិតនៃអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់គេ តាមការវាយតម្លៃដោយអ្នកឯកទេសជំនាញ ។

- បង្កើតនូវមូលនិធិសោធននិវត្តន៍ និងវិភាជន៍ដទៃទៀត ក្នុងគោលដៅពង្រីកការធានារ៉ាប់រងសុខភាពសង្គម និងសំណាញ់សុវត្ថិភាពសង្គមដល់ប្រជាជន ។

- ចំណូលប្រេងអាចយកទៅវិនិយោគនៅក្នុងវិស័យទេសចរណ៍ ដែលនឹងមានផលប៉ះពាល់ជាវិជ្ជមានដល់សកម្មភាព និង សេវាពាក់ព័ន្ធនឹងទេសចរណ៍ដទៃទៀត ។

- ចំណូលប្រេង និង ឧស្ម័ន អាចយកទៅប្រើប្រាស់ដើម្បីបង្កើតមូលនិធិលើកទឹកចិត្តដល់សហគ្រាសធុនតូច និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មធ្យម ក៏ដូចជា ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមភាពជាដៃគូឯកជន- សាធារណៈ (Public Private Partnership-PPP) ។

ជាទូទៅ ប្រាក់ចំណូលប្រេង គួរតែត្រូវបានគ្រប់គ្រងទៅតាមគោលការណ៍ដូចខាងក្រោម (CEF, 2006)៖

១. រក្សាស្ថិរភាពគោលនយោបាយហិរញ្ញវត្ថុសាធារណៈនៅក្នុងថវិកាជាតិ ។

២. ចំណូលប្រេង និង ឧស្ម័ន ត្រូវគ្រប់គ្រងនៅក្នុងមូលនិធិប្រេង ក្នុងលក្ខណៈដែលមានការទទួលខុសត្រូវ និង មានតម្លាភាព ។

៣. ចំណាយពីមូលនិធិប្រេង ត្រូវយកទៅវិនិយោគដើម្បីអភិវឌ្ឍធនធានមនុស្ស និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាជាងយកទៅប្រើប្រាស់ ។ ប្រការនេះ ជួយឱ្យកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សតាមការគ្រោងទុក ។

៤. យើងត្រូវធានាអោយបាននូវតុល្យភាពរវាងតម្រូវការជាក់ស្តែងនាពេលបច្ចុប្បន្ន និង តម្រូវការរយៈពេលវែងរបស់កម្ពុជា ដោយកំណត់អត្រាចំណាយប្រចាំឆ្នាំពីមូលនិធិប្រេង ។ និង

៥. មូលនិធិដែលយកទៅវិនិយោគនៅឯបរទេស ដែលមានប្រភពពីមូលនិធិប្រេង ត្រូវតែគ្រប់គ្រងដោយប្រយ័ត្នប្រយែងបំផុត ដោយត្រូវជួលអ្នកគ្រប់គ្រងមានជំនាញច្បាស់លាស់ ។

### ៧.៧.២. មូលនិធិប្រេង - ក្របខ័ណ្ឌគស្ថេរភាពនានា

**មូលនិធិប្រេង** គឺជាយន្តការដើម្បីអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដោយប្រយ័ត្នប្រយែង ដើម្បី (១). ការទប់ស្កាត់ «**ជំងឺហូឡង់**» (២). ការរារាំងមិនអោយអត្រាប្តូរប្រាក់ពិតកើនឡើង (៣). ការធ្វើឱ្យចំណូលប្រេង ដែលមានលក្ខណៈចុះឡើងឥតឈប់ឈរ រក្សាបាននូវលំហូររលូន ដើម្បីធ្វើហិរញ្ញប្បទានចំណាយ (៤). ធានាអោយចំណាយថវិកាមានលក្ខណៈរលូន កុំអោយឡើងចុះខ្លាំងពេក (៥) ពង្រឹងអភិបាលកិច្ច និង តម្លាភាព និង (៦). ផ្តល់នូវមធ្យោបាយសញ្ជ័យរយៈពេលវែង តាមរយៈការបង្កើនថែមនៃមូលធនហិរញ្ញវត្ថុ ។

អនុសាសន៍ខាងក្រោមនេះ គឺជាការរៀបចំយន្តការស្ថាប័នសម្រាប់មូលនិធិប្រេង ÷

- **មូលនិធិស្របមោល** - គឺជាប្លង់គណនេយ្យ ដែលគ្មានរចនាសម្ព័ន្ធស្ថាប័នដាច់ដោយឡែក សម្រាប់ការគ្រប់គ្រងមូលនិធិនោះទេ ហើយរាល់ប្រាក់ចំណូល និងចំណាយទាំងអស់គឺជាផ្នែកមួយនៃថវិកាជាតិ ។ ចំណូលប្រេងអាចរក្សាទុកនៅក្នុងគណនីទោលរដ្ឋាភិបាល ឬ នៅក្នុងគណនីដាច់ដោយឡែក តាមរយៈការរៀបចំគណនេយ្យពិសេសមួយ ។ រដ្ឋាភិបាលរៀបចំនូវវិធានតឹងរឹងចំពោះការដកសាច់ប្រាក់ចេញពីមូលនិធិ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់យកទៅទូទាត់ចំណាយ ។ ការដកប្រាក់បញ្ចេញពីមូលនិធិនឹងបង្ហាញថាជា ហិរញ្ញប្បទាននៃឱនភាពថវិកា ។ ទ្រព្យសកម្មនៃមូលនិធិនឹងត្រូវគ្រប់គ្រងដូចជាទ្រព្យសកម្មរបស់រដ្ឋាភិបាលដែរ ។ ធនធាននៃមូលនិធិនឹងមិនត្រូវបានរក្សាទុកសម្រាប់តែចំណាយពិសេសឡើយ ។ បណ្តាក្រសួង និង ស្ថាប័នពាក់ព័ន្ធនឹងអនុវត្តចំណាយ ទៅតាមការវិភាជនៃច្បាប់ថវិកា ដែលបានអនុម័តដោយសភាជាតិ ។ ការរៀបចំរបៀបនេះមានសង្គតិភាពជាមួយការសម្រេចចិត្តលើគោលនយោបាយ ប្រកបដោយតម្លាភាព គណនេយ្យភាព និង ការត្រួតពិនិត្យចំណាយ តាមរយៈនីតិវិធីថវិកាធម្មតា ដែលគាំទ្រដោយស្តង់ដារគណនេយ្យ របាយការណ៍ និង នីតិវិធីសវនកម្ម ។ **មូលនិធិស្រមោល** អាចពង្រឹងគណនេយ្យភាព និង ការគាំទ្រខាងផ្នែកនយោបាយ ដើម្បីសន្សំសំចៃប្រាក់ចំណូលបានពីធនធាន ដែលមិនអាចផលិតឡើងវិញ ។ វាក៏អាចជួយពង្រឹងនូវការបញ្ចូលនូវគោលការណ៍សេដ្ឋកិច្ចល្អៗ នៅក្នុងដំណើរការថវិកា ។

- **ចំណូលប្រេងទុកសម្រាប់ចំណាយលើខ្ទង់ចំណាយពិសេសក្នុងថវិកា-** អនុលោមតាមវិធីសាស្ត្រនេះ ការផ្ទេរទៅ និងផ្ទេរមករវាងគណនីមូលនិធិប្រេង និង ថវិកាជាតិ មានគោលដៅធ្វើហិរញ្ញប្បទាននូវជំពូកចំណាយជាក់លាក់នៅក្នុងថវិកាជាតិ ។ ចំណូលទាំងអស់នឹងដាក់បញ្ចូលនៅក្នុងចំណូលថវិកា ហើយចំណូលដែលត្រូវសន្សំ (អតិរេក) នៅក្នុងមូលនិធិ នឹងត្រូវបង្ហាញថាជាការផ្ទេរចូលទៅក្នុងមូលនិធិប្រេង ។ ប្រសិនបើមានការដកសាច់ប្រាក់ពីមូលនិធិ វានឹងត្រូវបង្ហាញនៅក្នុងថវិកាថាជាការផ្ទេរ ។ រាល់ចំណាយទាំងអស់នឹងត្រូវអនុវត្ត តាមនីតិវិធីវិភាជន៍ថវិកាជាធម្មតា ។ អភិក្រមនេះមានគោលដៅធានាអោយបាននូវគោលការណ៍ឯកត្តភាពនៃថវិកា ដោយមិនអនុវត្តនូវវិធានតឹងតែងណាមួយ ដូចក្នុងករណី **មូលនិធិស្រមោល** ឡើយ ។ ធនធានដែលបានផ្ទេរចូលក្នុងគណនីថវិកា អាចរក្សាទុកសម្រាប់ចំណាយពិសេសណាមួយ ។ ក៏ប៉ុន្តែ ការរក្សាទុកចំណូលដើម្បីចំណាយពិសេសណាមួយ (Earmarking) នឹងនាំឱ្យមានការបែងចែកធនធាននៅក្រៅដំណើរការវិភាជថវិកា ដែលអាចធ្វើអោយចំណាយគ្មានប្រសិទ្ធភាព និង ការប្រើប្រាស់ធនធានមិនចំទិសដៅ ។

មូលនិធិប្រេងអាចមានទម្រង់ជាច្រើនសណ្ឋាន៖

- **មូលនិធិសម្រាប់ស្ថិរភាពនីយកម្ម-** យន្តការដែលបានរៀបចំឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលញឹកញាប់នៃចំណូលប្រេង ទៅលើថវិកាជាតិ និង សេដ្ឋកិច្ចជាតិ ។ មូលនិធិនេះក៏មានគោលដៅពង្រឹងវិន័យថវិកា និង ធានាអោយបានកាន់តែច្រើននូវតម្លាភាពក្នុងចំណាយ ។ ប្រការនេះនឹងធ្វើអោយចំណូលថវិកាអាចប៉ាន់ប្រមាណបាន និង មានស្ថិរភាព តាមរយៈការផ្ទេរភាពមិនច្បាស់លាស់ និងភាពងាយផ្លាស់ប្តូរទៅក្នុងមូលនិធិ ។

- **មូលនិធិបម្រុងទុកសម្រាប់ស្ថិរភាពនីយកម្ម-** គឺការបម្រុងទុកសម្រាប់ធានានូវស្ថិរភាព ក្នុងករណីដែលថ្លៃ ឬ ចំណូលប្រេងប្រែប្រួលជាយថាហេតុ ។ មូលនិធិរបៀបនេះមានគោលដៅប្រមូលផ្តុំធនធាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅពេលដែលថ្លៃ ឬ ប្រាក់ចំណូល «ឡើងខ្ពស់» (លើសពិដានកំណត់មួយ) ហើយបញ្ចេញមកវិញនៅពេលដែលថ្លៃ ឬ ប្រាក់ចំណូល «ចុះទាប» (ធ្លាក់ចុះក្រោមកម្រិតកំណត់ទាបបំផុត) ។ មូលនិធិបម្រុងនេះធ្វើឱ្យចំណាយថវិកាមានលក្ខណៈថេរ នោះបីជាថ្លៃ ឬ ប្រាក់ចំណូលឡើង ឬ ចុះក៏ដោយ ។ គេអាចកំណត់វិធានជាយថាហេតុ ដើម្បីយកចំណូលទៅដាក់នៅក្នុងមូលនិធិ ប្រសិនបើថ្លៃនាំចេញ ឬ ប្រាក់ចំណូលកើនឡើងខ្ពស់ជាងកម្រិតណាមួយ ។ គេអាចកំណត់នូវបរិមាណអតិបរមារបស់មូលនិធិនេះ ដើម្បីកម្រិតនូវកំណើនទ្រព្យសកម្មនៅក្នុងមូលនិធិ ជាពិសេស ក្នុងករណីដែលគោលដៅចម្បងនៃមូលនិធិ គឺការធានាអោយបាននូវស្ថិរភាពក្នុងរយៈពេលខ្លី ។

- **មូលនិធិសញ្ច័យ-** ត្រូវបានបង្កើតឡើងដើម្បីរក្សាទ្រព្យសម្បត្តិ សម្រាប់ជនជំនាន់ក្រោយ ។ មូលនិធិសញ្ច័យកំណត់នូវភាគរយនៃចំណូលប្រេង ដែលត្រូវបង់ចូលក្នុងមូលនិធិក្នុងមួយឆ្នាំ ទោះបីជាស្ថានភាពចំណូល ឬថ្លៃប្រេងឡើង ឬ ចុះយ៉ាងណាក៏ដោយ ដោយមិនគិតពីការវិវត្តនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈឡើយ ។ មូលនិធិសញ្ច័យក៏អាចមានគោលដៅធានាអោយបាន នូវស្ថិរភាពចំណូលថវិកាផងដែរ ។ ក្នុងន័យនេះការដកប្រាក់ត្រូវបានអនុញ្ញាត ដើម្បីធ្វើហិរញ្ញប្បទានថវិកា នៅក្នុងពេលថ្លៃប្រេងធ្លាក់ចុះ ពេលមានវិបត្តិសេដ្ឋកិច្ច ឬ មានគ្រោះមហន្តរាយកើតឡើង ។

- **មូលនិធិសម្រាប់ហិរញ្ញប្បទាន-** ត្រូវបានបង្កើតឡើង ដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកាសរុប ។ មូលនិធិប្រេងរបស់ន័រវេ (The Norwegian State Petroleum Fund) គឺជាមូលនិធិសម្រាប់ហិរញ្ញប្បទាន ។ រដ្ឋមានកាតព្វកិច្ចផ្ទេរចំណូលពីប្រេងសុទ្ធ ចូលទៅក្នុងមូលនិធិ ។ មូលនិធិផ្តល់នូវហិរញ្ញប្បទាននូវឱនភាពថវិកាសម្រាប់វិស័យក្រៅពីប្រេង ដោយផ្ទេរថវិកាពីមូលនិធិចូលទៅក្នុងថវិការដ្ឋ ។ ប្រសិនបើថវិកាមានអតិរេកសរុប រដ្ឋត្រូវផ្ទេរអតិរេកនេះចូលទៅក្នុងមូលនិធិ ។ តែប្រសិនបើថវិកាមានឱនភាព ឱនភាពនេះនឹងត្រូវធ្វើហិរញ្ញប្បទានដោយមូលនិធិវិញ ។ ទ្រព្យសកម្មដែលរក្សាទុកនៅក្នុងគណនីត្រូវគ្រប់គ្រងតាមគោលការណ៍ណែនាំនៃការវិនិយោគដាច់ដោយឡែក ។ មូលនិធិសម្រាប់ហិរញ្ញប្បទាន គឺជាឧបករណ៍ហិរញ្ញវត្ថុមួយប្រកបដោយតម្លាភាព ដែលផ្សារភ្ជាប់គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ទៅនឹងការប្រមូលផ្តុំនូវទ្រព្យសកម្ម ។ កំណើនចំណាយថវិកា ជាស្វ័យប្រវត្តិនឹងនាំឱ្យប្រាក់បញ្ញើនៅក្នុងមូលនិធិធ្លាក់ចុះ ឬ ការដកប្រាក់ពីមូលនិធិកាន់តែកើនឡើង ។

### ករណីសិក្សា: មូលនិធិប្រេងរបស់ប្រទេសអាហ្សែបៃហ្សង់ (Azerbaijan)

អាហ្សែបៃហ្សង់ បានចុះហត្ថលេខាលើ**កិច្ចព្រមព្រៀងស្តីពីការចែករំលែកផលិតផល** (Production Sharing Agreement) ចំនួន ២៥ ជាមួយក្រុមហ៊ុនប្រេងបរទេស ។ កិច្ចព្រមព្រៀងចំនួនពីរកំពុងផ្តល់ប្រាក់ចំណូលចំនួន ២០០ ពាន់លានដុល្លារ ។ កិច្ចព្រមព្រៀងចំនួន ១០ ត្រូវបានបញ្ចប់ ហើយកិច្ចព្រមព្រៀងចំនួន ១៣ ទៀត នៅមិនទាន់អនុវត្តនៅឡើយ ។ កិច្ចព្រមព្រៀងស្តីពីការចែករំលែកផលិតផលនេះអនុញ្ញាតអោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រដ្ឋាភិបាលទទួលប្រាក់ចំណូល ប្រមាណ ជា ៧៥-៧៨ ភាគរយ ។

មូលនិធិប្រេងរដ្ឋរបស់អាហ្សែបាយហ្សង់ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៩ ជានីតិបុគ្គលដាច់ដោយឡែក ដែលមានគោលបំណងចំបងៗបីៈ (១). ប្រមូលផ្ដុំប្រាក់ចំណូលយ៉ាងច្រើនដែលបានពីអាជីវកម្មប្រេង ដោយផ្ញើប្រាក់ចំណូលទាំងនេះ នៅក្នុងគណនីធនាគារក្រៅប្រទេស (២). ប្រមូលចំណូលប្រេង និង សន្សំធនធានទុក សម្រាប់ប្រជាជនជំនាន់ក្រោយ និង (៣). ចំណាយធនធានដើម្បីបំពេញតម្រូវការរបស់ប្រជាជននាពេលបច្ចុប្បន្ន ។ មូលនិធិនេះឈរនៅលំដាប់ទី ៧ ក្នុងចំណោមមូលនិធិរដ្ឋចំនួន ៣២ ទូទាំងពិភពលោក ដោយជាប់លំដាប់ថ្នាក់ខាងក្រោយសហរដ្ឋអាមេរិក ន័រវេ អូស្ត្រាលី កាណាដា និង ទីម័រខាងកើត។

ទំហំនៃមូលនិធិប្រេង មានចំនួន ២,៥ ពាន់លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០០៧ ហើយត្រូវបានគេសង្ឃឹមថានឹងកើនឡើងដល់ ៣០ ពាន់លានដុល្លារ នៅឆ្នាំ ២០១១ ។ ចរន្តប្រាក់ចំណូលត្រូវបានគ្រោងទុកស្មើ នឹង ២០០ ពាន់លានដុល្លារ ក្នុងរយៈពេល ១៥ ឆ្នាំក្រោយ ។ ប្រាក់ចំណូលបានពីប្រេងត្រូវបានរក្សាទុកក្នុងគណនីរដ្ឋាភិបាលខាងក្រៅប្រទេស ។

### ប្រាក់ចំណូលរបស់មូលនិធិប្រេងៈ

- ភាគហ៊ុនរបស់រដ្ឋាភិបាលនៅក្នុងកិច្ចព្រមព្រៀងចែករំលែកផលិតផល
- កម្រៃឆ្លងកាត់ ដែលអនុវត្តចំពោះបំពង់នាំឧស្ម័ន
- ថ្លៃឈ្នួលដី ឬ ថ្លៃឈ្នួលលើផ្ទៃដីជួល
- រង្វាន់ហត្ថលេខា
- ពន្ធនាំចេញ យកលើបរិមាណនៃប្រេងដែលផលិតដោយក្រុមហ៊ុនប្រេងជាតិនានា ចំនួន ៧៥% នៃតម្លៃប្រេង ដែលលើសពី ៥០ ដុល្លារ ក្នុងមួយធុង ។

ប្រាក់ចំណូលបានពីប្រេង ត្រូវបានយកទៅវិនិយោគនៅក្នុងចំណូលទ្រព្យសកម្មថេរក្រៅប្រទេស ហើយមូលនិធិដ៏តិចតួចប៉ុណ្ណោះ ដែលវិនិយោគលើភាគហ៊ុន ។ រដ្ឋាភិបាលរបស់ Azerbaijan កំពុងធ្វើការត្រួតពិនិត្យឡើងវិញលើគោលនយោបាយវិនិយោគ ដើម្បីអនុញ្ញាតឱ្យមានការវិនិយោគកានតែច្រើនឡើងក្នុងភាគហ៊ុន និងក្នុងមូលបត្រ ។

ប្រាក់ចំណូលប្រមាណជា ៥០% ត្រូវបានរក្សាទុកជាប្រាក់ដុល្លារអាមេរិក ៤០% ជាប្រាក់អឺរ៉ូ ៥% ជាប្រាក់ផោនរបស់អង់គ្លេស និង ៥%ទៀតដែលនៅសេសសល់ រក្សាទុកជារូបិយប័ណ្ណមួយក្នុងចំណោមរូបិយប័ណ្ណ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាំងបីនេះ ។ ប្រការនេះ អាចឱ្យមូលនិធិប្រេងក្លាយជារូបិយវត្ថុអព្យាក្រឹត ដោយសារតែ នៅពេលថ្លៃដុល្លារអាមេរិកធ្លាក់ចុះ នោះវានឹងទូទាត់ជាមួយ ការកើនឡើងនៃរូបិយវត្ថុដទៃទៀត ។ ក៏ប៉ុន្តែ វាទាមទារអោយអតិថិជនពិនិត្យឡើងវិញនូវសមាមាត្រយូរៗម្តង ។

## ចំណាយរបស់មូលនិធិប្រេង

លក្ខណៈវិនិច្ឆ័យសម្រាប់ចំណាយ៖

- **អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** ដូចជា អតិផរណា ។
- **និរន្តរភាពរយៈពេលវែង**- តម្លៃបច្ចុប្បន្នសុទ្ធនៃចរន្តប្រាក់ចំណូល ដែលគ្រោងនឹងទទួលបានក្នុងរយៈពេល ២០ ឆ្នាំ ដោយឈរលើមូលដ្ឋានធនធានបម្រុងដែលបានកំណត់ ។
- **កំណត់ពីជាងឥណទានសម្រាប់ចំណាយ** ។

ចំណាយផ្តោតលើគម្រោងដែលមានសារៈសំខាន់សម្រាប់ជាតិ- ចំណាយសង្គមកិច្ច ដើម្បីលើកស្ទួយដល់ជីវភាពរស់នៅរបស់ជនអន្តោប្រវេសន៍ផ្ទៃក្នុង និង ចំណាយដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ដោយវិនិយោគទៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ រោងចក្រអគ្គិសនី ការផ្គត់ផ្គង់ទឹក បំពង់ឧស្ម័ន ផ្លូវរទេះភ្លើង ប្រព័ន្ធធារាសាស្ត្រជាដើម ។ល។

ថវិកានៃមូលនិធិប្រេង គឺជាផ្នែកនៃកញ្ចប់**ថវិការួម** (Consolidated budget) - *ថវិកាជាតិ ថវិកានៃមូលនិធិប្រេង និងមូលនិធិសោធននិវត្ត* ដែលត្រូវដាក់សភាអនុម័តជារៀងរាល់ឆ្នាំ ។ ចំណាយនេះចែកចេញជាពីរផ្នែកគឺ៖ ចំណាយលើការវិនិយោគដែលត្រៀមទុកក្នុងថវិកា និង ការផ្ទេរដោយផ្ទាល់ចូលក្នុងថវិកាដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកា ។

មូលនិធិប្រេងរដ្ឋក៏បានបង្កើតឡើងនូវ **ទីភ្នាក់ងារវិនិយោគ Azerbaijan** ដែលមានមូលធន ១០០ លាន ដុល្លារអាមេរិក ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៧.៧.៣. សំណើដើម្បីបង្កើតមូលនិធិប្រេងកម្ពុជា

**មូលនិធិប្រេងកម្ពុជា** (The Cambodian Petroleum Fund-CPF) **តែត្រូវបញ្ចូលទៅក្នុងដំណើរការថវិកាដោយរលូន** ដើម្បីអាចឱ្យរដ្ឋាភិបាលរក្សាបាននូវការត្រួតពិនិត្យរួម លើគោលនយោបាយហិរញ្ញវត្ថុសាធារណៈឯកភាព និងជៀសវាងបញ្ហាក្នុងការសម្របសម្រួលចំណាយថវិកា ។ សមាហរណកម្មនៃមូលនិធិប្រេង និង ថវិកាជាតិ គឺជាវិធានការ ដើម្បីជៀសវាងកុំអោយមាន «ថវិកាទ្វេ» ពោលគឺ ថវិកាជាតិ និងកម្មវិធីចំណាយដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិប្រេង ។ ប្រការនេះនឹងអនុញ្ញាតអោយអ្នកគ្រប់គ្រងថវិកាធ្វើការសម្រេចចិត្តនៅក្នុងបរិបថថវិកា ហើយចំណាយនឹងត្រូវបានបញ្ចូលទៅក្នុងថវិការួមតែមួយ ។

**រូប ១៧.២. យន្តការមូលនិធិប្រេង**




ការប្រមូលផ្តុំនូវទ្រព្យសកម្មនៅក្នុងមូលនិធិប្រេង ឆ្លុះបញ្ចាំងពីអតិរេកថវិកាជាក់ស្តែង ។ ការសម្រេចអោយបាននូវអតិរេកថវិកាមិនមែនបានពីប្រេង គឺជាមធ្យោបាយតែមួយគត់ដែលរដ្ឋាភិបាលអាចប្រមូលផ្តុំនូវទ្រព្យសកម្មហិរញ្ញវត្ថុលើមូលដ្ឋានសុទ្ធ ។ ប្រសិនបើមូលនិធិត្រូវបានបង្កើតឡើងជាមួយវិធានវិភាជន៍ធនធានដោយមិនផ្សារភ្ជាប់ទៅនឹងអតិរេកជាក់ស្តែង ការប្រមូលផ្តុំទ្រព្យសកម្មនៅក្នុងមូលនិធិនឹងមិនឆ្លុះបញ្ចាំងពីសញ្ញ័យថវិកា ដោយគ្រាន់តែបង្ហាញពីចំណូលដែលទទួលពីការធ្វើអាជីវកម្មលើធនធានធម្មជាតិប៉ុណ្ណោះ ។ ប្រសិនបើមូលនិធិនេះមិនមានវិធានសម្រាប់ត្រៀមចំណូលទុកទូទាត់ចំណាយពិសេសណាមួយ នោះគោលនយោបាយហិរញ្ញវត្ថុសាធារណៈនឹងមានលក្ខណៈទន់ភ្លន់ និងអាចបត់បែនបាននៅពេលមានផលប៉ះពាល់ ដោយសារចំណូលអាចធ្លាក់ចុះជាយថាហេតុនៅពេលអនាគត ។

ទំនាក់ទំនងអន្តរសកម្មរវាងមូលនិធិប្រេង និងថវិកា ត្រូវបានពន្យល់នៅក្នុងរូបភាពលេខ ១៧.២ ។ ចំណូល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់មូលនិធិ គឺជាប្រាក់ចំណូលសុទ្ធរបស់រដ្ឋាភិបាលបានមកពីអាជីវកម្មប្រេង និងចំណូលពីការបណ្តាក់ទុនវិនិយោគលើមូលនិធិ ។ ការប្រើប្រាស់ចំណូលពីការបណ្តាក់ទុនលើមូលនិធិប្រេងពិតនឹងធានាថា អត្ថប្រយោជន៍ពីទ្រព្យសកម្មនៃមូលនិធិ នឹងត្រូវបានផ្ទេរទៅអោយជនកម្ពុជាជំនាន់ក្រោយនៅពេលអនាគត ។

ចំណាយមូលនិធិរួមមានការផ្ទេរប្រចាំឆ្នាំទៅក្នុងគណនីរតនាគារ ទៅតាមចំនួនប្រាក់ចំណូលប្រេងដែលនឹងប្រើប្រាស់នៅក្នុងថវិកាជាតិ ដើម្បីធ្វើហិរញ្ញប្បទាននៃឱនភាពថវិកាមិនមែនប្រេង ។ បទពិសោធន៍របស់ប្រទេសមួយចំនួនបង្ហាញអោយឃើញថា ការប្រើប្រាក់ចំណូលពីប្រេង ក្នុងកម្រិតហួសប្រមាណ នឹងបណ្តាលអោយមាន **«ជម្ងឺហូឡង់»** និងនិកម្មភាព ។ ប្រការនេះធ្វើអោយរដ្ឋាភិបាលត្រូវចំណាយថវិកាជាច្រើនឥតគណនា ដើម្បីរៀបចំឡើងវិញនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច ។ ដូច្នេះ បញ្ហាសំខាន់ គឺត្រូវចំណាយក្នុងកម្រិតណា ដើម្បីអោយមានតុល្យភាពរវាងកំណើនសេដ្ឋកិច្ចជាមូលដ្ឋាន និង ការរុញច្រានវិនិយោគឯកជន ដោយសារតែរដ្ឋចំណាយច្រើនលើសលប់ពេក ។ Skancke (2003) បានចង្អុលបង្ហាញថា ការប្រើចំណូលពីការបណ្តាក់ទុនលើមូលនិធិប្រេង ដើម្បីធ្វើហិរញ្ញប្បទានថវិកា គឺជាជម្រើសដែលគួរឱ្យចាប់អារម្មណ៍បំផុត សម្រាប់ហេតុផលមួយចំនួនដូចតទៅៈ

- វាជាវិធានសាមញ្ញមួយ ដែលងាយស្រួលនឹងអនុវត្ត និង ផ្សព្វផ្សាយ ។
- វាកំណត់នូវមូលដ្ឋានសម្រាប់ដំណើរការរៀបចំថវិកា ។
- វាធានានិរន្តរភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក្នុងខណៈដែលចំណូលប្រេងមានភាពមិនច្បាស់លាស់ ។
- វាផ្តល់នូវដំណោះស្រាយប្រកបដោយសុភវិនិច្ឆ័យ ដើម្បីធានានូវសមធម៌ដល់ជនជំនាន់ក្រោយ ។

រាជរដ្ឋាភិបាលគួរអនុម័តច្បាប់ ឬ អនុក្រឹត្យស្តីពីមូលនិធិប្រេង ដើម្បីបែងចែកការទទួលខុសត្រូវក្នុងការគ្រប់គ្រង **មូលនិធិប្រេងកម្ពុជា** ។ មូលនិធិប្រេងកម្ពុជាត្រូវតែបង្កើតឡើងដោយឈរលើគោលការណ៍វិជ្ជាជីវៈ គណនេយ្យភាព និង តម្លាភាព ។

រាជរដ្ឋាភិបាលចាំបាច់ត្រូវមានយុទ្ធសាស្ត្ររយៈពេលវែង ស្តីពីការគ្រប់គ្រងទ្រព្យសកម្ម និង វិនិយោគសម្រាប់មូលនិធិប្រេង រួមមាន វិធានការប្រុងប្រយ័ត្នក្នុងវិស័យវិនិយោគធនធាន សម្រាប់កម្រិតហានិភ័យសាច់ប្រាក់សុទ្ធ និង ចំណូលពីការវិនិយោគ ដែលយើងចង់បាន ។ នីតិវិធីនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់មូលនិធិត្រូវតែរៀបចំឡើង ដើម្បីជៀសវាងការរាំងស្ទះទីផ្សារហិរញ្ញវត្ថុ និង បង្ករអោយមានអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ យុទ្ធសាស្ត្រនេះគួរតែឆ្លុះបញ្ចាំងផងដែរនូវសកម្មភាពជាអាទិភាពរបស់រដ្ឋាភិបាល ដែលទទួលហិរញ្ញប្បទានពីមូលនិធិ ។ ប្រតិបត្តិការរយៈពេលខ្លីនៃទ្រព្យសកម្មរបស់មូលនិធិ ត្រូវតែសម្របសម្រួលជាមួយការគ្រប់គ្រងបំណុលក្រៅប្រទេស ការគ្រប់គ្រងសាច់ប្រាក់ និងមូលធនហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ។ ការគ្រប់គ្រងមូលនិធិប្រេង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្ពុជាត្រូវតែរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃសមត្ថភាពវិជ្ជាជីវៈ និង ប្រព័ន្ធសមិទ្ធកម្ម ។

ការសម្រេចចិត្តលើការវិនិយោគធនធាននៃមូលនិធិប្រេង មានសារៈសំខាន់ខ្លាំងណាស់សម្រាប់គោល-នយោបាយរូបិយវត្ថុ និង ហិរញ្ញវត្ថុសាធារណៈ ។ ធនធានរបស់មូលនិធិមួយចំនួនសមស្រប អាចយកទៅធ្វើការវិនិយោគនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ចំណាយអាទិភាពខ្ពស់ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដទៃទៀត ។ ការវិនិយោគទាំងនេះនឹងពង្រឹងការប្រកួតប្រជែងរបស់កម្ពុជា ព្រមទាំងលើកកំពស់ដល់កំណើនវិស័យមិនមែនធនធានធម្មជាតិ ។ ក្នុងបរិការណ៍នេះ ការពង្រឹងគុណភាពគម្រោងវិនិយោគ គឺជាវិធាការដ៏ស័ក្តិសិទ្ធបំផុត ។ ការសម្រេចចិត្តលើការវិនិយោគ ត្រូវតែធ្វើឡើងនៅក្នុងក្របខ័ណ្ឌថវិកា ហើយមូលនិធិនេះមិនត្រូវអនុញ្ញាតឱ្យប្រើសម្រាប់ចំណាយមូលធនក្រៅបរិបទថវិកាឡើយ ។

ធនធានដែលបានមកពីការប្រមូលផ្តុំចំណូលនិងបង់ចូលមូលនិធិ ត្រូវតែយកទៅវិនិយោគនៅក្រៅប្រទេសដើម្បីជៀសវាង **បណ្តាសារធនធាន** ។ ប្រសិនបើធ្វីការវិនិយោគធនធានមូលនិធិនៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងស្រុកឯកជន នឹងនាំអោយសេដ្ឋកិច្ចទទួលរងនូវផលវិបាកដែលបណ្តាលមកពីការឡើងចុះខ្លាំងពេកនៃចំណូលដែលបានមកពីប្រេង និង ឧស្ម័នធម្មជាតិ ។ នៅពេលមានវិបត្តិសេដ្ឋកិច្ច ការជម្រះបញ្ជីនៃទ្រព្យសកម្មហិរញ្ញវត្ថុក្នុងស្រុក (ដូចជាប្រាក់បញ្ញើក្នុងស្រុក) នឹងធ្វើអោយសេដ្ឋកិច្ចកាត់បន្ថយសកម្មភាពផងដែរ លើកលែងតែមានប្រតិបត្តិការបើកចំហនៃទីផ្សារ (Open market operations) ។ ការវិនិយោគក្នុងទ្រព្យសកម្មហិរញ្ញវត្ថុក្នុងស្រុក និង ការបង្កើតសាច់ប្រាក់ពីលំហូរនៃមូលនិធិ នៅពេលដែលសេដ្ឋកិច្ចកំពុងងើបក្បាលឡើងវិញ អាចនឹងបង្កើនយ៉ាងខ្លាំងក្លានូវតម្រូវការសរុប ។

យើងមិនគួរយកមូលនិធិប្រេង ទៅវិនិយោគនៅក្នុងបំណុលក្នុងស្រុករបស់រដ្ឋ ឬ ទ្រព្យអកម្មបរទេសដែលជាផ្នែកមួយនៃការវិភាជទ្រព្យសកម្មរបស់ខ្លួនទេ ។ ប្រការនេះ មានន័យថា រដ្ឋាភិបាលបោះផ្សាយឧបករណ៍បំណុលដើម្បីលក់អោយខ្លួនឯង ។ មិនត្រូវផ្តល់អំណាយអោយមូលនិធិអាចខ្ចី ឬ ឱ្យគេខ្ចីប្រាក់ឡើយ ។ ដើម្បីធានាអោយបាននូវការអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ គួរតែអនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតែមួយគត់ ជាអ្នកសម្រេចខ្ចី និង ឱ្យខ្ចី ។ មិនត្រូវយកមូលធនរបស់មូលនិធិមកប្រើជាវត្ថុធានាសម្រាប់កម្ចីរបស់រដ្ឋាភិបាលឡើយ ។

**មូលនិធិប្រេងកម្ពុជា** នឹងទាមទារឱ្យមានការគ្រប់គ្រងប្រកបដោយជំនាញវិជ្ជាជីវៈ ។ ប្រសិនបើនៅក្នុងប្រទេសកម្ពុជា គ្មានអ្នកជំនាញខាងវិនិយោគ ដែលមានសមត្ថភាពទេនោះ រាជរដ្ឋាភិបាលត្រូវតែជួលក្រុមហ៊ុនជំនាញអន្តរជាតិ ដើម្បីជួយនៅក្នុងការចាត់ចែងផលបត្រមូលនិធិប្រេងកាត ។ យើងគួរតែទុកតួនាទីក្នុងការសម្រេចចិត្តខាងវិនិយោគ ទៅឱ្យអ្នកគ្រប់គ្រងមានវិជ្ជាជីវៈ ក្រោមការត្រួតពិនិត្យដោយក្រុមបច្ចេកទេស ដឹកនាំដោយមន្ត្រីរាជរដ្ឋាភិបាល និង ដោយមានគោលការណ៍ណែនាំរួមសម្រាប់ការងារវិនិយោគ ។

គោលការណ៍គ្រប់គ្រងទ្រព្យសកម្មគួរតែត្រូវអនុម័ត ដើម្បីគ្រប់គ្រងវិភាជន៍ធនធានរបស់មូលនិធិដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្លុះបញ្ចាំងពីការគិតគូរហានិភ័យ- ប្រាក់ចំណេញដែលចង់បាន សមាមាត្រនៃធនធានដែលត្រូវវិនិយោគនៅក្នុងទ្រព្យសកម្មប្រភេទផ្សេងៗ ការបែងចែកតាមភូមិសាស្ត្រនៃការវិនិយោគទ្រព្យសកម្មនេះ និង សមាមាត្រនៃរូបិយប័ណ្ណដែលត្រូវវិនិយោគ ។ រាជរដ្ឋាភិបាលត្រូវជួលអ្នកគ្រប់គ្រងមូលនិធិដែលមានជំនាញវិជ្ជាជីវៈ អោយមកគ្រប់គ្រងការវិនិយោគនៃធនធានមូលនិធិនេះ ។

ក្រុមបច្ចេកទេសត្រូវរៀបចំនូវគោលការណ៍ណែនាំស្តីពីការវិនិយោគ ក្នុងគោលដៅធានាការគ្រប់គ្រងហានិភ័យប្រកបដោយតម្លាភាព ។ គោលការណ៍ណែនាំនេះត្រូវកំណត់នូវសមាមាត្រនៃប្រភេទមូលបត្រដែលត្រូវវិនិយោគ ការបែងចែកការវិនិយោគតាមតំបន់ភូមិសាស្ត្រ និង តំបនវិនិយោគ ភាគហ៊ុនកម្មសិទ្ធិអតិបរមាក្នុងក្រុមហ៊ុនមួយ លក្ខណៈវិនិច្ឆ័យផលប័ត្រសម្រាប់សញ្ញាប័ណ្ណ និង មូលបត្រ កាលកំណត់នៃមូលប័ត្រចំណូលថេរដែលត្រូវវិនិយោគ ។

ទ្រព្យសកម្មនៃមូលនិធិប្រេងត្រូវតែគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយកត់ត្រាទុកនៅក្នុងគណនីទោលរតនាគារនៅក្នុងគណនីនៃធនាគារជាតិនៃកម្ពុជា ។ មូលនិធិប្រេងត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានតំណាងក្រសួង- ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលជាសមាជិក និង មានសមាជិកជាអ្នកជំនាញខាងផ្នែកហិរញ្ញវត្ថុ និង ទីផ្សារមូលប័ត្រមួយចំនួនជាសមាជិក ដោយមានការបែងចែកយ៉ាងច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវ ដើម្បីធានាអោយបាននូវគណនេយ្យភាព ក្នុងការគ្រប់គ្រងមូលនិធិប្រេងនេះ ។

**មូលនិធិប្រេងកម្ពុជា** អាចជាគណនីបញ្ញើ ដែលកាន់កាប់ដោយរដ្ឋាភិបាល និងកំណត់ជាដុល្លារអាមេរិកដែលផ្ញើនៅធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជាត្រូវផ្តល់របាយការណ៍លម្អិតពីការគ្រប់គ្រងមូលនិធិប្រេងកម្ពុជា ដែលរៀបរាប់ពីរបៀបដែលមូលនិធិត្រូវបានគ្រប់គ្រង ពីកន្លែងដែលធនធានត្រូវបានវិនិយោគ និង ដែលផ្តល់លម្អិតពីប្រាក់ចំណូលសរុប និង ថ្លៃនៃការគ្រប់គ្រង ។

### ៧.៧.៤. គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ

របកគំហើញប្រេងក្នុងពេលថ្មីៗនេះនៅក្នុងឈូងសមុទ្រកម្ពុជា បានធ្វើឱ្យមានការជជែកពិភាក្សាជាច្រើនពាក់ព័ន្ធនឹងការគ្រប់គ្រងប្រាក់ចំណូលប្រេង ។ ដៃគូអភិវឌ្ឍន៍មួយចំនួនបានស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាអនុម័តលើ **គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** ដែលភាសាអង់គ្លេសហៅថា **Extractive Industry Transparency Initiative** ឬ ហៅកាត់ថា **EITI** ។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវក្រុមការមួយនៅក្រោមឱវាទ **ក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (PFM) ដែលមានឈ្មោះថា ក្រុមការងារគំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ ដើម្បីស្រាវជ្រាវអំពីគោលការណ៍ និងបញ្ហាអនុវត្តរបស់គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ ព្រមទាំងផ្តល់នូវអនុសាសន៍ដល់រដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការត្រៀមនូវឯកសារ ដើម្បីដាក់ជូនអោយរាជរដ្ឋាភិបាលពិនិត្យ និង ពិចារណាពីសមាជិកភាពរបស់កម្ពុជា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុង **គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** នេះ ។

**គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** គឺជាការផ្តួចផ្តើមគំនិតរួមគ្នារវាងរដ្ឋាភិបាល ក្រុមហ៊ុនប្រេង ក្រុមសង្គមស៊ីវិល អ្នកវិនិយោគ និងអង្គការអន្តរជាតិ ដែលមានគោលបំណងពង្រឹងអភិបាលកិច្ចល្អ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាព នៅក្នុងឧស្សាហកម្មរុករករ៉ែ ។ កត្តានេះអាចសម្រេចបានតាមរយៈដំណើរការនៃការពិនិត្យមើល និង ការបោះផ្សាយនូវរាល់ចំណាយរបស់ក្រុមហ៊ុន និងប្រាក់ចំណូលរបស់រដ្ឋាភិបាល ដែលបានពីប្រេង ឧស្ម័នធម្មជាតិ និង រ៉ែ ។ ជារួម ដំណើរការទូទៅពាក់ព័ន្ធនឹងការប្រៀបធៀបចំណាយរបស់ក្រុមហ៊ុន និង ចំណូលរដ្ឋ ការពន្យល់ពីភាពលំអៀង និង ផ្សព្វផ្សាយរបាយការណ៍នេះជាសាធារណៈ ។

មកដល់ពេលបច្ចុប្បន្ននេះ មានប្រទេសដែលសំបូរធនធានចំនួន ២៩ ហើយ ដែលបានចូលជាសមាជិកនៅក្នុង **EITI** រួមបញ្ចូលទាំងប្រទេសចុងក្រោយគេ គឺ ន័រវេ ។ មានតែប្រទេសចំនួន ១៥ ទេ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា «ប្រទេសបេក្ខជន» ។ លេខាធិការដ្ឋាន **EITI** កំពុងរង់ចាំពត៌មានបន្ថែមពីប្រទេសចំនួន ៩ ទៀត ។ ប្រទេសចំនួន ៨ បានបោះផ្សាយនូវរបាយការណ៍មួយ ឬ ច្រើន ពីការអនុវត្តគោលការណ៍ **EITI** របស់ខ្លួន គឺប្រទេស អាហ្សែបៃហ្សង់ កាមីរូន ហ្គាបុង ហ្គាណា ហ្គីណេ សាធារណៈរដ្ឋគៀហ្គីស ម៉ូរីតានី និង នីហ្សេរីយ៉ា។

រចនាសម្ព័ន្ធអភិបាលកិច្ចរបស់ **គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** (**EITI**) មាន គណៈកម្មាធិការ EITI លេខាធិការដ្ឋានអន្តរជាតិ EITI សន្និសីទស្តីពី EITI ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និង ប្រទេស-ទីភ្នាក់ងារផ្តល់ជំនួយ ជួយគាំទ្រ ។

- **គណៈកម្មាធិការ** EITI គឺជាអង្គភាព ដែលមានឥទ្ធិពលខ្លាំងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង ក្នុងការផ្តល់នូវគំនិតផ្តួចផ្តើម ។ គណៈកម្មាធិការត្រូវបានដឹកនាំដោយប្រធានមួយរូប ដែលត្រូវបានបោះឆ្នោតជ្រើសរើស ។ ប្រធាននាពេលបច្ចុប្បន្ននេះ គឺសាស្ត្រាចារ្យ **ភីធី អេហ្គែន** (Prof. Peter Eigen) ។

- **លេខាធិការដ្ឋានអន្តរជាតិ** EITI គឺកន្លែងដំបូងនៃការទំនាក់ទំនងសម្រាប់រាល់គ្រប់អង្គការដែលពាក់ព័ន្ធ និង ដែលចាប់អារម្មណ៍លើ EITI ។ ដំណើរការរបស់លេខាធិការដ្ឋានអន្តរជាតិ EITI ត្រូវបានឧបត្ថម្ភ ដោយប្រទេសគាំទ្រ និង សមាជិកជាក់លាក់របស់គណៈកម្មាធិការ EITI។

- **សន្និសីទ** EITI ត្រូវបានរៀបចំធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង ដើម្បីប្រមូលផ្តុំគ្រប់អ្នកពាក់ព័ន្ធនៅក្នុងគំនិតផ្តួចផ្តើម ។ សន្និសីទនេះ ផ្តល់ឱ្យនូវឱកាសដល់គ្រប់អ្នកចូលរួម ដើម្បីផ្លាស់ប្តូរគំនិត ព្រមទាំងបទពិសោធន៍ក្នុងការអនុវត្ត **គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** ដើម្បីសម្រេចបាននូវមតិទូទៅមួយចំនួនលើបញ្ហាចម្បង និង ដើម្បីបោះឆ្នោតជ្រើសរើសសមាជិកថ្មីរបស់គណៈកម្មាធិការ EITI ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ/អ្នកផ្តល់ជំនួយ ជាអាទិ៍ ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារអភិវឌ្ឍន៍អាហ្វ្រិក គឺជាអ្នកសង្កេតការណ៍នៅក្នុងគណៈកម្មាធិការ EITI ។ ក្នុងចំណោមដៃគូអភិវឌ្ឍន៍ ទ្វេភាគី មានចក្រភពអង់គ្លេស អាឡឺម៉ង់ ហូឡង់ និង ន័រវេ ដែលបានគាំទ្រជាពិសេសដល់គំនិតផ្តួចផ្តើម ។

អត្ថប្រយោជន៍នៃការអនុវត្ត **គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** មានដូចខាងក្រោមៈ

- **គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** ផ្តល់ជាសារដ៏ខ្លាំងក្លាឱ្យប្រជាជន ក្រុមហ៊ុន និង សហគមន៍អន្តរជាតិ ដឹងអំពីការប្តេជ្ញាដើម្បីពង្រឹងតម្លាភាពនៅក្នុងវិស័យប្រេង ដើម្បីប្រមូលចំណូលជា អតិបរមាចូលទៅក្នុងថវិកា និង ដើម្បីប្រើប្រាស់ប្រាក់ចំណូលបានល្អប្រសើរ ។ សារនេះបញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តឱ្យមានតម្លាភាព គណនេយ្យភាព និង អភិបាលកិច្ចល្អកាន់តែខ្លាំង ព្រមទាំងលើក កំពស់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង ស្ថិរភាពនយោបាយ ។
- ការចូលរួមក្នុងកម្មវិធី **គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** ចង្អុលបង្ហាញពីការប្តេជ្ញាចិត្ត របស់ក្រុមហ៊ុនឯកជនចំពោះតម្លាភាព ដែលនឹងបង្កើនកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ។ ក្រុមហ៊ុនក៏ទទួល អត្ថប្រយោជន៍ពី EITI តាមរយៈបរិយាកាសវិនិយោគល្អប្រសើរ ពីព្រោះក្រុមហ៊ុនប្រេង និង រ៉ែ អាចដឹង ពីប្រទេសដែលកំពុងអនុវត្ត EITI ថាជាប្រទេសដែលមាន*ហានិភ័យតិច* ហើយដោយសារការយល់ដឹងនេះ ឱ្យលទ្ធផលដល់ក្រុមហ៊ុនទូវការទាមទារ*អត្រាចំណូលពីការវិនិយោគកាន់តែទាប-* មានន័យថា រាជរដ្ឋាភិបាល នឹងទទួលចំណែកធនធាន កាន់តែខ្ពស់ ។
- ការដឹងពីចំនួនពិតប្រាកដពីប្រាក់ចំណូល ដែលរដ្ឋាភិបាលទទួលបាន ធ្វើអោយប្រជាជនមានព័ត៌មានគ្រប់គ្រាន់ ដើម្បីវិនិច្ឆ័យពីរដ្ឋាភិបាលចំពោះការប្រើប្រាស់ប្រាក់ចំណូលរបស់ខ្លួន ក្នុងកម្មវិធីចំណាយសាធារណៈ ។ ទាំងនេះ នឹងធ្វើឱ្យការជជែកពិភាក្សាអំពីការប្រើប្រាស់ប្រាក់ចំណូលបានពីប្រេង ឧស្ម័ន និង រ៉ែ ត្រូវឈរលើមូលដ្ឋាន ពិតមួយ ។ សង្គមស៊ីវិលក៏អាចទទួលអត្ថប្រយោជន៍ផងដែរ ពីទំនាក់ទំនងដែលប្រសើរ និង ឥទ្ធិពលដ៏សមើ្យម ជាមួយក្រុមហ៊ុន និង រដ្ឋាភិបាល ពីឱកាសដែលបានកើនឡើង ដើម្បីកសាង និង ពង្រឹងបណ្តាញជាមួយ អ្នកវិនិយោគ និង អង្គការអន្តរជាតិព្រមទាំងរដ្ឋបាល ដែលល្អប្រសើរ ។

## ករណីសិក្សាៈ ការអនុវត្ត EITI នៅអាហ្វ្រិកខាងត្បូង

គណៈកម្មាធិការជាតិស្តីពី**គំនិតផ្តួចផ្តើមដើម្បីតម្លាភាពឧស្សាហកម្មរុករករ៉ែ** ដែលមានសមាជិកពីររូប ពីខាងរដ្ឋាភិបាល ពីររូបមកពីសង្គមស៊ីវិល និង ពីររូបទៀតមកពីក្រុមហ៊ុនឯកជន ត្រូវប្រជុំគ្នាដើម្បីពិនិត្យជ្រើសរើស ក្រុមហ៊ុនសវនកម្មមួយ ដែលមានភារកិច្ចផ្ទៀងផ្ទាត់ និង ប្រៀបធៀបតួលេខចំណូល- ចំណាយប្រេង ពីរបាយការណ៍ ដែលផ្តល់ដោយរដ្ឋាភិបាល និង ក្រុមហ៊ុនប្រេង ។ ការជ្រើសរើសនេះត្រូវឆ្លងកាត់នូវដំណើរការដេញថ្លៃដ៏ សមស្របមួយ ។ មានលក្ខណៈវិនិច្ឆ័យពីរសម្រាប់ការដេញថ្លៃ គឺវិនិច្ឆ័យលើបច្ចេកទេស និង លើហិរញ្ញវត្ថុ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គណៈកម្មការពិភាក្សា និង អនុម័តលើទម្រង់របាយការណ៍ប្រចាំឆមាស ដើម្បីដាក់អោយភាគីពាក់ព័ន្ធអនុវត្តតាម ។

តួនាទីរបស់ក្រុមហ៊ុនសវនកម្ម គឺ ត្រឹមតែផ្ទៀងផ្ទាត់របាយការណ៍របស់រដ្ឋាភិបាល និង ក្រុមហ៊ុនឯកជនតែប៉ុណ្ណោះ ។ *វាមិនមែនជាការធ្វើសវនកម្មឡើយ ប៉ុន្តែវាជាការធ្វើឱ្យស៊ីគ្នានូវតួលេខក្នុងរបាយការណ៍ និង ត្រូវពន្យល់បញ្ជាក់ប្រសិនបើមានតួលេខខុសគ្នា* ។

ថ្លៃសេវានៃការងារនេះស្មើនឹង មពី ៣០.០០០ ទៅ ៦០.០០០ដុល្លារ អាមេរិក ដោយភាគីរដ្ឋាភិបាលជាអ្នកចេញថ្លៃសេវារៀបចំរបាយការណ៍ប្រចាំឆមាស ហើយភាគីក្រុមហ៊ុនឯកជនជាអ្នកចេញសេវារៀបចំរបាយការណ៍ប្រចាំឆ្នាំ ។

ខាងភាគីរដ្ឋាភិបាល របាយការណ៍ត្រូវបានរៀបចំដោយមូលនិធិប្រេងរដ្ឋ ។ របាយការណ៍របស់ក្រុមហ៊ុនត្រូវបានរៀបចំដោយក្រុមហ៊ុនប្រេងរដ្ឋ និង ក្រុមហ៊ុនប្រេងឯកជន ។ មានភាពខុសគ្នាខ្លះដែលតែងតែកើតមាននៅក្នុងរបាយការណ៍ ភាគច្រើនបណ្តាលមកពីកង្វះខាតនូវការយល់ដឹង ការប្រើប្រាស់វិធាន និង ប្រព័ន្ធគណនេយ្យផ្សេងពីគ្នា (ដូចជាប្រព័ន្ធគណនេយ្យសាច់ប្រាក់ និង ប្រព័ន្ធគណនេយ្យបង្គរ) ។ ក្រុមហ៊ុនសវនកម្មត្រូវចំណាយពេលប្រហែលមួយសប្តាហ៍ដើម្បីផ្ទៀងផ្ទាត់តួលេខ និង ពន្យល់ពីភាពខុសគ្នានៅក្នុងរបាយការណ៍ ។

## ៧.៨ ការគ្រប់គ្រងឱនភាពថវិកា

ការគ្រប់គ្រងឱនភាពថវិកាអាចនាំអោយមានបញ្ហាមួយចំនួន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេស ។ ចំណាយថវិកាមិនដែលមានតុល្យភាពជាមួយប្រាក់ចំណូលថវិការហូតទេ ។ ប្រសិនបើចំណូលថវិកាសម្រេចបានលើសចំណាយថវិកា នោះនឹងមានអតិរេកថវិកា ។ ប្រសិនបើចំណាយថវិកាសម្រេចបានទាបជាងចំណូលថវិកា នោះនឹងមានឱនភាពថវិកា ។

***ឱនភាព = ចំណាយ- ចំណូល (ចំណូលសារពើពន្ធ និង ពុំមែនសារពើពន្ធ)***

**ឱនភាពថវិកាសរុប** ត្រូវឆ្លើយនឹងសំណួរថា÷ តើរដ្ឋាភិបាលត្រូវខ្ចីប្រាក់ចំនួនប៉ុន្មាន ដើម្បីធ្វើហិរញ្ញប្បទានចំណាយថវិកា? ឱនភាពក្នុងឆ្នាំណាមួយ គឺជាចំនួននៃធនធានបន្ថែមដែលរដ្ឋាភិបាលត្រូវខ្ចីក្នុងឆ្នាំនោះ ។

មានទស្សនទានពីរស្តីពី **ឱនភាព: ឱនភាពថវិកាបឋម** ដែលមិនរាប់បញ្ចូលនូវការប្រាក់សុទ្ធ ដែលជាចំណាយថវិកាចរន្ត ។ ទស្សនទាន**ឱនភាពថវិកាបឋម** មានគោលដៅឆ្លើយនឹងសំណួរថា: តើរដ្ឋាភិបាលអាចរកចំណូលអោយបានគ្រប់ ដើម្បីទូទាត់ចំណាយបានឬទេ? ប្រសិនបើ**ឱនភាពថវិកាបឋម**ស្មើនឹងសូន្យ រដ្ឋាភិបាល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាចប្រមូលចំណូលសារពើពន្ធ និង ពុំមែនសារពើពន្ធត្រឹមតែមួយគ្រប់ ដើម្បីទុកសម្រាប់ទូទាត់ចំណាយតែប៉ុណ្ណោះ។ ការសងការប្រាក់សុទ្ធ មិនត្រូវបានគេយកមកគិតគូរ នៅក្នុង **ឱនភាពថវិកាបឋម** ឡើយ ជំពូកចំណាយនេះ មិនមែនជាចំណាយចរន្តនៃថវិកាឆ្នាំនេះឡើយ ពីព្រោះការសងការប្រាក់ គឺជាប្រភេទចំណាយដែលពាក់ព័ន្ធនឹង ចំណាយឆ្នាំមុនៗ ដែលរដ្ឋាភិបាលត្រូវខ្ចី ដើម្បីយកមកធ្វើហិរញ្ញប្បទានឱនភាពថវិកា ។

***ឱនភាពថវិកាបឋម = ចំណាយ- ការប្រាក់សុទ្ធ- ចំណូល ឬ***

***ឱនភាពថវិកាបឋម = ឱនភាពសរុប- ការប្រាក់សុទ្ធ***

ហិរញ្ញប្បទានឱនភាពថវិកាអាចសម្រេចទៅបានតាមមធ្យោបាយមួយក្នុងចំណោមមធ្យោបាយបី ឬ ក៏ជាការអនុវត្តនូវមធ្យោបាយទាំងបីតែម្តង (Premchand, 1983)៖

- **ការខ្ចីពីធនាគារកណ្តាលដោយការបោះផ្សាយប័ណ្ណ ឬ ការផ្តល់បុរេប្រទាន:** ការធ្វើហិរញ្ញប្បទានឱនភាពថវិកា ដោយការបោះផ្សាយរូបិយវត្ថុកាន់តែច្រើន អាចនាំឱ្យការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង យ៉ាងឆាប់រហ័ស និង បណ្តាលអោយមានអតិផរណាខ្ពស់ ព្រមទាំងនឹងបង្កើតអោយមាននូវអស្ថិរភាពសេដ្ឋកិច្ចក្នុងបរិការណ៍នៃប្រទេសដែលប្រើប្រាក់ដុល្លារខ្ពស់ ។

- **ការខ្ចីពីសាធារណជន ឬពីបរទេស ដោយការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ:** ជាញឹកញាប់ រដ្ឋាភិបាលតែងតែធ្វើហិរញ្ញប្បទានឱនភាពថវិកា តាមរយៈការបោះផ្សាយមូលប័ត្ររដ្ឋ ដូចជា សញ្ញាប័ណ្ណរដ្ឋ ឬ ប័ណ្ណរតនាគារ ជាដើម ។ មូលបត្រទាំងនេះត្រូវសងការប្រាក់ ទាំងសម្រាប់រយៈពេលកំណត់ច្បាស់លាស់ ឬ មិនច្បាស់លាស់ ។ ប្រសិនបើការប្រាក់ និង សំណងមូលធនមានទំហំធំពេក នោះប្រទេសនោះអាចនឹងខកខានមិនបានសងបំណុលរបស់ខ្លួន ។ ប្រការនេះអាចបង្កើតជាវិបត្តិសេដ្ឋកិច្ច ជាពិសេសនៅពេលដែលបំណុលក្រៅប្រទេសកើនឡើងយ៉ាងខ្លាំង ។ ជារួម រាជរដ្ឋាភិបាលកម្ពុជាតែងតែធ្វើហិរញ្ញប្បទានឱនភាពថវិកាតាមរយៈកម្ចីសម្បទាន ឬ អំណោយ ។ ទម្រង់នៃការផ្តល់ហិរញ្ញប្បទាននេះ គឺដើម្បីធានានិរន្តរភាពបំណុល និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង ។

- **តាមរយៈយន្តការមេគុណថវិកាតុល្យភាព:** ដោយរក្សានូវឱនភាពថវិកាឱ្យនៅថេរ ហើយដោយការផ្តល់ហិរញ្ញប្បទានដល់កំណើនចំណាយតាមរយៈការប្រមូលពន្ធ ។ កំណើននៃចំណូលពីមេគុណថវិកាតុល្យភាពនឹងផ្តល់នូវកំណើនប្រាក់ចំណូល តាមរយៈសន្ទុះនៃការប្រមូលពន្ធ ដើម្បីយកមកទូទាត់ឱនភាព ។

**កម្ចីគឺជាការសន្យារបស់រដ្ឋាភិបាល ដើម្បីសងប្រាក់នេះវិញនាកាលបរិច្ឆេទខាងមុខ និង បង់ការប្រាក់សម្រាប់រយៈពេលនោះ** ។ នៅពេលរដ្ឋាភិបាលខ្ចីពីសាធារណៈ ដោយការលក់សញ្ញាប័ណ្ណ រដ្ឋាភិបាលសន្យាបង់ការប្រាក់សម្រាប់រយៈពេលនោះទៅអ្នកកាន់សញ្ញាប័ណ្ណ និង សងតម្លៃសញ្ញាប័ណ្ណវិញ ។ រដ្ឋាភិបាលនឹងត្រូវ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រមូលពន្ធបន្ថែមទៀតនៅពេលអនាគត និង ត្រូវខ្ចីម្តងទៀត ។ ដូចនេះ ហិរញ្ញប្បទានចំណាយថវិការដ្ឋតាមរយៈការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ គឺជាការពន្យាពេលប្រមូលពន្ធ ។ ពោលគឺជនជំនាន់ក្រោយ គឺជាអ្នកសងនូវអ្វីដែលជនជំនាន់មុនបានចំណាយ ។ ប្រការនេះក៏មានន័យថា ជនជំនាន់មុន គឺជាអ្នកជំពាក់ប្រាក់ដល់ជនជំនាន់ក្រោយផងដែរ ។ ដូច្នេះ ប្រសិនបើជនជំនាន់មុនបានផ្ទេរប្រាក់ចំណូល ឬ ទ្រព្យសម្បត្តិរបស់គេអោយទៅជនជំនាន់ក្រោយ ឬ ជាពិសេស ទៅកូនចៅរបស់ពួកគេ ដើម្បីទូរទាត់សងបំណុលនេះ នៅពេលនោះ ទើបចំណូលពីពន្ធ និង ចំណូលពីហិរញ្ញប្បទានដោយសញ្ញាប័ណ្ណរដ្ឋ នឹងមានតុល្យភាពឡើងវិញ ។ នេះ គឺជាឧទាហរណ៍នៃ **សមមូល Ricardo** ។

ដោយយោងទៅតាម**សម្មតិកម្មនៃ អព្យាក្រឹតភាពបំណុល (ឬ សមមូល** Ricardo) គឺជាការពន្យាពេលប្រមូលពន្ធ ។ នៅពេលដែលវិស័យឯកជនយល់ច្បាស់ និង ទទួលស្គាល់បញ្ហានេះ ពួកគេនឹងកែតម្រូវឥរិយាបទប្រើប្រាស់ និងសញ្ចយរបស់ខ្លួនឱ្យសមស្រប ។ នោះផលប៉ះពាល់ខាងផ្នែកហិរញ្ញវត្ថុនៃកម្ចី គឺនៅត្រឹមតែចំនួនមួយដែលសមមូលនឹងការប្រមូលពន្ធ ។

**សមមូល** Ricardo កើតឡើងនៅពេលដែលជនជំនាន់មុនស្ម័គ្រចិត្តធ្វើអោយ ផលប៉ះពាល់នៃការផ្ទេរបំណុលដែលធ្វើហិរញ្ញប្បទានដោយសញ្ញាប័ណ្ណ ពីមនុស្សមួយជំនាន់ ទៅជំនាន់មួយទៀត មានភាពអព្យាក្រឹត ។ ការផ្ទេរចំណូល ឬ ទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត ដើម្បីទូរទាត់សងជនជំនាន់ក្រោយ ចំពោះការយកពន្ធនៅពេលអនាគត ដែលពួកគេនឹងត្រូវបង់ ដើម្បីយកទៅសងការប្រាក់ និង ការសងសញ្ញាប័ណ្ណរដ្ឋ ។ ពោលគឺ ប្រសិនបើជនជំនាន់មុនបានបន្សល់ទុកនូវបំណុល សម្រាប់អោយជនជំនាន់ក្រោយសង ជនជំនាន់មុនក៏ត្រូវមានកាតព្វកិច្ចបង្កើតនូវទ្រព្យសម្បត្តិអោយបានគ្រប់គ្រាន់ ដើម្បីផ្ទេរទុកអោយជនជំនាន់ក្រោយផងដែរ ដែលយើងហៅថា **សមមូល Ricardo** ។

ឱនភាពថវិកាខ្ពស់ ដែលធ្វើហិរញ្ញប្បទានដោយកម្ចីពីប្រព័ន្ធធនាគារក្នុងស្រុក រួមចំណែកក្នុងការបង្កើននូវតម្រូវការដ៏ច្រើនលើសលប់ និង ការឡើងថ្លៃក្នុងស្រុក ។ ប្រការនេះនឹងធ្វើឱ្យប៉ះពាល់ដល់វិស័យខាងក្រៅតាមរយៈការធ្លាក់ចុះនៃថ្លៃរូបិយវត្ថុក្នុងស្រុក ។ នៅពេលថ្លៃដើម និង ថ្លៃកើនឡើងដោយប្រៀបធៀបជាមួយនឹងថ្លៃនៅបរទេស ការនាំចេញ និង ការនាំចូលនឹងធ្លាក់ចុះ ហើយជញ្ជីងទូទាត់នឹងកាន់តែយ៉ាប់យឺនឡើងៗ ជាហេតុនាំឱ្យមានការធ្វើហិរញ្ញប្បទានបន្ថែមពីបរទេស ឬ កម្ចីបន្ថែមពីបរទេស ។

ប៉ុន្តែ ក្នុងករណីដែលត្រូវខ្ចីប្រាក់ពីធនាគារកណ្តាលដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកា កម្ចីពីធនាគារកណ្តាលនឹងបង្កើតនូវរូបិយវត្ថុបន្ថែម ដែលជាមូលហេតុនៃការកើនឡើងនៃកម្រិតថ្លៃ ។ ប្រការនេះទាមទារអោយអ្នកកាន់តុល្យភាពរូបិយវត្ថុបង្កើននូវបរិមាណរូបិយវត្ថុតាមថ្លៃទីផ្សារដែលខ្លួនមាន ដើម្បីរក្សាអោយតុល្យភាពពិតនៅដដែល ។ ឧទាហរណ៍ ពីពេលមុនមានប្រាក់ ៤០.០០០ រៀល អាចទិញបានសាំង ១០ លីត្រ តែអីឡូវនេះទាល់តែមាន ៥០.០០០ រៀល ទើបអាចទិញសាំងបាន ១០ លីត្រ ។ បាតុភូតនេះគេហៅថា **ពន្ធអតិផរណា** ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ឱនភាពថវិកា** អាចត្រូវធ្វើហិរញ្ញប្បទានដោយបង្កើនការខ្ចីពីធនាគារពាណិជ្ជ ។ ក៏ប៉ុន្តែ សញ្ច័យឆ្លើយតបដ៏តិចតួចណាស់ ទៅនឹងអត្រាការប្រាក់ ។ មានន័យថា នៅក្នុងរយៈពេលខ្លី ទោះបីជាយើងបង្កើនអត្រាការប្រាក់ក៏ដោយ ក៏មិនអាចបង្កើននូវចំនួនប្រាក់សញ្ច័យស្ម័គ្រចិត្តបានច្រើនដែរ ។ ជាផលវិបាក នៅពេលដែលរដ្ឋធ្វើការកៀងគរឥណទានពីធនាគារពាណិជ្ជ ដោយប្រការណាមួយ ដើម្បីយកមកធ្វើហិរញ្ញប្បទានឱនភាពថវិកា នោះនឹងមិននៅសល់ធនធានច្រើនសម្រាប់អោយផ្នែកឯកជនខ្ចីឡើយ ។ មានន័យថាផ្នែកសាធារណៈកាន់តែរីកប៉ោង ដោយសាររដ្ឋបង្កើនចំណាយរបស់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់ ចំណែកឯផ្នែកឯកជនវិញមិនអាចរកហិរញ្ញប្បទានបាន សម្រាប់យកទៅពង្រីកការវិនិយោគរបស់ខ្លួន ។ សេដ្ឋវិទូហៅបាតុភូតនេះថា **ការច្រានចេញ** (Crowding out) នូវវិនិយោគឯកជន ។

ប្រសិនបើរដ្ឋមានគោលការណ៍ដាក់កម្រិតចំពោះទំហំឱនភាពនៃចំណាយសាធារណ ដែលត្រូវធ្វើហិរញ្ញប្បទានដោយសញ្ច័យក្នុងស្រុក នោះគឺមានតែជម្រើសតែមួយគត់ គឺការប្រើប្រាស់សញ្ច័យពីបរទេស ឬ ការកើនឡើងនៃឱនភាពគណនីចរន្តក្រៅប្រទេសនៃជញ្ជីងទូទាត់ ។ ទំនាក់ទំនងរវាង **ឱនភាពថវិកា** នៃវិស័យសាធារណៈ និង **ឱនភាពគណនីចរន្តក្រៅប្រទេស** មានលក្ខណៈជិតស្និទ្ធនឹងគ្នា ។ ជម្រើសគោលនយោបាយជាពិសេស គោលនយោបាយរូបិយវត្ថុ ដែលអមដោយគោលនយោបាយហិរញ្ញវត្ថុសាធារណៈពង្រីកទូលំទូលាយតាមរយៈ (Expansionary) (មានន័យថា ការបង្កើនចំណាយ ការកាត់បន្ថយពន្ធ និង ការកាត់បន្ថយអត្រាការប្រាក់) តាមរយៈផលប៉ះពាល់របស់វាទៅលើអត្រាការប្រាក់ និង អត្រាប្តូរប្រាក់ គឺជាកត្តាសំខាន់ៗ ដែលជះឥទ្ធិពលទៅលើទំនាក់ទំនងរវាង **ឱនភាពថវិកា** និង **ឱនភាពគណនីចរន្ត** ។ ប្រការនេះក៏អាចកាត់បន្ថយផងដែរនូវឥទ្ធិពលនៃគោលនយោបាយខាងលើ ចំពោះឱនភាពគណនីចរន្តក្រៅប្រទេស ។

ដោយសារតែ **ឱនភាពថវិកា** **ឱនភាពគណនីចរន្តក្រៅប្រទេស** និង **ការគ្រប់គ្រងបំណុលក្រៅប្រទេស** មានទំនាក់ទំនងដ៏ជិតស្និទ្ធនឹងគ្នា នោះការធានានូវនិរន្តរភាពនៃ **ឱនភាពថវិកា** មានសារៈសំខាន់ខ្លាំងណាស់ ។ នៅពេលដែល បំណុលកើនឡើង អត្រាការប្រាក់នឹងកើនឡើង ហើយកំណើននឹងត្រូវធ្លាក់ចុះ ។ ប្រសិនបើមានការដាក់កម្រិតខ្ពស់បំផុតចំពោះបន្ទុកបំណុល ឱនភាព និង បំណុលខ្ពស់ជាងកម្រិតនេះ នឹងត្រូវផ្តល់ហិរញ្ញប្បទានតាមរយៈ **ពន្ធអតិផរណា** ។ ហើយ អត្រាអតិផរណា អាចនឹងកើនឡើងដល់កម្រិតមួយយ៉ាងខ្ពស់ ដែលសាធារណជនមិនអាចទទួលយកបាន ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឯកសារស្រាវជ្រាវ


Alexander, W., Balino, T., and Enoch, C. (1996), "Adopting Indirect Instruments of Monetary Policy," Finance & Development, Washington, March.

Balino, T., Bennett, A. and Borensztein, E. (1999), "Monetary Policy in Dollarized Economies," IMF Occasional Paper, No. 171, (Washington: International Monetary Fund).

Berg, A., and Borensztein, E. (2000a), "The Choice of Exchange Rate Regime and Monetary Target in Highly Dollarized Economies," IMF Working Paper, No. 00/29, (Washington: International Monetary Fund).

___, (2000b), "Full Dollarization: The Pros and Cons," Economic Issues, No. 24, (Washington: International Monetary Fund).

Bogetic, Z. (2000), "Official Dollarization: Current Experiences and Issues," Cato Journal, Vol. 20, No. 2.

Calvo, G.A. and Vegh, C.A. (1992), "Currency Substitution in Developing Countries: An Introduction," IMF Working Paper 92/40, (Washington: International Monetary Fund).

Chandrasekhar, C.P. (2005), "Financial Liberalization and Poverty Reduction", UNDP, Colombo.

Chu, K-Y and Hemming, R. (1991), "Public Expenditure Handbook: A Guide to Public Policy and Issues in Developing Countries", (Washington: International Monetary Fund).

Davis, J.M., Ossowski, R. and Fedelino, A. (2003), "Fiscal Policy Formulation and Implementation in Oil-Producing Countries". (Washington: International Monetary Fund).





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

De Zamaroczy, M. and Sa, S. (2002), "Macroeconomic Adjustment in a Highly Dollarized Economy : The Case of Cambodia" IMF Working Paper 02/92, (Washington: International Monetary Fund).

Fisher, S. (1997), "Capital Account Liberalization and the Role of the IMF", Paper presented at the Seminar *Asia and the IMF*, held in Hong Kong, China, on September 19, 1997. IMF, September 1997.

Fisher, S. (2001), "On the Need for an International Lender of Last Resort", *Journal of Economic Perspectives* **13**, pp. 85-104.

Forster, J., and Wanna, J. (1990), "Budgetary Management and Control". Center for Australian Public Sector Management. Brisbane.

Galligan, B., Nethercote, J.R. and Walsh, C. (1990), "Decision Making in Australian Government: The Cabinet and Budget Process". Center for Research on Federal Financial Relations. The Australian National University, Canberra.

Ghosh, J. (2005), "Trade Liberalization and Poverty Reduction", UNDP, Colombo.

Hang Chuon Naron. (2003), "Cambodia: Medium-Term Expenditure Framework, 2003-2005. Manuscript.

Hillman, A. (2003) "Public Finance and Public Policy: Responsibilities and Limitations of Government", Cambridge University Press.

McKinnon, R. (1996), "Direct and Indirect Concepts of International Currency Substitution," in Paul Mizen and Eric Pentecost, (eds.), The Macroeconomics of International Currencies: Theory, Policy, and Evidence (U.K.: Edward Elgar) pp. 44-59.

Menon, J. (1998), "De-Dollarizing Cambodia," Cambodia Development Review, Vol. 2, Issue 2, (Cambodia Development Resource Institute).



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Ministry of Economy and Finance (2007). Guidelines for the Preparation of a Program Budget. Draft.

Mishkin, F. (2004) "The Economics of Money, Banking and Financial Markets", Pearson, Seventh Edition.

Musgrave, R. and Musgrave, P. (2004) "Public Finance in Theory and Practice", Tata McGraw-Hill, Fifth Edition.

Obstfeld, M. (1998), "The Global Capital Market: Benefactor or Menace?, *Journal of Economic Perspectives* **12,** 9-30.

Ortiz, G. (1983), "Currency Substitution in Mexico; the Dollarization Problem," Journal of Money, Credit, and Banking (U.S.), Vol. 15, pp. 174-185.

Palley, T. (2003), "The Economics of Exchange Rate and the Dollarization Debate: The Case Against Extremes", International Journal of Political Economy, vol. 33, no. 1, Spring 2003, pp. 61-82.

Palanivel, T. (2005), "Trade Liberalization, Macroeconomic Performance and Poverty Reduction. UNDP. Colombo.

Prakash, T., Davies, M., Paoletti, M., and Webber, D. (2001), "Cambodia: Framework for Improving Expenditure Management". Fiscal Affairs Department, (Washington: International Monetary Fund).

Premchand, A. (1983), "Government Budgeting and Expenditure Controls: Theory and Practice", (Washington: International Monetary Fund).

Premchand, A. (1993), "Public Expenditure Management", (Washington: International Monetary Fund).

Rodrik, D. (1998), "Who Needs Capital Account Convertibility?", http://ksghome.harvard.edu/



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Rodrik, D. (2002), "Trade Policy Reform as Institutional Reform", in B.M. Hoekman, P. English, and A. Mattoo, eds., *Development, Trade, and the WTO: A Handbook,* World Bank, Washington, D.C.

Rosen, H. (2005) "Public Finance", McGraw-Hill, Seventh Edition.

Schiavo-Campo, S. and Tommasi, D. (1999), "Managing Government Expenditure", (Manila: Asian Development Bank).

Selassie, A., Clements, B., Tareq, S., Martijn, J. and Bella, G. (2006), "Designing Monetary and Fiscal Policy in Low-Income Countries", IMF Occasional Paper 250, (Washington: International Monetary Fund).

Supreme National Economic Council (2002) «Dollarization in Cambodia », Phnom Penh, Internal Document.

Stiglitz, J. (2000) "The Economics of the Public Sector", W.W. Norton & Company, Third Edition.

The World Bank (1998), "Public Expenditure Management Handbook", Washington.

The World Bank and the Asian Development Bank (2003), "Cambodia: Enhancing Service Delivery through Improved Resource Allocation and Institutional Reform: Integrated Fiduciary Assessment and Public Expenditure Review", Washington.

UNDP (2007), "Overcoming Vulnerability to Rising Oil Prices: Options for Asia and the Pacific", UNDP Regional Centre in Bangkok, Bangkok.

Yossifov, P. (2002), "The Use of Credit Ceilings in the Presence of Indirect Monetary Instruments: An Analytical Framework," IMF Working Paper 02/206, (Washington: International Monetary Fund).



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Zee, H., Castro, P. and Wu, C. (1999), "Cambodia: Reforming Tariff Policy and Customs Administration". Fiscal Affairs Department, (Washington: International Monetary Fund).

| សទ្ទានុក្រម | |
|---|---|
| ពាក្យខ្មែរ | English |
| និកម្មភាព | Unemployment |
| អនិកម្មភាព | Employment |
| អនិកម្មភាពពេញលេញ | Full employment |
| ការរំលស់ | Depreciation |
| កេនសន៍និយម | Keynesian |
| សមតា | Equilibrium |
| គណនីចរន្ត | Current account |
| គណនីមូលធន | Capital account |
| គេហជន | Household |
| ការប្រើប្រាស់ | Consumption |
| ការវិនិយោគ | Investment |
| បុរាណនិយម | Classical |
| សុទ្ធ | Net |
| ផលិតផលសរុបក្នុងស្រុក | Gross Domestic Product |
| តាមថ្លៃទីផ្សារ | Nominal |
| តាមថ្លៃថេរ | Real |
| ផលិតផលសរុបក្នុងស្រុកតាមថ្លៃទីផ្សារ | Nominal GDP |
| ផលិតផលសរុបក្នុងស្រុកពិត | Real GDP |
| ប្រាក់ចំណូល | Income |
| ធាតុចូល | Input |
| ធាតុចេញ | Output |


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| សទ្ទានុក្រម | |
|---|---|
| ពាក្យខ្មែរ | English |
| អតិផរណា | Inflation |
| បរិត្តផរណា | Deflator |
| សញ្ច័យ | Savings |
| ចំណោត | Slope |
| មូលធន | Capital |
| ពលកម្ម | Labor |
| អនុគមន៍ | Function |
| ផលិតភាពនៃមួយឯកតាពលកម្មបន្ថែម | Marginal Productivity of Labor (MPN) |
| ភាពយឺត | Elasticity |
| បន្លាស់ប្តូរ | Change |
| កំណើន | Increase |
| ប្រាក់ចំណេញពីវិនិយោគ | Return to investment |
| សន្និធិ | Stock |
| អនុបាត | Ratio |
| ផលិតភាព | Productivity |
| រូបិយវត្ថុ | Money |
| សមីការពាណិជ្ជកម្ម | Equation of Exchange |
| ប្រតិបត្តិការ | Transaction |
| ល្បឿនបង្វិល | Volocity |
| សន្ទស្សន៍ថ្លៃទំនិញ | Index |
| អថេរ | Variable |

| សទ្ទានុក្រម | |
|---|---|
| **ពាក្យខ្មែរ** | **English** |
| **សំណល់** | Residial |
| **តម្រូវការ** | Demand |
| **ការផ្គត់ផ្គង់** | Supply |
| **ទ្រឹស្តីបរិមាណរូបិយវត្ថុ** | Quantity Theory of Money |
| **វិធីសាស្ត្រ** | Approach |
| **សមតុល្យសាច់ប្រាក់** | Cash balance |
| **សរុប** | Aggregate |
| **ក្ស័យធន** | Bankruptcy |
| **អតិរេក** | Surplus |
| **ឱនភាព** | Deficit |
| **រំកិល** | Shift |
| **ផាត់ទាត់ទីផ្សារ** | Clear the market |
| **ជ្រាលចុះ** | Downward sloping |
| **ចោទឡើងលើ** | Upward sloping |
| **មូលនិធិអាចអោយខ្ចីបាន** | Loanable funds |
| **មូលបត្រដែលមានការប្រាក់** | Interest yielding securities |
| **ថ្លៃឱកាស** | Opportunity cost |
| **អត្រាការប្រាក់** | Interest rate |
| **អត្រាអប្បហារ** | Discount rate |
| **បញ្ច្រាស់** | Inverse |
| **ការប្រែប្រួលដោយឯករាជ្យ** | Exogenous change |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សទ្ទានុក្រម

| ពាក្យខ្មែរ | English |
|---|---|
| កែតម្រូវដោយខ្លួនឯង | Self-adjusting |
| រំពឹងទុក | Expected |
| ការរំពឹងទុក | Expectation |
| ទ្រព្យសកម្ម | Assets |
| ចំណូលតាមថ្លៃទីផ្សារ | Nominal income |
| ភាគលាភ | Dividend |
| តម្រូវការប្រតិបត្តិការ | Transactional demand |
| តម្រូវការប្រុងប្រយ័ត្ន | Precautionary demand |
| តម្រូវការកេងយកចំណេញ | Speculative demand |
| ទ្រឹស្តីចំណូលតាមថ្លៃទីផ្សារ | Theory of nominal income |
| យន្តការបញ្ជូនចែកចាញ | Transmission mechanism |
| ទំនាក់ទំនងហេតុ - ផល | Causalty |
| ឧត្តមភាព | Superiority |
| ឆន្ទានុសិទ្ធិ | Discretionary |
| បដិខួប | Countercyclical |
| ការកំណត់គោលដៅអត្រាប្តូរប្រាក់ | Interest rate targeting |
| ការកំណត់គោលដៅអតិផរណា | Inflation targeting |
| ការកំណត់គោលដៅការផ្គត់ផ្គង់រូបិយវត្ថុ | Money supply targeting |
| អត្រាប្តូរប្រាក់អណ្តែត | Floating exchange rate |
| អត្រាប្តូរប្រាក់នឹងថ្កល់ | Fixed exchange rate |
| អត្រាប្តូរប្រាក់អណ្តែតដោយគ្រប់គ្រង | Managed float |


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| សទ្ទានុក្រម | |
|---|---|
| ពាក្យខ្មែរ | English |
| ទុនបម្រុងអន្តរជាតិ | International reserves |
| ទុនបម្រុងកាតព្វកិច្ច | Reserve requirement |
| ទុនអប្បបរមា | Minimum capital |
| ចំណាត់ថ្នាក់វិនិយោគ | Investment rating |
| គោលនយោបាយបង្រួម | Contractionary policy |
| គោលនយោបាយពង្រីក | Expansionary policy |
| គោលនយោបាយប្រយ័ត្នប្រយែង | Prudent policy |
| រឹតបន្តឹងគោលនយោបាយ | Tighten policy |
| ប្រាក់បញ្ញើ | Deposit |
| អន្តរការីកម្មហិរញ្ញវត្ថុ | Financial intermediation |
| ភាគហ៊ុន | Share |
| សញ្ញាប័ណ្ណ | Bond |
| លិខិតពាណិជ្ជកម្ម | Commercial paper |
| ឥណទាយិកចុងក្រោយ | Lender of the last resort |
| បង្កកឥណទាន | Credit crunch |
| វិបត្តិខ្វះឥណទាន | Liquidity crisis |
| ឥណទេយ្យរដ្ឋាភិបាលសុទ្ធ | Net claims on government |
| ឥណទានផ្នែកឯកជន | Credit to the private sector |
| រូបិយវត្ថុបម្រុង | Reserve money |
| ទ្រព្យសកម្មបរទេសសុទ្ធ | Net foreign assets |
| ការីបរិច្ឆេទ | Maturity |

| សទ្ទានុក្រម | |
|---|---|
| ពាក្យខ្មែរ | English |
| ការអង្កេតរូបិយវត្ថុ | Monetary survey |
| រូបិយវត្ថុក្រៅធនាគារ | Money outside bank |
| ប្រាក់បញ្ញើចរន្ត | Demand deposit |
| ការពង្រីកឥណទាន | Credit expansion |
| តម្រូវការសរុប | Aggregate demand |
| ការផ្គត់ផ្គង់សរុប | Aggregate supply |
| ឧបនិស្ស័យបន្ថែមដើម្បីប្រើប្រាស់ | Marginal prospensity to consume |
| ឧបនិស្ស័យបន្ថែមដើម្បីសញ្ជ័យ | Marginal prospensity to save |
| អថេរប្រែប្រួល | Induced variable |
| ចំណាយស្វយ័ត | Autonomous expenditures |
| អថេរផ្ទៃក្នុង | Endogenous variable |
| អថេរខាងក្រៅ | Exogenous variable |
| មេគុណ | Multiplier |
| ចំណូលក្រោយពេលបង់ពន្ធ | Disposable income |
| ពន្ធកើនឡើង | Progressive tax |
| ពន្ធថយចុះ | Regressive tax |
| អន្ទាក់រូបិយវត្ថុ | Liquidity trap |
| ចំណង់ចំណូលចិត្តរក្សារូបិយវត្ថុងាយស្រួល | Liquidity preference |
| តុល្យភាពរូបិយវត្ថុពិត | Real money balance |
| អញ្ញត្តិគោលនយោបាយ | Policy variable |
| រឹងត្អឹង | Sticky |

| សទ្ទានុក្រម | |
|---|---|
| ពាក្យខ្មែរ | English |
| ការច្រានចេញ | Crowding out |
| បដិដុល្លារូបនីយកម្ម | Dedollarization |
| ដុល្លារូបនីយកម្ម | Dollarization |
| បដិអន្តរការីយកម្មហិរញ្ញវត្ថុ | Financial de-intermediation |
| អន្តរាគមន៍ដោយបោះផ្សាយមូលបត្រ | Sterilized intervention |
| អន្តរាគមន៍ដោយមិនបោះផ្សាយមូលបត្រ | Unsterilized intervention |
| មច្ចុវដ្ត | Vicious cycle |
| វិរូបកម្ម | Distortion |
| អសទ្ធត្តិភាពនាំងបី | Impossible trinity |
| ស្ថាបនិកគោលនយោបាយ | Policy maker |
| បរាជ័យទីផ្សារ | Market failure |
| បទបញ្ញត្តិប្រុងប្រយ័ត្ន | Prudential regulations |
| សេដ្ឋវិទូខាងផ្នែកផ្គត់ផ្គង់ | Supply-side economist |
| ចំណាយបន្ថែម | Marginal cost |
| បណ្តាសារធនធាន | Resource curse |
| ឧបត្តហេតុចំណាយ | Expenditure incidence |
| មេគុណតុល្យភាពថវិកា | Balance budget multiplier |
| ភាពប្រសើរប៉ារេតូ | Pareto optimality |
| ជម្ងឺហូឡង់ | Dutch disease |
| ការកំណត់ដែនកាត់កងចំណាយពន្ធ | Ring-fencing |
| ថ្លៃបន្ទេរ | Transfer pricing |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



# បណ្ឌិត ហង់ ជួន ណារ៉ុន

បណ្ឌិត **ហង់ ជួន ណារ៉ុន** បច្ចុប្បន្នជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ក.ប.ស.) និងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បណ្ឌិត **ហង់ ជួន ណារ៉ុន** បានសិក្សាសេដ្ឋកិច្ចអន្តរជាតិនៅសកលវិទ្យាល័យរដ្ឋគៀវ (Kiev State University) នៅសាធារណៈរដ្ឋអ៊ុយក្រែន និង នៅវិទ្យាស្ថានរដ្ឋទំនាក់ទំនងអន្តរជាតិនៃទីក្រុងម៉ូស្គូ (Moscow State Institute of International Relations) (MGIMO) ពីឆ្នាំ ១៩៨២ ដល់ ឆ្នាំ ១៩៩១ ។ បន្ទាប់ពីបានទទួលសញ្ញាប័ត្រអនុបណ្ឌិត និង បណ្ឌិតផ្នែកសេដ្ឋកិច្ចអន្តរជាតិនៅវិទ្យាស្ថានរដ្ឋទំនាក់ទំនងអន្តរជាតិនៃទីក្រុងម៉ូស្គូ លោកបណ្ឌិតបានធ្វើការក្នុងបេសកកម្មការទូត និងនៅស្ថាប័នស្រាវជ្រាវ ជាអ្នកវិភាគសេដ្ឋកិច្ច និង នយោបាយ ។ លោកបណ្ឌិតធ្លាប់ធ្វើជាទីប្រឹក្សារបស់ធនាគារពិភពលោក ប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ នៅឆ្នាំ ២០០៤ លោកបណ្ឌិតបានចូលរៀនក្នុងកម្មវិធីប្រតិបត្តិនៅសាលា **កេណេឌី** (JF Kennedy School) របស់រដ្ឋាភិបាលនៃសកលវិទ្យាល័យ **ហាវ៉ាដ** (Harvard University) និង នៅឆ្នាំ ២០០៨ បានទៅធ្វើកម្មសិក្សានៅ **សាលារដ្ឋបាលជាតិ** នៅទីក្រុងប៉ារីស ។ នៅឆ្នាំ ២០០៧ លោកបណ្ឌិតបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី **វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី** និង នៅឆ្នាំ ២០០៨ សញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី **វិទ្យាស្ថានធានារ៉ាប់រង** (CII) នៃចក្រភពអង់គ្លេស ។ គាត់ជាសមាជិកនៃវិទ្យាស្ថានធានារ៉ាប់រងចក្រភពអង់គ្លេស (CII) និង ក៏ជាសមាជិកនៃវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (AMII) ផងដែរ ។

បណ្ឌិត **ហង់ ជួន ណារ៉ុន**ធ្លាប់កាន់តំណែងជាច្រើននៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចជា អ្នកសម្របសម្រួលស្រាវជ្រាវនៃក្រុមទីប្រឹក្សាសេដ្ឋកិច្ច និង ជាអនុប្រធាននាយកដ្ឋានទី១ នៃនាយកដ្ឋានថវិកា និងហិរញ្ញកិច្ច ។ បន្ទាប់មកលោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការរង ទទួលបន្ទុកគោលនយោបាយ រួមមានគោលនយោបាយហិរញ្ញវត្ថុ និង ហិរញ្ញវត្ថុសាធារណៈអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគគោលនយោបាយ ក៏ដូចជាទទួលបន្ទុកខាងចរចាជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ។ លោកបណ្ឌិតជាអ្នកនិពន្ធឯកសារគោលនយោបាយរបស់រដ្ឋាភិបាល និង សៀវភៅស្តីពីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

កម្ពុជា ។

បណ្ឌិត **ហង់ ជួន ណារ៉ុន** សមាជិក និងប្រធានក្រុមប្រឹក្សាភិបាលនៃសហគ្រាសរបស់រដ្ឋមួយចំនួន ដូចជា **ក្រុមហ៊ុនជាតិធានារ៉ាប់រងបន្តកម្ពុជា ទូរគមនាគមន៍កម្ពុជា** និង **អគ្គិសនីកម្ពុជា** (EDC) ក៏ដូចជាវិទ្យាស្ថានស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល (NGO) ដូចជា **វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI) **វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍** (CBNRMLI) និង **យុវតារាកម្ពុជា** (Youth Star Cambodia) ។

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

Phone: (855)23 722 664 Fax: (855) 23 427 798

**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

២០៨ អា មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ

Phone: (855)23 726 449 Fax: (855) 23 726 447

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia